វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

Cambodian Institute for
Cooperation and Peace

មូលនិធិ ហេនរិច ប៊ុល

Heinrich Böll
Foundation


# ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា

## សមិទ្ធិផល ការប្រឈមមុខ និងក្តីសង្ឃឹម

# Building Civil Society for Good Governance in Cambodia:

## Achievments, Challenges and Prospects


បណ្ណាល័យ
ក.ជ.អ.ប



Edited by

Dr. Kao Kim Hourn

With the Assistance of Mr. Samraing Kamsan



Published by
Cambodian Institute for Cooperation and Peace
With the Support of
Heinrich Böll Foundation

Phnom Penh, 2001

# មាតិកា


| | | |
|---|---|---|
| | វិវេទនកថា | i |
| | អារម្ភកថា | iv |
| I | សេចក្តីសង្ខេប | ១ |
| II | លទ្ធផលនៃកិច្ចពិភាក្សាតុមូល | ១៧ |
| | ២.១ កិច្ចពិភាក្សាតុមូលលើកទី១ | ១៧ |
| | ២.២ កិច្ចពិភាក្សាតុមូលលើកទី២ | ២៥ |
| | ២.៣ កិច្ចពិភាក្សាតុមូលលើកទី៣ | ៣១ |
| | ២.៤ កិច្ចពិភាក្សាតុមូលលើកទី៤ | ៣៨ |
| | ២.៥ កិច្ចពិភាក្សាតុមូលលើកទី៥ | ៤៦ |
| | ២.៦ កិច្ចពិភាក្សាតុមូលលើកទី៦ | ៥៧ |
| | ២.៧ កិច្ចពិភាក្សាតុមូលលើកទី៧ | ៦៦ |
| | ២.៨ កិច្ចពិភាក្សាតុមូលលើកទី៨ | ៧៥ |
| | ២.៩ កិច្ចពិភាក្សាតុមូលលើកទី៩ | ៨៥ |

២.១០ កិច្ចពិភាក្សាតុមូលលើកទី១០ ៩២

III ការបូកសរុបលទ្ធផលសន្និសីទជាតិ ស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផលការប្រឈមមុខនិងក្តីសង្ឃឹម" ៩៩

IV សេចក្តីសន្និដ្ឋាន ១២០

V សំណើមតិ ១៣៦

VI សុន្ទរកថានៃវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាតុមូល ១៤៩

៦.១ សុន្ទរកថាថ្លែងដោយឯកឧត្តម នៅ ការុី ១៤៩

៦.២ សុន្ទរកថាថ្លែងដោយលោកស្រី ជូ ប៊ុនអេង ១៦៣

៦.៣ សុន្ទរកថាថ្លែងដោយអ្នកស្រី ធីតា យឹះ ១៧០

៦.៤ សុន្ទរកថាថ្លែងដោយលោកស្រី ជា វណ្ណាត ១៨៤

៦.៥ សុន្ទរកថាថ្លែងដោយលោក ស្ទីវិន ប៉ក់ ២០៤

៦.៦ សុន្ទរកថាថ្លែងដោយលោក សុក សំអឿន ២១១

៦.៧ សុន្ទរកថាថ្លែងដោយលោកស្រី ប្រ៊ូក វ៉ាន់ឌី ២៣១

៦.៨ សុន្ទរកថាថ្លែងដោយលោកស្រី គុយ វ៉េត ២៣៧

៦.៩ សុន្ទរកថាថ្លែងដោយលោកស្រី រស់ សុភាព ២៥៦

៦.១០ សុន្ទរកថាថ្លែងដោយលោក ញ៉ែម វណ្ណថន ២៧០

៦.១១ សុន្ទរកថាថ្លែងដោយអ្នកស្រី ម៉ាក់ ឆាវ៉ា ២៩៤

៦.១២ សុន្ទរកថាថ្លែងដោយលោក សេក បរិសុទ្ធ ៣០៧

៦.១៣ សុន្ទរកថាថ្លែងដោយលោកស្រី មាស សុខុម ៣១៩

VII សុន្ទរកថានៃរាត្រីនកិត្តិយស ក្នុងកិច្ចពិភាក្សាសន្និសីទជាតិ ៣២៥

៧.១ សុន្ទរកថាថ្លែងដោយឯកឧត្តម ឱម រ៉ាដ្ឋសាឌី ៣២៥

៧.២ សុន្ទរកថាថ្លែងដោយ នពេត្តម សេរីវុឌ្ឍ ៣៣៣

៧.៣ សុន្ទរកថាថ្លែងដោយលោក ហៀក ព្រីង ៣៤២

៧.៤ សុន្ទរកថាថ្លែងដោយលោកស្រី ហោ ផល្លី ៣៥៨

៧.៥ សុន្ទរកថាថ្លែងដោយបណ្ឌិត ហ៊ាន សាហ៊ិប ៣៦៣

៧.៦ សុន្ទរកថាថ្លែងដោយលោកស្រី ជា មុយត្រី ៣៨០

៧.៧ សុន្ទរកថាថ្លែងដោយលោកស្រី ប្រុក វ៉ាន់នី ៣៨៧

៧.៨ សុន្ទរកថាថ្លែងដោយលោកស្រី ជូ ប៊ុនអេង ៣៩៣

៧.៩ សុន្ទរកថាថ្លែងដោយលោកបណ្ឌិត ហង្ស ពុទ្ធា ៣៩៧

៧.១០ សុន្ទរកថាថ្លែងដោយឯកឧត្តម បណ្ឌិត ឆយ យីហ៊ាន ៤០៤

៧.១១ សុន្ទរកថាថ្លែងដោយលោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី ៤២៨

៧.១២ សុន្ទរកថាថ្លែងដោយលោក ញ៉ែម វណ្ណថន ៤៣៧

៧.១៣ សុន្ទរកថាថ្លែងដោយលោកស្រី ជា ទណ្ណាត ៤៥៤

៧.១៤ សុន្ទរកថាថ្លែងដោយលោក សុក សំអឿន ៤៧០

៧.១៥ សុន្ទរកថាថ្លែងដោយលោក ញ៉ឹក សារិន ៤៧៦

៧.១៦ សុន្ទរកថាថ្លែងដោយលោកស្រីបណ្ឌិត ហៃគី ឡូស្ទាន់ ៤៨០

**VIII កម្មវិធីក្នុងកិច្ចពិភាក្សាតុមូលនីមួយៗ** ៤៨៦

# អំពីវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) គឺជាស្ថាប័នវិភាគី (Think Tank) ស្ថាបនាគោលនយោបាយឈានមុខមួយដែលបានបង្កើតឡើង ក្នុងឆ្នាំ១៩៩៤ ដើម្បីរួមវិភាគទានក្នុងការលើកកំពស់ ការយោគយល់គ្នា ឱ្យកាន់តែប្រសើរឡើងថែមទៀត អំពីបញ្ហាជាតិ បញ្ហាតំបន់ និងអន្តរជាតិ ដែលជះឥទ្ធិពលមកលើប្រទេសកម្ពុជា។

ដើម្បីបំពេញបេសកកម្មនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព បានរៀបចំបង្កើតឱ្យមាន បឋកថា សិក្ខាសាលា វេទិកាសាធារណៈ សន្និសីទអន្តរជាតិ វគ្គបណ្តុះបណ្តាលនិងថ្នាក់សិក្សាអំពីទំនាក់ទំនងអន្តរជាតិ គោលនយោបាយ ការបរទេស សេដ្ឋកិច្ច និងនយោបាយ។ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ក៏ជាវិទ្យាស្ថានសិក្សាស្រាវជ្រាវនិងបោះពុម្ពផ្សាយដ៏សកម្មមួយទៀត នៅលើវិស័យសំខាន់ៗមួយចំនួន ដូចជាសង្គមស៊ីវិលការស្ថាបនាសន្តិភាព ការអភិវឌ្ឍន៍សេដ្ឋកិច្ច នយោបាយការបរទេស សន្តិសុខនិងអាស៊ាន។

**អាសយដ្ឋានប្រៃសណីយ៍**: ប្រអប់សំបុត្រ លេខ១០០៧ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**ទូរស័ព្ទ**: (៨៥៥)_០២៣ ៧២២ ៧៥៩

**ហ្វាក់**: (៨៥៥) ០២៣ ៣៦២ ៥២០

**Email: cicp@camnet.com.kh**
**Home page : http // www.cicp.org.kh**

សូមរក្សាសិទ្ធិគ្រប់បែបយ៉ាង។ គ្មានវគ្គ ឬផ្នែកណាមួយនៃសៀវភៅនេះ នឹងត្រូវអនុញ្ញាតឱ្យយកទៅផលិតជាថ្មីឬ ក៏តាមរូបភាពឬមធ្យោបាយអេឡិចត្រូនិច ឬគ្រឿងយន្តណាមួយរួមទាំងការថតចម្លង ឬជាខ្សែអាត់ឬក៏តាមការរក្សាទុកពត៌មាន ក្នុងទីណាមួយ និងតាមប្រព័ន្ធផ្តល់ពត៌មានណាមួយ ដោយគ្មានការអនុញ្ញាតិ ពីវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពឡើយ៕

បោះពុម្ពផ្សាយនៅព្រះរាជាណាចក្រកម្ពុជា

# ទិវេទនកថា

៚៛

ក្នុងនាមវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព (Cambodia Institute for Cooperation and Peace, CICP) ខ្ញុំសូមសម្តែងនូវសេចក្តីអរគុណដ៏ជ្រាលជ្រៅ ចំពោះមូលនិធិ ហេនរិច បូល (Heinrich Böll Foundation, HBF) ដែលបានឧបត្ថម្ភគាំទ្រ និងផ្តល់មូលនិធិបង្កើតឱ្យមានគម្រោងកម្មវិធី ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា"។ ម្យ៉ាងទៀត ខ្ញុំសូមសម្តែងនូវកតញ្ញូតាដោយផ្ទាល់ចំពោះលោកស្រី ហេម៉ា ដែលបានវិនិយោគនូវគំនិត និងគោលដៅស្រាវជ្រាវ ដើម្បីធ្វើឱ្យសំរេចនូវកិច្ចពិភាក្សាតុមូលទាំង១០លើក ក្នុងឆ្នាំ ២០០០នេះ។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះផងដែរ ដើម្បីថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ ដែលជាគណៈវាគ្មិនកិត្តិយស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកមកចូលរួមធ្វើវិភាគទាន ចំណេះដឹង បទពិសោធន៍និងទស្សនៈល្អៗ ដើម្បីជាគុណប្រយោជន៍ដល់ការពង្រឹង និងផ្សព្វផ្សាយ អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា។

ទន្ទឹមនេះ យើងខ្ញុំក៏ពុំភ្លេចសម្តែង នូវសេចក្តីដឹងគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចូល

រួមបញ្ចេញទស្សនៈយោបល់ និងសមានចិត្តក្នុងន័យស្ថាបនា ទាំងក្នុងកិច្ចពិភាក្សាទាំង១០លើក និងទាំងក្នុងសន្និសីទជាតិ ដែលបានរៀបចំឡើងក្នុងរយៈពេល១ឆ្នាំកន្លងមកនេះ។ ទស្សនៈយោបល់និងសំណើមតិរបស់សមាជិក សមាជិកា នៃកិច្ចពិភាក្សាតុមូលទាំងអស់ ត្រូវបានប្រមូលផ្តុំ និងសរសេរបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំទី១ (ឆ្នាំ ២០០០) ស្តីអំពីអភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជានេះផងដែរ។

ក្នុងនាម នាយកប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ខ្ញុំក៏ពុំភ្លេចថ្លែងនូវអំណរគុណដោយស្មោះចំពោះឯកឧត្តម សមាជិកគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពទាំងអស់ ដែលបានអញ្ជើញចូលរួមនិងដឹកនាំកិច្ចប្រជុំពិភាក្សាតុមូលស្ទើរតែគ្រប់លើកកន្លងមក។

ម្យ៉ាងវិញទៀត ខ្ញុំក៏សូមសរសើរនិងសម្តែងការពេញចិត្តដោយស្មោះចំពោះអស់លោក លោកស្រី ទាំងអស់ ជាពិសេស កញ្ញា នេត ច័ន្ទថា, លោក អ៊ីន តុងអាន, លោក ស៊ីសុវត្តិ ប៊ួងច័ន្ទទោ, លោក អ៊ុក ផល្លី, លោក ហ៊ិន សុធី, លោក អ៊ីន តុងអ៊ុង, លោក ហៀក ព្រើង, លោក សេង សុវីរៈ, លោក នេត ណារ៉ូ, លោក ធុំ ធិច, អ្នកស្រី ប៉ក ផារ៉ាណែត, កញ្ញា ចាន់ ស្រីវឌ្ឍ, កញ្ញា ចាន់ ធី, ដែលជាបុគ្គលិកបំពេញការងារ នៅវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលបានរួមចំណែកខិតខំប្រឹងប្រែងអស់កម្លាំងចិត្ត កម្លាំង

កាយ និងកម្លាំងបញ្ញា ជួយសំរួលការរៀបចំធ្វើកិច្ចពិភាក្សាតុមូលទាំង ១០លើក រួមទាំងសន្និសីទជាតិមួយនៅចុងឆ្នាំ២០០០ នោះផង។

លទ្ធផលនៃកិច្ចពិភាក្សាទាំងអស់ នឹងត្រូវបោះពុម្ពផ្សាយបញ្ចូលគ្នា នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០០០-២០០១ នេះដើម្បីធ្វើឱ្យសំរេច នូវការពង្រឹងភាពជាដៃគូរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលជាបុព្វហេតុនៃការស្ថាបនា និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ក្រោយសម័យសង្គ្រាមដ៏ខ្ទេចខ្ទាំនេះ៕

ភ្នំពេញ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១

# អារម្ភកថា

ក្នុងការពិនិត្យមើលប្រវត្តិដឹកនាំនិងគ្រប់គ្រងនៃប្រទេសជាតិយើង ក្នុងសម័យកាលចុងក្រោយនេះ[1] យើងអាចពិនិត្យឃើញនូវទំនាស់និង ភាពឱនថយ រហូតដល់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃដ៏គ្រោះថ្នាក់និងការបែកបាក់ដ៏ យូរលង់ក្នុងសង្គមជាតិ ដែលបណ្ដាលមកពីកង្វះអភិបាលកិច្ចល្អ និងការ គ្រប់គ្រងមិនស្អាតស្អំ។ ឥទ្ធិពលដ៏គ្រោះថ្នាក់នៃការគ្រប់គ្រងមិនល្អនេះ កើតមានជាបន្តបន្ទាប់នៅក្នុងប្រវត្តិដឹកនាំជាតិយើង។ អ្វីដែលជាឥទ្ធិពល ដ៏គ្រោះថ្នាក់នេះ គឺការខុសឆ្គងនៃរចនាសម្ព័ន្ធថ្នាក់លើ ដែលជាគំរូ អាក្រក់ដល់ថ្នាក់ក្រោម។ អំពើមិនគប្បីនេះបានធ្វើឱ្យបាត់ជំនឿមហាជន ការប្រមាថមាក់ងាយមកលើរបបគ្រប់គ្រង ការរំលោភបំពានទៅលើ កម្មសិទ្ធិ សិទ្ធិសេរីភាព ទ្រព្យសម្បត្តិរបស់បុគ្គល និងជាតិ ដែលបង្ក ឱ្យមានការឈឺចាប់ ជម្លោះ ទំនាស់និងគំនុំ។ គឺចាប់ផ្ដើមពីបាតុភាព មិនល្អទាំងនេះហើយ ដែលនាំឱ្យមានអសន្តិសុខសង្គម អថេរភាព នយោបាយ និងការផ្លាស់ប្ដូររបបគ្រប់គ្រងជាបន្តបន្ទាប់។

ដូច្នេះ ប្រសិនបើគ្មានវិធានការ កែលំអ ភាពឱនថយ ក្នុង ការដឹកនាំ និងគ្រប់គ្រងសង្គម តាមរយៈការលើកស្ទួយការបណ្ដុះអប់រំ និងផ្សព្វផ្សាយអំពីអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងនឹងអំពើកេង

(1) *ក្នុងរយៈពេលបីទសវត្សចុងក្រោយនេះ*

ប្រវញ្ចន៍និងការកែបន្លំ[២] នៅក្នុងរចនាសម្ព័ន្ធសង្គមទេ នោះជាតិយើងពុំអាចពោះជំហានឆ្ពោះទៅរកវឌ្ឍនភាព សេចក្តីសុខសាន្តត្រាណ និងសន្តិភាពតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋយើងបានឡើយ។

នៅក្នុងយុគសម័យថ្មី ប្រទេសជាតិយើងចាំបាច់ត្រូវចូលរួមក្នុងតំបន់និងលើពិភពលោក ដើម្បីស្ថាបនាខឿនសេដ្ឋកិច្ច ជាតិរបស់ខ្លួនឱ្យមានភាពរុងរឿងនិងរឹងមាំស្របតាមនិន្នាការនៃសហសម័យ។ ទន្ទឹមនោះ គោលនយោបាយកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយយុត្តិធម៌សង្គមនិងកំណែទម្រង់រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុ តុលាការ យោធា និងសន្តិសុខ ដែលមានក្នុងកម្មវិធីនយោបាយជាតិនឹងអាចប្រព្រឹត្តទៅបានល្អលុះណាតែជំនះឱ្យបាននូវបញ្ហាធំពីរ គឺការកសាងប្រព័ន្ធសុចរិតធម៌តាមរយៈការលើកស្ទួយអភិបាលកិច្ចល្អ និងការប្រយុទ្ធនឹងការគ្រប់គ្រងឱនថយ។ ទាំងពីរនេះ គឺជាបញ្ហាដែលគប្បីពិចារណា ដើម្បីត្រួសត្រាយមាគ៌ា អភិវឌ្ឍន៍កម្ពុជា ក្រោយសម័យសង្គ្រាមឱ្យមានភាពជាប់លាប់និងរុងរឿងទៅអនាគត។ ការកសាងប្រព័ន្ធសុចរិតធម៌(Intergrity System) សង្គមនិងការលើកស្ទួយអភិបាលកិច្ចល្អនេះ ពុំមែនជាភារកិច្ចទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលតែម្នាក់ឯងទេ តែគឺជារបស់យើងទាំងឡាយ ជាអង្គការសង្គមស៊ីវិល ដែលជាសង្គមរបស់ប្រជាពលរដ្ឋផង។

---

(2) *ការប្រព្រឹត្តិអំពើពុករលួយ តាមរយៈការប្រើអំណាចខុស*

ដោយផ្អែកលើទស្សនៈនេះហើយ បានជាវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដោយមានជំនួយឧបត្ថម្ភពីមូលនិធិ ហេនរិច បូល (HBF) បានរៀបចំបង្កើតឱ្យមានកិច្ចប្រជុំពិភាក្សាតុមូលស្តីអំពី"អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា" ចំនួន១០លើក អស់រយៈពេលពេញមួយឆ្នាំ២០០០ រួមទាំងការបើកសន្និសីទថ្នាក់ជាតិមួយស្តីអំពីប្រធានបទនេះផង។

ជាគោលដៅ បំណងដ៏ពិសិដ្ឋនៃការបង្កើតឱ្យមានកិច្ចប្រជុំពិភាក្សាតុមូល និងសន្និសីទថ្នាក់ជាតិ ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា"នេះ គឺដើម្បីរួមចំណែកលើកស្ទួយការអប់រំផ្សព្វផ្សាយអំពីអភិបាលកិច្ចល្អឱ្យបានជ្រាលជ្រៅ និងទូលំទូលាយនៅក្នុងសង្គមជាតិយើង។ គឺមានតែការលើកកំពស់សារៈនៃអភិបាលកិច្ចល្អនិងការអនុវត្តន៍ជាក់ស្តែងនូវប្រសិទ្ធិភាពនៃការគ្រប់គ្រងល្អប្រកបដោយ ការទទួលខុសត្រូវតម្លាភាព ការដែលអាចទាយទុកជាមុនបាន និងការចូលរួមទេ ដែលអាចជួយទប់ស្កាត់ និងលុបបំបាត់ការប្រព្រឹត្តិខុសឆ្គង នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចសង្គម ការអភិវឌ្ឍន៍និងកំណែទម្រង់ទាំងឡាយរបស់ជាតិយើងបាន។ ភារកិច្ចទទួលខុសត្រូវក្នុងការស្ថាបនាប្រព័ន្ធសុចរិតធម៌ និងការលើកស្ទួយអភិបាលកិច្ចល្អ នេះគឺជាភារៈកិច្ចទទួលខុសត្រូវរបស់យើងទាំងឡាយជាជនជាតិខ្មែរ ពិសេសគឺអង្គការសង្គមស៊ីវិលដែលត្រូវចូលរួមជាមួយរាជរដ្ឋាភិបាល។ បេសកកម្មរបស់សង្គមស៊ីវិល ក៏គឺជាបេសកកម្មគន្លឹះមួយក្នុងការលើកស្ទួយអភិបាលកិច្ចល្អ។ ក៏ប៉ុន្តែ អង្គការ

សង្គមស៊ីវិល ពុំអាចធ្វើឱ្យសំរេចបេសកកម្មនេះទេ ប្រសិនបើគេពុំបាន រៀបចំខ្លួនឱ្យទៅជាស្ថាប័នរបស់ប្រជាពលរដ្ឋ ដែលមានអភិបាលកិច្ចល្អ ខ្លួនឯងមុនអ្នកដទៃ។ ការពង្រឹងនិងពង្រីកអភិបាលកិច្ចល្អនៅក្នុងអង្គការ សង្គមស៊ីវិល គឺជាការជះឥទ្ធិពលល្អដល់ការលើកស្ទួយអភិបាលកិច្ចល្អ នៅក្នុងសង្គមរបស់ប្រជាពលរដ្ឋ ដែលជាគ្រឹះដល់ការពង្រឹងអភិបាលកិច្ច ល្អនៅក្នុងស្ថាប័នរដ្ឋ និងឯកជនផងដែរ។

វត្ថុបំណងដ៏មានជម្រៅមួយទៀត នៃកិច្ចពិភាក្សាតុមូលនិងអង្គ សន្និសីទជាតិ ស្តីអំពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា" នោះគឺ ដើម្បីរកឱ្យឃើញនូវទស្សនៈ និងបទពិសោធន៍ជាចំណេះដឹងល្អៗ តាម រយៈការប្រមូលផ្តុំមតិពិភាក្សា បញ្ញា យល់ដឹងនិងការផ្លាស់ប្តូរទស្សនៈ វិស័យផ្សេងៗ ដើម្បីយកធ្វើជាចំណេះដឹងមូលដ្ឋាន សំរាប់ការលើកស្ទួយ អភិបាលកិច្ចល្អនិងការស្ថាបនាប្រព័ន្ធសុចរិតធម៌នៅក្នុងសង្គមជាតិយើង។

សៀវភៅនេះ គឺជាកម្រងលទ្ធផលនៃកិច្ចពិភាក្សា និងសន្និសីទ ថ្នាក់ជាតិ ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា" របស់វាគ្មិន កិត្តិយសទាំងឡាយ ដែលជាអ្នកដឹកនាំស្ថាប័នរដ្ឋ ប្រធានអង្គការសង្គម ស៊ីវិល គណៈគ្រប់គ្រងរដ្ឋ សមាជិករដ្ឋសភា ព្រឹទ្ធសភា និងសមាជិក សមាជិកាសន្និសីទជាតិ រួមទាំងនិស្សិត បញ្ញវន្ត និងអ្នកសិក្សាស្រាវ ជ្រាវសំខាន់ៗពីគ្រប់ស្ថាប័ននៃរាជរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងសមាគមយុវជន ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈ មតិយោបល់ ជម្រុះ និងចក្ខុវិស័យល្អៗជាគន្លឹះដល់ការអប់រំផ្សព្វផ្សាយ និងលើកស្ទួយ

អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍ ការដឹកនាំ និងគ្រប់គ្រងល្អនៅកម្ពុជាឱ្យមានអភិបាលកិច្ចល្អ ក្នុងពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត។

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព សូមធ្វើការការបោះពុម្ពផ្សាយនូវលទ្ធផលនៃកិច្ចប្រជុំតុមូលនិងសន្និសីទជាតិ ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា"នេះ ដើម្បីបានជាមូលដ្ឋាន ដល់ការលើកស្ទួយអភិបាលកិច្ចល្អ ការស្ថាបនាប្រព័ន្ធសុចរិតធម៌ និងការអភិវឌ្ឍន៍សង្គមស៊ីវិលនៅក្នុងសង្គមជាតិយើង។ ទស្សនៈ ចំណេះដឹង និង បទពិសោធន៍ល្អៗ ដែលប្រមូលផ្តុំបានតាមរយៈកិច្ចពិភាក្សាតុមូលទាំង១០លើក និងអង្គសន្និសីទជាតិជាចុងក្រោយនេះ នោះគឺជាគំនិតស្ថាបនាកម្ពុជា ក្នុងសហស្សវត្សរ៍ថ្មី ក្រោមការដឹកនាំនិងគ្រប់គ្រងមួយប្រកបដោយអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍។

ទស្សនៈ និងគំនិតយោបល់ទាំងឡាយ នៅក្នុងសៀវភៅនេះគឺជាទស្សនៈយោបល់របស់កិច្ចពិភាក្សាតុមូលនិងអង្គសន្និសីទជាតិ ស្តីអំពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា" ពុំមែនជារបស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាពទេ។ ការបោះផ្សាយនូវទស្សនៈ និងចំណេះដឹងទាំងនេះ គឺជាគុណប្រយោជន៍ដល់ការលើកកំពស់ ការដឹកនាំ និងគ្រប់គ្រងឱ្យបានប្រកបដោយអភិបាលកិច្ចល្អ និងសុចរិតធម៌ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិយើង

ប្រឆាំងនឹងការគ្រប់គ្រងឱនថយ និងភាពឱនាភិវឌ្ឍន៍ក្នុងសម័យក្រោយសង្គ្រាមនេះ។

វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព សូមស្វាគមន៍នូវមតិកែលំអទាំងឡាយ ដែលមានបំណងស្ថាបនា ដើម្បីប្រែក្លាយស្នាដៃនេះ ឱ្យទៅជាសមិទ្ធិផលថ្មីដ៏ល្អៀនល្អៀនមួយ ដើម្បីការអភិវឌ្ឍន៍ និងភាពរុងរឿងនៃប្រទេសជាតិយើង ក្នុងពេលបច្ចុប្បន្ននិងទៅអនាគត៕

*ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១*

**បណ្ឌិត កៅ គឹមហួន**

នាយកប្រតិបត្តិ

វិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការ និងសន្តិភាព

# កិច្ចពិភាក្សាតុមូល ស្តីអំពី
# "សង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ"

## សេចក្តីសង្ខេប :

ខាងក្រោមនេះ គឺជារបាយការណ៍ដ៏សង្ខេបមួយតែមានអត្ថន័យល្អិតល្អន់ ស្តីពី កិច្ចប្រជុំតុមូល "សង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ" ដែលបានរៀបចំឡើង ដោយវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ក្រោមការឧបត្ថម្ភនៃមូលនិធិ ហេនរិច បូល (HBF) ដោយផ្អែកទៅលើការប្រមូលផ្តុំមតិយោបល់ និងទស្សនៈពិភាក្សារបស់អ្នកដឹកនាំអង្គការសង្គមស៊ីវិល និងមន្ត្រីក្នុងស្ថាប័នរដ្ឋ ដែលអញ្ជើញមកពីស្ថាប័នសាធារណៈសំខាន់ៗនៃប្រទេសកម្ពុជា។

បំណងជាសក្តានុពលនៃកិច្ចពិភាក្សាតុមូល_ឆ្នាំ២០០០ ស្តីអំពី "សង្គមស៊ីវិលកម្ពុជា និងអភិបាលកិច្ចល្អ" គឺដើម្បីពិនិត្យមើលទស្សនៈចំរុះ[១] ក្នុងបរិបទនៃតួនាទីរបស់សង្គមស៊ីវិលកម្ពុជា ការលើកស្ទួយអភិបាលកិច្ចល្អ ជាគុណប្រយោជន៍ដល់ការស្ថាបនា និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ក្រោយសង្គ្រាមនិងភាពខ្ទេចខ្ទាំនេះ។ ទិសដៅ

(១) មតិយោបល់និងទស្សនៈដែលប្រមូលផ្តុំបាន ពុំមែនសុទ្ធតែត្រឹមត្រូវនិងល្អឥតខ្ចោះនោះទេ ។ ក៏ប៉ុន្តែទោះជាដូចម្តេចក្តី លទ្ធផលនៃកិច្ចពិភាក្សាតុមូលនោះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញនូវសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជា ដើម្បីរួមចំណែកកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិខ្លួនស្របតាមលទ្ធិប្រជាធិបតេយ្យ និងនិន្នាការនៃសហសម័យ។

នៃការពិភាក្សាក្នុងកិច្ចប្រជុំតុមូលនេះ ក៏គឺដើម្បីរកឱ្យឃើញនូវការយល់ដឹងរួមមួយក្នុងចំណោមអ្នកដឹកនាំអង្គការសង្គមស៊ីវិលទាំងឡាយ និងអ្នកដឹកនាំក្នុងស្ថាប័នរដ្ឋ និងផ្នែកឯកជនផង អំពីតួនាទីនិងភារកិច្ចរបស់គេក្នុងការជម្រុញឱ្យមានគោលការណ៍ដឹកនាំនិងគ្រប់គ្រងល្អ សំដៅអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ និងលើកស្ទួយយុត្តិធម៌សង្គម។ ការយល់ដឹងច្បាស់អំពីអភិបាលកិច្ចល្អ និងគុណប្រយោជន៍របស់វានឹងជួយឱ្យយើងមានកម្លាំងគាំទ្រកាន់តែច្រើនឡើងថែមទៀត ដើម្បីការកសាងនិងអភិវឌ្ឍប្រទេសជាតិយើង។ ប្រសិនបើគ្មានអភិបាលកិច្ចល្អទេ នោះការស្តារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍន៍ជនបទ ការប្រមូលពន្ធដារ និងចរិការដ្ឋនឹងជួបតែវិបត្តិ។

ម្យ៉ាងវិញទៀត កិច្ចប្រជុំពិភាក្សាតុមូលនេះ មិនគ្រាន់តែជួយពង្រឹងការដឹកនាំនិងគ្រប់គ្រងនៅក្នុងអង្គការសង្គមស៊ីវិលឱ្យមានអភិបាលកិច្ចល្អប៉ុណ្ណោះទេ តែគឺដើម្បីឱ្យអង្គការសង្គមស៊ីវិលក្លាយទៅជាកំលាំងចលករមួយសំរាប់លើកស្ទួយ និងជម្រុញឱ្យមានគំរូភាពកាន់តែច្រើនថែមទៀត ក្នុងការអនុវត្តន៍គោលការណ៍ នៃមគ្គទ្ទេសភាពសង្គមជាតិយើងឱ្យប្រកបដោយភាពស្អាតស្អំបរិសុទ្ធ ឬប្រកបដោយអភិបាលកិច្ចល្អនេះឯង។

អភិបាលកិច្ចល្អ មានសារៈសំខាន់ណាស់សំរាប់ការកាត់បន្ថយការប្រព្រឹត្តិអំពើពុករលួយនិងប្រព័ន្ធរដ្ឋបាលស្មុគស្មាញ (Red Tapes) នៅក្នុងការដឹកនាំនិងគ្រប់គ្រង។ ដោយមានសមាសធាតុនៃគណនេយ្យ

ភាព តម្លាភាព ភាពដែលអាចទាន់ប្រមាណបាន (Predictability) និងការចូលរួម (Participation) អភិបាលកិច្ចល្អមានលក្ខណៈវិនិច្ឆ័យងាយយល់ និងងាយទទួលស្គាល់ដោយការចូលរួមពីសំណាក់ប្រជាពលរដ្ឋអង្គការសង្គមស៊ីវិល ផ្នែកឯកជន និរន្តរភាព ភាពស្របច្បាប់ ការបង្កើនភាពត្រឹមត្រូវនិងសមភាព សមត្ថភាពក្នុងការអភិវឌ្ឍន៍ធនធានវិធីសាស្ត្រ ក្នុងការគ្រប់គ្រងតុល្យភាពរវាងភេទនិងភេទ ការប្រតិបត្តិដោយអំណាចនៃច្បាប់ការបង្កើន និងទទួលបានសេចក្ដីគោរព ការដែលអាចកំណត់ និងការទទួលយកបាននូវសេចក្ដីគោរពជំនឿនិងទំនុកចិត្តលក្ខណៈជួយជម្រុញនិងជួយសម្រួលកិច្ចការព្រមទាំងការដោះស្រាយបញ្ហាតាមពេលវេលានិងការតម្រង់ទិសឆ្ពោះទៅរក "សេវាសាធារណៈ" ល្អប្រសើរផង។

កិច្ចពិភាក្សាតុមូលស្ដីអំពី "សង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ" គឺជាប្រភេទនៃការប្រជុំពិភាក្សាផ្លាស់ប្ដូរទស្សនៈមតិយោបល់ ដែលត្រូវបានរៀបចំឡើង សំរាប់រយៈពេលមួយខែម្ដង_១០លើក ក្នុងមួយឆ្នាំគិតរួមទាំងការបើកសន្និសីទថ្នាក់ជាតិមួយ នៅខែមករា ឆ្នាំ២០០១ផង។ ដោយមានទីតាំងជាអចិន្ត្រៃយ៍សំរាប់រៀបចំកិច្ចពិភាក្សា នៅសាលប្រជុំនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព វិមានរាជរដ្ឋាភិបាលវត្តភ្នំ អ្នកចូលរួមភាគច្រើន ច្រើនតែជាអ្នកដឹកនាំនិងអ្នកតំណាងនៃអង្គការសង្គមស៊ីវិលធំៗនៅរាជធានីភ្នំពេញ(ខ្លះមកពីបណ្ដាខេត្ត) អ្នកតំណាងសមាគមវិជ្ជាជីវៈ សហជីពកម្មករ ផ្នែកឯកជន មន្ត្រីរាជការ

និស្សិត បញ្ញវន្ត និងអ្នកតំណាងកងកម្លាំងប្រដាប់អាវុធផង។ កម្មវិធីនៃកិច្ចពិភាក្សាតុមូលនេះ ត្រូវបានធ្វើឡើង ចាប់តាំងពីម៉ោង៨ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ ដោយមានធ្វើរបាយការណ៍ និងការបូកសរុបលទ្ធផលនៃអង្គពិភាក្សានីមួយៗជាបន្តបន្ទាប់គ្នា។ ដើម្បីឱ្យការពិភាក្សាមានមូលដ្ឋានច្បាស់លាស់ និងប្រមូលផ្តុំបាននូវទស្សនៈនិងបទពិសោធន៍ វិទ្យាស្ថានបានអញ្ជើញឱ្យមានការចូលរួមមានមតិ ជាបឋមពីគណៈវាគ្មិនកិត្តិយសពីររូប ជារៀងរាល់កិច្ចពិភាក្សាក្នុងខែនីមួយៗ។ គណៈវាគ្មិនកិត្តិយសទាំងនោះសុទ្ធសឹងជាវរជន ដែលអញ្ជើញមកពីស្ថាប័នរដ្ឋ អ្នកដឹកនាំអង្គការសង្គមស៊ីវិលធំៗ ប្រធានសមាគមវិជ្ជាជីវៈនិងគណៈដឹកនាំនៃកងខេមរភូមិន្ទ។ ជារៀងរាល់លើកប្រធានបទនៃការពិភាក្សាត្រូវបានកំណត់យកដោយនាយកកម្មវិធីនេះ និងទាក់ទងទៅនឹងខ្លឹមសារ តួនាទីអង្គការសង្គមស៊ីវិល ទំនាក់ទំនងរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាល ជុំវិញការអភិវឌ្ឍន៍អភិបាលកិច្ចល្អនៅកម្ពុជា។ កិច្ចពិភាក្សាតុមូលទាំង១០លើក និងសន្និសីទថ្នាក់ជាតិ ស្តីអំពី *"សង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ"* ត្រូវបានដឹកនាំការពិភាក្សា ទូទៅនិងការបូកសរុបដកពិសោធន៍ ដោយសមាជិកនៃក្រុមប្រឹក្សា (គណៈកម្មាធិការនាយក) នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។

ជាលទ្ធផល កិច្ចប្រជុំពិភាក្សាតុមូលនីមួយៗសុទ្ធតែមានការបូកសរុបយកទស្សនៈល្អៗ និងចំណេះដឹងដោយឡែកៗ សំរាប់ជាគុណប្រយោជន៍ដល់វឌ្ឍនភាព និងការផ្សព្វផ្សាយអភិបាលកិច្ចល្អនៅកម្ពុជា។

លទ្ធផលទាំងនេះ ត្រូវបានធ្វើឡើងជាទម្រង់របាយការណ៍ខ្លីៗ តែមានអត្ថន័យស៊ីជម្រៅ សំរាប់ចែកផ្សាយដល់សមាជិក នៃកិច្ចពិភាក្សាតុមូលទាំងអស់ ដែលបានអញ្ជើញចូលរួមដើម្បីពិចារណាបន្ថែម មុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

ជារួម លទ្ធផលនៃកិច្ចប្រជុំតុមូលទាំងនេះ ពិតជាបានជាគុណប្រយោជន៍ ដល់ការស្តាបនាមត្តុទ្ទេសភាពកម្ពុជា ក្នុងសហសម័យឱ្យប្រកបដោយទសពិធធម៌[១] និងវឌ្ឍនធម៌។ គឺការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ នេះហើយដែលអាចជួយអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យរួចផុតពីភាពក្រីក្រ និងអយុត្តិធម៌សង្គម។

ជាទូទៅ គេសង្កេតឃើញថា សព្វថ្ងៃនេះអភិបាលកិច្ចល្អកំពុងក្លាយជាគោលការណ៍ដែលកំពុងពេញនិយម នៅលើគ្រប់វិស័យនៃការដឹកនាំរដ្ឋ។ ភាពស្អាតស្អំបរិសុទ្ធក្នុងការដឹកនាំនិងគ្រប់គ្រងនេះ កំពុងត្រូវប្រជាពលរដ្ឋខ្មែរទទួលស្គាល់ និងប្រយុទ្ធតស៊ូទាមទារដើម្បីជួយរុញច្រានន្ធូវជីវភាពទុរ្គតរបស់គេឱ្យរួចផុតពីភាពក្រីក្រ និងមានសមធម៌ក្នុងការរស់នៅប្រចាំថ្ងៃ។ ប្រជាពលរដ្ឋកម្ពុជាគ្រប់ខេត្ត ខ័ណ្ឌ សុទ្ធតែបានជ្រួតជ្រាបថា អភិបាលកិច្ចល្អឬការគ្រប់គ្រងប្រកបដោយភាពបរិសុទ្ធ គឺជាតម្រូវការមិនអាចខ្វះបាន ដើម្បីរំដោះប្រទេសកម្ពុជា ឱ្យរួចផុតពីការជិះជាន់កៀបសង្កត់និងកេងប្រវ័ញ្ចន៍។

---

[១] ធម៌ទាំង១០យ៉ាងសំរាប់ព្រះរាជា

ជាផលវិបាកកន្លងមក ប្រទេសកម្ពុជា (ក្នុងសម័យសង្គ្រាម) តែងរួមរឹត ដោយការកៀបសង្កត់ និងការចម្រាញ់យកផលប្រយោជន៍។ ឥទ្ធិពលនៃសង្គ្រាមបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរខ្លាចរអា និងត្រៀមជានិច្ច ដើម្បីមិនឱ្យមានការខ្វះខាត និងភាពក្រីក្រ។ ម្ល៉ោះហើយមុខរបរអ្វីក៏ដោយចរិកាអ្វីក៏ដោយសំភារៈអ្វីក៏ដោយឱ្យតែស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ខ្លួន គេអាចឆ្លៀតយកបានទាំងអស់។ អាស្រ័យដោយភាពល្វឹងជូរចត់នៃសង្គ្រាម សេចក្តីអៀនខ្មាស ចំពោះអំពើអាក្រក់ និងភាពខ្លាចរអាចំពោះច្បាប់ បានត្រូវថមថយកម្លាំងហើយគំនិតស្វែងរកប្រយោជន៍បុគ្គល ដោយមិនគិតពីភាពខុសច្បាប់និងការកឹបកេងប្រវ័ញ្ចន៍ ត្រូវបានមកជំនួសវិញ។ ដូច្នោះហើយ ធាតុភាពនៃការគិតពីប្រយោជន៍បុគ្គលធំជាងផលប្រយោជន៍ជាតិនេះ បានក្លាយទៅជាទម្លាប់របស់ខ្មែរស្ទើរតែគ្រប់រូបទៅហើយ។ ដោយផ្តើមចេញពីទស្សនៈទុទ្ទិដ្ឋិនិយមនេះ ការទទួលខុសត្រូវ និងការគ្រប់គ្រងជាទូទៅ តែងជួបនឹងវិបត្តិ។ ដូច្នេះបទពិសោធន៍នៃការគ្រប់គ្រងឱនថយ (គ្មានអភិបាលកិច្ចល្អ) គឺជាហេតុផលចម្បងមួយដែលធ្វើឱ្យសង្គមជាតិស្ថិតនៅក្នុងភាពឱនថយនិងទុរភិក្ស។ ក៏ប៉ុន្តែ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាកំពុងស្វែងរកការដឹកនាំនិងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ ដើម្បីអភិវឌ្ឍន៍សង្គមគ្រួសារគេឱ្យមានសេដ្ឋកិច្ចជឿនលឿន រួចផុតពីភាពទុរភិក្សអត់ឃ្លាននិងអយុត្តិធម៌សង្គម។ ការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ ពុំអាចធ្វើបានក្នុងរយៈពេលមួយថ្ងៃ ពីរថ្ងៃឬមួយខែ ពីរខែ ឬ មួយឆ្នាំ ពីរឆ្នាំនោះ

ឡើយ។ ជាការពិតណាស់ ការអភិវឌ្ឍន៍អភិបាលកិច្ចល្អទាមទារឱ្យប្រើពេលវេលាយូរអង្វែង និងធនធានមនុស្សល្អផង។

ចំពោះហេតុការណ៍នេះ រាជរដ្ឋាភិបាលត្រូវមានឆន្ទៈនយោបាយខ្ពស់និងប្រាកដប្រជា ដើម្បីផ្ដល់ការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់មួយកំរិតខ្ពស់ទៀត ដល់ការអភិវឌ្ឍន៍អភិបាលកិច្ចល្អ ច្បាស់លាស់ល្អគ្មានអរិភាព (disputes)។ ក៏ប៉ុន្តែ កិច្ចការទាំងអស់នេះក៏វាអាស្រ័យទៅលើអង្គការសង្គមរបស់ប្រជាពលរដ្ឋ(សង្គមស៊ីវិល) សមាជិករដ្ឋសភា និងព្រឹទ្ធសភា ដែលបានជាប់ឆ្នោតដែលត្រូវធានាថា ការលើកស្ទួយអភិបាលកិច្ចល្អ ត្រូវតែធ្វើឡើងឱ្យបានជាប្រក្រតី និងត្រូវមាននិរន្តរភាពតទៅនៅកម្ពុជា។

ម្យ៉ាងវិញទៀត ការលើកស្ទួយមគ្គុទ្ទេសភាព និងការគ្រប់គ្រងឱ្យប្រកបដោយអភិបាលកិច្ចល្អនេះ ពុំអាចកាត់ផ្ដាច់បានពីការអប់រំនិងផ្សព្វផ្សាយទេ។ ពីឥឡូវនេះ ទៅរហូតដល់អនាគត ការអប់រំនិងផ្សព្វផ្សាយអំពី អភិបាលកិច្ចល្អ នៅតែមានសារៈសំខាន់ពុំអាចកាត់ថ្លៃបាន។ សារៈសំខាន់នៃអភិបាលកិច្ចល្អ គឺវាស្ថិតនៅត្រង់ការជួយស្រោចស្រង់មគ្គុទ្ទេសភាព និងការគ្រប់គ្រងឱ្យរួចផុតពី ការត្រួតត្រាផ្ដាច់ការគ្រួសារនិយម និងអំពើពុករលួយ។ ក៏ប៉ុន្តែ ការងារនេះគេពុំគួរតក់ក្រហល់ អស់សង្ឃឹម ឬបោះបង់ចោលការតស៊ូនៅពាក់កណ្ដាលទីទេ គេគួរតែធ្វើដោយសន្សឹមៗ មួយជំហានម្ដងៗ ដោយមានផែនការច្បាស់លាស់ ព្រោះការប្រែក្លាយ ទម្លាប់ឱនថយមួយឱ្យទៅជា

ទម្លាប់ល្អឡើងវិញ ពុំមែនអាចធ្វើបានក្នុង រយៈពេលមួយពព្រិចភ្នែកឡើយ។

មតិរបស់សមាជិកនៃអង្គការពិភាក្សាភាគច្រើន បានឯកភាពថា ប្រជាពលរដ្ឋកម្ពុជា ត្រូវការនិងចង់បានភាពស្អាតស្អំ និងបរិសុទ្ធមួយ ក្នុងការដឹកនាំនិងគ្រប់គ្រងប្រទេសជាតិខ្លួន។ ភាពស្អាតស្អំក្នុងការដឹកនាំ ឬអភិបាលកិច្ចល្អនេះ គួរតែមានមូលដ្ឋានមកពីការស្ម័គ្រចិត្ត និងស្មារតីភ្ញាក់រលឹក និងចេញពីក្រអៅបេះដូងរបស់មគ្គុទ្ទេសក៏ និងអ្នកគ្រប់គ្រងគ្រប់រូប។

ដើម្បីឱ្យគោលការណ៍នៃការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ កាន់តែមានប្រសិទ្ធិភាព ទាំងរាជរដ្ឋាភិបាល ទាំងអង្គការសង្គមស៊ីវិលនិងប្រជាពលរដ្ឋ គួរតែធ្វើការរួមគ្នា ក្នុងភាពជាដៃគូប្រកបដោយអត្ថន័យស្ថាបនាដ៏ពិតប្រាកដមួយ។ ប្រសិនបើគ្មានសហប្រតិបត្តិការជិតស្និទ្ធរវាងអ្នកទាំងពីរទេ (រដ្ឋាភិបាល និងសង្គមស៊ីវិល) នោះអភិបាលកិច្ចល្អពុំអាចកើតមាន និងវិវត្តស្ថិតស្ថេរនៅកម្ពុជាបានទេ។ ក៏ប៉ុន្តែ អ្វីដែលជាកត្តាជម្រុញដ៏ខ្លាំងក្លាមួយនោះគឺគំនាបរបស់សហគមន៍អន្តរជាតិ។

ដើម្បីបុព្វហេតុនៃការរស់រាននិងវឌ្ឍនភាពនៃអភិបាលកិច្ចល្អនៅកម្ពុជា គឺជាការសំខាន់ណាស់ ដែលជនបង្គោល ដែលមានតួនាទីដឹកនាំគ្រប់គ្រងនិងទទួលខុសត្រូវគិតគូរអំពីយុទ្ធសាស្ត្រនៃការពង្រឹងអភិបាលកិច្ចល្អ នៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ ឱ្យបានច្រើនជាងយុទ្ធវិធី

ព្រោះថា ការពុំគិតគូរអំពីយុទ្ធសាស្ត្រនៃការលើកស្ទួយអភិបាលកិច្ចល្អឱ្យបានច្រើន និងជាប់ជាប្រចាំនឹងនាំឱ្យយើងខ្វះភាពរឹងមាំក្នុងការទប់ស្កាត់អភិបាលកិច្ចឱនថយ។ ទន្ទឹមនោះ ការគិតគូរអំពីឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់គាត់ គួរតែត្រូវបានលើកតម្កើងឱ្យខ្ពង់ខ្ពស់ថែមទៀត។ ផលប្រយោជន៍និងសំណូមពរដ៏ទទូចរបស់ប្រជាពលរដ្ឋ គួរតែបានស្ថិតក្នុងកម្មវត្ថុនៃកម្មវិធីធ្វើការងាររបស់អ្នកដឹកនាំនិងអ្នកគ្រប់គ្រងគ្រប់ជាន់ថ្នាក់។

ជាការពិតណាស់ ប្រជាពលរដ្ឋកម្ពុជាតែងប្រាថ្នាចង់បានសង្គមជាតិខ្លួនមួយ ដែលមានភាពសុខដុមរមនា គ្មានមនុស្សកេងប្រវ័ញ្ចមនុស្ស និងគ្មានអំពើពុករលួយនិងភាពល្មើសច្បាប់។ បំណងប្រាថ្នានេះមានលក្ខណៈឧត្តុង្គឧត្តមណាស់ ក៏ប៉ុន្តែ ការធ្វើឱ្យសំរេចបំណងនេះ ពុំមែនជារឿងងាយស្រួលឡើយ។ ប្រសិនបើ ចិត្តគំនិតរបស់ជនជាតិយើង ក្នុងសម័យនេះ និងទម្លាប់ឱនថយរបស់គេ ពុំត្រូវបាន ផ្លាស់ប្តូរទេ គេពុំគួរសង្ឃឹមថា នឹងអាចសំរេចបាននូវបំណងនោះឡើយ។ គឺជាភ័ព្វសំណាងដ៏ល្អមួយហើយដែលប្រទេសកម្ពុជា បានឆ្លងផុតនូវសង្គ្រាមមិនាសកម្មរ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងមកនេះ ហើយការដែលប្រទេសកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស និងការប្រែក្លាយពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារនោះ គឺជាកាលានុវត្តភាព ដ៏វិសេសវិសាលមួយ ដែលអាចជួយឱ្យកម្ពុជាទទួលយកបាន នូវគោល

នយោបាយល្អ (Good Policy) និងបន្ទាប់មកគឺអភិបាលកិច្ចល្អ ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ។

ហេតុផលដែលមានសារៈបំផុត ក្នុងការលើកស្ទួយអភិបាលកិច្ចល្អ និងតួនាទីរបស់សង្គមស៊ីវិលនៅកម្ពុជា នោះគឺការអប់រំនិងការហ្វឹកហ្វឺនធនធានមនុស្ស។ ការអប់រំអំពីចិត្តគំនិតល្អបរិសុទ្ធ និងការបណ្តុះបណ្តាលអំពីមនសិការជាតិ គួរតែក្លាយជាអាទិភាពចំបងមួយទៀតបន្ថែម ទៅលើការលើកស្ទួយគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងការប្រយុទ្ធនឹងភាពមិនស្អាតស្អំ ក្នុងការដឹកនាំសង្គមជាតិ។ ដើម្បីភាពជាប់លាប់នៃវឌ្ឍនភាពសង្គមតាមរយៈការលើកស្ទួយអភិបាលកិច្ចល្អ និងតួនាទីរបស់សង្គមស៊ីវិលនេះ គ្មានអ្វីក្រៅពីការវិនិយោគខាងធនធានមនុស្សស្អាតស្អំ ភាពសច្ចៈយុត្តិធម៌ និងភាពជឿនលឿនទេ។

ការលុបបំបាត់ឱ្យអស់នូវភាពឱនថយនិងភាពអសកម្មទាំងឡាយ ដែលមាននៅក្នុងផ្នត់គំនិតមនុស្ស ខ្មែរក្រោយសម័យសង្គ្រាមនេះទាំងនៅក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មក៏ដូចជាក្នុងផ្នែករដ្ឋបាលសាធារណៈ ទាមទារឱ្យមានពេលវេលា ឆន្ទៈនយោបាយនិងការប្តេជ្ញាចិត្តខ្ពស់របស់ថ្នាក់ដឹកនាំស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋកម្ពុជា និងការឧបត្ថម្ភពីសហគមន៍អន្តរជាតិផង។

ម្យ៉ាងវិញទៀត ដំណើរការនៃការអភិវឌ្ឍន៍អភិបាលកិច្ចល្អ និងអង្គការសង្គមស៊ីវិលនៅកម្ពុជា ចាំបាច់ត្រូវតែប្រព្រឹត្តទៅជាប្រក្រតីដោយផ្អែកទៅលើបរិយ្ឋាននយោបាយបើកចំហ ការពង្រឹងប្រសិទ្ធិភាពនៃការ

គោរពច្បាប់ ការស្ថាបនាធនធានមនុស្ស និងការលុបបំបាត់ការប្រព្រឹត្តិផ្តេសផ្តាសនៅក្នុងរដ្ឋបាលសាធារណៈ ទាំងនៅក្នុងអង្គការសង្គមស៊ីវិល ទាំងនៅក្នុងផ្នែកឯកជន។

ពាក់ព័ន្ធទៅនឹងតួនាទីរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជាក្នុងការលើកស្ទួយអភិបាលកិច្ចល្អ អង្គពិភាក្សាបានរកឃើញជាសំខាន់បន្ថែមទៅលើតួនាទីជាច្រើនទៀត នោះគឺការអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីសញ្ញាណ និងគុណប្រយោជន៍នៃអភិបាលកិច្ចល្អ នៅក្នុងបរិបទនៃសង្គមស៊ីវិល ដែលមានសារៈសំខាន់បំផុតដល់ប្រទេសជាតិមួយដែលមានអំពើពុករលួយនិងការតែបន្លំ។

កិច្ចពិភាក្សាតុមូលបានរកឃើញថា ហេតុផលដ៏សំខាន់មួយក្នុងចំណោមហេតុផលទាំងឡាយ ដែលនាំឱ្យមានការបាត់បង់ជំនឿ ជម្លោះបែកបាក់ និងសង្គ្រាមវិនាសកម្មកន្លងមកក្នុងសង្គមខ្មែរ គឺបណ្តាលមកពីអភិបាលកិច្ចមិនល្អ។ បទពិសោធន៍អាក្រក់នេះ កំពុងជះឥទ្ធិពលដល់បច្ចុប្បន្ន។ ដូច្នេះ ការអប់រំ ហ្វឹកហ្វឺនអំពីចំណេះដឹងនៃអភិបាលកិច្ចល្អដល់មន្ត្រីរាជការខ្មែរគ្រប់ជាន់ថ្នាក់ មុននឹងចូលធ្វើការងារនិងកំពុងបំរើការងារ គឺជាតម្រូវការមិនអាចខ្វះបាន ដើម្បីប្រឆាំងតបនឹងអភិបាលកិច្ចឱនថយ។ អំពើពុករលួយ ភាពទុច្ចរិត និងអយុត្តិធម៌ ក្នុងការគ្រប់គ្រងគឺជាសត្រូវស្លាប់រស់របស់អភិបាលកិច្ចល្អ។ បើគ្មានការកាត់ទោសជនពុករលួយ ការស្ថាបនានីតិរដ្ឋ និងការអភិវឌ្ឍន៍គុណធម៌និងសីលធម៌ខាងផ្លូវចិត្តគំនិតទេ អភិបាលកិច្ចល្អពុំអាចកើតមានឡើយ។

ម្យ៉ាងវិញទៀត ដើម្បីឱ្យសហប្រតិបត្តិការ និងភាពជាដៃគូរវាង សង្គមស៊ីវិល និងរដ្ឋាភិបាល មានដំណើរការល្អក្នុងការកសាងអភិបាលកិច្ចល្អនៅកម្ពុជា អង្គពិភាក្សាតុមូលបានរកឃើញថា អ្នកទាំងពីរត្រូវខិតខំពង្រឹងនូវមត្តុទ្ទេសភាពរបស់ខ្លួន ឱ្យមានលក្ខណៈសម្បត្តិល្អបីយ៉ាងគឺ ១_ត្រូវមានអភិបាលកិច្ចល្អ ២_ត្រូវមានសុចរិតធម៌ និងសេចក្តីយោគយល់ និង៣_ត្រូវចៀសវាងកុំធ្វើកិច្ចការណាមួយ ដែលផ្ទុយពីភារកិច្ច និងហួសព្រំដែននៃតួនាទីរបស់ខ្លួន។ ចំពោះអង្គការសង្គមស៊ីវិល គួរតែប្រកាន់នូវជំហរ ឯករាជ្យ អព្យាក្រឹត មិនធ្វើនយោបាយ ត្រូវចេះលើកស្ទួយនូវវប្បធម៌ពិគ្រោះយោបល់ ធ្វើការងារតាមយន្តការរបស់ខ្លួននិងគួរតែធ្វើការរិះគន់កែលំអគ្នាតាមរយៈអនុសាសន៍ ប្រសើរជាងការរិះគន់ដោយចំហ ខុសពីគោលការណ៍នៃសាមគ្គីភាព។ ទាំងរដ្ឋាភិបាល ទាំងអង្គការស៊ីវិល គួរតែមានគោលដៅរួម ការចេះបែងចែកផលប្រយោជន៍ និងសេចក្តីយោគយល់។ បើគ្មានសេចក្តីស្មោះត្រង់ គ្មានវប្បធម៌នៃសេចក្តីអត់ឱន តម្លាភាពនិងគណនេយ្យភាពក្នុងការដឹកនាំទេ ភាពជាដៃគូល្អរវាងអ្នកទាំងពីរពុំអាចមានអត្ថិភាពរឹងមាំបានទេ។ ទន្ទឹមនោះការមានធនធានមនុស្សប្រកបដោយភាពជឿនលឿន ដែលមានសមត្ថភាពយល់ដឹងមានបច្ចេកវិជ្ជាខ្ពស់ មានមនសិការវិជ្ជាជីវៈនិងការទទួលខុសត្រូវខ្ពស់ គឺជាកត្តាដែលជម្រុញឱ្យភាពជាដៃគូរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលកាន់តែមានប្រសិទ្ធិភាពល្អ និងស្ថិតស្ថេរយូរអង្វែង។

ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា គួរតែប្រមូលផ្តុំជាសំខាន់ទៅលើការអភិវឌ្ឍន៍គុណធម៌ ផ្លូវចិត្តនិងសុចរិតធម៌ផង។បន្ថែមទៅលើមុខវិជ្ជាអភិបាលកិច្ចល្អ គេគួរតែត្រូវបានបណ្តុះបណ្តាលអំពីការគ្រប់គ្រងល្អ(Good Management) និងរដ្ឋបាលល្អ (Good Administration)។

ការលើកស្ទួយអភិបាលកិច្ចល្អនៅកម្ពុជា ពុំអាចចៀសផុតពីឥទ្ធិពល នៃសកលភាវូបនីយកម្មទេ។ សកលភាវូបនីយកម្មនៅកម្ពុជាបាននាំមកទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ប្រទេសកម្ពុជា ពុំអាចនៅឯកោ ក្រៅប្រព័ន្ធសាកលភាវូបនីយកម្មបានឡើយ។ ប្រទេសកម្ពុជាអាចនឹងមានវឌ្ឍនភាព ដូចបណ្តាប្រទេសដទៃទៀត នៅក្នុងតំបន់ក៏ដូចជានៅលើពិភពលោក លុះណាតែប្រទេសជាតិនេះ បង្កើតបានច្បាប់ថ្មីៗ សំរាប់កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគទុនត្រឹមត្រូវ ព្រមទាំងការគ្រប់គ្រងមធ្យ័តរឹងមាំ (Stronger Governance) ក្នុងការទប់ស្កាត់ភាពអវិជ្ជមាន នៃសកលភាវូបនីយកម្មនេះ។ ប្រសិន បើគ្មានវិធានការមធ្យ័តទាំងនេះទេ នោះប្រទេសកម្ពុជាដែលជាប្រទេសតូចតាច ទុរភិក្សដែលទើបនឹងងើបពីសង្គ្រាមនេះគង់នឹងគេចមិនផុតពីភាពរងគ្រោះ។

អំពីការការពារសិទ្ធិសុខមនុស្ស អង្គការសង្គមស៊ីវិលកម្ពុជាមានតួនាទីសំខាន់ណាស់ ក្នុងការជួយទប់ស្កាត់ការរំលោភសិទ្ធិសុខមនុស្សតាមរយៈការជួយបណ្តុះបណ្តាល និងអប់រំអំពីសិទ្ធិមនុស្សសំរាប់ប្រជា

ពលរដ្ឋខ្មែរគ្រប់រូបក្នុងសង្គម ជាពិសេសគឺអាជ្ញាធរមូលដ្ឋាន កងកម្លាំងយោធានិងសន្តិសុខ និងអ្នកដែលមានសមត្ថកិច្ចទទួលខុសត្រូវ ក្នុងការដឹកនាំនិងគ្រប់គ្រងសង្គម។

ការជួយពង្រឹងធម្មាធិបតេយ្យ (ការគោរពច្បាប់ជាធំ) ការទប់ស្កាត់កំណើននៃនិទណ្ឌភាព(Impunity) និងការកាប់សម្លាប់ជីវិតមនុស្សក្រៅច្បាប់ ក៏ដូចជាការវិនិច្ឆ័យទោស ជនរំលោភសិទ្ធិមនុស្សគឺសុទ្ធសឹងជាវិធានការដ៏ប្រសើរ ដល់ការលើកស្ទួយការការពារសន្តិសុខមនុស្ស និងអភិបាលកិច្ចល្អនៅកម្ពុជា ដែលទាំងអស់នេះគឺជាតួនាទីមិនអាចខ្វះបាននៃអង្គការសង្គមស៊ីវិលកម្ពុជាគ្រប់ជាន់ថ្នាក់ផងដែរ។

ការជួយលើកស្ទួយវឌ្ឍនភាពនៃ "យែនឌ័រ_Gender" ក៏ជាតួនាទីដ៏សំខាន់មួយទៀត នៃអង្គការសង្គមស៊ីវិលដើម្បីបុព្វហេតុ នៃអភិបាលកិច្ចល្អនៅកម្ពុជា។ សមភាពរវាងបុរសនិងស្ត្រីក្នុងសង្គម គឺជាថាមពលដ៏ខ្លាំងក្លាមួយសំរាប់ការអភិវឌ្ឍន៍។ ក៏ប៉ុន្តែ សមភាពនេះពុំអាចកាត់ផ្តាច់បានពីការអប់រំទេ។ ទន្ទឹមនោះ ការផ្សព្វផ្សាយ និងឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលនិងការឧបត្ថម្ភគាំទ្ររបស់បុរសភេទគឺជាកត្តាស្លាប់រស់មួយនៃការអភិវឌ្ឍន៍ "យ៉េនឌ័រ_Gender" នៅកម្ពុជា។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ជាងនោះ គឺកត្តារបស់ស្ត្រីខ្លួនឯង ដែលត្រូវខិតខំរំដោះខ្លួនដោយខ្លួនឯង ឱ្យរួចផុតពីភាពល្ងង់ខ្លៅនិងភាពអសកម្ម ក៏ដូចជាប្រពៃណីឱនថយទាំងឡាយ។

សមត្ថភាព និងគុណភាពដឹកនាំប្រកបដោយភាពស្អាតស្អំ និងការគិតពីផលប្រយោជន៍រួមជាធំ គ្មានបក្សពួក គ្មានអំពើពុករលួយនិងការកេងប្រវ័ញ្ច នៅក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា គឺជាលក្ខណៈសម្បត្តិដែលពុំអាចខ្វះបាន ដើម្បីឱ្យសង្គមស៊ីវិលលើកស្ទួយអភិបាលកិច្ចល្អមិនគ្រាន់តែនៅក្នុងអង្គការសង្គមស៊ីវិលខ្លួនឯងប៉ុណ្ណោះ តែដើម្បីធ្វើជាគំរូល្អដល់សង្គមជាតិទាំងមូលផង។

ម្យ៉ាងវិញទៀត អភិវឌ្ឍនភាព (Development) ដើម្បីរក្សាការពារនិរន្តរភាព នៃអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ តាមរយៈការប្រមូលផ្តុំធនធានទាំងឡាយដែលមានជាអាទិ៍ ធនធានមនុស្ស ធនធានសម្ភារៈបច្ចេកទេសជំនាញ និងសមត្ថភាពដឹកនាំផង ក៏គឺជាបច្ច័យដ៏ល្អមួយដល់ការលើកស្ទួយអភិបាលកិច្ចល្អនៅកម្ពុជា។ និរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា ពុំអាចកើតមានបាននៅលើភាពល្ងង់ខ្លៅទេ គឺកើតមាននៅលើចំណេះដឹង សមត្ថភាពចាត់ចែងការងារនិងសេចក្តីស្មោះត្រង់។

សរុបសេចក្តីមក កិច្ចពិភាក្សាតុមូលទាំង១០លើក ក្នុងឆ្នាំ ២០០០ ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា" បានរកឃើញ និងប្រមូលផ្តុំបាននូវទស្សនៈល្អៗ ក៏ដូចជាចំណេះដឹង និងបទពិសោធន៍ជាច្រើន ដែលមានសារសំខាន់ដល់ការកសាងសង្គមស៊ីវិលនៅកម្ពុជា ឱ្យមានវឌ្ឍនភាពប្រកបដោយអភិបាលកិច្ចល្អ។ កិច្ចពិភាក្សាតុមូលពេញមួយឆ្នាំនេះ បានត្រួសត្រាយផ្លូវ ជាច្រើនជំហានថ្មីទៅមុខ

ទៀត ដោយបានផ្តល់ឱ្យសង្គមស៊ីវិល "នាំងចំណេះដឹងនាំងចំណេះធ្វើ" ល្អមនឹងស្ថាបនាសង្គមស៊ីវិល ឱ្យមានអភិបាលកិច្ចរឹងមាំហើយ។ ក៏ប៉ុន្តែ ចំណេះដឹងទាំងនោះនឹងអាចប្រើប្រាស់មានប្រសិទ្ធិភាពបាន លុះណាតែ សង្គមស៊ីវិលខ្លួនឯង ខិតខំជំនះឱ្យបានចំណុចខ្សោយរបស់ខ្លួនដោយខ្លួនឯង។ គឺ "កត្តាខ្លួនឯង" នេះហើយដែលជា "កត្តាខ្លាំង_កត្តាឈ្នះ"និង ដែលអាចនាំមក នូវវឌ្ឍនភាពប្រកបដោយអភិបាលកិច្ចល្អ នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា។

ការស្គាល់ខ្លួនឯងច្បាស់ និងការស្គាល់តួនាទីរបស់ខ្លួន ចំពោះខ្លួនឯង និងសង្គមជាតិ ព្រមទាំងការស្គាល់ចំណុចខ្សោយរបស់ខ្លួននិង ការជំនះចំណុចខ្សោយនោះ ដោយខ្លួនឯង..គឺជាលក្ខណៈសម្បត្តិមិនអាចខ្វះបាន ដើម្បីអភិវឌ្ឍអភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា។

សូមអង្គការសង្គមស៊ីវិលនាំងឡាយ ក្រោកឈរឲ្យស្រុះគ្នាឡើង ដើម្បីលើកស្ទួយវឌ្ឍនភាពនៃសង្គមស៊ីវិលនិងអភិបាលកិច្ចល្អនៅកម្ពុជា!

## II. លទ្ធផលនៃកិច្ចពិភាក្សាតុមូល ស្តីអំពី អភិបាលកិច្ចល្អ និង សង្គមស៊ីវិលកម្ពុជា

### ២.១ កិច្ចពិភាក្សាតុមូលលើកទី១

- ប្រធានបទនៃការពិភាក្សា ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា"។
- គណៈវាគ្មិនកិត្តិយស : (១). **ឯកឧត្តម នៅ កាសុី** នាយកប្រតិបត្តិ វិទ្យាស្ថានកម្ពុជា ដើម្បីសិទ្ធិមនុស្ស និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (CIHR) និង (២). **លោក Jeffry Kaplan** អតីតទីប្រឹក្សា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអ្នកសិក្សាស្រាវជ្រាវស្តីពី "អភិបាលកិច្ចល្អ" ជាមួយអង្គការCDRI។

#### ខ្លឹមសារសង្ខេប

**I- មតិនិងទស្សនៈរបស់គណៈវាគ្មិនកិត្តិយស :**

១. <u>ឯកឧត្តម នៅ កាសុី នាយកប្រតិបត្តិ វិទ្យាស្ថានកម្ពុជា ដើម្បីសិទ្ធិមនុស្ស និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត</u> :

- ការផ្សព្វផ្សាយ ដែលទាក់ទិនទៅនឹងអភិបាលកិច្ចល្អ ក្នុងបរិបទសង្គមស៊ីវិលមានសារៈសំខាន់ណាស់ ចំពោះសង្គមជាតិមួយដែលមានអំពើពុករលួយ។

- សង្គមខ្មែរកំពុងជួបប្រទះ វប្បធម៌ហឹង្សា វប្បធម៌និទណ្ឌភាព និង អំពើពុករលួយ ការយកអំណាចទៅប្រើខុស សកម្មភាពខុសរបស់មន្ត្រីរាជការសាធារណៈ រចនាសម្ព័ន្ធរដ្ឋាភិបាល ពុំមានប្រសិទ្ធិភាព កង្វះឯកទេស និងធនធានមនុស្ស។ ចរន្តដំណើរការឥតឈប់ឈរ វិលទៅវិលមកមិនដឹងផ្តើមពីណា រដ្ឋាភិបាលគ្មានប្រាក់ចំណូល ⇒ មន្ត្រីរាជការប្រាក់ខែតិចមិនសប្បាយចិត្តធ្វើការ ⇒ ប្រជាពលរដ្ឋគ្មានសេវាគ្រប់គ្រាន់ មិនសប្បាយចិត្ត មិនបង់ពន្ធ ជូនរដ្ឋ ⇒ រតនាគារអត់លុយ⇒ មន្ត្រីរាជការប្រាក់ខែតិច បើកយឺតយ៉ាវ មិនសប្បាយចិត្ត អត់ធ្វើការ⇒ រដ្ឋាភិបាលគ្មានប្រាក់ចំណូល⇒ រដ្ឋក្រ ⇒ ប្រជាពលរដ្ឋក្រ..........។

- **សញ្ញាណអភិបាលកិច្ចល្អមាន ៦យ៉ាងគឺ :**

  ១- ផ្តល់សេវាសាធារណៈ

  ២- ឱ្យសាធារណៈជនចូលរួម

  ៣- ផ្តល់ឱកាសឱ្យសាធារណជនជូនមតិ

  ៤- ធ្វើឱ្យគេឯងដឹងឮពីតម្លាភាព

  ៥- ធ្វើអ្វីត្រូវទទួលខុសត្រូវ និង

  ៦- គ្រប់គ្រងល្អឬមានបទពិសោធន៍ខាងការចាត់ចែងល្អ។

- **លក្ខណៈវិនិច្ឆ័យនៃអភិបាយកិច្ចល្អ ១៩ ចំនុច :**

១. ការរួមចំណែករបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងផ្នែកឯកជន
២. និរន្តរភាពនៃគោលនយោបាយ និងវិធានការ
៣. ភាពស្របច្បាប់ ប្រជាពលរដ្ឋអាចទទួលយកបាន
៤. តម្លាភាព
៥. សមភាពត្រឹមត្រូវក្នុងការចាត់ចែងការងារ
៦. សមត្ថភាពអនុវត្តន៍ ក្នុងការលើកស្ទួយធនធានមនុស្ស និងការគ្រប់គ្រង
៧. សមភាព និងតុល្យភាពរវាងបុរស និងស្ត្រី
៨. ការអត់ឱន និងការទទួលយកបដិមតិ
៩. សមត្ថភាពប្រមូលកម្លាំង និងធនធានដើម្បីបុព្វហេតុសង្គម
១០. ការយកចិត្តទុកដាក់ចំពោះជនជាតិភាគតិច
១១. អ្វីៗទាំងឡាយត្រូវធ្វើទៅតាមអំណាចច្បាប់
១២. មានសមត្ថភាពប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព
១៣. បង្កើន និងទទួលបានការគោរព និងជំនឿទុកចិត្ត
១៤. មានការទទួលខុសត្រូវ
១៥. អំណាត់អត់ធន់
១៦. មានលក្ខណៈជួយជម្រុញ និងសម្របសម្រួលការងារ
១៧. ធ្វើឱ្យការងារមានប្រក្រតីភាពជាងការត្រួតត្រា

១៨. ដោះស្រាយបញ្ហាទាន់ពេល

១៩. អ្វីៗទាំងអស់ដើម្បីសាធារណជន។

- **សង្គមស៊ីវិលអាចជួយកសាងអភិបាលកិច្ចល្អបាន តាមមុខសញ្ញា ៦ យ៉ាង៖**

**១. ជាដៃគូរបស់រដ្ឋាភិបាល**

**២. ជាស្ពានចម្លងពីក្រុមជំទាស់ទៅរដ្ឋាភិបាល**

**៣. ជាអ្នកទទូចទាមទារឱ្យមានការផ្លាស់ប្តូរនិងការរីកចំរើន**

**៤. ជាអ្នកជួយសង្គមជាតិឱ្យបរិសុទ្ធពិតប្រាកដកុំឱ្យទៅជាឈ្នាន់នយោបាយ**

**៥. ជាអ្នកកណ្តាល**

**៦. ជាអ្នករួមចំណែក។**

**២. <u>លោក Jeffry Kaplan អតីតទីប្រឹក្សា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u> :**

- កាលណានិយាយពីអភិបាលកិច្ចល្អ គេត្រូវផ្តោតទៅលើបញ្ហាសំខាន់បួនគឺ ៖

**១. តម្លាភាព**

**២. ការទទួលខុសត្រូវ**

**៣. ការដែលអាចទាយទុកជាមុនបាន និង**

៤_ ការចូលរួម។

- សំណូមពរ បី ដើម្បីពង្រឹងភាពជាដៃគូជាមួយរដ្ឋាភិបាល :

  ១_ សុំឱ្យរដ្ឋាភិបាលស្នើងយល់គំនិតយោបល់និងបទពិសោធន៍ជំនាញរបស់អង្គការសង្គមស៊ីវិល។

  ២_ ស្នើសុំឱ្យរដ្ឋាភិបាលបើកចំហ ក្នុងការតាក់តែងច្បាប់។

  ៣_ ស្នើសុំឱ្យរដ្ឋាភិបាលទទួលយកសង្គមស៊ីវិលជាដៃគូ ក្នុងការពង្រឹងអភិបាលកិច្ចល្អ។

II- លទ្ធផលនៃការពិភាក្សារួម :

១_ ការបណ្តុះបណ្តាលសមត្ថភាពយល់ដឹង អំពីអភិបាលកិច្ចល្អក្នុងអង្គការសង្គមស៊ីវិល គឺជាការបណ្តុះបណ្តាល បេះដូងអ្នកដឹកនាំសង្គមស៊ីវិលឱ្យមានអភិបាលកិច្ចល្អ។

២_ អភិបាលកិច្ចល្អនឹងរីកចំរើនបានលុះត្រាតែមាន៖(១)_ស្ថាប័នជាតិគ្រប់គ្រាន់ និងត្រឹមត្រូវ. (២)_មានច្បាប់គ្រប់គ្រាន់ (៣)_មានការអនុវត្តន៍ច្បាប់ត្រឹមត្រូវ និង(៤)_អ្វីៗទាំងអស់ត្រូវតែធ្វើទៅតាមច្បាប់។

៣_ សង្គមស៊ីវិលកម្ពុជា មានភារកិច្ចសំខាន់ពីរគឺ ៖ បណ្តុះបណ្តាលអភិបាលកិច្ចល្អនិងអភិវឌ្ឍន៍អភិបាលកិច្ចល្អ ក្នុងចិត្តគំនិតរបស់ខ្លួន។

៤. សំពាធបរិស្ថានដឹកនាំនិងការគ្រប់គ្រងឱនថយ គឺជាហេតុដែលនាំឱ្យមានអភិបាលកិច្ចមិនល្អ។ រាល់ការអនុគ្រោះនិងការយោគយល់ច្រើនហួស ជាហេតុនាំឱ្យមានការគ្រប់គ្រងឱនថយ។ កង្វះការត្រួតពិនិត្យ និងអសមត្ថភាព ក្នុងការគ្រប់គ្រងក៏ដូចជាកង្វះ គុណធម៌ដឹកនាំ គឺសុទ្ធសឹងជាហេតុផលមួយទៀត ដែលនាំឱ្យគ្មាន អភិបាលកិច្ចល្អ។

៥. ការហ្វឹកហ្វឺនអំពីអភិបាលកិច្ចល្អជូនមហាជន និងប្រជាពលរដ្ឋ ក៏ដូចជា មន្ត្រីរាជការមិនអាចទទួលបានលទ្ធផលល្អទេប្រសិនបើអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋគ្រប់ជាន់ថ្នាក់មិនបានទទួលការសិក្សារៀនសូត្រទេ។

៦. ការបាត់បង់ជំនឿ ជម្លោះបែកបាក់និងសង្គ្រាម វិនាសកម្មកន្លងមកក្នុងសង្គមខ្មែរ គឺបណ្ដាលមកពីអភិបាលកិច្ចមិនល្អ។ បទពិសោធន៍ ដ៏អាក្រក់នេះ គឺជាមេរៀនដល់បច្ចុប្បន្ន។ ដូច្នេះ ការអប់រំបណ្ដុះបណ្ដាល អំពីចំណេះដឹងនៃអភិបាលកិច្ចល្អដល់មន្ត្រីរាជការខ្មែរ គ្រប់ជាន់ថ្នាក់មុននឹងចូលបំរើការងារគឺជាតម្រូវការមិនអាចខ្វះបាន ក្នុងការប្រឆាំងតបនឹងអភិបាលឱនថយ។

៧. អំពើពុករលួយ ភាពទុច្ចរិតនិងអយុត្តិធម៌ ក្នុងការគ្រប់គ្រងគឺជាសត្រូវស្លាប់រស់របស់អភិបាលកិច្ចល្អ បើគ្មានការកាត់ទោសជនពុករលួយ ការស្លាបនាទីតិរដ្ឋ និងការអភិវឌ្ឍន៍

គុណធម៌ សីលធម៌ខាងផ្លូវចិត្តគំនិតទេ កុំសង្ឃឹមថាមានអភិបាលកិច្ចល្អ។

៨_ អំពើពុករលួយ គឺជាផលិតផលនៃការរំលោភអំណាច និងសិទ្ធិទទួលខុសត្រូវ (ការប្រើអំណាចខុស) ទុច្ចរិតនិយមនិងញាតិបក្សនិយម (Nepotism) ការគោរពបុគ្គលជាងការគោរពច្បាប់និងអត្តទត្តភាព (ការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន)។

## III_ អំពីសំណូមពរនិងអនុសាសន៍ :

១_ ស្នើសុំបង្កើតយន្តការ ពុំមែនរាជរដ្ឋាភិបាលដើម្បីគ្រប់គ្រងអភិបាលកិច្ចល្អឱ្យបានត្រឹមត្រូវនិងយុត្តិធម៌។

២_ ស្នើសុំពង្រីកតួនាទី និងភារកិច្ចរបស់អង្គការសង្គមស៊ីវិលឱ្យត្រឹមត្រូវតាមប្រព័ន្ធជំនាញនិងភារកិច្ចឱ្យស្របជាមួយស្ថាប័នរដ្ឋ។

៣_ ស្នើសុំឱ្យមានវិធានការទប់ស្កាត់អំពើពុករលួយតាមរយៈការលើកស្ទួយការអប់រំសិក្សាអំពីអភិបាលកិច្ចល្អ និងការចាត់តាំងអនុវត្តន៍។

៤_ ស្នើសុំបញ្ចូលគំនិតនិងគោលការណ៍អនុវត្តន៍ល្អៗ ពោលគឺគតិបណ្ឌិត និងការដឹកនាំប្រកបដោយភាពបរិសុទ្ធជូនថ្នាក់ដឹកនាំ និងគ្រប់គ្រងទាំងអស់ ឱ្យបានមួយជំហានមុនឬក៏យ៉ាងហោចណាស់ឱ្យបានទន្ទឹម និងអង្គការសង្គមស៊ីវិល

ដើម្បីលើកស្ទួយការអភិវឌ្ឍន៍ "អភិបាលកិច្ចល្អ" នៅក្នុងស្ថាប័នសិក្សាអប់រំវប្បធម៌សង្គមកិច្ចនយោបាយនិងសន្តិសុខ។

៥- មុននឹងអនុម័តច្បាប់ណាមួយ ស្នើសុំឱ្យសភាជាតិលៃទុកឱកាសឱ្យមហាជនអង្គការសង្គមស៊ីវិលនិងប្រជាពលរដ្ឋបានចូលរួមមតិផង។

## IV- សេចក្តីសន្និដ្ឋាន :

កិច្ចពិភាក្សាតុមូលលើកទី១ បានទទួលលទ្ធផលល្អប្រសើរដោយប្រមូលផ្តុំបានចំណេះដឹង និងបទពិសោធន៍អំពីអភិបាលកិច្ចល្អ និងការចាត់តាំងអនុវត្តន៍ជាច្រើន។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ការស្ថាបនាអភិបាលកិច្ចល្អ នៅក្នុងអង្គការសង្គមស៊ីវិលពិត ជាមិនបានទទួលលទ្ធផលល្អប្រសើរទេ ប្រសិនបើអ្នកដឹកនាំសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់មិនបានយល់ដឹងពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការកសាង និងពង្រឹង "អភិបាលកិច្ចល្អ" ដើម្បីវឌ្ឍនភាព និងវិបុលភាពរបស់ប្រទេសជាតិនិងប្រជាពលរដ្ឋទេ។ ថាមពលការងារមានប្រតិកម្មយ៉ាងជ្រាលជ្រៅទៅលើអភិបាលកិច្ចល្អ។ បើគ្មានសេចក្តីស្មោះត្រង់ និងការគិតពីប្រយោជន៍រួមធំជាងប្រយោជន៍បុគ្គលទេ នោះអភិបាលកិច្ចល្អមិនអាចមានអត្ថិភាពនិងនិរន្តរភាពបានឡើយ។

សូមឱ្យអង្គការសង្គមស៊ីវិលខ្មែរ គ្រប់ជាន់ថ្នាក់ឆាប់ទទួលបាននូវការយល់ដឹង នេះហើយប្តេជ្ញាបន្តគោរពតាមការយល់ដឹងនេះ ដោយការភ្ញាក់រំលឹក សហប្រតិបត្តិការ និងការទទួលខុសត្រូវខ្ពស់។

## ២.២ កិច្ចពិភាក្សាតុមូលលើកទី ២

➢ ប្រធានបទនៃការពិភាក្សា ស្ដីពី "មគ្គុទ្ទេសភាព និងការទទួលខុសត្រូវនៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា"។

➢ គណៈវាគ្មិនកិត្តិយស (១)_បណ្ឌិត ប៉ែន ដារេត ទីប្រឹក្សារដ្ឋាភិបាល ទទួលបន្ទុកអង្គការ NGOs (២)_លោក ហៀវ វាស្នា នាយកអភិបាល រដ្ឋបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)។

ខ្លឹមសារសង្ខេប

I- **មតិរបស់គណៈវាគ្មិនកិត្តិយស :**

១_ **បណ្ឌិត ប៉ែន ដារេត ទីប្រឹក្សារបស់រដ្ឋាភិបាល ទទួលបន្ទុកអង្គការ NGOs :**

- មគ្គុទ្ទេសភាព និងការទទួលខុសត្រូវនៅក្នុងអង្គការសង្គមស៊ីវិលគឺជាការដឹកនាំប្រកបដោយភាពបរិសុទ្ធ និងការទទួលខុសត្រូវខ្ពស់ដែលអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវធ្វើឱ្យបានដើម្បីក្លាយជាដៃគូដ៏ល្អរបស់រដ្ឋាភិបាល។

- ពាក្យថា "Think Tank" មានន័យថាជា "ស្ថាប័នវិភាគី ឬធនាគារគំនិត"។ ស្ថាប័ននេះ បំរើផលប្រយោជន៍សាធារណៈ។ ស្ថាប័នវិភាគី តែងតែរួមចំណែកផ្ដល់មតិយោបល់សំរាប់ការស្ថាបនាប្រទេសជាតិនិងជាខួរក្បាលសំរាប់ជួយរដ្ឋាភិបាលនៅលើគ្រប់វិស័យនៃគោលនយោបាយរបស់រដ្ឋ។

- កង្វះបទពិសោធន៍ក្នុងការដឹកនាំ និងកង្វះធនធានមនុស្សដោយសារតែសង្គ្រាមអូសបន្លាយយូរអង្វែង គឺជាបញ្ហាប្រឈមមុខមួយរបស់អង្គការសង្គមស៊ីវិលកម្ពុជា។

- ដើម្បីរក្សាបាន នូវភាពដៃគូដ៏ល្អប្រសើរ ជាមួយរដ្ឋាភិបាលអង្គការសង្គមស៊ីវិលទាំងអស់ ត្រូវតែប្រកាន់គោលជំហរអព្យាក្រឹតឯករាជ្យ និងមិនមាននិន្នាការធ្វើនយោបាយប្រឆាំង និងគោលនយោបាយរបស់រដ្ឋាភិបាល។ រាល់ការរិះគន់ ឬការជួយធ្វើការកែលំអរបស់អង្គការសង្គមស៊ីវិល ចំពោះការខ្វះខាតរបស់រាជរដ្ឋាភិបាលគួរតែធ្វើឡើងតាមអនុសាសន៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋាភិបាល ពុំគួរធ្វើឡើងតាមកន្ត្រកបក្សប្រឆាំងឡើយ។

- អង្គការសង្គមស៊ីវិលកម្ពុជាឬ NGOs មានតួនាទី : (១)_ជួយឃ្លាំមើលការផ្ដល់ជំនួយ (២)_ចូលរួមផ្ដល់ការគាំទ្រការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា (៣)_លើកស្ទួយអភិបាលកិច្ចល្អ និងការទទួលខុសត្រូវ ប្រឆាំងនឹងអំពើពុករលួយ (៤)_រួមចំណែករៀបចំច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ (៥)_ជួយឧបត្ថម្ភគាំទ្រការអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាននិង (៦)_ជួយស្វែងរកយុទ្ធវិធីគាំពារសុខភាពរបស់ប្រជាពលរដ្ឋ និងទប់ស្កាត់ការជួញដូរស្ត្រីភេទ និងកុមារ។

## ២_ លោក ហៀវ វាស្នា នាយកអភិបាលរដ្ឋបាល នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) :

- អង្គការសង្គមស៊ីវិលទាំងអស់សុទ្ធតែមានវិបត្តិដូចៗគ្នា វាគ្រាន់តែច្រើននិងតិច។ បើអង្គការទាំងនោះគ្មានការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ អង្គការទាំងនោះ នឹងជួបតែវិបត្តិ។ អភិបាលកិច្ចល្អ គឺជាអាយុជីវិតរបស់អង្គការសង្គមស៊ីវិល។
- ប្រព័ន្ធដឹកនាំរបស់រដ្ឋនិងប្រព័ន្ធដឹកនាំរបស់អង្គការសង្គមស៊ីវិលពុំដូចគ្នាទេ។ ប្រព័ន្ធដឹកនាំរបស់រដ្ឋមានលក្ខណៈតឹងរ៉ឹង តាមឋានានុក្រម តែប្រព័ន្ធដឹកនាំរបស់អង្គការសង្គមស៊ីវិលមានលក្ខណៈ ជាសហប្រតិបត្តិការឬជាក្រុមការងារ។
- ការងារដឹកនាំក្នុងអង្គការសង្គមស៊ីវិលចាំបាច់ត្រូវមានលក្ខណៈសម្បត្តិពីរយ៉ាង : នោះគឺសមត្ថភាពដឹកនាំ និងសមត្ថភាពគុណធម៌។ សមត្ថភាពទាំងពីរនេះមិនអាចខ្វះមួយណាបានឡើយ។ ប្រព័ន្ធដឹកនាំក្នុងអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវតែមានតម្លាភាព និងគណនេយ្យភាព នោះទើប មានសហប្រតិបត្តិការល្អនៅក្នុងការងាររបស់ខ្លួន។
- ដើម្បីឱ្យសហប្រតិបត្តិការ និងភាពជាដៃគូរបស់ខ្លួនបានល្អ ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ ទាំងសង្គមស៊ីវិល និងរដ្ឋាភិបាល ត្រូវតែពង្រឹងការដឹកនាំរបស់ខ្លួន ឱ្យមានអភិបាលកិច្ចល្អ សុចរិតធម៌ និងការទទួលខុសត្រូវ។

រាល់ការរៀបសង្កត់ដោយល្បិចនយោបាយ ដើម្បីដណ្តើមយកសហប្រតិបត្តិការ និងភាពជាដៃគូនេះគឺជាការខុសឆ្គង។ ដរាបណាអ្នក

ទាំងពីរគ្មានសេចក្តីស្មោះត្រង់ និងការគោរពផលប្រយោជន៍ជាតិជាធំទេ នោះទំនាក់ទំនងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលនៅតែមានបញ្ហា។ សហប្រតិបត្តិការនេះ ត្រូវឈរលើសុចរិតធម៌និងសេចក្តីយោគយល់។

II- អំពីលទ្ធផលនៃការពិភាក្សារួម :

១- ដើម្បីពង្រឹងមត្តុទ្ទេសភាព និងការទទួលខុសត្រូវនៅក្នុងអង្គការសង្គមស៊ីវិលបានល្អ គេគួរតែយកចិត្តទុកដាក់ទៅលើបញ្ហាមួយចំនួនដូចខាងក្រោម ៖

→ ជំហរឯករាជ្យ និងអព្យាក្រឹតភាព។

→ ការពិគ្រោះយោបល់ និងទំនាក់ទំនងជាមួយរដ្ឋាភិបាល។

→ លើកស្ទួយវប្បធម៌ សហប្រតិបត្តិការជាមួយរដ្ឋាភិបាល។

→ ការរិះគន់កែលំអ គួរតែធ្វើឡើងតាមអនុសាសន៍ ជាលាយលក្ខណ៍អក្សរនិងតាមរយៈតំណាង។

→ ចូលរួមសហការដោយត្រង់ៗកុំធ្វើដោយប្រយោល។

២- អង្គការសង្គមស៊ីវិល គ្រាន់តែជាអង្គការមហាជនមួយ ដើម្បីបំរើផលប្រយោជន៍របស់សមាជិកខ្លួន និងសង្គមជាតិ។ សង្គមស៊ីវិលពុំអាចជំនួសរដ្ឋាភិបាល ដែលប្រជាពលរដ្ឋជ្រើសតាំងឡើងបានទេ។ ក៏ប៉ុន្តែ សហប្រតិបត្តិការ និងការបំពេញភាពខ្វះចន្លោះរបស់រដ្ឋាភិបាល គឺជាបេសកកម្មរបស់អង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់។

៣. អង្គការសង្គមស៊ីវិល គួរធ្វើការងារជាមួយរដ្ឋាភិបាល តាមរយៈយន្តការរបស់ខ្លួនមួយ។ តែការបង្កើតយន្តការនោះ គួរតែប្រយ័ត្នប្រយែងអំពីការជ្រៀតចូលរបស់គណបក្សនយោបាយ ព្រោះបើធ្វើនយោបាយនោះសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋានឬជាមួយរដ្ឋាភិបាលមិនអាចស្ថិតស្ថេរបានឡើយ។

៤. បើចង់ពង្រឹងយន្តការមួយរបស់អង្គការសង្គមស៊ីវិល ដើម្បីធ្វើការជាមួយរដ្ឋាភិបាលឱ្យបានរឹងមាំល្អ អង្គការសង្គមស៊ីវិលទាំងអស់ត្រូវមានគោលដៅរួមដូចគ្នា ត្រូវប្រកាន់ឱ្យបាននូវអព្យាក្រឹតភាពរបស់ខ្លួននិងត្រូវធ្វើវិមជ្ឈការអំណាច និងការទទួលខុសត្រូវរបស់ខ្លួន។

៥. ដើម្បីឱ្យសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិលនិងរដ្ឋាភិបាលមានដំណើរការល្អប្រសើរមិនមែនជារឿងងាយស្រួលទេ។ នឹងធ្វើបានលុះណាតែអ្នកទាំងពីរមានសេចក្តីស្មោះត្រង់ ហើយពិតជាចង់ធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីផលប្រយោជន៍របស់សង្គមពិតៗមែន។

៦. យន្តការរបស់អង្គការសង្គមស៊ីវិល ដែលត្រូវធ្វើការជាមួយរាជរដ្ឋាភិបាល ប្រសិនបើបានបង្កើតហើយ ត្រូវតែមានតម្លាភាពក្នុងការជ្រើសរើសប្រធានឬសមាជិកតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌។ បើពុំដូច្នោះទេ យន្តការនោះមិនអាចបំរើគោលដៅនិងសំណូមពររបស់អង្គការសង្គមស៊ីវិលបានឡើយ។

៧_ អង្គការសង្គមស៊ីវិល ប្រសិនបើចង់ធ្វើឬជួយតាក់តែងច្បាប់អ្វីមួយឱ្យរដ្ឋាភិបាលគេគួរតែពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលផងដែរ នោះទើបសំរេចបានលទ្ធផលល្អ។

## III_ សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន អំពីមគ្គុទ្ទេសភាព នៅក្នុងអង្គការសង្គមស៊ីវិល ដើម្បីឱ្យការដឹកនាំ និងគ្រប់គ្រងអង្គការសង្គមស៊ីវិលបានល្អ ត្រូវតែមានលក្ខណៈប្រជាធិបតេយ្យ និងវប្បធម៌នៃការចូលរួម។

គោលដៅរួមដូចគ្នា ការចែះរំលែងចែកផលប្រយោជន៍ និងសេចក្តីយោគយល់ គឺជាគោលការណ៍ មិនអាចខ្វះបាន។ ម៉្យាងទៀត រចនាសម្ព័ន្ធរបស់អង្គការសង្គមស៊ីវិល មិនគួរតឹងតែងពេកទេ តែត្រូវតែមានតម្លាភាព គណនេយ្យភាពក្នុងការប្រើប្រាស់ហិរញ្ញវត្ថុ។ ទន្ទឹមនោះការបែងចែកប្រព័ន្ធការងារ ត្រូវតែច្បាស់លាស់ប្រាកដប្រជា និងធានាបានប្រាក់បៀវត្សរ៍សមរម្យទៅតាមមុខតំណែង និងតួនាទីរបស់បុគ្គលិក។

ចំពោះសហប្រតិបត្តិការ និងទំនាក់ទំនងជាដៃគូល្អរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាលវិញ មិនអាចកើតមាននៅលើភាពមិនស្មោះត្រង់និងល្បិចនយោបាយឡើយ។

ភាពជាដៃគូនេះ ត្រូវតែឈរនៅលើសុចរិតធម៌ សេចក្តីយោគយល់និងអភិបាលកិច្ចល្អ។

## ២_៣ កិច្ចពិភាក្សាតុមូលលើកទី៣

➢ ប្រធានបទនៃពិភាក្សា ស្តីពី "ការអភិវឌ្ឍន៍ធនធានមនុស្សនិងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិល បទពិសោធន៍នៅកម្ពុជា"។

➢ គណៈវាគ្មិនកិត្តិយស : (១)_លោកស្រី ធីដា ឃិះ នាយិកា អង្គការស៊ីលការ[(១)] និង(២)_ លោកស្រី ជូ ប៊ុនអេង នាយិកា សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍[(២)]។

## ខ្លឹមសារសង្ខេប

### I- មតិ និងទស្សនៈរបស់គណៈវាគ្មិន

**១_ លោកស្រី ធីដា ឃិះ** <u>នាយិកា អង្គការស៊ីលការ</u>[(១)] :

→ ការណែនាំឱ្យស្គាល់អង្គការស៊ីលការ និងសេវាដែលអង្គការនេះធ្វើ។

→ ការវាយតម្លៃលើស្ថានភាពអង្គការ NGOs ទូទៅនៅកម្ពុជានិង

→ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ខ្លះទៅអនាគត។

→ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា ត្រូវមានសីលវិន័យ។ វិន័យជាសំខាន់លើ

---

(១) *បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថារបស់លោកស្រី ធីដា ឃិះ ។*

(២) *បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថា របស់ លោកស្រី ជូ ប៊ុនអេង ។*

(១) *បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថារបស់លោកស្រី ធីដា ឃិះ ។*

អ្វីៗទាំងអស់។ បើគ្មានសីលវិន័យទេ អ្វីៗក៏គ្មានដែរ។ ត្រូវមានច្បាប់និងការគោរពច្បាប់។

→ អង្គការសីលការមានសកម្មភាពសំខាន់៤គឺ ៖

១- ការហ្វឹកហ្វឺន

២- ការពិគ្រោះយោបល់

៣- ការកសាងសាមគ្គី និង

៤- ការស្រាវជ្រាវ និងការអភិវឌ្ឍន៍។

→ វិន័យត្រូវដើរទន្ទឹមនឹងការហ្វឹកហ្វឺនសមត្ថភាពការរីកចំរើននៃលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស។ ត្រូវអប់រំទ្រឹស្តី ទន្ទឹមនឹងការប្រតិបត្តិជាក់ស្តែង។

→ ជាបទពិសោធន៍ ការខ្វះខាតកន្លងមក : ភ្នាក់ងារសង្គមស៊ីវិលច្រើនខ្វះសាមគ្គីភាព ខ្វះប្រជាធិបតេយ្យភាពក្នុងការគ្រប់គ្រងខ្វះការបំពេញតម្រូវការរបស់ម្ចាស់អំណោយ ខ្វះឯករាជភាព ខ្វះការពង្រឹងវិន័យ។ ត្រូវកសាងទស្សនវិស័យរួមមួយ ដើម្បីលើកស្ទួយសង្គមស៊ីវិលកម្ពុជាទៅអនាគត។

## ២-លោកស្រី ជូ ប៊ុនអេង នាយិកាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍[២]

---

(២) *បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថា របស់ លោកស្រី ជូ ប៊ុនអេង ។*

→ ទាំងរដ្ឋាភិបាលទាំងសង្គមស៊ីវិល និងប្រជាពលរដ្ឋត្រូវរស់នៅរួម សុខរួមទុក្ខជាមួយគ្នា ដូចជិះក្នុងនាវាតែមួយ : ត្រូវមានគោលដៅនិងបំណងច្បាស់លាស់ ត្រូវមានការទទួលខុសត្រូវរួមគ្នា ត្រូវមានធនធានមនុស្សល្អនិងយុទ្ធសាស្ត្រដឹកនាំពិតប្រាកដ។

→ ធនធានមនុស្ស ដែលយើងចង់បានត្រូវមាន ៖ សាមគ្គីភាព សេចក្តីស្មោះត្រង់ ចិត្តអធ្យាស្រ័យគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមកត្រូវមានគំនិតជឿនលឿន និងអភិវឌ្ឍន៍ត្រូវមានឆន្ទៈការប្តេជ្ញាចិត្តខ្ពស់ទទួលខុសត្រូវសីលធម៌និងសុចរិតធម៌ ត្រូវស្គាល់ខ្លួនឯង និងតួនាទីរបស់ខ្លួនចំពោះអ្នកដទៃ និងសង្គមជាតិ។

→ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពត្រូវដើរទន្ទឹមនឹងការកសាង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

→ ត្រូវកសាងទាំងធនធានអ្នកដឹកនាំ និងអ្នកដែលត្រូវដើរតាម។ អ្នកដឹកនាំត្រូវមានចរិតប្រាកដនិយមនិងនឹងនរ។ អ្នកដើរតាមត្រូវមានសេចក្តីស្មោះត្រង់និងគោរពវិន័យ។

→ កត្តាមនុស្សគឺជាកត្តាកំណត់ : ត្រូវមានធនធានមនុស្សល្អនិងជឿនលឿនត្រូវមានសមត្ថភាពយល់និងសមត្ថភាពធ្វើឆន្ទៈស្មារតីទទួលខុសត្រូវ ទំនាក់ទំនងល្អ សុចរិតធម៌ និងសីលធម៌ល្អ

→ អ្នកដឹកនាំត្រូវមានគំនិតអភិវឌ្ឍន៍ : អភិវឌ្ឍទាំងខ្លួនឯងនិងអ្នកនៅជុំវិញខ្លួន អភិវឌ្ឍទាំងទស្សនៈទាំងសកម្មភាព។

→ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពគឺជាគន្លឹះសំរាប់ពង្រឹងស្ថាប័នឱ្យរឹងមាំ និងមានចីរភាព។

→ ដើម្បីសំរេចការងារនេះ សង្គមស៊ីវិលគួរបន្តធ្វើការផ្លាស់ប្ដូរបទពិសោធន៍ និងចំណេះដឹងរួមគ្នាដោយទស្សនៈទូលំទូលាយ អព្យាក្រឹតនិងយុត្តិធម៌។

## II- លទ្ធផលនៃការពិភាក្សារួម :

- ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលគួរប្រមូលផ្ដុំ ជាសំខាន់ទៅលើការអភិវឌ្ឍន៍គុណធម៌ ផ្លូវចិត្ត និងសុចរិតធម៌។
- ទន្ទឹមនឹងការអភិវឌ្ឍន៍ គុណធម៌ សុចរិតធម៌ សមត្ថភាព និងបទពិសោធន៍ សង្គមស៊ីវិលគួរតែយកចិត្តដាក់ពង្រឹងអភិបាលកិច្ចល្អ គោលនយោបាយគ្រប់គ្រងបុគ្គលិកដោយសច្ចយុត្តិធម៌ ចៀសវាងភាពផ្ដាច់ការក្នុងការគ្រប់គ្រង និងត្រូវយកចិត្តទុកដាក់លើកកំពស់គុណភាពនៃជីវភាពរស់នៅរបស់បុគ្គលិក។
- ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងកសាងសមត្ថភាពក្នុងសង្គមស៊ីវិលបានល្អ គេគួរតែកសាងបេះដូងមនុស្សល្អ ព្រមជាមួយនឹងការបណ្ដុះបណ្ដាល ចំណេះដឹង បទពិសោធន៍និងការអភិវឌ្ឍន៍ធនធានសេដ្ឋកិច្ច។

- ការកសាងសមត្ថភាពបន្ថែមទៅលើមុខវិជ្ជាខាងអភិបាលកិច្ចល្អ ត្រូវមានមុខវិជ្ជានៃការគ្រប់គ្រងល្អ (Good Management); រដ្ឋបាលល្អ (Good Administration); និងសុចរិតធម៌ (Integrity)ផង។

- ការអភិវឌ្ឍន៍ធនធានមនុស្សត្រូវអភិវឌ្ឍទាំងចំណេះដឹងនិងចំណេះធ្វើ (ទាំងទ្រឹស្តីនិងការអនុវត្តន៍ជាក់ស្តែង)។ ទាំងអ្នកដឹកនាំ ទាំងបុគ្គលិកត្រូវអភិវឌ្ឍការយល់ដឹងឱ្យស្របៗគ្នា។

- ដើម្បីឱ្យសង្គមស៊ីវិលមានភាពរឹងមាំ គេត្រូវអភិវឌ្ឍរចនាសម្ព័ន្ធការងារឱ្យបានត្រឹមត្រូវបង្កើនសមត្ថភាព និងធ្វើវិមជ្ឈការ ការដឹកនាំនិងទទួលខុសត្រូវតាមលំដាប់ថ្នាក់ឱ្យបានល្អ។ ការធ្វើវិមជ្ឈការបានល្អលុះណាតែមានការយល់ដឹងដូចៗគ្នា ទាំងអ្នកដឹកនាំនិងបុគ្គលិក។

- ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពត្រូវមានយុទ្ធសាស្ត្រនិងគោលដៅច្បាស់លាស់។ គេគួរតែអភិវឌ្ឍធនធាន ប្រជាពលរដ្ឋជាសំខាន់ ដើម្បីជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ បើប្រជាពលរដ្ឋមានការយល់ដឹងត្រឹមត្រូវ ប្រជាពលរដ្ឋនឹងចេះពិចារណាចេះជូនយោបល់និងចេះបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ។ យ៉ាងណាមិញការអភិវឌ្ឍន៍ធនធានមនុស្សនិងការកសាងសមត្ថភាពក្នុងសង្គមស៊ីវិលក៏គួរគិតពីការអភិវឌ្ឍន៍សមត្ថភាពយល់ដឹងរបស់បុគ្គលិកជាបឋមដែរ។

- ការអភិវឌ្ឍន៍ធនធានមនុស្ស គួរគិតពិចារណាពី : (១)_បរិមាណ (២)_លក្ខណៈសម្បត្តិ (៣)_ព្រលឹងមនុស្ស។ គេគួរតែគិតពីការ

អភិវឌ្ឍន៍មនោគមវិជ្ជាជាតិ ទន្ទឹមនឹងការអភិវឌ្ឍន៍ ចំណេះដឹងបច្ចេកទេស។

- ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលអាចនឹងធ្វើបានល្អ ព្រមជាមួយនិងការអភិវឌ្ឍន៍ចំណេះដឹងគេគួរតែគិតពីគុណភាពនៃជីវភាពរស់នៅ (លំនៅដ្ឋាន អាហារហូបចុក សម្ភារៈប្រើប្រាស់បៀវត្សរ៍ និងការព្យាបាលសុខភាព) របស់បុគ្គលិកផង។

- ការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងសង្គមស៊ីវិលត្រូវតែប្រមូលផ្តុំទៅលើការអភិវឌ្ឍន៍ ជំនាញ ឯកទេសកម្ម និងបច្ចេកវិជ្ជាឱ្យបានច្បាស់លាស់។

វីឯការបង្កើនសមត្ថភាពត្រូវផ្តោតទៅលើ : (១)_ការបង្កើនសមត្ថភាពរបស់ស្ថាប័ន (សមត្ថភាព តួនាទី រចនាសម្ព័ន្ធគ្រប់គ្រង គោលនយោបាយ រដ្ឋបាល និងថវិកា) (២)_ការគិតគូរអំពីកម្មវិធី (៣)_កំរិតសមត្ថភាព តាមឯកទេសកម្មនិង (៤)_ការចេះសហការ ការកសាងបណ្តាញទំនាក់ទំនងការងារ និងភាពជាដៃគូជាមួយស្ថាប័នឬអង្គការដទៃទៀតផង ពិសេសគឺជាមួយស្ថាប័នរដ្ឋ។

## III. អំពីសំណូមពរ និងអនុសាសន៍

១_ ស្នើសុំឱ្យវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព បន្ថែមពេលវេលាសំរាប់ការពិភាក្សាឱ្យបានពេញ១ថ្ងៃ ឬពីរព្រឹក

ដើម្បីឱ្យសមាជិក នៃនាទីពិភាក្សាមានពេលគិតពិចារណា និងពិភាក្សាបានល្អិតល្អន់។

២- ស្នើសុំឱ្យវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ធ្វើការបោះពុម្ពផ្សាយនិងចែកផ្សាយឱ្យដល់ស្រទាប់ប្រជាពលរដ្ឋមូលដ្ឋានផង។

## III- សេចក្តីសន្និដ្ឋាន :

ការកសាងធនធានមនុស្ស និងការកសាងសមត្ថភាពក្នុងសង្គមស៊ីវិលកម្ពុជាមានសារៈសំខាន់ណាស់ នោះគឺជាកត្តាស្លាប់រស់របស់សង្គមស៊ីវិល ព្រោះថា បើគ្មានធនធានមនុស្សល្អឬធនធានល្អនោះគ្មានសមត្ថភាពគ្រប់គ្រាន់ទេ នោះសង្គមស៊ីវិលមិនអាចអភិវឌ្ឍរឹងមាំបានទេ។

ធនធានមនុស្ស ក្នុងសង្គមស៊ីវិលត្រូវមានលក្ខណៈសម្បត្តិជាសារវ័ន្តបីគឺ :

(១)-មានសមត្ថភាពយល់ដឹងទូលំទូលាយ។

(២)-មានសមត្ថភាពបច្ចេកទេសខ្ពស់។

(៣)-មានគុណធម៌ និងសីលធម៌ខាងផ្លូវចិត្តគំនិត។

ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពក្នុងសង្គមស៊ីវិលត្រូវតែឆ្លើយតបទៅនឹងជំនាញឯកទេសកម្ម និងការវិវត្តន៍នៃចរន្តអភិវឌ្ឍន៍ សេចក្តីត្រូវការ កាលៈទេសៈរបស់សង្គមដោយផ្សាភ្ជាប់

ទៅនឹងតំបន់និងពិភពលោកផង។ បើធ្វើដូច្នេះបាន នោះសង្គមស៊ីវិលនឹងវិវត្តរីកចំរើន។ ផ្ទុយទៅវិញ បើគ្មានការកសាងធនធានមនុស្ស និងការកសាងសមត្ថភាពដូចបានរៀបរាប់ខាងលើទេ នោះសង្គមស៊ីវិលមិនអាចអភិវឌ្ឍស្របតាមសេចក្ដីត្រូវការរបស់សង្គម និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋឡើយ៕

## ២.៤ កិច្ចពិភាក្សាតុមូលលើកទី៤

➢ ប្រធានបទនៃការពិភាក្សាស្ដីពី *"ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា"*។

➢ គណៈវាគ្មិនកិត្តិយស (១)-លោក ស៊្វីន ប៉ក់ នាយកប្រតិបត្តិវិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស (២)-លោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម។

### ខ្លឹមសារសង្ខេប

I- ទស្សនៈ និងមតិរបស់គណៈវាគ្មិនកិត្តិយស ៖

១- <u>លោក ស៊្វីន ប៉ក់ នាយកប្រតិបត្តិ វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស</u>[1]

→ និន្នាការនៃរដ្ឋ និងរដ្ឋាភិបាល ក្នុងពិភពលោកក្នុងសហស្សវត្សរ៍ថ្មីកំពុងខិតខំបឹងប្រែងពង្រឹង និងពង្រីកសាមគ្គីភាព និងសហ

(1) *បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថារបស់ លោក ស៊្វីន ប៉ក់ ។*

ប្រតិបត្តិការអន្តរជាតិ ដើម្បីលើកស្ទួយវប្បធម៌សន្តិភាព កាត់បន្ថយមនោគមន៍វិជ្ជា នយោបាយឈ្លានពាននិងការមិនទុកចិត្តគ្នាសំដៅឱ្យចេះស្រុះស្រួល មូលមតិគ្នា_ជួយគ្រោះគ្នានិងបែងចែកផលប្រយោជន៍ឱ្យគ្នាតាមផ្លូវសីលធម៌ សន្តិវិធីសេចក្ដីថ្លៃថ្នូរ និងភាតរភាព។

→ ជាការពិតណាស់ប្រទេសនីមួយៗ មិនអាចគេចមិនទទួលយកសកលភាវូបនីយកម្មបានទេ ព្រោះសកលភាវូបនីយកម្មវាជាទំនោរនៃឥទ្ធិពលនយោបាយសេដ្ឋកិច្ច និងវប្បធម៌របស់ពិភពលោក។ ក៏ប៉ុន្តែ ផលល្អឬអាក្រក់វា កើតមានដំណាលគ្នាមកលើប្រទេសទន្ទ្រិក្ស ដែលកំពុងខ្វះខាតធនធានមនុស្សដូចប្រទេសកម្ពុជាយើងជាអាទិ៍នេះ។

→ សង្គមស៊ីវិល គឺជាស្ពានដ៏ពិសេសមួយ សំរាប់ចម្លងសកលភាវូបនីយកម្មឱ្យចេញឬចូលក្នុងស្រុក។ ដូច្នេះ អង្គការសង្គមស៊ីវិលគួរពិចារណាដោយប្រុងប្រយ័ត្ន នូវឥទ្ធិពលនៃសកលភាវូបនីយកម្មនេះថា តើអ្វីដែលគួរទទួលយក និងអ្វីទៅដែលមិនគួរទទួលយក។

## ២_ លោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម [២]

- អ្វីទៅជាសង្គមស៊ីវិល?

[2] បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថារបស់ លោកស្រី ជា វណ្ណាត ។

- អ្វីទៅជាសកលភាវូបនីយកម្ម?
- លំហូរនៃសកលភាវូបនីយកម្ម ដូចទឹកហូរធ្លាក់ពីលើកំពូលភ្នំ ហូរចូលមកទាំងល្អ ទាំងអាក្រក់ ⇒ នាំឱ្យសង្គមរីកចំរើនផង និងឱនថយផង ប្រសិនបើគ្មានការគ្រប់គ្រងល្អ និងមធ្យ័ត។
- ក្នុងការទទួលយកសកលភាវូបនីយកម្មនេះ អង្គការសង្គមស៊ីវិលមានតួនាទីជួយដោះស្រាយបញ្ហាសង្គមដែលកើតមកពីបញ្ហានេះ ដូចជាបញ្ហានៃសេចក្តីក្រីក្រ ជម្ងឺអេដស៍ ការជួញដូរស្ត្រីភេទកុមារ ការជក់គ្រឿងញៀន ការបាត់បង់ដីធ្លី ការបំផ្លាញបរិស្ថាន ត្រី អំពើពុករលួយនិងវិបត្តិនៃគុណធម៌ជាតិ និងសីលធម៌សង្គម ។ល។
- ស្នើសុំឱ្យជួយដោះស្រាយបញ្ហាទាំងនេះ តាមរយៈការពង្រឹងនិងពង្រីកអភិបាលកិច្ចល្អមធ្យ័តរឹងមាំ និងការគ្រប់គ្រងសង្គមដោយច្បាប់។

## II_ លទ្ធផលនៃការពិភាក្សារួម :

### ១_ <u>អំពីឧស្សនៈរួម</u> :

- សកលភាវូបនីយកម្ម គឺជាដំណើរការនៃសមាហរណកម្មខាងវិស័យនយោបាយសេដ្ឋកិច្ច វប្បធម៌ និងបច្ចេកវិជ្ជារបស់ពិភពលោក។ ក្នុងលោកនេះគ្មានប្រទេសជាតិណាមួយដែលបដិសេធមិនទទួលយកសកលភាវូបនីយកម្មទេ។ ក៏ប៉ុន្តែ សកលភាវូ

បនីយកម្ម វាមានចំណុចសកម្មផង និងអសកម្មផង។ ចំណុចសកម្មនាំឱ្យប្រទេសជាតិមួយជឿនលឿន ចំណុចអសកម្មនាំឱ្យប្រទេសជាតិមួយឱនថយ។

- សកលភាវូបនីយកម្មមានគុណប្រយោជន៍ដល់វឌ្ឍនភាពនៃសង្គមស៊ីវិលនិងប្រទេសជាតិកម្ពុជា តែបើគ្មានការគ្រប់គ្រងសង្គមដោយច្បាប់រឹងមាំនិងមធ្យ័តទេ នោះសកលភាវូបនីយកម្មនឹងស៊ីបំផ្លាញអ្នកទាំងពីរវិញ។
- សង្គមស៊ីវិល មានតួនាទីសំខាន់ណាស់ ក្នុងការជួយទប់ស្កាត់វិបត្តិសង្គម ដែលកើតមានដោយឥទ្ធិពល នៃសកលភាវូបនីយកម្មនេះ។

## ២_ អំពីចំណេះដឹង និងបទពិសោធន៍ :

- សកលភាវូបនីយកម្ម គឺជាសណ្ដាប់ធ្នាប់ថ្មី របៀបរៀបរយថ្មីនៃនយោបាយរបស់ពិភពលោក ដែលប្រទេសជាតិទាំងឡាយចូលរួមគ្នា នៅក្នុងអង្គការអន្តរជាតិ និងតំបន់ដើម្បីបង្ការទំនាស់និងដោះស្រាយទំនាស់របស់ប្រជាជាតិនានា ជាភូមិសកលដែលពិភពលោកចាត់ទុកដូចជាសហគមន៍ តែមួយសំរាប់ទទួលយករួមគ្នានូវបច្ចេកវិជ្ជាទំនើប និងគមនាគមន៍អន្តរជាតិ_ជាសណ្ដាប់ធ្នាប់នៃសាជីវកម្មសកល។

- សកលភាវូបនីយកម្ម រមែងផ្តល់ផលចំណេញច្រើនឱ្យបណ្តាប្រទេសធំៗដែលមានវឌ្ឍនភាពសេដ្ឋកិច្ចលឿនលឿន ដែលមានធនធានមនុស្សសម្បូរបែបនិងបច្ចេកវិជ្ជាទំនើប។ តែផ្ទុយទៅវិញចំពោះប្រទេសក្រីក្រ រមែងទទួលបានផលវិបាកច្រើនជាងផលចំណេញ។

- សកលភាវូបនីយកម្មពិតជាមានសារៈប្រយោជន៍ដល់ការកសាង និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ក្រោយសម័យសង្គ្រាម ក៏ប៉ុន្តែទន្ទឹមនោះ សកលភាវូបនីយកម្មក៏បានផ្តល់នូវវិបត្តិសង្គមជាច្រើនឱ្យកម្ពុជាដែរ។

- វិបត្តិសង្គមទាំងនោះមានជាអាទិ៍ ភាពក្រីក្រដែលកាន់តែក្រីក្រទៅការបាត់បង់ គុណធម៌ សីលធម៌សង្គម និងអត្តសញ្ញាណជាតិ ការខូចបរិស្ថាន ការបាត់បង់ត្រីនិងព្រៃឈើ ការបាត់បង់ដីធ្លី ការបាត់បង់ពលកម្ម ការរាតត្បាតនៃជម្ងឺអេដស៍ ការជួញដូរស្ត្រីភេទ កុមារ និងគ្រឿងញៀន ឧក្រិដ្ឋកម្ម និងអំពើពុករលួយ ឆ្លងដែន ការលាងលុយកខ្វក់ ពេស្យាចារ និងការបាត់បង់សន្តិសុខមនុស្ស ។ល។

- អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ គឺជាភ្នាក់ងារនាំចូលដ៏សំខាន់ និងជាបណ្តាញឆ្លងកាត់យ៉ាងឆាប់រហ័ស នៃសកលភាវូបនីយកម្មមកកម្ពុជា។ ម្ចាស់អំណោយនិងសហគមន៍អន្តរជាតិរមែងឃ្លាំមើលហេតុការណ៍នៅកម្ពុជានិងផ្សព្វផ្សាយហេតុការណ៍

នោះទៅគ្រប់ទិសទី នៃពិភពលោកយ៉ាងលឿនបំផុតតាមរយៈរបាយការណ៍របស់ដៃគូថ្នាក់ជាតិរបស់គេនៅកម្ពុជា។

ដូច្នេះទំនាក់ទំនងការគ្រប់គ្រងល្អ និងសហប្រតិបត្តិការជិតស្និទ្ធជាមួយអង្គការអន្តរជាតិ ភ្នាក់ងារសង្គមស៊ីវិលជាតិ និងសមាគមទាំងនេះមានសារៈសំខាន់ណាស់ ក្នុងការជួយទប់ស្កាត់ផលវិបាកនៃសកលភាវូបនីយកម្មមកលើកម្ពុជា។

៣_ អំពីតួនាទីរបស់សង្គមស៊ីវិល :

- ដោយមើលឃើញនូវគុណប្រយោជន៍ និងផលវិបាកនៃសកលភាវូបនីយកម្មនេះ អង្គការសង្គមស៊ីវិលកម្ពុជា គួររៀបចំខ្លួនចូលរួមប្រឈមមុខនិងបញ្ហាធំបីគឺ ៖

  ១_ បញ្ហាសេដ្ឋកិច្ចៈ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដើម្បីឧបត្ថម្ភខ្លួនដោយខ្លួនឯង ដោយលុបបំបាត់ស្មារតី ពឹងផ្អែកតែទៅលើជំនួយបរទេស។

  ២_ បញ្ហាសង្គមកិច្ចនិងសុខាភិបាលៈ ខិតខំជួយបង្កើតច្បាប់និងគោរពច្បាប់គ្រប់គ្រងឱ្យបានមធ្យ័តតាមរយៈការលើកកំពស់អភិបាលកិច្ចល្អនិងកិច្ចព្រមព្រៀង (Agreement) ជាមួយម្ចាស់អំណោយ។

  ៣_ បញ្ហាធនធានមនុស្ស ខិតខំជួយលើកស្ទួយការអភិវឌ្ឍន៍ធនធានមនុស្ស និងអប់រំប្រជាពលរដ្ឋខ្មែរ ឱ្យមាន

សមត្ថភាពយល់ដឹងខ្ពស់ខាងបច្ចេកវិជ្ជា វិទ្យាសាស្ត្រនិងមនសិការស្នេហាជាតិ ដើម្បីទទួលយកសកលភាវូបនីយកម្មសំរាប់កសាងនិងអភិវឌ្ឍប្រទេសជាតិ និងទប់ស្កាត់វិបត្តិសង្គម ដែលមានឥទ្ធិពលមកពីសកលភាវូបនីយកម្មនេះ។

- អង្គការស៊ីវិលកម្ពុជា មានតួនាទីសំខាន់ណាស់ ក្នុងការជួយទប់ស្កាត់ និងកែលំអបញ្ហានេះតាមរយៈការខិតខំលើកស្ទួយវឌ្ឍនភាព សេដ្ឋកិច្ចសង្គមគ្រួសាររបស់ប្រជាពលរដ្ឋ និងការបង្កើនការងារឱ្យបានច្រើនជូនប្រជាពលរដ្ឋ។
- ខណៈពេល ដែលរដ្ឋពុំទាន់មានច្បាប់គ្រប់គ្រាន់សំរាប់គ្រប់គ្រងលំហូរចូលនៃសកលភាវូបនីយកម្មលើវិស័យវប្បធម៌សាសនានោះឥទ្ធិពល នៃវប្បធម៌បរទេសអាចនឹងធ្វើឱ្យខូចដល់ប្រពៃណីសាសនា ទំនៀមទម្លាប់ សីលធម៌ គុណធម៌និងអត្តសញ្ញាណជាតិ។

ដូច្នេះ សង្គមស៊ីវិលមានបេសកកម្មជួយទប់ស្កាត់បញ្ហានេះ តាមរយៈការខិតខំជួយធ្វើសកម្មភាពបំផុសស្មារតី ថែរក្សាប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ សីលធម៌ គុណធម៌ ព្រលឹងជាតិ និងការផ្តួចផ្តើមគំនិត ជាជំនួយឱ្យរាជរដ្ឋាភិបាលក្នុងការបង្កើតច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទងនឹងបញ្ហានេះ។

- ព្រមជាមួយនោះ តួនាទីរបស់សង្គមស៊ីវិលដែលមិនអាចខ្វះបាននោះគឺការជួយរកវិធានការដោះស្រាយបញ្ហាសង្គម ដែលកើតមានមកពីបញ្ហានេះ ការជួយទប់ស្កាត់ការជួញដូរស្ត្រីភេទនិងកុមារ ឧក្រិដ្ឋកម្ម និងអំពើពុករលួយ ឆ្លងដែន ការឆ្លតវង្វេងនិងគ្រឿងញៀន ពេស្យាចារ ការបាត់បង់ធនធានធម្មជាតិនិងបរិស្ថាន អំពើរអក់ឬលន់សន្តិសុខមនុស្សនិងសង្គម ។ល។

## III- សេចក្តីសន្និដ្ឋាន :

ការប្រជុំតុមូលលើកទី៤ស្តីពី "ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា" បានបញ្ចប់ទៅដោយស្មារតីសាមគ្គី និងភាពផុសផុលក្នុងការពិភាក្សា។ អង្គប្រជុំបានសន្និដ្ឋានថា : ចំពោះប្រទេសកម្ពុជា សកលភាវូបនីយកម្មបាននាំមកទាំងគុណប្រយោជន៍ និងគុណវិបត្តិ។

ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ប្រទេសកម្ពុជាពុំអាចនៅឯកោក្រៅប្រព័ន្ធសកលភាវូបនីយកម្មបានទេ។ កម្ពុជាអាចនឹងមានវឌ្ឍនភាពបានដូចបណ្តាប្រទេសដទៃទៀត ក្នុងករណីណាដែលប្រទេសកម្ពុជា បង្កើតបានច្បាប់ថ្មីៗ សំរាប់កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការវិនិយោគទុនត្រឹមត្រូវ និងការគ្រប់គ្រងរឹងមាំ (Stronger Governance) នោះទើបអាចទទួលយកបាននូវផលចំណេញពីសកលភាវូបនីយកម្ម។

ផ្ទុយទៅវិញ បើគ្មានវិធានការទាំងនេះទេ នោះកម្ពុជាដែលជាប្រទេសតូចតាច និងក្រីក្រដែលទើប និងងើបពីសង្គ្រាមនេះគង់នឹងគេចមិនផុតពីភាពរងគ្រោះ។

ការពិភាក្សាតុមូល បានអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ជួយយកចិត្តទុកដាក់ ចំពោះបញ្ហានេះនិងស្នើសុំឱ្យពិចារណានូវអ្វីដែលគួរទទួលយកនិងអ្វីដែលមិនគួរទទួលយកអំពីសកលភាវូបនីយកម្មនេះ៕

## ២_៥ កិច្ចពិភាក្សាតុមូលលើកទី ៥

- ប្រធានបទនៃការពិភាក្សា ស្តីពី "តួនាទីរបស់សង្គមស៊ីវិលកម្ពុជាក្នុងការពារសន្តិសុខមនុស្ស"
- គណៈវាគ្មិនកិត្តិយសៈ (ក)_លោក ធន សារាយ ប្រធានសមាគមកម្ពុជាការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (ខ)_ឯកឧត្តម ឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា នាយកដ្ឋាននយោបាយ និងផែនការក្រសួងការពារជាតិ។

### ខ្លឹមសារសង្ខេប

I. **មតិ និងទស្សនៈរបស់គណៈវាគ្មិនកិត្តិយស**

**១_ លោក ធន សារាយ ប្រធានសមាគមកម្ពុជាការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍** (ADHOC) :

- រំលឹកឡើងវិញអំពីសិទ្ធិមនុស្ស ពិសេសច្បាប់សំខាន់ៗ ទាំងឡាយ ទាំងច្បាប់អន្តរជាតិនិងអង្គការសហប្រជាជាតិ និងច្បាប់រដ្ឋធម្មនុញ្ញ របស់ព្រះរាជាណាចក្រកម្ពុជា សុទ្ធតែផ្តោតទៅលើការការពារសិទ្ធិ មនុស្ស។ ជនគ្រប់រូបមានសិទ្ធិសេរីភាពនិងសន្តិសុខស្មើៗគ្នា។ ប្រជា ពលរដ្ឋគ្រប់រូបត្រូវបានរដ្ឋធានាជូននូវសន្តិសុខបុគ្គលខ្លួនម្នាក់ៗ។

- អំពីសន្តិសុខបុគ្គល ពុំមែនគិតតែទៅលើរូបរាងកាយទេ តែគឺវាទាក់ ទងទៅដល់សន្តិសុខផ្លូវចិត្ត ព្រមទាំងសន្តិសុខខាងទ្រព្យសម្បត្តិផង។

- ហេតុអ្វីបានជាត្រូវការពារសន្តិសុខ? ការការពារសន្តិសុខនេះវាមាន ដំណាក់កាលរបស់វា។ សន្តិសុខមុនសម័យប្រវត្តិសាស្ត្រជាសន្តិសុខ តាមបែបធម្មជាតិ ដែលអ្នកខ្លាំង និងអ្នកមានអំណាចតែងធ្វើបាបជិះ ជាន់សង្កត់សង្កិនអ្នកតូចទាបទន់ខ្សោយ។

- ទ្រឹស្តីពីរដែលពាក់ព័ន្ធនឹងមនុស្សនឹងការរស់នៅក្នុងសង្គម :

  (១)- បើចង់ឱ្យសង្គម ឬរដ្ឋធានាសន្តិសុខឱ្យខ្លួន ប្រជាពលរដ្ឋត្រូវ ប្រគល់សិទ្ធិរបស់ខ្លួនឱ្យរដ្ឋទទួលគាំពារ។

  (២)- ការរស់នៅក្នុងសង្គមពុំដូច្នោះទេ។ រដ្ឋត្រូវតែទទួលស្គាល់សិទ្ធិ របស់បុគ្គលម្នាក់ៗ ព្រោះរដ្ឋជារបស់ប្រជាពលរដ្ឋ ប្រជាពល រដ្ឋគឺជាម្ចាស់របស់រដ្ឋឬសង្គមនោះ។ រដ្ឋត្រូវគោរព និងរក្សា ការពារសិទ្ធិរបស់បុគ្គលឬប្រជាពលរដ្ឋ។ ទ្រឹស្តីទីពីរនេះត្រូវ បានទទួលការគាំទ្រពីពិភពលោក និងអង្គការសហប្រជាជាតិ។

កំប៉ុន្ដែ ទ្រឹស្ដីនេះក៏បានបែងចែកភារកិច្ច និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋផងដែរ ។

- ហេតុដែលនាំឱ្យមានការរំលោភសន្ដិសុខរបស់មនុស្ស គឺបណ្ដាលមកពី :

  ១- អ្នកមាន និងអ្នកធំដែលត្រូវការពារអំណាច និងផលប្រយោជន៍របស់គេ។

  ២- មនុស្សមិនគោរពច្បាប់ និងរំលោភច្បាប់។

- សង្គមស៊ីវិលមានភារកិច្ចពីរយ៉ាងគឺ ៖

  ១- ជួយអប់រំបណ្ដុះបណ្ដាលអំពីសិទ្ធិមនុស្ស សំរាប់មនុស្សគ្រប់រូបក្នុងសង្គម។

  ២- ជួយពង្រឹងធម្មាធិបតេយ្យ និងអភិបាលកិច្ចល្អក្នុងសង្គមជាតិ។

- ការសម្លាប់មនុស្សក្រៅច្បាប់ គឺវាផ្ទុយនឹងច្បាប់រដ្ឋធម្មនុញ្ញ ដែលហាមប្រាមមិនឱ្យមានការសម្លាប់ជីវិតមនុស្ស (គ្មានទោសប្រហារជីវិត) និងផ្ទុយនឹងច្បាប់សិទ្ធិមនុស្ស។

- វិធានការ ៤ ដើម្បីរក្សាការពារសន្ដិសុខមនុស្ស :

  ១- ត្រូវពង្រឹងប្រព័ន្ធតុលាការដើម្បីឱ្យរាស្ដ្រមានជំនឿ។

  ២- ត្រូវពង្រឹងអាជ្ញាធរ និងអ្នកមានសមត្ថកិច្ច។

  ៣- ត្រូវចូលរួមទប់ស្កាត់ការសម្លាប់ជីវិតមនុស្សក្រៅច្បាប់។

៤_ ត្រូវលើកកំពស់ការអប់រំសីលធម៌ និងគុណធម៌ជាតិ។

## ២_ ឯកឧត្តម ឧត្តមសេនីយ៍ទោ ណើម សុវត្ថិ អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា នាយកដ្ឋាននយោបាយ និងផែនការ ក្រសួងការពារជាតិ :

- សន្តិសុខមនុស្សមានអត្ថន័យទូលំទូលាយ និងខុសគ្នាទៅតាមតំបន់ កាលៈទេសៈ និងបរិស្ថាន។ សន្តិសុខមនុស្សមាន៧យ៉ាងគឺ ៖

  ១) សន្តិសុខសេដ្ឋកិច្ច

  ២) សន្តិសុខស្បៀងអាហារ

  ៣) សន្តិសុខជាតិ

  ៤) សន្តិសុខបរិស្ថាន

  ៥) សន្តិសុខបុគ្គល

  ៦) សន្តិសុខសហគមន៍

  ៧) សន្តិសុខនយោបាយ និងសន្តិសុខខាងសុខភាព។

- គោលនយោបាយ "ឈ្នះ_ឈ្នះ" របស់រាជរដ្ឋាភិបាលដែលកងខេមរភូមិន្ទយកទៅអនុវត្ត មានគោលដៅលើកស្ទួយសន្តិសុខរបស់កងកម្លាំងផ្តាច់ខ្លួនបីយ៉ាងគឺ :

  ១) ធានាអាយុជីវិតរបស់ជនផ្តាច់ខ្លួន

  ២) រក្សាឋានន្តរស័ក្តិរបស់ជនផ្តាច់ខ្លួន

៣) ធានាកម្មសិទ្ធិដីធ្លី ឬទ្រព្យសម្បត្តិរបស់ជនផ្ទាល់ខ្លួន។

- តួនាទីសំខាន់បីរបស់កងខេមរភូមិន្ទ ៖

១) ជាពលរដ្ឋ

២) ជាយុទ្ធជន

៣) ជាពលរដ្ឋដែលមានការទទួលខុសត្រូវ។

ក្នុងសម័យក្រោយសង្គ្រាមនេះ កងខេមរភូមិន្ទ នៅតែមានតួនាទីរស់នៅជាមួយប្រជាពលរដ្ឋជាដរាប។ ក៏ប៉ុន្តែ ភារកិច្ចក្នុងការរក្សាការពារសន្តិសុខប្រជាពលរដ្ឋ ត្រូវបានផ្ទេរជូនទៅកងនគរបាលជាតិ និងកងរាជអាវុធហត្ថ។ កងកម្លាំងយោធា គ្រាន់តែចាំជួយសហការណ៍តែប៉ុណ្ណោះ។ ក្រោយសមាហរណកម្ម នៃកងកម្លាំងប្រដាប់អាវុធពីគ្រប់ភាគីមកកងខេមរភូមិន្ទមិនបានគិតពីអតីតភាពទៀតទេ។

- កងខេមរភូមិន្ទត្រូវការធនធានមួយចំនួនដើម្បីបំពេញភារកិច្ច។ ថវិកាកងទ័ពដែលឮថាមានចំនួន៨០លានដុល្លារអាមេរិក នោះបើគិតទៅតាមតួលេខនិងចំនួនកងទ័ពទាំងអស់បានក្នុងម្នាក់ៗតែ$៥០ប៉ុណ្ណោះក្នុងមួយខែ។
- ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍធនធានមនុស្សអង្គការសង្គមស៊ីវិលកម្ពុជាមានភារកិច្ចជួយពីក្រោមឡើងលើ។ រីឯស្ថាប័នរដ្ឋវិញត្រូវធ្វើពីលើចុះក្រោម។

- កង្វះខាតរបស់សង្គមជាតិ សព្វថ្ងៃគឺការខ្វះខាតធនធានមនុស្សនិងធនធានសេដ្ឋកិច្ច។

II- លទ្ធផលនៃកិច្ចពិភាក្សាក្រុមមូល :

១_ ទស្សនៈរួម :

- ទ្រព្យសម្បត្តិ ដ៏ប្រសើរលើសទ្រព្យសម្បត្តិទាំងឡាយរបស់ប្រទេសជាតិមួយនោះគឺប្រជាពលរដ្ឋ។ បើគ្មានប្រជាពលរដ្ឋ ប្រទេសជាតិក៏គ្មានដែរ។

បើប្រជាពលរដ្ឋទទួលការជិះជាន់សង្កត់សង្កិន ការរំលោភបំពាន ឬការគំរាមកំហែងលើរូបរាងកាយ ក៏ដូចជាចិត្តគំនិត ប្រទេសជាតិនោះក៏ទទួលការជិះជាន់ការគំរាមកំហែងនិងការរំលោភបំពានដូចប្រជាពលរដ្ឋដែរ។

បើប្រជាពលរដ្ឋ ឈឺល្ងង់ខ្លៅ គ្មានការងារធ្វើឬក្រីក្រល្ហែមល្ហាម ប្រទេសជាតិនោះក៏មានសភាពដូចគ្នានេះដែរ។

- សន្តិសុខរបស់មនុស្សគឺជាប្រការចាំបាច់ដែលត្រូវតែយកចិត្តទុកដាក់ ព្រោះជាសិទ្ធិនៃការរស់នៅនិងអាយុជីវិតរបស់គេ។ រដ្ឋដែលមិនបាន គិតគូរពីសន្តិសុខរបស់ប្រជាពលរដ្ឋ ពុំមែនជារដ្ឋរបស់ប្រជាពលរដ្ឋឡើយ (Non-democratic State)។

២_ ចំណេះដឹងជាបទពិសោធន៍ :

→ សន្តិសុខរបស់មនុស្សនៅសម័យសង្គ្រាមត្រជាក់ គឺវាប៉ះពាល់ដោយសព្វាវុធ។ ក៏ប៉ុន្តែ សន្តិសុខមនុស្សក្នុងសម័យនេះ គឺពុំមែនតែប៉ះពាល់ដោយអាវុធទេ គឺវាប៉ះពាល់ដល់សិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ ឯករាជភាពបុគ្គល មនុស្សធម៌ និងសារធាតុពិតរបស់មនុស្សពីធម្មជាតិផង។

→ ប្រជាពលរដ្ឋម្នាក់ៗមានតួនាទី និងភារកិច្ចជួយរក្សាការពារនិងលើកស្ទួយសន្តិសុខរបស់ប្រជាពលរដ្ឋ។ ក៏ប៉ុន្តែដើម្បីឱ្យការងារនេះមានប្រសិទ្ធភាព អាជ្ញាធរ មូលដ្ឋាន កងកម្លាំងយោធានគរបាល និងភ្នាក់ងារមានសមត្ថកិច្ច គួរតែធ្វើគំរូឈានមុខក្នុងបញ្ហានេះ។

→ បញ្ហាអសន្តិសុខរបស់សង្គម គឺមនុស្សជាអ្នកបង្កើត។ ដូច្នេះដើម្បីរក្សាការពារសន្តិសុខសង្គម គេត្រូវអប់រំ កុំឱ្យមនុស្សប្រព្រឹត្តអំពើអាក្រក់ឱ្យមនុស្សធ្វើតែអំពើល្អនិងអប់រំចិត្តឱ្យបរិសុទ្ធទន្ទឹមនឹងការប្រើប្រាស់ប្រសិទ្ធិភាពច្បាប់។

→ ហេតុដែលនាំឱ្យមានការរំលោភសន្តិសុខឬសិទ្ធិមនុស្ស គឺព្រោះតែភាពល្ងង់ខ្លៅ។ គឺភាពល្ងង់ខ្លៅនេះហើយដែលនាំឱ្យមនុស្សលោភលន់កេងប្រវ័ញ្ច ខឹងសម្បារ ស្អប់ខ្ពើមគ្នានិងពុករលួយ។ គឺមានតែការខិតខំរំដោះមនុស្សឱ្យរួចផុត ពីភាពល្ងង់ខ្លៅនេះទេ ទើបមនុស្សឈប់ប៉ះពាល់ដល់សន្តិសុខរបស់អ្នកដទៃ ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងធម្មជាតិ។

→ បញ្ហាសន្តិសុខរបស់ប្រជាពលរដ្ឋ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរ ព្រោះអាជ្ញាធរជាអ្នកគ្រប់គ្រងសង្គម។ បើអាជ្ញាធរមិនអើពើចំពោះសន្តិសុខនេះទេ នោះសង្គមលែងមានសន្តិសុខហើយ។

៣_ តួនាទីរបស់សង្គមស៊ីវិលក្នុងការរក្សាការពារសន្តិសុខមនុស្ស:

→ យកចិត្តទុកដាក់ជួយទប់ស្កាត់ការរំលោភសិទ្ធិមនុស្សនិងសន្តិសុខរបស់ប្រជាពលរដ្ឋតាមរយៈការជួយបណ្តុះបណ្តាល និងអប់រំអំពីសិទ្ធិមនុស្ស សំរាប់មនុស្សគ្រប់រូបក្នុងសង្គម ជាពិសេសគឺអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ នគរបាល រាជអាវុធហត្ថ និងអ្នកដែលមានសមត្ថកិច្ចទទួលខុសត្រូវក្នុងការដឹកនាំនិងគ្រប់គ្រងសង្គម។

→ ជួយពង្រឹងធម្មាធិបតេយ្យ (ការគោរពច្បាប់ជាធំ) និងអភិបាលកិច្ចល្អ ទប់ស្កាត់ការកើនឡើង នៃនិទណ្ឌភាព (Impunity) ការកាប់សម្លាប់ក្រៅច្បាប់ ភាពអយុត្តិធម៌ ក្នុងការវិនិច្ឆ័យទោសពិរុទ្ធជន និងអំពើរំលោភសិទ្ធិមនុស្ស។

→ ជួយតាមដានឃ្លាំមើល ការអនុវត្តន៍ច្បាប់ក្នុងទីឃុំឃាំង ការរំលោភសិទ្ធិមនុស្ស នៅតាមមូលដ្ឋាន ការកាប់សម្លាប់ជីវិតមនុស្សក្រៅច្បាប់ ការប្រើអំណាចផ្តាច់ការទៅលើជនស្លូតត្រង់ ពិសេសគឺទៅលើស្ត្រីនិងកុមារដើម្បីរាយការណ៍ជូនទៅអាជ្ញាធរដែលពាក់ព័ន្ធ (រដ្ឋាភិបាល) ដើម្បីមានវិធានការទប់ស្កាត់និងផ្តន្ទាទោសចំពោះជនខិលខូច ដែលរំលោភច្បាប់នោះ។

→ ជួយកាត់បន្ថយភាពក្រីក្រនិងបន្តការយកចិត្តទុកដាក់លើកស្ទួយការអប់រំសីលធម៌ និងគុណធម៌ផ្លូវចិត្ត (ឱ្យមនុស្សចេះស្រឡាញ់មនុស្ស អាណិតអាសូរមនុស្ស មិនរំលោភ ឬសម្លាប់ជីវិតមនុស្ស) តាមគ្រួសារ សាលារៀន កន្លែងធ្វើការងារ និងក្នុងសង្គមជាតិទាំងមូល។ ការលើកស្ទួយការអប់រំព្រហ្មវិហារធម៌និងការលើកលែងទោស តាមរយៈទស្សនវិជ្ជាសាសនា គឺជាការសំខាន់ណាស់ ដើម្បីជួយកាត់បន្ថយអំពើហិង្សា ការរំលោភសិទ្ធិមនុស្ស និងការកាប់សម្លាប់។

→ ត្រូវប្រកាន់ជំហរជាអ្នកអប់រំផង និងជាដៃគូដ៏ល្អរបស់រាជរដ្ឋាភិបាលផង ក្នុងការរក្សាការពារសន្តិសុខរបស់ប្រជាពលរដ្ឋ។ ដោយមានធម្មជាតិកំណើតរស់នៅជិតស្និទ្ធ ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិលត្រូវខិតខំជួយអប់រំប្រជាពលរដ្ឋ កុំឱ្យប្រើប្រាស់អំពើហិង្សារំលោភគ្នាទៅវិញទៅមក និងឱ្យចេះដោះស្រាយបញ្ហាដោយការសម្របសម្រួល ការអាណិតអាសូរ ការលើកលែងទោសនិងតាមផ្លូវច្បាប់។

សង្គមស៊ីវិលត្រូវចេះអប់រំខ្លួនឯងមុនអ្នកដទៃ ហើយអ្វីដែលសំខាន់ នោះគឺត្រូវចេះជួយកែប្រែអ្វី ដែលខុសឱ្យទៅជាល្អឡើងវិញ។

## ៤_ សំណូមពរ និង អនុសាសន៍

- ស្នើសុំ និងអំពាវនាវឱ្យអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ជួយតាមដានពិនិត្យមើលនិងប្រមូលផ្ដុំគ្នាទទួលពត៌មានឬពាក្យបណ្ដឹងអំពីការរំលោភសិទ្ធិ និងសន្តិសុខមនុស្ស ដើម្បីរាយការណ៍ជូនអង្គការមានសមត្ថកិច្ចនិងរដ្ឋាភិបាល។

→ ស្នើសុំបង្កើតឱ្យមាន "សមាគមអ្នកប្រើប្រាស់ គ្រឿងឧបភោគបរិភោគ" ដើម្បីជួយតាមដាន និងត្រួតពិនិត្យគ្រឿងបរិភោគ និងឧបភោគកុំឱ្យប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ។

→ ស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ មេត្តាជួយយកចិត្តទុកដាក់ដល់ការរំលោភសិទ្ធិមនុស្ស ការចាប់ជំរិតមនុស្សការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខបរិស្ថានអំពើឆក់ប្លន់ ដើម្បីធានាឱ្យបានល្អនូវសន្តិសុខរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម។

→ ស្នើសុំឱ្យរាជរដ្ឋាភិបាល មានវិធានការទប់ស្កាត់អំពើពុករលួយក្នុងតុលាការ ទប់ស្កាត់និងផ្ដន្ទាទោស ជនសម្លាប់មនុស្សក្រៅច្បាប់ពង្រឹងប្រព័ន្ធតុលាការឱ្យមានយុត្តិធម៌ លើកស្ទួយការអប់រំសីលធម៌សង្គម គុណធម៌ជាតិ ដើម្បីលុបបំបាត់អំពើហិង្សាការរំលោភសេចក្ដីសុខសាន្តរបស់ប្រជាពលរដ្ឋ និងការកាប់សម្លាប់ជីវិតមនុស្សក្រៅច្បាប់។

→ ស្នើសុំឱ្យរដ្ឋាភិបាលទទួលស្គាល់នូវតួនាទីរបស់សង្គមស៊ីវិលក្នុងការជួយតាមដានពិនិត្យមើល នូវការអនុវត្តន៍កម្មវិធីនយោបាយ

របស់រដ្ឋាភិបាល ក្នុងការរក្សាការពារសិទ្ធិមនុស្សនិងសន្តិសុខរបស់ប្រជាពលរដ្ឋ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលកែលំអការខុសឆ្គងឱ្យបានទាន់ពេលវេលា សំដៅពង្រឹងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើអាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាលក្នុងការក្សាការពារសន្តិសុខរបស់ប្រជាពលរដ្ឋ។

## III. សេចក្ដីសន្និដ្ឋាន :

- សន្តិសុខរបស់មនុស្ស ឬប្រជាពលរដ្ឋមានអត្ថន័យគ្របដណ្ដប់ជាសំខាន់ទៅលើសិទ្ធិនៃការរស់នៅ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ។
- ការបាត់បង់នូវសន្តិសុខមនុស្ស គឺជាការបាត់បង់នូវសិទ្ធិនៃការរស់នៅនិងអាយុជីវិតរបស់ប្រជាពលរដ្ឋ ។
- សន្តិសុខរបស់មនុស្ស ឬប្រជាពលរដ្ឋនឹងរក្សាការពារបានលុះណាតែ ៖

(១)_គ្មានចម្បាំង (២)_មានសន្តិភាពពិតប្រាកដ (៣)_អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់មានការទទួលខុសត្រូវ (៤)_មនុស្សគ្រប់គ្នាគោរពច្បាប់ (៥)_សង្គមមានយុត្តិធម៌ (៦)_រាជរដ្ឋាភិបាលមានវិធានការតឹងរឹងក្នុងការផ្ដន្ទាទោស ជនរំលោភច្បាប់ ជនរំលោភសិទ្ធិមនុស្ស ជនសម្លាប់ជីវិតមនុស្សក្រៅច្បាប់ និង(៧)_សង្គមមានសីលធម៌ និងគុណធម៌ខ្ពស់។

ផ្ទុយទៅវិញ បើគ្មានលក្ខណៈសម្បត្តិនេះទេ នោះសង្គមជាតិនឹងត្រូវទទួលការរំលោភ អសន្តិសុខ អស្ថេរភាព អសុវត្ថិភាព ចម្បាំង និងភាពវិនាសសាបសូន្យ៕

## ២.៦ កិច្ចពិភាក្សាតុមូលលើកទី ៦

- ប្រធានបទនៃការពិភាក្សា ស្តីពី "គម្រោងច្បាប់ និងសង្គមស៊ីវិលកម្ពុជា : ស្ថានការណ៍ ការប្រឈមមុខនិងក្តីសង្ឃឹមនៅអនាគត"
- គណៈវាគ្មិនកិត្តិយស : (១)_ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងនៃអគ្គនាយកដ្ឋាន រដ្ឋបាលនៃក្រសួងមហាផ្ទៃ : (២)_លោក សុខ សំអឿន នាយកប្រតិបត្តិក្រុមអ្នកច្បាប់ សិទ្ធិមនុស្សអន្តរជាតិប្រចាំនៅកម្ពុជា។

### ខ្លឹមសារសង្ខេប

I_ មតិ និងទស្សនៈរបស់គណៈវាគ្មិនកិត្តិយស :

១_ <u>ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងនៃអគ្គនាយកដ្ឋាន រដ្ឋបាលនៃក្រសួងមហាផ្ទៃ</u> :

- **អំពីស្ថានការណ៍ បច្ចុប្បន្ននៃអង្គការសង្គមស៊ីវិល និងការរៀបចំក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងអង្គការសង្គមស៊ីវិល :**

→ អង្គការ NGOs និងសមាគមនានា គឺជាផ្នែកមួយនៃសង្គមស៊ីវិលកម្ពុជា។ តាមមាត្រា៤២ នៃច្បាប់រដ្ឋធម្មនុញ្ញ។ ប្រជា

ពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ តែត្រូវកំណត់នៅក្នុងច្បាប់មួយ។ ច្បាប់គ្រប់គ្រង NGOs និងសមាគមត្រូវបានព្រាងចាប់តាំងពីអាណត្តិទី១ នៃរាជរដ្ឋាភិបាលកម្ពុជាមកម្ល៉េះ (១៩៩៣_១៩៩៨)។ ដោយមានការតវ៉ាទាមទារមួយចំនួនពីអង្គការ NGOs ការសំរេចច្បាប់នេះ ក៏ត្រូវអាក់ខានទៅវិញ។

→ ថ្វីបើគ្មានច្បាប់គ្រប់គ្រងមែនតែចំនួនអង្គការ NGOs ក្នុងស្រុកសព្វថ្ងៃនេះ មានចំនួនកើនឡើងដល់៧៥៧អង្គការទៅហើយ។ ក្នុងស្ថានភាព ដែលពុំទាន់មានច្បាប់គ្រប់គ្រងនេះ យើងមានការលំបាកជាច្រើន។

❖ **អំពីការរៀបចំក្របខ័ណ្ឌច្បាប់ NGOs :**

→ ក្នុងអាណត្តិទី២ (១៩៩៨_២០០៣) នេះក្រសួងមហាផ្ទៃបានកែសំរួលច្បាប់ នេះជាលើកទី២ និងបានដាក់ជូនទៅ ទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីសំរេចមុន នឹងផ្ញើជូនទៅរដ្ឋសភាហើយ។ ច្បាប់នេះគ្មានដាក់លក្ខខ័ណ្ឌ អ្វីធ្ងន់ធ្ងរដល់អង្គការ NGOs និងសមាគមឡើយ គឺគ្រាន់តែនិយាយអំពីការកើត និងការគ្រប់គ្រងព្រមទាំងសុំឱ្យ បំពេញទម្រង់បែបបទមួយចំនួនតែប៉ុណ្ណោះ។ ក្រោយពេលដែលអង្គការនីមួយៗ បានដាក់ពាក្យសុំទៅក្រសួងមហាផ្ទៃហើយ ប្រសិនបើក្រសួងនេះមិនបានឆ្លើយតបវិញក្នុង

រយៈពេល ៤៥ថ្ងៃទេ អង្គការ NGOs ឬសមាគមក្នុងស្រុក អាចប្ដឹងទៅតុលាការបាន។

→ ច្បាប់គ្រប់គ្រងអង្គការ NGOs នេះ មានតែ ២៩ មាត្រាទេ។ ក្នុងមាត្រាទាំងនោះ ក៏មានចែងច្បាស់អំពីប្រភពធនធានផ្សេងៗ របស់អង្គការ NGOs និងការរំសាយអង្គការផងដែរ។ ច្បាប់ នេះមិនបានចែងពីការគ្រប់គ្រងអង្គការ NGOs អន្តរជាតិទេ ហើយ ក៏មិនបាននិយាយអំពីការគ្រប់គ្រងអង្គការសហជីពផង ដែរ។

→ ក្រសួងមហាផ្ទៃ គ្មានបំណងយកអំណាចឬ ឥទ្ធិពលរបស់ខ្លួន មករឹតត្បិតឬកៀបសង្កត់អង្គការ NGOs តាមរយៈច្បាប់នោះ ឡើយ។ បំណងពិតប្រាកដនោះគឺដើម្បីឱ្យអង្គការ NGOs និង សមាគម ក្នុងស្រុកបានក្លាយជាដៃគូពិតប្រាកដរបស់អាជ្ញាធរ និងរាជរដ្ឋាភិបាលក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ យើង។

២_ <u>លោក សុខ សំអឿន នាយកប្រតិបត្តិក្រុមអ្នកច្បាប់សិទ្ធិមនុស្ស អន្តរជាតិប្រចាំនៅកម្ពុជា</u> :

→ ថ្វីបើសិទ្ធិ នៃការបង្កើតអង្គការនិងសមាគមក្នុងស្រុកនានា ត្រូវ បានចែងក្នុងរដ្ឋធម្មនុញ្ញ និងកំណត់ដោយច្បាប់មួយ ក៏ប៉ុន្តែ រាជរដ្ឋាភិបាល គួរតែប្រយ័ត្នប្រយែងក្នុងការបង្កើតច្បាប់នេះ ដើម្បីការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ច្បាប់នេះត្រូវ

ផែនានា និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការបង្កើតអង្គការ និងសមាគមនានា ដើម្បីជួយស្ថាបនានិងអភិវឌ្ឍប្រទេសជាតិ។

→ ការធ្វើច្បាប់នេះ គួរតែគ្របដណ្ដប់ទៅលើគ្រប់ទិដ្ឋភាពនៃអង្គការ NGOs និងសមាគម និងគួរតែមានការចូលរួមមតិរបស់អង្គការ និងសមាគមផង មិនគួរយកតាមតែមតិរបស់អ្នកជំនាញការខាងច្បាប់ឡើយ។ ច្បាប់នេះ គួរតែតម្រូវទៅតាមសំណូមពរ និងសេចក្ដីត្រូវការរបស់អង្គការ និងសមាគម "មិនគួរកាត់ជើង តម្រូវតាមស្បែកជើងឡើយ"។

→ ច្បាប់នេះ ត្រូវតែសរសេរឱ្យច្បាស់ ដើម្បីចៀសវាងកុំឱ្យអ្នកអនុវត្តពង្រីកឱ្យខុចអត្ថន័យច្បាប់។

→ ច្បាប់នេះ គួរតែគោរពសេរីភាពរបស់ប្រជាពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញឱ្យបានច្រើន ជាងការគ្រប់គ្រង និងការរក្សាសណ្ដាប់ធ្នាប់។

## II អំពីលទ្ធផលនៃការពិភាក្សារួម :

១- ការបង្កើតច្បាប់គ្រប់គ្រងអង្គការ NGOs និងសមាគមនានាគួរតែឈរលើមូលដ្ឋាននៃសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ការព្រាងច្បាប់នេះ គួរតែមានការស្ទាបស្ទង់ និងពិគ្រោះយោបល់ជាមួយថ្នាក់ក្រោមផង។ បើពុំដូច្នោះទេ

ច្បាប់នោះពុំមានចរិតបំរើផលប្រយោជន៍ និងការពារផលប្រយោជន៍ ក៏ដូចជាសិទ្ធិសេរីភាពរបស់សង្គមស៊ីវិលឡើយ។

២_ អង្គការសង្គមស៊ីវិលគឺជាកម្លាំងឈានមុខមួយ (A driving Force) ដែលជួយជំរុញឱ្យកម្ពុជាក្លាយជានីតិរដ្ឋពិតប្រាកដ។ ការដែលអង្គការ និងសមាគមក្នុងស្រុកនានា ខិតខំទៅចុះ បញ្ជីជាមួយក្រសួងមហាផ្ទៃ នោះគឺជាការគោរពច្បាប់មួយហើយ។ ដើម្បីឱ្យច្បាប់គ្រប់គ្រងអង្គការ NGOs និងសមាគមនោះទទួលយក បាននិងគោរពទាំងអស់គ្នាការពិគ្រោះ និងផ្លាស់ប្តូរយោបល់រវាងថ្នាក់លើ និងថ្នាក់ក្រោមរវាងរួមនិងដោយឡែកគឺជាការចាំបាច់ណាស់។

៣_ ដើម្បីឱ្យប្រទេសជាតិយើងក្លាយជានីតិរដ្ឋពិតប្រាកដចាំបាច់ត្រូវតែមានច្បាប់ត្រឹមត្រូវ និងការគោរពច្បាប់ផង។ តាមបទពិសោធន៍នៃប្រទេសជប៉ុន ច្បាប់គ្រប់គ្រងអង្គការ និងសមាគមនានា ត្រូវបានព្រាងឡើងដោយអង្គការនិងសមាគមនោះខ្លួនឯង។ រដ្ឋាភិបាលគ្រាន់តែចាំពិនិត្យកែលំអ និងធ្វើការអនុម័តតែប៉ុណ្ណោះ។ ជាលទ្ធផល ច្បាប់នេះត្រូវបានអនុវត្តយ៉ាងល្អប្រសើរ។ ប្រទេសជាតិយើងក៏គួរតែពិនិត្យពិចារណា និងដកពិសោធន៍តាមប្រទេសជប៉ុនផងដែរ ដើម្បីបង្កើតច្បាប់គ្រប់គ្រងមួយ ដែលមានលក្ខណៈប្រជាធិបតេយ្យ និងធានាសេរីភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ។

៤_ សេចក្តីព្រាងច្បាប់គ្រប់គ្រង NGOs និងសមាគមខ្មែរពុំមែនត្រូវបានព្រោងឡើងដោយ គ្មានការពិគ្រោះយោបល់ជាមួយអង្គការ

NGOs និងសមាគមទេ។ ការពិតច្បាប់នេះត្រូវបានកែសំរួលតាមសំណូមពររបស់អង្គការនិងសមាគមយើងពីរដងរួចមកហើយ។ ការព្រាងច្បាប់នេះ ជាបឋមត្រូវបានគិតពីទិដ្ឋភាពនយោបាយ បន្ទាប់មកទើបគិតពីទិដ្ឋភាពច្បាប់។ អ្នកជំនាញការខាងច្បាប់ជាតិ និងអន្តរជាតិនៃក្រសួងមហាផ្ទៃបានចុះទៅស្ទាបស្ទង់មតិតាមបណ្តាអង្គការនិងសមាគមមូលដ្ឋាននានា រួចយកមតិទាំងនោះមកគ្រោងច្បាប់ រួចដាក់ជូនអង្គសិក្ខាសាលាដែលមានការចូលរួមផ្តល់មតិពីអ្នកតំណាងអង្គការនិងសមាគមនានាផងដែរ។ ជាការពិតណាស់ រាល់ច្បាប់តែដាក់ទៅហើយមិនអាចតម្រូវចិត្តមនុស្សបានគ្រប់ៗគ្នាទេ។ ក៏ប៉ុន្តែ ការគាំទ្រភាគច្រើន គឺជាការចាំបាច់ណាស់។

៥_ ដោយស្ថិតក្នុងស្ថានភាពគ្មានច្បាប់គ្រប់គ្រងនេះមានអង្គការ NGOs និងសមាគមមួយចំនួនបានឆ្លៀតយកសិទ្ធិស្របច្បាប់ ក្នុងការនាំចូលសំភារៈ រួចពន្ធទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យខូចដល់កិត្យានុភាពនៃអង្គការ និងសមាគមដទៃទៀត។ ការស្នើសុំដីធ្លីពីរដ្ឋាភិបាលយកទៅចែកគ្នាជាកម្មសិទ្ធិបុគ្គល ឬលក់យកកម្រៃចែកគ្នាជម្លោះផ្ទៃក្នុង គណៈកម្មាធិការដឹកនាំនិងគ្រប់គ្រងរបស់ខ្លួន គឺជាបច្ច័យអាក្រក់ ដែលនាំឱ្យត្រីមួយត្រកស្អុយមួយស្អុយទាំងអស់។ ចំពោះបញ្ហានេះ អង្គពិភាក្សាបានស្នើសុំឱ្យក្រសួងមានសមត្ថកិច្ច តាមដានពិនិត្យឱ្យឃើញ ការពិតជាក់ស្តែងនិងផ្តន្ទាទោសជនខិលខូច ដែលធ្វើឱ្យប៉ះពាល់ដល់ កិត្តិយស និងភាពស្អាតស្អំរបស់អង្គការ និងសមាគមនានា។

៦_សំណូមពររបស់អង្គការ និងសមាគមទាំងឡាយដែលចង់ស្នើសុំឱ្យមានការកែសំរួលខ្លឹមសារមាត្រាខ្លះនៃច្បាប់ NGOs ដើម្បីឱ្យស្របតាមមតិនិងយោបល់របស់ខ្លួននោះ ពុំទាន់ឃើញយ៉ាងនៅឡើយទេ។ អង្គការ និងសមាគមទាំងអស់អាចមានលទ្ធភាពពីរយ៉ាងគឺ (១)_ធ្វើអនុសាសន៍ជាលាយលក្ខណ៍អក្សរ ផ្ញើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី និង(២)_ស្នើសុំជួបជាមួយអ្នកតំណាងរាស្ត្រនៅមណ្ឌលរបស់ខ្លួន ដើម្បីឱ្យជួយយកសំណូមពរ ឬមតិរបស់ខ្លួនទៅពិនិត្យពិចារណាមុននឹងធ្វើការអនុម័តច្បាប់នោះ។

## III_ អំពីសំណូមពរ និងអនុសាសន៍ :

- ស្នើសុំឱ្យក្រសួងមហាផ្ទៃ (តាមរយៈ ឯកឧត្តម សក់ សេដ្ឋា) ពិនិត្យពិចារណា ពីស្ថិតិជាតួលេខពិតប្រាកដរបស់អង្គការ NGOs និងសមាគមក្នុងស្រុកឡើងវិញ ព្រោះតាមរបាយការណ៍របស់ក្រុមប្រឹក្សាកម្ពុជាដើម្បីអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវរបស់យើងឃើញមានចំនួនអង្គការជាច្រើន ដែលមានតែឈ្មោះ ក្នុងបញ្ជីតែគ្មានរូបភាព និងការិយាល័យធ្វើការងារពិតប្រាកដទេ។ ការកំណត់បាននូវស្ថិតិ និងសកម្មភាពរបស់អង្គការ និងសមាគមនេះច្បាស់លាស់ មានសារៈសំខាន់ណាស់ដល់ការគ្រប់គ្រង និងការអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលឱ្យល្អប្រសើរនៅអនាគត។
- ស្នើសុំឱ្យវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពធ្វើការប្រជុំតុមូលមួយទៀត ស្តីពី "គម្រោងច្បាប់នេះនិងសង្គមស៊ីវិល

កម្ពុជា" ដោយមានច្បាប់ក្នុងដៃគ្រប់គ្នា ដើម្បីងាយស្រួលដល់ការមានមតិកែលំអ។ នាយកប្រតិបត្តិ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាពបានបំភ្លឺថា ការប្រជុំលើកនេះគ្រាន់តែជាការប្រមូលផ្តុំទស្សនៈរួមតែប៉ុណ្ណោះ។ តាមគម្រោងកម្មវិធីនៃការប្រជុំតុមូល ស្តីពី ច្បាប់នេះនឹងមានធ្វើសារជាថ្មីម្តងទៀត ដោយស្នើសុំគម្រោងច្បាប់ ពីទីស្តីការគណៈរដ្ឋមន្ត្រី មកដាក់ជូនពិភាក្សាតាមសំណូមពរជាក់ស្តែងតែម្តង។

- ស្នើសុំឱ្យរាល់សេចក្តីព្រាងច្បាប់ទាំងឡាយ របស់រដ្ឋាភិបាលឬរបស់សមាជិកសភាជាតិ មុននឹងអនុម័ត គួរមានការចូលរួមមតិពិភាក្សារបស់មហាជននិងប្រជាពលរដ្ឋផង។ ធ្វើដូច្នេះបាននោះការអនុវត្តន៏ច្បាប់នេះនឹងកាន់តែបំរើបានសំណូមពរសេចក្តីត្រូវការរបស់សង្គមនិងផលប្រយោជន៏របស់ប្រជាពលរដ្ឋ។
- ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ក្នុងស្ថានភាពដែលពុំទាន់មានច្បាប់ការពារសិទ្ធិ និងសកម្មភាពរបស់ខ្លួននេះ ប្រកាន់គោលជំហរឱ្យបានល្អត្រឹមត្រូវតាមច្បាប់គ្រប់គ្រងសង្គម និងពលរដ្ឋ ដោយត្រូវចៀសវាងដាច់ខាត នូវរាល់ទង្វើណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងភាពបរិសុទ្ធពិតត្រង់របស់អង្គការសង្គមស៊ីវិលក្នុងការបំរើផលប្រយោជន៏សង្គម និងប្រជាពលរដ្ឋ។

រាល់សកម្មភាពទាំងឡាយណា ដែលស្តែងឱ្យឃើញនូវការកេងប្រវ័ញ្ចន៏ផលប្រយោជន៏រួមមកធ្វើជាផលប្រយោជន៏បុគ្គលដោយខុសនឹង

គោលដៅពិតប្រាកដរបស់អង្គការសង្គមស៊ីវិលកម្ពុជា ជាទូទៅត្រូវតែទទួលខុសត្រូវនៅចំពោះមុខច្បាប់។

## IV. សេចក្តីសន្និដ្ឋាន :

ជារួមកិច្ចប្រជុំតុមូលលើកទី៦ ស្តីពី "គម្រោងច្បាប់និងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា : ស្ថានភាពណ៍ ការប្រឈមមុខ និងក្តីសង្ឃឹមនៅអនាគត" បានទទួលលទ្ធផលល្អ។

ដោយមានវត្តមាន ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ ដែលបានចូលរួមជាគណៈវាគ្មិនកិត្តិយសអង្គពិភាក្សាបានប្រព្រឹត្តទៅដោយការយោគយល់។ សេចក្តីព្រាងច្បាប់នោះ គ្មានបំណងអ្វីរឹតត្បិតឬកៀបសង្កត់អង្គការ និងសមាគមនានា ក្រៅពីការលើកកំពស់ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុនៃការស្ថាបនានិងអភិវឌ្ឍន៍ប្រទេសជាតិក្រោយសម័យសង្គ្រាមឱ្យមានភាពរីកចំរើនជឿនលឿន និងរុងរឿងទៅអនាគតទេ។

ជាក្តីសង្ឃឹមទៅអនាគត ពុំមែនតែច្បាប់ NGOs និងសមាគមនេះទេ ដែលត្រូវមានការចូលរួមមតិពីមហាជន។ ច្បាប់ដទៃទៀតដែលនឹងត្រូវព្រាងឡើង ក៏នឹងទទួលយកមតិយោបល់របស់ថ្នាក់ក្រោមដែរ។ ធ្វើដូច្នេះ គឺដើម្បីច្បាប់ទាំងនោះមានចរិតបំរើ គាំពារនិងគោរព

ផលប្រយោជន៏របស់ប្រជាពលរដ្ឋខ្មែរ ស្របតាមលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

អង្គប្រជុំពិភាក្សាបានបញ្ចប់ទៅ ដោយស្មារតីសាមគ្គីសេចក្តីយោគយល់ និងបទពិសោធន៏ជាចំណេះដឹងល្អជាច្រើនដែលមានសារៈសំខាន់ដល់ការស្ថាបនា និងលើកកំពស់អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា៕

## ២_៧ កិច្ចពិភាក្សាតុមូលលើកទី ៧

- ប្រធានបទនៃការពិភាក្សាស្តីពី " ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធាន ពត៌មាន បទពិសោធន៍និងក្តីបារម្ភ "។
- គណៈវាគ្មិនកិត្តិយស : (១_) លោកស្រី ប្រុក រ៉ាន្នី នាយិកាប្រតិបត្តិអង្គការខេមរា[(២)] និង (២)_លោក ណែប ស៊ិនថៃ អ្នកសំរបសំរួលការងារប្រតិបត្តិក្រុមការងារ ដើម្បីកាត់បន្ថយអាវុធនៅកម្ពុជា :

### ខ្លឹមសារសង្ខេប

I- អំពីទស្សនៈរបស់វាគ្មិនកិត្តិយស :

១_ <u>លោកស្រី ប្រុក រ៉ាន្នី នាយិកាប្រតិបត្តិ អង្គការខេមរា</u>[(២)]

---

(2) *បើចង់ជ្រាប់ច្បាស់សូមអាន សុន្ទរកថារបស់លោកស្រី ប្រុក រ៉ាន្នី*

(2) *បើចង់ជ្រាប់ច្បាស់សូមអាន សុន្ទរកថារបស់លោកស្រី ប្រុក រ៉ាន្នី*

- អត្ថន័យជាមូលដ្ឋាននៃបណ្តាញសង្គមស៊ីវិល គឺជាប្រព័ន្ធទំនាក់ទំនងសហការគ្នាទៅវិញទៅមកក្នុងការចែកចាយបទពិសោធន៍ ពត៌មានផ្សេងៗដំណឹងសំខាន់ៗដែលអាចរៀនសូត្រ_អាចជាកម្លាំង_ជាការជួយគាំទ្រស្មារតីឬមធ្យោបាយផ្សេងៗ ដែលអាចធ្វើបានដើម្បីឱ្យបានសំរេចការងារល្អ (ការបកស្រាយនេះ សំដៅទៅលើតែអង្គការ NGOs)។

- បណ្តាញសង្គមស៊ីវិលកំពុងរីកចំរើនយ៉ាងខ្លាំង ហើយកើតមានឡើងគ្រប់ទីកន្លែង តាំងពីក្រុង ខេត្តរហូតដល់មូលដ្ឋាន។

- ជាលទ្ធផល ការស្ថាបនាបណ្តាញសង្គមស៊ីវិលកម្ពុជា ជានិច្ចកាលតែងបានធ្វើឡើង តាមរយៈការបើកវគ្គហ្វឹកហ្វឺន អប់រំ ការរៀបចំយុទ្ធសាស្ត្ររួមគ្នា ការប្រជុំសិក្សារៀនសូត្រដកពិសោធន៍ ប្រចាំខែប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

- បណ្តាញសង្គមស៊ីវិលខ្មែរ ពុំមានមែនតែក្នុងប្រទេសទេ គឺមានរហូតដល់ក្នុងតំបន់ជនបទ និងសហគមន៍អន្តរជាតិផងដែរ។

- ការកសាងបណ្តាញសង្គមស៊ីវិលកម្ពុជា មានទាំងចំណុចល្អ និងចំណុចមិនល្អ។ ចំណុចល្អបានធ្វើឱ្យអង្គការស៊ីវិលមានការរីកចំរើន។ តែចំណុចមិនល្អ បានធ្វើឱ្យការកសាងបណ្តាញសង្គមស៊ីវិលខុសគោលដៅបាត់ទំនាក់ទំនងល្អ ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។

- គោលដៅនៃការប្រើប្រាស់បណ្តាញសង្គមស៊ីវិល ពុំមែនដើម្បីហេតុផលនយោបាយបដិបក្ខទេ។ តែគឺដើម្បីបុព្វហេតុអភិវឌ្ឍន៍សេចក្តីសុខសន្តិភាពនិងការរំដោះប្រជាពលរដ្ឋឱ្យរួចផុតពីសេចក្តីក្រីក្រ។

២- លោក ណែប ស៊ិនថៃ អ្នកសំរបសំរួលការងារប្រតិបត្តិក្រុមការងារដើម្បីកាត់បន្ថយអាវុធនៅកម្ពុជា

- អត្ថន័យនៃពាក្យថា "បណ្តាញសង្គមស៊ីវិល" ដែលប្រៀបបាននឹងសំណាញ់ប្រទាក់ប្រឡាខ្វាត់ខ្វែងគ្នា ឬក៏ដូចជាប្រព័ន្ធទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិលទាំងមូល ដើម្បីសហការគ្នាធ្វើការងារអ្វីមួយឱ្យស្របទៅតាមបំណង និងសកម្មភាពរបស់ខ្លួន។
- បណ្តាញសង្គមស៊ីវិលកម្ពុជា មានប្រភេទខុសគ្នា-ខ្លះហៅថា ជាសម្ព័ន្ធ ជាសហព័ន្ធ ជាក្រុមការងារ ជាសហប្រតិបត្តិការឬជាគណៈកម្មការផ្សេងៗ ដើម្បីប្រមូលផ្តុំធ្វើការរួមគ្នា សំដៅបំរើផលប្រយោជន៍សមាជិកសង្គម និងប្រជាពលរដ្ឋ។

បណ្តាញអង្គការសង្គមស៊ីវិលមានជាអាទិ៍ បណ្តាញអង្គការសិទ្ធិមនុស្ស បណ្តាញ ដោះស្រាយទំនាស់ បណ្តាញក្រុមអ្នកច្បាប់ បណ្តាញអង្គការអភិវឌ្ឍន៍ បណ្តាញអប់រំសីលធម៌ សាសនា ។ល។ និង ។ល។។

- បណ្តាញនៃអង្គការសង្គមស៊ីវិលមានសារៈសំខាន់ណាស់ ដើម្បីចែករំលែកប្រភពធនធាន បទពិសោធន៍ ចំណេះដឹង ពត៌មាន និងក្តីកង្វល់សំរាប់ដោះស្រាយបញ្ហារួម។
- ប្រភពធនធានសង្គមស៊ីវិលមានច្រើនយ៉ាង ដូចជាធនធានមនុស្ស ធនធានថវិកា ចំណេះ ដឹងធនធានសំភារៈ និងបច្ចេកទេស។

ការរួមគ្នាបែងចែកធនធាន ពត៌មាន បទពិសោធន៍ និងក្តីបារម្ភនេះ នឹងជួយធ្វើឱ្យអង្គការសង្គមស៊ីវិលកាន់តែមានភាពរឹងមាំ។

ការបែងចែកពត៌មាន ទាំងនៅក្នុងស្រុក ទាំងនៅក្នុងតំបន់តាមរយៈ អ្នកផ្តល់ពត៌មាន ឬរបាយការណ៍តាមរយៈ E-mail, Internet ឬទូរស័ព្ទទាំងអស់នេះ ត្រូវតែមានមូលដ្ឋានប្រាកដនិយម (សច្ចធម៌)_ចៀសវាងការបែងចែក ឬផ្សព្វផ្សាយពត៌មានបំផ្លើសដែលនាំឱ្យមានផលអាក្រក់ដល់ការដោះស្រាយបញ្ហាឬការធ្វើសេចក្តីសំរេចចិត្ត។ ការចែករំលែកពត៌មានខុស នាំឱ្យមានការយល់ភាន់ច្រឡំ។ ការយល់ភាន់ច្រឡំនាំឱ្យមានការដោះស្រាយខុស

- សកម្មភាពនៃអង្គការកាត់បន្ថយសព្វាវុធ ដែលបានចូលរួមជាមួយរដ្ឋាភិបាល ដើម្បីរួមចំណែកពង្រឹងសន្តិសុខ សុវត្ថិភាពសង្គម និងសេចក្តីសុខសាន្តរបស់ប្រជាពលរដ្ឋ។

## II- អំពីលទ្ធផលនៃកិច្ចពិភាក្សា :

១_ បណ្តាញអង្គការសង្គមស៊ីវិលកម្ពុជាបាន និងកំពុងអភិវឌ្ឍន៍ទៅដល់មូលដ្ឋានរហូតទៅដល់ក្នុងតំបន់ និងអន្តរជាតិផង។

គោលដៅសំខាន់ នៃការស្ថាបនាបណ្ដាញអង្គការសង្គមស៊ីវិលនេះគឺដើម្បីចែករំលែកប្រភពធនធានពត៌មាន បទពិសោធន៍ចំណេះដឹង ក៏ដូចជាដើម្បីជួយដោះស្រាយទំនាស់ និងក្ដីកង្វល់របស់អង្គការសង្គមស៊ីវិលនីមួយៗ ដោយសន្តិវិធី និងអហិង្សាធម៌។

២. ការស្ថាបនាបណ្ដាញអង្គការសង្គមស៊ីវិល ខុសគោលដៅនឹងនាំមកនូវផលវិបាកជាច្រើនដល់អង្គមស៊ីវិលនឹងសង្គមជាតិ។ គោលដៅនៃស្ថាបនាបណ្ដាញសង្គមស៊ីវិល ពុំមែនដើម្បីហេតុផលនយោបាយបដិបក្ខទេ។ គោលដៅនៃការស្ថាបនាបណ្ដាញសង្គមស៊ីវិលគឺដើម្បីជួយពង្រឹងអង្គការសង្គមស៊ីវិលទាំងអស់ ឱ្យកាន់តែមានភាពរឹងមាំសំរាប់ជួយរក្សាការពារសេចក្ដីសុខសាន្ត សុភមង្គលរបស់ប្រទេស និងរំដោះជាតិឱ្យរួចផុតពីភាពក្រីក្រ និងទុរភិក្សអត់ឃ្លាន។

៣. បើចង់កែប្រែបណ្ដាញសង្គមស៊ីវិលឱ្យបានរឹងមាំគឺត្រូវកែប្រែមជ្ឈដ្ឋានសង្គមស៊ីវិល។ បើចង់កែប្រែមជ្ឈមដ្ឋានសង្គមស៊ីវិល គឺត្រូវកែប្រែមនុស្សក្នុងអង្គការសង្គមស៊ីវិលនោះ។ បើចង់កែប្រែមនុស្សក្នុងសង្គមស៊ីវិល គឺត្រូវកែប្រែទស្សនៈ និងផ្នត់គំនិតឬបេះដូងរបស់អ្នកទាំងនោះ។ បើកែប្រែដូច្នេះបាន នោះបណ្ដាញអង្គការសង្គមស៊ីវិលនឹងមានភាពរឹងមាំយូរអង្វែងទៅអនាគត។

ផ្ទុយទៅវិញ បើគ្រាន់តែកែប្រែប្រព័ន្ធ ឬបណ្ដាញសង្គមស៊ីវិលជាអត្តនោម័តទេ នោះបណ្ដាញអង្គការសង្គមស៊ីវិលមិនអាចមានភាពស្ថិតស្ថេរយូរអង្វែងទៅអនាគតឡើយ។

១. ការនិយាយស្រួលណាស់ តែការអនុវត្តន៍មានការលំបាកពន់ប្រមាណ។ បើគេចង់ស្ថាបនាបណ្តាញសង្គមស៊ីវិលមួយរឹងមាំគេគួរតែកំណត់សារៈ (Essence) ឱ្យបានមុនកំណើត (Existence) របស់វា។ បើចង់កសាងបណ្តាញសង្គមស៊ីវិលមួយឱ្យបានរឹងមាំគេគួរតែយល់ចិត្តយល់ថ្លើមគ្នាមានបំណងរួមដូចគ្នា មានបេះដូងតែមួយ មានផលប្រយោជន៍រួមគ្នា និងចេះយោគយល់គ្នា។ រាល់ការស្ថាបនាបណ្តាញដោយបង្ខំចិត្ត ឬដោយការកៀបសង្កត់ គឺជាការបំផ្លាញសេរីភាព នោះគឺជាការខុសឆ្គង។ ការកសាងបណ្តាញសង្គមស៊ីវិលគួរតែឈរលើការស្ម័គ្រចិត្ត និងសុឆន្ទៈរួម។ បើពុំដូច្នោះទេ បណ្តាញ នោះគ្រាន់តែមានឈ្មោះជាបណ្តាញគ្មានខ្លឹមសារស្អិតស្អែរអ្វីឡើយ។

២. ការកសាងបណ្តាញ អង្គការសង្គមស៊ីវិលមានសារៈសំខាន់ណាស់។ ពិភពលោក សព្វថ្ងៃឈានដល់រលកទីពហើយគឺរលកពត៌មាន។ រលកទីមួយ គឺរលកកសិកម្ម។ រលកទីពីរគឺរលកឧស្សាហកម្ម។ ការកសាងបណ្តាញសង្គមស៊ីវិល គឺដើម្បីភ្ជាប់ពត៌មាន។ ការភ្ជាប់ពត៌មាន នេះគឺជាមុខព្រួញមួយសំខាន់ណាស់។ ការភ្ជាប់ពត៌មានមានគុណប្រយោជន៍ដល់ការកសាង ការផ្លាស់ប្តូរបទពិសោធន៍ ការផ្លាស់ប្តូរ សមត្ថភាព ការចូលរួមក្នុងពលកម្មសហប្រតិបត្តិការភាពជាដៃគូនិងការយោគយល់គ្នា ព្រោះថាយុគសម័យនេះ គឺជាយុគសម័យ ទូរគមនាគមន៍ និងពត៌មាន។

៣_ អត្ថន័យដ៏មានជម្រៅ នៃការកសាងបណ្តាញអង្គការសង្គមស៊ីវិល នោះគឺការស្វែងរក "មិត្តភក្តិដែលស្មោះត្រង់ ដើម្បីធ្វើជាដៃគូ"។ គោលដៅជាសក្តានុពល នៃការកសាងបណ្តាញនេះ គឺសំដៅអភិវឌ្ឍវប្បធម៌សន្តិភាព ភាពសុខដុមរមនា ក៏ដូចជាវិបុលភាពរបស់បុគ្គលនិងសង្គមជាតិ។

៤_ ការកសាងបណ្តាញសង្គមស៊ីវិលល្អបាន លុះណាតែមានមនុស្សក្នុងអង្គការសង្គមស៊ីវិលល្អ។ មនុស្សក្នុងអង្គការសង្គមស៊ីវិលគឺជាមនុស្សដែលស្គាល់ខ្លួនឯងច្បាស់ និងស្គាល់នាទីរបស់ខ្លួន ចំពោះសង្គមស៊ីវិលនិងសង្គមជាតិ។ គឺមានតែកល្យាណមិត្ត និងសប្បុរសមិត្តទេដែលជាស្ថាបនិកដ៏ល្អ សំរាប់ការស្ថាបនាបណ្តាញសង្គមស៊ីវិលកម្ពុជា។ កល្យាណមិត្តគឺបានដល់មិត្តដែលមានសេចក្តីស្មោះត្រង់ មានចិត្តអធ្យាស្រ័យ និងការលើកលែងទោស។ រីឯសប្បុរស មិត្តគឺជាមិត្តដែលគ្មានចិត្តស្គាល់តែប្រយោជន៍ផ្ទាល់ខ្លួន_មិនមើលងាយប្រមាថចំពោះមិត្តរបស់ខ្លួន មិនច្រណែននិន្ទាចំពោះលាភសក្ការៈរបស់មិត្ត តែអបអរសាទរចំពោះជោគជ័យរបស់មិត្ត និងកើតទុក្ខជាមួយមិត្តក្នុងពេលដែលមិត្តមានទុក្ខ។

៥_ ការកសាងបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីបំផ្លាញបណ្តាញអង្គការសង្គមស៊ីវិល ដោយគំនិតឈ្នានីសឬដោយមហិច្ឆិតាត្រួតត្រាយកផលប្រយោជន៍ឬការកេងប្រវ័ញ្ចន៍ គឺជាប្រការដែលត្រូវចៀស

រវាង ព្រោះការកសាងបណ្តាញបែបនោះ គឺជាគ្រោះមហន្តរាយដល់សង្គមស៊ីវិលនិងសង្គមជាតិ។

៦- បញ្ហាប្រឈមមុខ ឬចំណុចខ្សោយ នៃការកសាងបណ្តាញសង្គមស៊ីវិលជាសំខាន់នោះ គឺការប្រកាន់វណ្ណៈ បក្សពួកក្នុងមជ្ឈដ្ឋានសង្គមស៊ីវិលគ្នាឯង។ រាល់ការប្រមាថមើលងាយការវាយតម្លៃទាបរវាងអង្គការស៊ីវិល និងអង្គការសង្គមស៊ីវិល គឺជាការខុសឆ្គងដែលគប្បីចងចាំនិងចៀសវាង។

៧- ការកសាងបណ្តាញសង្គមស៊ីវិលមួយរឹងមាំ មិនអាចកាត់ផ្តាច់បានពីការអប់រំនិងការអភិវឌ្ឍន៍ ធនធានមនុស្សឡើយ។ ធនធានមនុស្សដែលសង្គមស៊ីវិលកម្ពុជាចង់បាន គឺជាអ្នកខ្លាំងអ្នកឈ្នះលើចំណុចខ្សោយរបស់ខ្លួនដោយខ្លួនឯង។

៨- ការកសាងបណ្តាញសង្គមស៊ីវិលកម្ពុជា ត្រូវតែផ្សារភ្ជាប់ជាមួយ និងការធ្វើសកលភាវូបនីយកម្ម (Globalization)។ ពត៌មានពិតគឺជាកត្តាផលិតកម្ម។ បើគ្រប់គ្រងបានពត៌មានពិតនោះ គេគ្រប់គ្រងហានិភ័យ គ្រប់បែបយ៉ាងរបស់សង្គម ដែលកើតមានមកពីពត៌មានបំផ្លើស ព្រោះថា ការផ្សព្វផ្សាយពត៌មានមិនត្រឹមត្រូវវានាំឱ្យមានគ្រោះថ្នាក់ដល់សង្គមជាតិ។

ដើម្បីធានាបាននូវអភិវឌ្ឍនភាព នៃសង្គមស៊ីវិលកម្ពុជា អង្គការសង្គមស៊ីវិលទាំងអស់ មិនគួរធ្វើការប្រកួតប្រជែង ដើម្បីផលប្រយោជន៍បុគ្គលរបស់អង្គការខ្លួនទេ គេគួរតែចងបណ្តាញ

ជាចង្កោមដើម្បីស្វែងរក និងរក្សាការពារនូវផលប្រយោជន៍រួមនិងផលប្រយោជន៍ដោយឡែក។

## III. អំពីសំណូមពរ និង អនុសាសន៍ :

១. ស្នើសុំឱ្យ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព រៀបចំបង្កើតឱ្យមានសន្និសីទថ្នាក់ជាតិមួយ ស្តីពីអំពី ការអភិវឌ្ឍន៍ អង្គការពុំមែនរដ្ឋាភិបាល ដើម្បីបំរើផលប្រយោជន៍ពិតរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋក្រោយពេលដែលមានច្បាប់ NGOs ហើយ។

២. ស្នើសុំឱ្យរាជរដ្ឋាភិបាលលើកកំពស់ប្រសិទ្ធភាព នៃការអនុវត្តន៍ច្បាប់ ដាក់ទោសឧក្រិដ្ឋជន និងអ្នករំលោភច្បាប់។

## IV- សេចក្តីសន្និដ្ឋាន :

អង្គពិភាក្សាតុមូលលើកទី៧ ស្តីពី " ការស្ថាបនាបណ្តាញសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកបទពិសោធន៍ ពត៌មាន និងក្តីបារម្ភ" បានបញ្ចប់ទៅដោយបរិយាកាស រីករាយនិងលទ្ធផលល្អប្រសើរ ។

គោលដៅជាយុទ្ធសាស្ត្រសំខាន់ពីរ នោះគឺការកសាងបណ្តាញដើម្បីរួមចំណែកអភិវឌ្ឍសង្គមស៊ីវិល ឱ្យទៅជាកម្លាំងចលករ (Driving Force) សំរាប់ការស្ថាបនា និងការអភិវឌ្ឍន៍ជាតិ និងការរៀបចាកការស្ថាបនាបណ្តាញ ដើម្បីបំផ្លាញបណ្តាញក្រៅពីការបំរើបុព្វហេតុជាតិ

និងការអភិវឌ្ឍន៍សង្គមជាតិ ឱ្យរួចផុតពីការបែកបាក់ និងសង្គ្រាមវិនាសកម្ម គឺជាប្រការមួយដែលគួរចងចាំ និងចៀសវាងដាច់ខាត។

រាល់ការកសាងបណ្ដាញសង្គមស៊ីវិល ដើម្បីផ្លាស់ប្ដូរប្រភពធនធាន ពត៌មានក៏ដូចជាបទពិសោធន៍នឹងក្ដីកង្វល់ គឺជាតម្រូវការចាំបាច់ ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍជាតិ និងរំដោះប្រជាពលរដ្ឋកម្ពុជាឱ្យរួចផុតពីទំនាស់ឥតន័យ ជម្លោះបែកបាក់ សង្គ្រាមវិនាសកម្មនិងភាពក្រីក្រ។

ភារកិច្ចដ៏វិសេសវិសាល និងឧត្ដុង្គឧត្ដមទាំងពីរនេះ នឹងអាចធ្វើបានលុះណាតែប្រជាពលរដ្ឋ ខ្មែរគ្រប់រូបស្គាល់ជាតិខ្លួនច្បាស់ និងស្គាល់ខ្លួនឯងជានរណា? ហើយធ្វើការដើម្បីអ្វី?

ក្នុងករណីណាដែលខ្មែរ ពុំស្គាល់ខ្លួនឯងច្បាស់ទេ នោះជនជាតិខ្មែរមិនអាចអភិវឌ្ឍសង្គមជាតិនិងប្រទេសជាតិខ្លួនឱ្យចូលរួមក្នុងតំបន់ និងសហគមន៍អន្តរជាតិឡើយ។

កិច្ចពិភាក្សាតុមូលលើកទី៧ បានរកឃើញទស្សនៈ និងចំណេះដឹងជាបទពិសោធន៍ជាច្រើន ដែលអាចយកធ្វើជាគតិសំរាប់ការដឹកនាំ និងគ្រប់គ្រងប្រទេសជាតិឱ្យប្រកបដោយស្ថេរភាព សុវត្ថិភាព សន្តិភាព អភិបាលកិច្ចល្អ និងសុភមង្គលរបស់ប្រជាពលរដ្ឋកម្ពុជា៕

## ២_៨ កិច្ចពិភាក្សាតុមូលលើកទី៨

- ប្រធានបទនៃការពិភាក្សា ស្ដីពី: "តួនាទីរបស់យេនឌ័រ_Gender នៅក្នុងសង្គមស៊ីវិលកម្ពុជា : ប្រភពដើម ស្ថានការណ៍និងក្ដីសង្ឃឹម"។

➢ គណៈវាគ្មិនកិត្តិយស : (១)_លោកស្រី កុយ វើត ប្រធានអង្គការសម្លេងស្ត្រីខ្មែរនិង (២)_លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា។

## ខ្លឹមសារសង្ខេប

I. មតិ និងទស្សនៈរបស់គណៈវាគ្មិនកិត្តិយស :

១_ <u>លោកស្រី កុយ វើត ប្រធានអង្គការសម្លេងស្ត្រីខ្មែរ</u> :

→ និយមន័យពិតរបស់ "យេនឌ័រ" ពុំមែនសង្កត់ធ្ងន់ទៅលើជីវសាស្ត្រ (ជាបុរសភេទឬស្ត្រីភេទនោះទេ) តែគឺប្រមូលផ្តុំទៅលើសិទ្ធិអំណាច លំដាប់ថ្នាក់ តួនាទី និងសកម្មភាពស្មើគ្នារវាងបុរស និងស្ត្រីដែលសង្គមអាចកែប្រែបាន។

- ការងារបីរបស់សង្គម (ដែលត្រូវបែងចែក) គឺ៖ (១)_ការងារផ្ទះសម្បែង (២)_ការងារសហគមន៍ នយោបាយការងារដឹកនាំការងារសាធារណៈ និង (៣)_ការងារផលិតកម្ម : កសិកម្មឧស្សាហកម្ម សិប្បកម្មពាណិជ្ជកម្ម ។ល។

- ពីសង្គមមុនៗ ការបែងចែកមុខងារឬការងារឱ្យស្ត្រី និងបុរសដោយផ្អែកទៅលើជីវសាស្ត្ររបស់គេ (បុរសខ្លាំង_ស្ត្រីខ្សោយ) បាននាំបង្កើតឱ្យមានការបែងចែកវណ្ណៈ ទំនាស់រវាងបុរស និងស្ត្រីការរើសអើស និងការមើលបំណាំគ្នា។

- ការបែងចែកការងារតាម "យេនឌ័រ" នាំឱ្យមានការរីកចំរើន។ ការបែងចែកការងារតាម "យេនឌ័រ" គឺការបែងចែកតាម សមត្ថភាព បទពិសោធន៍និងចំណេះដឹង។ ទាំងបុរស ទាំងស្ត្រី គឺជាដៃគូជាមួយគ្នាក្នុងការងារបី គឺការងារផ្ទះសម្បែង ការងារសហគមន៍និងការងារផលិតកម្ម។ ការបែងចែកការងារតាម "យេនឌ័រ" នាំមានសាមគ្គីភាពសេចក្តី អត់ឱន និងការអភិវឌ្ឍន៍។

- អំពីប្រភពនៃការវិវត្តន៍របស់ "យេនឌ័រ" : ពីសម័យដើម (មុនឆ្នាំ ១៩១១) ស្ត្រីភេទមិនបានបំពេញតួនាទីទាំងបីដូចពោលខាងលើនេះទេ។ ក៏ប៉ុន្តែ ក្រោយឆ្នាំ១៩១១ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិ ស្ត្រីបានចូលរួមយ៉ាងសកម្ម ក្នុងការងារសំខាន់បីរបស់ពិភពលោកនោះគឺ(១)_ការអភិវឌ្ឍន៍ (២)_សមភាព និង (៣)_សន្តិភាព។ ចាប់តាំងពីពេលនោះមកស្ត្រីក៏បានទទួលសិទ្ធិស្មើនឹងបុរស។

- ទស្សនាទាននិងសកម្មភាពនៃ "យេនឌ័រ" បានចូលមកស្រុកខ្មែរក្នុងឆ្នាំ១៩៨០។ សកម្មភាពរបស់ "យេនឌ័រ" បានប្រមូលផ្តុំទៅលើមុខសញ្ញា៥គឺ (១)_ដើម្បីកាត់បន្ថយភាពក្រីក្រ (២)_ដើម្បីឱ្យតម្លៃចំពោះស្ត្រីភេទ (៣)_ដើម្បីជំរុញឱ្យរចនាសម្ព័ន្ធ សេដ្ឋកិច្ចនយោបាយទទួលស្គាល់តម្លៃ និងតួនាទីស្ត្រី (៤)_ដើម្បីជម្រុញឱ្យមានការយកមតិរបស់ស្ត្រី និង(៥)_ដើម្បីជំរុញឱ្យស្ត្រីបានចូលរួមក្នុងការអភិវឌ្ឍន៍ជាមួយបុរស។

- ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី បច្ចុប្បន្ននេះស្ត្រីកម្ពុជានៅតែចាញ់ប្រៀបបុរសនៅក្នុងការទទួលអប់រំ ការគាំពារសុខភាព និងនៅក្នុងការធ្វើសេចក្តីសំរេចចិត្តក្នុងការដឹកនាំ និងគ្រប់គ្រងសង្គម។
- ស្នើសុំឱ្យស្ត្រីភេទបានទទួល នូវសមភាពពិតប្រាកដក្នុងការអភិវឌ្ឍន៍ ក្នុងការដឹកនាំ និងគ្រប់គ្រងសង្គម ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង ក្នុងការទទួលផលប្រយោជន៍ ដោយចៀសវាងកុំឱ្យមានការរំលោភកេងប្រវ័ញ្ច និងប្រមាថមាក់ងាយស្ត្រីភេទ។

## ២_ <u>លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិនៃអង្គការ "យេនឌ័រ" និងអភិវឌ្ឍន៍ដើម្បីកម្ពុជា</u> :

- បន្ថែមទៅលើមតិរបស់ លោកស្រី កុយ វ៉េត : ពាក្យថា "យេនឌ័រ" មិនគ្រាន់តែមានអត្ថន័យថា ជាតុល្យភាពឬសមភាពរវាងបុរសនិងស្ត្រីភេទប៉ុណ្ណោះទេ តែជាទស្សនៈអភិវឌ្ឍន៍ ក្នុងការលើកស្ទួយតម្លៃ និងសារៈរបស់ស្ត្រីឱ្យមានសមភាពស្មើ និងបុរសភេទនៅគ្រប់វិស័យនៃការងារសង្គម។
- ពាក្យថា "យេនឌ័រ" នេះត្រូវបានប្រើរួមគ្នា ទូទាំងពិភពលោក ដោយមិនបានបកប្រែតម្រូវទៅតាមភាសានៃជាតិនីមួយៗទេ។
- ស្ត្រីភេទ ជាការពិតណាស់ គឺជាអ្នកដែលធ្វើការច្រើនជាងគេនៅក្នុងសង្គមដូចជាការងារ ផលិតកម្ម ការងារមិនយកកម្រៃ និងការងារសហគមន៍។

- ការងារ"យេនឌ័រ" គឺជាការងារស្ត្រីក្នុងការអភិវឌ្ឍន៍។ ការងារស្ត្រីក្នុងការអភិវឌ្ឍន៍នេះ គឺជាតុល្យភាព ឬជាសមភាពរបស់ស្ត្រីជាមួយបុរសក្នុងការអភិវឌ្ឍន៍សង្គមគ្រួសារនិងប្រទេសជាតិ។ គ្មានការងារណាមួយដែលស្ត្រីមិនអាចធ្វើបាននោះទេ។ ស្ត្រីគឺជាដៃគូរបស់បុរសក្នុងការកសាងសង្គមគ្រួសារ និងការអភិវឌ្ឍន៍ប្រទេសរួមទាំងការងារដឹកនាំ និងគ្រប់គ្រងផង។

## II- អំពីលទ្ធផលនៃការពិភាក្សារួម :

១- តាមការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជា ប្រជាពលរដ្ឋខ្មែរបានលើកស្ទួយស្ត្រីថា ជា "មាតា"។ របបគ្រប់គ្រងប្រទេសកម្ពុជាក្នុងសតវត្សទី ១ នៃគ.ស គឺជារបបមាតាធិបតេយ្យ (Matriarchal Regime)។ របបនេះបានចាត់ទុកស្ត្រីភេទជាធំ។ ស្ត្រីជាមាតា-មាតាគឺជាព្រហ្មវិហារធម៌ ដែលបុត្រធិតាខ្មែរចាត់ទុកជាទីគោរពសក្ការៈ។

ក៏ប៉ុន្តែ សម័យក្រោយៗមកអាស្រ័យដោយវប្បធម៌អាណានិគមនិយម (សតវត្សទី១៩) និងភាពស្រុតចុះខាងវប្បធម៌ ប្រពៃណីជាតិអាស្រ័យដោយសង្គ្រាមឈ្លានពាន និងមនោគមវិជ្ជាបរទេស របបមាតាធិបតេយ្យខ្មែរត្រូវចុះថមថយកម្លាំង ហើយស្ត្រីភេទក៏ធ្លាក់ចុះទន់ខ្សោយ ត្រូវទទួលការរំលោភបំពាន និងរងគ្រោះដោយអាជីវកម្មផ្លូវភេទ។

ជាភ័ព្វសំណាងនៅដើមឆ្នាំ១៩៨០ អាស្រ័យដោយមានរលកនៃសកលភាវូបនីយកម្មអំពី "យេនឌ័រ" ស្ត្រីខ្មែរត្រូវបានលើកស្ទួយឱ្យ

ទទួលយកតម្លៃថ្មី នៃពិភពលោក នោះគឺសមភាពក្នុងកិច្ចការពលកម្ម អភិវឌ្ឍន៍ សមភាពក្នុងការទទួលផល សមភាពក្នុងការកសាងសន្តិភាព និងសមភាព ក្នុងការដើរតួនាទីជាអ្នកធ្វើសេចក្ដីសំរេចចិត្តគ្រប់បែបយ៉ាង ដើម្បីរួមចំណែកកសាងប្រវត្តិសាស្ត្រសង្គម អភិវឌ្ឍប្រទេសជាតិនិងការស្ថាបនាវប្បធម៌សន្តិភាព។

ក៏ប៉ុន្តែទោះជាដូចម្ដេចក្ដី ស្ត្រីភេទកម្ពុជានៅតែចាញ់ប្រៀបបុរស ក្នុងការទទួលយកការអប់រំ ការគាំពារសុខភាព ការទទួលតួនាទី ធ្វើសេចក្ដីសំរេចចិត្ត និងការទទួលផល។

២_បញ្ហាប្រឈមមុខនិងឧបសគ្គដែលនាំឱ្យស្ត្រីខ្មែរ នៅតែមានប្រៀបចាញ់បុរសភេទ នោះគឺទស្សនៈសង្គម ប្រពៃណី និងវប្បធម៌ ឱនថយរបស់ខ្មែរ ដែលធ្លាប់ទទួលឥទ្ធិពលពីសង្គម សក្តិភូមិ និង អាណានិគមនិយមបរទេស ដែលបានចាត់ទុកស្ត្រី ជាភេទទន់ខ្សោយ បង្វិលចង្ក្រានមិនជុំ និងជាអ្នកចាំផ្ទះតែប៉ុណ្ណោះ។

៣_ ដើម្បីលើកកំពស់តួនាទីស្ត្រីភេទ ឱ្យមានតុល្យភាពនិងសមភាពក្នុងមគ្គុទ្ទេសភាព និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងសង្គមជាតិបានស្មើនឹងបុរសភេទ គឺគ្មានអ្វីក្រៅពីការអប់រំទេ។ ការអប់រំនេះត្រូវធ្វើឡើងតាំងពីក្នុងគ្រួសារឡើងទៅ។ ការជំរុះចោលនូវប្រពៃណីរឹតត្បិតកូនស្រីមិនឱ្យបង្ហាញមុខក្នុងសង្គមគ្រួសារ ឬពិធីការធំៗ គឺជាការចាំបាច់ណាស់ ដើម្បីទម្លាប់ឱ្យស្ត្រីមានសេចក្ដីក្លាហានចេញមុខមាត់ធ្វើការងារក្នុងសហគមន៍ និងលើផ្ទៃប្រទេស។

៤_ អង្គការសង្គមស៊ីវិលនីមួយៗត្រូវចេះលើកស្ទួយវត្តមាន និងតួនាទីរបស់ស្ត្រីក្នុងការដឹកនាំ និងគ្រប់គ្រងអង្គការឱ្យដូចជាបុរសផង។ គឺការផ្តើមចេញពីការលើកស្ទួយស្ត្រីភេទក្នុងអង្គការ សង្គមស៊ីវិលនេះឯង ដែលអាចនាំឱ្យតម្លៃនិងសារៈសំខាន់របស់ស្ត្រីភេទ កាន់តែត្រូវបានសង្គមមើលឃើញ ហើយអាចប្រយុទ្ធដណ្តើមយកតួនាទីដឹកនាំ និងគ្រប់គ្រងសង្គមជាតិដោយសន្តិវិធី និងភាពឈ្លាសវៃ។

៥_ ការលើកកំពស់ការអប់រំអំពី "សិទ្ធិរបស់ស្ត្រី" តាំងពីថ្នាក់ក្រោមឡើងទៅ គឺជាការចាំបាច់ណាស់ដើម្បីអភិវឌ្ឍន៍ "យេនឌ័រ" ឱ្យទៅជាទស្សនាទានចាំបាច់និងជាវប្បធម៌សង្គមខ្មែរ។ ការអប់រំនេះគួរចាប់ផ្តើមបណ្តុះបណ្តាលតាំងពីកុមារភាពឡើងទៅ ដើម្បីឱ្យកូនខ្មែរមានព្រលឹង "យេនឌ័រ"។ ទន្ទឹមនោះការលើកកំពស់សមត្ថភាពយល់ដឹងរបស់ស្ត្រីនិងការផ្តល់ឱកាសឱ្យស្ត្រីបានរៀនសូត្រ ស្មើមុខមាត់នឹងបុរសទាំងអំពីចំណេះដឹងទូទៅ ក៏ដូចជាវិជ្ជាជីវៈបច្ចេកទេស និងការគ្រប់គ្រង គឺជាថាមពលស្ថាបនា ដែលជួយឱ្យស្ត្រីខ្មែរកាន់តែមានមោទនភាព និងសេចក្តីក្លាហានក្នុងការធ្វើការងារ និងប្រកួតប្រជែងយកតួនាទីដឹកនាំនិងគ្រប់គ្រងសង្គមជាតិដូចបុរសភេទដែរ។

៦_ ការអភិវឌ្ឍន៍ "យេនឌ័រ" នៅកម្ពុជាពិតជាពុំអាចរឹងមាំបានទេ ប្រសិនបើប្រទេសជាតិគ្មានចេរភាពនយោបាយ គ្មានសន្តិភាព និងនៅតែមានភាពក្រីក្រ។ បើស្ថានភាពប្រទេសជាតិធ្លាក់ចុះដុនដាប

អសន្តិសុខ អថេរភាព គ្មានសន្តិភាពនោះ ការអភិវឌ្ឍន៍យេនឌ័រមិនអាចមានដំណើរការល្អប្រសើរឡើយ។

៧_ ហេតុផលដែលមិនអនុញ្ញាតឱ្យស្ត្រី បានទទួលការអប់រំខ្ពស់ដូចបុរសនោះគឺព្រោះតែ៖

(១)_ ជីវភាពក្រីក្រ (ព្រោះសេដ្ឋកិច្ចឱនថយ ប្រទេសជាតិទុរភិក្ស)

(២)_ ខ្វះការអប់រំរបស់មាតានិងបិតាក្នុងគ្រួសារ (សង្គមគ្រួសារ)

(៣)_ ប្រពៃណីអៀនខ្មាសព្រោះតែស្ត្រីមិនស្គាល់ខ្លួនឯងច្បាស់ថា ខ្លួនមានអ្វី? ខ្វះអ្វី? ហើយត្រូវធ្វើអ្វី?

៨_ ការអប់រំអ្នកទាំងពីរ (ទាំងស្ត្រីភេទ_ទាំងបុរសភេទ) ឱ្យចេះគោរពស្រឡាញ់រាប់អានគ្នា ឱ្យចេះយោគយល់គ្នា ឱ្យចេះអាណិតអាសូរ ឱ្យចេះធ្វើការរួមគ្នា សហប្រតិបត្តិការគ្នា គឺជាការចាំបាច់មិនអាចខ្វះបាន។ បើភាគីទាំងពីរនៅមានការប្រកាន់ ការប្រមាថមើលងាយគ្នា បង្អាប់បន្តុះគ្នា ហើយមិនយល់ពីវប្បធម៌នៃសេចក្តីអត់ឱនតាមបែបលទ្ធិប្រជាធិបតេយ្យទេ នោះបុរសនិងស្ត្រី មិនអាចអភិវឌ្ឍជឿនលឿនទៅមុខបានទេ។

៩_ ការលើកស្ទួយគុណភាពនៃជីវភាពរស់នៅ (Quality of life) និងការកាត់បន្ថយភាពក្រីក្រ គឺជាមធ្យោបាយអាចជួយលើកស្ទួយ

"ការអភិវឌ្ឍន៍យេនឌ័រ" បានមួយកំរិតធំដើម្បីឱ្យគេមានលទ្ធភាពទទួលយកការអប់រំឱ្យរួចផុតពីភាពអវិជ្ជា។ ជីវភាពក្រីក្រគឺជាប្រភពនៃភាពល្ងង់ខ្លៅ។

១០_ការបាត់បង់ទំនុកចិត្ត និងជំនឿលើខ្លួនឯង និងសំពាធវប្បធម៌ប្រពៃណី ដែលចាត់ទុកស្ត្រីជាភេទទន់ខ្សោយជីវភាពក្រីក្រនិងការមិនផ្តល់ឱកាសឱ្យស្ត្រីបានរៀនសូត្រទាំងអស់នេះ បានធ្វើឱ្យស្ត្រីមានពហុចិត្ត (Complex) ឃ្លាតឆ្ងាយពីទីប្រជុំ គ្មានសេចក្តីក្លាហានបញ្ចេញសមត្ថភាព និងមតិយោបល់បាត់បង់ឱកាសតស៊ូ ដើម្បីប្រកួតយកសមភាពជាមួយបុរសភេទ។ គឺហេតុទាំងនេះហើយដែលនាំឱ្យស្ត្រីងើបមុខមិនរួចពីការងារផ្ទះសម្លៀងចង្ក្រានបាយនិងកូនចៅ។

១១_កង្វះការធានារ៉ាប់រងពីសង្គម កង្វះការភ្ញាក់រលឹករៀនសូត្រដោយខ្លួនឯង កង្វះការជួយឧបត្ថម្ភពីបុរសភេទ នេះស្ថានភាពទ័លក្រក្នុងគ្រួសារ និងកង្វះគោលនយោបាយឧបត្ថម្ភពីរបបគ្រប់ គ្រងនេះគឺជាប្រការដែលត្រូវជំនះឱ្យបាននោះទើបអាចលើកស្ទួយសមភាពឬតុល្យភាពរបស់ស្ត្រីជាមួយបុរសបាន។

កត្តាសំខាន់ ដែលអាចជួយលុបបំបាត់ចំនុចខ្សោយទាំងនេះបាននោះគឺឆន្ទៈនយោបាយរបស់រដ្ឋាភិបាល ក្នុងការលើកស្ទួយការអប់រំថ្នាក់ជាតិអំពីសារៈសំខាន់នៃ "យេនឌ័រ" និងស្មារតីភ្ញាក់រលឹកជួយខ្លួនដោយខ្លួនឯងរបស់ស្ត្រី និងការផ្សព្វផ្សាយ។

## IV_ សេចក្ដីសន្និដ្ឋាន

នៅទីបញ្ចប់ កិច្ចប្រជុំតុមូលលើកទី៨ ស្ដីពី "តួនាទីរបស់យេនឌ័រ_Gender នៅក្នុងសង្គមស៊ីវិលកម្ពុជា: ប្រភពដើម ស្ថានភាពណ៍ និងក្ដីសង្ឃឹម" បានវាយតម្លៃថា : អង្គការសង្គមស៊ីវិលកម្ពុជាមានតួនាទីសំខាន់ណាស់ក្នុងការលើកស្ទួយ "យេនឌ័រ" នៅក្នុងការងារសំខាន់បីគឺ : (១)ការអភិវឌ្ឍន៍ (២)សមភាព និង (៣)សន្តិភាព ។

ការងារនេះមិនអាចខ្វះបាននូវការអប់រំសិក្សា និងការផ្សព្វផ្សាយទេ។ ទន្ទឹមនោះ ឆន្ទៈនយោបាយរបស់រដ្ឋាភិបាល និងការឧបត្ថម្ភគាំទ្រពីបុរសភេទ គឺជាកត្តាស្លាប់រស់មួយនៃការអភិវឌ្ឍន៍ យេនឌ័រនៅកម្ពុជា។

ក៏ប៉ុន្តែអ្វីដែលសំខាន់ជាងនេះគឺ "កត្តាខ្លួនឯងរបស់ស្ត្រី" ដែលត្រូវខិតខំរំដោះខ្លួនដោយខ្លួនឯងឱ្យរួចផុតពីភាពល្ងង់ខ្លៅ (អសមត្ថភាព) ភាពទន់ខ្សោយ និងប្រពៃណីឱនថយដែលមិនបានឱ្យតម្លៃស្ត្រី និងប្រមាថមើលងាយស្ត្រីជាភេទទន់ខ្សោយ។

កត្តាខ្លួនឯង គឺជាកត្តាឈ្នះ ( **Self-Reliance First!**) ដែលអាចជួយលើកស្ទួយតុល្យភាព និងសមភាពរវាងបុរស និងស្ត្រីបានគ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈ។

ស្ត្រីទាំងអស់! សូមក្រោកឈរឱ្យស្រុះគ្នាឡើង! (នេះជាសេចក្ដីអំពាវនាវរបស់អង្គប្រជុំ)។

## ២-៩ កិច្ចពិភាក្សាតុមូលលើកទី ៩

➢ ប្រធានបទនៃការពិភាក្សា ស្តីពី "ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា"។

➢ គណៈវាគ្មិនកិត្តិយសៈ (១)-លោកស្រី ម៉ក់ ផារ៉ា ប្រធានសមាគមលើកស្ទួយសិប្បកម្មខ្មែរ (ស.ស.ស.ខ.) (២)-លោក ញ៉ៀម ចណ្ណាថន នាយកប្រតិបត្តិ អង្គការសិទ្ធិមនុស្សខ្មែរនិងប្រឆាំងអំពើពុករលួយ។

### ខ្លឹមសារសង្ខេប

**I.** ទស្សនៈ និង មតិរបស់គណៈវាគ្មិនកិត្តិយស :

១- <u>លោកស្រី ម៉ក់ ផារ៉ា ប្រធានអង្គការសមាគមលើកស្ទួយសិប្បកម្មខ្មែរ</u> :

- ការធ្វើសេចក្តីសំរេចចិត្តល្អមាន ១០ ចំណុច :
  - ១- ត្រូវមានជំនាញច្បាស់លាស់។
  - ២- ត្រូវមានបុគ្គលិកប្រកបដោយសមត្ថភាពជំនាញ។
  - ៣- ត្រូវមានទំនាក់ទំនងល្អ ជាមួយរដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់។
  - ៤- ត្រូវបើកចំហការរិះគន់។
  - ៥- ត្រូវមានការផ្តួចផ្តើមគំនិតឱ្យបានច្រើន។

៦. ត្រូវដោះស្រាយឱ្យបាននូវអំពើពុករលួយផ្ទៃក្នុង។

៧. ត្រូវចេះប្រមើលមើលទៅអនាគត។

៨. ត្រូវយកមតិរួមជាធំ។

៩. ត្រូវមានផែនការច្បាស់លាស់។

១០. ត្រូវមានសេចក្តីស្មោះត្រង់។

- ភាពទន់ខ្សោយក្នុងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងអង្គការសង្គមស៊ីវិលមានប្រភពមកពីអំពើអសកម្មបីយ៉ាងគឺ ៖

១. អំពើពុករលួយ។

២. បក្សពួកនិយម។

៣. ភាពគ្មានសមត្ថភាព។

**២. <u>លោក ញ៉ែម វណ្ណថន នាយកប្រតិបត្តិ អង្គការសិទ្ធិមនុស្សខ្មែរ និងប្រឆាំងអំពើពុករលួយ</u>:**

- ជាទស្សនៈ ដើម្បីធ្វើសេចក្តីសំរេចចិត្តឱ្យបានល្អ នៅក្នុងអង្គការសង្គមស៊ីវិលគេត្រូវតែស្គាល់ប្រភពបញ្ហា និងកំណត់គោលដៅឱ្យបានច្បាស់លាស់។ បើគេកំណត់មិនបាននូវប្រភពបញ្ហា និងគោលដៅនេះទេ នោះការធ្វើសេចក្តីសំរេចចិត្តនឹងវង្វេងទិស។

- ប្រវត្តិសង្គមខ្មែរធំៗបួន :

១. របបសង្គមរាស្ត្រនិយមរបស់សម្តេចឪ។

បណ្ណាល័យ
គ.ជ.អ.ប

២_ របបលន់នល់។

៣_ របបខ្មែរក្រហម។

៤_ របបរដ្ឋកម្ពុជារហូតដល់បច្ចុប្បន្ន។

របបទាំងបួននេះមានសារធាតុខុសគ្នាតែធ្វើអន្តរកម្មរវាងគ្នាទៅវិញទៅមក។

- ការគ្រប់គ្រងនិងការធ្វើសេចក្តីសំរេចចិត្តល្អ ត្រូវតែប្រឆាំងនឹងអំពើពុករលួយការកេងប្រវ័ញ្ច និងអភិបាលកិច្ចឱនថយ។
- ចំណុចខ្លាំងនិងចំណុចខ្សោយរបស់អង្គការសង្គមស៊ីវិលកម្ពុជា។

• ជាគុណសម្បត្តិ អង្គការសង្គមស៊ីវិលកម្ពុជា មានគោលដៅច្បាស់លាស់ត្រូវបានអនុម័តឱ្យបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ម្ចាស់ឧបត្ថម្ភថវិកាពេញចិត្ត កម្ពុជាជាទីលានអភិវឌ្ឍន៍កាត់បន្ថយបានការរំលោភសិទ្ធិមនុស្ស រដ្ឋាភិបាលទទួលស្គាល់ និងជួយទប់ស្កាត់មិនឱ្យមានកម្លាំងបំបែកបំបាក់។

• ជាគុណវិបត្តិ អង្គការសង្គមស៊ីវិលមួយចំនួន ត្រូវបានបង្កើតឡើងដោយចៃដន្យ មានបរិមាណច្រើន តែខ្វះគុណភាព ពុំសូវមានបទពិសោធន៍ ខ្វះសហប្រតិបត្តិការផ្ទៃក្នុងខ្វះសុចរិតធម៌។

ទាំងគុណសម្បត្តិ និងការខ្វះខាតនេះ សុទ្ធតែមានឥទ្ធិពលដល់ការធ្វើសេចក្តីសំរេចចិត្ត នៅក្នុងអង្គការសង្គមស៊ីវិលនីមួយៗ។

- ការធ្វើសេចក្ដីសំរេចចិត្តបានល្អ ត្រូវតែផ្អែកទៅលើការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ សុចរិតធម៌ (ប្រឆាំងអំពើពុករលួយ) កម្មវិធីនយោបាយអភិវឌ្ឍន៍ និងកំណែទម្រង់របស់រដ្ឋាភិបាល។

## II. សំណូមពរ

- ស្នើសុំឱ្យរដ្ឋាភិបាល មានវិធានការកាត់បន្ថយអំពើពុករលួយ ស្នើអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ខិតខំរួមចំណែកសហប្រតិបត្តិការជួយកាត់បន្ថយអំពើពុករលួយកេងប្រវ័ញ្ចនៅក្នុងអង្គការសង្គមស៊ីវិល និងចូលរួមធ្វើសេចក្ដីសំរេចចិត្តល្អ តាមរយៈការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អនិងសុចរិតធម៌។

## III. អំពីលទ្ធផលនៃការពិភាក្សារួម

ឆ្លងតាមរយៈការពិភាក្សាតុមូលអស់រយៈពេលជាង ៤ ម៉ោង អង្គពិភាក្សាបានរកឃើញចំណេះដឹង និងបទពិសោធន៍ល្អៗ ក្នុងការធ្វើសេចក្ដីសំរេចចិត្តរបស់អង្គការសង្គមស៊ីវិលកម្ពុជាដូចខាងក្រោម ÷

១. ការធ្វើសេចក្ដីសំរេចចិត្តបានល្អក្នុងអង្គការសង្គមស៊ីវិល មិនគ្រាន់តែត្រូវស្គាល់ប្រភពបញ្ហា ត្រូវមានគោលដៅច្បាស់លាស់ ត្រូវមានអភិបាលកិច្ចល្អនិងត្រូវផ្អែកលើសមត្ថភាពជំនាញ និងបទពិសោធន៍ផ្សារភ្ជាប់ទៅនឹងគោលនយោបាយកែទម្រង់របស់រដ្ឋាភិបាលប៉ុណ្ណោះទេ គឺត្រូវចេះវាយតម្លៃសភាពការណ៍ឱ្យបានត្រឹមត្រូវ និងមានសច្ចធម៌ផង នោះទើបបានទទួលលទ្ធផលល្អ។

២. រាល់ការធ្វើឱ្យសេចក្តីសំរេចចិត្ត នៅក្នុងអង្គការសង្គមស៊ីវិលមិនអាចកាត់ផ្តាច់បានពីស្មារតីទទួលខុសត្រូវឡើយ។ ការធ្វើសេចក្តីសំរេចចិត្តដោយការស្រមើស្រមៃ គ្មានស្មារតីចាត់តាំង គ្មានស្មារតីផែនការ គ្មានការត្រួតពិនិត្យវាយតម្លៃ និងគ្មានស្មារតីទទួលខុសត្រូវពុំអាចយកជាបានការទេ។

៣. ដើម្បីឱ្យការធ្វើសេចក្តីសំរេចចិត្តបានល្អ គេត្រូវតែកំណត់ព្រំដែននៃសិទ្ធិក្នុងការធ្វើសេចក្តីសំរេចចិត្តនោះ ដោយផ្អែកទៅលើសិទ្ធិ និងតួនាទីរបស់អ្នកធ្វើសេចក្តីសំរេចចិត្តទៅនឹងច្បាប់របស់រដ្ឋដើម្បីចៀសវាងកុំឱ្យការធ្វើសេចក្តីសំរេចចិត្តនោះប៉ះពាល់ទៅលើច្បាប់របស់រដ្ឋ។

៤. គេអាចលុបបំបាត់អំពើពុករលួយនៅក្នុងការធ្វើសេចក្តីសំរេចមួយបានភ្លាមៗ ដោយមិនទុកឱ្យស៊ីពេលយូរអង្វែងឡើយ។ កិច្ចការនេះអាចធ្វើបានតាមរយៈការដឹងខ្លួនទាន់ ការភ្ញាក់រលឹក និងសេចក្តីប្តេជ្ញាចិត្តខ្ពស់របស់អ្នកធ្វើសេចក្តីសំរេចចិត្តនោះដោយខ្លួនឯង។

៥. សង្គមមួយដែលអាចរីកចំរើនបាន លុះណាតែមានការគោរពច្បាប់។ យ៉ាងណាមិញការធ្វើសេចក្តីសំរេចចិត្ត ក្នុងអង្គការសង្គមស៊ីវិលមួយអាចនឹងជឿនលឿនបាន លុះណាមានការគោរពច្បាប់ លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់អង្គការសង្គមស៊ីវិលនោះ ដោយផ្សាភ្ជាប់ទៅនឹងច្បាប់របស់រដ្ឋផង។

៦. ដើម្បីឱ្យការធ្វើសេចក្តីសំរេចចិត្ត នៅក្នុងអង្គការសង្គមស៊ីវិលបានប្រកបដោយគតិសច្ចៈ យុត្តិធម៌ មានអភិបាលកិច្ចល្អ និងគ្មានអំពើ

ពុករលួយបាន លុះណាតែអង្គការសង្គមស៊ីវិលទាំងអស់ ឧស្សាហ៍ព្យាយាមប្រើប្រាស់វិធីសាស្ត្រអប់រំខ្លួន តាមរយៈច្បាប់ពីរយ៉ាងគឺ ច្បាប់ក្រៅនិងច្បាប់ក្នុង។ ច្បាប់ក្រៅគឺច្បាប់រដ្ឋ រីឯច្បាប់ក្នុងគឺច្បាប់គុណធម៌ និងសីលធម៌ខាងផ្លូវចិត្តគំនិត។ ច្បាប់រដ្ឋធ្វើឱ្យមនុស្សខ្លាចអំពើអាក្រក់។ ច្បាប់សីលធម៌និងគុណធម៌ធ្វើឱ្យមនុស្សខ្មាសអៀនចំពោះអំពើអាក្រក់។ ច្បាប់ទាំងពីរ មិនអាចខ្វះច្បាប់មួយណាបានឡើយ ។

៧. ស្នើសុំឱ្យរដ្ឋាភិបាលបំបាត់អំពើពុករលួយ នៅក្នុងមជ្ឈដ្ឋានអ្នកដឹកនាំរដ្ឋនិងក្នុងគណបក្សនយោបាយធំៗ ដើម្បីកុំឱ្យនាយទុនបរទេសមានបង្អែក ហើយយកបង្អែកនោះ ទៅកេងប្រវ័ញ្ចកម្លាំងញើសឈាមរបស់កម្មករ ដោយធ្វើសេចក្តីសំរេចចិត្តក្នុងការគ្រប់គ្រងផលកម្រៃជាទឹកប្រាក់បៀវត្សរ៍ ឬផលប្រយោជន៍របស់កម្មករផ្ទុយទៅនឹងច្បាប់ការងារ (ព្រោះនាយទុនបរទេស មិនចេះច្បាប់ការងាររបស់រដ្ឋឡើយ)។

៨. អ្នកធ្វើសេចក្តីសំរេចចិត្តទាំងអស់ ត្រូវតែគោរពទៅតាមក្រមសីលធម៌មួយ។ បើអ្នកដឹកនាំគ្មានក្រមសីលធម៌ ការធ្វើសេចក្តីសំរេចចិត្តក៏គ្មានសីលធម៌ដែរ។ បើគ្មានក្រមសីលធម៌ ហើយការធ្វើសេចក្តីសំរេចចិត្តនោះ ពុំអាចមានភាពប្រាកដនិយម និងការប្រតិបត្តិល្អឡើយ។

៩. ការនិយាយព្រោកប្រាជ្ញពីទ្រឹស្តីគឺជាការងាយស្រួល តែការប្រតិបត្តិគឺការលំបាកពន់ប្រមាណ។ ការធ្វើសេចក្តីសំរេចចិត្តនោះ នឹងប្រព្រឹត្តទៅបានល្អ នោះណាតែរបៀបរបបធ្វើការងារ និងចិត្តគំនិតរបស់ដឹកនាំមានសេចក្តីស្មោះត្រង់ សុចរិតធម៌ និងការប្តេជ្ញាចិត្តខ្ពស់។

## IV. អំពីអនុសាសន៍

១. សង្គមគ្រួសារមួយជឿនលឿន អាស្រ័យដោយឪពុកម្តាយ។ ជាតិមួយរុងរឿង គឺអាស្រ័យដោយមគ្គុទ្ទេសក៏។ កត្តាដឹកនាំគឺជាអាយុជីវិតរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋ។ កិច្ចប្រជុំតុមូលលើកទី៩ស្តីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា" ស្នើសុំឱ្យអ្នកដឹកនាំគ្រប់ជាន់ថ្នាក់ធ្វើគំរូល្អ និងទទួលស្គាល់មុនគេនូវអភិបាលកិច្ចល្អ និងសុចរិតធម៌ក្នុងការដឹកនាំនិងគ្រប់គ្រងប្រទេសជាតិ។

២. ស្នើសុំឱ្យអ្នកដឹកនាំរដ្ឋ គោរពនូវពាក្យសន្យារបស់ខ្លួនផ្សាភ្ជាប់ជាមួយប្រជាពលរដ្ឋនិងម្ចាស់អំណោយក្នុងការទប់ស្កាត់ការប្រព្រឹត្តិអំពើកេងប្រវ័ញ្ចន៏ ក្នុងការគ្រប់គ្រងជំនួយ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានឱ្យបានល្អប្រសើរ ស្របតាមកម្មវិធីនយោបាយដែលរដ្ឋាភិបាលបានលើកឡើង។

៣. ស្នើអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ខិតខំពង្រឹងនូវសមត្ថភាព និងគុណភាពដឹកនាំរបស់ខ្លួន ឱ្យមានតម្លាភាព

គណនេយ្យភាព និងការទទួលខុសត្រូវ និងធ្វើគំរូល្អ ក្នុងការលើកស្ទួយអភិបាលកិច្ចល្អ ក្នុងការធ្វើសេចក្តីសំរេចចិត្តដឹកនាំនិងគ្រប់គ្រងអង្គការរបស់ខ្លួន។

## V- សេចក្តីសន្និដ្ឋាន

កិច្ចពិភាក្សាតុមូលលើកទី៩ ស្តីពី "ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា" បានបញ្ចប់ទៅដោយធ្វើសន្និដ្ឋានថា : សមត្ថភាព និងគុណភាពដឹកនាំប្រកបដោយភាពស្អាតស្អំ និងការគិតពីផលប្រយោជន៍រួមជាធំ គ្មានបក្សពួក គ្មានអំពើពុករលួយ និងការកេងប្រវ័ញ្ច នៅក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនៅក្នុងអង្គការសង្គមស៊ីវិល គឺជាប្រៀបខ្លាំងប្រៀបឈ្នះដែលធ្វើឱ្យសង្គមស៊ីវិលមានការវិវត្តន៍ រីកចំរើនស្ថិតស្ថេររឹងមាំ។

ផ្ទុយទៅវិញ រាល់ដំណើរនៃការធ្វើសេចក្តីសំរេចចិត្តណាដែលមានភាពអត្តនោម័តបុគ្គលនិយម ពុករលួយនិងបក្សពួក គ្មានសុចរិតធម៌ និងគុណធម៌ដឹកនាំ រមែងនាំមកនូវការបែកបាក់និងភាពវិនាសអន្តរាយ។ ការធ្វើសេចក្តីសំរេចចិត្តល្អ គឺត្រូវផ្អែកលើកមូលដ្ឋាននៃសច្ចធម៌អភិវឌ្ឍធម៌ និងអភិបាលកិច្ចល្អ៕

## ២_១០ កិច្ចពិភាក្សាតុមូលលើកទី ១០

➢ ប្រធានបទនៃការពិភាក្សា ស្តីពី : "បញ្ហាប្រឈមមុខក្នុងការប្រមូលផ្តុំធនធាន ដើម្បីស្ថាបនា និរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា"។

➢ គណៈវាគ្មិនកិត្តិយសៈ (១)_លោក សេក បរិសុទ្ធ មន្ត្រីជាតិទទួលបន្ទុកវិទ្យាស្ថានសារគមនាគមន៍កម្ពុជា (CCI) (២)_លោកស្រី មាស សុខុម អ្នកសំរបសំរួលកម្មវិធីប្រឆាំង នឹងអំពើហិង្សាក្នុងគ្រួសារ (PADV)

## ខ្លឹមសារសង្ខេប :

## I_ មតិ និងទស្សនៈរបស់គណៈវាគ្មិនកិត្តិយស :

### ១_ <u>លោក សេក បរិសុទ្ធ មន្ត្រីជាតិទទួលបន្ទុក វិទ្យាស្ថានសារគមនាគមន៍កម្ពុជា :</u>

- ការចែករំលែកបទពិសោធន៍ របស់វិទ្យាស្ថានសារគមនាគមន៍កម្ពុជាក្នុងការបង្កើនពត៏មាន ការកែលំអប្រព័ន្ធផ្សព្វផ្សាយ ការបណ្ដុះបណ្ដាលអ្នកសារពត៏មានខ្មែរ ទាំងក្នុងស្ថាប័នក្រៅរដ្ឋាភិបាល និងក្នុងរដ្ឋាភិបាល។

- បទពិសោធន៍ល្អក្នុងការប្រមូលផ្ដុំធនធាន :

ដើម្បីទប់ស្កាត់ចាន្ទវ៉បញ្ហាទាំងឡាយដែលកើតមាន ក្នុងការប្រមូលផ្ដុំធនធាន អង្គការសង្គមស៊ីវិលកម្ពុជាត្រូវតែស្ថាបនាឱ្យបានធ្ងរ៖

១_ ការចូលរួមគាំទ្រ ក្នុងការបង្កើនកម្មវិធី និងសកម្មភាព។

២_ ការយល់ដឹងនិងការទទួលស្គាល់អំពីសារៈសំខាន់នៃការប្រមូលផ្ដុំធនធាន។

៣- ការចេះស្វែងរកធនធាននិងការប្រមូលផ្តុំធនធាន ទាំងថវិកានិងធនធានមនុស្សទាំងពីក្នុងនិងក្រៅរដ្ឋាភិបាល។

៤- ការឈ្វេងយល់ និងសហការជាមួយរដ្ឋាភិបាលនិងផ្នែកឯកជនដើម្បីឈានទៀង។

- ការប្រមូលផ្តុំធនធាន ក្នុងអង្គការសង្គមស៊ីវិលគប្បីចៀសវាង ការប្រកួតប្រជែង ដើម្បីយកធនធាន សំរាប់បុគ្គលអង្គការមួយដើម្បីបំបាក់អង្គការមួយ។
- សហប្រតិបត្តិការ និងសាមគ្គីភាពផ្ទៃក្នុងសំខាន់ណាស់។ លក្ខណៈសម្បត្តិនេះត្រូវតែបានអភិវឌ្ឍជាមួយនឹងអភិបាលកិច្ចល្អ សុចរិតធម៌និងសេចក្តីស្មោះត្រង់[១]។

២- <u>លោកស្រី មាស សុខុម អ្នកសម្របសម្រួលកម្មវិធីប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ</u> :

- អំពីបទពិសោធន៍របស់អង្គការ (PADV) ក្នុងការប្រមូលផ្តុំធនធាន
- ដើម្បីប្រមូលផ្តុំធនធាន កសាងសង្គមស៊ីវិលមួយស្ថិតស្ថេរយូរអង្វែងបានគេគួរតែយល់ដឹងលក្ខខ័ណ្ឌ៦យ៉ាងគឺ : (១)-ត្រូវស្គាល់ខ្លួនឯងច្បាស់ថាជានរណា? មកពីណា? ទៅទីណា? ហើយត្រូវធ្វើអ្វីឬធ្វើសកម្មភាពដើម្បីអ្វី? (២)-ត្រូវមានសមត្ថភាពដឹកនាំចាត់ចែងការងារអនុវត្តន៍ ការងារទំនាក់ទំនងចងក្រងបណ្តាញទំនាក់ទំនងប្រមូលផ្តុំធនធាន និងការផ្តួចផ្តើមគំនិត (៣)-ស្គាល់សភាពការណ៍

[1] បើចង់ជ្រាបច្បាស់ សូមអានសុន្ទរកថារបស់លោក សេក បរិសុទ្ធ (តំកលទុកនៅវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ស្គាល់គោលនយោបាយរបស់ប្រទេសជាតិ (៤)_មានគោលនយោបាយត្រឹមត្រូវមានរចនាសម្ព័ន្ធការងារច្បាស់លាស់ និងមានវិន័យល្អប្រពៃ (៥)_មានឆន្ទៈ ស្មារតីទទួលខុសត្រូវ និងសាមគ្គីភាព (៦)_មានតម្លាភាព។

- អ្វីទៅជាធនធាន? : ធនធានគឺ សមត្ថភាពដឹកនាំ បុគ្គលិកអ្នកគ្រាំទ្រមូលនិធិទាំងក្នុង និងក្រៅស្រុក អ្នកចូលរួមកិច្ចសហការភាពជាដៃគូ បណ្ដាញការងារ ស្ថាប័នពត៌មាន ជំនាញ បច្ចេកទេស សំភារៈ ឯកសារ ពត៌មាន ឱកាស ពេលវេលា ការទំនាក់ទំនង ភាពជឿជាក់លើខ្លួនឯងនិងជំនឿពីអ្នកដទៃ ។ល។
- អំពីបញ្ហាប្រឈមមុខៈ កង្វះទំនាក់ទំនងគោលនយោបាយមិនច្បាស់លាស់ កង្វះសមត្ថភាព ចាត់ចែងរចនាសម្ព័ន្ធមិនសមស្របទិសដៅស្រពិចស្រពិល គ្មានតម្លាភាព កង្វះការគាំទ្រ ពីរដ្ឋាភិបាល កង្វះថវិកា ពេលវេលាមិនសមស្រប មិនយល់ការផ្លាស់ប្ដូរមិនគោរពកិច្ចព្រមព្រៀង មិនស្វែងរកដៃគូ ការងារមិនល្អ បែកបាក់សាមគ្គី ការរើសអើង ។ល។

II- អំពីលទ្ធផលនៃការពិភាក្សារួម :

- បញ្ហាប្រឈមមុខជាអាទិភាពមួយ ក្នុងការប្រមូលផ្តុំធនធាន ក្នុងសង្គមស៊ីវិល នោះគឺការផ្សព្វផ្សាយ។ បំណងច្បាស់លាស់ និងសុចរិតធម៌ ក្នុងការប្រមូលផ្តុំធនធាន ត្រូវតែបានផ្សព្វផ្សាយឱ្យទូលំទូលាយ នោះទើបប្រមូលផ្តុំបានសហប្រតិបត្តិការ និងការចូលរួម។

- ដើម្បីរក្សាបាននូវភាពជាប់លាប់របស់ខ្លួន អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវស្គាល់ច្បាស់នូវតួនាទីរបស់ខ្លួនជាដៃគូរបស់រដ្ឋាភិបាលត្រូវចេះជួយគ្នា ត្រូវចេះធ្វើការងារជាចង្កោមតាមចរិតការងារ និងត្រូវច្បាមជាប់នូវគោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាល។
- ហេតុផលដែលនាំឱ្យមានការលំបាក ក្នុងការប្រមូលផ្ដុំធនធាននោះគឺបណ្ដាលមកពីបញ្ហាមនុស្ស បញ្ហាធនធានមនុស្ស បញ្ហាថវិកានិងការគ្រប់គ្រងគ្មានអភិបាលកិច្ចល្អ និងទស្សនៈគ្រប់ជ្រុងជ្រោយ។
- កង្វះការពង្រឹងភាពជាដៃគូ ក៏ជាបញ្ហាមួយដែលផ្ដល់ការលំបាកដល់ការប្រមូលផ្ដុំធនធាន ក្នុងអង្គការសង្គមស៊ីវិលផងដែរ។ ភាពជាដៃទាំងបីដែលត្រូវពង្រឹងនោះគឺ (១)_ភាពជាដៃគូជាមួយរដ្ឋាភិបាល (២)_ភាពជាដៃគូជាមួយម្ចាស់ឧបត្ថម្ភថវិកានិង (៣)_ភាពជាដៃគូជាមួយបណ្ដាផ្នែកឯកជន។

ម្យ៉ាងវិញទៀត ការពង្រឹងជំនឿទុកចិត្តរវាងដៃគូទាំងបី គឺជាបញ្ហាសំខាន់ដែលត្រូវយកចិត្តទុកដាក់។ ជំនឿទុកចិត្តនេះនឹងកើតមានបានលើមូលដ្ឋាននៃគោលនយោបាយយុទ្ធសាស្ត្រ ច្បាស់លាស់កម្មវិធីការងារល្អ ការគ្រប់គ្រងប្រកបដោយភាពស្អាតស្អំ និងវឌ្ឍនភាពនៃធនធានមនុស្ស។

- បញ្ហាប្រឈមមុខមួយទៀត ដែលនាំឱ្យមានភាពរាំងស្ទះ ក្នុងការប្រមូលផ្ដុំធនធាន ក្នុងអង្គការសង្គមស៊ីវិលកម្ពុជា នោះគឺកង្វះការយល់ដឹង ភាពទន់ខ្សោយខាងសីលធម៌ និងកង្វះសេដ្ឋកិច្ច។ ដូច្នេះ

ការបង្កើនសមត្ថភាពយល់ដឹង និងការលើកស្ទួយគុណធម៌_សីលធម៌ ក៏ដូចជាការលើកកំពស់ជីវិតជីវភាពរស់នៅ គឺជាការចាំបាច់ណាស់ ដើម្បីកាត់បន្ថយនូវបញ្ហានេះ។

- ដើម្បីប្រមូលផ្ដុំបាននូវប្រភពធនធានទាំងឡាយសំរាប់ភាពជាប់លាប់ នៃអង្គការសង្គមស៊ីវិលគ្រប់ផ្នែកគ្រប់ថ្នាក់ គេគួរតែយកចិត្តទុកដាក់ ដល់អប់រំផ្សព្វផ្សាយ និងអនុវត្តតាមគោលការណ៍មួយចំនួនដូចខាងក្រោមនេះ ៖

  ១_ ត្រូវយល់ច្បាស់ពីបំណង និងសារៈសំខាន់ពិតប្រាកដនៃការប្រមូលផ្ដុំធនធាន។

  ២_ ត្រូវមានភាពស្រុះស្រួល ការប្ដេជ្ញាចិត្តខ្ពស់ សេចក្ដីស្មោះត្រង់ ស្មារតីតស៊ូ សាមគ្គីភាព និងសហប្រតិបត្តិការ។

  ៣_ ត្រូវចេះស៊ើបអង្កេតលទ្ធភាព ត្រូវមានស្មារតីផែនការ ត្រូវមានការចាត់តាំងអនុវត្ត ត្រូវមានការត្រួតពិនិត្យ បូកសរុបដកពិសោធន៍ និងដៅទិសអនុវត្ត

## III- សេចក្ដីសន្និដ្ឋាន

កិច្ចពិភាក្សាតុមូលលើកទី ១០ បានសន្និដ្ឋាននៅទីបញ្ចប់ថា :

- ការប្រមូលធនធាន ដើម្បីអភិវឌ្ឍន៍ គឺជាការសំខាន់ណាស់សំរាប់និរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា។
- ការប្រមូលផ្ដុំនេះនឹងធ្វើបានល្អ លុះណាតែអង្គការសង្គមស៊ីវិលទាំងអស់ចាត់តាំងបង្កើតឱ្យមានគណៈកម្មាធិការ សំរបសំរួលការងារមួយ

ដើម្បីជាស្នូលនៃការប្រមូលផ្តុំ។ គណៈកម្មាធិការនេះ ត្រូវបំរើគោលបំណងរួម ត្រូវមានការគ្រប់គ្រងល្អ ត្រូវមានផែនការនិងកម្មវិធីត្រឹមត្រូវក្នុងការបំរើផលប្រយោជន៍និងភាពជាប់លាប់នៃសង្គមស៊ីវិលកម្ពុជា។

- ធនធានសំខាន់ដែលត្រូវប្រមូលផ្តុំ និងចែករំលែកមាន ៖ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សំភារៈបរិក្ខារ សមត្ថភាពបំពេញការងារ បច្ចេកទេស_វិជ្ជាជីវៈ បទពិសោធន៍ ពត៌មាន សុចរិតធម៌ក្នុងការគ្រប់គ្រង សហប្រតិបត្តិការនិងគំរោងកម្មវិធីអភិវឌ្ឍន៍ ។ល។
- និរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា ដែលបានមកពីការប្រមូលផ្តុំធនធានមិនអាចកើតមានបានលើភាពល្ងង់ខ្លៅទេ គឺកើតមាននៅលើចំណេះដឹង សមត្ថភាពចាត់ចែងការងារអភិបាលកិច្ចល្អ និងសេចក្តីស្មោះត្រង់។

ការងារនេះនឹងធ្វើបានល្អអាស្រ័យទៅលើការយល់ដឹងពីបំណងពីសារៈសំខាន់នៃការប្រមូលផ្តុំធនធាននិងការប្តេជ្ញាចិត្តខ្ពស់របស់អង្គការសង្គមស៊ីវិលខ្លួនឯង។ គឺកត្តាខ្លួនឯងដែលមានភាពច្បាស់លាស់ និងការយល់ដឹងត្រូវនេះហើយ ដែលអាចទប់ស្កាត់បាននូវគ្រប់បញ្ហាប្រឈមមុខទាំងឡាយ ក្នុងការប្រមូលផ្តុំធនធាន ដើម្បីកសាងភាពជាប់លាប់ (និរន្តរភាព) នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា៕

## III. ការបូកសរុបលទ្ធផលសន្និសីទជាតិ ស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងក្តីសង្ឃឹម"

សន្និសីទជាតិ ស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខនិងក្តីសង្ឃឹម" បានប្រព្រឹត្តទៅនិងបានបញ្ចប់ជាស្ថាពរ កាលពីថ្ងៃទី ៤_៥ ខែធ្នូ ឆ្នាំ ២០០០ នៅវិមានរដ្ឋាភិបាល វត្តភ្នំ រាជធានីភ្នំពេញ។ សន្និសីទដ៏មានសារៈសំខាន់នេះ ត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព (វ.ខ.ស.ស.) ក្រោមជំនួយឧបត្ថម្ភជាមូលនិធិពីហេនរិច បូលនៃប្រទេសអាឡឺម៉ង់ Heinirch Böll Foundation (HBF)។

ប្រធានបទ នៃអង្គសន្និសីទ បានប្រមូលផ្តុំទៅលើទស្សនៈមួយចំនួនជាសំខាន់ដូចតទៅនេះ៖

តាមការប្រមើលមើលទំនោរថ្មី នៃប្រទេសកម្ពុជា ក្នុងបណ្តាឆ្នាំក្រោយសម័យសង្គ្រាម យើងបានឃើញថា កម្ពុជាពិតជាត្រូវការរបៀបរបបដឹកនាំ និងគ្រប់គ្រងមួយ ដែលមានលក្ខណៈជឿនលឿនស្អាតស្អំបរិសុទ្ធ នោះទើបអាចរំដោះជាតិយើង ឱ្យរួចផុតពីភាពក្រីក្រ ការប្រព្រឹត្តិអំពើពុករលួយ និងសង្គ្រាមវិនាសកម្មបាន។ អាស្រ័យដោយ

ឥទ្ធិពលនៃសង្គ្រាមយូរអង្វែង និងការបាត់បង់ទៅនូវតម្លៃសីលធម៌_គុណធម៌ខាងផ្លូវចិត្តគំនិត ការដឹកនាំនិងគ្រប់គ្រងជាតិយើង ត្រូវបានជួបនឹងអភិបាលកិច្ចមិនល្អជាបន្តបន្ទាប់។ ម្ល៉ោះហើយ ផលទុនជាតិ ភោគផល និងបរិស្ថានធម្មជាតិ នៃមាតុភូមិយើង ត្រូវបានបំផ្លិចបំផ្លាញដោយការគ្រប់គ្រងបែបញាតិបក្សនិយមនិងការកេងប្រវ័ញ្ច ដោយគ្មានការបែងចែកឱ្យមានសមធម៌អ្វីឡើយ។ ដរាបណាជាតិយើងរកពុំឃើញឱ្យបានទាន់ពេលនូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អទេ នោះប្រទេសជាតិយើង ពុំអាចអភិវឌ្ឍឈានទ្បើង ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ អប់រំ សង្គមកិច្ច និងវប្បធម៌ ក៏ដូចជាវិស័យយោធា និងសន្តិសុខជាតិ ឱ្យទាន់គេឯងក្នុងតំបន់ តាមរយៈសមាហរណកម្មនៃយុគសម័យឡើយ។ គឺជាការខកខាន និងយឺតយ៉ាវមួយ ប្រសិនបើកម្ពុជា នៅតែបណ្តែតបណ្តោយឱ្យការដឹកនាំនិងគ្រប់គ្រងនៃសង្គមជាតិស្ថិតនៅក្នុងភាពអសកម្ម ភុំរ៉ៃក្របដណ្តប់ដោយការតែបន្លំ និងអំពើពុករលួយ។

ដើម្បីជំនះបាន នូវការខ្វះខាតនេះ មធ្យោបាយមានតែមួយទេ នោះគឺការប្រើកម្លាំងរួម សហប្រតិបត្តិការរួម និងការប្តេជ្ញាចិត្តខ្ពស់ពីគ្រប់និន្នាការនយោបាយក្នុងសង្គមជាតិ ពិសេសគឺគំរូភាពក្នុងការលើកស្ទួយការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ ពីអង្គការសង្គមស៊ីវិលកម្ពុជា និងបណ្តាផ្នែកឯកជន ជាមួយនឹងអង្គការរដ្ឋគ្រប់ជាន់ថ្នាក់។ ដោយមានសារៈកំណើត និងតួនាទីជាសារវ័ន្តរបស់ខ្លួន ក្នុងការស្វែងរក ក៏ដូចជាការរក្សាការពារផលប្រយោជន៍របស់សមាជិក និងសង្គមជាតិ

ទាំងមូល អង្គការសង្គមស៊ីវិលខ្មែរ គ្រប់ជាន់ថ្នាក់ត្រូវតែចូលរួមចំណែកអភិវឌ្ឍវប្បធម៌ប្រជាធិបតេយ្យមួយជឿនលឿន ដែលមានសារៈដល់ការអប់រំចិត្តគំនិតឱ្យមានអភិបាលកិច្ចល្អ និងសុចរិតធម៌។

ដោយសារតែប្រទេសជាតិយើង ត្រូវអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ខ្លួនឱ្យបានរុងរឿងឆាប់រហ័ស ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយគុណភាព នៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្រោយសម័យសង្គ្រាមដ៏យូរលង់នេះ ក៏ដូចជាដើម្បីជម្រុញការចូលរួម ក្នុងតំបន់របស់យើងឱ្យកាន់តែមានភាពល្អប្រសើរឡើង ប្រទេសជាតិយើងចាំបាច់ត្រូវប្រឈមមុខនឹងបញ្ហាសំខាន់ពីរ : មួយ គឺការគ្រប់គ្រងឱនថយដែលគ្មានការទទួលខុសត្រូវ។ ពីរ គឺការគ្រប់គ្រងដែលគ្មានអភិបាលកិច្ចល្អ និងសុចរិតធម៌។ ទាំងពីរនេះ គឺជាបញ្ហាដែលជនជាតិយើង ពិសេសគឺមគ្គុទ្ទេសភាពរបស់យើងកំពុងជួបប្រទះ។

ដូច្នេះ សន្និសីទជាតិក្នុងរយៈពេលពីរថ្ងៃនេះ បានគិតពិចារណា និងឃើញនូវទស្សនវិស័យ ចំណេះដឹង និងបទពិសោធន៍ល្អៗមួយចំនួនក្នុងការដឹកនាំនិងគ្រប់គ្រងប្រទេសជាតិ។

បំណងដ៏ពិសិដ្ឋនៃការរៀបចំឱ្យមានសន្និសីទជាតិយើង នោះគឺដើម្បីពិនិត្យមើលលទ្ធផល នៃកិច្ចពិភាក្សាតុមូលរយៈពេល១០លើកស្តីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា" ដែលបានរៀបចំឡើង

ដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព អស់រយៈពេលពេញមួយឆ្នាំកន្លងមកនេះ។

ការត្រួតពិនិត្យនូវលទ្ធផលនោះ គឺជាការបំពេញបន្ថែមឬការឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈ និងបទពិសោធន៍ដែលកិច្ចពិភាក្សាតុមូលទាំង ១០លើក បានរកឃើញអំពីអត្ថន័យ និងសារៈសំខាន់នៃអភិបាលកិច្ចល្អ និងតួនាទីរបស់សង្គមស៊ីវិលកម្ពុជា ក្នុងការលើកស្ទួយអភិបាលកិច្ចល្អឱ្យទៅជាវប្បធម៌ដឹកនាំ និងគ្រប់គ្រងមួយរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង ពិសេសគឺរបស់អ្នកដឹកនាំនិងគ្រប់គ្រងជាតិគ្រប់ជាន់ថ្នាក់។ ការលើកកំពស់វប្បធម៌នៃការដឹកនាំឱ្យមានអភិបាលកិច្ចល្អ នោះគឺដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្រ និងយុត្តិធម៌សង្គម។

ក្រោយពីបញ្ចប់អង្គសន្និសីទនោះទៅ ចំណេះដឹង និងបទពិសោធន៍ទាំងឡាយ ដែលបានរកឃើញត្រូវតែបានផ្សព្វផ្សាយ ដើម្បីជាគុណប្រយោជន៍ដល់ការដឹកនាំ និងគ្រប់គ្រងសង្គមជាតិឱ្យមានភាពស្អាតស្អំ គ្មានអំពើកែបន្លំ និងអសមធម៌ក្នុងសង្គម។

វត្ថុបំណងជាសក្តានុពលមួយទៀត ដែលអង្គសន្និសីទត្រូវរកឱ្យឃើញនោះគឺ "តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ អភិបាលកិច្ចល្អនៅអង្គការរបស់ខ្លួន"។ ការបំពាក់ និងកំណត់បាននូវតួនាទីជាសារវ័ន្ត(Essential Roles) និងភារកិច្ចដ៏ចាំបាច់របស់សង្គមស៊ីវិលកម្ពុជា

ដែលមានចំនួនកើតឡើង ក្នុងបច្ចុប្បន្នមិនតិចជាង១០០០អង្គការទៅហើយនោះ គឺជាការជួយស្ថាបនាកម្លាំងចលករ ( A motive force) ដ៏ស្រួចស្រាវមួយដើម្បីបានជាដៃគូ ជាមួយរដ្ឋាភិបាល ក្នុងការអប់រំផ្សព្វផ្សាយ អនុវត្តទស្សនាទាន និងគុណប្រយោជន៍នៃអភិបាលកិច្ចល្អ ដែលជាសំណូមពរដ៏ទទូច និងចាំបាច់ជាបន្ទាន់របស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង ក្នុងការដឹកនាំនិងគ្រប់គ្រងជាតិឱ្យមានអភិបាលកិច្ចល្អពិតប្រាកដក្រោយសម័យសង្គ្រាមនេះ។

សន្និសីទជាតិ រយៈពេលពីរថ្ងៃ ស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខនិងក្តីសង្ឃឹម" បានមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយមានវត្តមាននៃស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍ ប្រធានគណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងជាឧត្តមក្រុមប្រឹក្សាផ្ទាល់នៃព្រះមហាក្សត្រកម្ពុជា និងវត្តមាននៃលោកស្រី បណ្ឌិត ហៃគីឡូស្មាន់ នាយិកានៃមូលនិធិ ហេនរិច បូល នៃប្រទេសអាឡឺម៉ង់ដ៏ការិយាល័យប្រចាំតំបន់អាស៊ីភាគអគ្នេយ៍ ក្នុងពិធីបើកនិងបិទអង្គសន្និសីទដ៏មានសារៈសំខាន់នោះផង។

គណៈអធិបតី និងវាគ្មិនកិត្តិយស ភាគច្រើនសុទ្ធសឹងជាវរជន និងជាអ្នកដឹកនាំអង្គសង្គមស៊ីវិលសំខាន់ៗ ដែលកំពុងធ្វើសកម្មភាពទាំងនៅក្នុងនិងក្រៅរដ្ឋាភិបាល។ រីឯសមាជិកចូល រួមទាំងអស់

ក៏សុទ្ធសឹងជាអ្នកដឹកនាំ និងអ្នកទទួលខុសត្រូវនិងជាអ្នកតំណាងអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ រួមទាំងម្ចាស់ឧបត្ថម្ភថវិកាមួយចំនួនផង។

សន្និសីទថ្នាក់ជាតិនេះ បានរៀបចំសម័យប្រជុំ និងបែងចែកសម័យប្រជុំរបស់ខ្លួន ជាប្រាំមួយផ្នែក។ ផ្នែកនីមួយៗសុទ្ធតែប្រធានបទសំខាន់ និងក្រុមវាគ្មិនជំនាញ តាមប្រធានបទនោះ។ ពីធីបើក និងបិទអង្គសន្និសីទត្រូវបានរៀបចំឡើង តាមរយៈការចោទនិងដោះស្រាយអំពីបញ្ហានៃការស្ថាបនាអង្គការសង្គមស៊ីវិលខ្មែរ ដើម្បីបុព្វហេតុនៃការអភិវឌ្ឍន៍អភិបាលកិច្ចល្អនៅកម្ពុជា។

សម័យប្រជុំទីមួយ និយាយអំពី របាយការណ៍សង្ខេប ស្ដីពីលទ្ធផលនៃកិច្ចពិភាក្សាតុមូលទាំង១០លើកក្នុងឆ្នាំ២០០០ អំពីអភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា។ របាយការណ៍នេះ បាននិយាយយ៉ាងល្អិតល្អន់ អំពីទស្សនៈ ចំណេះដឹង បទពិសោធន៍ ដែលប្រមូលផ្ដុំបានក្នុងពេលបើកកិច្ចពិភាក្សាតុមូល ដែលជាមូលដ្ឋានដ៏សំខាន់ដល់កិច្ចពិភាក្សាក្នុងសម័យប្រជុំទាំងអស់នៃអង្គសន្និសីទ។ របាយការណ៍នេះមានអត្ថន័យ ខ្លីខ្លឹមសង្ខេប តែមានលក្ខណៈប្រមូលផ្ដុំ ដកពិសោធន៍និងដៅទិសអនុវត្ត។ ក៏ប៉ុន្តែ នោះគឺពុំមែនមានន័យថា ល្អឥតខ្ចោះនោះទេ។ គឺនៅមានការខ្វះខាតជាច្រើន។

ក្នុងសម័យប្រជុំបន្តបន្ទាប់ទៀត អង្គសន្និសីទបានរកឃើញថា : ដើម្បីបុព្វហេតុ នៃមគ្គុទ្ទេសភាពនៃប្រទេសកម្ពុជា អភិបាលកិច្ចល្អមាន

គោលដៅសំខាន់បី គឺ : (១)_ដើម្បីកាត់បន្ថយភាពក្រីក្រ (២)_ដើម្បីបង្កើនប្រាក់ចំណូលនិង (៣)_ដើម្បីធានាកំណើនសេដ្ឋកិច្ចជាតិឱ្យប្រកបដោយចីរភាព។

ការពង្រឹងអភិបាលកិច្ចល្អនៅកម្ពុជា អាចនឹងផ្តល់នូវគុណប្រយោជន៍ ៤យ៉ាងទៀត ដែលគប្បីយល់ឱ្យបាន។ គុណប្រយោជន៍ទាំង៤នោះ គឺ(១)_ជាគន្លឹះសំខាន់សំរាប់អូសទាញ ការវិនិយោគទុនបរទេស (២)_សំរាប់ការអភិវឌ្ឍន៍ជាតិ ដើម្បីកាត់បន្ថយការប្រព្រឹត្តអំពើពុករលួយ និងការកេងប្រវ័ញ្ចន៍ (៣)_សំរាប់ពង្រឹងជំនឿទុកចិត្ត និង (៤)_អាចកាត់បន្ថយបានភាពក្រីក្រ។

សង្គមស៊ីវិលមានតួនាទីសំខាន់ណាស់ ក្នុងការជួយអប់រំបណ្តុះបណ្តាលអំពីអភិបាលកិច្ចល្អ ជូនសង្គមជាតិតាមរយៈភាពធ្វើគំរូ និងអភិវឌ្ឍអភិបាលកិច្ចល្អឱ្យកើតមានពិតប្រាកដ នៅក្នុងផ្នត់គំនិតរបស់ខ្លួន។ នោះគឺជាតួនាទីចំពោះខ្លួនឯងផង និងចំពោះសង្គមជាតិផង។

□ <u>អំពីមត្តុទ្ទេសភាព និងការទទួលខុសត្រូវ</u> :

កាលណានិយាយអំពីមត្តុទ្ទេសភាព និងការទទួលខុសត្រូវគ្រប់ផ្នែកគ្រប់ថ្នាក់ គឺត្រូវនិយាយអំពី លក្ខណៈសម្បត្តិពីររបស់អ្នកដឹកនាំ នោះគឺភាពជាអ្នកដឹកនាំល្អ និងការទទួលខុសត្រូវ។

ជាតិយើង ព្រោះតែសង្គ្រាមឈ្លានពានរ៉ាំរ៉ៃបានបាត់បង់ស្ទើរតែអស់ទៅហើយ នូវភាពជាអ្នកដឹកនាំល្អនិងការទទួលខុសត្រូវ។ គេបាន

វាយតម្លៃថា ហេតុផលដែលនាំឱ្យមានភាពឱនថយ និងវិបត្តិទាំងឡាយនៃសង្គមជាតិយើង មួយផ្នែកធំគឺបណ្តាលមកពី "វិបត្តិដឹកនាំ" នេះ។

ជាការពិតណាស់ ការដឹកនាំនិងការទទួលខុសត្រូវ គឺគ្រាន់តែទង្វើ ឬសកម្មភាពខាងផ្លូវកាយរបស់មនុស្សតែប៉ុណ្ណោះ។ ការដឹកនាំនិងការទទួលខុសត្រូវអាក្រក់ឬល្អ វាអាស្រ័យទៅលើចិត្តគំនិតរបស់មនុស្ស។ បើចង់កែប្រែសង្គម គឺត្រូវកែប្រែមជ្ឈដ្ឋានរស់នៅរបស់មនុស្ស។ កែប្រែមជ្ឈដ្ឋានរស់នៅរបស់មនុស្ស គឺត្រូវកែប្រែចិត្តគំនិតរបស់មនុស្សដែលរស់នៅក្នុងមជ្ឈដ្ឋាននោះ។

ដូច្នេះ ប្រសិនបើគេចង់ធ្វើឱ្យមគ្គុទ្ទេសភាព និងការទទួលខុសត្រូវមានកំរិតខ្ពស់នៅក្នុងស្ថាប័នរដ្ឋ ស្ថាប័នសភាទាំងពីរ និងនៅក្នុងអង្គការសង្គមស៊ីវិលគ្រប់ថ្នាក់គ្រប់ផ្នែក គេត្រូវតែកែប្រែផ្នត់គំនិតរបស់អ្នកដឹកនាំ។ គឺគុណធម៌ខាងផ្លូវចិត្តគំនិតនេះហើយ ដែលអាចនាំឱ្យអ្នកដឹកនាំមានមគ្គុទ្ទេសភាពល្អ និងការទទួលខុសត្រូវខ្ពស់។

- ក្នុងសម័យប្រជុំទី២ ស្តីពី ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា អង្គសន្និសីទបានរកឃើញថា ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងអង្គការសង្គមស៊ីវិលមានសារៈសំខាន់ណាស់។ នោះគឺជាកត្តាស្លាប់រស់របស់អង្គការសង្គមស៊ីវិលកម្ពុជា។ បើគ្មានការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនេះទេ សង្គមស៊ីវិលមិន

អាចអភិវឌ្ឍរឹងមាំបាននទេ។ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាព នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិបីគឺ (១)_ត្រូវមានសមត្ថភាពយល់ដឹងទូលំទូលាយ (២)_ត្រូវមានសមត្ថភាពបច្ចេកទេសវិជ្ជាជីវៈខ្ពស់ និង(៣)_ត្រូវមានសុចរិតធម៌និង គុណធម៌ល្អ។

ធនធានមនុស្ស ដែលសង្គមជាតិយើងត្រូវមាននិងចង់បាន គឺជាធនធានមនុស្ស ដែលមានគុណភាពខាងផ្លូវចិត្តគំនិតសុចរិត មានសាមគ្គីភាព និងសេចក្តីអត់ឱន មានសច្ចៈយុត្តិធម៌ មានមនុស្សធម៌ ឯករាជ្យ អព្យាក្រឹត ឥតលំអៀងមានទស្សនៈជឿនលឿន និងអភិវឌ្ឍមានភាពប្រាកដនិយមនឹងនរ និងឧស្សាហ៍ព្យាយាម។

ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា ត្រូវផ្សារភ្ជាប់ទៅនឹងមុខសញ្ញា៦យ៉ាងគឺ ៖ (១)_សេចក្តីត្រូវការ (២)_កាលៈទេសៈ (៣)_ចរន្តអភិវឌ្ឍន៍សង្គម (៤)_បំណងប្រាថ្នារបស់ប្រជាពលរដ្ឋ (៥)_គុណភាពនៃជីវភាពរស់នៅ និង (៦)_កម្មវិធីកែទម្រង់ និងអភិវឌ្ឍន៍របស់ប្រទេសជាតិ។

ឆ្លងតាមរយៈការផ្លាស់ប្តូរមតិយោបល់ ក្នុងសម័យប្រជុំទី៤ស្តីពីឥទ្ធិពលនៃសាកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា អង្គពិភាក្សាបានរកឃើញថា សាកលភាវូបនីយកម្មមានសារៈប្រយោជន៍ដល់ការកសាង និងអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលកម្ពុជា ក៏ដូចជាក្នុងការកសាង

និងអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ក៏ប៉ុន្តែទន្ទឹមនេះ សាកលភាវូបនីយកម្ម ក៏បានផ្តល់ផលវិបាកជាច្រើនឱ្យសង្គមខ្មែរផងដែរ។ ផលវិបាកទាំងនោះ គឺ: (១)_ភាពក្រីក្រដែលកាន់តែក្រីក្រទៅ (២)_ការបាត់បង់សីលធម៌ និងគុណធម៌ជាតិ (៣)_ការបាត់បង់ដី ត្រី និងព្រៃឈើ (៤)_ការបាត់បង់ពលកម្ម (៥)_ការរាតត្បាតនៃជម្ងឺអេដស៍ (៦)_ការជួញដូរកុមារនិងស្ត្រីភេទ (៧)_ការជួញដូរគ្រឿងញៀន (៨)_ឧក្រិដ្ឋកម្មឆ្លងដែន អំពើពុករលួយ ការលាងលុយកខ្វក់ ពេស្យាចារ និងការបាត់បង់សន្តិសុខមនុស្ស។ សង្គមស៊ីវិលកម្ពុជា មានតួនាទីសំខាន់ណាស់ក្នុងការទទួលយកគុណប្រយោជន៍នៃសកលភាវូបនីយកម្ម និងទប់ស្កាត់ផលវិបាកនៃសកលភាវូបនីយកម្ម។ ដើម្បីសំរេចគោលដៅនេះ សង្គមស៊ីវិលត្រូវរៀបខ្លួនប្រឈមមុខ នឹងបញ្ហាសំខាន់បីយ៉ាងគឺ (១)_ត្រូវចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដើម្បីឧត្តមភាពជាតិខ្លួនដោយខ្លួនឯង (២)_ត្រូវជួយលើកស្ទួយ និងដោះស្រាយបញ្ហាសន្តិសុខសង្គម សុខាភិបាល និង(៣)_ត្រូវជួយលើកំពស់ការអភិវឌ្ឍន៍ធនធានមនុស្ស។

ដើម្បីទប់ស្កាត់ផលវិបាកសង្គម ដែលបង្កឡើងដោយសកលភាវូបនីយកម្មបាន លុះណាតែមានការពង្រឹងអភិបាលកិច្ចល្អឱ្យមានរឹងមាំនិងមធ្យ័ត និងការពង្រឹងការគ្រប់គ្រងសង្គមដោយច្បាប់ឬនីតិរដ្ឋផង។

អំពី "តួនាទីរបស់សង្គមស៊ីវិល ក្នុងការរក្សាការពារសន្តិសុខមនុស្ស" :

ក្នុងសម័យប្រជុំទី៥ អង្គពិភាក្សាបានរកឃើញថាៈ ទ្រព្យសម្បត្តិដ៏ប្រសើរលើសទ្រព្យសម្បត្តិទាំងឡាយរបស់ប្រទេសជាតិមួយ នោះគឺប្រជាពលរដ្ឋ។ បើប្រជាពលរដ្ឋទទួលការជិះជាន់សង្កត់សង្កិន ការរំលោភបំពាន ឬការគំរាមកំហែងខាងរូបរាងកាយ ក៏ដូចជាចិត្តគំនិត ប្រទេសជាតិនោះ ក៏ត្រូវទទួលរងនូវអំពើទាំងនេះដូចប្រជាពលរដ្ឋដែរ។ បើប្រជាពលរដ្ឋល្ងង់ខ្លៅគ្មានការងារធ្វើ ក្រីក្រល្ហេមល្ហាម ប្រទេសជាតិនោះក៏មានសភាពដូចគ្នានោះដែរ។ សន្តិសុខមនុស្សឬប្រជាពលរដ្ឋមានអត្ថន័យគ្របដណ្ដប់ជាសំខាន់ទៅលើសិទ្ធិនៃការរស់នៅ និងអាយុជីវិតនៃប្រជាពលរដ្ឋ។ ការបាត់បង់សន្តិសុខមនុស្ស គឺជាការបាត់បង់សិទ្ធិរស់នៅ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ។ ក្នុងករណីនេះ សង្គមស៊ីវិលកម្ពុជាមានតួនាទីសំខាន់ណាស់ ក្នុងការជួយតាមដានឃ្លាំមើល ជួយទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ការសម្លាប់ជីវិតមនុស្សក្រៅច្បាប់ ជួយពង្រឹងការគោរពសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អ ជួយកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយការអប់រំសីលធម៌សង្គម និងអហឹង្សាធម៌។ សង្គមស៊ីវិលត្រូវប្រកាន់ជំហរជាអ្នកអប់រំផង និងជាដៃគូរបស់រដ្ឋាភិបាលក្នុងការការពារសន្តិសុខមនុស្សផង។

ម្យ៉ាងវិញទៀត ក្នុងសម័យប្រជុំទី៣ អង្គពិភាក្សាបានកត់កំណត់ថា ដើម្បីកសាងបណ្ដាញសង្គមស៊ីវិលបានល្អ សង្គមស៊ីវិលកម្ពុជាគ្រប់ជាន់ថ្នាក់ គួរគិតពិចារណាឱ្យបានល្អិតល្អន់ អំពីការកសាងបណ្ដាញធំពីរយ៉ាងគឺ *ការកសាងបណ្ដាញរស់* និង *ការកសាងបណ្ដាញស្លាប់*។

ការកសាងបណ្ដាញរស់ គឺការកសាងបណ្ដាញ ដើម្បីការអភិវឌ្ឍន៍រួមគ្នា ដើម្បីគោលដៅរួមឬ ការឈានទៀងដូចៗគ្នា និងការចេះបែងចែកផលប្រយោជន៍ឱ្យគ្នា ដោយការយោគយល់។ រីឯការកសាងបណ្ដាញស្លាប់ គឺជាការកសាងបណ្ដាញ ដើម្បីបំផ្លាញបណ្ដាញ ឬដោយគំនិតឈ្នានីស មានមហិច្ឆតាត្រួតត្រាយកផលប្រយោជន៍ និងការកេងប្រវ័ញ្ចន៍ឬដោយល្បិចកលនយោបាយ ខ្វះសេចក្ដីស្មោះត្រង់។ ទន្ទឹមនឹងប្រធានបទទាំងឡាយខាងលើ អង្គពិភាក្សាបានរកឃើញ ក្នុងសម័យប្រជុំទី៦ ស្ដីពី "សង្គមស៊ីវិល និងគម្រោងច្បាប់នៅប្រទេសកម្ពុជា : បញ្ហាប្រឈមមុខ និងទិសដៅទៅអនាគត" ថា អំពីស្ថានភាពជាក់ស្ដែងនៃគម្រោងច្បាប់ NGOs ទោះបីក្រសួងមហាផ្ទៃ បានធ្វើការកែសំរួលមួយលើកជាពីរលើកមកហើយក៏ដោយ ក៏នៅនៅតែមិនទាន់ចេញរួចនៅឡើយ។ ឆ្លងតាមរយៈការពិភាក្សា ការផ្លាស់ប្ដូរទស្សនៈ និងក្ដីកង្វល់អង្គការសង្គមស៊ីវិលទាំងអស់បានស្នើសុំថា ច្បាប់គ្រប់គ្រងអង្គការសង្គមស៊ីវិលគួរតែមានការចូលរួមរបស់អង្គការសង្គមស៊ីវិល និងគួរតែតម្រូវទៅតាមសំណូមពរ និងសេចក្ដីត្រូវការរបស់សង្គមស៊ីវិលផង។ ច្បាប់ NGOs ពុំគួរមានលក្ខណៈ ដូច "កាត់ជើងតម្រូវតាមស្បែកជើងនេ គឺត្រូវកាត់ស្បែកជើងតម្រូវតាមជើង បើកាត់ជើងតម្រូវតាមស្បែកជើង ជើងនោះនឹងចេញឈាម"។ អង្គពិភាក្សាស្នើសុំឱ្យរាជរដ្ឋាភិបាល និងសភាទាំងពីរពិចារណារឿងនេះឱ្យល្អិតល្អន់ និងស្នើសុំឱ្យទទួលយក ការចូលរួមមតិរបស់ថ្នាក់ក្រោមផង ក្នុងការបង្កើត និងអនុម័តច្បាប់ទាំងឡាយ។

សរុបសេចក្ដីមក អង្គសន្និសីទជាតិ ស្ដីពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងក្ដីសង្ឃឹម" គឺជាសាលារៀនដ៏ទូលំទូលាយមួយ ដែលមានសារៈប្រយោជន៍ បំផុតដល់ការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ។ ការផ្លាស់ប្ដូរមតិយោបល់ចម្រុះ ទស្សនៈរួម និងដោយឡែក មតិបដិបក្ខជាចំហនៅលើវេទិកាសេរី គឺជាចំណុចចាប់ផ្ដើមដ៏ល្អមួយ ក្នុងការជួយស្ដាបនាវប្បធម៌ ប្រជាធិបតេយ្យសេរី និងអភិបាលកិច្ចល្អ។ ចំណុចដែលល្អនោះគឺត្រង់ថា សមាជិកនៃអង្គពិភាក្សាទាំងអស់ មានសិទ្ធិសេរីភាពក្នុងការបញ្ចេញ មតិតាមការយល់ឃើញរបស់ខ្លួន។ វេទិកាសេរីនេះ បានផ្ដល់នូវក្ដីសង្ឃឹមចំពោះការរីកលូតលាស់រុងរឿងនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

អភិបាលកិច្ចល្អ បើតាមទស្សនៈរបស់អង្គសន្និសីទ គឺជាទស្សនាទាននៃសុចរិតធម៌ ក្នុងការដឹកនាំ និងគ្រប់គ្រងដែលកំពុងពេញនិយមនៅក្នុងតំបន់ និងលើសកលលោក។ នៅប្រទេសកម្ពុជា អភិបាលកិច្ចល្អ គឺជាតម្រូវការ ពុំអាចខ្វះបានក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្រោយសម័យសង្គ្រាម។ ជាងពេលណាៗទាំងអស់ អភិបាលកិច្ចល្អ ឬភាពស្អាតស្អំក្នុងការដឹកនាំ និងគ្រប់គ្រងនេះ បានត្រូវប្រជាពលរដ្ឋគាំទ្រ និងទទួលយក ជាគោលការណ៍គ្រប់គ្រង ដែលមានគុណប្រយោជន៍បំផុតដល់ការកសាងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិឱ្យរួចផុតពីភាពឱនថយ និងក្រីក្រតោកយ៉ាក។ ជាចំណុចខ្វះខាត យើងពុំសង្កេតឃើញមានច្រើនទេ។ សមាជិកដែលបានចូលរួមក្នុងគ្រប់សម័យ

ប្រជុំនៃអង្គសន្និសីទជាតិនេះ ទោះបីអញ្ជើញមកពីគ្រប់និន្នាការនយោបាយក្ដី ក៏អស់លោក លោកស្រីទាំងអស់ រក្សាបាននូវការគិតគូរពីផលប្រយោជន៍ជាតិជាធំជាងផលប្រយោជន៍របស់គណបក្សនយោបាយរបស់អស់លោក។ គឺជាបទពិសោធន៍មួយដ៏ប្រពៃណាស់ ដែលប្រទេសកម្ពុជា បង្កើតបាននូវច្បាប់រដ្ឋធម្មនុញ្ញមួយ ដែលបានកំណត់គោលការណ៍ដឹកនាំនិងគ្រប់គ្រងប្រទេសជាតិ តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការនិយាយស្ដី ក្នុងការបង្កើតសមាគមឬបក្សនយោបាយផ្សេងៗ ដែលត្រូវបានហាមឃាត់ពីសង្គមមុនត្រូវបានធានា។ គឺផ្ដើមចេញពីការធានាខាងផ្លូវច្បាប់នោះ ហើយដែលធ្វើឱ្យការប្រជុំបញ្ចេញមតិយោបល់ និងទស្សនៈ នៅលើវេទិកាសេរីដូចមានក្នុងអង្គសន្និសីទជាតិនេះ និងនៅក្នុងសម័យប្រជុំ ទាំងឡាយមានកំណើតឡើង។ ការចូលរួមមតិរបស់មហាជន និងប្រជាពលរដ្ឋនៅក្នុងការដឹកនាំនិងគ្រប់គ្រង ពិសេសគឺមតិយោបល់របស់សមាជិកនៃអង្គការសង្គមស៊ីវិលទាំងអស់ មានសារៈសំខាន់ដល់ការកសាង និងអភិវឌ្ឍន៍សង្គមជាតិ។ យ៉ាងណាមិញ ការពង្រឹងគុណភាពនៃការដឹកនាំប្រកបដោយអភិបាលកិច្ចល្អ តាមរយៈការអប់រំផ្សព្វផ្សាយ ក៏ដូចជាការបណ្ដុះបណ្ដាល គឺពិតជាទាមទារឱ្យមានការគិតគូរអំពីការចូលរួមនេះជាសំខាន់ណាស់។ ឆ្លងតាមរយៈការផ្លាស់ប្ដូរ ទស្សនៈ និងមតិយោបល់ ទាំងនៅក្នុងសម័យប្រជុំទាំង៦ នៃអង្គសន្និសីទ ក៏ដូចជានៅក្នុងពិធីបើក និងបិទអង្គសន្និសីទ យើងអាចប្រមូលផ្ដុំបានចក្ខុ

វិស័យល្អៗ ជាច្រើនសំរាប់ធ្វើឱ្យមានការចូលរួមមតិល្អៗ ច្រើនទៀត ដើម្បីស្ថាបនាសង្គមស៊ីវិលកម្ពុជា និងអភិបាលកិច្ចល្អឱ្យមានភាពរឹងមាំ។ ការបង្កើតឱ្យមានការប្រជុំសិក្សា សិក្ខាសាលា នាទីពិភាក្សា និង សន្និសីទ ឬក៏ក្រុមការងារសិក្សាស្រាវជ្រាវ អំពី "សង្គមស៊ីវិលនិង អភិបាលកិច្ចល្អនៅកម្ពុជា" ឱ្យបានច្រើនថែមទៀត ដើម្បីប្រមូលផ្តុំមតិ និងទស្សនៈល្អៗ សំរាប់កសាងអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុនៃ វឌ្ឍនភាពអភិបាលកិច្ចល្អនៅប្រទេសកម្ពុជា គឺជាតម្រូវការចាំបាច់មិន អាចខ្វះបាន។ ប្រធានបទនៃការពិភាក្សា ត្រូវមានចរិតឯករាជ្យ ពី កិច្ចការនយោបាយរបស់គណបក្ស និងត្រូវបំរើតែគោលដៅអភិវឌ្ឍន៍ សង្គមស៊ីវិលនិងអភិបាលកិច្ចល្អមួយប៉ុណ្ណោះ។ ទន្ទឹមនោះ សេរីភាពក្នុង ការបញ្ចេញមតិត្រូវតែបានធានា។ សេចក្តីយោគយល់ អាធ្យាស្រ័យ និង ការលើកលែងទោស ចំពោះពាក្យពេចន៍ខុសឆ្គង ឬកំហុសដោយ អចេតនា ក្នុងការបញ្ចេញទស្សនៈ យោបល់ ត្រូវតែមាន បើពុំដូច្នោះ ទេ យើងពុំអាចប្រមូលផ្តុំបាន មតិយោបល់ល្អៗរបស់មហាជនបានទេ។

ជារួម អង្គពិភាក្សាយល់ថា អភិបាលកិច្ចល្អ និងការស្ថាបនា សង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា ពុំអាចកើតមានបាននៅ លើទស្សនៈ និងយោបល់ ពិរោះរណ្តំនៅលើតែពាក្យនិយាយស្តីទេ តែគឺនៅលើការអនុវត្តន៍ជាក់ស្តែង។ ការប្រមូលផ្តុំបានមតិយោបល់ល្អៗ គឺជាគុណសម្បត្តិមួយ តែការយកមតិយោបល់ល្អៗនោះ ទៅអនុវត្ត ឱ្យកើតជាផលប្រយោជន៍ពិតប្រាកដ ដល់ការស្ថាបនាសង្គមស៊ីវិល និង

អភិបាលកិច្ចល្អ គឺជាគុណសម្បត្តិមួយទៀត ដែលពុំអាចខ្វះឬមើលរំលងបាន។ អង្គការសង្គមស៊ីវិលកម្ពុជាគ្រប់ជាន់ថ្នាក់ រួមទាំងអង្គការឯកជន និងស្ថាប័នរដ្ឋផង គួរតែយកលទ្ធផលនៃអង្គសន្និសីទទៅធ្វើជាមូលដ្ឋាន សំរាប់ពិចារណា ឬធ្វើជាកម្មវិធីការងារ និងការកសាងផែនការអនុវត្តន៍ជាក់ស្តែង ទៅតាមសមត្ថកិច្ច ឬជំនាញរៀងៗខ្លួន។ បើធ្វើដូច្នោះបាន នោះមតិយោបល់ទាំងនោះ នឹងមានជីវិតរស់នៅរីកនៅក្នុងបរិបទនៃការពង្រឹង និងពង្រីកអង្គការសង្គមស៊ីវិល និងអភិបាលកិច្ចល្អ។ ទន្ទឹមនោះ ការតាមដានត្រួតពិនិត្យនិងការបូកសរុប ដកពិសោធន៍ អំពីលទ្ធផលនៃការអនុវត្តន៍តាមរយៈអង្គប្រជុំពិភាក្សានានា និងការដៅទិសអនុវត្តបន្ថែមទៀត ដើម្បីធ្វើឱ្យកម្មវិធីប្រតិបត្តិកាន់តែមានប្រសិទ្ធិភាព នោះគឺជាការសំខាន់ណាស់។

ដើម្បីនិរន្តរភាពយូរអង្វែងនៃអង្គការសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា ការប្រជុំពិភាក្សា រៀនសូត្រ មិនអាចខ្វះបានទេ។ ការសិក្សារៀនសូត្រនេះ គួរតែធ្វើឡើងដោយស្មារតីភ្ញាក់រលឹក និងការយល់ច្បាស់ពីគុណប្រយោជន៍នៃចំណេះដឹង ដែលបានមកពីការសិក្សានោះ។ ការកសាងសង្គមស៊ីវិលកម្ពុជា ដើម្បីបុព្វហេតុនៃវឌ្ឍនភាពអភិបាលកិច្ចល្អនៅកម្ពុជា ពុំអាចប្រព្រឹត្តទៅបាននៅលើ "អវិជ្ជា" ឬ "ភាពល្ងង់ខ្លៅ" ទេ_គឺត្រូវតែកើតមាននៅលើ "ចំណេះដឹង និងបទពិសោធន៍ល្អ"។ ចំណេះដឹងជាវិជ្ជមាន ដែលផ្តល់នូវគុណប្រយោជន៍ដ៏ប្រសើរដល់កិច្ចការអភិវឌ្ឍន៍នេះ នោះគឺការយល់ច្បាស់ឬការគិតឃើញ

ត្រូវ (Right thought) អំពីតម្រូវការចាំបាច់របស់ជាតិយើងនូវអភិបាលកិច្ចល្អ និងសារៈសំខាន់របស់វា ក្នុងការកសាងនិងអភិវឌ្ឍន៍ជាតិ។ ជំនឿលើអភិបាលកិច្ចល្អថា ជាមធ្យោបាយតែមួយគត់ដល់ការលើកស្ទួយភាពស្អាតស្អំ និងយុត្តិធម៌ក្នុងការដឹកនាំប្រទេសជាតិនេះមួយ ចិត្តស្រឡាញ់ប្រសិទ្ធភាព នៃការដឹកនាំប្រកបដោយអភិបាលកិច្ចល្អនេះមួយ សេចក្ដីព្យាយាម និងការតស៊ូជួយធ្វើឱ្យមានអភិបាលកិច្ចល្អនេះមួយនិងទស្សនៈដែលយល់ថា គឺមានតែបញ្ហា និងការឈ្លាសវៃនេះមួយ ទាំងអស់នេះ គឺពិតជាថាមពលស្លាបនា ដែលអាចជួយកសាងសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជាឱ្យមាននិរន្តរភាពយូរអង្វែងបាន។

ជាសេចក្ដីសន្និដ្ឋាន សន្និសីទជាតិ ស្ដីអំពី *"ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អ : សមិទ្ធិផល ការប្រឈមមុខ និងក្ដីសង្ឃឹម"* បានទទួលលទ្ធផលល្អប្រសើរ។ លទ្ធផលនៃកិច្ចពិភាក្សាតុមូលទាំង១០ លើកស្ដីអំពី *"សង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ"* ពេញមួយឆ្នាំកន្លងមកនឹងមតិបំពេញបន្ថែមដោយសម័យប្រជុំទាំង៦នៃអង្គ សន្និសីទជាតិ បានឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈ និងបទពិសោធន៍ផ្សេងៗ គ្នាជាច្រើន ដែលអាចយកធ្វើជាគុណប្រយោជន៍ ដល់ការកសាងសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា។

ការប្រមូលផ្ដុំបាននូវលទ្ធផលជាទស្សនៈ និងចំណេះដឹងទាំងនេះ គឺអាស្រ័យដោយការផ្ដួចផ្ដើមគំនិតលើកយកបញ្ហា នៃសង្គមស៊ីវិលនិង

អភិបាលកិច្ចល្អ ដោយវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និង សន្តិភាព (វ.ខ.ស.ស.) មកធ្វើជាប្រធានបទនៃកិច្ចពិភាក្សាតុមូល និងការចូលរួមមតិប្រកបដោយបញ្ញា និងវិចារណញ្ញាណរបស់អ្នកដឹកនាំ នៃអង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ រួមទាំងវរជន និងបញ្ញវន្តពី ស្ថាប័នសាធារណៈមួយចំនួនធំផង ការធ្វើវិភាគទានទូវទស្សនៈ និង មតិយោបល់ដ៏ល្អៗ ប្រកបដោយទស្សនៈវិភាគទាំងនេះ គឺជាការរួម ចំណែកដោយស្មោះដល់ការស្ថាបនាអង្គការស៊ីវិលខ្មែរ ដើម្បីវឌ្ឍនភាព នៃអភិបាលកិច្ចល្អនៅកម្ពុជា។

ទស្សនៈ និងបទពិសោធន៍ជាចំណេះដឹង ដែលប្រមូលផ្តុំបាន តាមរយៈនៃកិច្ចពិភាក្សា ក្នុងសម័យប្រជុំទាំង៦នៃអង្គសន្និសីទនេះអាច ល្មមឱ្យយើងយកធ្វើជាគំនិតដល់ការកសាង និងអភិវឌ្ឍន៍សង្គមស៊ីវិល យើងដើម្បីបុព្វហេតុនៃអភិបាលកិច្ចល្អបានហើយ។ ក៏ប៉ុន្តែ អ្វីដែលនៅ ជាបញ្ហានោះ គឺការប្រែក្លាយទស្សនៈ មតិយោបល់ ទាំងនោះឱ្យទៅ ជាការប្រតិបត្តិពិតប្រាកដ។

ជាបទពិសោធន៍កន្លងមក គេសង្កេតឃើញថា មានការប្រជុំ សិក្សាជាច្រើនដែលត្រូវបានធ្វើឡើង ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី សេចក្តី សំរេចរបស់អង្គប្រជុំនោះ នៅតែពុំបានគេយកទៅអនុវត្តតាមនៅ ឡើយ។ ការនិយាយអំពីទស្សនៈ និងការបញ្ចេញមតិយោបល់គឺជាការ ងាយស្រួលណាស់ តែការអនុវត្តន៍ជាក់ស្តែង គឺជាការលំបាក។ អង្គ សន្និសីទបានលើកយកចំណុចខ្វះខាតនេះ មករំលឹកសមាជិកដែលបាន

អញ្ជើញចូលរួមទាំងអស់ និងពិចារណាដើម្បីប្រែក្លាយ ចំណេះដឹងទាំងឡាយនិងបទពិសោធន៍ល្អៗ ដែលអង្គសន្និសីទបានរកឃើញទាំងនោះឱ្យកើតជាប្រយោជន៍ពិតប្រាកដ ដល់ការកសាងអង្គការសង្គមស៊ីវិលនិងអភិបាលកិច្ចល្អនៅកម្ពុជា។

អភិបាលកិច្ចល្អនៅកម្ពុជា និងតួនាទីរបស់អង្គការសង្គមស៊ីវិលចំពោះវឌ្ឍនភាពនៃអភិបាលកិច្ចល្អនេះ ត្រូវបានអង្គសន្និសីទវាយតម្លៃថាមានសារៈសំខាន់ដល់ការលើកស្ទួយការស្ថាបនាកម្ពុជាឡើងវិញ និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យរួចផុតពីភាពក្រីក្រ ជម្លោះបែកបាក់ និងសង្គ្រាមវិនាសកម្ម។ ការអប់រំផ្សព្វផ្សាយអំពីទស្សនៈនេះ និងការអប់រំផ្សព្វផ្សាយអំពីលទ្ធផលទាំងឡាយ ដែលកិច្ចពិភាក្សាតុមូលទាំង១០ លើក និងអង្គសន្និសីទជាតិបានរកឃើញ គឺជាការចាំបាច់ណាស់ ប្រសិនបើយើងចង់កសាងសង្គមស៊ីវិលឱ្យមានភាពរឹងមាំ និងមានគុណប្រយោជន៍ដល់វឌ្ឍនភាពនៃអភិបាលកិច្ចល្អនៅកម្ពុជា។ ការអប់រំនិងផ្សព្វផ្សាយនេះ គួរតែធ្វើឡើងឱ្យបានទូលំទូលាយ ទាំងនៅក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋ និងអ្នកដឹកនាំ និងគ្រប់គ្រង។ ក៏ប៉ុន្តែ ក្នុងមជ្ឈដ្ឋានទាំងពីរនេះ គឺមជ្ឈដ្ឋានអ្នកដឹកនាំ និងគ្រប់គ្រង ដែលត្រូវយកចិត្តទុកដាក់ជាសំខាន់។

ម្យ៉ាងវិញទៀត ចំណេះដឹង ទស្សនៈ និងបទពិសោធន៍ទាំងឡាយ ដែលអង្គសន្និសីទជាតិប្រមូលផ្ដុំបាន បើមិនតិចក៏ច្រើននឹងបង្កើតបាននូវគោលគំនិតត្រួសត្រាយផ្លូវដ៏សំខាន់មួយ សំរាប់ការលើកស្ទួយ

អភិបាលកិច្ចល្អនៅកម្ពុជា។ ក្រអឺក្រចុះកុំឱ្យតែក្រការគិត។ ពាក្យចាស់ទុំបុរាណខ្មែរមួយឃ្លានេះ អាចយកមកឆ្លុះបញ្ចាំងអំពីលទ្ធផលទាំងនេះបាន។ បន្តិចម្តងៗប្រជាពលរដ្ឋកម្ពុជា នឹងបានជ្រួតជ្រាបអំពីទស្សនៈទាំងនេះ ហើយចំណេះដឹងទាំងនេះ នឹងជ្រាបចូលទៅក្នុងផ្នត់គំនិតនៃអ្នកដឹកនាំល្អដោយពុំដឹងខ្លួន។ អ្វីៗទាំងអស់ពុំអាចនៅនឹងមួយកន្លែងបានទេ។ ប្រទេសកម្ពុជា ប្រជាពលរដ្ឋកម្ពុជា អ្នកដឹកនាំនិងអ្នកគ្រប់គ្រងប្រទេសកម្ពុជា ដាក់ខាតត្រូវតែមានការផ្លាស់ប្តូរ។ ហើយការផ្លាស់ប្តូរ ដែលកំពុងចង់បាននិងត្រូវការនោះ គឺការផ្លាស់ប្តូរពីភាពឱនថយទៅជឿនលឿន ពីអាក្រក់ទៅល្អ ពីឱនាអភិវឌ្ឍន៍ទៅអភិវឌ្ឍន៍។

អង្គសន្និសីទជាតិស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា សមិទ្ធិផល ការប្រឈមមុខ និងក្តីសង្ឃឹម" បានសន្និដ្ឋាននូវសមិទ្ធិផលរបស់ខ្លួនថា គឺជាសមិទ្ធិផលដែលបានមកពីបំណងច្បាស់លាស់ និងសកម្មភាពត្រឹមត្រូវរបស់ខ្លួន។ បញ្ហាប្រឈមមុខទាំងឡាយពិតជានឹងអាចទប់ស្កាត់បាន ប្រសិនបើអង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់និងជនជាតិខ្មែរគ្រប់រូបមានការខិតខំប្រឹងប្រែង ឧស្សាហ៍ព្យាយាម ការប្តេជ្ញាចិត្តខ្ពស់ និងស្រុះស្រួលមូលមតិគ្នាថា គឺមានតែការលើកស្ទួយអភិបាលកិច្ចល្អទេ ដែលអាចជួយឱ្យប្រទេសជាតិមានការអភិវឌ្ឍន៍ជឿនលឿនឆាប់រហ័ស ឆ្ពោះទៅរករបបប្រជាធិបតេយ្យសេរីពហុបក្សប្រកបដោយសមធម៌ និងយុត្តិធម៌សង្គមនៅក្នុងភាពរុងរឿងមួយទៅអនាគត។

បើមិនមានការលើកស្ទួយអភិបាលកិច្ចល្អទេ ប្រទេសកម្ពុជាមិនអាចកាត់បន្ថយបានភាពក្រីក្រ និងអយុត្តិធម៌ សង្គមឡើយ។

ជាក្តីសង្ឃឹមទៅអនាគត អង្គសន្និសីទជាតិបានរកឃើញថា ជនជាតិខ្មែរគឺជាអ្នកមានពូជ! ធ្លាប់មានអរិយធម៌រុងរឿង! ធ្លាប់ស្ថាបនាប្រទេសកម្ពុជាមួយដ៏សំបូររុងរឿងពីអតីតកាល។ ព្រលឹងជាតិខ្មែរ នៅតែជារបស់ខ្មែរ ពុំអាចបាត់បង់ពីរូបកាយខ្មែរឡើយ។ ព្រលឹងជាតិខ្មែរដ៏ជឿនលឿននេះ នៅតែរស់ក្នុងសរសៃឈាមខ្មែរ រស់ក្នុងបញ្ញាញាណខ្មែរជានិច្ចនិរន្តរ៍ទៅអនាគត។

សូមប្រជាពលរដ្ឋខ្មែរ ក្រោកឈរឡើងវិញ ឱ្យស្រុះគ្នាឡើង ដើម្បីស្ថាបនាជាតិយើង ឱ្យរួចផុតពីភាពឱនថយ តាមរយៈការលើកស្ទួយវឌ្ឍនភាពនៃសង្គមស៊ីវិលកម្ពុជា និងអភិបាលកិច្ចល្អ៕

## IV_សេចក្ដីសន្និដ្ឋាន

ជាសេចក្ដីសន្និដ្ឋាន កិច្ចប្រជុំពិភាក្សាតុមូលទាំង១០លើក អស់រយៈពេលពេញមួយឆ្នាំកន្លងមក រួមទាំងសន្និសីទជាតិ_ឆ្នាំ ២០០០ ស្ដីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា" បានរកឃើញនូវទស្សនៈ បទពិសោធន៍ និងចំណេះដឹងជាច្រើនដែលមានសារៈសំខាន់ដល់ការអភិវឌ្ឍន៍វិស័យសង្គមស៊ីវិល និង អភិបាលកិច្ចល្អនៅប្រទេសកម្ពុជា។ ពុទ្ធិដ៏ល្អៗ និងបទពិសោធន៍ទាំងនោះ បានជាមូលដ្ឋានដ៏ប្រសើរដល់ការស្ថាបនាអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុនៃអភិបាលកិច្ចល្អនិងសុចរិតធម៌។ ដើម្បីវឌ្ឍនភាពដ៏ជាប់លាប់មួយនៃអង្គការសង្គមស៊ីវិលកម្ពុជាទៅអនាគត គឺជាការសំខាន់ណាស់ដែលគេត្រូវពិចារណាទៅលើលទ្ធផលជាសក្ដានុពល នៃកិច្ចពិភាក្សាតុមូលទាំងអស់ដូចខាងក្រោមនេះ ៖

១_ <u>លទ្ធផលនៃកិច្ចពិភាក្សាតុមូល បានផ្ដល់នូវសុក្រឹតភាពនៃទំនាក់ ទំនង និងភាពជាដៃគូរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាល</u> :

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទំនាក់ទំនងរវាងសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជារដ្ឋាភិបាល ពុំមានដំណើរការល្អប្រសើរទេ។ អ្នកទាំងពីរហាក់ដូចជាមើលគ្នាក្នុងផ្លូវមិនល្អ។ ការប្រកាន់ពីអតីតភាពជាគូរបដិបក្ខក្នុងសម័យសង្គ្រាម ភាពមិនទុកចិត្តគ្នា ការប្រមាថមាក់ងាយ ដំណាក់ចិត្តស្អប់ខ្ពើម ការវាយតម្លៃគ្នាដោយ

បុរេនិច្ឆ័យ កង្វះសេចក្តីស្រឡាញ់រាប់អាន កង្វះសេចក្តីសន្តោសអនុគ្រោះ និងការយោគយល់ នៅតែកើតមានក្នុងបេះដូងអ្នកទាំងពីរ សឹងគ្មានថ្ងៃ បំភ្លេចបាន។ ជាការពិតណាស់ មន្ត្រីនៃរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាកងកម្លាំងយោធា និងសន្តិសុខភាគច្រើន គឺជាអ្នកក្នុងស្រុក។ រីឯអ្នកដឹកនាំអង្គការសង្គមស៊ីវិល និងសមាគមភាគច្រើនគឺជា អ្នកធ្លាប់រស់នៅក្រៅស្រុក។ ម្ល៉ោះហើយ ក្រោយពេលដែលអ្នកទាំងពីរត្រូវបានបង្រួបបង្រួមឱ្យមកធ្វើការរួមគ្នា នៅក្នុងប្រទេសជាតិតែមួយ សំណល់នៃបដិបក្ខភាព ក្នុងសតិអារម្មណ៍ពីសម័យប្រឈមមុខគ្នាដោយអាវុធនៅតែបង្កឱ្យមានបញ្ហានៅឡើយ។

ព្រមជាមួយនោះការយល់ដឹងអំពីតួនាទី និងភារកិច្ចរៀងៗខ្លួននៅមានកំរិត។ ដោយអារម្មណ៍ ដូចចាស់ទុំនិយាយថា រមែងកំណត់សកម្មភាព ដូច្នេះ ទំនាក់ទំនងការងារឬការធ្វើការជាមួយគ្នា រវាងអ្នកទាំងពីរច្រើនស្ថិតក្នុងទំនាស់ឬបដិបក្ខភាព។ ដោយហេតុផលនេះ ការចោទប្រកាន់គ្នា ភាពសង្ស័យគ្នា ការរកល្បិចផ្ចាញ់ផ្ចាលគ្នា ការបាត់ទំនុកចិត្តគ្នា និងភាពបុរេនិច្ឆ័យក្នុងការធ្វើការងារ ត្រូវបានគេមើលឃើញថា ភាគច្រើនគឺត្រូវបានតមុខដោយរឿងនយោបាយ។ សំអប់ គំនុំ ការបាត់ជំនឿទុកចិត្តនិងការបែកបាក់ក្នុងសង្គមខ្មែរ នៅតែជាបញ្ហារាំងស្ទះដល់ការកសាងជាតិ ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៍ជាតិ។

ឆ្លងតាមរយៈការជួបប្រជុំពិភាក្សាគ្នា និងការយកបញ្ហាមកដាក់លើតុដើម្បីធ្វើការសិក្សារួមគ្នា ដោះស្រាយរួមគ្នា ក្នុងវេទិកាតុមូល

ស្ដីអំពី "សង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា_ឆ្នាំ២០០០" ពេញមួយឆ្នាំនោះ បានកាត់បន្ថយនូវការយល់ច្រឡំ ភាពសង្ស័យ ស្រពិចស្រពិល ការប្រមាថមាក់ងាយគ្នា ក្នុងផ្លូវខុស និងបដិបក្ខភាពរវាងអ្នកដឹកនាំសង្គមស៊ីវិល និងមន្ត្រីនៃរាជរដ្ឋាភិបាល រវាងមន្ត្រីនៃគណបក្សនយោបាយ និងអាជ្ញាធរមូលដ្ឋានមួយកំរិតធំ។

ដោយមានការលើកយកតួនាទី និងភារកិច្ចរបស់អង្គការសង្គមស៊ីវិល និងទំនាក់ទំនងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលមកធ្វើជាប្រធានបទសំខាន់ៗក្នុងកិច្ចប្រជុំតុមូលជាច្រើនលើក ដើម្បីសិក្សារួមគ្នារកហេតុផលនៃគុណវិបត្តិកន្លងមក អង្គពិភាក្សារួម បានផ្ដល់នូវចំណេះដឹង និងបទពិសោធន៍ជាក់ស្ដែងជាច្រើន ដល់ការស្ថាបនាភាព ជាដៃគូរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាលក្នុងការលើកស្ទួយវឌ្ឍនភាពនៃអភិបាលកិច្ចល្អនៅកម្ពុជា។

ក្នុងតួនាទី និងភារកិច្ចរបស់ខ្លួន ជាអង្គការសង្គមស៊ីវិលរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិលពុំមែនជាបដិបក្ខនយោបាយរបស់រដ្ឋាភិបាលទេ តែគឺជាអ្នកជួយបំពេញបន្ថែមនូវភាពខ្វះចន្លោះរបស់រដ្ឋាភិបាល ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ។ រីឯរដ្ឋាភិបាល ដែលជាអ្នកបំរើនិង ជាអ្នកតំណាងរបស់ប្រជាពលរដ្ឋ និងសង្គមជាតិ តាមរយៈសន្លឹកឆ្នោតរបស់ប្រជាពលរដ្ឋវិញ ត្រូវតែទទួលស្គាល់ និងធ្វើការងារជាមួយអង្គការសង្គមស៊ីវិលរបស់ប្រជាពលរដ្ឋ ដោយឆន្ទៈស្ថាបនា សហប្រតិបត្តិការនិងសេចក្ដីគោរពស្រឡាញ់។ ការចេះធ្វើការរួមដើម្បីគោលដៅ

រួមតាមរយៈការចេះផ្ដល់សារៈសំខាន់ សេចក្ដីយោគយល់ និងការ មិនប្រកាន់ទោស គឺជារូបមន្តគន្លឹះដែលអង្គពិភាក្សាបានរកឃើញ ដើម្បីកាត់បន្ថយនូវការយល់ច្រឡំ ភាពឃ្លាតឆ្ងាយគ្នា និងការប្រកាន់គ្នារវាងអង្គការសង្គមស៊ីវិល និងមន្ត្រីនៃរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់។ ជាលទ្ធផលរួម បច្ចុប្បន្ននេះ សហប្រតិបត្តិការ និងការយោគយល់ពិសេស គឺការទទួលស្គាល់នូវសារៈសំខាន់នៃតួនាទីរបស់អ្នកទាំងឡាយដូចបានលើកយកមកពណ៌នាខាងលើ ត្រូវបានគេមើលឃើញថា មានភាពវិជ្ជមានដោយភាពស្រុះស្រួល សាមគ្គីភាព និងក្ដីសង្ឃឹម។ គុណសម្បត្តិដ៏ប្រសើរនេះ ក៏គឺជាស្នាដៃ និងការខិតខំប្រឹងប្រែងនៃកិច្ចប្រជុំពិភាក្សាតុមូលរបស់យើង។ ដរាបណាជនជាតិខ្មែរចេះអង្គុយពិភាក្សាគ្នាដោះស្រាយបញ្ហា ដោយឆន្ទៈស្លាបនា នៅជុំវិញតុ ដរាបនោះជនជាតិខ្មែរពិតជាអាចកាត់បន្ថយបាននូវភាពយល់ច្រឡំ អរិភាព និងការបែកបាក់។

២_ <u>អង្គការសង្គមស៊ីវិលកម្ពុជា ត្រូវការវឌ្ឍនភាពដ៏ជាប់លាប់របស់ខ្លួនមួយឈើម្ចាស់មូលដ្ឋាននៃអភិបាលកិច្ចល្អ និងសុចរិតធម៌</u> :

ប្រទេសកម្ពុជា ត្រូវបានហែកហួរ និងធ្វើឱ្យខ្ទេចខ្ទាំដោយសង្គ្រាមរាប់សិបឆ្នាំ។ សង្គ្រាមកើតមាននៅទីណា ភាពអយុត្តិធម៌ អំពើអសកម្ម និងអំពើពុករលួយកើតមាននៅទីនោះ។ គឺព្រោះតែសង្គ្រាមអូសបន្លាយរ៉ាំរ៉ៃនេះហើយ ដែលបានពន្យឺតការអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងសហសម័យ។ ការតែបន្តការប្រព្រឹត្តិអំពើកេងប្រវ័ញ្ចន៍ ញាតិបក្ស

និយម (Nepotism) និងការឆ្លៀតឱកាសយកមានបាន ក្នុងស្រុកមានសង្គ្រាម បានក្លាយជាទម្លាប់មួយនៅក្នុងសង្គមខ្មែរ។ ទម្លាប់ឱនថយនេះបានបន្សល់ទុកដល់បច្ចុប្បន្ន។ បាតុភាពនៃការគ្រប់គ្រងមិនល្អ នៅមានមហិទ្ធិឫទ្ធិយ៉ាងខ្លាំងក្លាក្នុងសង្គមកម្ពុជា។ ភាពអសកម្ម និងអំពើកេងប្រវ័ញ្ចន៍ ក៏ដូចជាបក្សពួកនិយមនៅក្នុងប្រព័ន្ធរដ្ឋបាល បានបង្កើតឱ្យមានបញ្ហានិងការលំបាកជាច្រើនដល់រដ្ឋាភិបាល។ ជម្ងឺមហារីកនេះបានរីករាលដាល និងឆ្លងស្ទើរងកោសិកាសង្គម។ ពុំមែនតែក្នុងស្ថាប័នរដ្ឋទេ សូម្បីតែផ្នែកឯកជន ពិសេសគឺក្នុងអង្គការសង្គមស៊ីវិល ដែលធ្លាប់តាំងខ្លួនថា ជាអង្គការជឿនលឿននឹងស្អាតស្អំ ក៏ត្រូវទទួលការរួមរិតដោយការគ្រប់គ្រងមិនល្អដែរ។

អង្គពិភាក្សាតុមូល បានវាយតម្លៃថា អង្គការសង្គមស៊ីវិលកម្ពុជាពិតជាត្រូវការវឌ្ឍនភាពជាប់លាប់របស់ខ្លួនមួយ ដែលត្រូវកសាងលើមូលដ្ឋាននៃអភិបាលកិច្ចល្អ (ការគ្រប់គ្រងស្អាតស្អំ_គ្មានអំពើពុករលួយ) និងសុចរិតធម៌ដែរ។ អត្ថន័យជាមូលដ្ឋាននៃអភិបាលកិច្ចល្អ និងសារៈជាសារវ័ន្តនៃអភិបាលកិច្ចល្អ ក៏ដូចសុចរិតធម៌ក្នុងការដឹកនាំគ្រប់គ្រង ត្រូវតែបានអប់រំផ្សព្វផ្សាយ និងអនុវត្តនៅអង្គការសង្គមស៊ីវិលខ្មែរ គ្រប់ថ្នាក់គ្រប់ផ្នែក។ ដោយមានសារៈកំណើតរបស់ខ្លួន ជាអង្គការសង្គមរបស់ប្រជាពលរដ្ឋ ដែលបង្កើតឡើងដោយប្រជាពលរដ្ឋ នៅជាមួយប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ_អង្គការសង្គមស៊ីវិលត្រូវតែជាអង្គការស្អាតស្អំបរិសុទ្ធ សច្ចៈយុត្តិធម៌ និងចំរើនជឿនលឿន។ អង្គការនេះពុំអាចជាទី

រុករាន និងទទួលការរាតត្បាតដោយអភិបាលកិច្ចឱនថយឡើយ។ អង្គការសង្គមស៊ីវិលនៅកម្ពុជា ពុំអាចធ្វើគំរូល្អ និងជាដៃគូរឹងមាំរបស់រដ្ឋាភិបាល ក្នុងការកសាងនិងអភិវឌ្ឍន៍ជាតិបានទេ ក្នុងករណីណាដែលសង្គមស៊ីវិលមិនបំពាក់ឱ្យខ្លួននូវការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និងសុចរិតធម៌។ នេះគឺជាទស្សនៈរបស់អង្គពិភាក្សាទាំងមូល។

## ៣- ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលត្រូវឈរលើគោលនៅរួម ការលើកស្ទួយសារៈសំខាន់ និងសេចក្តីយោគយល់ :

ទំនាស់ឬភាពផ្ទុយគ្នាខាងទស្សនៈ បាននាំមកនូវវិបត្តិ និងការបែកបាក់ដល់សង្គមខ្មែរជាច្រើនជំនាន់មកហើយ។ សំរាប់ប្រជាពលរដ្ឋកម្ពុជា ការយល់ឃើញមិនដូចគ្នានេះមួយ គំនិតមិនស្របគ្នានេះមួយ និងជំនឿផ្សេងគ្នានេះមួយសុទ្ធសឹងនាំមកនូវការប្រកាន់និងបដិបក្ខភាព។ គឺផ្តើមចេញពីភាពផ្ទុយគ្នាខាងទស្សនៈ នេះហើយ ដែលបង្កើតឱ្យមានការប្រកាន់បក្សពួក ការប្រឈមមុខ និងចម្បាំងរាំងជល់។

ជាការពិតណាស់ ទំនាក់ទំនងសុទ្ធតែមានឫសគល់របស់វានៅក្នុងចិត្តគំនិតរបស់មនុស្ស។ ជាធម្មតា ការពិចារណាសើៗ (មិនស៊ីជម្រៅ)ពុំបានឱ្យតម្លៃទៅលើផ្លូវចិត្តទេ។ ចិត្តរបស់មនុស្សមានឧត្តមភាពណាស់។ ចិត្តបញ្ជាកាយ។ ចិត្តប្រៀបបាននឹងអ្នកបើកបរ។ បើអ្នកបើកបរចង់ទៅទីណាហើយ យានយន្តក៏ទៅទីនោះដែរ។ សកម្មភាព

ទាំងអស់របស់កាយ គឺសុទ្ធតែស្ថិតនៅក្រោមបញ្ជាការរបស់ចិត្ត។ ទស្សនៈ និងការយល់ឃើញ ក៏ដូចជាការប្រកាន់ និងមនោសញ្ចេតនាផ្សេងៗ គឺជាផលិតផលនៃចិត្ត។ ទាំងសេចក្ដីស្រឡាញ់ ទាំងសំអប់ ទាំងភាពស្រុះស្រួល និងបដិបក្ខភាព គឺជាប្រភពដែលបង្កើតឱ្យមានសកម្មភាព ឬការប្រព្រឹត្ត។ ដូច្នេះដើម្បីកាត់បន្ថយបាននូវការប្រព្រឹត្ត ឬសកម្មភាពបដិបក្ខរបស់មនុស្ស ឬរវាងមនុស្សនឹងមនុស្ស គេគួរតែយកចិត្តទុកដាក់អំពី "ការអប់រំផ្លូវចិត្ត"។

កិច្ចពិភាក្សាតុមូល បានរកឃើញ និងសន្និដ្ឋានថា: ការមានទស្សនៈដូចគ្នា ការមានគោលដៅរួមតែមួយ ការចេះលើកស្ទួយសារៈសំខាន់ឱ្យគ្នានិងគ្នា និងសេចក្ដីយោគយល់ឬសេចក្ដីសន្ដោសអនុគ្រោះទាំងអស់នេះ គឺជាគន្លឹះ និងជាគ្រឹះដ៏រឹងមាំសំរាប់ការស្ថាបនាទំនាក់ទំនង និងភាពជាដៃគូរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាល។ បើអ្នកទាំងពីរមានគោលដៅរួមដូចគ្នា ចេះផ្ដល់ផលប្រយោជន៍ឱ្យគ្នានិងគ្នា និងចេះយោគយល់គ្នាហើយ បញ្ហាអ្វីក៏ដោយដែលកើតមានឡើងរវាងអ្នកទាំងពីរ សុទ្ធតែអាចសម្របសម្រួល និងដោះស្រាយ។ គឺជាការសំខាន់ណាស់ ដែលអ្នកទាំងពីរ អាចប្រកាន់យកទស្សនៈដ៏ថ្លៃថ្លានេះ។ គេគួរតែកំណត់គោលដៅរួម (Common Goal) របស់គេ នោះគឺគោលដៅនៃការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីផលប្រយោជន៍ជាតិជាធំ។ ដើម្បីធ្វើឱ្យសំរេចគោលដៅនោះ ការបែងចែកផល

ប្រយោជន៍ សារៈសំខាន់និងការយោគយល់ គឺជាសកម្មភាពមិនអាចខ្វះបាន។

ទំនាក់ទំនងល្អ និងភាពជាដៃគូដ៏ជាប់លាប់រវាងសង្គមស៊ីវិលនិងរដ្ឋាភិបាល ត្រូវតែមានមូលដ្ឋាននៃការអប់រំផ្លូវចិត្ត ដើម្បីបង្កើតឱ្យមានទស្សនៈដូចគ្នា មានគោលដៅរួមដូចគ្នា ការចេះបែងចែកផលប្រយោជន៍ និងសេចក្តីយោគយល់។

**៤_ វឌ្ឍនភាពនៃសង្គមស៊ីវិលកម្ពុជា និងអភិបាលកិច្ចល្អ គឺជាអន្តរកម្មមិនអាចខ្វះបាន :**

ការដឹកនាំ និងគ្រប់គ្រងប្រកបដោយភាពស្អាតស្អំនិងសុចរិតធម៌ (Integrity) គឺជាកត្តាស្លាប់រស់របស់សង្គមជាតិ សហគមន៍មូលដ្ឋាន អង្គការ គ្រួសារ និងបុគ្គល។ នាវាត្រូវបានបើកបរធ្លាក់ថយ ឬលឿនលយទៅមុខអាស្រ័យដោយ "អ្នកបើកបរ"។ អ្នកបើកបរល្អឬឈ្លាសវៃប្រកបដោយបញ្ញា និងពលិកម្ម កំណត់វឌ្ឍនភាពលឿនលយទៅមុខនៃនាវា។ អ្នកបើកបរឱនថយ គ្មានបញ្ញា ឬបុគ្គលនិយមតែងនាំមកនូវភាពឱនភាពវឌ្ឍន៍ ទំនាស់និងគ្រោះថ្នាក់ដល់នាវា។ លក្ខណៈសម្បត្តិល្អឬមិនល្អរបស់អ្នកដឹកនាំ ឬមគ្គុទ្ទេសភាព គឺជាកត្តាចម្បងនៃវឌ្ឍនភាព។ គឺមានតែការដឹកនាំប្រកបដោយអភិបាលកិច្ចល្អទេ ដែលអាចនាំមកនូវវឌ្ឍនភាព និងសេចក្តីសុខសាន្តដល់សង្គមគ្រួសារអង្គការ និងស្ថាប័ន។

អង្គការសង្គមស៊ីវិល ពុំអាចអភិវឌ្ឍរឹងមាំបានទេ ប្រសិនបើមគ្គុទ្ទេសភាពនៅក្នុងអង្គការនោះ គ្មានភាពស្អាតស្អំ ញាតិបក្សនិយម គ្មានជំនឿទុកចិត្ត ខ្វះតម្លាភាព ខ្វះគណនេយ្យភាព និងការទទួលខុសត្រូវ។ គ្រប់ពេល គ្រប់កន្លែង គ្រប់គម្រោងកម្មវិធី និងការអនុវត្តន៍ត្រូវស្ដែងចេញឱ្យឃើញនូវសហប្រតិបត្តិការ ការចូលរួម វិន័យថ្លៃថ្នូរ សេចក្ដីស្មោះត្រង់ ការយោគយល់និងការប្រតិបត្តិច្បាប់ជាធំ។ បើមានលក្ខណៈសម្បត្តិនេះ នៅក្នុងការដឹកនាំនិងគ្រប់គ្រងហើយ នោះសង្គមស៊ីវិលនឹងអភិវឌ្ឍលឿនលឿន និងជាប់លាប់ទៅអនាគត។ ផ្ទុយទៅវិញ បើគ្មានលក្ខណៈសម្បត្តិនេះទេ នោះសង្គមស៊ីវិលនឹងជួបតែវិបត្តិ។

ដូច្នេះ អង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ និងវឌ្ឍនភាពរបស់ខ្លួនពុំអាចកាត់ផ្ដាច់បានពីអភិបាលកិច្ចល្អឡើយ។ វឌ្ឍនភាពនៃសង្គមស៊ីវិលកម្ពុជា និងអភិបាលកិច្ចល្អ គឺជាអន្តរកម្មមិនអាចខ្វះបាន ដើម្បីបុព្វហេតុនៃការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ក្រោយសម័យសង្គ្រាម។ នេះគឺជាសេចក្ដីសន្និដ្ឋានរបស់កិច្ចពិភាក្សាតុមូលរបស់យើង។

៥_ <u>ការអប់រំបណ្ដុះបណ្ដាលធនធានមនុស្ស និងការបង្កើនសមត្ថភាព គឺជាតម្រូវការមិនអាចខ្វះបាន សំរាប់និរន្តរភាពនៃសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា</u> :

មនុស្ស គឺស្ថាបនិកសង្គមផង និងជាអ្នកបំផ្លាញសង្គមផង។ ល្បឿននៃការកសាងមានរយៈពេលវែងនិងភាពលំបាកលំបិន តែល្បឿន

នៃការបំផ្លាញមានរយៈពេលតែមួយភ្លែត និងងាយស្រួលបំផុត។ ទាំងការស្ថាបនា ទាំងការបំផ្លិចបំផ្លាញ គឺជាផលិតផលនៃស្នាដៃរបស់មនុស្ស។ បើមនុស្សជាកត្តាកំណត់នៃវឌ្ឍនភាព និងភាពឱនាអភិវឌ្ឍន៍ដូច្នេះ ការស្ថាបនាធនធានមនុស្ស គឺជាកត្តាសំខាន់ណាស់។ ធនធានមនុស្សដែលអាចផ្តល់នូវវឌ្ឍនភាពបាន គឺជាប្រភេទធនធានមនុស្សដែលមានទាំងចំណេះដឹង ទាំងចំណេះធ្វើ និងគុណធម៌ផ្លូវចិត្ត។ បើគ្មានធនធានមនុស្ស ប្រកបដោយសមត្ថភាពផលិតកម្មទេ អ្វីៗក៏គ្មានដែរ។ ធនធានមនុស្សដែលសង្គមជាតិយើងចង់បាន គឺជាធនធានមនុស្សជឿនលឿន ប្រកបដោយចំណេះដឹងទូទៅខ្ពស់ មានបច្ចេកទេសជឿនលឿន និងមានមនសិការវិជ្ជាជីវៈ។ គឺសមត្ថភាពឬលក្ខណៈសម្បត្តិទាំងបីនេះហើយ ដែលជាតម្រូវការមិនអាចខ្វះបានសំរាប់វឌ្ឍនភាពសង្គម និងភាពជាប់លាប់របស់វាទៅអនាគត។

អង្គពិភាក្សាតុមូល ស្តីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា" បានរកឃើញនិងសន្និដ្ឋានថា ការកសាងធនធានមនុស្សនិងការកសាងសមត្ថភាពក្នុងសង្គមស៊ីវិលកម្ពុជា មានសារៈសំខាន់ណាស់ដល់ភាពស្ថិតស្ថេររឹងមាំនៃសង្គមស៊ីវិលទៅអនាគត។ ប្រសិនបើគ្មានធនធានមនុស្សល្អ ចំរើនជឿនលឿន និងមានសមត្ថភាពជំនាញ-វិជ្ជាជីវៈខ្ពស់ទេ នោះអង្គការសង្គមស៊ីវិលមិនអាចអភិវឌ្ឍឈានឡើងបានទេ។ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលត្រូវតែឆ្លើយតបទៅនឹងជំនាញឯកទេសកម្ម ការវិវត្តន៍នៃចរន្ត

អភិវឌ្ឍន៍សេចក្ដីត្រូវការ កាលៈទេសៈរបស់សង្គមនិងការអភិវឌ្ឍន៍របស់តំបន់និងពិភពលោកផង។ បើមានធនធានមនុស្សដូច្នោះ នោះទើបអង្គការសង្គមស៊ីវិលអាចអភិវឌ្ឍបាន។ ផ្ទុយទៅវិញ បើគ្មានវឌ្ឍនភាពនោះទេ នោះសង្គមស៊ីវិលនឹងជួបតែវិបត្តិ។

## ៦_ វឌ្ឍនភាពនិងនិរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា ក៏ផ្អែកទៅលើមូលដ្ឋាននៃការស្ថាបនាបណ្ដាញសង្គមស៊ីវិល ការប្រមូលផ្ដុំ និងបែកចែកធនធាន ពត៌មាន និងបទពិសោធន៍ :

ចង្កឹះតែមួយគេអាចកាច់បំបាក់បាន តែចង្កឹះមួយបាច់គេពុំអាចកាច់បំបាក់បានដោយងាយស្រួលឡើយ។ យ៉ាងណាមិញ អង្គការសង្គមស៊ីវិលក៏ដូច្នោះដែរ។ ការចងបាច់គ្នាជាចង្កោម គឺជាកម្លាំងដ៏ខ្លាំងក្លាមួយសម្រាប់ការអភិវឌ្ឍន៍។ បណ្ដាញនៃសង្គមស៊ីវិល ដែលយើងចង់បាននោះគឺជាបណ្ដាញដែលមានបេសកកម្ម ប្រមូលផ្ដុំធនធានពត៌មាន និងបទពិសោធន៍ ដើម្បីអភិវឌ្ឍអង្គការសង្គមស៊ីវិលឱ្យទៅជាកម្លាំងចលករដ៏ស្រួចស្រាវមួយ ក្នុងការលើកស្ទួយអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍នៅកម្ពុជា។

ក៏ប៉ុន្តែ យុទ្ធសាស្ត្រមួយដែលគប្បីចៀសវាង ក្នុងការកសាងបណ្ដាញសង្គមស៊ីវិល ការប្រមូលផ្ដុំធនធានពត៌មាន និងបទពិសោធន៍នោះគឺគោលដៅនៃការកសាងបណ្ដាញ ដើម្បីបំផ្លាញបណ្ដាញ។ ការកសាងបណ្ដាញ ដើម្បីបំរើល្បិចនយោបាយ ឬមហិច្ឆតាបុគ្គល ក្រុម

និងបក្សពួក ពុំអាចរក្សាបានវឌ្ឍនភាពនិងនិរន្តរភាពនៃសង្គមស៊ីវិលបានឡើយ។ យុទ្ធសាស្ត្រជាសក្តានុពលពិតនៃការកសាងបណ្តាញក្នុងសង្គមស៊ីវិល នោះគឺដើម្បីស្ថាបនាកម្លាំងឯកភាព សម្លេងតែមួយ ដែលជាថាមពលដ៏រឹងមាំសំរាប់វឌ្ឍនភាព និងនិរន្តរភាព និងសំរាប់ចែករំលែកប្រភពធនធាន ពត៌មាន បទពិសោធន៍ ចំណេះដឹង ដើម្បីជួយរួមចំណែកដោះស្រាយទំនាស់ ក្តីកង្វល់របស់អង្គការសង្គមស៊ីវិល ដោយសន្តិវិធី និងអហិង្សាធម៌។ វឌ្ឍនភាព និងនិរន្តរភាពនៃអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ តាមសេចក្តីសន្និដ្ឋានរបស់កិច្ចពិភាក្សាតុមូល គឺដើម្បីបុព្វហេតុនៃការកសាងជាតិយើងឡើងវិញ និងអភិវឌ្ឍន៍ជាងឱ្យរួចផុតពីភាពក្រីក្រទំនាស់បែកបាក់និងការបាត់បង់។ វឌ្ឍនភាព និងនិរន្តរភាពនេះ ពុំអាចកាត់ផ្តាច់បានពីការកសាងបណ្តាញសង្គមស៊ីវិល ដើម្បីប្រមូលផ្តុំធនធាន ចំណេះដឹង ពត៌មាន និងបទពិសោធន៍ឡើយ។

## ៧_ សង្គមស៊ីវិលគឺជាស្ពានដ៏ពិសេសមួយ សំរាប់ចម្លងសកលភាវូបនីយកម្មឲ្យចូលមកកម្ពុជា និងចេញពីកម្ពុជា តែត្រូវតែប្រុងប្រយ័ត្ននូវឥទ្ធិពលរបស់វាថា តើអ្វីដែលត្រូវទទួលយក និងមិនត្រូវទទួលយក :

សកលភាវូបនីយកម្ម ប្រៀបបាននឹងទឹកហូរធ្លាក់ពីលើកំពូលភ្នំ។ លំហូរនេះ តែងនាំមកទាំងទឹកឃ្មុំ និងទាំងថ្នាំពិស។ នៅលើលោកនេះ គ្មានប្រទេសជាតិណាមួយ ដែលមិនទទួលយកនូវសាកលភាវូបនីយកម្មឡើយ ព្រោះសកលភាវូបនីយកម្ម គឺជាទំនោរនៃឥទ្ធិពល សេដ្ឋកិច្ចនយោបាយ និងវប្បធម៌ពិភពលោក។ ក៏ប៉ុន្តែ ផលល្អឬអាក្រក់របស់វា

កើតមានដំណាលគ្នាមកលើប្រទេសក្រីក្រ ឱនាភិវឌ្ឍន៍ ដែលកំពុងខ្វះខាតធនធានមនុស្ស ដូចប្រទេសកម្ពុជាយើងនេះជាអាទិ៍។

សកលភាវូបនីយកម្ម ពិតជាមានសារៈប្រយោជន៍ ដល់ការកសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ក្រោយសម័យសង្គ្រាម។ ក៏ប៉ុន្តែទន្ទឹមនោះ សកលភាវូបនីយកម្មក៏បានផ្តល់ នូវវិបត្តិសង្គមជាច្រើនឱ្យកម្ពុជាដែរ។ ភាពក្រីក្រ (ដែលកាន់តែក្រីក្រទៅ) ការបាត់បង់គុណធម៌ វប្បធម៌ និងអត្តសញ្ញាណជាតិ ការខូចបរិស្ថាន សត្វព្រៃ ដីធ្លី ការបាត់បង់សន្តិសុខមនុស្ស ការរាតត្បាតនៃជម្ងឺ អេដស៍ ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរស្ត្រីភេទ_កុមារ និងគ្រឿងញៀន ។ល។ និង ។ល។ ទាំងអស់នេះ គឺជាផលិតផលនៃសកលភាវូបនីយកម្មផងដែរ។

អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ គឺជាភ្នាក់ងារនាំចូលដ៏សំខាន់ និងជាបណ្តាញឆ្លងកាត់យ៉ាងឆាប់រហ័សនៃសកលភាវូបនីយកម្មមកកម្ពុជា។

ដូច្នេះ អង្គការសង្គមស៊ីវិលទាំងអស់ ត្រូវបានស្នើសុំអំពាវនាវឱ្យជួយគិតគូរពិចារណា និងប្រយ័ត្នប្រយែងនូវឥទ្ធិពលនៃសកលភាវូបនីយកម្មនេះថា តើអ្វីដែលគួរទទួលយក និងអ្វីដែលមិនគួរទទួលយក។

៨_ <u>មគ្គុទ្ទេសភាពប្រកបដោយអភិបាលកិច្ចល្អ សុចរិតធម៌ និងគុណធម៌គឺជាកត្តាស្នូលរបស់នៃសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា</u> :

វិបត្តិរបស់មនុស្ស និងសង្គម គឺបណ្ដាលមកពីមនុស្ស។ មនុស្ស គឺជាអ្នកបង្កើតផង និងជាអ្នកបំផ្លាញផង។ វឌ្ឍនភាព និងឱនាភិវឌ្ឍន៍ របស់ប្រទេសជាតិ ឬសង្គមគ្រួសារមួយ គឺអាស្រ័យដោយមនុស្សនៃ សង្គមជាតិនោះ។ មនុស្សជាតិ មិនអាចរស់ដាច់ដោយឡែកម្នាក់ឯង ដោយគ្មានសង្គម_ភូមិស្ថាន ឬគ្រួសារឡើយ។ សង្គមភូមិស្ថានឬគ្រួសារ នោះ ពុំអាចមានស្ថេរភាព សុវត្ថិភាព និងវឌ្ឍនភាពបានទេ ប្រសិន បើគ្មាន "មេឬអ្នកដឹកនាំ"។ អ្នកដឹកនាំដែលអាចនាំមកនូវលក្ខណៈ សម្បត្តិនេះបាន លុះតែមគ្គុទ្ទេសភាពរបស់គេ មានភាពស្អាតស្អំ មាន សុចរិតធម៌ និងគុណធម៌ខ្ពស់។

មគ្គុទ្ទេសភាព នៅក្នុងអង្គការសង្គមស៊ីវិល ពុំអាចអភិវឌ្ឍរឹងមាំ បានទេ បើគ្មានអភិបាលកិច្ចល្អ សេចក្ដីស្មោះត្រង់ និងគុណធម៌ដឹក នាំ។ អភិបាលកិច្ចល្អនាំឱ្យសង្គមស៊ីវិល មានភាពស្រុះស្រួល និងសុខ ដុមរមនានៅក្នុងអង្គការរបស់ខ្លួន។ សុចរិតធម៌នាំមកនូវយុត្តិធម៌។ រីឯ គុណធម៌នាំមកនូវសេចក្ដីគោរពស្រឡាញ់ និងការកោតខ្លាច។ គឺគុណ សម្បត្តិទាំងនេះ ហើយដែលកំណត់អត្ថិភាព និងវឌ្ឍនភាពនៃអង្គការ សង្គមស៊ីវិលកម្ពុជា។

កិច្ចពិភាក្សាតុមូល បានរកឃើញថា មគ្គុទ្ទេសភាពប្រកបដោយ អភិបាលកិច្ចល្អ សុចរិតធម៌ និងគុណធម៌ គឺជាកត្តាស្លាប់រស់នៃ សង្គមស៊ីវិលនៅកម្ពុជា។ វិបត្តិទាំងឡាយ កន្លងមករបស់អង្គការសង្គម ស៊ីវិល (ទាំងវឌ្ឍនភាពផង) គឺអាស្រ័យដោយកត្តាដឹកនាំនេះឯង។ បើ

គ្មានភាពជាអ្នកដឹកនាំល្អ នៅក្នុងអង្គការនីមួយៗទេ អង្គការនោះនឹងជួបតែវិបត្តិ។

ដោយផ្ដើមចេញពីទស្សនៈនេះ អង្គការពិភាក្សាបានអំពាវនាវស្នើសុំឱ្យអង្គការស៊ីវិលទាំងអស់ ខិតខំយកចិត្តទុកដាក់ទៅលើការបង្កើនសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន ឱ្យមានគណនេយ្យភាព តម្លាភាព ភាពដែលមានអាចប្រមាណបាន និងការចូលរួមរបស់មហាជន/បុគ្គលិក ក្នុងការពិគ្រោះយោបល់ ក្នុងការដឹកនាំនិងគ្រប់គ្រងរបស់ខ្លួន។ ធ្វើដូច្នោះ នោះសង្គមស៊ីវិលនិងអភិវឌ្ឍរឹងមាំទៅអនាគត។ ផ្ទុយទៅវិញ បើគ្មានការយល់ដឹងត្រឹមត្រូវ (Right Understanding) អំពីប្រសិទ្ធភាពល្អនៃមគ្គុទ្ទេសភាពប្រកបដោយអភិបាលកិច្ចល្អទេ នោះអង្គការសង្គមស៊ីវិលនឹងជួបតែភាពឱនថយ។

សូមអង្គការសង្គមស៊ីវិលកម្ពុជា យល់បានអំពីទស្សនៈនេះហើយ ខិតខំជំរុះឱ្យអស់នូវការដឹកនាំឱនថយ ដើម្បីឈោងចាប់យកមគ្គុទ្ទេសភាពល្អ (Good Leadership) ដើម្បីអភិវឌ្ឍនភាព និងនិរន្តរភាពរបស់ខ្លួនក្នុងការលើកស្ទួយការកសាង និងការអភិវឌ្ឍន៍ជាតិឱ្យរុងរឿងទៅអនាគត។

សរុបសេចក្ដីមក ជាសេចក្ដីសន្និដ្ឋាន កិច្ចពិភាក្សាតុមូល ស្ដីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា" បាននាំមកនូវចំណេះដឹង ស្មាបនា និងបទពិសោធន៍ល្អជាច្រើន ដល់ការកសាងសង្គមស៊ីវិលនិងអភិបាលកិច្ចល្អនៅកម្ពុជា។ ចំណេះដឹងទាំងនេះ មានគុណប្រយោជន៍ដ៏

ឧត្តុង្គឧត្តមដល់ការលើកស្ទួយប្រសិទ្ធិភាពការងារ និងមុខនាទីជាចាំបាច់របស់អង្គការសង្គមស៊ីវិល ក្នុងការកសាង និងអភិវឌ្ឍន៍ជាតិ ក្រោយសម័យសង្គ្រាម។ ក៏ប៉ុន្តែ អ្វីដែលមានសារៈសំខាន់ជាងនោះ គឺការបណ្តុះបណ្តាលអប់រំនូវពន្លក នៃអភិបាលកិច្ចល្អឱ្យកាន់តែមានភាពរឹងមាំនៅក្នុងអង្គការសង្គមស៊ីវិល ដែលជាអង្គការរបស់ប្រជាពលរដ្ឋ ដើម្បីបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងសង្គមជាតិ ដោយផ្ទាល់នេះ។ ជាការពិតណាស់ ទស្សនៈ និងបទពិសោធន៍ជាចំណេះដឹងទាំងនេះ អាចស្ថិតនៅក្រៅតម្រូវការឬគ្រាន់តែជា "មនោគតិ" ប៉ុណ្ណោះ ប្រសិនបើគ្មានការប្រតិបត្តិជាក់ស្តែង។ គឺមានតែការប្រើប្រាស់ចំណេះដឹងទាំងនោះ ឱ្យមានភាពប្រាកដនិយមទេ ដែលអាចរក្សានូវសារៈ និងគុណប្រយោជន៍របស់វាបាន។

ចំណេះដឹងទាំងឡាយ វាគ្រាន់តែជាភាពអត្តនោម័តរបស់មនុស្សតែប៉ុណ្ណោះ ប្រសិនបើចំណេះដឹងទាំងនោះ មិនត្រូវបានគេយកទៅប្រើប្រាស់ឱ្យកើតជាគុណប្រយោជន៍ជាក់ស្តែងទេ៕

## V-សំណើមតិ

ឆ្លងតាមរយៈកិច្ចពិភាក្សាតុមូលទាំង១០លើក ស្តីពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា" និងសន្និសីទថ្នាក់ជាតិ ស្តីពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងក្តីសង្ឃឹម" យើងអាចប្រមូលផ្តុំបានសំណើមតិមួយចំនួនធំ ដូចខាងក្រោមនេះ ៖

១- ស្នើសុំឱ្យរាជរដ្ឋាភិបាលឈ្វេងយល់ គំនិតយោបល់ បទពិសោធន៍ជំនាញរបស់អង្គការសង្គមស៊ីវិលនិងស្នើសុំឱ្យទទួលយកសហប្រតិបត្តិការ និងភាពជាដៃគូរបស់អង្គការសង្គមស៊ីវិល ក្នុងការកសាង និងពង្រឹងអភិបាលកិច្ចល្អនៅកម្ពុជា។ រាល់ការតាក់តែងនិងអនុម័តច្បាប់គួរតែមានការចូលរួមមតិរបស់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋផង។

២- ស្នើសុំបង្កើតយន្តការ "ពុំមែនរដ្ឋាភិបាល" មួយ ដើម្បីជួយជ្រោមជ្រែង និងគ្រប់គ្រងអភិបាលកិច្ចល្អឱ្យបានត្រឹមត្រូវ និងយុត្តិធម៌។ តួនាទី និងភារកិច្ចរបស់អង្គការសង្គមស៊ីវិល គួរតែត្រូវបានពង្រីកភារកិច្ចឱ្យត្រឹមត្រូវតាមប្រព័ន្ធជំនាញ និងឱ្យស្របជាមួយស្ថាប័នរដ្ឋ។

៣- ស្នើសុំឱ្យមានវិធានការទប់ស្កាត់អំពើពុករលួយ តាមរយៈការលើកស្ទួយ ការអប់រំសិក្សាអំពីអភិបាលកិច្ចល្អ សុចរិតធម៌ និងការអនុវត្តន៍។ ទន្ទឹមនោះ ស្នើសុំឱ្យមានការបញ្ចូលគំនិត និងគោលការណ៍អនុវត្តន៍ល្អៗ ពោលគឺគតិបណ្ឌិតក្នុងការដឹកនាំ និងគ្រប់គ្រង

ប្រកបដោយភាពស្អាតស្អំ បរិសុទ្ធ ជូនថ្នាក់ដឹកនាំ និងគ្រប់គ្រង ដើម្បីលើកស្ទួយការអភិវឌ្ឍន៍"អភិបាលកិច្ចល្អ" ឱ្យបានទូលំទូលាយ លើគ្រប់វិស័យនៃសង្គមជាតិ។

៤. ស្នើសុំបង្កើតឱ្យមានយន្តការរបស់អង្គការសង្គមស៊ីវិលមួយ ដើម្បីធ្វើការជាមួយរដ្ឋាភិបាល។ យន្តការនេះ ត្រូវមានតម្លាភាព ក្នុងការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន តាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងត្រូវតែមានចរិតឯករាជ្យ អព្យាក្រឹត។

៥. ស្នើសុំឱ្យម្ចាស់គម្រោងកម្មវិធី (វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព) បន្ថែមពេលវេលាសំរាប់ការពិភាក្សាឱ្យបាន១ថ្ងៃ ឬពីរព្រឹក ដើម្បីឱ្យសមាជិកនៃកិច្ចពិភាក្សាតុមូល មានពេលគិតពិចារណា និងពិភាក្សាឱ្យបានល្អិតល្អន់។ ទន្ទឹមនោះ អង្គពិភាក្សាស្នើសុំឱ្យមានធ្វើការបោះពុម្ពផ្សាយ និងចែកផ្សាយនូវលទ្ធផលនៃកិច្ចពិភាក្សាតុមូល ស្តីអំពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា" ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋមូលដ្ឋានផង។

៦. អំពីសាកលភាវូបនីយកម្ម និងឥទ្ធិពលរបស់វាមកលើសង្គមស៊ីវិលកម្ពុជា ក៏ដូចជាមកលើប្រទេសកម្ពុជាទាំងមូល អង្គពិភាក្សាតុមូលបានស្នើសុំឱ្យរាជរដ្ឋាភិបាល បង្កើនការគ្រប់គ្រងឱ្យបានមធ្យ័តថែមទៀត។ ប្រសិនបើគ្មានច្បាប់គ្រប់គ្រងតឹងរ៉ឹងឱ្យបានច្រើនទេ នោះសាកលភាវូបនីយកម្មនឹងស៊ីបំផ្លាញនូវការអភិវឌ្ឍន៍ប្រទេសជាតិយើងឱ្យខ្ទេចខ្ទាំ។

៧. ជាការពិតណាស់ ប្រទេសជាតិនីមួយៗ មិនអាចគេចមិនទទួលយកសាកលភាវូបនីយកម្មបានទេ ព្រោះសាកលភាវូបនីកម្មជាទំនោរនៃឥទ្ធិពលនយោបាយ សេដ្ឋកិច្ចនិងវប្បធម៌របស់ពិភពលោក។ លំហូរនៃសាកលភាវូបនីយកម្ម ប្រៀបបានដូចទឹកដែលហូរធ្លាក់ពីកំពូលភ្នំ វាអាចនាំមកទាំងទឹកឃ្មុំ ទាំងថ្នាំពុល។

ដូច្នេះ អង្គពិភាក្សាតុមូល ស្នើសុំអំពាវនាវឱ្យសង្គមស៊ីវិលកម្ពុជាគ្រប់ជាន់ថ្នាក់ ខិតខំជួយការពារគ្រោះមហន្តរាយដែលបង្កឡើងដោយសាកលភាវូបនីយកម្ម ក្នុងសម័យនេះ។

៨. ដើម្បីទប់ស្កាត់ឥទ្ធិពលជាអវិជ្ជមាន នៃសាកលភាវូបនីយកម្មមកលើប្រទេសកម្ពុជា ស្នើសុំឱ្យរាជរដ្ឋាភិបាលបង្កើតឱ្យបានច្បាប់ថ្មីៗសំរាប់កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការវិនិយោគទុនឱ្យបានត្រឹមត្រូវ និងសូមឱ្យបង្កើនគោលការណ៍ដឹកនាំ និងគ្រប់គ្រងជាតិឱ្យបានមធ្យ័តថែមទៀត។ ធ្វើដូច្នេះបាន នោះទើបអាចទប់ស្កាត់ជាតិពុលនៃសាកលភាវូបនីយកម្មបាន។ ផ្ទុយទៅវិញ បើគ្មានវិធានការនោះទេ ប្រទេសកម្ពុជា គង់នឹងគេចមិនផុតពីមហន្តរាយទេគ្រោះ ដែលបង្កដោយសាកលភាវូបនីយកម្មនេះ។

៩. ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិលគ្រប់ផ្នែកគ្រប់ថ្នាក់ ជួយតាមដានពិនិត្យមើល និងប្រមូលផ្តុំគ្នា ទទួលពត៌មានឬពាក្យបណ្តឹងអំពីការរំលោភសិទ្ធិមនុស្ស និងសន្តិសុខមនុស្ស ដើម្បីរាយការណ៍ជូនអង្គការមានសមត្ថកិច្ច និងរាជរដ្ឋាភិបាល។

១០. ស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ មេត្តាខិតខំជួយយកចិត្តទុកដាក់ ប្រឆាំងតបនឹងការរំលោភសិទ្ធិមនុស្ស ការចាប់ជីវិតមនុស្សការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ បរិស្ថាន អំពីឆក់ប្លន់ដើម្បីធានាឱ្យបានល្អនូវសន្តិសុខរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម។

១១. ស្នើសុំឱ្យរាជរដ្ឋាភិបាល មានវិធានការទប់ស្កាត់អំពើពុករលួយក្នុងប្រព័ន្ធតុលាការ។ ស្នើសុំផ្តន្ទាទោសជនសម្លាប់ជីវិតមនុស្សក្រៅច្បាប់។ ស្នើសុំពង្រឹងប្រព័ន្ធតុលាការឱ្យមានយុត្តិធម៌និងស្នើសុំលើកស្ទួយការអប់រំសីលធម៌សង្គម និងគុណធម៌ជាតិ ដើម្បីលុបបំបាត់អំពើហិង្សា ការរំលោភសេចក្តីសុខសាន្តរបស់ប្រជាពលរដ្ឋ និងការកាប់សម្លាប់ជីវិតមនុស្សក្រៅច្បាប់។

១២. ស្នើសុំឱ្យរាជរដ្ឋាភិបាល ទទួលស្គាល់នូវតួនាទីរបស់អង្គការសង្គមស៊ីវិល ក្នុងការជួយតាមដានពិនិត្យមើល ការអនុវត្តន៍កម្មវិធីនយោបាយរបស់រដ្ឋាភិបាលក្នុងការរក្សាការពារសិទ្ធិមនុស្ស មនុស្ស និងសន្តិភាពរបស់ប្រជាពលរដ្ឋ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលកែលំអការខុសឆ្គងឱ្យបានទាន់ពេលវេលា សំដៅពង្រឹង ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើអាជ្ញាធរមូលដ្ឋាន ក៏ដូចជា មន្ត្រីរបស់រាជរដ្ឋាភិបាលក្នុងការរក្សាការពារសន្តិសុខរបស់ប្រជាពលរដ្ឋ។

១៣. ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិល យកចិត្តទុកដាក់ឱ្យបានល្អនូវការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា។ យុទ្ធនាការស្ថាបនា ទាំងពីរនេះគឺជា

គន្លឹះនៃការពង្រឹងស្ថាប័នឱ្យរឹងមាំ និងមានចីរភាព។ ការងារអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាព នៅក្នុងសង្គមស៊ីវិល គួរតែប្រមូលផ្ដុំទៅលើចំណេះដឹងសំខាន់បីគឺ (១)_ចំណេះដឹងទូទៅ (២)_ចំណេះដឹងបច្ចេកទេសវិជ្ជាជីវៈ និង (៣)_ចំណេះដឹងគុណធម៌។ ព្រមជាមួយនោះ ក៏គួរតែយកចិត្តទុកដាក់ហ្វឹកហ្វឺនឱ្យបានល្អនូវមុខវិជ្ជាខាងអភិបាលកិច្ចល្អ រដ្ឋបាលល្អនិងសុចរិតធម៌។ ធ្វើដូច្នោះបាន សង្គមស៊ីវិលកម្ពុជា នឹងអភិវឌ្ឍស្ថិតស្ថេររឹងមាំទៅអនាគត។

១៤_ ស្នើសុំឱ្យអ្នកដឹកនាំនិងគ្រប់គ្រងសង្គមស៊ីវិលមានគំនិតអភិវឌ្ឍន៍ៈ អភិវឌ្ឍទាំងខ្លួនឯង ទាំងអ្នកនៅជុំវិញខ្លួន អភិវឌ្ឍទាំងទស្សនៈ ទាំងគោលបំណង និងសកម្មភាព។ អ្នកដឹកនាំគួរមានចរិតនឹងនរ និងប្រាកដនិយម ដើម្បីធ្វើគំរូឱ្យអ្នកដើរតាម ដែលត្រូវមានសេចក្ដីស្មោះត្រង់និងគោរពវិន័យ។

១៥_ ស្នើសុំរដ្ឋាភិបាលខិតខំត្រិះរិះរកវិធានការទប់ស្កាត់ភាពអសីលធម៌សង្គម វប្បធម៌អសកម្មពីខាងក្រៅ ដើម្បីលើកស្ទួយគុណធម៌ជាតិ សីលធម៌ ប្រពៃណីជឿនលឿន និងអរិយធម៌ដ៏រុងរឿងរបស់ដូនតាយើង។ ការលើកស្ទួយសីលធម៌សង្គម គឺជាការរួមចំណែកស្ថាបនាធនធានមនុស្សខ្មែរ ឱ្យមានចិត្តគំនិតស្អាតស្អំ សុចរិតធម៌ យុត្តិធម៌ និងចំរើនជឿនលឿនសំរាប់ប្រទេសកម្ពុជាមួយ ឯករាជ្យ ថ្លៃថ្នូរនិងសន្តិភាព។

១៦. ស្នើសុំក្រសួងមហាផ្ទៃ ពិនិត្យពិចារណា អំពីស្ថិតិជាតួលេខាពិតប្រាកដរបស់អង្គការក្រៅរដ្ឋាភិបាល និងសមាគមក្នុងស្រុកឡើងវិញ ព្រោះតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការសិក្សាស្រាវជ្រាវ ឃើញមានចំនួនអង្គការក្រៅរដ្ឋាភិបាល និងសមាគមជាច្រើន ដែលមានតែឈ្មោះក្នុងបញ្ជី តែគ្មានរូបភាព ឬការិយាល័យធ្វើការងារពិតប្រាកដ។ ការកំណត់បាន នូវស្ថិតិពិតប្រាកដ និងសកម្មភាពធ្វើការងាររបស់អង្គការ និងសមាគមនេះ មានសារៈសំខាន់ណាស់ដល់ការគ្រប់គ្រង និងការអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលឱ្យល្អប្រសើរទៅអនាគត។

១៧. ស្នើសុំឱ្យវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលជាម្ចាស់គម្រោងកម្មវិធី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា" ធ្វើការប្រជុំតុមូលមួយទៀត ស្តីពី "គម្រោងច្បាប់អង្គការក្រៅរដ្ឋាភិបាល NGOs" ដោយត្រូវមានច្បាប់ក្នុងដៃគ្រប់គ្នា ដើម្បីងាយស្រួលដល់ការមានមតិ និងការធ្វើអនុសាសន៍។

១៨. ស្នើសុំ រាល់សេចក្តីព្រាងច្បាប់ទាំងឡាយរបស់រដ្ឋាភិបាល ឬរបស់សភាជាតិ មុននឹងអនុម័ត គួរតែមានការចូលរួមមតិពិភាក្សារបស់មហាជន និងប្រជាពលរដ្ឋផង។ ធ្វើដូច្នោះបាន នោះការអនុវត្តន៍ច្បាប់ទាំងនោះ កាន់តែបំរើបានសំណូមពរ សេចក្តីត្រូវការរបស់សង្គម និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។

១៩. ស្នើអំពាវនាវឱ្យអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ក្នុងស្ថានភាពដែលពុំទាន់មានច្បាប់ការពារសិទ្ធិ និងសកម្មភាពរបស់ខ្លួន ប្រកាន់គោលជំហរឱ្យបានល្អត្រឹមត្រូវតាមច្បាប់ គ្រប់គ្រងសង្គមនិងពលរដ្ឋដោយត្រូវចៀសវាងដាច់ខាត នូវរាល់ទង្វើណាដែលប៉ះពាល់ដល់កិត្តិយស និងភាពបរិសុទ្ធពិតត្រង់របស់អង្គការសង្គមស៊ីវិលក្នុងការបំរើផលប្រយោជន៍សង្គម និងប្រជាពលរដ្ឋ។ រាល់សកម្មភាពទាំងឡាយណា ដែលស្ដែងឱ្យឃើញ នូវការកេងប្រវ័ញ្ចយកផលប្រយោជន៍រួមមកធ្វើជាផលប្រយោជន៍បុគ្គល ដោយខុសនឹងគោលការណ៍ពិតប្រាកដរបស់អង្គការសង្គមស៊ីវិលកម្ពុជា ជាទូទៅ ត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់និងមហាជន។

២០. ស្នើសុំឱ្យម្ចាស់គម្រោងកម្មវិធី វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព រៀបចំបង្កើតឱ្យមានសន្និសីទថ្នាក់ជាតិមួយ ស្ដីពី "ការអភិវឌ្ឍន៍អង្គការពុំមែនរដ្ឋាភិបាល ដើម្បីអត្ថប្រយោជន៍ពិតរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋ ក្រោយពេលមានច្បាប់អង្គការពុំមែនរដ្ឋាភិបាល NGOs"។

២១. ស្នើសុំឱ្យរាជរដ្ឋាភិបាលលើកកំពស់ប្រសិទ្ធភាព នៃការអនុវត្តន៍ច្បាប់ ដាក់ទោសឧក្រិដ្ឋជននិងអ្នករំលោភច្បាប់។

២២. ដើម្បីលើកកំពស់តួនាទីស្ត្រីភេទឱ្យមានតុល្យភាព និងសមភាពក្នុងមតុទ្ទេសភាព និងការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងសង្គមជាតិស្មើនិងបុរសភេទ អង្គការពិភាក្សាតុមូល ស្នើសុំរដ្ឋាភិបាលខិត

ខំបង្កើនគោលនយោបាយអប់រំស្ត្រីខ្មែរឱ្យបានច្រើននិងមានប្រសិទ្ធភាពថែមទៀត។ ការងារនេះអាចសំរេចទៅបាន គ្មានអ្វីក្រៅពីការអប់រំទេ។ ការអប់រំត្រូវធ្វើឡើងចាប់តាំងពីគ្រួសារឡើងទៅ រហូតដល់សង្គមទាំងមូល។ ការជំរុះចោលនូវប្រពៃណីរិតត្បិតកូនស្រីមិនឱ្យបង្ហាញមុខក្នុងសង្គមគ្រួសារឬពិធីការធំៗក្នុងសង្គមជាតិ គឺជាការចាំបាច់ណាស់ ដើម្បីទម្លាប់ឱ្យស្ត្រី មានសេចក្តីក្លាហានចេញមុខមាត់ធ្វើការងារក្នុងគ្រួសារក្នុងសហគមន៍ និងសង្គមទាំងមូល។

២៣- ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ ជួយលើកស្ទួយវត្តមាន និងតួនាទីរបស់ស្ត្រីនៅក្នុងការដឹកនាំ និងគ្រប់គ្រងនៅក្នុងអង្គការរបស់ខ្លួន ស្មើភាពនឹងបុរសផង។ គឺផ្តើមចេញពីការលើកស្ទួយស្ត្រីភេទ នៅក្នុងអង្គការសង្គមស៊ីវិលនេះហើយ ដែលអាចនាំឱ្យតម្លៃនិងសារៈសំខាន់របស់ស្ត្រីភេទ កាន់តែត្រូវបានសង្គមមើលឃើញ ហើយប្រយុទ្ធដណ្តើមយកតួនាទីដឹកនាំ និងគ្រប់គ្រងសង្គមជាតិ ស្មើនឹងបុរសភេទ។

២៤- ហេតុដែលមិនអាចអនុញ្ញាតឱ្យស្ត្រី បានទទួលការអប់រំសិក្សាខ្ពស់ស្មើនិងបុរស គឺព្រោះតែជីវភាពក្រីក្រ កង្វះការអប់រំពីមាតាបិតាក្នុងគ្រួសារ និងប្រពៃណីអៀនខ្មាស។

ហេតុដូច្នេះ កិច្ចពិភាក្សាតុមូល ស្នើសុំរាជរដ្ឋាភិបាល និងសង្គមគ្រួសារ មេត្តាខិតខំយកចិត្តទុកដាក់ ជួយជំនះឱ្យបាននូវបញ្ហាប្រឈមមុខនេះ។

២៥. ការលើកស្ទួយ វឌ្ឍនភាពនៃ "យេនឌ័រ_Gender" នៅកម្ពុជា ពុំអាចកាត់ផ្តាច់បានពីការអប់រំសិក្សា និងការផ្សព្វផ្សាយឡើយ។ ទន្ទឹមនោះ ឆន្ទៈនយោបាយរបស់រដ្ឋាភិបាល និងការឧបត្ថម្ភពីបុរសភេទ គឺជាកត្តាស្លាប់រស់មួយនៃការអភិវឌ្ឍន៍ "យេនឌ័រ_Gender" នៅកម្ពុជា។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ជាងនោះ គឺ "កត្តារបស់ស្ត្រីខ្លួនឯង" ដែលត្រូវខិតខំរំដោះខ្លួនឱ្យរួចផុតពីភាពល្ងង់ខ្លៅ ភាពអសមត្ថភាព ភាពទន់ខ្សោយ និងប្រពៃណីឱនថយ ដែលពុំបានផ្តល់តម្លៃឱ្យស្ត្រី និងប្រមាថមាក់ងាយស្ត្រីថា ជាភេទទន់ខ្សោយ។ គឺ "កត្តាខ្លួនឯងរបស់ស្ត្រី" នេះហើយដែលជាកត្តាឈ្នះដែលអាចជួយលើកស្ទួយតុល្យភាព និងសមភាពរវាងបុរស និងស្ត្រីបានគ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ។

សូមស្ត្រីទាំងអស់ ក្រោកឈរឱ្យស្រុះគ្នាឡើង! នេះគឺជាសេចក្តីអំពាវនាវរបស់កិច្ចពិភាក្សាតុមូល។

២៦. អំពើពុករលួយ គឺជារោគមហារីកសង្គម ដែលធ្វើឱ្យសង្គមឈឺរាំរ៉ៃ ហើយវិនាសសាបសូន្យនៅទីបំផុត។ គឺមានតែការប្រើប្រាស់វិធានការច្បាប់ និងការកាត់ទោសជនពុករលួយទេ ដែលអាចទប់ស្កាត់អំពើពុករលួយបាន។

កិច្ចពិភាក្សាតុមូល ស្នើសុំឱ្យរាជរដ្ឋាភិបាលមានវិធានការទប់ស្កាត់និងលុបបំបាត់អំពើពុករលួយក្នុងសង្គម និងស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ខិតខំជួយរួមចំណែកទប់ស្កាត់អំពើ

ពុករលួយ និងការកែបន្លំ នៅក្នុងអង្គការសង្គមស៊ីវិល ក៏ដូចជាក្នុងសង្គមជាតិ តាមរយៈការលើកស្ទួយអភិបាលកិច្ចល្អ និងសុចរិតធម៌ក្នុងការដឹកនាំនិងគ្រប់គ្រង។

២៧. ដើម្បីធ្វើឱ្យ "ការធ្វើសេចក្តីសំរេចចិត្ត" នៅក្នុងអង្គការសង្គមស៊ីវិល បានប្រកបដោយគតិបណ្ឌិត សច្ចៈ យុត្តិធម៌ មានអភិបាលកិច្ចល្អ និងគ្មានអំពើពុករលួយ ស្នើសុំឱ្យអង្គការសង្គមស៊ីវិលទាំងអស់ ឧស្សាហ៍ព្យាយាមធ្វើអន្តោបនិជ្ឈាន (អត្តពិគ្រោះ-Introspection) នូវទង្វើរបស់ខ្លួន តាមរយៈវិធីសាស្ត្រអប់រំខ្លួនដោយខ្លួនឯង ដោយច្បាប់ពីរយ៉ាង គឺច្បាប់ក្រៅនិងច្បាប់ក្នុង។ ច្បាប់ក្រៅគឺច្បាប់រដ្ឋ-ច្បាប់ក្នុង គឺច្បាប់គុណធម៌ និងសីលធម៌ខាងផ្លូវចិត្តគំនិត។ ច្បាប់រដ្ឋធ្វើឱ្យមនុស្សខ្លាចអំពើអាក្រក់។ រីឯច្បាប់សីលធម៌គុណធម៌ធ្វើឱ្យមនុស្សអៀនខ្មាសចំពោះអំពើអាក្រក់។ ច្បាប់ទាំងពីរនេះមិនអាចខ្វះច្បាប់មួយណាបានឡើយ។

២៨. ស្នើសុំឱ្យរាជរដ្ឋាភិបាល មានវិធានការជួយទប់ស្កាត់អំពើពុករលួយនៅក្នុងមជ្ឈដ្ឋាន អ្នកមានអំណាចដឹកនាំ និងគណបក្សនយោបាយធំៗ ដើម្បីកុំឱ្យនាយទុនបរទេសមានបង្អែក ហើយយកបង្អែកនោះ ទៅកេងប្រវ័ញ្ចកម្លាំងញើសឈាមរបស់កម្មករ។

ស្នើសុំឱ្យអ្នកដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសំរេចទាំងអស់ គោរពក្រមសីលធម៌មួយ ព្រោះបើអ្នកដឹកនាំគ្មានក្រមសីលធម៌ការដឹកនាំឬការធ្វើសេចក្តីសំរេចចិត្តក៏គ្មានសីលធម៌ដែរ។

២៩. ដើម្បីទប់ស្កាត់បាននូវបញ្ហាទាំងឡាយ ដែលកើតមាននៅក្នុងការប្រមូលផ្តុំធនធាន ក្នុងការកសាងនិរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា អង្គពិភាក្សាស្នើសុំឱ្យអង្គការសង្គមស៊ីវិលទាំងអស់ស្ថាបនាឱ្យបាននូវ៖

(១). ការចូលរួមគាំទ្រ ក្នុងការបង្កើនកម្មវិធីនិងសកម្មភាព។

(២). ការយល់ដឹង និងការទទួលស្គាល់ពីសារៈនៃការប្រមូលផ្តុំធនធាន។

(៣). ការចេះស្វែងរកធនធាន និងការប្រមូលផ្តុំធនធានទាំងធនធានថវិកា និងធនធានមនុស្ស នៅក្នុងរដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាល។

(៤). ការឈ្វេងយល់ និងសហការជាមួយរដ្ឋាភិបាលនិងផ្នែកឯកជន ដើម្បីអភិវឌ្ឍន៍។

៣០. បញ្ហាប្រឈមមុខជាចំបងមួយ ក្នុងការប្រមូលផ្តុំធនធានក្នុងអង្គការសង្គមស៊ីវិល នោះគឺការផ្សព្វផ្សាយ។ អង្គពិភាក្សាស្នើសុំឱ្យអង្គការសង្គមស៊ីវិលទាំងអស់ មានបំណងច្បាស់លាស់ និងសុចរិតធម៌ នៅក្នុងការប្រមូលផ្តុំធនធាន ព្រមទាំងស្នើសុំឱ្យមានការផ្សព្វផ្សាយទូលំទូលាយផង នោះទើបប្រមូលផ្តុំបានសហប្រតិបត្តិការនិងការចូលរួម។

៣១. ដើម្បីរក្សាបាននូវភាពជាប់លាប់របស់ខ្លួន អង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចូលរួម ស្នើសុំអំពាវនាវឱ្យអង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ ស្គាល់ច្បាស់នូវតួនាទីរបស់ខ្លួន ភាពជាដៃគូរបស់

រដ្ឋាភិបាល ស្នើសុំឱ្យចេះជួយគ្នា ចេះធ្វើការតាមចង្កោមនិងចរិតការងារនិងចេះច្បាមជាប់នូវគោលនយោបាយនិងកម្មវិធីការងាររបស់រដ្ឋាភិបាល ដើម្បីស្រាវជ្រាវស្វែងរកចំណុចដែលត្រូវជួយ។

ហេតុ ដែលនាំឱ្យមានការលំបាក ក្នុងការប្រមូលផ្ដុំធនធានដើម្បីនិរន្តរភាពនៃអង្គការសង្គមស៊ីវិលកម្ពុជា នោះគឺបណ្ដាលមកពីបញ្ហាមនុស្ស បញ្ហាធនធានមនុស្ស បញ្ហាថវិកា ការគ្រប់គ្រងគ្មានអភិបាលកិច្ចល្អ និងទស្សនៈចង្អៀតចង្អល់។

ដូច្នេះ ស្នើសុំឱ្យសង្គមស៊ីវិល ខិតខំពង្រឹងឱ្យបាននូវភាពជាដៃគូជាមួយរដ្ឋាភិបាល-ជាមួយម្ចាស់ឧបត្ថម្ភថវិកានិងភាពជាដៃគូជាមួយផ្នែកឯកជន ដើម្បីលុបបំបាត់ឱ្យបាននូវហេតុផលនេះ។

៣២- និរន្តរភាពនៃសង្គមស៊ីវិលកម្ពុជា ដែលបានមកពីការប្រមូលផ្ដុំធនធាន មិនអាចកើតមានបានលើភាពល្ងង់ខ្លៅទេ គឺកើតមាននៅលើចំណេះដឹង។ ស្នើសុំឱ្យអង្គការសង្គមស៊ីវិលទាំងអស់បន្តការខិតខំប្រឹងប្រែងយកចិត្តទុកដាក់អំពីការសិក្សារៀនសូត្រ និងស្នើសុំជួយលើកស្ទួយស្មារតីឧបត្ថម្ភខ្លួន ដោយខ្លួនឯង និងការយល់ដឹងត្រូវនោះទើបអាចទប់ស្កាត់បាននូវបញ្ហាប្រឈមមុខទាំងឡាយ ក្នុងការប្រមូលផ្ដុំធនធាន ដើម្បីកសាងភាពជាប់លាប់ (និរន្តរភាព) នៅក្នុងអង្គការសង្គមស៊ីវិលកម្ពុជា។

សរុបសេចក្តីមក អនុសាសន៍ទាំងអស់ខាងលើគឺជាសំណូមពរសំខាន់ៗ របស់អ្នកតំណាងអង្គការសង្គមស៊ីវិល និងសមាជិកទាំងអស់ដែលបានចូលរួម ក្នុងកិច្ចពិភាក្សាតុមូលទាំង១០លើក និងក្នុងសន្និសីទថ្នាក់ជាតិ។ សំណូមពរទាំងនេះ ត្រូវបានផ្សព្វផ្សាយតាមរបាយការណ៍ជាបន្តបន្ទាប់ទៅគ្រប់ស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ អាជ្ញាធរដែលពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលភាគច្រើន។

ហើយនៅលើកចុងក្រោយនេះទៀត អនុសាសន៍ទាំងនេះ ត្រូវបានប្រមូលផ្តុំចងក្រង និងបោះពុម្ពផ្សាយទូលំទូលាយ ដើម្បីបានជាសំណូមពរ និងចំណេះដឹងដល់អ្នកសិក្សាទាំងឡាយ។

សង្ឃឹមថា រាជរដ្ឋាភិបាល សភាជាតិ ព្រឹទ្ធសភា ព្រមទាំងអ្នកដឹកនាំ អាជ្ញាធរពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលគ្រប់ថ្នាក់ គ្រប់ផ្នែកជួយពិនិត្យពិចារណា និងរួមចំណែកដោះស្រាយ ដោយស្មារតីស្ថាបនា សហប្រតិបត្តិការ និងការទទួលខុសត្រូវ។

សូមឱ្យអនុសាសន៍ទាំងនេះ ត្រូវបានស្រាយ និងក្លាយជាការប្រតិបត្តិជាក់ស្តែង ដើម្បីវឌ្ឍនភាពនៃសង្គមស៊ីវិល និងអភិបាលកិច្ចល្អនៅកម្ពុជា៕

## VI- សុន្ទរកថានៃវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាតុមូល :

### ៦.១-សុន្ទរកថាថ្លែងដោយឯកឧត្តម នៅ កាស៊ី នាយកវិទ្យាស្ថានកម្ពុជា ដើម្បីសិទ្ធិមនុស្ស និងជាអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពី "សញ្ញាណអភិបាលកិច្ចល្អដោយផ្សាភ្ជាប់នៅនឹងតួនាទីសង្គមស៊ីវិលខ្មែរ"

**សេចក្តីផ្តើម :**

- មានភាពខុសគ្នារវាងការគ្រប់គ្រងបែបអត្តាធិតេយ្យ ដែលធ្វើឡើងតាមរបៀបបញ្ជា (ពីលើចុះក្រោម) និងការគ្រប់គ្រងបែបប្រជាធិបតេយ្យ គឺធ្វើតាមរបៀបបំរើដោយ អនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមមានមតិយោបល់។
- គោលការណ៏ចាត់ចែងឬការគ្រប់គ្រង (ដែលជាទ្រឹស្តី)។

អ្វីទៅគោលការណ៍ចាត់ចែងឬការគ្រប់គ្រង?

គោលការណ៏ចាត់ចែងឬការគ្រប់គ្រងគឺជា វិធីឬជាសិល្បៈ ដែលអ្នកគ្រប់គ្រងទាំងឡាយប្រើប្រាស់ក្នុងគោលបំណង ធ្វើឱ្យការងារ របស់ខ្លួនអាច **សម្រេចបានតាមរយៈមនុស្ស**។

ដំណើរការនៃការគ្រប់គ្រង

ការគ្រប់គ្រងនេះដំណើរការបានជាមួយមនុស្សតាមរយៈ ៖

■ ការធ្វើផែនការ ■ ការចាត់តាំង ■ ការត្រួតពិនិត្យ

## រូបតាងសង្ខេបការងារគ្រប់គ្រង




→ មនុស្ស

→ សម្ភារៈ ថវិកា

→ ពេលវេលា

ជារួម អ្នកពូកែគ្រប់គ្រងគឺជាអ្នកមានគំនិតផ្តួចផ្តើម ហើយយកមកធ្វើការថ្លៃប្រឌិត បានជាផែនការល្អៗ ព្រមទាំងចេះធ្វើការចាត់តាំង និងតាមដានត្រួតពិនិត្យការងារបានយ៉ាងត្រឹមត្រូវទៀតផង។

អ្វីទៅអភិបាលកិច្ចល្អ?

គឺការប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកទេសល្អបំផុតដើម្បីគ្រប់គ្រងឱ្យបានល្អ។ បើយើងនិយាយថា គោលការណ៍ចាត់ចែងឬការគ្រប់គ្រងជាទ្រឹស្តីនោះ អភិបាលកិច្ចល្អគឺជាការអនុវត្តន៍ទ្រឹស្តីនៃការគ្រប់គ្រង។

# លក្ខណៈនៃការគ្រប់គ្រងល្អ និងការអនុវត្តន៍

## ១_ ផ្ដល់សេវាជូនសាធារណៈ

គឺមន្ត្រីជាអ្នកបំរើប្រជាពលរដ្ឋ។ តើជាការពិតទេ ដែលគេលើកឡើងថា មន្ត្រីផ្ដល់សេវាជូនសាធារណៈឬជាអ្នកបំរើប្រជាពលរដ្ឋ?




## ការរៀបចំផែនការ

- ពិនិត្យមើលកិច្ចការឬបញ្ហាដែលអ្នកចង់សំរេចឬដោះស្រាយ
- សំរេចយកកិច្ចការដែលអ្នកយល់ថាចង់ និងអាចសំរេចបាន

- ប្រមូលពត៌មានស្តីពីបញ្ហានោះ
- កំណត់ទិសដៅ និងកម្មវត្ថុរបស់អ្នក
- បង្កើតផែនការការងារ

<u>**ការចាត់តាំង**</u> (មនុស្ស សម្ភារៈ ថវិកា ពេលវេលា)

- តើនរណានឹងធ្វើកិច្ចនោះ?
- តើត្រូវធ្វើអ្វីខ្លះ ?
- ជួបនិយាយជាមួយមនុស្ស ដែលត្រូវផ្ទេរកិច្ចឱ្យ
- ត្រូវធ្វើការព្រមព្រៀងគ្នា (សន្យា)

<u>**ការត្រួតពិនិត្យ**</u>

- ចុះទៅការដ្ឋាន (កន្លែងធ្វើការ)
- ជួបប្រជុំជាមួយបុគ្គលិក កម្មករ
- ជួបជាមួយអតិថិជន
- វាយតម្លៃបរិមាណ និងគុណភាពការងារ
- ផ្តល់ពត៌មានតបវិញ (Feedback)

**កំណត់ចំណាំ** : មន្ត្រីគឺជាអ្នកបំរើដ៏ថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ទៅតាមតួនាទី ភារកិច្ច ដែលខ្លួនបានទទួលតាមរយៈការជ្រើសរើសពីរដ្ឋាភិបាល តែមន្ត្រីដាច់ខាតមិនមែនជាខ្ញុំកុំដរដាច់ថ្លៃ ឬ ជាទាសកររបស់ប្រជាពលរដ្ឋឡើយ។

## ២. ការចូលរួមរបស់ប្រជាពលរដ្ឋ

តើការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការងាររបស់អ្នកគ្រប់គ្រងពិតជាមានសារៈសំខាន់មែនឬយ៉ាងណា?

<u>សំណួរ</u>

- តើសិក្ខាសាលាអាចសម្រេចបាន តាមទិសដៅរបស់ខ្លួនទេ បើសិក្ខាកាម មិនបានចូលរួមរៀនសូត្រផងនោះ?
- តើគ្រូបង្រៀនអាចបង្រៀនបានទេ បើកូនសិស្សមិនមកចូលរួមស្តាប់ការបង្រៀនរបស់ខ្លួន?
- តើមណ្ឌលសុខភាពមួយអាចដំណើរការបានទេ បើប្រជាពលរដ្ឋជឿ ស៊ប់តែទៅលើអបិយជំនឿ?
- តើភោជនីយដ្ឋានមួយ អាចដំណើរការលក់ដូរបានយូរអង្វែងទេ បើគ្មានអតិថិជនមកជួយចូលរួមហូបចុក ក្នុងភោជនីយដ្ឋាននោះ?
- ឧទាហរណ៍នៃការមិនចូលរួមរបស់ប្រជាពលរដ្ឋ។
- អង្គការក្រៅរដ្ឋាភិបាល មួយដែលមានកម្មវិធីការងារកែលំអអនាម័យ បានចុះទៅមូលដ្ឋានដាច់ស្រយាល ហើយសង្កេតឃើញថា ប្រជាពលរដ្ឋក្នុងមូលដ្ឋាននោះស្គាំងស្គមដោយខ្វះអនាម័យ (គ្មានបង្គន់អនាម័យ)។

- ក្រោយពីបានពិចារណាសព្វគ្រប់ មន្ត្រីទាំងនោះបានសំរេចគ្នាគាត់ថាធ្វើសំណើរសុំថវិកា ដើម្បីសាងសង់បង្គន់អនាម័យជូនគ្រប់គ្រួសារទាំងអស់ ក្នុងភូមិដែលនៅទីបំផុតសំណើនោះបានសំរេច។

- លុះធ្វើការងារចប់សព្វគ្រប់ មន្ត្រីអង្គការក្រៅរដ្ឋាភិបាលត្រឡប់ទៅទីស្នាក់ការខ្លួនវិញ ដោយសន្យាថានឹងត្រឡប់មកវិញនៅឆ្នាំបន្ទាប់ដើម្បីតាមដានលទ្ធផលការងាររបស់ខ្លួន។

- តាមការសន្យា គាត់បានវិលត្រឡប់មកវិញ ហើយពិនិត្យឃើញថា គ្មានការប្រែប្រួលអ្វីសោះ (ប្រជាពលរដ្ឋនៅស្ដាំងស្ដមដដែល) ដោយមូលហេតុប្រជាពលរដ្ឋយកបង្គន់ខ្លួនទៅប្រើជាជង្រុកទាំងអស់គ្នា។

- ទាំងនេះសឱ្យឃើញថា ការងាររបស់អង្គការក្រៅរដ្ឋាភិបាលមិនបានសម្រេចដោយប្រជាពលរដ្ឋពុំបានចូលរួមជាមួយ។ ប្រការដែលមន្ត្រី អង្គការក្រៅរដ្ឋាភិបាលធ្វើសេចក្ដីសំរេចខ្លួនឯង ដោយពុំបានសួរមតិយោបល់របស់ប្រជាពលរដ្ឋហើយដាក់សេចក្ដីសំរេចនេះចុះមកឱ្យប្រជាពលរដ្ឋអនុវត្ត គឺជាការអនុវត្តន៍ការគ្រប់គ្រងអត្តាធិបតី។ លទ្ធផលដូចបានរៀបរាប់ជូនខាងលើ (ប្រជាពលរដ្ឋនៅស្ដាំងស្ដមដដែល) គឺអ្វីដែលមន្ត្រីទទួលបានពីការអនុវត្តន៍ ការគ្រប់គ្រងបែបអត្តាធិបតី។

**តើធ្វើដូចម្ដេចទើបទទួលបានការចូលរួម?**

ដើម្បីទទួលបានការចូលរួម ត្រូវបង្កលក្ខណៈឱ្យមានការចូលរួម តាំងពីការចាប់ផ្ដើមអនុវត្តការងារ។ ត្រូវជួបប្រជុំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យបានយល់ដឹងពីអនាម័យ។ សួរមតិប្រជាពលរដ្ឋមានយោបល់ពីសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ។ ធ្វើការព្រមព្រៀងជាមួយប្រជាពលរដ្ឋ អំពីការប្រើបង្គន់អនាម័យ។ ដាក់ភ្នាក់ងារឱ្យតាមដានការប្រើប្រាស់ដើម្បីធានាបាននិរន្តរភាព។

ធ្វើរបៀបនេះ នាំឱ្យប្រជាពលរដ្ឋយល់ថា ខ្លួនគេមានការរួមចំណែកក្នុងកម្មវិធីនេះដែរ ហើយជួយខិតខំទាំងអស់គ្នា ដោយបង្កើតបាននូវសាមគ្គីភាព ជំនឿទំនុកទុកចិត្តការគាំទ្រ ជាពិសេសការចូលរួមជាហេតុដែលនាំឱ្យទទួលបានលទ្ធផលល្អពីការងារ ដែលមន្ត្រីបំរុងធ្វើឱ្យសំរេច។

ដូច្នេះ ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ក្នុងការងាររបស់អ្នកគ្រប់គ្រងមានសារៈសំខាន់ណាស់ចំពោះការងារគ្រប់គ្រង។

ដើម្បីទទួលបានការចូលរួម ជាមតិយោបល់នេះអ្នកគ្រប់គ្រងអាចប្រើប្រាស់ការពិភាក្សាបំផុសគំនិត។ ឯការចូលរួមរបស់ប្រជាពលរដ្ឋដែលជាមូលដ្ឋានគ្រឹះ នៃលទ្ធិប្រជាធិតេយ្យ គឺការសម្ដែងមតិតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន។

ម្យ៉ាងវិញទៀត អ្នកគ្រប់គ្រងត្រូវផ្ដល់ឱកាស ជូនសាធារណៈ ដើម្បីទទួលបានការចូលរួមនេះ។

៣_ ការផ្ដល់ឱកាសជូនសាធារណជន :

នេះគឺជាទិដ្ឋភាពមួយនៃការចូលរួមរបស់ប្រជាពលរដ្ឋ ការផ្ដល់ឱកាសមានន័យថា អនុញ្ញាតឱ្យប្រជាពលរដ្ឋចូលមកជួបជាមួយអ្នកគ្រប់គ្រងដោយផ្ទាល់ ដើម្បីសាកសួរចង់ដឹងអំពីអ្វីដែលអ្នកគ្រប់គ្រងកំពុងធ្វើថាតើសមស្របទៅនឹងប្រយោជន៍របស់ពួកគេដែរឬទេ? ឬដើម្បីផ្ដល់ពត៌មាន ឱ្យអ្នកគ្រប់គ្រងបានដឹងពីចំណុចខ្វះខាត ហើយដែលត្រូវបំពេញបន្ថែមក្នុងទិសដៅធ្វើការបំរើប្រជាពលរដ្ឋគ្រប់ជ្រុងជ្រោយ។

ដើម្បីអាចទទួលឱកាសនេះបាន អ្នកគ្រប់គ្រងត្រូវរៀបចំខ្លួនឱ្យទៅជាមនុស្សសាមញ្ញ ដែលប្រជាពលរដ្ឋក្នុងមូលដ្ឋានគោរពរាប់អានស្រឡាញ់ ហើយហ៊ាននិយាយប្រាប់ពីអាថ៌កំបាំងនានា ពីព្រោះគេមានជំនឿថានឹងមិនយកអ្វីដែលគេនិយាយប្រាប់ទៅផ្សព្វផ្សាយជាបន្តឡើយ។

ទោះបីជាប្រជាពលរដ្ឋដែលមកជួបខ្លួនជាអ្នកមានឬអ្នកក្រក្ដី អ្នកគ្រប់គ្រងត្រូវបង្ហាញឱ្យឃើញថា ការទទួលបានពត៌មាននេះនាំមកនូវផលចំណេញទាំងសងខាង។ ប្រជាពលរដ្ឋអាចទទួលបានអ្វីតាមសំណូមពររបស់គេ។

ឯអ្នកគ្រប់គ្រងវិញ អាចដឹងពីការខ្វះខាតរបស់ខ្លួន ហើយមានលទ្ធភាពបំពេញការខ្វះខាតនោះ ដែលនាំឱ្យប្រជាពលរដ្ឋពេញចិត្តនឹងការបំរើគេបានគ្រប់ជ្រុងជ្រោយ។

នៅពេលធ្វើការងារបានលទ្ធផលល្អ អ្នកគ្រប់គ្រងនឹងទទួលបានការសរសើរពីថ្នាក់លើរបស់គាត់។ ការសរសើរនេះគឺជាការផ្តល់ពត៌មានតបវិញ ក្នុងលក្ខណៈវិជ្ជមាន (positive feedback) ដែលក្នុងការគ្រប់គ្រងបែបប្រជាធិបតេយ្យ គេអនុវត្តរបៀបនេះឱ្យបាន៩៥%។

៤_ តម្លាភាព (ភាពបើកចំហ ឬមិនលាក់លៀម)

ក្លាយមកពីពាក្យថ្លា ហើយមានន័យថា អ្នកគ្រប់គ្រងធ្វើការផ្សព្វផ្សាយ ពត៌មានដល់ប្រជាពលរដ្ឋឱ្យបានដឹងឮនូវអ្វីដែលគេកំពុងធ្វើដើម្បីបម្រើប្រជាពលរដ្ឋ។

ឧទាហរណ៍ : ធៀបឧបមាថា គ្រួសារមួយចិញ្ចឹមក្មេងប្រុសកម្លោះឱ្យនៅរៀនសូត្រ ក្នុងគ្រួសាររបស់ខ្លួន។ ពេលថ្ងៃក្មេងប្រុសនោះនៅផ្ទះជាធម្មតា លើកលែងតែរាល់យប់ពីម៉ោង៩:០០ ទៅដល់ម៉ោង ១០:០០ ក្មេងនោះតែងតែទៅបាត់ពីផ្ទះដោយគ្មានដំណឹងអ្វីសោះ។

ក្នុងនាមជាអាណាព្យាបាលលើក្មេង តើគ្រួសារនោះ មានការសង្ស័យអ្វីដែរឬទេ? ហើយបើសង្ស័យ តើសង្ស័យក្មេងនោះទៅប្រព្រឹត្តអំពើល្អឬអាក្រក់?

តាមធម្មតាបើមានការសង្ស័យ គឺតែងសង្ស័យទៅលើផ្លូវអាក្រក់ ហើយពីព្រោះបើក្មេងនោះទៅធ្វើអ្វីល្អ ពិតជាក្មេងនោះមិនខ្លាចនឹងប្រាប់ការពិត (តម្លាភាព) ដល់អាណាព្យាបាលឡើយ។

ប៉ុន្តែតាមការពិតពេលដែលក្មេងទៅបាត់ពីផ្ទះវាពុំបានទៅប្រព្រឹត្តអំពើអ្វីអាក្រក់ទេ។ វាទៅញ៉ាំបង្អែមនៅផ្សារ រួចវាត្រឡប់មកផ្ទះវិញ។ ដូច្នេះ ទោះបីជាវាធ្វើល្អយ៉ាងណាក៏ដោយ ការខ្វះតម្លាភាពនេះឱ្យវារងការសង្ស័យពីសំណាក់ម្ចាស់ផ្ទះថា វាទៅប្រព្រឹត្តអំពើមិនល្អនោះ។ ព្រោះហេតុយ៉ាងនេះហើយ ដើម្បីកុំឱ្យប្រជាពលរដ្ឋសង្ស័យថា មន្ត្រីកេងប្រវ័ញ្ចលើគេ តាមរយៈការងារដែលខ្លួនមានភារៈត្រូវបម្រើ មន្ត្រីត្រូវអនុវត្តតម្លាភាព ពោលគឺត្រូវជម្រាបប្រជាពលរដ្ឋពីអ្វី ដែលខ្លួនកំពុងធ្វើឬបានធ្វើកន្លងមក។

*ឧទាហរណ៍*

សរសេរផ្លាកប្រាប់ប្រជាពលរដ្ឋនៅនឹងកន្លែងសាងសង់អាងស្តុកទឹកថា :

អំណោយរបស់.....................................

ដែលផ្តល់ថវិកាចំនួន.......................

សាងសង់អាងទទឹង........បណ្តោយ........កំពស់......កម្រាស់.........

## ៥_ ការទទួលខុសត្រូវ

ពាក្យខ្មែរល្អណាស់ ការទទួលខុសត្រូវអាចឱ្យយើងយល់ន័យបានតាមរយៈពាក្យដោយផ្ទាល់ពោលគឺ : "*ទទួលខុសពេលធ្វើខុស ហើយទទួលត្រូវពេលធ្វើត្រូវ* "។

ការដែលមនុស្សម្នាក់ៗ ទទួលខុសត្រូវដោយមកពីអ្នកទាំងនោះប្រើសិទ្ធិរបស់ខ្លួន។ ប្រការដែលយកការទទួលខុសត្រូវមកផ្សារភ្ជាប់ជាមួយនឹងសិទ្ធិគឺដើម្បីការពារកុំឱ្យមានភាពអានាធិបតេយ្យនៅក្នុងសង្គម។

យ៉ាងណាមិញ បើលោកប្រើសិទ្ធិក្នុងការប្រើប្រាស់កង់ លោកត្រូវចងភ្ជាប់ដោយការទទួលខុសត្រូវមួយ ពីព្រោះនៅពេលដែលលោកជិះកង់ទៅបុកអ្នកដទៃ បណ្តាលឱ្យមានគ្រោះថ្នាក់ លោកត្រូវប៉ះប៉ូវសងការខូចខាតដែលបណ្តាលមកពីការប្រើប្រាស់កង់របស់លោក។

ម្យ៉ាងវិញទៀត បើលោកប្រើសិទ្ធិក្នុងការចិញ្ចឹមឆ្កែឱ្យចាំផ្ទះនោះក៏មានការចង លោកត្រូវមានការទទួលខុសត្រូវមួយដែរ ពេលដែលឆ្កែលោកខាំគេ។

ចំពោះមន្ត្រីវិញ លោកមានការទទួលខុសត្រូវលើសពីប្រជាពលរដ្ឋ ដោយមូលហេតុលោកបានទទួលបុព្វសិទ្ធិ លើសពីប្រជាពលរដ្ឋ (ប្រាក់បៀវត្សប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន.....)។ ពាក់ព័ន្ធការទទួលខុសត្រូវនេះ លោកមានភារកិច្ចបម្រើប្រជាពលរដ្ឋឱ្យបានគ្រប់ជ្រុងជ្រោយតាមលក្ខណៈជាមន្ត្រីស្មោះត្រង់ មិនសំអាងអំណាចកៀបសង្កត់ប្រជាពលរដ្ឋ ដើម្បីគេងប្រវ័ញ្ចយកប្រយោជន៍ផ្ទាល់ខ្លួន និងមិនប្រព្រឹត្តអំពើពុករលួយជាដើម។

ប្រការមួយទៀត មានការទទួលខុសត្រូវមានន័យថា ធ្វើឱ្យបានសម្រេចរាល់ភារកិច្ចដែលខ្លួនទទួល។

ចំណែកពាក្យថា ទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់មានន័យថាត្រូវតែឆ្លើយតបចំពោះរាល់សំណួររបស់អ្នកនោះ។

ដូចបានរៀបរាប់ជូនខាងលើ បើមន្ត្រី ឬអ្នកគ្រប់គ្រងធ្វើការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់នោះនឹងនាំឱ្យប្រជាពលរដ្ឋស្រឡាញ់ទុកចិត្ត ព្រមទាំងពេញចិត្ត និងចូលរួមក្នុងការងារដែលអ្នកគ្រប់គ្រង ឬមន្ត្រីត្រូវធ្វើដើម្បីបម្រើគេ។

ទោះបីជាអ្នកគ្រប់គ្រងមានលក្ខណៈទាំង៥ខាងលើហើយក៏ដោយតែបើគេ មិនចេះចាត់ចែងការងារឱ្យបានល្អទេនោះ លទ្ធផលដែលគេទទួលនឹងពុំបានល្អដូចដែលគេប្រាថ្នាទេ។

## ៦_ ការចាត់ចែងល្អ

អ្នកគ្រប់គ្រងដែលចេះចាត់ចែងល្អ គឺអ្នកគ្រប់គ្រងដែលចេះរៀបចំប្រព័ន្ធអនុវត្តការងារ ក្នុងអង្គភាពខ្លួនឱ្យមានប្រសិទ្ធភាពល្អ ពោលគឺអាចសម្រេចការងារ បានល្អក្នុងរយៈពេលខ្លី (កាត់បន្ថយ ការិយាធិបតេយ្យ និងមិនខ្ជះខ្ជាយ) ចំណាយលុយកាក់អស់តិច។

<u>លំហាត់</u>

I បណ្ណាគារពីរនៅជិតគ្នា មានរបស់លក់ដូចគ្នាទាំងអស់។

**បណ្ណាគារ ក**

- មិនសូវរាក់ទាក់ជាមួយភ្ញៀវ
- ច្រើនប្រើសំដីមិនល្អជាមួយភ្ញៀវ
- យឺតយ៉ាវក្នុងការបម្រើភ្ញៀវ
- លក់ដោយតម្លៃថ្លៃជាងចំពោះរបស់ដូចគ្នា

**បណ្ណាគារ ខ**

- រាក់ទាក់នឹងភ្ញៀវ
- ប្រើសំដីពិរោះ យកចិត្តភ្ញៀវ
- បម្រើភ្ញៀវរហ័សទាន់ចិត្ត
- អាចទិញដោយតម្លៃថោកជាងចំពោះរបស់ដូចគ្នា

<u>សំណួរ</u>

- តើលោកអ្នកចូលចិត្តជ្រើសរើសចូលទិញក្នុងបណ្ណាគារណា?
- ដោយមូលហេតុអ្វី?
- តើបណ្ណាគារណាបានទទួលលទ្ធផលផ្លែផ្កាជាង?
- ក្នុងនាមជាមន្ត្រី តើលោកជ្រើសរើសអនុវត្តតាមគំរូបណ្ណាគារណាដើម្បីបានទទួលលទ្ធផលល្អពីការងាររបស់លោក?

II ប្រធានស្ថាប័នពីរផ្សេងគ្នា (ស្តីពីការគ្រប់គ្រងបុគ្គលិកក្រោមបង្គាប់)។

**ប្រធានស្ថាប័ន ក**

- ស្តីបន្ទោសបុគ្គលិកណាធ្វើខុស
- ស្តីបន្ទោសនៅចំពោះមុខសាធារណៈ

**ប្រធានស្ថាប័ន ខ**

- ណែនាំបុគ្គលិកណាធ្វើខុស
- ស្តីបន្ទោសនៅកន្លែងស្ងាត់កំបាំងពីសាធារណៈ

| | |
|---|---|
| ❑ ដាក់ទណ្ឌកម្មភ្លាមៗចំពោះកំហុស | ❑ ធ្វើការព្រមានជាមុនមួយលើកឬពីរលើក |
| ❑ ដាក់វិន័យតឹងរឹងឱ្យបុគ្គលិកប្រតិបត្តិតាមជាដាច់ខាត់ | ❑ ចងក្រងវិន័យសម្រាប់ស្ថាប័នទាំងដោយមានការចូលរួមចងក្រងពីសំណាក់បុគ្គលិក |
| ❑ អ្នកដឹកនាំមានចរិកលក្ខណៈឱ្យបុគ្គលិកកោតខ្លាច | ❑ បុគ្គលិកមិនខ្លាចទេ ប៉ុន្តែបុគ្គលិកគោរពដោយស្រឡាញ់ |

<u>សំណួរ</u>

តើលោក (ជាអ្នកដឹកនាំ) ជ្រើសយកលក្ខណៈមួយណា?

ក_ ចង់ឱ្យគេគោរពកោតខ្លាច.ឬ

ខ_ ចង់ឱ្យគេគោរពស្រឡាញ់?

*នេះជាអភិបាលកិច្ចល្អមួយ។*

## ៦.២_សុន្ទរកថាថ្លែងដោយ លោកស្រី ជូ ប៊ុនអេង អគ្គលេខាធិការ និងជានាយកប្រតិបត្តិ សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ស្តីអំពី "ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា បទពិសោធន៍ពលរដ្ឋកម្ពុជា"

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលបានអនុញ្ញាតឱ្យរូបខ្ញុំចូលរួម ក្នុងកិច្ចពិភាក្សាដ៏មានសារៈសំខាន់នេះ និងមានឱកាសផ្លាស់ប្តូរ នូវបទពិសោធន៍ដ៏ស្តួចស្តើង សំរាប់រួមចំណែកដល់ការពង្រឹងសង្គមស៊ីវិលរបស់យើង ឱ្យក្លាយជាដៃគូដ៏រឹងមាំរបស់រាជរដ្ឋាភិបាលក្នុងគោលដៅធ្វើឱ្យប្រទេសជាតិ ឈានឆ្ពោះទៅរកសេចក្តីសុខសន្តិភាពនិងអភិវឌ្ឍន៍យ៉ាងពេញលេញ។

ខ្ញុំសូមអនុញ្ញាត លើកយកទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ និងរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ក្នុងដំណើរការកសាងធនធានមនុស្សនិងការកសាងសមត្ថភាព នៅក្នុងសង្គមស៊ីវិលកម្ពុជាមកជំរាបជូនដូចខាងក្រោមៈ

នៅក្នុងប្រទេសមួយ រដ្ឋាភិបាល ស្ថាប័នមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ គ្រប់លំដាប់ថ្នាក់រស់នៅរួមសុខទុក្ខជាមួយគ្នា ប្រៀបបានអ្នករួមដំណើរក្នុងនាវាតែមួយ។ រដ្ឋាភិបាលមានភារកិច្ចជាអ្នកកសាងនាវានោះដោយប៉ាន់ប្រមាណ នូវទំហំបរិមាណផ្ទុកកម្លាំងចែវ សម្ភារ

បរិយាកាសស្បៀងនិងកិច្ចការពារជាច្រើនទៀត។ ពេលនាវានោះចេញដំណើរ រដ្ឋាភិបាលគឺជាអ្នកផ្តួចផ្តើម ក្នុងការកំណត់ទិសដៅដោយមានការព្រមព្រៀងពីប្រជាពលរដ្ឋរួមទាំងអស់ថា តើត្រូវធ្វើដំណើរឆ្ពោះទៅណា? តាមទិសណាទើបប្រសើរ? ត្រូវធ្វើអ្វីខ្លះ? ត្រូវធ្វើដូចម្តេច? តើអ្នកណាខ្លះជាអ្នកធ្វើអ្វី?...។ល។ ចំណែកស្ថាប័នដ៏ទៃទៀត គឺជាអ្នកដែលរួមដំណើរក្នុងនាវានោះ មានកាតព្វកិច្ចជួយចូកជួយចែវ ជួយតំរង់ទិសជួយជុសជុលកែលំអ បើមានការបាក់បែកខូចខាតឬជួយការពារបើសិនជាមានគ្រោះអាសន្ន ឬបើមាននរណាម្នាក់ចង់បំផ្លាញនាវានោះ។ ទាំងអស់គ្នា ត្រូវតែរួមចំណែកទទួលខុសត្រូវ មិនអាចយករួចខ្លួនបានឡើយ។ បើទូកនោះចេញ ខុសទិសដៅគ្រោងទុកឬមានបញ្ហាគ្មាននរណាម្នាក់ដែលរួចខ្លួនឡើយ ពោលគឺត្រូវទទួលផលប៉ះពាល់ទាំងអស់គ្នា។ នៅមានរឿងរ៉ាវច្រើនទៀតក្នុងដំណើរការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដែលត្រូវទំនាក់ទំនងសហការ ឬប្រកួតប្រជែងជាមួយមជ្ឈដ្ឋានជុំវិញថែមទៀត។

ដូច្នេះ ដើម្បីឱ្យនាវានេះមានសន្ទុះលឿនទៅមុខ និងត្រង់ទិសដៅបានទាមទារឱ្យមានផែនការច្បាស់លាស់ និងយុទ្ធសាស្ត្រការងារដ៏ល្អមួយ។ ប៉ុន្តែ ដើម្បីឱ្យមានឧបករណ៍ទាំងពីរនេះចាំបាច់ត្រូវមានធនធានមនុស្សដ៏រឹងមាំ និងឯកភាពគ្នាធ្វើឱ្យសំរេចនូវគោលដៅតែមួយ។

ដូចគ្នានេះដែរចំពោះស្ថាប័ន ឬអង្គការមួយដែលមានមនុស្សមួយក្រុមធ្វើការរួមគ្នា ត្រូវតែយកចិត្តទុកដាក់លើបញ្ហានេះដូចគ្នា។

ថវិកាគឺជាកត្តាចាំបាច់ដែលអាចធ្វើឱ្យមានសំភារៈ និងមធ្យោបាយសំរាប់ជាជំនួយក្នុងការធ្វើឱ្យមានសកម្មភាព។

ដោយឡែកកត្តាមនុស្ស គឺជាកត្តាកំណត់ដែលអាចបង្កើតឱ្យមានថវិកាសំភារៈ និងមធ្យោបាយទាំងនេះ ព្រមទាំងគំនិតផ្តួចផ្តើមជាច្រើនឈានដល់ការសំរេចជោគជ័យ។ បើសិនជាគ្មានធនធានមនុស្សដែលរឹងមាំនោះទេ មិនត្រឹមតែគ្មានការចាប់ផ្តើមទេ សូម្បីតែការបន្តវេនពីដំណាក់កាលជោគជ័យមួយក៏អាចធ្វើឱ្យជោគជ័យនោះបាត់បង់ទៅវិញដែរ។ មនុស្សដែលអាចក្លាយជាធនធាន សំរាប់កម្មវិធីការងារមួយបានទាមទារឱ្យមានសមត្ថភាពយល់ដឹង សមត្ថភាពធ្វើឆន្ទៈ ស្មារតីទទួលខុសត្រូវ ទំនាក់ទំនងល្អនិងសីលធម៌ល្អ។ ក្នុងការងារជា ក្រុមកត្តាមនុស្ស គឺជាតម្រូវការចាំបាច់រួមទាំងអ្នកដឹកនាំ និងអ្នកដើរតាមដែលនៅគ្រប់ផ្នែករហូតដល់ស្រទាប់ក្រោមបំផុត។ អ្នកទាំងពីរក្រុមត្រូវតែមានលក្ខណៈ រួមមួយចំនួនពោល គឺមានទស្សនៈ និងគោលដៅរួមតែមួយចេះសាមគ្គីគ្នា ចេះយល់ អាធ្យាស្រ័យគ្នា ចេះជួយគ្នា ហើយស្មោះត្រង់និងគ្នាទៅវិញទៅមក។ ទាំងអ្នកដឹកនាំ និងអ្នកដើរតាមត្រូវចេះអធ្យាស្រ័យគ្នា ចេះជួយគ្នា ហើយក៏បំពេញឱ្យគ្នាទៅវិញទៅមកដែរ។ ទោះបីជាអ្នកដឹកនាំពូកែយ៉ាងណាក៏ដោយ បើមិនមានអ្នករួមការងារល្អនោះទេ ក៏មិនអាចធ្វើឱ្យការងារ មួយសំរេចជោគជ័យបានដែរ។ ឧទាហរណ៏ អ្នកបើកបររថយន្តម្នាក់មានសមត្ថភាព ជំនាញយ៉ាងប៉ុនប្រសប់ក្នុងការបញ្ជារថយន្ត ប៉ុន្តែបើសិនជារថយន្តនោះ បែក

កង់ ឬអស់សាំងឬដាច់ហ្វ្រាំងរថយន្តនោះពិតជាមិនអាចទៅដល់គោលដៅតាមការគ្រោងទុកបានឡើយ។ ដូច្នេះ អ្នកដឹកនាំដែលពូកែត្រូវតែមានជំនាញជាច្រើនទៀត ដូចជាស្គាល់ គ្រឿងម៉ាស៊ីន ចេះជុសជុលគ្រឿងម៉ាស៊ីន ចេះត្រួតពិនិត្យ ចេះថែទាំជាដើម។ លើសពីនេះទៅទៀត ចំពោះមនុស្សគឺខុសពីគ្រឿងម៉ាស៊ីន ត្រង់មនុស្សមានអារម្មណ៍មានការគិត មានការពិចារណា។ ដូច្នេះមនុស្សត្រូវការទំនាក់ទំនងត្រូវការចិត្តសាស្ត្រដែលតម្រូវឱ្យមានវិធីសាស្ត្រផ្សេងៗ ជាច្រើនទៀតសំរាប់ប្រាស្រ័យទាក់ទង។ ជាការពិតណាស់ អ្នកដឹកនាំត្រូវតែមានគំនិតអភិវឌ្ឍ ពោលគឺអភិវឌ្ឍទាំងខ្លួនឯង អភិវឌ្ឍទាំង អ្នកពាក់ព័ន្ធជុំវិញខ្លួនទាំងទស្សនៈ ទាំងសកម្មភាព ទើបនាំមកនូវភាព រីកចំរើនបាន។

ជាប្រពៃណីតាំងពីដើមរៀងមក យើងតែងតែសង្កេត ឃើញថាអ្នកចេះដឹងជំនាន់មុន កំរបានចែករំលែកចំណេះដឹង និងបទពិសោធន៍មកអ្នកជំនាន់ក្រោយណាស់ ដូចពាក្យចាស់ពោលថា សុខចិត្តស្លាប់យកទៅផង។ ម្ល៉ោះហើយរបៀនមន្តអាគមទាំងឡាយ បានរលប់រលាយបាត់បង់ទៅបន្តិចម្តងៗ និងឈានទៅបាត់បង់ទាំងស្រុង ចំពោះមុខជំនាញខ្លះ។ ប៉ុន្តែ ចាស់ជំនាន់មុន គាត់ឱ្យតម្លៃខ្លាំងទៅលើចរិកនិងស្មារតី។ ទំរាំនិងទទួលអ្នកណាម្នាក់ធ្វើជាសិស្ស លុះត្រាតែគាត់សង្កេតឃើញថា អ្នកនោះមានការប្តេជ្ញាចិត្តមុះមុត មានស្មារតីទទួលខុសត្រូវនិងមានចរិកល្អគួរឱ្យស្រឡាញ់រាប់អាន។ ចំពោះខ្ញុំ យល់ថាការកំណត់បែបនេះ ក៏ត្រឹមត្រូវដែរ ព្រោះបើគ្មានឆន្ទៈ គ្មានការប្តេជ្ញាចិត្ត

ស្មារតីទទួលខុសត្រូវ និងសីលធម៌ទេ មិនអាចធ្វើឱ្យការងារសំរេចបានទេ ជួនកាលអាចសំរេចដែរ ប៉ុន្តែពុំមាននិរន្តរភាព និងភាពជឿនលឿនឡើយ។ បើក្នុងក្រុមមួយមានមនុស្សប្រភេទនេះច្រើននឹងនាំឱ្យមានគ្រោះថ្នាក់ ដល់ភាពរីកចំរើនក្នុងថ្ងៃណាមួយជាមិនខាន បើសិនជាមិនយកចិត្តទុកដាក់ ក្នុងការបណ្តុះបណ្តាលពង្រឹងស្មារតីទាំងប៉ុន្មាននេះបន្ថែមទៀតទេនោះ។ ជាការពិតណាស់ ក្នុងជំហានដំបូងនៃការអនុវត្តន៍ការងារ មនុស្សភាគច្រើន ពុំទាន់មានលក្ខណៈគ្រប់គ្រាន់ទាំងអស់នោះទេ ប៉ុន្តែបន្តិចម្តងៗ អាស្រ័យដោយការយកចិត្តទុកដាក់ហ្វឹកហ្វឺន និងពង្រឹងសមត្ថភាពគេនិងក្លាយជាធនធានមនុស្សដ៏ល្អប្រសើរ។

និយាយដោយខ្មែរ ចំពោះសមាគមនារីកម្ពុជា ដើម្បីសន្តិភាព គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលបានឆ្លងកាត់នូវបទពិសោធន៍ក្នុងដំណាក់កាលដ៏វែងបន្តួរអស់រយៈពេល២០ឆ្នាំ មកហើយ។ សមាគមយើងបានកំណត់គោលដៅរបស់ខ្លួនយ៉ាងជាក់លាក់ គឺរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថានភាពស្ត្រីតាមគ្រប់មធ្យោបាយសមស្រប ដើម្បីចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ជាតិមាតុភូមិ។ ដូច្នេះ តាំងពីជំហានចាប់ផ្តើមដំបូងរហូតមកដល់បច្ចុប្បន្ននេះ សមាគមយើងតែងតែធ្វើដំណើរ តាមទិសដៅគ្រោងទុក ហើយបានសំរេចនូវលទ្ធផលជាបណ្តើរៗ យ៉ាងល្អប្រសើរទៅតាមដំណាក់កាលនីមួយៗរហូតមក។

ជានិច្ចជាកាល សមាគមតែងតែយកចិត្តលើការកសាងធនធានមនុស្ស ព្រោះយើងចង់ផ្ដល់ឱកាសឱ្យស្ត្រី បានចូលប្រឡូកក្នុងការងារសង្គម ដោយចាប់ផ្ដើមពីមេផ្ទះឬសិស្ស និស្សិតគ្មានការងារធ្វើ ។ល។ អ្នកទាំងនេះ ដើមឡើយគ្មានបទពិសោធន៍ការងារទេ តែបន្ទាប់ពីបានទទួលឱកាស និងការបង្កនលក្ខណះឱ្យហ្វឹកហ្វឺនជាបន្តបន្ទាប់មកគេក៏ក្លាយទៅជាអ្នកជំនាញតាមផ្នែកនីមួយៗយ៉ាងពិតប្រាកដ។ អ្នកទាំងនោះមិនត្រឹមតែជាធនធានមនុស្សសំរាប់សមាគមយើងប៉ុណ្ណោះទេ តែមួយចំនួនធំក្លាយទៅជាអ្នកជំនាញសំរាប់ការងារ ក្នុងរដ្ឋាភិបាលក្នុងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមួយចំនួនទៀតផង។

កម្មវិធីសំខាន់ៗរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍គឺទី១ កម្មវិធីអភិវឌ្ឍន៍ ដែលរួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស និងធនធានសេដ្ឋកិច្ចទី២ កម្មវិធីលើកកំពស់សុខភាព និងទី០៣ កម្មវិធីអប់រំផ្សព្វផ្សាយ។ កម្មវិធីនីមួយៗត្រូវផ្ដោតការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រ និងសិទ្ធិស្ត្រីដែលជាគន្លឹះ ក្នុងការបង្កើតឱ្យមានសមត្ថភាពនិងយុត្តិធម៌ក្នុងសង្គម។

គ្រប់កម្មវិធីទាំងអស់ យើងតែងតែបញ្ចូលនូវការបណ្ដុះបណ្ដាលទៅតាមកំរិតតាំងពីថ្នាក់គ្រប់គ្រង រហូតដល់អ្នកទទួលអនុវត្ត តាមវិធីសាស្ត្រ និងរយៈពេលខុសៗគ្នា។ ពេលខ្លះយើងត្រូវចាប់ផ្ដើមពីបង្រៀនអក្ខរកម្មបញ្ជូនទៅសិក្សាក្នុងសាលាក្រៅ ប្រព័ន្ធសាលា បំពេញវិជ្ជា

ក្រៅម៉ោងធ្វើការឱ្យចូលរួម ក្នុងសិក្ខាសាលាធ្វើទស្សនកិច្ចសិក្សា និង រៀនសូត្រជំនាញរយៈពេលខ្លីវែង នៅក្នុងនិងក្រៅប្រទេស។

ជាសេចក្តីសន្និដ្ឋាន ការបណ្តុះបណ្តាលធនធានមនុស្សគឺជាគន្លឹះ សំរាប់ការពង្រឹងស្ថាប័ន ឬ អង្គការមួយឱ្យរឹងមាំ និងមានចេរភាព។ ជាពិសេស ចំពោះសង្គមស៊ីវិល ទាំងមូលត្រូវតែបន្ថែមចំណុចពិសេស មួយចំនួនទៀត គឺការផ្លាស់ប្តូរបទពិសោធន៍ និងការប្តូររួមគ្នាដោយ ទស្សនៈបើកទូលាយ និងដោយអារម្មណ៍អព្យាក្រឹត និងយុត្តិធម៌រវាង គ្នានិងគ្នាថែមទៀតទើបប្រសើរ៕

## ៦.៣_សុន្ទរកថាថ្លែងដោយអ្នកស្រី ធីតា ឃីះ នាយិកា អង្គការសីលការស្តីអំពី"ការអភិវឌ្ឍន៍ធនធានមនុស្សនិងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា : បទពិសោធន៍ខ្មែរ"

តាងនាមឱ្យអង្គការសីលការ ខ្ញុំសូមអរគុណដល់ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពដែលផ្តល់កិត្តិយសដល់ខ្ញុំនៅពេលនេះ។ នៅក្នុងបទអន្តរាគមន៍របស់ខ្ញុំនៅពេលនេះ ខ្ញុំសូមលើកមកនូវចំនុចបីមកជំរាបជូនដូចតទៅនេះ ៖

១_ ការណែនាំឱ្យស្គាល់អង្គការសីលការ និងសេវាដែលអង្គការសីលការបានធ្វើ។

២_ ការវាយតម្លៃលើស្ថានភាពអង្គការ NGOs ជាទូទៅនៅកម្ពុជា។

៣_ ការសន្និដ្ឋាន និងអនុសាសន៍ខ្លះក្នុងពេលអនាគត។

### ១_ការណែនាំឲ្យស្គាល់អង្គការសីលការនិងសេវាដែលអង្គការសីលការបានធ្វើ

អង្គការសីលការ បានចាប់កំណើតមកតាំងពីចុងបញ្ចប់នៃគំរោងកម្មវិធី CANDO នៅបំណាច់ឆ្នាំ១៩៩៦។ គំរោងកម្មវិធី CANDO បានធ្វើខ្មែរូបនីយកម្មមកជាអង្គការកសាងសមត្ថភាពក្នុងស្រុក ដែលយកចិត្តទុកដាក់ជាសំខាន់ទៅលើការហ្វឹកហ្វឺន និងបង្កើនសមត្ថភាព។ សីលការ បានក្លាយមកជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ក្នុងស្រុកនៅ

ខែមករា ឆ្នាំ ១៩៩៧។ ការិយាល័យរបស់សីលការ គឺនៅទីក្រុងភ្នំពេញ ដែលមានសកម្មភាពបង្កើនសមត្ថភាពអង្គការ និងស្ថាប័នក្នុងស្រុកជាបន្តបន្ទាប់ និងនៅតាមខេត្តនានាផងដែរ។

ក_យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ធនធានមនុស្សរបស់អង្គការសីលការ

ឧស្សនវិស័យ :

- ប្រជាជនកម្ពុជា ប្រឹងប្រែងសំរេចបាននូវសន្តិភាព សេរីភាព ពោរពេញទៅដោយទឹកចិត្តមេត្តា ដើម្បីរុញច្រានឱ្យមានការផ្លាស់ប្តូរសង្គមជាវិជ្ជមាននឹងធ្វើឱ្យកាន់តែប្រសើរឡើង នូវសេចក្តីត្រូវការរួមនៃសង្គមកម្ពុជា។
- សង្គមកម្ពុជាដែលប្រកបដោយភាពបើកចំហ ការសិក្សាជឿនលឿនសិទ្ធិមនុស្ស និងភាពរីកដុះដាលដោយការបង្កបង្កើនផល។
- ស្ថាប័ននៅក្នុងប្រទេសកម្ពុជារឹងមាំ និងសកម្មភាពក្នុងការ ការពារនិងបំរើឱ្យផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋរួម (ដោយមិនប្រកាន់លើភេទ ពូជសាសន៍ អាយុ សញ្ជាតិ សាសនា និងពិការភាព) ដល់បរិស្ថានតំបន់ និងពិភពលោក។

គោលបំណង

អង្គការសីលការមានគោលបំណងរួមចំណែក ក្នុងការអប់រំនិងជំរុញលើកទឹកចិត្តបុគ្គល ក្នុងការប្រើប្រាស់ សក្តានុពលភាពរបស់គេផ្ទាល់ក្នុងការអភិវឌ្ឍន៍អង្គការឬស្ថាប័នរបស់គេ។

បេសកកម្ម

បេសកកម្មចំបងរបស់សីលការគឺស្ថាបនាកសាងនិងពង្រឹងសមត្ថភាព បុគ្គលិក មន្ត្រីរាជការ ស្ថាប័នសាធារណៈតាមរយៈ ៖

- ការយកចិត្តទុកដាក់ទៅនឹងកង្វះខាត និងសេចក្ដីត្រូវការរបស់គេ។
- ផ្ដល់នូវការហ្វឹកហ្វឺនដ៏ប្រសើរ។
- ផ្គត់ផ្គង់បណ្ដាញការងារ និងកិច្ចសហប្រត្តិបត្តិការ ជាមួយអង្គការដ៏ទៃ។ ចែករំលែកបទពិសោធន៍ដែលសីលការ ទទួលបានដើម្បីចូលរួមផ្លាស់ប្ដូរ និងជួយឱ្យមានការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

*យោងតាមទស្សនៈវិស័យ និងបេសកកម្មរបស់សីលការខាងលើសីលការមានកម្មវិធី៤ដូចតទៅនេះ ៖*

១. វគ្គហ្វឹកហ្វឺន :

- វគ្គនៅទីស្នាក់ការនៅភ្នំពេញនិងនៅតាមខេត្ត
- ការរៀបចំវគ្គពិសេសៗ
- ការពិគ្រោះយោបល់
- ទៅលើការកសាងអង្គការ ការប៉ាន់ប្រមាណសមត្ថភាពគ្រប់គ្រងនិងផែនការ
- ការវាយតម្លៃទៅលើសេចក្ដីត្រូវការហ្វឹកហ្វឺន
- ការតាមដាននិងការវាយតម្លៃ

៣. ការកសាងសាមគ្គីភាព :

- សកម្មភាពសន្តិភាពនិងអហិង្សា
- ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី
- ការបង្កើនសមត្ថភាព

៤. ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ :

- ការរៀបចំកែលំអកម្មវិធីសិក្សា និងវិធីសាស្ត្រថ្មីៗឱ្យត្រូវទៅនឹងសេចក្តីត្រូវការតាមការជាក់ស្តែង។

អង្គការសីលការបានសង្កត់ធ្ងន់ទៅលើជំនាញរដ្ឋបាល អភិបាលកិច្ចល្អ និងការគ្រប់គ្រងជាជំនាញចំបងក្នុងការពង្រឹងស្ថាប័នសាធារណៈ ទាំងអង្គការមិនមែនរដ្ឋាភិបាលនិងតាម ក្រសួងមន្ទីររបស់រាជរដ្ឋាភិបាលផងដែរ។ យើងជឿថាជំនាញទាំងអស់នេះ ជាជំនាញចាំបាច់ដើម្បីសំរេចនូវតម្លាភាព និងការទទួលខុសត្រូវចំពោះអ្នកដែលទទួលផលពីស្ថាប័នផង និងចំពោះអ្នកដែលជួយគាំទ្រឧបត្ថម្ភផង។

តើអភិបាលកិច្ច រដ្ឋបាលនិងការគ្រប់គ្រងមានអ្វីខ្លះ? ប្រធានបទ និងជំនាញដែលយើងបង្រៀនមាន ៖

- <u>វគ្គគ្រប់គ្រង</u> : គឺជាវគ្គដែលផ្តោតទៅលើ បែបផែនគំរូផ្សេងៗនៃការគ្រប់គ្រង តួនាទីនិងភារកិច្ច និងជំនាញបបំមរបស់អ្នកគ្រប់គ្រង និងអ្នកដឹកនាំ ក្នុងការធ្វើឱ្យសំរេចនូវការងាររបស់អង្គការតាមរយៈបុគ្គលិកឬអ្នកដែលដើរតាមខ្លួន។

- វគ្គការងារការិយាល័យ: គឺជាអ្នកដែលពង្រឹងតួនាទីអ្នកដែលទទួលភ្ញៀវនិងជាតំណាងស្ថាប័នមុនគេបង្អស់ នៅពេលដែលភ្ញៀវមកដល់ការិយាល័យឬហៅទូរស័ព្ទមក។ គេក៏ជាអ្នកទទួលនូវតួនាទីក្នុងការអនុវត្តគោលនយោបាយរបស់អង្គការស្ថាប័ន។
- វគ្គស្វ័យគ្រប់គ្រង: ជាវគ្គសំរាប់ពង្រឹងអ្នកគ្រប់គ្រងនិងដឹកនាំដោយសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងពេលវេលា និងការសំរេចចិត្តក្នុងតួនាទីរបស់ខ្លួន។
- វគ្គស្វ័យគ្រប់គ្រង និងការអភិវឌ្ឍន៍បុគ្គលិក: រៀបចំអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្រ្ត ជាមួយគ្នា និងការរៀបចំផែនការបុគ្គលិកនិងការគ្រប់គ្រងបុគ្គលិកផងដែរ។
- វគ្គមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ : សំរាប់អ្នកគ្រប់គ្រងដឹកនាំ និងគណនេយ្យករ ក្នុងការគ្រប់គ្រងចាត់ចែងថវិកានិងធនធានរបស់អង្គភាពដែលប្រកបទៅដោយគណនេយ្យភាព និងតម្លាភាព។
- វគ្គទំនាក់ទំនងដើម្បីកសាងក្រុម: ពង្រីកជំនាញអ្នកដឹកនាំ និងអ្នកអភិវឌ្ឍន៍ ក្នុងការកសាង និងថែទាំតាមរយៈជំនាញទំនាក់ទំនងដោយពាក្យសំដី ការដោះស្រាយទំនាស់ក្នុងក្រុមការជំនះនូវឧបសគ្គក្នុងការទំនាក់ទំនង ។ល។
- វគ្គរបាយការណ៍ហិរញ្ញវត្ថុ : ជាជំនាញបន្ថែមទៅលើការរៀបចំបញ្ជីស្នាមកត់ត្រា។

- សរុបបញ្ជីចំណូលចំណាយ ដើម្បីធ្វើរបាយការណ៍ឱ្យទៅតាមគំរោងថវិកា។
- វគ្គរៀបចំគំរោងសំណើ : ជាវគ្គពង្រឹងការរៀបចំកម្មវិធីការរកការឧបត្ថម្ភ និងការរៀបរៀងជាសំណើ។

យើងមិនបានធ្វើនូវគ្រប់ប្រធានបទនោះទេ តែយើងក៏អាចធ្វើតម្រូវទៅតាមសេចក្ដីត្រូវការរបស់ស្ថាប័ននីមួយៗដែរ។ ដូចជាការពង្រឹងតួនាទី និងជំនាញរបស់អ្នកសំរបសំរួលសហគមន៍អ្នកប្រើប្រាស់ទឹកនៅក្នុងខេត្ត៦ របស់កម្មវិធីអង្គការប្រាសាក់ ការរៀបចំផែនការ៥ឆ្នាំ របស់ក្រសួងកិច្ចការនារី ការរៀបចំកម្មវិធីដើម្បីពង្រឹងគណៈកម្មការអភិវឌ្ឍន៍ខេត្ត៦ នៅក្រោមកម្មវិធីការពង្រឹងតួនាទីគ្រប់គ្រង របស់គណៈកម្មការនាយកមន្ទីរសុខាភិបាលស្រុក នៅឧត្ដង្គ កំពង់ព្រះ និងស្វាយចេក។ ការវាយតម្លៃសេចក្ដីត្រូវការ ការបង្កើនសមត្ថភាពគណៈកម្មការអភិវឌ្ឍន៍ខេត្តបាត់ដំបង។ល។ ហើយក្នុងពេលបច្ចុប្បន្ននេះ យើងក៏ចូលរួមក្នុងការវាយតម្លៃសកម្មភាព និងផលប៉ះពាល់នៃអង្គការ៨ ក្នុងវិស័យសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

ដូច្នេះយើងបានខិតខំសុំការគាំទ្រ ដើម្បីផ្ដល់ឱកាសឱ្យអង្គការខ្មែរចូលរួមក្នុងវគ្គយើងផង។ ក្នុងរយៈពេលកន្លងមក យើងមានអាហារូបករណ៍ផ្ដល់ឱ្យអង្គការខ្មែរយើងបានចូលរៀន។ យើងក៏កំពុងរកអ្នកគាំទ្រ ដើម្បីដំណើរការកម្មវិធីមួយទៀត ក្នុងគោលបំណងពង្រឹង

សមត្ថភាពគ្រប់គ្រង និងការរៀបចំកម្មវិធីដល់អង្គការខ្មែរចំនួន២៥នាក់ទៀត ក្នុងខេត្តកំពង់ធំនិងខេត្តបន្ទាយមានជ័យ។

យើងបានផ្តល់អាហារូបករណ៍ ដល់និស្សិតស្រីចំនួន ១១នាក់ ដើម្បីឱ្យនាងៗ អាចបន្តការសិក្សានៅតាមមហាវិទ្យាល័យ។

**សមិទ្ធផលដែលយើងធ្វើបានកន្លងមកមានដូចជា :**

**ស្ថាប័នដែលបញ្ជូនបុគ្គលិកមករៀនជាមួយអង្គការសីលការ**[១]

| ប្រភេទស្ថាប័ន | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០០ | សរុប |
|---|---|---|---|---|---|
| រដ្ឋាភិបាល | ១០ | ១០ | ២៥ | ៤ | ៤៩ |
| អង្គការក្នុងស្រុក | ២៣ | ៤៤ | ៧៤ | ២២ | ១៦៣ |
| អង្គការអន្តរជាតិ | ៤១ | ៣៣ | ៥៣ | ១៩ | ១៤៦ |
| ផ្សេងៗ | ២ | ២ | ១១ | ១ | ១៦ |
| សរុប | ៧៦ | ៨៩ | ១៦៣ | ៤៦ | ៣៧៤ |

**ចំនួនសិស្សដែលបានទទួលការហ្វឹកហ្វឺនពីអង្គការសីលការ**[២]

| ប្រភេទស្ថាប័ន | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០០ | សរុប |
|---|---|---|---|---|---|
| រដ្ឋាភិបាល | ១០៥ | ១៧១ | ១៧២ | ៣០ | ៤៧៨ |

(1) *គិតមកដល់ខែឧសភា ឆ្នាំ ២០០០*

(2) *ដូចខាងលើក*

| | | | | | |
|---|---|---|---|---|---|
| អង្គការក្នុងស្រុក | ៥១ | ១៨១ | ១៥៨ | ៥៣ | ៤៤៣ |
| អង្គការអន្តរជាតិ | ៤៤៧ | ១៨៧ | ១៦១ | ៤៨ | ៨៤៣ |
| ផ្សេងៗ | ២ | ២ | ១១ | ១ | ១៦ |
| សរុប | ៦០៥ | ៥៨១ | ៥០២ | ១៣២ | ១៧៨០ |

ក្នុងវិស័យកសាងសាមគ្គីភាពរវាងអង្គការដ៏ទៃទៀត យើងបានរៀបចំ និងបានចូលរួមក្នុងការងារផ្នែកសន្តិភាព និងអហិង្សាតាំងពីឆ្នាំ១៩៩៧ មកដោយមានសកម្មភាព វេទិកាផ្សាយមេត្តាធម៌ធ្វើសកម្មភាពអប់រំខាងផ្នែកសតិអារម្មណ៍ និងសីលធម៌ និងធ្វើការជាមួយព្រះសង្ឃអង្គការជាតិ និងអន្តរជាតិ។ យើងក៏បានរៀបចំសកម្មភាពដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រី ក្នុងការសំរេចចិត្តដោយកោះហៅប្រជុំ និងរុញច្រានការងារនេះ ឱ្យមានការយកចិត្តទុកដាក់ពីសំណាក់អង្គការនិងគណបក្សនយោបាយនានាផងដែរ។ យើងមានការរួមគ្នាក្នុងនយោបាយសាមគ្គី ១ ខែម្តង រវាងស្ត្រីដែលធ្វើការក្នុងអង្គការអភិវឌ្ឍន៍ដើម្បីប្តូរពត៌មាននិង គាំទ្រគ្នាទៅវិញទៅមក។ យើងបានចូលរួមក្នុងការបើកវេទិកាដើម្បីពិគ្រោះយោបល់រវាង stakeholders ផ្សេងៗផង ដើម្បីរិះរកមធ្យោបាយបង្កើនសមត្ថភាពអង្គការក្រៅរដ្ឋាភិបាលខ្មែរ។

យើងសួរទៀតថា តើលទ្ធផលដែលយើងធ្វើបានត្រឹមណា? យើងអាច ឆ្លើយតាមដែលខ្ញុំបានរៀបរាប់ខាងលើ តែខ្ញុំសូមលើកមកនូវ

លទ្ធផលដ៏ទៃទៀត មកជំរាបជូនថាក្នុងចំនួនអ្នកដែលមករៀន ជាមួយយើងគេអាចអនុវត្តការងារគេបាន ៧៥% បើតាមស្ថិតិ ដែលយើងមានដោយការចុះតាមដានកន្លងមក។ តែនៅមានកត្តាច្រើនទៀតដែលនឹងធ្វើឱ្យកត្តាកសាងសមត្ថភាព ស្ថាប័នទទួលបានន្ធូវជោគជ័យពេញលេញនោះ។ គេត្រូវការធ្វើច្រើនជាងការបញ្ជូនបុគ្គលិកទៅរៀនសូត្រ។ គេត្រូវមានសុឆន្ទៈផ្លាស់ប្តូរ ។

អ្នកមករៀនជាមួយយើងទាំងនោះ គេមានការពិសោធន៍ទៅលើការអនុវត្តផ្ទាល់របស់គេ ហើយគេបានយកចំណេះដឹងទាំងទ្រឹស្តីទាំងការពិសោធន៍ទាំងគ្រួសារផង និងពីអ្នកដឹកនាំអង្គភាពដទៃទៀតផង គេអាចដឹកនាំមានប្រសិទ្ធភាព។ គេអាចនិយាយដោយមានទ្រឹស្តីបញ្ជាក់ផង ហើយគេមានការងាយស្រួលក្នុងការទំនាក់ទំនង និងរកវិធីសាស្ត្រដោះស្រាយបញ្ហា ក្នុងការប្រតិបត្តិរបស់គេផង។ ឧទាហរណ៍ដូចជាៈ យើងណែនាំឱ្យគេ រៀបចំរចនាសម្ព័ន្ធឱ្យមានតុល្យភាព និងតម្លាភាពដោយមានគោលនយោបាយសំរាប់អង្គការគេផង ។ល។

## ២_ការវិភាគទៅលើស្ថានការណ៍ទូទៅលើសង្គមស៊ីវិលនៅកម្ពុជា

ដោយប្រធានបទរបស់យើង ក្នុងពេលនេះ សំដៅទៅលើការកសាងធនធានមនុស្សនៅក្នុងសង្គមស៊ីវិល។ យើងសូមលើកយកផ្នែកនេះមកលំអិតបន្ថែមទៀត សង្គមស៊ីវិលនៅកម្ពុជា នៅពេលនេះមានច្រើនតែសមាគមក្រៅរដ្ឋាភិបាល។ នៅពេលនេះ មានអង្គការដទៃទៀតដែរដូចជាសហជីពគណបក្សនយោបាយ អង្គការមហាជន អង្គការ

អភិវឌ្ឍន៍ភូមិ ឃុំដែរ ដែលយើងមិនទាន់រាប់បញ្ចូលផងទេ។ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា មកទល់ពេលនេះបានរីកស្គុះស្គាយយ៉ាងខ្លាំងពីចំនួន១២ នៅឆ្នាំ ១៩៩៣ មកដល់ចំនួន ៥៩៥[៣] នៅក្នុងបញ្ជីក្រសួងមហាផ្ទៃដោយមិនរាប់បញ្ចូលទាំងចំនួនដែលមិនចុះឈ្មោះជាមួយក្រសួងដទៃ និងទីស្តីការគណៈរដ្ឋមន្ត្រី។ ចំនួនអង្គការមិនមែនរដ្ឋាភិបាលអន្តជាតិ[៤] មានចំនួន១៧២ បើប្រៀបធៀបទៅឆ្នាំ ១៩៩២ ដែលមានចំនួនតែ៥៦ប៉ុណ្ណោះ។ ក្នុងចំណោមអង្គការទាំងនេះអង្គការមានថវិកាសំរាប់កម្មវិធីចំនួន៩០% នៃចំនួនថវិកាសរុបដែលអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ (៨០.៩៧២.០០០.០០ USD) បានទទួលក្នុងឆ្នាំ២០០០។ ដូច្នេះមានន័យថា សមត្ថភាពរបស់អង្គការខ្មែរនៅមានកំរិតទាបដែលគួរឱ្យកត់សំគាល់។ យើងសង្កេតឃើញថាអង្គការខ្មែរដែលមានភាពរឹងមាំ និងមានសកម្មភាពនៅមានចំនួនតិចបើប្រៀបធៀបទៅ នឹងចំនួនដែលបានចុះឈ្មោះជាផ្លូវការនោះ។ កត្តាដែលជាឧបសគ្គ ក្នុងការរីកចំរើននេះមានច្រើន តែយើងសូមលើកមកជាអាទិ៍មាន ៖

- សង្គមអង្គការសមាគមខ្មែរ នៅមានភាពក្មេងខ្ចីក្នុងតួនាទីបច្ចុប្បន្ននេះ។ យើងទើបតែមានអាយុមិនទាន់បាន១០ឆ្នាំផង។ យើងពុំទាន់

---

(3) 199 Country Study: Non Organization in Cambodian by Thida Khus, SILAKA,

(4) 2000 NGO Statement to the 2000 Consultative Group Meeting on Cambodia by MEDICAM, NGO Forum, and CCC.

មានគំរូត្រឹមត្រូវក្នុងការប្រតិបត្តិផ្សេងៗ ឯធនធានមនុស្សក៏នៅមានកំរិតដែលបណ្ដាលឱ្យមានផលលំបាកដូចមានចែងខាងក្រោម ៖

→ អ្នកដឹកនាំអង្គការខ្មែរ ដែលឈានមុខគេនៅមានចំនួនតិចតួចពេក។ បន្ថែមទៅលើនោះទៀត ក្នុងចំណោមអ្នកទាំងនោះមានចំនួនតិចណាស់ ដែលមានលទ្ធភាព ឬមានគោលការណ៍ឈោងជួយអ្នកដទៃនៅក្នុងចំណោម NGOs គ្នាឯង។ ធ្វើឱ្យសង្គមស៊ីវិលនៅមិនទាន់រឹងមាំនិងមិនទាន់មានទស្សនៈរួមគ្នាក្នុងការកសាងសង្គមជាតិខ្មែរធ្វើឱ្យដំណើរការ នៅមានការរាំងស្ទះនិងមិនទាន់ស្រុះគ្នា គេច្រើនតែធ្វើការងាររៀងៗខ្លួននៅឡើយ។ ហើយក្នុងចំណោមនោះទៀត ភាគច្រើននៅអនុវត្តប្រព័ន្ធអូតូក្រាតិច (អនុវត្តតាមបញ្ជាពីលើនៅឡើយ)។

→ គណបក្សនយោបាយ មិនសូវគោរពបូរណភាពរបស់អង្គការសមាគម ហើយតែងតែយកអង្គការធ្វើជាឈ្នាន់ ដើម្បីគោលបំណងខ្លួន ដោយធ្វើឱ្យខាតបង់ប្រយោជន៍រួមច្រើន ក្នុងពេលអនាគត។ យើងពុំទាន់មានច្បាប់សមស្របណាមួយ ដើម្បីអនុវត្តន៍តួនាទីយើងនៅឡើយទេ។

→ រដ្ឋាភិបាល មិនទាន់យល់ពេញលេញពីតួនាទីអង្គការសមាគមនៅឡើយ នៅក្នុងសង្គមលទ្ធិប្រជាធិបតេយ្យមួយ។ គាត់ពុំសូវទទួលស្គាល់និងលើកទឹកចិត្តអង្គការសមាគមនៅឡើយទេ។

→ ម្ចាស់អំណោយមានគោលការណ៍មិនដូចគ្នា ក្នុងការជួយគាំទ្រអង្គការខ្មែរ ដែលបណ្តាលឱ្យមាន ការទំនាក់ទំនងរវាងម្ចាស់អំណោយនិងអង្គការខ្មែរមានការលំបាកក្នុងការយល់គ្នា ដើម្បីឱ្យទៅជាដៃគូរ អភិវឌ្ឍន៍ដ៏ល្អ។ ម្ចាស់អំណោយតែងតែយល់ថាអង្គការខ្មែរ ធ្វើតែទៅតាមម្ចាស់អំណោយ តែមិនទៅតាមឧត្តមគតិខ្លួនទេ។ ផលប៉ះពាល់ទៅលើអង្គការខ្មែរឃើញថា យើងធ្វើការមិនសូវសហការគ្នា ច្រើនតែធ្វើរៀងៗខ្លួន ដោយមើលរូបភាពមិនឃើញ។

→ សមត្ថភាពចាត់ចែងអភិបាលកិច្ច គោលការណ៍និងការអនុវត្តន៍តាមក្រមសីលធម៌ជា NGOs នៅមានកំរិតនៅក្នុងចំណោមអង្គការខ្មែរ។ ខ្វះវិធានការណ៍ពង្រឹងវិន័យ នៅក្នុងវិស័យនេះដោយខ្លួនឯង នាំឱ្យមានការអាប់អោនកិត្តិយស និងភាពសក្តិសិទ្ធិរបស់អង្គការខ្មែរ។

→ ម្ចាស់អំណោយដែលផ្តល់ការឧបត្ថម្ភអង្គការខ្មែរ នោះជួយក្នុងរយៈពេលតិចពេក បង្កឱ្យមានការលំបាកក្នុងការពង្រឹងស្ថាប័ន និងផែនការរយៈពេលវែងបណ្តាលឱ្យអង្គការខ្មែរ ពុំមានភាពរឹងមាំ និងផុយស្រួយបាក់បែកផ្ទៃក្នុង។ អង្គការអន្តរជាតិពុំមានទស្សនៈ និងយុទ្ធសាស្ត្រសមស្របដើម្បីដកខ្លួនថយ និងផ្តល់អំណាចដល់ NGOs ខ្មែរ ធ្វើឱ្យមានការរាំងស្ទះដល់កម្លាំង

សង្គមស៊ីវិលខ្មែរ និងពន្យាពេលឱ្យកាន់តែវែងអន្លាយក្នុងភាពជាម្ចាស់ការរបស់អង្គការខ្មែរ។

→ អង្គការអន្តរជាតិ និងម្ចាស់អំណោយពុំសូវយល់ពីសង្គមខ្មែរធ្វើឱ្យការអនុវត្តន៍របស់ខ្លួនមិនមានប្រសិទ្ធភាព ក្នុងការពង្រឹងអង្គការខ្មែរ។

## ៣_សេចក្តីសន្និដ្ឋានទៅលើបញ្ហាពង្រឹងអង្គការខ្មែរ_សង្គមស៊ីវិល

សង្គមស៊ីវិលនៅកម្ពុជា ទោះបីមានការរីកចំរើនច្រើនក៏ដោយ ក៏ចាំបាច់ត្រូវការវិធានការរួមមួយ ក្នុងការកសាងស្ថាប័ននេះឱ្យរឹងមាំ ដើម្បីបំពេញតួនាទីរបស់គេនៅក្នុងសង្គម។ សក្តានុពលរបស់គេក្នុងតួនាទីជាអ្នកឃ្លាំមើលការអនុវត្តន៍ ការបង្កលក្ខណៈដើម្បីឱ្យប្រជាពលរដ្ឋមានសិទ្ធិអំណាចក្នុងការងារផលប្រយោជន៍របស់គេ។ វិធានការណា ក៏ដោយ ក៏ត្រូវការសហការពីគ្រប់ស្ថាប័ន ដើម្បីធ្វើឱ្យសំរេចនូវជោគជ័យ។ ក្នុងនាមអង្គការសីលការ យើងបានយកវិធានការមួយចំនួនដើម្បីពង្រឹងនូវស្ថាប័ននេះ តែយើងពុំអាចធ្វើតែម្នាក់ឯងបានដែរ។ យើងពេញចិត្តសហការជាមួយសមាគមដទៃ ក្នុងគោលបំណងរួម។ យើងស្នើសុំឱ្យអង្គការដែលជារៀមច្បង ក្នុងសង្គមស៊ីវិលខ្មែរទទួលគិតនូវការចូលរួមកសាងទស្សនវិស័យរួមមួយ នៅក្នុងចំណោមសង្គមស៊ីវិលខ្មែរ យើងនិងស្នើរសុំឱ្យគេពិចារណាទៅលើការចាត់វិធានការរួមមួយដើម្បីជួយលើកស្ទួយអង្គការសមាគមខ្មែរ ដើម្បីទាមទារឱ្យគោលនយោបាយ

រាជរដ្ឋាភិបាល និងម្ចាស់អំណោយមានការផ្លាស់ប្ដូរ ក្នុងការជួយកសាងសមត្ថភាពអង្គការសមាគមយើងឱ្យមានភាពរឹងមាំ ដើម្បីគេអាចទទួលយកនូវភារៈកិច្ចនិងអាចបំពេញនូវកាតព្វកិច្ចគេ ដើម្បីជាផលប្រយោជន៍រួមដល់ប្រជាពលរដ្ឋទូទៅនៅក្នុងសង្គមកម្ពុជាយើង៕

## ៦.៤_សុន្ទរកថាថ្លែងដោយលោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា : "ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា"

### I_ និយមន័យ :

សង្គមស៊ីវិល (Civil Society): សមាគមវិជ្ជាជីវៈ អង្គការសហគមន៍ អង្គការពុំមែនរដ្ឋាភិបាល ក្រុមសាសនា ក្រុមស្រ្តី ប្រព័ន្ធផ្សព្វផ្សាយ។

សកលភាវូបនីយកម្ម : សកលភាវូបនីយកម្ម មានអត្ថន័យខុសៗគ្នាទៅតាមការយល់ឃើញរបស់មនុស្សខុសៗគ្នា។ ក្នុងចំណោមអ្នកទាំងនោះ យើងអាចប្រមូលផ្តុំបានអត្ថន័យខ្លះដូចតទៅនេះ៖

(១)_ សកលភាវូបនីយកម្ម គឺជារបៀបរបបឬសណ្តាប់ធ្នាប់នយោបាយរបស់ពិភពលោកថ្មីមួយ ដែលប្រជាជាតិទាំងឡាយចូលរួមជាមួយគ្នាក្នុងអង្គការពិភពលោក ឬក្នុងតំបន់ដើម្បីការពារនិង/ឬ ដោះស្រាយទំនាស់រវាងសមាជិកទាំងឡាយ។

(២)_ សកលភាវូបនីយកម្ម គឺជាភូមិសកលមួយ ដែលពិភពលោកទាំងមូលចាត់ទុកថា ជាសហគមន៍តែមួយដែលនាំមករួមគ្នានូវបច្ចេកវិជ្ជាជាន់ខ្ពស់ និងគមនាគមន៍អន្តរជាតិរួមគ្នា។

(៣)_ សកលភាវូបនីយកម្ម គឺជាសណ្តាប់ធ្នាប់សកលមួយ ដែលការធ្វើអាជីវកម្ម ធនធានមនុស្សនិងធម្មជាតិរយៈពេលខ្លី ធ្វើឱ្យខាតបង់ផលកម្រៃ និងចីរភាព និងដែលនាំឱ្យប្រជាជាតិ សហគមន៍និងបុគ្គលបាត់បង់នូវការផ្តល់អំណាចរបស់ខ្លួន។

## II_ និន្នាការនៃសកលភាវូបនីយកម្មនៅកម្ពុជា :

បន្ទាប់ពីភាពឯកោអស់រយៈពេលពីរទសវត្សរ៍ ការមកដល់ក្នុងឆ្នាំ ១៩៩២ នូវបុគ្គលិកអង្គការសហប្រជាជាតិជាង ២៣០០០នាក់ និងវប្បធម៌របស់គេពីគ្រប់ផ្នែកនៃពិភពលោក បាននាំមកឱ្យប្រទេសកម្ពុជានូវបទពិសោធន៍ល្អផង អាក្រក់ផង និងតក្រិចផង។

ជាការពិតណាស់ ដែលថាប្រទេសកម្ពុជាបច្ចុប្បន្ននេះ បានបង្ហាញនូវសញ្ញាអភិវឌ្ឍន៍ជាវិជ្ជមាន។ ការផ្លាស់ប្តូរជាគន្លឹះ នៅក្នុងបរិបទនៃនយោបាយសង្គម បានរួមបញ្ចូលនូវចលនាកម្មកររោងចក្របាតុកម្មដោយសន្តិវិធីរបស់កសិករ ដែលឈរនៅមុខរដ្ឋសភា (បច្ចុប្បន្ននៅជិតនាវ៉ា កាស៊ីណូណាហ្គា) ប្រឆាំងនឹងការលួចយកដីធ្លីដោយកងកម្លាំងប្រដាប់អាវុធ ការរីកកើនឡើងនៃចំនួនប្រព័ន្ធពត៌មាន និងសារពត៌មាន ការកើនឡើងនូវសេរីភាពក្នុងការបញ្ចេញមតិ (ជាពិសេសនៅទីក្រុង) ជំហររឹងមាំនៃគណបក្សប្រឆាំង និងសម្លេងដ៏សំខាន់របស់គេនៅក្នុងសភាជាតិ។ នៅទីបញ្ចប់តែក៏សំខាន់ណាស់ដែរ ស្ត្រីក៏កំពុងរៀបចំខ្លួន និងកំពុងខិតខំប្រយុទ្ធតស៊ូ ដើម្បីឱ្យសម្លេងរបស់គេកាន់តែឮខ្លាំងឡើង ទាំងក្នុងសង្គម និងក្នុងនយោបាយ។

សូមអរគុណចំពោះជំនួយអន្តរជាតិ ដែលបានជួយឧបត្ថម្ភគាំទ្រឱ្យអង្គការក្រៅរដ្ឋាភិបាល បានរីកដុះដាលធំឡើង និងកំពុងរួមផ្សាឡើងបានជាកម្លាំងមួយ នៅក្នុងការអភិវឌ្ឍន៍នៃប្រទេសជាតិ ក្នុងវិសាលគមនៃសកម្មភាពដ៏ពេញលេញមួយ។

វិស័យសាសនានិងវប្បធម៌ បច្ចុប្បន្ននេះកំពុងឆ្លុះបញ្ចាំងឱ្យឃើញនូវគតិបណ្ឌិត ដែលសម្តែងចេញ ដោយវោហាសាស្ត្ររបស់ព្រះសង្ឃទេសនា និងការចូលរួមក្នុងធម្មយាត្រារបស់មហាជន និងការកើនឡើងនៃចំនួនអង្គការ ដែលមានគោលដៅបំរើសន្តិភាព ដូចជាវេទិកាដើម្បីសន្តិភាព មជ្ឈមណ្ឌលធម្មយាត្រានិងអហិង្សាធម៌។ អង្គការទាំងនេះបានជះឥទ្ធិពល ជាវិជ្ជមានដល់ចិត្តគំនិតរបស់ប្រជាពលរដ្ឋកម្ពុជា។

បច្ចេកវិជ្ជាទំនើប ដូចជា កុំព្យូទ័រ ទូរស័ព្ទ ទូរទស្សន៍ តារាវណាប និង អ៊ិនធឺណែត បាននាំមកកម្ពុជានូវគំនិតថ្មី ពុទ្ធិ និងរបៀបឃើញ និងការអនុវត្តន៍ដែលកំពុងពង្រឹងនូវសមត្ថភាពនៃកម្លាំងធ្វើការងារឱ្យមានកិរិតអន្តរជាតិ។ ភាពកាន់តែមានឥទ្ធិពលនិងប្រជាប្រិយភាព នៃភាសាអង់គ្លេស និងម៉ាកអាមេរិកកាំង ដូចជា កូកាកូឡា និងខោខៅប៊ិយពណ៌ខៀវ គឺជាសញ្ញានៃការកើនឡើង នៃសកលភាវូបនីយកម្ម ក្នុងរបៀបរបបរស់នៅរបស់ជនជាតិខ្មែរ។

ការទទួលយកប្រទេសកម្ពុជា ឱ្យចូលក្នុងសមាគមនៃប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) និងដំណើរការបច្ចុប្បន្ននៃការបង្កើតគណៈកម្មការសិទ្ធិមនុស្សអាស៊ាន ឯករាជ្យមួយ នោះគឺជាការទទួលស្គាល់ថា

ប្រជាជាតិនីមួយៗ ត្រូវតែធ្វើសកម្មភាពរួមគ្នា ដើម្បីដោះស្រាយបញ្ហារួម ដែលរួមបញ្ចូលទាំងបញ្ហាមួយចំនួន ដូចជាការរំលោភសិទ្ធិមនុស្ស ដែលកន្លងមកគេចាត់ទុកថាបញ្ហានេះ គឺជាកិច្ចការផ្ទៃក្នុង។

## III_ បញ្ហាសង្គម :

ថ្វីបើមានការអភិវឌ្ឍន៍ជាវិជ្ជមាន ជាការពិត ប្រទេសជាតិនៅតែស្ថិតនៅក្នុងសភាពងាយនឹងគ្រោះថ្នាក់នៅឡើយ ប្រៀបបានទៅនឹងមនុស្ស ដែលទើបនឹងងើបពីឈឺ។ ដំណើរការនៃការចូលរួមនិងការអភិវឌ្ឍន៍មានទាំងវឌ្ឍនភាព និងការធ្លាក់ចុះ។ ដំណើរការជឿនលឿននិងធ្លាក់ចុះនេះ ស្ដែងចេញឱ្យឃើញនៅក្នុងរបៀបរៀបចំសង្គមដែលដាច់ដាចដោយសង្គ្រាមនៃប្រទេសកម្ពុជា និងដែលមានរបបផ្ដាច់ការបំផ្លិចបំផ្លាញខ្លួនឯង ដោយឥតសមហេតុផលបីទសវត្សរ៍កន្លងមក។ បញ្ហាធំៗនៃសង្គម ដែលភាគច្រើនជាលទ្ធផលនៃឥទ្ធិពលនៃសកលភាវូបនីយកម្មនៅប្រទេសកម្ពុជារួមមាន៖

### ១_ភាពក្រីក្រ :

ចាប់តាំងពីមានការផ្លាស់ប្ដូរសេដ្ឋកិច្ចបែបសង្គមនិយមមក សេដ្ឋកិច្ចទីផ្សារសេរី ប្រទេសកម្ពុជាបានរងគ្រោះដោយការបែងចែកគ្មានសមធម៌នូវធនធានសេដ្ឋកិច្ច និងកាលានុវត្តភាព (Opportunities)។ ការកើនឡើងនៃសេចក្ដីក្រីក្រ និងភាពគ្មានដីធ្លី បាននាំឱ្យប្រជាពលរដ្ឋជាច្រើនរត់ពីជនបទមកទីក្រុង ជាពិសេសគឺទីក្រុងភ្នំពេញ ដោយ

បានបង្កផលវិបាកដល់ហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យខូចដល់ជីវភាពរស់នៅនិងធ្វើការងាររបស់ប្រជាពលរដ្ឋ អ្នកទីក្រុងជាពិសេស។

ក្នុងពេលដែលប្រជាពលរដ្ឋកើនឡើង សំពាធនៃការលំបាកក្នុងការរកដីធ្លីរស់នៅក៏កើនឡើងដែរ។ អ្នកក្រីក្រមិនមានលទ្ធភាពទិញដីធ្លីដែលមានតម្លៃខ្ពស់។ ផលវិបាលនេះនាំឱ្យមានការរំលោភទន្ទ្រានយកដីធ្លីនិងការយកដីធ្លីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋម្ចាស់ដើមមកធ្វើជារបស់ខ្លួន។

**២. ជម្ងឺអេដស៍** (AIDS):

ការរីករាលដាលយ៉ាងខ្លាំងក្លា និងឆាប់រហ័ស (Virulent Spread) នៃជម្ងឺ ហ៊ីវ/អេដស៍ (HIV/AIDS) នៅប្រទេសកម្ពុជាគឺជាឥទ្ធិពលដោយចំពោះនៃសកម្មភាពសកលភាវូបនីយកម្មទាំងក្នុងបំលាស់លំនៅ(Migration)ទាំង ក្នុងនិងក្រៅប្រទេស(ទេសចរ) និងភាពគ្មានសមធម៌ ក្នុងការបែងចែកភោគទ្រព្យ។ ការរីករាលដាលនេះ ក៏ឆ្លុះបញ្ចាំងឱ្យឃើញ នូវភាពខ្វាយខ្វល់ជាសកលក្នុងការទប់ស្កាត់អំពើជួញដូរស្ត្រីនិងកុមារ។

ការសិក្សាស្រាវជ្រាវថ្មីៗនេះ បានប្រាប់ឱ្យដឹងថា មានស្ត្រីរកស៊ីផ្លូវភេទប្រមាណ១០.០០០នាក់។ គ្រាន់តែនៅទីក្រុងភ្នំពេញ ដែលជាក្រុងមួយ មានប្រជាពលរដ្ឋជាងមួយលាននាក់ប៉ុណ្ណោះ ត្រូវបានបង្ខំដោយសេចក្តីក្រីក្រឱ្យធ្លាក់ចូលនៅក្នុងពាណិជ្ជកម្មផ្លូវភេទ។ ស្ត្រីទាំងនោះរស់នៅនិងធ្វើការងារដោយគ្មានការការពារសិទ្ធិជាមូលដ្ឋានរបស់មនុស្ស

រួមទាំងការគ្មានម្ហូបអាហារ គ្មានជំរក គ្មានសេរីភាពដើរហើរ គ្មានសេរីភាពទទួលការអប់រំ និងការគាំពារសុខភាពផង។ ភេទទន់ខ្សោយ អាយុតិចនិងភាពគ្មានសេរីភាពខាងរូបកាយ សង្គម និងសេដ្ឋកិច្ច ទាំងអស់នេះមានន័យថា គេមានលទ្ធភាពការពារខ្លួនតិចតួចឬ ក៏គ្មានសោះក្នុងការប្រឆាំងនឹងភាពផ្សងព្រេង នៃការចម្លងមេរោគអេដស៍ ដ៏គ្រោះថ្នាក់ពីអតិថិជនរបស់គេ។ ការសិក្សាស្រាវជ្រាវថ្មីៗបំផុតនេះបានបង្ហាញថា ក្នុងមួយថ្ងៃៗមានមនុស្ស១០០នាក់ បានឆ្លងមេរោគអេដស៍ នៅប្រទេសកម្ពុជា។ សារពត៌មានកោះសន្តិភាព ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០០ និយាយថា មានអតិថិជន ២០,០០០នាក់ ដែលត្រូវការសេវាកម្មផ្លូវភេទ ដែលមានតម្លៃពីរដុល្លារអាមេរិក ($U ២,០០) ក្នុងមួយលើកៗ។

៣_កុមារនិងក្មេងទំនៀន :

កុមារកាន់តែច្រើនត្រូវបានបង្ខំឱ្យបូជានូវអនាគត ដើម្បីការងារសំរាប់ការរស់រានមានជីវិតរបស់គេ និងគ្រួសារគេ។ អង្គការការងារអន្តរជាតិ ប៉ាន់ស្មានថាមានកុមារខ្មែរចំនួន ៦០០,០០០នាក់ ដែលមានអាយុពី៥ឆ្នាំទៅ១៧ឆ្នាំ កំពុងធ្វើការងារនៅកសិដ្ឋាន សំណង់និងតាមផ្ទះសម្បែង (សេវាគ្រួសារ)។ ប្រាក់ថ្លៃឈ្នួលរបស់គេមានកំរិតទាបគួរឱ្យអាណិតស្វរ ហើយចំនួនប្រមាណ ៦០% នៃកុមារទាំងនោះបានបោះបង់សាលារៀនឬមិនបានរៀនសូត្រសោះឡើយ។ កុមារតូចៗនៅទីក្រុង ដើររកស៊ីតាមតំនរសំរាម ដើរសុំទានឬត្រូវគេបង្ខំឱ្យធ្លាក់ចូលទៅ

ក្នុងពាណិជ្ជកម្មផ្លូវភេទ។ ថ្នាំអំភេតាមីនធ្វើឱ្យគេស្ពឹកស្រពន់ និងរងគ្រោះដោយការអាប់ឱនបញ្ញាស្មារតី ដែលធ្វើឱ្យគេមិនអាចនឹងថែរក្សាខ្លួនគេបាន ក្នុងពេលដែលរកគេឃើញ នឹងនាំចូលមកមាតុភូមិកម្ពុជាវិញ។

៤_ភាពគ្មានដីធ្លី និងការបំផ្លាញបរិស្ថាន :

ប្រជាពលរដ្ឋខ្មែរ ដែលក្រីក្របំផុតនិងដែលងាយនឹងធ្វើឱ្យឈឺចាប់ជាងគេ កំពុងតែបាត់បង់ដីធ្លី និងរបរចិញ្ចឹមជីវិតរបស់គេ ព្រោះតែត្រូវបានបដិសេធមិនឱ្យចូលទៅក្នុងព្រៃ និងតំបន់ដីមានទឹក ដែលធ្លាប់តែជាធនធានរួម។ ដីធ្លីទាំងនេះត្រូវបានគំរាមយកដោយកម្លាំងរបស់កងទាហ៊ានឬអាជ្ញាធរពុករលួយឬក៏ត្រូវគេប្រគល់ឱ្យក្រុមហ៊ុនបរទេស ដើម្បីធ្វើអាជីវកម្ម ដោយគ្មានការពិចារណាដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋឬដល់ឥទ្ធិពល នៃបរិស្ថានមូលដ្ឋាន។ ភាពប្រេះស្រាំសង្គមយូរអង្វែង នៃប្រជាពលរដ្ឋមូលដ្ឋាន និងការបំផ្លិចបំផ្លាញនៃបរិស្ថានមូលដ្ឋាន គឺជាលទ្ធផលនៃអំពើនេះ។ ឥទ្ធិពលជាអវិជ្ជមាននៃសកលភាវូបនីយកម្ម ក្នុងពេលថ្មីនេះទៀត ត្រូវបានគេរកឃើញក្នុងជាតិពុលដែលបណ្តាលមកពីការប្រើប្រាស់មិនរើសមុខនៃថ្នាំសម្លាប់សត្វល្អិតដែលផលិតនៅបរទេស ដែលប្រជាពលរដ្ឋកម្ពុជាមិនអាចអានបាននូវផ្លាកណែនាំពីរបៀបប្រើប្រាស់។ សាជីវកម្មពហុជាតិ និងរបស់បណ្តាប្រទេសដទៃទៀត បានប្រើប្រាស់ប្រទេសកម្ពុជាធ្វើជាកន្លែងចាក់ចោលកាកសំណល់ផលិតរបស់គេ ដូចជាឱសថផុតកំណត់ប្រើប្រាស់ដែលគេ

មិនអាចលក់ដូរបាននៅប្រទេសគេ ព្រោះតែផលិតផលនោះខុសច្បាប់ឬក៏អ្នកប្រើប្រាស់មិនអាចទទួលយកបាន ក៏យកមកចោលនៅស្រុកខ្មែរ។

គ្មានប្រទេសជាតិណាមួយ ដែលក្នុងនោះមានប្រទេសកម្ពុជាដែរ ដែលអាចគេចផុតពីឥទ្ធិពលនៃសកលភាវូបនីយកម្មនៅលើបរិស្ថានពិភពលោកឡើយ។ ការបាត់បង់ជាសកលនូវជីវៈដោយឡែកៗ (Bio-diversity) ការធ្វើឱ្យហិនហោចនូវធនធានធម្មជាតិ និងការធ្វើឱ្យខូចខាតនូវប្រព័ន្ធគាំទ្រនូវជីវិតផ្កាយព្រះគ្រោះ (Planet's Life) ដូចជាមានសក្ខីភាពស្រាប់ ក្នុងការបំផ្លាញស្រទាប់ OZONE កំដៅរបស់ពិភពលោក ការបាត់បង់រុក្ខជាតិឬហ្វូងសត្វ និងលំនៅដ្ឋាន ការបំផ្លិចបំផ្លាញព្រៃឈើ និងការធ្វើឱ្យសមុទ្រឬផ្លូវទឹកខ្វក់......ទាំងអស់នេះ សុទ្ធតែជះឥទ្ធិពលកាន់តែខ្លាំងឡើងៗ ដល់ប្រទេសនិងប្រជាពលរដ្ឋកម្ពុជា ក្នុងថ្ងៃស្អែកនិងទៅអនាគត។ ប្រទេសកម្ពុជា បាននាំមកនៅការធ្វើឱ្យខូចដល់បរិស្ថានសាកល ដោយការអភិវឌ្ឍន៍គ្មានធនធានស្ថិតស្ថេរ ដែលក្នុងនោះមានរួមបញ្ចូលទាំងការប្រមូលផលហួសហេតុនៃព្រៃឈើ ការនេសាទ ការបរបាញ់និងការជួញដូរខុសច្បាប់ នូវពពួកសត្វទាំងឡាយដែលមានកំណើតនៅស្រុកខ្មែរនិងភាពកើនឡើងនៃការធ្វើឱ្យទឹកកខ្វក់។ សារពត៌មាន (Cambodia Daily) ចេញផ្សាយថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០០ អត្ថបទក្រោមចំណងជើងថា (Study Faults Human for Larges Share of Global Warming)........សិក្សាស្រាវជ្រាវរបស់ភូគព្ភវិទូ (Geologist) មួយរូបនៅ Texas A&M University បាន

ប្រាប់ឱ្យដឹងថា គឺមានតែកំដៅ ២៥% ប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ១៩០០ ដែលធ្វើឱ្យប៉ះពាល់ដល់អាកាសធាតុនៃផែនដី។ ចំណែកដ៏ធំសម្បើមនៃកំដៅអាចប៉ះពាល់ដល់មនុស្សលោក ពិសេសគឺដល់កំរិតកើនឡើងនៃការបោន ឌីយូស៊ីដ (Carbon Dioxide) នៃគ្រឿងប្រដាប់ចាប់កំដៅនៃអាគារកញ្ចក់សំរាប់ដាំដើមឈើនៅស្រុកត្រជាក់ ដែលបានមកពីការឆេះប្រេងឥន្ធនៈនិងព្រៃ។

៩_អំពើពុករលួយ :

នៅក្នុងការសិក្សាស្រាវជ្រាវ ស្ទាបស្ទង់មតិមួយ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម(CSD) កាលពីពីរឆ្នាំមុខនេះគេបានរកឃើញថា អំពើពុករលួយបានរីករាលដាលយ៉ាងខ្លាំងនៅប្រទេសកម្ពុជា។ ប្រជាពលរដ្ឋកម្ពុជា ៨៤% បានយល់ស្របថា ការសូកប៉ាន់ការទទួលសំណូក គឺជាទម្លាប់ធម្មតាឬជាប្រពៃណីទៅហើយ ដើម្បីធ្វើកិច្ចការអ្វីមួយឱ្យបានសំរេច។ នៅខែកញ្ញា ឆ្នាំ១៩៩៩ អង្គការតម្លាភាពអន្តរជាតិ(Trensparency International) បានចេញសន្ទស្សន៏ស្តីពី ការសូកប៉ាន់ដោយធ្វើការចាត់ថ្នាក់បណ្តាប្រទេស ដែលមានការសូកប៉ាន់។ ការបញ្ចូលមកនូវប្រាក់ជំនួយដ៏ធំសម្បើម នៃប្រទេសម្ចាស់អំណោយ និងការបើកចំហយ៉ាងឆាប់រហ័ស ដើម្បីទទួលយកការវិនិយោគទុនបរទេស ក្រោយពេលដែលប្រទេសជាតិ បានបិទជិតមិនមានទីផ្សារសេរីអស់រយៈពេលជិតបីទសវត្សរ៏មក នោះគឺមានន័យថា វាមានហេតុផល និងឱកាសជាច្រើន សំរាប់ការសូកប៉ាន់នៅប្រទេស

កម្ពុជា ក្នុងការបំផ្លិចបំផ្លាញ និងកេងប្រវ័ញ្ចន៍យកធនធានមនុស្ស និងធម្មជាតិខ្មែរ។

## ៦. ការិយាល័យកម្ពុជានៃគណៈកម្មាធិការជាន់ខ្ពស់សំរាប់សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (COHCHR) :

ក្នុងពេលអនុម័តច្បាប់រដ្ឋធម្មនុញ្ញថ្មី ក្នុងឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាយល់ព្រមគោរពតាមសេចក្ដីប្រកាសជាសកល ស្ដីពី សិទ្ធិមនុស្ស និងបរិធាននៃសិទ្ធិមនុស្សអន្តរជាតិដទៃទៀត។ ដោយសារតែមានការប្រព្រឹត្តិដ៏តក់ស្លុតនៃអតីតកាល មជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិមួយ ត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញ ដើម្បីឃ្លាំមើលការរំលោភសិទ្ធិមនុស្ស។ ក៏ប៉ុន្តែ ខណៈដែលប្រទេសកម្ពុជាជិតចូលដល់ការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ភាពតានតឹងរវាងរដ្ឋាភិបាលនិង COHCHR ក៏ចាប់ផ្ដើមឡើង។ COHCHR បានបង្ខិតបង្ខំឱ្យរដ្ឋាភិបាលមានវិធានការជាក់ស្ដែងដើម្បីកាត់ទោសជនប្រព្រឹត្តបទឧក្រិដ្ឋ ខាងហិង្សានយោបាយដែលក្នុងនេះមានជនទាំងឡាយដែលទទួលខុស ត្រូវចំពោះការសម្លាប់កិត្តិមជននៃគណបក្សប្រឆាំង កាលពីថ្ងៃទី៥_៦ ខែកក្កដា ឆ្នាំ១៩៩៧។ ការស្ដារឡើងវិញ នូវសេរីភាពខាងសារពត៌មាន សេរីភាពពេញលេញឱ្យគណបក្សប្រឆាំងចាប់ផ្ដើមធ្វើសកម្មភាពដោយការភ័យព្រួយការបំភិតបំភ័យឬអំពើហិង្សាពីភ្នាក់ងាររដ្ឋាភិបាល ឬបុគ្គលដែលអនុវត្តតាមបញ្ជារបស់រដ្ឋាភិបាល និងបញ្ចប់នូវការរំខានឬការបង្អាក់បន្ទុចដល់អ្នកធ្វើការងារខាងសិទ្ធិមនុស្ស។

រដ្ឋាភិបាលបានចោទមជ្ឈមណ្ឌលសិទ្ធិមនុស្ស អង្គការសហប្រជាជាតិថា បានជ្រៀតជ្រែកចូលកិច្ចការនយោបាយផ្ទៃក្នុងនៃប្រទេសកម្ពុជា ដែលមានអធិបតេយ្យភាព ហើយក៏បានបង្កើតនូវគណៈកម្មការជាតិសិទ្ធិមនុស្សផ្ទាល់របស់ខ្លួនមួយ ដើម្បីត្រួតពិនិត្យការរំលោភដូចដែលបានចោទប្រកាន់នោះ។

៧_ការកាត់ទោសខ្មែរក្រហម :

ជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាព នាទីក្រុងប៉ារីស សហគមន៍អន្តរជាតិត្រូវផ្តល់ ជំនួយប្រចាំឆ្នាំឱ្យប្រទេសកម្ពុជា។ ជំនួយនេះមុខពីរ: ទី១_ផ្តល់ការលើកទឹកចិត្តឱ្យរដ្ឋាភិបាលគោរពសិទ្ធិមនុស្ស និងលើកស្ទួយការអភិវឌ្ឍន៍នៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។ ប្រទេសម្ចាស់អំណោយធំៗមួយចំនួន បានដាក់សំពាធឱ្យរដ្ឋាភិបាលកម្ពុជា សហការដោយចំហជាមួយអង្គការសហប្រជាជាតិ ដើម្បីរៀបចំតុលាការអន្តរជាតិសំរាប់កាត់ទោស អតីតមេដឹកនាំខ្មែរក្រហម។ ទីពីរ_ ជំនួយមានន័យសំរាប់ឱ្យប្រទេសម្ចាស់អំណោយបង្ខំឱ្យរដ្ឋាភិបាលប្រព្រឹត្តតាមបមាណីយនិងសិទ្ធិមនុស្សអន្តរជាតិ។ រាជរដ្ឋាភិលកម្ពុជា បានគិតឃើញថា វាពុំមែនជាភាពងាយស្រួលទេ ចំពោះការកាត់បន្ថយអំណាចជាអធិបតេយ្យនៃកម្ពុជា ដើម្បីត្រួតពិនិត្យអនាគតផ្ទាល់ខ្លួនរបស់គេ ក្នុងខណៈដែលអំណាចខាងសេដ្ឋកិច្ច និងនយោបាយបានផ្លាស់ប្តូរទៅស្ថាប័នសកល និងឆ្លងដែន។

៤_សាសនា :

ការសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី៧_២០ ឆ្នាំ២០០០បានចុះផ្សាយថា ជនជាតិអារ៉ាប់ ដែលមានជំនឿស៊ប់ បានជះប្រាក់ដុល្លារ ដើម្បីបន្សុទ្ធជនជាតិចាម។ សារពត៌មាននេះបាននិយាយថា សហគមន៏ចាមមូស្លីម នៃប្រទេសកម្ពុជាកំពុងស្ថិតក្នុងសភាពផ្លាស់ប្តូរ ខណៈដែលក្រុមសាសនទូត មូស្លីម ដែលមានមូលនិធិច្រើនមកពីប្រទេសគុយវ៉ែត និងអារ៉ាប់ សេអ៊ូឌីត បានញ៉ាំងឱ្យគេផ្លាស់ប្តូរសាសនាគេទៅកាន់និកាយ "Wahabi" ដោយបោះបង់ចោល ការប្រតិបត្តិតាមសាសនាប្រពៃណីចាម។ ជនជាតិជាច្រើន ក្នុងសហគមន៏ចាមមានការព្រួយបារម្ភថា ការខិតខំប្រឹងប្រែងរបស់សាសនទូត ក្នុងការបន្សុទ្ធជនជាតិចាមតាមបែបឥស្លាមនេះនឹងធ្វើឱ្យវប្បធម៌ចាមមានការផ្លាស់ប្តូរដែលគេមិនចង់បាន។

នៅក្នុងសារពត៌មានដដែលនេះ អត្ថបទក្រោមចំណងជើង "ប្រជាជនកម្ពុជា ដែលប្តូរពីព្រះពុទ្ធមកជាយេស៊ូ" បាននិយាយថា: នៅក្នុងប្រទេសកម្ពុជា មាននិកាយប្រូតេស្តង់ដ៏ចំនួនជាង ៧០០ និងសាសនទូតរាប់រយនាក់ កំពុងធ្វើការយ៉ាងខ្លាំងក្នុងការសាងសង់វិហារកាតូលិក ដោយផ្តល់ជំនួយឱ្យសហគមន៏ដែលត្រូវការ និងកំពុងស្វែងរកក្នុងចំណោមប្រជាពលរដ្ឋដែលធ្លាប់មានប្រពៃណីជាពុទ្ធសាសនិកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សារពត៌មាននេះបានដកស្រង់សំដីរបស់អ្នកកាន់សាសនាគ្រីស្តម្នាក់ ដែលមានជំនឿច្បាស់ ក្នុងខ្លួនថា

"ប្រសិនបើរដ្ឋាភិបាលកម្ពុជា អនុញ្ញាតឱ្យគេធ្វើការដោយសេរី ថ្ងៃណាមួយប្រទេសជាតិនេះនឹងក្លាយជាប្រទេសមួយ ដែលកាន់សាសនាគ្រីស្តទាំងស្រុង"។

ជានិច្ចកាលសាសនាតែងឆ្លងកាត់ព្រំដែនជាតិនីមួយៗ។ ក៏ប៉ុន្តែសាសនទូតខាងសាសនាអាចរីកឡើង លុះណាតែមានការសុខចិត្តលះបង់នៃប្រព័ន្ធជំនឿក្នុងស្រុក ដែលជានិច្ចកាលសាសនានោះ បានជាប់ពាក់ព័ន្ធជាច្រើនសិបឆ្នាំកន្លងមក និងកាន់តែមានទំនាក់ទំនងជាមួយវប្បធម៌ក្នុងស្រុក និងបរិស្ថានផង។ សកលភាវូបនីយកម្មខាង សាសនាមានន័យថា សាសនទូតអន្តរជាតិនិងអ្នកដែលមានជំនឿស៊ប់ ដែលមានមូលនិធិច្រើនអាចនឹងប្រើប្រាស់យ៉ាងស័ក្តិសិទ្ធ នូវជំនួយឬដកយកជំនួយ ដើម្បីទិញឬធ្វើឱ្យផ្លាស់ប្តូរលទ្ធិសាសនាដើម មកកាន់និកាយពិសេសៗរបស់ពួកគេវិញ។ ទង្វើបែបនេះ បង្កើតឱ្យមានការបែកបាក់នៅក្នុងសហគមន៍មូលដ្ឋាន។

## IV- ឥទ្ធិពលជាវិជ្ជមាននៃសកលភាវូបនីយកម្ម ពិនិត្យឃើញដោយវេទិកាអន្តរជាតិស្តីពី សកលភាវូបនីយកម្ម (IFG)

វេទិកាអន្តរជាតិ ស្តីពី សកលភាវូបនីយកម្ម (IFG) ដែលជាសម្ព័ន្ធភាព (Alliances) របស់អ្នកប្រាជ្ញ (វិជ្ជាករ) សកម្មជន អ្នកសេដ្ឋកិច្ច អ្នកសិក្សាស្រាវជ្រាវ និងអ្នកនិពន្ធ បានមើលឃើញដំណើរ

ការនៃសកលភាវូបនីយកម្មដោយក្តីបារម្ភ មកលើប្រជាពលរដ្ឋដែលបាន រងឥទ្ធិពល។

វេទិកាអន្តរជាតិ ស្តីពីសកលភាវូបនីយកម្ម (IFG) ជឿថា កិច្ចព្រមព្រៀងនៃពាណិជ្ជកម្ម និងការនិយោគទុនអន្តរជាតិ ដែលក្នុង នោះរួមបញ្ចូលទាំង GATT និងកិច្ចព្រមព្រៀងពហុភាគី ស្តីពីការ វិនិយោគដែលមិនទាន់បានសំរេច (MAI) ដែលរួមបញ្ចូលទាំងគោល នយោបាយហិរញ្ញវត្ថុ ដែលដាក់កំហិតដោយ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោកទៅលើបណ្តាប្រទេសដែលត្រូវការប្រាក់ កម្ចី នឹងទៅជាគ្រឿងលើកទឹកចិត្តដោយផ្ទាល់ដល់ដំណើរការទាំងឡាយ ដែលធ្វើឱ្យខ្សោយនូវលទ្ធិប្រជាធិបតេយ្យជាតិ និងបង្កើតឱ្យមានសណ្តាប់ ធ្នាប់ពិភពលោកថ្មីមួយ ស្ថិតនៅក្រោមការត្រួតពិនិត្យនៃសាជីវកម្មឆ្លង ដែន ដោយមានការទទួលខុសត្រូវតិចតួច ចំពោះប្រជាពលរដ្ឋឬចំពោះ រដ្ឋាភិបាលជាតិផង។

នៅឆ្នាំ ១៩៩៨ IFG បានព្រមានថា : សហប្រតិបត្តិការ ដែលនាំឱ្យមានសកលភាវូបនីយកម្មសេដ្ឋកិច្ច ដូចដែលសម្តែងយោបល់ និងលើកទឹកចិត្តដោយបទបញ្ជានៃការវិនិយោគទុននិងពាណិជ្ជកម្មសកល អាចនឹងបណ្តាលឱ្យមានការផ្លាស់ប្តូរភ្លាមៗ ក្នុងទីផ្សារហិរញ្ញវត្ថុសកល និងភាពដែលងាយនឹងទទួលរងគ្រោះខ្លាំងឡើង សំរាប់ប្រទេសជាតិនិង ប្រជាពលរដ្ឋ។ ការផ្លាស់ប្តូរភ្លាមៗនេះ កំពុងនាំមកនូវការខូចខាត សេដ្ឋកិច្ចធំៗនៅក្នុងប្រទេសជាតិខ្លះ នៅក្នុងអសន្តិសុខ ក្នុងប្រទេស

ជាតិទាំងអស់ សេចក្តីលំបាកវេទនាដែលមិនកើតមានពីមុនមក សំរាប់ប្រជាពលរដ្ឋរាប់លាននាក់ ដោយបង្កើតឱ្យមានការរីកធំឡើង នូវភាពគ្មានការងារធ្វើ និងការផ្លាស់ប្តូរទីលំនៅ នៅគ្រប់តំបន់ ការរំលោភដោយផ្ទាល់ទៅលើល័ក្ខខ័ណ្ឌបរិស្ថាន និងពលកម្ម ការបាត់បង់នូវទីរហោឋាននិងភាពដោយឡែកនៃជីវៈ (Bio-diversity) ការប្តូរទីលំនៅធំៗនៃប្រជាពលរដ្ឋ ការបង្កើនភាពតានតឹងខាងជនជាតិ និងពូជសាសន៍និងលទ្ធផលដ៏គ្រោះថ្នាក់ឬការបំផ្លិចបំផ្លាញដទៃទៀត។ លទ្ធផលឬឥទ្ធិពលដ៏ធ្ងន់ធ្ងរទាំងនេះ បច្ចុប្បន្ននេះ កំពុងក្លាយជាការបង្ហាញឱ្យឃើញទូទាំងពិភពលោកនិងកំពុងកើនឡើងជារៀងរាល់ថ្ងៃ។

## V_ អំពីអនុសាសន៍ :

លក្ខខ័ណ្ឌ ដែលជាបញ្ហាលេខមួយនៅប្រទេសកម្ពុជា សព្វថ្ងៃ ដែលអាចចូលរួមដោះស្រាយសេចក្តីក្រីក្របាន នោះគឺភាពដែលមិនអាចដាច់គ្នាបានរវាងហេតុផលក្នុងស្រុក និងក្រៅស្រុក (សកល)។ ភាពនៅឯកោ ក្នុងរបបកុម្មុយនិស្តនៃប្រទេសកម្ពុជា អស់រយៈពេលបីទសវត្សរ៍បានបំផ្លិចបំផ្លាញប្រទេសជាតិនេះ ទាំងវិស័យនយោបាយសង្គម និងសេដ្ឋកិច្ច ក៏ប៉ុន្តែ គ្រាន់តែមួយទសវត្សរ៍នៃការបើកទ្វារចំហឱ្យពិភពលោកប៉ុណ្ណោះ បាននាំមកនូវជម្ងឺដ៏អាក្រក់ៗ បំផុតនៃសកលភាវូបនីយកម្ម។ នេះគឺមានន័យថា បើមានតែរដ្ឋាភិបាល និងសង្គមស៊ីវិលមិនអាចដោះ ស្រាយបញ្ហាដែលកំពុងកើតមាននៅប្រទេសកម្ពុជា បានទេ។ ដូចច្នេះ យើងអាចខ្ចីឃ្លាមួយពីចលនាបរិស្ថាន ហើយយកមក

និយាយថា យើងជាសមាជិកនៃអង្គការសង្គមស៊ីវិលកម្ពុជា ត្រូវតែ : គិតគូរជា សកលតែធ្វើទៅតាមជាតិយើង_Think Global Act Local។

ឧទាហរណ៍ :

- ដើម្បីកាត់បន្ថយភាពកើតឡើងច្រំដែលៗ នៃសេចក្តីក្រីក្រ សង្គមស៊ីវិលត្រូវលើកកំពស់វិស័យសេដ្ឋកិច្ច និរន្តរភាពនៃការគ្រប់គ្រងដីធ្លី និងការលើកស្ទួយឥណទានទ្រទ្រង់គ្រួសារជនបទ។ យើងក៏ត្រូវធ្វើសកម្មភាពដើម្បីការពារភាពដោយឡែក (Diversity) នៃវប្បធម៌ប្រពៃណីរបស់ប្រជាពលរដ្ឋ និងរបស់សង្គមជាតិដោយត្រូវគាំទ្រសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ដីធ្លីនៃប្រជាពលរដ្ឋដើមនៅកម្ពុជា។
- ដើម្បីកាត់បន្ថយអត្រារីករាលដាលនៃជម្ងឺហ៊ីវ/អេដស៍(HIV/AIDS) និងការជួញដូរស្ត្រីភេទនិងកុមារ យើងត្រូវខិតខំបញ្ឈប់ទេសចរផ្លូវភេទ និងលើកស្ទួយទេសចរជាប់លាប់នៅនឹងកន្លែងដោយបរិស្ថានវិទ្យា និងសេដ្ឋកិច្ច។
- ដើម្បីកាត់បន្ថយ ឧប្បត្តិហេតុនៃការជួញដូរស្ត្រីនិងកុមារទៅប្រទេសដទៃ និងដើម្បីកាត់បន្ថយលំហូរ នៃគ្រឿងញៀនខុសច្បាប់ឆ្លងកាត់ព្រំដែននៃប្រទេសយើង យើងត្រូវរួបរួមគ្នាជាមួយនឹងរដ្ឋាភិបាលនិងអង្គការរបស់បណ្តាប្រទេសជិតខាង។
- ដើម្បីចូលរួម ជួយបញ្ឈប់ការបំផ្លិចបំផ្លាញបរិស្ថានសកល យើងត្រូវបញ្ឈប់ ការប្រមូលផលធនធានធម្មជាតិរបស់អ្នកវិនិយោគទុនបរទេសនិងការីរបស់គេ (Operators) យើងត្រូវបង្វែរ ការទទួល

ខុសត្រូវខ្លះអំពីបរិស្ថានក្នុងស្រុក (បរិស្ថានជាតិ) ឱ្យសហគមន៍មូលដ្ឋានទទួលខុសត្រូវ ព្រោះគេជាអ្នកទទួលរងគ្រោះច្រើនជាងគេបំផុត ដែលបណ្តាលមកពីការប្រើប្រាស់ខុស នូវជនធនធម្មជាតិនោះ។

- ដើម្បីបញ្ឈប់នូវការកើតមានច្រំដែលៗ (Cycle) នៃអំពីពុករលួយ យើងត្រូវជួយស្នើសុំម្ចាស់អំណោយនិងវិនិយោគិនបរទេស កុំឱ្យផ្តល់ឱកាសឱ្យមានការសូកប៉ាន់ និងការទទួលសំណូក។ យើងត្រូវរៀបចំបង្កើតឱ្យមានកម្មវិធីសិក្សាអំពីអភិបាលកិច្ចល្អ និងតម្លៃសីលធម៌បញ្ចូលទៅក្នុងប្រព័ន្ធសិក្សាអប់រំថ្នាក់ជាតិ និងផលិតពត៌មានឯកសារប្រឆាំងនឹងអំពើពុករលួយ អប់រំសាធារណជនអំពីតម្លៃ នៃការខាតបង់ដោយសារតែអំពើពុករលួយចំពោះប្រទេសជាតិ។
- ដើម្បីចូលរួមលើកស្ទួយការគោរពសិទ្ធិមនុស្ស យើងត្រូវផ្តល់ជំនួយការពេញលេញជូនរដ្ឋាភិបាល និងសភាជាតិ ដែលមាននៅក្នុងសិទ្ធិអំណាចរបស់យើង ដើម្បីបង្កើតឱ្យបាននូវគណៈកម្មការសិទ្ធិមនុស្ស នៅក្នុងតំបន់អាស៊ានដ៏ខ្លាំងមួយ។
- ដើម្បីពង្រឹងដំណើរការ នៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសជាតិ យើងត្រូវផ្តល់អំណាច និងស្តារសហគមន៍មូលដ្ឋាន ដោយផ្តល់នូវសេដ្ឋកិច្ចឱ្យកាន់តែច្រើន និងការត្រួតពិនិត្យនយោបាយទៅលើជីវិតផ្ទាល់របស់គេ និងវិស័យទាំងឡាយរបស់គេ ដោយរួមបញ្ចូលទាំង

តាមរយៈការផ្តល់ការគាំទ្រ ចំពោះប្រសិទ្ធិភាពនៃការអនុវត្តន៍ច្បាប់រដ្ឋបាលឃុំនិងបោះឆ្នោតឃុំផង។

- ដើម្បីពង្រឹង ជំនឿសាសនារបស់ជាតិ និងសុខភាពស្មារតីរបស់ប្រជាជាតិទាំងមូល យើងត្រូវលើកស្ទួយតម្លៃប្រពៃណី និងទស្សនាទាន នៃសីល៥របស់ព្រះពុទ្ធ ដែលហាមប្រាមមិនឱ្យសម្លាប់សត្វលួចទ្រព្យ សម្បត្តិគេ កុហកគេ មិនប្រព្រឹត្តខុសក្នុងផ្លូវកាម (លួចកូនប្រពន្ធគេ) និងការសេពគ្រឿងស្រវឹង។
- សរុបសេចក្តីមក យើងគប្បីគាំទ្រ ការបង្កើតសហគ្រាស សេដ្ឋកិច្ច និងស្ថាប័នរួមផ្សំ ដែលអាចពង្រឹងភាពប៉ិនប្រសប់របស់ប្រជាពលរដ្ឋក្នុងការអនុវត្តន៍ការត្រួតពិនិត្យ តាមបែបលទ្ធិប្រជាធិបតេយ្យទៅលើសេចក្តីសំរេចចិត្តទាំងឡាយ ដែលប៉ះពាល់ដល់គេ នៅពេលដែលត្រូវលើកស្ទួងជីវភាពប្រកបដោយអត្ថន័យ និងភាពជាប់លាប់សំរាប់ទាំងអស់គ្នា។ នេះមានន័យថា ជាការសង្កត់ធ្ងន់ទៅលើផលិតកម្មក្នុងស្រុក ដែលរៀបចំឡើង ដើម្បីដោះស្រាយតម្រូវការនៃសេចក្តីប្រើប្រាស់ក្នុងស្រុក។ ធ្វើដូច្នេះ គឺដើម្បីបង្កើតឱ្យមាននូវតុល្យាភាពល្អប្រសើររវាងការនាំចេញ និងការនាំចូល។ នេះក៏មានន័យថា ជាការអភិវឌ្ឍន៍នូវចង្វាក់ផលិតកម្មស្វ័យភាព ក្នុងស្រុកក្នុងតំបន់ និងតម្រូវការប្រើប្រាស់ ដែលមានមូលដ្ឋានជាបឋម ទៅលើធនធានថ្មីៗ ថែមទៀតនៃថាមពល.វត្ថុធាតុដើម នោះគឺជាការថែរក្សាធនធានធម្មជាតិសំរាប់ជំនាន់ក្រោយ ក៏ដូចជា គតិបណ្ឌិត

និងសោភ័ណនៃធម្មជាតិ។ ទាំងអស់នេះ គឺជាឱកាសដ៏មានសង្ឃឹមគ្រប់ចំណុចសំរាប់ប្រទេសកម្ពុជា : ប្រទេសជាតិមានសន្តិភាព, សេដ្ឋកិច្ច មានស្ថេរភាពថ្មីៗនេះ រដ្ឋាភិបាលបានប្តេជ្ញា សហគមន៍ជាតិកំពុងត្រូវបានកសាងឡើងវិញជាបណ្តើរៗ ហើយសម្បត្តិវប្បធម៌កំពុងតែរកឃើញឡើងវិញ។

ប្រទេសកម្ពុជាមានសក្តានុពលភាពជាច្រើន ដើម្បីចម្រាញ់យកធនធានផ្សេងៗសំរាប់ការលូតលាស់ : កសិកម្ម ធនធានធម្មជាតិ ឧស្សាហកម្មធុនស្រាលវប្បធម៌ និងទេសចរ។ ភាពឈ្លាសវៃរបស់ប្រទេសកម្ពុជា ក្នុងការចម្រាញ់យកភាពលូតលាស់ទាំងនេះ អាស្រ័យមួយផ្នែកទៅលើការដោះស្រាយ កង្វះខាងធនធានមនុស្ស និងសំភារៈ តែជាបឋមគឺ ការដោះស្រាយឱកាសជាប់លាប់សំរាប់រដ្ឋាភិបាលធ្វើការកែទម្រង់។ ជាការពិតណាស់ប្រទេសកម្ពុជា ត្រូវការពេលវេលាច្រើនឆ្នាំច្រើនទសវត្សរ៍ ដើម្បីនឹងឈានឡើង (Take off)។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាមានយន្តការនៅនឹងកន្លែងរួចហើយអ្វីដែលត្រូវការបន្ថែមទៀតនោះគឺ "ការស្គាល់ខ្លួនឯង និងជំនឿលើអាត្មាខ្លួន"។

បន្ទាប់ពីមានវិបត្តិហិរញ្ញវត្ថុនៅតំបន់មួយចំនួន នៃទ្វីបអាស៊ីក៏ដូចជារុស្ស៊ី ព្រេស៊ីលនិងតំបន់ដទៃទៀតនៃពិភពលោក អ្នកសង្កេតការជាច្រើនបានចាប់ផ្តើមទទួលស្គាល់ថាសកលភាវូបនីយកម្មនឹងធ្វើឱ្យមានវិនាសកម្មមិនខានឡើយ។ តាមទស្សនៈរបស់អង្គការ

IFG គេបានចាប់ផ្ដើមសួរដោយត្រង់ៗថា តើសកលភាវូបនីយកម្ម ពិសេសគឺពាណិជ្ជកម្មសេរី ដែលកំពុងបង្ហូរហិរញ្ញវត្ថុនឹងផ្ដល់ផល ប្រយោជន៍ល្អឱ្យជាតិរបស់ខ្លួន ឬក៏ជាតិដទៃឬទេ។ ប្រទេសជាតិ ដែលបាន ត្រួតពិនិត្យយ៉ាងមធ្យ័តទៅលើ "ដើមទុន_Capital " បានបង្ហាញឱ្យឃើញនូវស្ថេរភាពកំរិតខ្ពស់ ហើយនឹងផ្ដល់នូវផល ប្រយោជន៍ដ៏ជោគជ័យដល់ធនធាន និងមូលដ្ឋានសេដ្ឋកិច្ចរបស់គេ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋគេ។

ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជានៃយើងក៏គួរតែផ្ដើមគំនិតដោះ ស្រាយបញ្ហានៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍បន្តិចម្ដង ដោយពឹងផ្អែកទៅលើធនធានរបស់ជាតិ ជាជាងការពឹងផ្អែកតែទៅ លើអំណោយបរទេស និងស្ថាប័នប្រាក់កម្ចី។ គតិបណ្ឌិតខាងលើ នេះក៏គួរតែបង្កើតឱ្យមានផងដែរ នៅក្នុងផែនការយុទ្ធសាស្ត្រនៃការ ឧបត្ថម្ភខ្លួនឱ្យមានភាពយូរអង្វែងដោយខ្លួនឯងនៃអង្គការសង្គមស៊ីវិល កម្ពុជាគ្រប់លំដាប់ថ្នាក់៕

## ៦.៥_សុន្ទរកថាថ្លែងដោយលោក ស៊ីទិន ម៉ក់ នាយកប្រតិបត្តិនៃ វិទ្យាស្ថានកម្ពុជា ដើម្បីសិទ្ធិមនុស្ស ស្ដីអំពី "ឥទ្ធិពលនៃសកលភាវូបនីយកម្មលើសង្គមស៊ីវិលកម្ពុជា"

ពាក្យថា សកលភាវូបនីយកម្ម លើសង្គមស៊ីវិលកម្ពុជាជាប្រធានបទថ្មីមួយ សំរាប់ពលរដ្ឋកម្ពុជា និងពលរដ្ឋនានាដទៃទៀត ក្នុងសកលលោកចាប់តាំងពីសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់។ រដ្ឋាភិបាលនិងរាជរដ្ឋាភិបាលទាំងអស់ ដែលមានលើសកលលោកយើងនេះ កំពង់ខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីពង្រីក និងបង្រួបបង្រួមសាមគ្គីគ្នាជាខ្នាតអន្តរជាតិ តាមរយៈកិច្ចសហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមកក្នុងស្មារតីលើកស្ទួយវប្បធម៌សន្តិភាព ដើម្បីកាត់បន្ថយមនោគមន៍វិជ្ជានយោបាយ វប្បធម៌ហិង្សា សង្គ្រាមឈ្លានពាន រាគត្បាត និងការមិនទុកចិត្តគ្នា។ នេះគឺជាគោលបំណងមួយ ដើម្បីធ្វើឱ្យមនុស្សក្នុងសង្គមពិភពលោកសព្វថ្ងៃ ចេះស្រុះស្រួលមូលមតិគ្នា ស្គាល់សុខទុក្ខគ្នាជួយសង្គ្រោះគ្នា និងចែករំលែកនូវផលប្រយោជន៍ឱ្យគ្នា តាមផ្លូវសីលធម៌សន្តិវិធីប្រកបដោយសេចក្ដីថ្លៃថ្នូរ និងភាតរភាពជាសកល។

ពាក្យថា "សកលភាវូបនីយកម្ម" (Globalization) គឺការធ្វើអ្វីៗទាំងអស់ឱ្យទៅជាសកល។ ប៉ុន្តែ យើងគប្បីត្រូវយល់ដឹងដែរថាតើវិស័យអ្វីខ្លះ ដែលយើងអាចធ្វើវាឱ្យទៅជាសកលបាន ដោយមិនឱ្យ

មានផលប៉ះពាល់ដល់ប្រយោជន៍ ផ្ទៃក្នុងរបស់ជាតិរៀងៗខ្លួន? ជាពិសេសនៅក្នុងប្រទេសកម្ពុជាយើង ដែលជាប្រទេសទើបនឹងចាប់ផ្តើមមានការអភិវឌ្ឍន៍ ហើយស្ទើរគ្រប់វិស័យទាំងអស់ កំពុងមានដំណើរការនៅមិនទាន់បានល្អប្រសើរនៅឡើយ ជាអាទិ៍មានដូចជាវិស័យ អប់រំ សុខាភិបាល សង្គមកិច្ច យុត្តិធម៌ កសិកម្ម និងវប្បធម៌ជាដើម ។ល។ ដូច្នេះ ប្រសិនបើការផ្សព្វផ្សាយចូលក្នុងស្រុក តាមរយៈការធ្វើសកលភាវូបនីយកម្ម មានលក្ខណៈលឿនជ្រុលហួសហេតុពេក នៅពេលនោះយើងច្បាស់ជាមិនអាចគេចផុតពីគ្រោះថ្នាក់ម្តងទៀត ជាមិនខានឡើយ ពីព្រោះយើងកំពុងជួបប្រទះនូវបញ្ហាមួយចំនួន ដែលមានដូចជាធនធានមនុស្សនិងការទទួលខុសត្រូវទាំងខាងស្មារតីសម្បជញ្ញៈ និងជាតិនិយម។ តើយើងអាចខាត ឬអាចចំណេញពីការធ្វើសកលភាវូបនីយកម្មនេះ? តើយើងត្រូវរត់ឬត្រូវធ្វើដំណើរដោយរបៀបណា ដើម្បីឱ្យទាន់គេបាន? នេះជាបញ្ហាពិបាកចំពោះអនាគតរបស់យើងទាំងអស់គ្នា?

ឧទាហរណ៍ សព្វថ្ងៃនេះមានការហូរចូលយ៉ាងសម្បូរបែប នូវវប្បធម៌បរទេសមកក្នុងស្រុកតាមរយៈ INTERNET, ELECTRONIC MEDIA និងតាមរយៈការធ្វើទេសចរណ៍ឆ្លងដែន។ នេះជាឧទាហរណ៍ទី១។ ឧទាហរណ៍ទី២ ការធ្វើសកលភាវូបនីយកម្មយ៉ាងសកម្មបំផុតជាងគេ នោះគឺតាមរយៈក្រុមប្រតិបត្តិការរបស់ភ្នាក់ងារ សង្គមស៊ីវិលដែលមានអង្គការ សមាគមក្រៅរដ្ឋាភិបាលក្នុងស្រុក និង ក្រៅស្រុកនានា។ ក្រុមនេះគេអាចផ្លាស់ប្តូរយោបល់ ទស្សនៈ បច្ចេកទេស

បទពិសោធន៍ របាយការណ៍ដល់គ្នាទៅវិញទៅមក ដែលជួនកាលបាន ទទួលផលល្អ ជួនកាលបានទទួលផលអាក្រក់អាចនាំមកនូវគ្រោះថ្នាក់ ដល់ផលប្រយោជន៍ជាតិផងក៏មាន។ តួយ៉ាងដូចជាបញ្ហាសិទ្ធិមនុស្សនិង ច្បាប់ក្នុងស្រុកនៅកម្ពុជា កាលពីពេលថ្មីៗកន្លងទៅ អាជ្ញាធរក្រុងបាន ចាត់វិធានការរៀបចំសណ្តាប់ធ្នាប់បង្ក្រាប ឬបោសសំអាតការហូរចូល ជនបរទេសខុសច្បាប់ សង់លំនៅដ្ឋានយ៉ាងអនាធិបតេយ្យតាមដងផ្លូវ ទន្លេ បឹងបួរ ឬមូលដ្ឋាននានាក្នុងក្រុង នៅពេលអាជ្ញាធរចុះប្រតិបត្តិ រៀបចំបង្ក្រាបតាមច្បាប់ក្នុងឋានៈជាអាជ្ញាធរផង និងក្នុងឋានៈជាម្ចាស់ ផ្ទះផង ពេលនោះយើងឃើញមានអង្គការ សមាគមមួយចំនួនមាន ប្រតិកម្មថា យើងបានរំលោភសិទ្ធិមនុស្ស គេបានធ្វើការផ្សព្វផ្សាយ តាមរយៈ INTERNET ទូទាំងពិភពលោកនូវដំណឹងមិនល្អនេះ ដែល វាអាចធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ជាតិ។ សួរថា តើ បញ្ហាបែបនេះ យើងត្រូវធ្វើដូចម្តេច? អ្នកណាជាអ្នកទទួលខុសត្រូវ ចំពោះផលវិបាកដែលបានទទួលមកពីទង្វើទាំងនេះ?

ជាការពិតណាស់ យើងមិនអាចគេចបានពីការធ្វើសកលភាវូបនីយកម្មទេ ព្រោះវាជាទំនោរនៃឥទ្ធិពលនយោបាយរបស់រដ្ឋាភិបាល ពិភពលោក ហើយផលល្អ និងផលអាក្រក់ វាក៏កើតមានតំណាលគ្នា មកលើប្រទេសក្រីក្រ ដែលកំពុងខ្វះខាតធនធានមនុស្ស ដូចជាកម្ពុជា យើងជាដើម។

ភ្នាក់ងារដ៏សំខាន់ដែលជាអ្នកត្រូវទទួលយក និងបញ្ចេញបញ្ចូលចរន្តសកលវូបនីយកម្មនៅកម្ពុជា គឺអង្គការសមាគមនានា នៃសង្គមស៊ីវិលនេះឯង ពីព្រោះពត៌មានល្អក្តី អាក្រក់ក្តី វាត្រូវឆ្លងកាត់តាមបណ្តាញដូចបានជំរាបជូនខាងលើនេះ។ វាមានល្បឿនលឿន និងមានប្រសិទ្ធិភាពខ្ពស់ណាស់។ ម្យ៉ាងទៀតសង្គមស៊ីវិល គឺជាភ្នាក់ងារក្រៅរដ្ឋាភិបាល វាស្ថិតនៅចន្លោះបរិយាកាសកិច្ចការនយោបាយរបស់រដ្ឋាភិបាល និងសង្គមប្រជាពលរដ្ឋ។ រាល់កង្វះខាតនានា ដែលរដ្ឋាភិបាលផ្តល់សេវាមិនបានគ្រប់គ្រាន់ឬខ្វះចន្លោះ សង្គមស៊ីវិល ជាអ្នកចេញមុខជួយឬរ៉ាប់រងបំពេញជំនួស។ ដូច្នេះសេវាជំនួយនេះ សង្គមស៊ីវិលត្រូវតែមានទំនាក់ទំនងល្អជានិច្ច ទាំងជាមួយរដ្ឋាភិបាលនិងប្រជារាស្ត្រ។ ម្ចាស់អំណោយ ឬអង្គការអន្តរជាតិ គេជាអ្នកឃ្លាំមើលហេតុផលតាមរបាយការណ៍របស់ដៃគូរបស់គេនៅថ្នាក់ជាតិ រួចបានបន្តទៅស្ថាប័នអន្តរជាតិនានា រួចហើយក៏បានផ្សព្វផ្សាយជាទូទៅ ទាំងសកលលោក រួមទាំងការហូរចូលមកក្នុងស្រុកនៃភាគីជាដៃគូរបស់ខ្លួនវិញដែរ។

ម្យ៉ាងវិញទៀត ពិភពលោកទាំងមូល កំពុងតែស្វាគមន៍យ៉ាងគគ្រឹកគគ្រេង នូវការមកដល់នៃសហសវត្សថ្មី ក្នុងការកសាងប្រជាធិបតេយ្យពិភពលោក។ ប្រទេសនានាដែលគ្មានប្រជាធិតេយ្យ ត្រូវបានទទួលនូវការកៀបសង្កត់ ដោយតំរូវមានការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។ ការចាប់ផ្តើមដំបូងនៃសម្ព័ន្ធភាព ដើម្បីលទ្ធិប្រជាធិបតេយ្យ គឺទាមទារឱ្យប្រជាជនដែលស្នេហាសន្តិភាព និងសេរីភាព

រួមកំលាំងគ្នា ក្នុងការស្វែងរកប្រជាធិបតេយ្យភាវូបនីយកម្ម ពិតប្រាកដ ហើយឱ្យមានតុល្យភាព ដើម្បីស្ថាបនាសន្តិភាពរបៀបរៀបរយអន្តរជាតិ នាពេលណាមួយដោយខានមិនបាន។ ជោគជ័យនៃការធ្វើសកលភាវូបនីយកម្ម ពិតជាបានទទួលផលល្អ សំរាប់បណ្តាប្រទេសដែលបានអភិវឌ្ឍន៍ ព្រោះគេមានធនធានមនុស្សយ៉ាងសម្បូរហូរហៀរ ចេញមកក្រៅទាំងថវិកាទាំងមនុស្ស ហើយអាចគ្រប់គ្រងបាននូវអ្វីៗទាំងអស់។ ប្រទេសក្រីក្រប្រហែលជាអាចទទួលរងនូវគ្រោះថ្នាក់តិច ឬច្រើនឬខាតបង់ប្រយោជន៍ខ្លះជាមិនខាន ដោយសារភាពក្រីក្រនិងការខ្វះ ខាតធនធានមនុស្ស ប៉ុន្តែដាច់ខាតត្រូវតែទទួលយកឥទ្ធិពលពីគេ ដើរតាមគេទៅរណបគេ ដោយភ្លេចនូវអ្វីៗដែលជាស្នាដៃរបស់ខ្លួន ដែលធ្លាប់មានពីមុនៗមក។

ចំពោះកម្ពុជាវិញ តើយើងយល់យ៉ាងណាដែរ បើយើងខ្វះខាតទាំងសព្វទាំងគ្រប់ ទាំងហិរញ្ញវត្ថុ ទាំងការអប់រំធនធានមនុស្ស ទាំងមធ្យោបាយ សំភារៈបច្ចេកទេស ។ល។ ជាពិសេស គឺយើងត្រូវពឹងអាស្រ័យគេទាំងស្រុង។ តើយើងមានមធ្យោបាយអ្វី ឬមានវិធានការអ្វីដើម្បីទប់ស្កាត់រាល់ការហូរចូលនូវវប្បធម៌បរទេស ដែលសង្គមខ្មែរមិនអាចទទួលបានជាទូទៅនៅឡើយ? អាចមានបញ្ហាធំៗពីរ ប្រឈមមុខដាក់គ្នាគឺឥទ្ធិពលដែលហូរចូលមកពីក្រៅតាមរយៈធ្វើសកលភាវូបនីយកម្ម ដែលអាចបណ្តាលឱ្យក្រុមមនុស្សសម័យថ្មី លើកតម្កើង ទស្សនៈអន្តរជាតិធំជាងទស្សនៈជាតិ អាចបណ្តាលឱ្យបាត់បង់អត្តសញ្ញាណជាតិ ជា

បណ្តើរៗ បើយើងបណ្តែតបណ្តោយមិនពិចារណា។ បញ្ហាទី២ ក្រុមមនុស្សដែលមានស្មារតីជាតិនិយមខ្ពស់គេ ពិតជាមិនសប្បាយចិត្តហើយអាចមានកង្វល់ក្នុងអារម្មណ៍ជាប្រចាំបង្កឱ្យមានការប្រុងប្រយ័ត្ន និងមិនទុកចិត្តគ្នា កាន់តែខ្លាំងឡើយៗ។ យើងអាចធ្វើការប្រៀបធៀបរវាងប្រទេសយើងនិងប្រទេសជិតខាងយើង តើពលរដ្ឋយើង និងគេមានការយល់ដឹងខុសត្រូវយ៉ាងដូចម្តេចខ្លះ។ ជនជាតិគេ គេចេះការពារផលប្រយោជន៍ជាតិគេខ្ពស់ជាងប្រយោជន៍ផ្ទាល់ខ្លួន។ ចុះយើងវិញ?

ដូច្នេះ ជាទស្សនៈអត្តនោមតិរបស់ខ្ញុំ ខ្ញុំយល់ថាសង្គមស៊ីវិលកម្ពុជា គឺជាស្ថានមួយដ៏វិសេសវិសាលមួយ សំរាប់ចំលងចរន្តសកលភាវូបនីយកម្មចេញ និងចូលក្នុងស្រុក។ ខ្ញុំសូមស្នើសុំឱ្យភ្នាក់ងារសង្គមស៊ីវិលទាំងអស់ រក្សាការពិចារណាដោយប្រុងប្រយ័ត្ន នូវឥទ្ធិពលនេះដោយសម្បជញ្ញៈរៀងៗខ្លួន គឺថាតើអ្វីដែលយើងគប្បីទទួល និងអ្វីដែលយើងមិនគប្បីទទួល។

## ការធ្វើសកលភាវូបនីយកម្ម
## ទំនាក់ទំនងរវាងរដ្ឋាភិបាល សង្គមស៊ីវិល និងអន្តរជាតិ




<u>សង្គមស៊ីវិលត្រូវមានចរិត</u> : អព្យាក្រឹត ឯករាជ្យ បំរើសេវាមិនយកកម្រៃ មិនធ្វើនយោបាយដើម្បីអំណាច ជួយសង្គ្រោះការពារច្បាប់ និងសិទ្ធិមនុស្ស ប្រកាន់សច្ចធម៌សីលធម៌ សាមគ្គីធម៌និងសហប្រតិបត្តិការជាដៃគូជាមួយរាជរដ្ឋាភិបាលនិងអន្តរជាតិ។

## ៦.៦_សុន្ទរកថាថ្លែងដោយលោក សុក សំអឿន នាយកក្រុម អ្នកច្បាប់សិទ្ធិមនុស្សអន្តរជាតិប្រចាំកម្ពុជា ស្តីអំពី "គម្រោងច្បាប់និងសង្គមស៊ីវិលនៅកម្ពុជា ស្ថានភាពណ៍ ការប្រឈមមុខ និងក្តីសង្ឃឹមទៅអនាគត : ទស្សនៈសង្គមស៊ីវិល"

សេចក្តីផ្តើម :

មានការកត់សំគាល់មួយ នៅពេលដែលមានការប្រជុំរបស់ប្រទេសម្ចាស់អំណោយ និងរាជរដ្ឋាភិបាលនៅទីក្រុងប៉ារីស កាលពីខែមេសា ឆ្នាំ២០០០ តំណាងរាជរដ្ឋាភិបាលបានលើកឡើង ពីបញ្ហាអភិបាលកិច្ចល្អ ហើយក៏បានបង្ហាញពីគំរោង ផែនការស្តីពីអភិបាលកិច្ចល្អផងដែរ។ មានតំណាងប្រទេស និងអ្នកបច្ចេកទេសជាច្រើន ដែលយល់ថា នេះជាការចំឡែកនិងអស្ចារ្យណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាហ៊ានធ្វើបែបនេះ ដែលកម្រនឹងមានរដ្ឋាភិបាល ប្រទេសណាមួយធ្វើបែបនេះនោះទេ។ នេះជាជំហ៊ានឆ្ពោះទៅរកការរីកចំរើន តែទោះជាយ៉ាងណាការគ្រាន់តែមានគំរោងជាគោល តែមិនទាន់មានផែនការអនុវត្តន៍លំអិត និងមិនទាន់អនុវត្ត។ នេះក៏មានន័យថាជំហានោះមិនទាន់បោះទៅមុខផងដែរ។

និយមន័យ (Definition) :

អភិបាលកិច្ចល្អ មានន័យថា ជាការគ្រប់គ្រងមួយដែលប្រើធនធានទាំងទ្រព្យ និងទាំងមនុស្សដោយប្រសិទ្ធិភាព គ្មានបញ្ហាកើត

ឡើង និងមានការពេញចិត្តពីសមាជិកទាំងអស់គ្នា ព្រមទាំងបានផ្តល់លទ្ធផលជាអតិបរមាផង។

លក្ខណះរបស់អភិបាលកិច្ចល្អ (Characteristics of Good Governance) :

ដើម្បីអាចឱ្យអភិបាលកិច្ចល្អ ប្រព្រឹត្តដោយល្អទៅបាននោះ លុះត្រាតែអភិបាលកិច្ចល្អនោះប្រព្រឹត្តឡើងក្នុងល័ក្ខខ័ណ្ឌដូចតទៅ :

១- នីត្យានុកូលភាព Legality

២- ការចូលរួម Participation

៣- គណនេយ្យភាព Accountability

៤- តម្លាភាព Transparency

នីត្យានុកូលភាព គឺសំដៅទៅលើភាពស្របច្បាប់នៃការដឹកនាំ។ បើនិយាយពីរដ្ឋាភិបាលវិញ នោះត្រូវកើតឡើងដោយស្របច្បាប់ ពោលគឺ កើតឡើងដោយការផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា ដែលកើតឡើងដោយការបោះឆ្នោតពីប្រជារាស្ត្រ។ ទាក់ទងនឹងការបោះឆ្នោត ដើម្បីឱ្យនីត្យានុកូលភាពនោះមានតម្លៃទៅបាន លុះត្រាតែការបោះឆ្នោតធ្វើឡើងដោយសេរី និងយុត្តិធម៌។

ការចូលរួម គឺជាគ្រឹះនៃអភិបាលកិច្ចល្អ ហើយក៏ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីផងដែរ។ ការចូលរួមនេះគឺកត្តាសំខាន់សំរាប់ការងាររបស់អំណាចនីតិប្រតិបត្តិ និងអំណាចនីតិប្បញ្ញត្តិ។ ការធ្វើច្បាប់របស់អំណាចនីតិប្បញ្ញត្តិ ត្រូវតែមានការចូលរួមផ្តល់មតិឱ្យបានច្រើន ពី

សំណាក់ប្រជារាស្ត្រ និងពីសំណាក់សង្គមស៊ីវិល។ ការផ្តល់មតិនេះមិនមែនបានចាំបាច់ទាល់តែជាមតិឬយោបល់នោះទេ តែយ៉ាងហោចក៏ជាការប្រមូលមតិនេះអាចនឹងប្រមូលបាននូវព័ត៌មាននិងបញ្ហាដែលកើតឡើងនៅក្នុងសង្គមច្បាស់លាស់ដែរ។ ចំពោះការងាររដ្ឋាភិបាលក៏ត្រូវមានការចូលរួមពីប្រជារាស្ត្រផងដែរ តែការចូលរួមនេះមិនមែនដូចជាការចូលរួមក្នុងការផ្តល់មតិដល់រដ្ឋសភានោះទេ ក៏ប៉ុន្តែមុននឹងធ្វើអ្វីមួយរដ្ឋាភិបាលក៏ត្រូវដឹងពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងមតិប្រជាពលរដ្ឋផងដែរ។

គណនេយ្យភាព គឺជាការទទួលខុសត្រូវចំពោះភារកិច្ច ឬកិច្ចការរបស់ខ្លួនដែលបានបំពេញ។ សមាជិកនៃអំណាចនីតិបញ្ញត្តិត្រូវទទួលខុសត្រូវក្នុងការធ្វើច្បាប់របស់ខ្លួន និងរិះរកមធ្យោបាយធ្វើយ៉ាងណាឱ្យការធ្វើច្បាប់នោះបានល្អ។ សមាជិកអំណាចនីតិប្រតិបត្តិត្រូវទទួលខុសត្រូវអនុវត្តច្បាប់ឱ្យបានល្អនិងធ្វើការឆ្លើយតបទៅនឹងសំណូមពររបស់ប្រជារាស្ត្រឱ្យបានជាអតិបរមា។ ចៅក្រមត្រូវធ្វើការកាត់សេចក្តីឱ្យស្របទៅតាមច្បាប់ និងធានាឱ្យបាននូវសេរីភាពរបស់ប្រជារាស្ត្រ ដែលធានាដោយច្បាប់រដ្ឋធម្មនុញ្ញ។ ទាក់ទងទៅនឹងលក្ខខណ្ឌនេះ យើងឃើញថា មានគោលការណ៍ខ្លះៗដែលត្រូវបំពេញ ដើម្បីធានាឱ្យបាននូវគណនេយ្យភាពនេះ។ គោលការណ៍ទាំងនោះមាន :

- **គោលការណ៍នៃការបែងចែកអំណាច** (Separation of Power): ស្ថាប័នរដ្ឋត្រូវបែងចែកជា៣ អំណាចនីតិប្រតិបត្តិ អំណាច

នីតិប្បញ្ញត្តិ និងអំណាចតុលាការ។ តាមគោលការណ៍នេះ អំណាចទាំងបីនេះត្រូវតែឯករាជ្យ ពោលគឺ មានន័យថា អំណាចនីមួយៗ មិនត្រូវរងការជ្រៀតជ្រែកពីអំណាចផ្សេងទៀតនោះទេ។

- **គោលការណ៍ត្រួតពិនិត្យទៅវិញទៅមកនិងតុល្យភាព** (Check and Balance): គ្រាន់តែមានការបែងចែកអំណាចទាំងបី មិនទាន់គ្រប់គ្រាន់នោះទេ អំណាចទាំងបីត្រូវការឱ្យមានអំណាចត្រួតពិនិត្យគ្នាទៅវិញទៅមកថែមទៀត។

- **នីត្យានុកូលភាព** (Rule of Law): នេះក៏ជាកត្តាមួយដែលនាំឱ្យមានគណនេយ្យភាពផងដែរ។ គោលការណ៍នេះ គឺដើម្បីការពារមិនឱ្យមានការគ្រប់គ្រង ដោយមនុស្សតែម្នាក់ឬមួយក្រុមពោលគឺគ្មាននរណាម្នាក់អាចនៅពីលើច្បាប់បានទេ។

តម្លាភាព គឺជាភាពមិនលាក់កំបាំង ធ្វើអ្វីដោយបើកចំហ។ សមាជជាតិ ដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញ ថាត្រូវតែរៀបចំម្តងជារៀងរាល់ឆ្នាំគឺជាសញ្ញានៃតម្លាភាព។

**អភិបាលកិច្ចល្អនិងយន្តការគ្រប់គ្រង** (Good Governance and Mechanism)

ដើម្បីធ្វើឱ្យអភិបាលកិច្ចល្អ អាចដំណើរការទៅបានល្អប្រសើរបាន គឺពឹងផ្អែកទៅលើយន្តការនៃអភិបាលកិច្ច ឱ្យបានល្អប្រសើរផងដែរ ដើម្បីធានាឱ្យបាននូវលក្ខណៈទាំង ៤ខាងលើ។

**ការបែងចែកអំណាច (Separation of Powers):**

ជាបឋម ការរៀបចំរចនាសម្ព័ន្ធរដ្ឋ ត្រូវឱ្យស្របទៅនឹងទ្រឹស្តីនៃការបែងចែកអំណាច (the theory of separation) ជាមុនសិន។ ស្ថាប័នរបស់រដ្ឋាភិបាលជាតិ ត្រូវបែងចែកជាបីមានឯករាជភាពដាច់ពីគ្នា ដោយមិនត្រូវមានការជ្រៀតជ្រែកគ្នាទៅវិញទៅមកនោះទេ ដោយគេយល់ថា អំណាចមិនត្រូវផ្តល់ទៅលើតែមួយកន្លែងនោះទេ។ អំណាចទាំងបីនោះគឺ : អំណាចនីតិបញ្ញត្តិ (Legislative Power), អំណាចនីតិប្រតិបត្តិ (Executive Power) និងអំណាចនីតិវិនិច្ឆ័យ (Judicial Power) (ឬអំណាចតុលាការ)។ អំណាចទាំងបីត្រូវអាចមើលគ្នាទៅវិញទៅមកក្នុងគោលបំណងធានាឱ្យបានថា ការងាររបស់អំណាចទាំងបីត្រឹមត្រូវទៅតាមគោលការណ៍ ដើម្បីប្រយោជន៍សង្គម។ គ្រាន់តែបែងចែកអំណាចជាបីប៉ុណ្ណោះ វាមិនទាន់គ្រប់គ្រាន់នោះទេ ដើម្បីការពារកុំឱ្យអំណាចនីមួយៗទោលតែឯង ដែលអាចទៅជាការធ្វើដោយអនាធិបតេយ្យនោះ អំណាចទាំងបីក៏មានអំណាចកែលំអគ្នាទៅវិញទៅមកដែរ ដែល គេហៅថា ការត្រួតពិនិត្យទៅវិញទៅមក និងតុល្យកម្ម (Checks and Balance)។ ឧទាហរណ៍ ប្រធានាធិបតីអាចមានសិទ្ធិតវ៉ានឹងការចេញច្បាប់របស់រដ្ឋសភា សភាមានសិទ្ធិកោះហៅ រដ្ឋាភិបាលទៅសាកសួរឬដេញដោលពីការប្រព្រឹត្តិណាមួយរបស់រដ្ឋាភិបាល ប្រធានាធិបតីឬព្រះរាជាមានសិទ្ធិលើកលែងទោសជាដើម។ល។ យោងទៅតាមមាត្រា ៥១ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា :

"*អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ*"។ ព្រះរាជាណាចក្រកម្ពុជា ក៏អនុវត្តទ្រឹស្តីនៃការបែងចែកអំណាចនេះដែរ ដែលជាគ្រឹះនៃគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី (សូមមើលបុព្វកថានិងមាត្រា៥១ រដ្ឋធម្មនុញ្ញ) ហើយនេះក៏ជាគ្រឹះនៃអភិបាលកិច្ចល្អផងដែរ។

ក្រៅពីគោលការណ៍នៃការបែងចែកអំណាចនេះ រដ្ឋធម្មនុញ្ញកម្ពុជា ក៏មានចែងពីកំលាំងត្រួតពិនិត្យរវាងអំណាចទាំងបីនេះផងដែរ ដូចជាៈ

- តំណាងរាស្ត្រមានសិទ្ធិដាក់សំនួរទៅរដ្ឋាភិបាល (ម.៩៦)។
- គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន (ម.៩៧)។
- រដ្ឋសភាអាចទម្លាក់ សមាជិកគណៈរដ្ឋមន្ត្រីឬទំលាក់រាជរដ្ឋាភិបាលពីតំណែង (ម.៩៨)។
- រដ្ឋសភាអាចនឹងត្រូវបានរំលាយមុនផុតអាណត្តិបាន ប្រសិនបើរាជរដ្ឋាភិបាល ត្រូវបានរំលាយពីរដងក្នុងរយៈពេល១២ខែ (ម.៧៨)។

តែទោះជាយ៉ាងណាយើងឃើញថា ថ្វីត្បិតតែរដ្ឋធម្មនុញ្ញខ្លួនឯងចែងច្បាស់ពីគោលការណ៍ នៃការបែងចែកអំណាចបែបនេះក៏ពិតមែនតែរដ្ឋធម្មនុញ្ញខ្លួនឯង បើកលទ្ធភាពឱ្យការបែងចែកអំណាចនេះទៅជាមិនច្បាស់លាស់ទៅវិញ ដោយអនុញ្ញាតឱ្យរដ្ឋមន្ត្រី ដែលជាអំណាចនីតិប្រតិបត្តិជ្រើសរើសចេញពីសមាជិកសភា ដែលជាអំណាចនីតិប្បញ្ញត្តិ ហើយនៅរក្សាតំណែងជាសមាជិកសភាដដែរ។

**ការមិនអាចដកដំណែងសមាជិកគណៈរដ្ឋមន្ត្រី :** ថ្វីត្បិតតែមាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា "*រដ្ឋសភា អាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី*" ក៏ពិតមែន ក៏ប៉ុន្តែក្នុង ប៉ុន្មានអាណត្តិនេះ រដ្ឋសភាមិនមានលទ្ធភាពនឹងអនុវត្តនូវអំណាចបានឡើយ ព្រោះថា រាជរដ្ឋាភិបាលកើតឡើងច្រើនដោយការធ្វើរដ្ឋាភិបាលចំរុះរវាងបក្ស ដែលមានសំលេងឆ្នោតច្រើនជាងគេពីរ ដូចនេះបើចង់រកសំលេងពីរភាគបី ដើម្បីទំលាក់សមាជិករាជរដ្ឋាភិបាលណានោះ លុះត្រាតែសមាជិកសភា នៃគណបក្សទាំងពីរដែលជាអ្នកទទួលខុសត្រូវរាជរដ្ឋាភិបាលយល់ព្រមផង។

**អំណាចនីតិប្រតិបត្តិ (Executive Power) :**

អំណាចនីតិប្រតិបត្តិគឺជាអំណាចដែលផ្តល់ឱ្យ ដើម្បីធ្វើយ៉ាងណាឱ្យច្បាប់ ដែលចេញពីអំណាចនីតិប្បញ្ញត្តិ ត្រូវអនុវត្តនិងគោរព។ អំណាចនេះដាច់ស្រឡះពី អំណាចនីតិប្បញ្ញត្តិនិងអំណាចនីតិវិនិច្ឆ័យ។ យោងទៅតាមមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ គណៈរដ្ឋមន្ត្រីគឺជារាជ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីគោរព និងធ្វើឱ្យមានការអនុវត្តចំពោះច្បាប់ដែលចេញមកពីអំណាចនីតិប្បញ្ញត្តិនោះ អំណាចនីតិប្រតិបត្តិក៏ត្រូវគោរពទៅតាមការសំរេចរបស់តុលាការដែរ។ អំណាចនីតិប្រតិបត្តិនេះគេអាចហៅបានថាជាអំណាចរដ្ឋបាល។ អំណាចនីតិប្រតិបត្តិទាំងអស់ ត្រូវបានផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ។

អំណាចនីតិប្បញ្ញត្តិ (Legislative Power):

គឺជាអំណាចនៃការធ្វើច្បាប់។ រដ្ឋសភា គឺជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ (ម.៩០រដ្ឋ)។ សមាជិករដ្ឋសភា គឺជាតំណាងរាស្ត្រគឺមានន័យថា ជាអ្នកតំណាងគំនិតនិងមតិរបស់ប្រជារាស្ត្រ នៅក្នុងមណ្ឌលរបស់ខ្លួន។ នេះគឺជាគ្រឹះនៃតម្លាភាពនិងការចូលរួម។ ពាក្យតំណាងរាស្ត្រខុសពីពាក្យតំណាងបុគ្គលខ្លួនឯង ដែលជាមនុស្សនិយាយអ្វីផ្អែកទាំងស្រុងទៅលើការគិត ការយល់ និងមតិផ្ទាល់ខ្លួនរបស់ខ្លួន ហើយក៏ខុសពីពាក្យតំណាងបក្សដែលមានន័យថា ជាមនុស្សនិយាយអ្វីគឺស្របទៅតាមគោលការណ៍ និងបញ្ជារបស់បក្សរបស់ខ្លួនផងដែរ។

អំណាចនីតិវិនិច្ឆ័យ (Judicial Power)

គឺជាអំណាចនៃការអនុវត្តន៍របស់តុលាការក្នុងការសំរេចវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនឱ្យតុលាការដោះស្រាយ។ អំណាចនេះ គឺមានតែចំពោះស្ថាប័នតុលាការតែប៉ុណ្ណោះ។ ដើម្បីឱ្យអំណាចនេះអាចនឹងមានលទ្ធភាពអនុវត្តនូវអំណាចរបស់ខ្លួននេះបាន លុះត្រាតែអំណាច

នេះឯករាជ្យនិងអព្យាក្រឹត ហើយចៅក្រមនីមួយៗត្រូវតែមានសមត្ថភាពឯករាជ្យនៃការសំរេចចិត្ត និងប្រកបទៅដោយគតិយុត្តិធម៌។ ខ្ញុំសូមប្រើពាក្យនីតិវិនិច្ឆ័យ ដើម្បីកុំឱ្យច្រឡំព្រោះថាសព្វថ្ងៃនេះ អយ្យការក៏គេចាត់ទុកជាចៅក្រម និងស្ថិតនៅក្នុងអំណាចតុលាការ ចៅក្រមស៊ើបអង្កេតក្រឡាបញ្ជី និងនគរបាលយុត្តិធម៌ក៏គេយល់ថាស្ថិតនៅក្នុងអំណាចតុលាការផងដែរ។ នីតិវិនិច្ឆ័យ គឺសំដៅទៅលើអំណាចសំរេចលើរឿងក្តី។ នគរបាល ក្រឡាបញ្ជី អយ្យការ និងចៅក្រមស៊ើបអង្កេតគ្មានអំណាចនឹងសំរេចថា នរណាម្នាក់មានទោស និងត្រូវដាក់ទោសប៉ុណ្ណោះដែរ គឺមានតែចៅក្រមជំរះតែម្នាក់ប៉ុណ្ណោះ ដែលមានអំណាចសំរេចបែបនេះ។

ព្រះមហាក្សត្រ ជាអ្នកធានានូវឯករាជភាពរបស់តុលាការដោយមានជំនួយពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម (ម.១៣២ នៃរដ្ឋធម្មនុញ្ញ)។ ដោយសារឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នកំពូលដែលជាអ្នកពិនិត្យទៅលើសីលធម៌ដាក់វិន័យទៅលើចៅក្រមនិងជាអ្នកជួយដល់ព្រះមហាក្សត្រ ក្នុងការធានានូវឯករាជភាពរបស់តុលាការនោះជាការចាំបាច់ណាស់ ដែលសមាជិកនៃឧត្តមក្រុមប្រឹក្សានេះ មិនត្រូវមកពីអំណាចនីតិប្បញ្ញត្តិនោះទេ ហើយត្រូវមានអគ្គលេខាធិការដ្ឋានមួយនិងថវិកាស្វ័យត្រ។

មន្ត្រីរាជការត្រូវតែអព្យាក្រឹត (Bureaucracy shall be neutral)

ដើម្បីឱ្យការងាររដ្ឋ អាចដំណើរការទៅបានប្រសើរ និងស្រប ទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងមានគុណនេយ្យភាព ផងនោះ ជាការចាំបាច់ណាស់ ដែលមន្ត្រីរាជការទាំងឡាយ ដែលជា មន្ត្រីសាធារណៈត្រូវតែបំពេញតួនាទី ប្រកបដោយវិជ្ជាជីវៈ និងក្នុងជំហរ អព្យាក្រឹត។ មន្ត្រីរាជការនេះរាប់បញ្ចូលផង ទាំងកងកំលាំងនគរបាល និងមន្ត្រីតុលាការ។ នៅប្រទេសអាស៊ីខ្លះ ចៅក្រម មន្ត្រីរាជការនិង នគរបាល ច្បាប់បញ្ជាក់ច្បាស់ថា មិនត្រូវជាសមាជិករបស់គណបក្ស នយោបាយណាមួយទេ ការធ្វើបែបនេះ ដើម្បីឱ្យជនទាំងនោះធ្វើការ របស់គេដោយមិនគិតលំអៀងទៅរកគណបក្សណា ពោលគឺប្រកាន់តែ ទៅលើវិជ្ជាជីវៈនិយមរបស់គេតែប៉ុណ្ណោះ។

កំលាំងប្រដាប់អាវុធ (Armed Forces)

យើងឃើញថា ប្រទេសដែលមានអ្នកដឹកនាំ ឬអ្នកគណបក្ស នយោបាយដែលមានកងទ័ពគាំទ្រច្រើន តែមិនយូរមិនឆាប់នឹងឈាន ទៅរករបបផ្ដាច់ការ។ យោងទៅតាមបទពិសោធន៍នៅកូរ៉េខាងត្បូងជា ការប្រសើរអ្នកដឹកនាំ ឬ អ្នកនយោបាយមិនត្រូវមានការគាំទ្រ ឬមាន អំណាចទៅលើកងទ័ពពេកនោះទេ។ ហេតុដូចនេះ ហើយមានអ្នក វិភាគច្រើនបានយល់ថា ដើម្បីធានាឱ្យបាននូវនិរន្តរភាព នៃលទ្ធិប្រជា

ធិបតេយ្យនោះ ជាការចាំបាច់ណាស់ ដែលកងកំលាំងប្រដាប់អាវុធ មានយោធា និងនគរបាលត្រូវតែអព្យាក្រឹត។

ក្រុមឯករាជ្យ (Independent Bodies):

យោងទៅតាមការពិសោធន៍ នៅប្រទេសលទ្ធិប្រជាធិបតេយ្យជាច្រើន ការគ្រាន់តែមានការបែងចែកអំណាចរវាងស្ថាប័នរដ្ឋនោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺត្រូវមានពួកឯករាជ្យមួយចំនួនទៀត ដែលមានភារកិច្ចត្រួតពិនិត្យលើការងាររបស់ស្ថាប័នទាំងបីនោះ។ ស្ថាប័នទាំងនោះចាំបាច់ត្រូវតែអព្យាក្រឹត និងឯករាជ្យហើយមានយន្តការការងារច្បាស់លាស់ និងមានអំណាចនឹងប្រតិបត្តិការ ការងាររបស់គេ។ ក្រុមឯករាជ្យនេះមានច្រើនបែប និងប្លែកៗតាមប្រទេសនីមួយៗដូចជា៖

១- សមាជជាតិ (National Conngress): យោងទៅតាមមាត្រា១៤៧ នៃរដ្ឋធម្មនុញ្ញរាជរដ្ឋាភិបាលកម្ពុជា ត្រូវរៀបចំឱ្យមានសមាជជាតិជារៀងរាល់ឆ្នាំ។ ក្នុងឱកាសសមាជជាតិនេះ ប្រជានុរាស្ត្រអាចនឹងសុំឱ្យរាជរដ្ឋាភិបាលឆ្លើយបំភ្លឺនូវសកម្មភាពរបស់ខ្លួន ធ្វើសំណូមពរឱ្យរាជរដ្ឋាភិបាលជួយដោះស្រាយ និងសូមឱ្យរាជរដ្ឋាភិបាលរៀបរាប់ពីគំរោងផែនការទៅថ្ងៃមុខ លើកលែងតែផែនការណាដែលពាក់ព័ន្ធដល់សន្តិសុខជាតិ។ នេះគឺជាលទ្ធិប្រជាធិបតេយ្យដោយផ្ទាល់និងជាគ្រឹះតម្លាភាព និងជាការធានាដល់សិទ្ធិទទួលពត៌មាន និងបញ្ចេញមតិ ដែលកម្រប្រទេសណារៀបចំឱ្យមានបែបនេះណាស់។ តែមក

ដល់ពេលនេះរាជរដ្ឋាភិបាលទាំងពីរ អាណត្តិមិនទាន់បានរៀបចំសមាជជាតិនេះម្តងនៅឡើយទេ។

២. ក្រុមប្រឹក្សាធម្មនុញ្ញឬតុលាការធម្មនុញ្ញ (Constitutional Council or Constitutional Courts): ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលដែលមានអំណាចធ្វើការបកស្រាយច្បាប់។ នៅប្រទេសប្រជាធិបតេយ្យជាច្រើន ក្រុមប្រឹក្សានេះ ជាស្ថាប័នឯករាជ្យសំរាប់ត្រួតពិនិត្យទង្វើរបស់ស្ថាប័នកំពូលទាំងបី ដែលជាគ្រឹះជំរុញឱ្យរដ្ឋាភិបាលមានគណនេយ្យភាព។ ប្រទេសយើងមានក្រុមប្រឹក្សាធម្មនុញ្ញមួយដែរ តែនៅមិនទាន់ដំណើរការ ដោយប្រសិទ្ធិភាពនៅឡើយទេ ហើយក៏មិនទាន់ឯករាជ្យនៅឡើយដែរ ដោយសារសមាសភាពនៅមាននិន្នាការនយោបាយនៅឡើយ ហើយនីតិវិធីនៃការដាក់បណ្តឹងចូល ទៅក្រុមប្រឹក្សានេះនៅមានលក្ខណៈចង្អៀត និងនៅមានការញញើត ក្នុងការប្រឈមនឹងការដោះស្រាយបញ្ហាធំៗដែលអាចពាក់ព័ន្ធនឹងរឿងនយោបាយទៀតផង។ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញរបស់យើងមិនទាន់ចាត់ជាក្រុមឯករាជ្យ និងជួយដល់រដ្ឋាភិបាលឱ្យមានគណនេយ្យភាពនៅឡើយទេ។

៣. គណៈកម្មាធិការសិទ្ធិមនុស្សឯករាជ្យ (Independent Human Rights Commission): សព្វថ្ងៃ នៅប្រទេសយើងមានគណៈកម្មាធិការសិទ្ធិមនុស្សដល់ទៅបី តែសុទ្ធតែមិនឯករាជ្យ ហើយហាក់ដូចជា

មិនទាន់មាននាទីសកម្មក្នុងការគាស់កកាយរឿងរំលោភសិទ្ធិមនុស្ស ដើម្បីជំរុញឱ្យរដ្ឋាភិបាលដោះស្រាយនោះទេ។ នៅប្រទេសសេរីលង្កា គណៈកម្មាធិការសិទ្ធិមនុស្សរបស់គេ បានធ្វើការយ៉ាងមានប្រសិទ្ធភាព។ ថ្វីត្បិតតែជាការបង្កើតដោយរដ្ឋាភិបាល ក៏ពិតមែន តែគេយល់ពីសិទ្ធិមនុស្ស និងធ្វើការកែលំអការគោរពសិទ្ធិមនុស្សនៅស្រុកគេ។ តែទោះជាយ៉ាងណាបញ្ហានេះវាទាក់ទិនខ្លាំងទៅលើឆន្ទៈនយោបាយ។ ប្រសិនបើគណៈកម្មាធិការនេះ អាចទៅជាឯករាជ្យ និងមានអំណាចគ្រប់គ្រាន់ ដើម្បីអាចនឹងបំពេញកិច្ចការរបស់ខ្លួន ដោយមានប្រសិទ្ធភាពនោះ គណៈកម្មាធិការនេះ ដែលទោះជាមានតែមួយក៏ដោយ អាចនឹងជំរុញឱ្យមានគណនេយ្យ ដែលជាកត្តាមួយដ៏សំខាន់ដល់អភិបាលកិច្ចល្អ។

៤_ គណៈកម្មាធិការប្រឆាំង និងអំពើពុករលួយ (Independent Commission on Anti-Corruption): គណៈកម្មាធិការប្រឆាំងនឹងអំពើពុករលួយ នៅទីក្រុងហុងកុង បានបំពេញកិច្ចការបង្ក្រាបអំពើពុករលួយយ៉ាងជោគជ័យ។ ជាការសំខាន់ណាស់ ដែលត្រូវមានយន្តការនេះ បើពុំដូច្នោះទេ ទោះជាមានទណ្ឌកម្មធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏នឹងមិនមានជនពុករលួយធំៗណានឹងត្រូវបញ្ជូនទៅកាត់ទោសដែរ។ ប្រទេសយើងទើបតែត្រូវរដ្ឋាភិបាល សហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ធ្វើសេចក្តីព្រាងច្បាប់ ស្តីពី ការប្រឆាំងអំពើពុករលួយ ដែលមានចែងពីគណៈកម្មាធិការនេះ តែ

នៅមានទស្សនៈបី (១)_គួរបង្កើតតុលាការអំពើពុករលួយ (២)_បង្កើត គណៈកម្មាធិការប្រឆាំងអំពើពុករលួយ តាមបែបប្រទេសហុងកុងនិង(៣)_បង្កើតទាំងតុលាការ និងគណៈកម្មាធិការប្រទេសប្រឆាំងអំពើ ពុករលួយតាមបមាណើយហុងកុង។ យោងទៅតាមឧទាហរណ៍ នៅក្រុងហុងកុងគណៈកម្មាធិការនេះ គឺជាយន្តការមួយ ដែលជួយឱ្យមានគណនេយ្យភាពក្នុងកិច្ចការរដ្ឋ។

៥_ គណៈកម្មាធិការឯករាជ្យជាតិ រៀបចំការបោះឆ្នោត (National Election Committee): គណៈកម្មាធិការរៀបចំ ការបោះឆ្នោត ក៏គេត្រូវការឱ្យស្ថានប័ននេះ គឺជាអាជ្ញាកណ្ដាលសំរាប់កាត់សេចក្ដីការប្រកួតបោះឆ្នោតរវាងគណបក្សនយោបាយជាច្រើន ដូចនេះលុះត្រាតែអាជ្ញាកណ្ដាលនេះមិនលំអៀងទៅខាងណាមួយ និងធ្វើឱ្យមានការទុកចិត្តពីភាគីប្រកួតនិងអ្នកមើល (ប្រជាពលរដ្ឋ)ផង ទើបលទ្ធផលនៃការបោះឆ្នោតនោះ ត្រូវបានគោរព និងទទួលយកពីភាគីពាក់ព័ន្ធទាំងឡាយ។ នៅប្រទេសហ្វីលីពីន គណៈកម្មាធិការនេះឯករាជ្យ ហើយមានបទពិសោធន៍ខ្ពស់តែគណៈកម្មាធិការរៀបចំការបោះឆ្នោតរបស់ប្រទេសយើងនៅ មានលក្ខណៈនយោបាយភាគច្រើន និងមិនទាន់មានបទពិសោធន៍ ច្រើននៅឡើយទេ។ គណៈកម្មាធិការនេះអាចជួយឱ្យមានតម្លាភាពក្នុងការជ្រើសរើសអ្នកដឹកនាំ និងជួយឱ្យរដ្ឋាភិបាលមាននីត្យានុកូលភាពពេញលេញ។

៦. គណៈកម្មាធិការពត៌មានផ្លូវការ (Independent Official Information Commission): គណៈកម្មាធិការពតិមានផ្លូវការមានជាលើកដំបូងនៅប្រទេសថៃ។ គណៈកម្មាធិការនេះ កើតឡើងក្រោយពេលដែលប្រទេសថៃ អនុម័តនូវច្បាប់មួយ ស្ដីអំពី ពតិមានផ្លូវការ (Official Information) ដែលអនុញ្ញាតឱ្យប្រជារាស្ត្រថៃទាំងឡាយអាចនឹងសុំពតិមាន និងឯកសារផ្លូវការផ្សេងៗរបស់រដ្ឋាភិបាល លើកលែងតែពតិមានពាក់ព័ន្ធនឹងសន្តិសុខឬរបៀបរៀបរយសាធារណៈ។ ក្នុងករណីដែលមានវិវាទរវាងរដ្ឋាភិបាល និងប្រជារាស្ត្រ អ្នកសុំពតិមានណាមួយនោះ គឺបណ្ដឹងត្រូវបញ្ជូនទៅគណៈកម្មាធិការនេះដើម្បីសំរេច។ ការសំរេចរបស់គណៈកម្មាធិការនេះក៏មានប្រសិទ្ធភាព ដូចជាការសំរេចរបស់តុលាការរដ្ឋបាលផងដែរ។ វត្តមាននៃច្បាប់ស្ដីអំពីពតិមានផ្លូវការ និងគណៈកម្មាធិការពតិមានផ្លូវការនេះជាកត្តាជំរុញ និងជាយន្តការនាំឱ្យមានតម្លាភាព និងកាត់បន្ថយឱកាសពុករលួយក្នុងជួរស្ថាប័នរដ្ឋាភិបាលបាន។

៧. អយ្យការប្រជាជន (Ombudsmen): មានប្រទេសជាច្រើនមិនថាប្រព័ន្ធច្បាប់អង់គ្លោសាក់សុង ឬប្រព័ន្ធអឺរ៉ុបនោះទេ គេមានបង្កើតឱ្យមានអយ្យការប្រជាជននេះឡើង ដើម្បីពង្រឹងគណនេយ្យភាពរបស់រដ្ឋាភិបាល។ ស្ថាប័នមានមុខនាទី ជាអយ្យការធ្វើការចោទប្រកាន់មន្ត្រីរាជការ ដែលជាប់ចោទឬចោទប្រកាន់រឿងក្ដីណាដែលស្ថាប័នអយ្យការរដ្ឋមិនធ្វើការចោទប្រកាន់ ហើយប្ដឹងមិនសុខចិត្ត

ពីប្រជាពលរដ្ឋ។ នៅប្រទេសថៃ ក្នុងករណីដែលជនជាប់ចោទជាមន្ត្រីរាជការ ស្ថាប័នអយ្យការនឹងក្លាយទៅជាមេធាវីរបស់មន្ត្រីដែលជាប់ចោទនោះ ហើយស្ថាប័នអយ្យការប្រជាជននឹងក្លាយទៅជាស្ថាប័នចោទប្រកាន់លើមន្ត្រីនោះវិញ។ គេធ្វើបែបនេះ ព្រោះគេយល់ថា ស្ថាប័នអយ្យការ ដែលធ្វើការជាប់រាល់ថ្ងៃជាមួយនឹងនគរបាលឬមន្ត្រីរាជការ មិនអាចនឹងធ្វើការចោទប្រកាន់អ្នកដែលខ្លួនធ្វើការទាក់ទងរាល់ថ្ងៃដោយប្រសិទ្ធិភាពនោះទេ។ ការធ្វើបែបនេះគឺដើម្បីឱ្យការចោទប្រកាន់ច្បាស់លាស់ មានគុណនេយ្យភាព និងមានតម្លាភាពផង។

៨. សារពត៌មាន (Newspapers): កន្លងមក យើងតែងតែចាត់ទុកថាសារពត៌មាន ជាអំណាចទី៤បន្ទាប់ពីអំណាចនីតិទាំងបី។ ក៏ប៉ុន្តែដោយសារតែភាពលំអៀងរបស់សារពត៌មានកន្លងមក បានធ្វើឱ្យអំណាចរបស់សារពត៌មានត្រូវថមថយ ហើយប្រជាពលរដ្ឋអ្នកអានក៏មិនសូវជាទុកចិត្ត និងឱ្យតំលៃទៅលើសារពត៌មានភាគច្រើនដែរ។ ដូចនេះ ជាការចាំបាច់ណាស់ ដែលសារពត៌មានកម្ពុជាត្រូវតែពង្រឹង ជាពិសេសរក្សាឯករាជភាព តម្លៃពត៌មាន និងសីលធម៌របស់ខ្លួន ដើម្បីក្លាយជាកម្លាំងទី៤ពិតប្រាកដ។ ប្រសិនបើសារពត៌មាន មានសមត្ថភាពខ្ពស់ និងជាកម្លាំងទី៤ពិតប្រាកដនោះសារពត៌មាននឹងក្លាយជាកម្លាំងចលករមួយយ៉ាងខ្លាំងក្លា ជួយឱ្យមាន

តម្លាភាព គណនេយ្យភាព និងការចូលរួមដ៏ខ្លាំងក្លាពីសំណាក់ប្រជានុរាស្ត្រ។

៩. អង្គការក្រៅរដ្ឋាភិបាល (Non-governmental Organizations): ក្រុមអង្គការក្រៅរដ្ឋាភិបាល ទើបតែនឹងចាប់មាននៅឆ្នាំ ១៩៩៣ ក្រោយអ៊ុនតាក់ចូលមកកម្ពុជាតែប៉ុណ្ណោះ តែក្រុមនេះមានជឿនលឿនយ៉ាងខ្លាំង ជាពិសេសគឺដោយសារតែ ឯករាជភាព ភាពមិនលំអៀង និងសមត្ថភាពរបស់ក្រុមទាំងនេះតែម្តង ដែលធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលភាគច្រើន ទទួលបាននូវការកោតសរសើរ និងការគោរពពីសំណាក់ប្រជាពលរដ្ឋក៏ដូចជារដ្ឋាភិបាល។ សព្វថ្ងៃនេះយើងឃើញថា អង្គការក្រៅរដ្ឋាភិបាលបានជួយជំរុញគ្រប់ផ្នែកទាំងជួយឱ្យមាននីត្យានុកូលភាព ការចូលរួមតម្លាភាព និងគណនេយ្យភាព ដែលជាលទ្ធផលគឺធ្វើឱ្យមានអភិបាលកិច្ចល្អ។

**អភិបាលកិច្ចល្អលើដំណើរអភិវឌ្ឍន៍ (Good Governance on Development):**

ដូចជាបានលើកឡើងមកហើយ អភិបាលកិច្ចល្អ គឺជាការគ្រប់គ្រង ឬប្រើប្រាស់ធនធានដោយមានប្រសិទ្ធិភាព ហើយដោយគ្មានបញ្ហាឬដោយពេញចិត្តពីសមាជិកគ្រប់រូប។ ក្នុងការងារអភិវឌ្ឍន៍មិនមែនជាការអភិវឌ្ឍន៍ ឬធ្វើឱ្យតែមនុស្សមួយក្តាប់តូចមានជីវភាពធូរធារដោយទុកឱ្យមានមនុស្សភាគច្រើនផ្សេងទៀត នៅតែក្រីក្រ ឬជួបការលំបាកនោះទេ។ ការអភិវឌ្ឍន៍គឺសំដៅធ្វើឱ្យប្រជាពលរដ្ឋ ភាគច្រើនមានការ

លើកកំពស់ផ្នែកជីវភាព និងសេដ្ឋកិច្ច។ ដូចនេះប្រសិនបើមានការរីកចំរើនសេដ្ឋកិច្ចឬអភិវឌ្ឍន៍តែទីក្រុង ក៏ប៉ុន្តែមិនមានការកាត់បន្ថយនូវភាពក្រីក្រទេនោះ នោះក៏មិនអាចចាត់ទុកថា ជាអភិបាលកិច្ចល្អបានដែរ។




## សេចក្តីសន្និដ្ឋាន (Conclusion) :

ជាការប្រសើរណាស់ ដែលរាជរដ្ឋាភិបាលមានការចាប់អារម្មណ៏លើការធ្វើយ៉ាងណាឱ្យមានអភិបាលកិច្ចល្អ។ ដើម្បីអាចឱ្យមានអភិបាលកិច្ចល្អទៅបាន លុះត្រាតែការគ្រប់គ្រងរដ្ឋធ្វើយ៉ាងណាឱ្យស្របទៅនឹងលក្ខខណ្ឌនីត្យានុកូលភាព ភាពចូលរួម គណនេយ្យភាព និងតម្លាភាព។ ដើម្បីឱ្យលក្ខខណ្ឌទាំង ៤ អាចនឹងសំរេចទៅបាននោះ

លុះត្រាតែមានយន្តការដ៏ត្រឹមត្រូវមួយ ដើម្បីធ្វើឱ្យប្រព័ន្ធគ្រប់គ្រងអាចដំណើរការទៅបាន។ យន្តការនោះត្រូវបង្កើតឡើង ដោយគោរពនូវគោលការណ៍បែងចែកអំណាច ដោយមានអំណាចត្រួតពិនិត្យ និងតុល្យាកម្មកម្លាំងសាធារណៈត្រូវបំពេញកិច្ចការរបស់ខ្លួនដោយអព្យាក្រឹតឈរលើសីលធម៌វិជ្ជាជីវៈ និងមានកម្លាំងឯករាជ្យអព្យាក្រឹតជួយពិនិត្យខាងក្រៅផង។

ទាំងនេះជាគោលដៅដែលកម្ពុជា ត្រូវតែតម្រង់ទិសទៅរកគោលដៅទាំងនេះ ដើម្បីធានាឱ្យបាននូវអភិបាលកិច្ចល្អ ប្រកបដោយគោលការណ៍លទ្ធិប្រជាធិបតេយ្យ៕

# យន្តការអភិបាលកិច្ចល្អ



## ៦.៧_សុន្ទរកថាថ្លែងដោយ លោកស្រី ប្រ៊ូក ឡាន្នី នាយិកាប្រតិបត្តិ អង្គការខេមរាស្ត្រីអំពី"ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធាន ពត៌មាន បទពិសោធន៍ និងក្តីបារម្ភ"

បណ្តាញការងារ : ជាប្រព័ន្ធទំនាក់ទំនងសហការគ្នាទៅវិញទៅមក ក្នុងការងារចែកចាយបទពិសោធន៍ពត៌មានផ្សេងៗ ដំណឹងសំខាន់ៗដែលអាចរៀនសូត្រអាចជាកម្លាំង ជាការជួយគាំទ្រជាស្មារតីឬមធ្យោបាយផ្សេងៗដែលអាចធ្វើបាន ដើម្បីឱ្យបានសំរេចលទ្ធផលការងារ។

ការកសាងបណ្តាញការងារ :

១_ តើយើងគួររៀបចំបណ្តាញការងារយ៉ាងណា?

- គួររៀបចំទៅតាម វិស័យ ឧទាហរណ៍: សុខភាព បរិស្ថាន កសិកម្ម ។ល។
- គួរជាក្រុមអង្គការដែលមានកម្មវិធីប្រហាក់ប្រហែលគ្នា ឧទាហរណ៍ : កម្មវិធីស្ត្រី កម្មវិធីសិទ្ធិមនុស្ស ។ល។
- គួរផ្អែកលើភូមិសាស្ត្រ ឧទាហរណ៍ : ក្រុមបណ្តាញនៃអង្គការដែលមានកម្មវិធី នៅទីក្រុងភ្នំពេញ ក្រុមអង្គការនៅខេត្តបាត់ដំបង ។ល។

២_ តើហេតុអ្វីបានជាយើងត្រូវមានបណ្តាញការងារ?

- អាចមានភាពងាយស្រួល ក្នុងការផ្តល់ដំណឹងទៅវិញទៅមក យើងមិនចាំបាច់ធ្វើផ្ទាល់ នៅគ្រប់កន្លែងទាំងអស់នោះទេ។
- អាចជាកម្លាំងរឹងមាំសំរាប់ផ្តល់សម្លេងសំរាប់ជួយដំណើរការងារគ្នាទៅវិញទៅមកដែលអាចនឹងធ្វើទៅបាន។
- អាចជាការរួបរួមគ្នា បង្ហាញស្មារតីសាមគ្គីភាពលើការងាររួមគ្នា

៣_ តើអ្នកណាអាចជាសមាជិករបស់បណ្តាញយើង?

- អាចជាបុគ្គលដែលមានបំណងចូលរួម ដែលជាបុគ្គលិករបស់អង្គការក្រុមការងារឬបុគ្គលខ្លួនឯងផ្ទាល់ ឧទាហរណ៍: ក្រុមការងារ ដើម្បីដោះស្រាយទំនាស់ ដែលមានសមាជិកមកពីសាលាក្រុងភ្នំពេញ អស់លោក លោកស្រី មួយចំនួនមកពីអង្គការផ្សេងៗ និងអស់លោកមកពីក្រសួងនានា ដែលជាសិក្ខាកាមនៃវគ្គដោះស្រាយទំនាស់ ដែលរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា មជ្ឈមណ្ឌលកម្ពុជា ដើម្បីដោះស្រាយទំនាស់។
- អាចជាក្រុម ជាអង្គការ ជាស្ថាប័នដែលពាក់ព័ន្ធ។

៤_ តើប្រធានបទ ឬ រឿងរ៉ាវបែបណា ដែលគួរត្រូវរៀបចំឱ្យមានបណ្តាញការងារ?

- គួរជាប្រធានបទ ឬរឿងរ៉ាវដែលពាក់ព័ន្ធទៅនឹងសន្តិសុខរបស់តំបន់ស្រុក ខេត្ត ឬប្រទេស។ ឧទាហរណ៍: ក្រុមការងារកាត់

បន្ថយអាវុធ កម្មវិធីនេះ ជាកម្មវិធីទូទាំងប្រទេស។ ដូចនេះ បណ្តាញការងារ ក៏គួររៀបចំឱ្យមានដល់ខេត្ត។ កម្មវិធីបែបនេះ អ្នកណាស្ថាប័នណា ក៏ចូលរួមធ្វើជាសមាជិកបានដែរ ឱ្យតែគេមានបំណងចង់ចូលរួម។

- គួរជាប្រធានបទ រឿងរ៉ាវដែលទាក់ទិននឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន។
- ឧទាហរណ៍: ក្រុមការងារកម្មវិធីរបស់សហគមន៍ទីក្រុង ប៉ុន្តែបណ្តាញការងារនេះរៀបចំសំរាប់តែអង្គការ ដែលធ្វើការងារក្នុងទីក្រុងប៉ុណ្ណោះ។
- គួរជាប្រធានបទ រឿងរ៉ាវដែលទាក់ទិននឹងស្ថានភាពស្ត្រី ។
- ឧទាហរណ៍: ក្នុងបណ្តាញការងារស្ត្រី "ក្រុមប្រឹក្សាជាតិនៃអង្គការស្ត្រីកម្ពុជា" ក្រុមការងារបែបនេះរៀបចំឡើងតែសំរាប់ស្ត្រី ហើយក៏មិនអនុញ្ញាតឱ្យបុរសចូលជាសមាជិកទេ ។ល។
- រឿងរ៉ាវឬប្រធានបទ ដែលបានរៀបរាប់ខាងលើជារឿងរ៉ាវ ឬប្រធានបទខ្លះៗ តែប៉ុណ្ណោះ អាចមានច្រើនជាងនេះទៀតអាស្រ័យទៅតាមអង្គការ ឬក្រុមផ្សេងៗ ដែលគេមានបំណងចង់បង្កើតសំរាប់ហេតុផលសមរម្យណាមួយរបស់ក្រុម។

៥_ តើពេលណាដែលយើងត្រូវចាប់ផ្តើមឱ្យមាន?

- អាចកកើតឡើងដោយការចូលរួមប្រជុំជាមួយគ្នាពីដំបូង។

- អាចជាការចប់វគ្គសិក្ខាសាលាឬវគ្គហ្វឹកហ្វឺនណាមួយ។

ឧទាហរណ៍ : បណ្ដាញការងារ នៃក្រុមអំពើហិង្សាលើស្ត្រីភេទនៃបណ្ដាប្រទេសតាមដងទន្លេមេគង្គ

៦_ តើគួរត្រូវជ្រើសរើសកន្លែងណាជាកន្លែងសំរាប់ប្រជុំ?

- អាចនៅកន្លែងណាមួយប្រាកដ មិនមានការផ្លាស់ប្ដូរ។
- អាចប្ដូរទៅតាមកន្លែងណាមួយដ៏សមគួរ ដែលមានការយល់ព្រមពីអង្គប្រជុំឬពីសមាជិកក្រុមការងារ។

បនពិសោធន៍

✍ **ចំណុចល្អ :**

- បណ្ដាញក្រុមការងារ ដែលរៀបចំឡើងតាមការឯកភាពយល់ព្រមពីសាមីខ្លួន ហើយដែលខ្លួនឯងផ្ទាល់មានឆន្ទៈនឹងចូលរួម និងបរិច្ចាកពេលវេលាសំរាប់មកចូលរួមជាមួយក្រុមផងដែរ។
- បើសិនជាសមាជិក នៃក្រុមការងារ ពេលដែលបានទទួលពត៌មានឬក៏ទទួល លិខិតអញ្ជើញណាមួយរបស់ប្រធានក្រុម ឬសមាជិកណាមួយ។ យើងគួរផ្ដល់ត្រឡប់ឱ្យគេដឹងថា យើងបានទទួលពត៌ហើយ និងបញ្ជាក់ថា "អាចទៅចូលរួមឬមិនអាច" បើធ្វើបែបនេះគឺជាការល្អបំផុត។

- បើសិនយើងជាប្រធានក្រុមបណ្ដាញ ក៏គួរត្រូវផ្ដល់ពត៌មានឱ្យសមាជិកមុនពេលប្រជុំ ឬក៏ព្យាយាមទាក់ទងផ្ដល់ពត៌មានឱ្យសមាជិកជាប់ជាប្រចាំផង។ បើមិនដូច្នោះទេ បណ្ដាញការងារនឹងត្រូវចាប់ផ្ដើមបាត់ជាបណ្ដើរៗជាក់ជាមិនខាន។ ជាប្រធានក្រុមការងារ ក៏គួររៀបចំគំរោងការងារណាមួយដែល ត្រូវតែឱ្យមានដំណើរការជាប់ជាលំដាប់ផងដែរ ឬក៏លើកផែនការការងាររួមគ្នាជាមួយសមាជិក និងកំណត់ថ្ងៃប្រជុំ ឬថ្ងៃចុះសកម្មភាពការងាររួមគ្នាឱ្យហើយ ប៉ុន្ដែ ត្រូវតែផ្ដល់ពត៌មានរំលឹកដែរមុនពេលអនុវត្តការងារ។ ការថែរក្សាបណ្ដាញការងារគឺជាការងារមួយសំខាន់ណាស់ ព្រោះថា បើបណ្ដាញការងារកើតមានឡើង តែក្នុងករណីចាំបាច់ណាមួយតែប៉ុណ្ណោះទេនោះដូចជាមិនគួររៀបឱ្យមានសោះឡើយ។

- ការបង្កើតបណ្ដាញវាជាកិច្ចការមួយមិនលំបាកខ្លាំងក្លា ដូចគ្នានឹងការថែទាំបណ្ដាញឱ្យមានស្ថេរភាពជាប់ជាលំដាប់នោះទេ។ តាមបទពិសោធន៍ ការរក្សាបណ្ដាញឱ្យនៅឋិតថេរ មានការទាក់ទងនឹងពីចំណុច :

  - បុគ្គលខ្លួនឯង ស្ម័គ្រចិត្តចូលរួមធ្វើជាសមាជិកក្រុមបណ្ដាញការងារដោយឆន្ទៈផ្ទាល់ និងមានការប្ដេជ្ញាចិត្តខ្ពស់
  - បុគ្គលដែលមានការគាំទ្រ ពីសាមីអង្គការដែលបានយល់ព្រមអនុញ្ញាតឱ្យបុគ្គលរបស់ខ្លួនចូលរួមប្រជុំឬធ្វើសកម្មភាព

ផ្សេងៗ ជាមួយក្រុមនោះ ដំណើរការងារបណ្ដាញមានប្រសិទ្ធភាពដែរ។ ប៉ុន្តែ ពេលដែលប្រធាននៃសាមីអង្គការមិនយល់ព្រម ហើយសាមីខ្លួនផ្ទាល់មិនសូវមានការចាប់អារម្មណ៍លើការងារនោះដែរ បណ្ដាញការងារនេះក៏ចាប់ផ្ដើមបាត់បន្តិចម្ដងៗដែរ។

## ✍ ចំណុចកង្វល់

- ទស្សនៈដែលគិតប្រយោជន៍ផ្ទាល់ខ្លួន ធំជាងផលប្រយោជន៍របស់បណ្ដាញ។ ឧទាហរណ៍ៈ ការចូលជាសមាជិកបណ្ដាញដើម្បីទាមទាររកប្រយោជន៍ រកលាភសក្ការៈ ដែលបុគ្គលខ្លួនផ្ទាល់រំពឹងថា អាត្មាខ្លួននឹងបានទទួលនាពេលខាងមុខ។ ប៉ុន្តែផ្ទុយទៅវិញ ពេលដែលមិនបានដូចការប៉ងទុកនោះ ជួនកាលបុគ្គលបែបនេះចូលរួមប្រជុំសំរាប់ជាការរំខាន និងរាំងស្ទះអង្គប្រជុំទៀតផង។

- ការរៀបចំឱ្យមានបណ្ដាញជាការមួយល្អណាស់ ប៉ុន្តែការដែលបារម្ភគឺការដែលធ្វើឱ្យសង្គមកម្ពុជាទាំងមូលយល់ថា "បណ្ដាញការងាររបស់សង្គមស៊ីវិលរៀបចំឡើង សំរាប់ពង្រឹងការងារបង្កើនការយល់ដឹង ធ្វើឱ្យមានភាពជឿនលឿនភាពរីកចំរើននៃសង្គមស៊ីវិល "។ មានមតិមួយចំនួនបានយល់ថា បណ្ដាញការងាររបស់សង្គមស៊ីវិល គឺជាក្រុមដែលធ្វើឡើងដើម្បីប្រឆាំងឬដើម្បីរំខាន៕

## ៦.៨_សុន្ទរកថាថ្លែងដោយ លោកស្រី កុយ វ៉េត ប្រធានអង្គការសម្លេងស្ត្រីខ្មែរស្តីអំពី "តួនាទីនៃតុល្យភាពភេទនៅក្នុងសង្គមស៊ីវិលកម្ពុជា : ប្រវត្តិពដើម ស្ថានការណ៍ និងក្តីសង្ឃឹម"

យេនឌ័រ Gender

គឺជាពាក្យដែលយើងឱ្យនិយមន័យផ្សេងៗគ្នា ហើយនិយមន័យនោះមិនទាន់ ឯកភាពគ្នានៅឡើយ។ ចំពោះនិយមន័យថា តុល្យភាពភេទក៏មិនត្រឹមត្រូវ។

ភេទ : គឺជាលក្ខណៈវិទ្យាសាស្ត្រ ដែលត្រូវបានកំណត់ដល់មនុស្ស ទាំងបុរសនិងស្ត្រី ឬជាលក្ខណៈធម្មជាតិបន្តនូវសរីរាង្គកាយជាបុរស ឬស្ត្រី។ លក្ខណៈ ទាំងនេះមិនអាចកែប្រែបានឡើយ។

ឧទាហរណ៍ :

- ស្ត្រីមានសុដន់សំរាប់បំបៅកូន
- បុរសមានគ្រាប់ពោន
- ស្ត្រីមានស្បូន
- បុរស មានមេជីវិតឈ្មោល ។ល។

យេនឌ័រ : គឺជាការទំនាក់ទំនងរវាងបុរសនិងស្ត្រី ដែលសង្គមជាអ្នកស្ថាបនា និងឱ្យតំលៃ ហើយដែលសង្គមជាអ្នកកែប្រែ។ បើគេនិយាយអំពីយេនឌ័រ គឺគេសំដៅទៅលើសិទ្ធិអំណាចលំដាប់សក្តិ តួនាទីដែលសង្គមស្ថាបនាខុសៗ គ្នារវាងនិងស្ត្រី ហើយដែលការស្ថាបនានេះ

បង្កើតជាវិសមភាពក្នុងសង្គម។ ស្ត្រីស្ថិតនៅក្នុងភាពចំណុះរបស់បុរស ឬក្នុងភាពចាញ់ប្រៀប។ ដោយសង្គមជាអ្នកស្ថាបនានូវវិសមភាព ដូច្នេះ សង្គមក៏អាចកែប្រែវិសមភាពឱ្យទៅជាសមភាពបានដែរ។

## I- ការវិភាគយេនឌ័រ :

ទស្សនៈយេនឌ័រ គឺផ្តោតទៅលើលក្ខណៈសម្បត្តិនិងទំនាក់ទំនង ដែលបានកំណត់ដោយសង្គមដល់ស្ត្រី និងបុរសនៅក្នុងស្ថានភាពណាមួយតាមរយៈ ការងារតួនាទីភារកិច្ច សមត្ថភាព និងលទ្ធភាពនៃការងារទាំងនោះ។ ការវិភាគយេនឌ័រ ត្រូវបានគេទទួលស្គាល់ជាទូទៅ ដើម្បីបញ្ចូលលទ្ធផលនៃការវិភាគនេះ ទៅក្នុងការរៀបចំកម្មវិធីគោលការណ៍ និងគម្រោងផ្សេងៗ។ ដូច្នេះគេធ្វើវិភាគ យេនឌ័រ ទៅលើតួនាទីសកម្មភាព សមត្ថភាព និងលទ្ធភាពប្រើប្រាស់សិទ្ធិគ្រប់គ្រងលើធនធានឱកាសផលប្រយោជន៍ និងតំរូវការរបស់យេនឌ័រ។

### ១_តួនាទីយេនឌ័រ :

តួនាទីយេនឌ័រ គឺជាតួនាទីទាំងឡាយណា ដែលរៀបចំឡើងទៅតាមសមត្ថភាព គឺមានទំនាក់ទំនងរវាងបុរស និងស្ត្រីនៅក្នុងសង្គម តែមិនមែនតាមលក្ខណៈធម្មជាតិ និងជីវសាស្ត្រទេ។

ឧទាហរណ៍ៈ ប្រសិនបើការចិញ្ចឹមកូន ត្រូវបានគេចាត់ទុកថាជាប្រភេទតួនាទីរបស់ភេទស្រីនោះ គឺពុំត្រឹមត្រូវទេ។ ការចិញ្ចឹមកូនគឺជា

តួនាទីរបស់យេនឌ័រ ទៅវិញទេ ពីព្រោះការចិញ្ចឹមកូនអាចធ្វើបានទាំងស្រីទាំងប្រុស។

✳ តួនាទីយេនឌ័រ កំណត់ដោយសង្គម ដូច្នេះសង្គមក៏អាចកែប្រែតួនាទីនេះបានដែរ។

២_ តួនាទីភេទ :

តួនាទីភេទមានន័យផ្ទុយពីតួនាទី យេនឌ័រ ពីព្រោះតួនាទីភេទសំដៅលើការងារឬ មុខងារតាមបែបជីវសាស្រ្ត ដែលមានលក្ខណៈពិសេសទៅតាមភេទនៃ "ភេទ" ណាមួយ។

ឧទាហរណ៍ : ស្រ្តីពរពោះ គឺជាតួនាទីភេទរបស់ស្រ្តី ពីព្រោះមានតែស្ត្រីទេ ដែលអាចមានផ្ទៃពោះបាន និងបង្កើតកូនបាន។

II- ការបែងចែកការងារនៅក្នុងសង្គម

នៅក្នុងសង្គមការងារមាន ៣ ប្រភេទ គឺ:

១_ ការងារផ្ទះសម្បែង

២_ ការងារផលិត (ចិញ្ចឹមសត្វ ជំនាញ ដាំដុះនេសាទ......)

៣_ ការងារសហគមន៍ (សមូហភាព/ ក្រុម អង្គការសមាគម សកម្មភាពនយោបាយ សេវាកម្ម)

ផ្អែកលើផ្នត់គំនិតចាស់ សង្គមតែងតែកំណត់តួនាទី សកម្មភាព ការទទួលខុសត្រូវឱ្យបុរសនិងស្ត្រី ដោយឡែកពីគ្នា :

- មិនឱ្យកូនស្រីរៀនសូត្រ បណ្តាលឱ្យស្រ្តីខ្វះចំណេះដឹងនិងធ្វើឱ្យគំនិតយោបល់ខ្វះតុល្យភាព សង្គមមានទស្សនៈ បាក់ផ្ទត់បន្ទាបបន្ថោកស្រ្តីនិងសន្និដ្ឋានដោយស្វ័យប្រវត្តិថា ស្រ្តីពុំអាចកាន់តួនាទីសំខាន់ៗបាន។

៤. ពេលស្រ្តីពុំមានតួនាទីសំខាន់ ស្រ្តីពុំអាចការពារគំនិតយោបល់ និងសេចក្តីត្រូវការ ឬផលប្រយោជន៍របស់ស្រ្តី។

៥. សមត្ថភាពរបស់ស្រ្តីត្រូវបានគេបំភ្លេចចោល និងបង្កើតការរើសអើងចំពោះស្រ្តី។

១. <u>ការបែងចែកការងារតាមភេទនាំមកនូវទំនាស់</u> :

សង្គមបានផ្តល់តួនាទី ការទទួលខុសត្រូវសកម្មភាពផ្សេងគ្នា និង ឱ្យតំលៃខុសគ្នាដល់បុរស និងស្រ្តីទៅតាមលក្ខណៈពីធម្មជាតិ អាស្រ័យ តាមការយល់ឃើញថាសមស្រប។ បែបនេះគេហៅថា ការបែងចែកការងារតាមភេទ។ គឺជាការបែងចែកឋានៈ ការរើសអើងដែលនាំមកនូវទំនាស់។

ឧទាហរណ៍ : ស្រ្តីមានលក្ខណៈទន់ភ្លន់ សមតែនៅធ្វើការផ្ទះការស្រាលៗជិតៗផ្ទះ។

បុរសមានកម្លាំងរឹងមាំ សមតែចេញទៅធ្វើការធ្ងន់ៗ រកកម្រៃចិញ្ចឹមភរិយាកូនចៅ។

ជាការសង្កេតឃើញ ការបែងចែកការងាររបៀបនេះច្រើនប្រចាំគ្នាមិនជួយការងារគ្នា។ បុរសមិនជួយការងារផ្ទះសម្បែង ដោយគិតថាជាការងារកំប៉ិកកំប៉ុកមិនសក្តិសមនឹងបុរសធ្វើ ហើយគឺជាការងាររបស់ស្ត្រី។ ចំពោះស្ត្រីយល់ថា ទាល់តែស្ត្រី ទើបជាអ្នកធ្វើការងារផ្ទះសម្បែងឯការងារផលិត និងការងារសហគមន៍ (សាធារណៈ) គឺជាការងាររបស់បុរសមិនត្រូវឱ្យស្ត្រីទៅធ្វើការងាររបស់បុរសឡើយ។

តើការយល់ឃើញដូច្នេះ នាំមកនូវអ្វីខ្លះ សំរាប់ស្ថានភាពកម្ពុជាបច្ចុប្បន្ន?

ការបែងចែកការងារតាមភេទ គឺជាការបែងចែកការងារតាមការសមស្របនាំមកនូវវិសមភាព ភាពរើសអើង ទំនាស់ ភាពក្រីក្រ ។ល។

២_<u>ការបែងការងារតាមយេនឌ័រ</u> <u>នាំមកនូវភាពរីកចំរើនជឿនលឿន</u> :

នៅក្នុងសង្គមដែលបែងចែកការងារតាមភេទ យើងសង្កេតឃើញថាមានវិសមភាពក្នុងការបែងចែកអំណាច ដោយគេកំនត់ថា ការងារគ្មានកំរៃឬមានកំរៃទាប គឺជាការងាររបស់ស្ត្រីឯការងារមានកំរៃឬមានកំរៃខ្ពស់ គឺជាការងាររបស់បុរស។ ជាក់ស្តែងការងារក្នុងផ្ទះនិងការងារក្រៅផ្ទះ ត្រូវបានសង្គមកំណត់ឱ្យការងារក្រៅផ្ទះ មានតំលៃជាងការងារក្នុងផ្ទះ។ ប៉ុន្តែ ជាផ្លូវច្បាប់ការងារក្នុងផ្ទះ មានតម្លៃស្មើនឹងការងារក្រៅផ្ទះ។

ជាការសង្កេត បន្ទុកការងារក្នុងផ្ទះរបស់ស្ត្រី អាចជារនាំងធ្វើឱ្យខកខានមិនបានចូលរួមក្នុងការងារអភិវឌ្ឍន៍ នៅពេលស្ត្រីចូលរួមក្នុងការងារអភិវឌ្ឍន៍ស្ត្រីត្រូវ ចំណាយពេលវេលាបន្ថែម ដូចជាគេត្រូវការពេលវេលាបន្ថែម ក្នុងការងារផលិតការងារសាធារណៈជាដើម។ នេះមានន័យថា គេត្រូវការជំនួយសំរាប់ការងារផ្ទះសម្បែង។ ដូច្នេះ បុរស ស្ត្រី ក្មេងប្រុស ក្មេងស្រី ទំនងជាត្រូវរួមចំណែកក្នុងវិស័យការងារទាំង៣ ឱ្យបានជាដៃគូមិនអាចប្រកែកបានឡើយ។

ការងារផ្ទះសម្បែង ការងារផលិត និងការងារសាធារណៈ តើការងារណា មួយដែលមានកម្រៃមានអំណាច និងមានកិត្តិយស?

តាមធម្មតាការងារផ្ទះសម្បែង ពុំបានទទួលប្រាក់កម្រៃទេ (អ្នកបំរើនៅក្នុងផ្ទះអាចមានកម្រៃ ប៉ុន្តែ ពុំមានកិត្តិយសឡើយ ហើយត្រូវគេចាត់ទុកថាមិនសំខាន់)។

ប៉ុន្តែ បើពុំមានស្ត្រីនៅរ៉ាប់រងការងារផ្ទះសម្បែងទេ បុរសឬស្វាមី ក៏មិនអាចចេញទៅធ្វើការងារក្រៅផ្ទះ ឬបង្កើនសមត្ថភាព ឬធ្វើដំណើរកំសាន្តលំហែបានដែរ។ ភាពរវល់នឹងការងារដ៏ច្រើនរបស់ស្ត្រីធ្វើឱ្យស្ត្រី គ្មានឱកាសនឹងបានចូលរួម ក្នុងការងាររកកម្រៃសំខាន់ៗដូចបុរស ម្ល៉ោះហើយ ស្ត្រីត្រូវគេឱ្យតំលៃទាបនិងគ្មានអំណាច។

ដូច្នោះ ការបែងចែកការងារតាមយេនឌ័រគឺ :

៦. សង្គមកែប្រែឥរិយាបថ ពុំមានវិសមភាពទេ។

៧. ការកំណត់តួនាទី សកម្មភាពការទទួលខុសត្រូវផ្អែកលើ សមត្ថភាព ពុំមែនលើការសមស្រប នៃភេទទៀតទេ។

៨. លុបបំបាត់ភាពរើសអើង។

៩. កាត់បន្ថយទំនាស់។

១០. នាំមកនូវការរីកចំរើនលឿនលឿន/ធនធានមនុស្សសំបូរបែប។

១១. លុបបំបាត់ភាពក្រីក្រ។

<u>ប្រភពដើម</u>

ប្រវត្តិខ្លះៗទាក់ទងស្រ្តីក្នុងការអភិវឌ្ឍន៍ (WID) និងយេនឌ័រក្នុងការអភិវឌ្ឍន៍ (GAD) អង្គការសហប្រជាជាតិមានដំណើរការនៅក្នុងឆ្នាំ១៩៨៥។ ប៉ុន្តែ ទិវាអន្តរជាតិ៨មីនា ដែលជាសមិទ្ធិផលនៃការតស៊ូរើបំរាស់របស់ស្រ្តី ចាប់ផ្តើមតាំងពីថ្ងៃទី៨មីនា ឆ្នាំ១៩១១មកម្ល៉េះ។ គឺជាការទាមទារសិទ្ធិសេរីភាពក្នុងការងាររបស់នារីគឺ:

១២. ធ្វើការដូចគ្នាប្រាក់បៀវត្សស្មើគ្នា។

១៣. ធ្វើការក្នុង១ថ្ងៃ៨ម៉ោង។

១៤. នារីត្រូវថែទាំសុខភាពពេលមានគភ៌ និងពេលសម្រាលកូន។

មុនឆ្នាំ ១៩៧០ : គេយល់ថាការអភិវឌ្ឍន៍មិនចាំបាច់មានស្ត្រីទេ

១៩៧០: តួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចត្រូវបានកែសម្រួល

១៩៧៣: នៅវ៉ាស៊ីនតោន គេបញ្ចូលស្ត្រីទៅក្នុងកិច្ចអភិវឌ្ឍន៍ (WID)

១៩៧៥: សន្និសីទអន្តរជាតិ បានកំណត់អន្តរជាតិរបស់ស្ត្រីនៅទីក្រុង Mexico ដែលមានប្រធានបទ៣គឺ : អភិវឌ្ឍ សមភាព សន្តិភាព។

១៩៨០ : សន្និសីទពិភពលោករបស់ស្ត្រី សំរាប់ពាក់កណ្តាលទស្សវត្សរបស់ស្ត្រីនៅទីក្រុង Copenhagen (Danemark) បានធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ផែនការសកម្មភាពដែលស្តីអំពីសមភាព សន្តិភាពនិងអភិវឌ្ឍន៍។

១៩៨៥: សន្និសីទស្ត្រីចុងទសវត្សរ៍នៅ Nairobi (Kenya)

១៩៩៥: សន្និសីទពិភពលោកលើកទី៤ នៅទីក្រុងប៉េកាំងបានលើកឡើងអំពីកង្វល់ ១២ចំណុចនៅទូទាំងពិភពលោក គឺ : ភាពក្រីក្រ ការអប់រំ សុខភាព បរិស្ថាន សិទ្ធិស្ត្រី វិសមភាពយេនឌ័រ និងភាពរើសអើងប្រឆាំងនឹងស្ត្រី ការផ្សព្វផ្សាយ អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ផលវិបាកនៃជម្លោះអាវុធ រចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយ វិសមភាពក្នុងការធ្វើសេចក្តីសំរេចបញ្ហាកុមារី។

នៅរវាង៤ឆ្នាំក្រោយនេះ គេបានគិតគូរពីយេនឌ័រ និងការអភិវឌ្ឍន៍ដែលគេហៅថា GAD សមស្របនឹងការរីកចំរើនផ្នែកសម្ព័ន្ធ-ភាព រវាងបុរសនិងស្ត្រី និងដើម្បីពិនិត្យពីទំនាក់ទំនងដែលមិនអាចខ្វះបានរវាងបុរសនិងស្ត្រី ដែលចាំបាច់ត្រូវតែពឹងពាក់អាស្រ័យ និងបំពេញការខ្វះខាតគ្នាទៅវិញទៅមក។ យេនឌ័រ និងការអភិវឌ្ឍន៍មានទិសដៅ :

១- កាត់បន្ថយភាពក្រីក្រ

២- ជំរុញឱ្យការងារនារីបានទទួលតម្លៃសមរម្យ

៣- ជំរុញឱ្យរចនាសម្ព័ន្ធរដ្ឋបាល ផ្នែកសេដ្ឋកិច្ចនយោបាយទទួលស្គាល់តម្លៃ និងតួនាទីជាអ្នកសំរេចចិត្តរបស់ស្ត្រី

៤- ជំរុញឱ្យមានការទទួលយកមតិយោបល់របស់នារី

៥- ជំរុញឱ្យស្ត្រីបានចូលរួម ក្នុងការងារអភិវឌ្ឍន៍ជាដៃគូរបស់បុរស។

## ស្ត្រីក្នុងការអភិវឌ្ឍន៍ (WID)

វិធីសាស្ត្រស្តីពីស្ត្រីក្នុងការអភិវឌ្ឍន៍ (WID) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧០ ដោយផ្តោតការយកចិត្តទុកដាក់ ទៅលើការចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៍។ កម្មវិធី (WID) ពុំបានទទួលជោគជ័យភាគច្រើនដោយសារ :

- ផ្តោតការយកចិត្តទុកដាក់ទៅលើការចូលរួមរបស់ស្ត្រីនៅក្នុងភាពជាអ្នកផលិត និងក្នុងផ្នែកសុខមាលភាពរបស់ស្ត្រី។
- មិនបានគិតគូរ ដល់តួនាទីចំរុះរបស់ស្ត្រីក្នុងការផលិត និងការងារសាធារណៈ។
- ផ្តោតការយកចិត្តទុកដាក់ តែទៅលើតម្រូវការជាក់ស្តែងកម្មវិធីប្រាក់ចំណូល។
- មិនបានយកចិត្តទុកដាក់ដល់ផលប្រយោជន៍របស់ស្ត្រី។ ឧទាហរណ៍ : សិទ្ធិអំណាចរបស់ស្ត្រី។
- គម្រោងកម្មវិធីតូច ហើយនៅដាច់តែឯងមិនបានចូលរួមឱ្យបានច្រើននៅក្នុងដំណើរការអភិវឌ្ឍន៍

ឧ_ កាត់ដេរ តម្បាញ។

<u>យេនឌ័រ និងអភិវឌ្ឍន៍</u> (GAD)

វិធីសាស្ត្រស្តីពីយេនឌ័រនិងអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨០ ដើម្បីដោះស្រាយបញ្ហាវិសមភាពរវាងបុរស និងស្ត្រីដោយយកចិត្តទុកដាក់លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយនិងវប្បធម៌ ដើម្បីជំរុញឱ្យ :

- ធានាឱ្យបុរសស្ត្រី បានទទួលផលប្រយោជន៍ស្មើគ្នាក្នុងកម្មវិធីអភិវឌ្ឍន៍

- លើកទឹកចិត្តឱ្យបុរសនិងស្ត្រីបានចូលរួមស្មើភាពគ្នាក្នុងគំរោងកម្មវិធី។
- ធានាឱ្យបុរស និងស្ត្រីមានលទ្ធភាពនិងសិទ្ធិស្មើគ្នា ក្នុងការគ្រប់គ្រងលើធនធាន។
- ជំរុញឱ្យបុរសជួយជ្រោមជ្រែងដល់ការប្រែប្រួល ទូវទំនាក់ទំនងរបស់បុរស និងស្ត្រី។

លទ្ធផលសង្ឃឹមទុក

- ចូលរួមក្នុងភាពជាអ្នកផលិត។
- ការអភិវឌ្ឍន៍មាននិរន្តរភាព។
- បង្កើនយុត្តិធម៌សង្គមបុរសនិងស្ត្រី (អ្នកដែលងាយរងបញ្ហាលំបាក) អាចមានលទ្ធភាពទទួល និងគ្រប់គ្រងធនធានបាន។
- បុរសស្ត្រី ក្នុងភាពងាយរងគ្រោះ ត្រូវបានផ្ដល់សិទ្ធិអំណាចជូន។

| ស្ថាប័ន | ចំនួនស្ត្រី | សរុប |
|---|---|---|
| ព្រឹទ្ធសភា | ៨ | ៦១ |
| រដ្ឋសភា | ១៤ | ១២២ |

| | | |
|---|---|---|
| គណៈរដ្ឋមន្ត្រី | ៦ | ៨២ |
| រដ្ឋមន្ត្រី (កិច្ចការនារីនិងវប្បធម៌) | ២ | ២៥ |
| រដ្ឋលេខាធិការ | ៤ | ៥០ |
| អនុរដ្ឋលេខាធិការ | ៥ | ១៣២ |
| អភិបាលខេត្ត-ក្រុង | ០ | ២៤ |
| អភិបាលរងទី២ | ១ | |
| អភិបាលស្រុក /ខណ្ឌ | ១ | ១៨៤ |
| មេឃុំ /ចៅសង្កាត់ | ១០ | ១៦២៣ |

គ្មាននារីម្នាក់សោះ ក្នុងចំណោមរដ្ឋអាជ្ញាទាំង៤០នាក់។

មាននារីប្រហែល ១៣%នៃមុខតំណែងអ្នករដ្ឋបាល និង២៨% នៃមុខតំណែងផ្នែកវិជ្ជាជីវៈនិងបច្ចេកទេស(ស្ត្រីជាអ្នកកាន់ការ)។

យើងសង្កេតឃើញថា កត្តាដែលជាឧបសគ្គរាំងស្ទះស្ត្រីមិនអាចចូលរួមក្នុងការងារដូចខាងលើ គឺមកពីទំលាប់ចាស់មិនជឿនលឿនទប់ស្កាត់មិនឱ្យស្ត្រីបានរៀនសូត្រ និងបង្កើនសមត្ថភាពរបស់ខ្លួន។

ឧទាហរណ៍ : ជាក់ស្តែងដែលមួយចំនួនជាឧបសគ្គរាំងស្ទះដល់ការលូតលាស់របស់នារី :

បញ្ហាសិក្សាអប់រំ :

អត្រាអក្ខរកម្ម : មានស្ត្រី៥៥% ក្នុងចំណោមមនុស្សពេញវ័យ (បុរស ៧៩%)

អត្រានៃការសិក្សា: ការចុះឈ្មោះចូលរៀនចាប់ពីក្រោមអាយុ ១០ឆ្នាំ មានប្រហាក់ប្រហែលគ្នារវាងកូនស្រី និងកូនប្រុស។ ត្រឹមអាយុ១៥ឆ្នាំការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុស ខ្ពស់ជាងក្មេងស្រី២ដង ហើយចាប់ពីអាយុ១៨ឆ្នាំការ ចុះឈ្មោះចូលរៀនរបស់សិស្សប្រុស ស្មើជិតពាដងនៃ ការចុះឈ្មោះរបស់សិស្សស្រី។

ការបោះបង់ការសិក្សារបស់សិស្សស្រី : សិស្សស្រីបោះបង់ការសិក្សាជា ច្រើននៅក្រោមថ្នាក់ទី៤ និងទី៥ ជិតពាក់កណ្តាលនៃ ចំនួនសិស្សស្រី ដែលបានចុះឈ្មោះចូលរៀននៅមធ្យម សិក្សា។

* គួរពិចារណា

បុរសដែលបានរៀនសូត្រដល់ថ្នាក់បឋមសិក្សា រកចំណូលជា ប្រាក់ប្រចាំឆ្នាំ លើសបុរសដែលមិនបានរៀនសូត្រ១០%។ ចំណែកស្ត្រី ដែលបានរៀនសូត្រដល់ថ្នាក់បឋមសិក្សារកប្រាក់ចំណូល បានច្រើនជាង ស្ត្រីដែលមិនបានរៀនសូត្រដល់ទៅ៣២%។ ចំពោះប្រាក់បៀវត្សរ៍របស់ ស្ត្រី ដែលមានការរៀនសូត្រដល់ថ្នាក់មធ្យមសិក្សាកើនគុណ២ ច្រើនលើស

ប្រាក់បៀវត្សរបស់បុរស ៤២% និងលើសប្រាក់ចំណូលរបស់ស្ត្រី ដែលមិនបានរៀនសូត្រដល់ទៅ៨០%។

បញ្ហាសុខភាព

- សុខភាពបន្តពូជ : ស្ថិតិប៉ាន់ស្មានប្រហែល $\frac{600}{100,000}$ (៦០០ ករណីស្លាប់ក្នុង ១០០.០០០ ករណី)។ នេះគឺជាការប្រឈមមុខនឹងគ្រោះថ្នាក់ ដែលខ្ពស់ជាងគេបំផុតនៅក្នុងតំបន់។ គេប៉ាន់ស្មានថាមានស្ត្រីកម្ពុជា ស្លាប់ប្រហែល ២.០០០នាក់ក្នុង១ឆ្នាំ (៣ខែ ស្លាប់២នាក់)
- កាមរោគនិងអេដស៍
- អាត្រាចម្លងកាមរោគ និងអេដស៍ពីបុរសទៅស្ត្រីមេផ្ទះនិងកុមារកំពុងកើនឡើង នៅក្នុងប្រទេសកម្ពុជាយ៉ាងធ្ងន់ធ្ងរ គួរឱ្យភ័យព្រួយបំផុតនៅអាស៊ី។

បញ្ហាក្រីក្រ

៣៦% នៃចំនួនប្រជាពលរដ្ឋស្ថិតនៅក្នុងភាពក្រីក្រ ក្នុងនោះនារី ជាមេគ្រួសារច្រើនស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺន។

បញ្ហាអហិង្សាក្នុងគ្រួសារ

ការអង្កេតនៅក្នុងឆ្នាំ១៩៩៥_៩៦ បានឱ្យដឹងថា១៦% នៃស្ត្រីដែលបានឆ្លើយសំនួរ បានរាយការណ៍ថា ត្រូវបានប្តីធ្វើបាបលើរាងកាយ។

*ជំនឿតៗគ្នាទៅលើគំនិតចាស់ដែលធ្លាប់តែបង្ក្រាបនារី :*

ជាទូទៅស្ត្រីស្ថិតនៅក្នុងភាពចាញ់ប្រៀបឬងាយរងគ្រោះដោយមានមូលហេតុសំខាន់ដូចខាងក្រោម :

ការទទួលបាន និងការចាត់ចែងធនធានឱកាស និងផលប្រយោជន៍មានកម្រិតទាប និងមានសភាពចាញ់ប្រៀប។ ដែលហៅថាធនធាន គឺធនធានសេដ្ឋកិច្ច និងធនធាននយោបាយមានការដឹកនាំ ការអប់រំ ពត៌មាន ជំនឿលើខ្លួនឯង បទពិសោធន៍ក្នុងការងារ ចំណេះដឹង ។ល។ ចំពោះឱកាស គឺជាធនធានកម្រ ដែលមនុស្សយើងប្រឹងប្រែងឆក់យកឱ្យបានដើម្បីបង្កើនជីវភាព សមត្ថភាព តួនាទីរបស់ខ្លួន។ ចំពោះផលប្រយោជន៍របស់ស្ត្រីគឺ :

- ការកែប្រែ ការបែងចែកការងារតាមភេទ។ មានវិធានការកាត់បន្ថយបន្ទុកការងារផ្ទះសម្បែង ដែលធ្លាប់តែទម្លាក់ឱ្យតែនារីជាអ្នកទទួលខុសត្រូវតែឯង។
- ការកាត់បន្ថយភាពរើសអើងចំពោះស្ត្រី
- ការលើកកំពស់សមត្ថភាព លើផ្នែកនយោបាយ និងផ្នែកច្បាប់សំរាប់ស្ត្រី
- វិធានការកាត់បន្ថយអំពើហិង្សា និងការកេងប្រវ័ញ្ចន៍លើស្ត្រី
- បង្កើនសុវត្ថិភាពសេដ្ឋកិច្ច ឯករាជ្យ សិទ្ធិអំណាច និងឱកាសសមរម្យដល់ស្ត្រី

- បង្កើនកម្មវិធីអភិវឌ្ឍន៍ ដើម្បីការចូលរួមពីស្ត្រី
- ចងក្រងក្រុម/សម្ព័ន្ធ ជាធនធាន ដើម្បីជាកំលាំងសាមគ្គី
- ការបង្កើនសមត្ថភាពក្នុងការលើកកំពស់ជីវភាពនិងអនាគតកូនចៅឱ្យមានលក្ខណៈល្អប្រសើរ។

សេចក្តីត្រូវការយេនឌ័រ ឆ្លើយតបទៅនឹងផលប្រយោជន៍ខាងលើមាន២យ៉ាងគឺ : សេចក្តីត្រូវការចំពោះមុខ និងសេចក្តីត្រូវការយូរអង្វែងឬជាយុទ្ធសាស្ត្រ។

សេចក្តីត្រូវការចំពោះមុខមាន: ស្បៀងអាហារ ជំរក ថ្នាំពេទ្យ សំលៀកបំពាក់...។ សេចក្តីត្រូវការទាំងនេះ អាចដោះស្រាយតាមសកម្មភាពអភិវឌ្ឍន៍ជនបទ ដែលជាសកម្មភាពរយៈពេលខ្លី ដើម្បីដោះស្រាយបញ្ហាស្ត្រី មិនឱ្យធ្លាក់ក្នុងភាពលំបាកជាងមុន។

សេចក្តីត្រូវការយូរអង្វែង ឬយុទ្ធសាស្ត្រ : ទាក់ទងនឹងការលំអផ្លាស់ប្តូរឋានៈតួនាទីរបស់ស្ត្រី ដែលទាក់ទងទៅនឹងការបែងចែកការងារ អំណាចការគ្រប់គ្រងត្រួតត្រាលើធនធាន និងបញ្ហាច្បាប់បង្ការអំពើហិង្សា ការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ ការផ្តល់ឱកាសឱ្យស្ត្រីច្រើនថែមទៀត ក្នុងការគ្រប់គ្រងធនធាន និងការបង្កើនការចូលរួមស្មើគ្នាជាមួយបុរសក្នុងការសម្រេចផ្សេងៗ។

ដូច្នេះអនុសញ្ញា ស្តីពីការលុបបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) អាចឱ្យយើងយល់ពីគោល

ការណ៍នៃឱកាសសមភាពយេនឌ័រ ក្នុងគ្រប់ទិដ្ឋភាពរស់នៅរបស់ជន គ្រប់រូប និងសេដ្ឋកិច្ចគ្រប់ផ្នែក។

សមភាពយេនឌ័រ

សមភាពយេនឌ័រមានន័យថា មានភាពត្រឹមត្រូវ និងយុត្តិធម៌ ក្នុងការបែងចែកធនធាន ឱកាសនិងផលប្រយោជន៍រវាងបុរសនិងស្ត្រី។

សមធម៌ សមភាព ភាពត្រឹមត្រូវ ឬយុត្តិធម៌ ឧទាហរណ៍ : "រឿងកុកនិងកញ្ជ្រោង " ឆ្លុះបញ្ចាំងឱ្យឃើញនូវសមភាព និងសមធម៌។ កុក និងកញ្ជ្រោងត្រូវបានផ្ដល់ឱកាសស្មើគ្នា ដើម្បីទទួលទានអាហារ។ ដូចនេះ អ្នកអាចទទួលបានច្រើនហើយស្រួលនោះ គឺអាស្រ័យទៅនឹង ប្រភេទរបស់ចានបានន័យថា បើចាននោះធំហើយរាក់ គឺជាលក្ខណៈ ងាយស្រួលដល់កញ្ជ្រោង។ ប៉ុន្តែផ្ទុយទៅវិញ បើចាននោះតូចហើយ ជ្រៅគឺបង្កលក្ខណៈសំរាប់តែកុក។ ដូច្នេះបើ យើងចង់ឱ្យមានឥទ្ធិពល ប្រកបដោយសមធម៌កុក និងកញ្ជ្រោង គួរតែមានចានពិសេសផ្ទាល់ខ្លួន ដើម្បីឱ្យការទទួលទានរបស់អ្នកទាំងពីរប្រព្រឹត្តទៅដោយសុវត្ថិភាព។

បើយើងសង្កេតមើលការរស់នៅជាក់ស្ដែង អំពីដំណើរជីវិតក្នុង សង្គមយើងឃើញថា វិសមភាពបានកើតឡើង ចំពោះជីវិតក្មេងស្រី ដែលជាអ្នកក្រីក្រដែលបង្ហាញជូនតាមរយៈ ឧទាហរណ៍ ខាងក្រោម៖

<u>ឧទាហរណ៍ទី១</u> : កុមារាកុមារីទាំងអ្នកមាន ទាំងអ្នកក្រត្រូវបានគេ អនុញ្ញាតឱ្យចូលរៀនដូចៗគ្នា ប៉ុន្តែ ដោយជីវភាពក្រខ្សត់ កុមារនៃ

គ្រួសារក្រីក្រ ពុំសូវបានទៅរៀនសូត្រដូចកុមារធូរធារទេ ព្រោះកុមារទាំងនោះជួយធ្វើការផ្ទះ ការងារផលិតនិងការងារសហគមន៍។ កុមារនៃគ្រួសារក្រីក្រពុំមានលទ្ធភាពបន្តការសិក្សារៀនសូត្រនៅអនុវិទ្យាល័យ ឬឧត្តមសិក្សាទេ។ ដូច្នេះ ឧទាហរណ៍នេះបញ្ជាក់ឱ្យឃើញថា កុមារទាំងអស់ (ក្រនិងមាន) បានទទួលនូវសមភាពគឺការចូលរៀនគ្រប់ៗគ្នា តែទន្ទឹមនឹងនេះកុមារ នៃគ្រួសារក្រីក្រពុំបានទទួលសមធម៌ពីសង្គមទេ។ ទោះយ៉ាងណាក៏ដោយកុមារមិនថា មានឬក្រ ពួកគេនៅតែមានលទ្ធភាពរៀនសូត្របានចប់ចុងចប់ដើម បើឪពុកម្ដាយរបស់គេឱ្យតំលៃទៅលើការសិក្សារបស់កូនប្រុស ហើយគាំទ្រដល់ការសិក្សារបស់កូនប្រុសក្នុងករណីនេះកូនប្រុសបានទទួលសមធម៌។

ឧទាហរណ៍ទី២ : កុមារាកុមារី ត្រូវបានសាលាទទួលឱ្យចូលរៀនដូចៗគ្នា (ស្មើគ្នា) ដោយមិនប្រកាន់ពីភេទឡើយ។ ដោយឡែកនៅក្នុងគ្រួសារមានជីវភាពក្រីក្រមាន តែកុមារាប៉ុណ្ណោះត្រូវបានឪពុកម្ដាយយកចិត្តទុកដាក់ និងខិតខំជម្រុញឱ្យបានរៀនសូត្រជានិច្ច ទោះជាស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយបានន័យថា មាតាបិតាខិតខំអស់ពីសមត្ថភាពទាំងកម្លាំងកាយ និងចិត្តរបស់គាត់គួបផ្សំ និងការរួមចំណែករបស់កុមារានៅក្នុងគ្រួសារ និងគាំទ្រតែការសិក្សារបស់កុមារា។ ដូច្នេះ គឺមានតែកុមារាប៉ុណ្ណោះ បានទទួលសមធម៌។

ជាក្ដីសង្ឃឹមរបស់សង្គម ស៊ីវិលនារីគួរតែបានទទួលសមធម៌យេនឌ័រ នៅក្នុងការបែងចែកការងារទាំង៣ប្រភេទ ដើម្បីឱ្យនារីទទួល

បាននិងគ្រប់គ្រងធនធានឱកាស និងផលប្រយោជន៍ស្មើភាពនៅក្នុងសង្គម។ ម្យ៉ាងទៀត នៅក្នុងអភិបាលកិច្ចល្អ សមធម៌ ក៏ជាគោលការណ៍សំខាន់សម្រាប់ជម្រុញឱ្យមានការចូលរួម និងការទទួលខុសត្រូវពីប្រជាពលរដ្ឋ។ អាស្រ័យដោយរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ទៅលើអភិបាលកិច្ចល្អ គួរតែយើងខិតខំពង្រីកការអប់រំប្រជាពលរដ្ឋឱ្យមានទស្សនៈ យេនឌ័រ ដើម្បីជម្រុញការកែប្រែឥរិយាបថ និងទម្លាប់ចាស់មិនជឿនលឿន ដែលនាំឱ្យសង្គមជាតិមិនអាចលូតលាស់ ប្រសិនបើប្រជាពលរដ្ឋ មិនទាន់មានទស្សនៈ យេនឌ័រទេ ដំណើរការនៃអភិបាលកិច្ចល្អ ក៏មិនអាចរីកចំរើនពីព្រោះ ការចូលរួមនិងការទទួលខុសត្រូវពីប្រជាពលរដ្ឋនឹងមានកំរិតដោយមូលហេតុធនធានមនុស្សពុំមានតុល្យភាពឬខ្វះធនធានមនុស្សក្នុងការអភិវឌ្ឍន៍សង្គម។

មធ្យោបាយដែលមានប្រសិទ្ធិភាព គឺស្របគ្នានឹងការអប់រំផ្សព្វផ្សាយអំពីទស្សនៈ យេនឌ័រ គយរតែបង្កើតគោលនយោបាយជម្រុញលើកទឹកចិត្តឱ្យមានកំណត់ Quota សំរាប់មុខសញ្ញានារីលើគ្រប់វិស័យទាំងអស់៕

## ៦.៩_សុន្ទរកថាថ្លែងដោយលោកស្រី រស់ សុភាព នាយិកា ប្រតិបត្តិ អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជាស្តីពី "តួនាទីនៃគុណភាពភេទនៅក្នុងសង្គមស៊ីវិលកម្ពុជា : ប្រភពដើម ស្ថានការណ៍ និងក្តីសង្ឃឹម"

### យេនឌ័រជាអ្វី?

ជាភាពខុសគ្នារវាងយេនឌ័រ និងភេទ ត្រូវបានទទួលស្គាល់នៅស្ទើរតែពាសពេញពិភពលោក។

១_ ភេទត្រូវបានកំនត់ដោយលក្ខណៈជីវសាស្ត្រ។

២_ យេនឌ័រ ជាកត្តាកំណត់តាមលក្ខណៈសង្គមនិងលក្ខណៈជីវសាស្ត្រ។ នេះមានន័យថា ជាការកំណត់ទៅតាមវប្បធម៌ និងទៅតាមប្រវត្តិសាស្ត្រដូច្នេះ ៖

- យេនឌ័រខុសពីភេទ ពោលគឺ វាមិនមែនត្រូវបានកំណត់ឡើងតាមលក្ខណៈជីវសាស្ត្រដូចភេទទេ
- យេនឌ័រមានលក្ខណៈខុសគ្នាពីវប្បធម៌មួយទៅវប្បធម៌មួយទៀត ព្រមទាំងអនុលោមទៅតាមបរិបទសង្គម សេដ្ឋកិច្ច និងនយោបាយផងដែរ។
- វាមានការប្រែប្រួលពីពេលមួយទៅពេលមួយ

- តួនាទីរបស់យេនឌ័រនេះបញ្ជាក់ថា អាចប្រែប្រួលបានអ្នកដែលធ្វើអ្វីមួយស្ថិតនៅក្រៅតួនាទី យេនឌ័ររបស់ខ្លួនអាចនឹងត្រូវប្រឈមមុខជាមួយនឹងការមិនទទួលស្គាល់ពីអ្នកដទៃ។
- វាជាការសំខាន់ណាស់ ក្នុងការយកចិត្តទុកដាក់គិតគូរដល់ទំនាក់ទំនងយេនឌ័រ។

## ហេតុអ្វីបានជាយេនឌ័រក្លាយជាកត្តាសំខាន់នៅក្នុងសង្គមស៊ីវិល?

ក្នុងពេលមានការប្រកាសឱ្យប្រើធម្មនុញ្ញរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៥ និងសេចក្ដីថ្លែងការអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨ ពេលនោះអ្នកធ្វើផែនការ និងអ្នកធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ ភាគច្រើនមិនបានយកចិត្តទុកដាក់ ដោះស្រាយពីឋានៈរបស់ស្ត្រី នៅក្នុងដំណើរការអភិវឌ្ឍន៍ឱ្យបានពេញលេញទេ។ អ្នកស្រាវជ្រាវមួយចំនួន បានបញ្ជាក់ឱ្យដឹងថា អ្នកធ្វើផែនការអភិវឌ្ឍន៍បានធ្វើការប៉ាន់ស្មានថាអ្វី ដែលបានផ្ដល់ផលប្រយោជន៍ដល់បុរស នៅក្នុងសង្គមស៊ីវិល វាក៏នឹងផ្ដល់ផលប្រយោជន៍ដល់ស្ត្រីដែរ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០និង ១៩៦០ បញ្ហានានារបស់ស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងចំណោមបញ្ហាផ្នែកសិទ្ធិមនុស្ស។

សន្និបាតរបស់អង្គការសហប្រជាជាតិ ដែលបានយកចិត្តទុកដាក់ដោយឡែកចំពោះស្ត្រីរួមមាន ៖

- សន្និបាតនៅឆ្នាំ១៩៤៩ ស្ដីពី "ការហាមប្រាមនូវការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍ខាងផ្លូវភេទ"

- នៅឆ្នាំ១៩៥១ ស្តីពី ប្រាក់ឈ្នួលស្មើភាពគ្នារវាងកម្មករបុរសនិងស្ត្រីសំរាប់ការងារដែលមានតម្លៃស្មើគ្នា។
- សន្និបាតឆ្នាំ១៩៥២ ស្តីពី សិទ្ធិនយោបាយរបស់ស្ត្រី។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ បើទោះជាស្ត្រីមិនត្រូវបានចាត់ទុកជាភាគីចាំបាច់សំរាប់ធ្វើការពិគ្រោះក៏ដោយក៏ ឋានៈតន្លឹះនៅក្នុងដំណើរការអភិវឌ្ឍន៍របស់គេត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ។ ស្ត្រីត្រូវបានគេយល់ឃើញថា ជាធនធានមួយដែលមានសារៈសំខាន់ណាស់នៅក្នុងសង្គមស៊ីវិល ក្នុងការបញ្ចូលទៅក្នុងដំណើរការអភិវឌ្ឍន៍។

នៅក្នុងសង្គមណាក៏ដោយ តួនាទីស្ត្រីបំពេញមានលក្ខណៈខុសគ្នា ហើយស្ថានភាពរបស់គេ ត្រូវបានកំណត់ដោយច្បាប់បទដ្ឋានសាសនា ឋានៈ ឬស្ថានការណ៍ សេដ្ឋកិច្ច តម្លៃផ្នែកវប្បធម៌ ជាតិសាសន៍ និងប្រភេទសកម្មភាព ដែលប្រកបដោយផលិតភាពរបស់ប្រទេស សហគមន៍ និងគ្រួសាររបស់គេ (សង្គមស៊ីវិល)។

តួនាទីយេនឌ័រនៅក្នុងសង្គមស៊ីវិលមានបី ៖

១_ ការងារបានកម្រៃ

២_ ការងារមិនបានកម្រៃ

៣_ ការងារសហគមន៍

ដើម្បីយល់បានអំពីយេនឌ័រ តម្រូវឱ្យមានការលើកឡើងដាច់ដោយឡែកៗ ពីគ្នារវាងសកម្មភាពរបស់បុរសនិងស្ត្រី។ ការងារដែល

ស្ត្រីកំពុងបំពេញរួមមានការងារមិនបានកម្រៃ (ការងារមេផ្ទះ) ការងារផលិតកម្ម ការងារសហគមន៍ និងការងារក្នុងសង្គម ក៏ដូចគ្នាទៅនឹងការងារផ្នែកសេដ្ឋកិច្ច និងការងារសង្គមដែលបុរសកំពុងតែបំពេញដែរ។

ប្រវត្តិរបស់យេនឌ័រ (ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ និងយេនឌ័រ និងការអភិវឌ្ឍន៍)

ក/-វិធីសាស្ត្ររបស់ : "ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍" ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧០ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការចូលរួម នៅក្នុងដំណើរការអភិវឌ្ឍន៍។ គម្រោងកម្មវិធីស្ត្រី ក្នុងការអភិវឌ្ឍន៍ភាគច្រើនមិនបានទទួលជោគជ័យទេ ដោយសារតែ ៖

- ផ្តោតការយកចិត្តទុកដាក់តែទៅលើការចូលរួមរបស់ស្ត្រីនៅក្នុងផលិតភាព និងសុខមាលភាពរបស់គេ
- មិនបានគិតគូរដល់តួនាទី ជម្រុះរបស់ស្ត្រីគឺតួនាទីផលិត និងតួនាទីមេផ្ទះ។
- ផ្តោតការយកចិត្តទុកដាក់ តែទៅលើតម្រូវការជាក់ស្តែងរបស់ស្ត្រី ឧទាហរណ៍ កម្មវិធីប្រាក់ចំណូល។
- មិនបានយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ស្ត្រី ឧទាហរណ៍ សិទ្ធិអំណាចរបស់ស្ត្រី
- គម្រោងកម្មវិធីតូច ហើយនៅដាច់តែឯងមិនដែលបានចូលរួមឱ្យបានច្រើន នៅក្នុងដំណើរការអភិវឌ្ឍន៍ ឧទាហរណ៍ កាត់ដេរ តម្បាញ ។ល។

៩/-វិធីសាស្ត្រនានារបស់យេនឌ័រនិងការអភិវឌ្ឍន៍ : ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨០ ដើម្បីដោះស្រាយបញ្ហាវិសមភាពរវាងបុរស និងស្ត្រី ដោយការយកចិត្តទុកដាក់ដល់បញ្ហានានា ក្នុងផ្នែកសេដ្ឋកិច្ចសង្គម នយោបាយនិងវប្បធម៌ដែលជាកត្តាកំណត់នូវវិធីសាស្ត្រនានាក្នុងការ ៖

- លើកទឹកចិត្តបុរស និងស្ត្រីឱ្យបានចូលរួមស្មើភាពគ្នា នៅក្នុងគម្រោងកម្មវិធី។
- ធានាឱ្យបុរស និងស្ត្រីបានទទួល នូវផលប្រយោជន៍ស្មើគ្នាពីគម្រោងកម្មវិធី។
- ធានាឱ្យបុរស និងស្ត្រីមានលទ្ធភាព និងមានសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រងលើធនធាន។
- ជម្រុញបុរសជួយជ្រោមជ្រែងដល់ការកែប្រែនូវតួនាទី ឬទំនាក់ទំនងរបស់បុរសនិងស្ត្រី។

វិធីសាស្ត្រនានារបស់យេនឌ័រនិងការអភិវឌ្ឍន៍ផ្ដល់ជូននូវលទ្ធផលដែលបានសង្ឃឹមទុកដូចខាងក្រោម ៖

- ផលិតភាពខ្ពស់។
- ការអភិវឌ្ឍន៍ដែលមាននិរន្តរភាព។
- បង្កើនយុត្តិធម៌សង្គម។
- បុរសនិងស្ត្រីអាចមានលទ្ធភាពទទួលនិងគ្រប់គ្រងធនធានបាន។
- បុរសនិងស្ត្រីទន់ខ្សោយត្រូវបានផ្ដល់សិទ្ធិអំណាចជូន។

## ស្ថានភាពយេនឌ័រនៅក្នុងសង្គមកម្ពុជា :

នៅក្នុងប្រទេសកម្ពុជាបញ្ហាយេនឌ័រជាកត្តាមួយសំខាន់ណាស់។ កត្តាខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះៗ ដែលបង្ហាញពីស្ថានភាពនាពេលបច្ចុប្បន្ន ៖

ក/-ថ្នាក់ជាតិ

*តួនាទីស្ត្រីក្នុងឆាកនយោបាយ :*

- ព្រឹទ្ធសភាមានស្ត្រី៨រូប ក្នុងចំណោមសមាជិកព្រឹទ្ធសភា សរុប ៦២រូប។
- រដ្ឋសភាមានស្ត្រី១២រូបក្នុងចំណោមសមាជិកសភាសរុប១២២រូប
- ក្រុមប្រឹក្សារដ្ឋមន្ត្រី មានស្ត្រី៦រូប ក្នុងចំនួនសរុប៨២រូប។
- រដ្ឋមន្ត្រីមានស្ត្រីជារដ្ឋមន្ត្រី២រូប ក្នុងចំនួនរដ្ឋមន្ត្រីសរុប ទាំងអស់២៥រូប។
- រដ្ឋលេខាធិការ មានស្ត្រី៤រូប ក្នុងចំនួនសរុប ៥០រូប។
- អនុរដ្ឋលេខាធិការ មានស្ត្រី៥រូប ក្នុងចំនួនសរុប១៣២រូប។
- គ្មានស្ត្រីជាអភិបាលខេត្ត-ក្រុងទេ។
- មានស្ត្រីជាអភិបាលស្រុក១រូប ក្នុងចំនួនសរុប១៨៤រូប។
- មានស្ត្រីជាមេឃុំ១០រូប ក្នុងចំនួនសរុប១,៦២៣រូប។

- តួនាទីរបស់ស្ត្រីជាថ្នាក់ដឹកនាំនៅក្នុងសភាពាណិជ្ជកម្ម មាន៤រូប ក្នុងចំនួនសរុប៣៦រូប។

*តួនាទីស្ត្រីក្នុងវិស័យអប់រំ :*

- គ្រូបង្រៀនជាស្ត្រីមាន២១.៥៨៦នាក់ លើចំនួនសរុប៦១.៦៤២ នាក់។

៩/-ថ្នាក់សហគមន៍

*តួនាទីស្ត្រីក្នុងសហគមន៍ :*

- កម្មករក្នុងរោងចក្រៈ មានស្ត្រី៧៨.៨២៣នាក់ លើចំនួនសរុប ៨៨.១៧១នាក់ (៨៩.៣៨%)។
- ការកេងប្រវ័ញ្ចន៍លើកំលាំងពលកម្មរបស់ស្ត្រី ឧទាហរណ៍ លក់ខ្លួន ការងារលំបាកនៅតាមរោងចក្រកាត់ដេរ។
- ស្ត្រីមេផ្ទះ ជាចំនួនដ៏ធំមួយនៅក្នុងសហគមន៍ ដែលងាយទទួលរងគ្រោះ។
- ស្ត្រីពុំមានជំនឿទុកចិត្តក្នុងការសំរេចដោយខ្លួនឯងទេ ទាំងនៅកន្លែងធ្វើការនិងនៅក្នុងគ្រួសារ ហើយជាងនេះទៅទៀត គេពុំមានលទ្ធភាព និងសិទ្ធិគ្រប់គ្រងលើធនធានឡើយ។
- បើប្រៀបធៀបជាមួយបុរស ស្ត្រីបានទទួលការអប់រំតិចណាស់
- វប្បធម៌/ប្រពៃណី បានជំរុញមិនឱ្យស្ត្រីចូលរួមក្នុងផលប្រយោជន៍សហគមន៍។

- បន្ទាប់ពីមានការលែងលះគ្នា ការបែងចែកការទទួលខុសត្រូវក្នុងការចិញ្ចឹមកូនមិនមានលក្ខណៈស្មើភាពគ្នាទេ។
- ស្ត្រីមេម៉ាយ ត្រូវបានទទួលរង នូវការមើលងាយមើលថោកពីសង្គម។
- សម្លេងរបស់ស្ត្រី មិនត្រូវបានគេទទួលស្គាល់ឱ្យបានខ្ពង់ខ្ពស់ទេ។

**តួនាទីយេនឌ័រនៅក្នុងសង្គមស៊ីវិល :**

វប្បធម៌របស់សង្គមស៊ីវិល បង្ហាញឱ្យឃើញអំពីមនោគមវិជ្ជារបស់ប្រទេសជាតិ (រដ្ឋ)។ គ្រួសារ សាលារៀន វត្តអារាម ប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ អង្គការផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលមានទិសដៅស្រដៀងគ្នា ដូចជាអង្គការក្រៅរដ្ឋាភិបាល សហជីពពាណិជ្ជកម្ម ក្រុមនិយោជក់ ស្ថាប័នកីឡា ។ល។ ទាំងអស់នេះ គឺជាតំណាងសង្គមស៊ីវិលដែលបានកំណត់ជាធម្មជាតិពិតៗ សំរាប់ប្រទេសជាតិរបស់យើង (រដ្ឋរបស់យើង)។ លើសពីរដ្ឋធម្មនុញ្ញឬច្បាប់ទៅទៀត វប្បធម៌របស់សង្គមស៊ីវិលដែលបង្ហាញ អំពីអាកប្បកិរិយារបស់ប្រជាពលរដ្ឋដោយមានទំនាក់ទំនងទៅនឹងគោលគំនិតគ្រប់គ្រង ចំពោះស្ថានភាពដែលថា តើប្រជាពលរដ្ឋ គួរតែមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមកយ៉ាងដូចម្តេចខ្លះ? នៅក្នុងការងារនយោបាយសេដ្ឋកិច្ច និងសង្គម ហើយវប្បធម៌ នេះបានពន្យល់ប្រាប់ ចំពោះខ្លួនយើងទាំងអស់គ្នា និងចំពោះមនុស្សដទៃទៀត យ៉ាងជាក់ច្បាស់នូវអ្វីដែលយើងជឿថា វាមានលក្ខណៈធម្មតា និងជាអំពើល្អវាប្រាប់យើងអំពីអ្វីដែលត្រឹមត្រូវ និង

អ្វីដែលត្រឹមត្រូវ ហើយវាប្រាប់យើងនូវអ្វីដែលជាផ្លូវដ៏សមរម្យ ក្នុងការដឹកនាំជីវិតរបស់យើង។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវពឹងផ្អែកទៅលើមូលដ្ឋាន នៃជំនឿមិនត្រឹមតែចំពោះសិទ្ធិមនុស្សប៉ុណ្ណោះទេ តែថែមទាំងចំពោះសិទ្ធិស្មើគ្នា របស់ពលរដ្ឋគ្រប់រូបទាំងអស់ ដោយមិនគិតអំពីពូជសាសន៍ សាសនា ឬយេនឌ័រឡើយ។ ជាពិសេសនៅមាត្រាទី៤៥ និង៤៦នៃរដ្ឋធម្មនុញ្ញ បានហាមឃាត់មិនឱ្យមានការរើសអើង ការកេងប្រវ័ញ្ច ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការជួញដូរមនុស្ស លើសពីនេះទៅទៀត មាត្រាទី៤៦ បានសន្យាថា "រដ្ឋនិងសង្គមត្រូវផ្តល់ឱកាស ឱ្យបានគ្រប់គ្រាន់ដល់ស្ត្រី" ។ ដូច្នេះ ក្រមច្បាប់របស់យើងបានឆ្លើយតបទៅនឹងមូលដ្ឋាន នៃជំនឿដូចខាងលើនេះ ហើយជាការពិតណាស់ ប្រទេសកម្ពុជាបានចុះ ហត្ថលេខា និងឱ្យសច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិសំខាន់ៗ យ៉ាងច្រើនដែលការពារដល់សិទ្ធិជាមូលដ្ឋានរបស់ស្ត្រី នេះមានន័យថា ជាសិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន និងគ្មានការរើសអើង។

តែទោះជាយ៉ាងណាក៏ដោយ វាជាការពិតណាស់ថា ប្រសិនបើយើងពិនិត្យ ទៅលើវប្បធម៌នៃសង្គមស៊ីវិល នោះយើងនឹងឃើញថា សិទ្ធិទាំងនេះ ត្រូវបានគេបំភ្លេចចោល ត្រូវបានគេបដិសេធ ត្រូវបានគេរំលោភ និងត្រូវបានគេជាន់ឈ្លីនៅគ្រប់ទីកន្លែងទាំងអស់។ សូមពិចារណាឧទាហរណ៍ខ្លះៗ ដូចខាងក្រោមនេះ ៖

១/- គ្រួសារ :

- យោងតាមការស្រាវជ្រាវ ដែលធ្វើឡើងដោយអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងក្រសួងកិច្ចការនារី បានបង្ហាញថា អំពើហិង្សាក្នុងគ្រួសារ ដែលមានទម្រង់ទ្រាយជា ការវាយដំលើរាងកាយយ៉ាងធ្ងន់ធ្ងរទៅលើប្រពន្ធនិងកូន វាគឺជាអំពើដែលមិនអាចទ្រាំទ្របានហើយជាញឹកញាប់វាកើតឡើងប្រចាំថ្ងៃ ចំពោះស្ត្រីដែលយ៉ាងតិចណាស់មានស្ត្រីម្នាក់ក្នុងចំណោមគ្រួសារកម្ពុជាចំនួន៦គ្រួសារ។ ការស្រាវជ្រាវជាច្រើនរបស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារនាពេលថ្មីៗ នេះបានបង្ហាញឱ្យឃើញថា ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារចំនួន៥៧% ដែលបានស្លង់មតិ គឺជាអ្នកដែលទទួលរងជាទៀងទាត់ ពីអំពើចាប់រំលោភក្នុងចំណងអាពាហ៍ពិពាហ៍របស់គេ។
- យ៉ាងតិចណាស់ ក្មេងស្រីចំនួនពាក់កណ្តាល ដែលជាអ្នករងគ្រោះពីការជួញដូរផ្លូវភេទ គឺដោយសារតែឪពុកម្តាយរបស់គេយកទៅលក់ ហើយជនប្រព្រឹត្តអំពើជួញដូរនោះបានទទួលកម្រៃយ៉ាងច្រើន។
- ទោះបីជាមានមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញបានចែងថាអាពាហ៍ពិពាហ៍ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត រវាងភាគីទាំងពីរក៏ដោយ តាមការស្រាវជ្រាវនាពេលថ្មីៗនេះ បានបង្ហាញថា ស្ត្រីវ័យក្មេងជាច្រើន នៅតែទទួលរងការបង្ខិតបង្ខំឱ្យទទួលយកដៃគូរបស់គេ

ដែលឪពុកម្ដាយរបស់គេបានជ្រើសរើសឱ្យ ហើយករណីដែលធ្ងន់ធ្ងរជាងនេះទៅទៀត នោះគឺគេត្រូវបង្ខំឱ្យរៀបការជាមួយដៃគូដែលជាអ្នករំលោភគេទៅវិញ។

២/-សាលារៀន :

- ស្ត្រីកម្ពុជាប្រហែលជា ៤២%ដែលមានអាយុលើសពី១៥ឆ្នាំមិនដែលបានចូលរៀននៅសាលាទេ តែផ្ទុយទៅវិញអត្រានៃចំនួនបុរសមានតែពាក់កណ្ដាលនៃចំនួនស្ត្រីគឺ (២១%) ប៉ុណ្ណោះ។
- សិស្សប្រុស និងសិស្សស្រី មានអត្រាចុះឈ្មោះចូលរៀនស្មើរតែប្រហាក់ប្រហែលគ្នា រហូតដល់អាយុ១០ឆ្នាំ ក៏ប៉ុន្តែ ចំនួនសិស្សស្រីទាំងនោះ ត្រូវធ្លាក់ចុះ គឺទាបជាងអត្រាចុះឈ្មោះចូលរៀនរបស់សិស្សប្រុស។ នៅអាយុ១៥ឆ្នាំ ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសមាន ៥០% ច្រើនជាងសិស្សស្រី ហើយនៅអាយុ១៨ឆ្នាំ អត្រាចុះឈ្មោះ ចូលរៀនរបស់សិស្សប្រុស គឺស្មើនឹងអត្រាចុះឈ្មោះរបស់សិស្សស្រី ដល់ទៅចំនួន៣ដង។
- សិស្សប្រុសមានចំនួនច្រើននៅក្នុងមហាវិទ្យាល័យវេជ្ជសាស្ត្រនិងច្បាប់នេះមានន័យថា វិជ្ជាជីវៈទាំងនេះនឹងផ្ដល់ដល់ពួកគេ នូវឋានៈខ្ពស់ក្នុងសង្គម និងទទួលបានផលប្រយោជន៍យ៉ាងច្រើន។ នៅពេលដែលស្ត្រីឈានដល់ក័វិត ឧត្តមសិក្សាគឺជាធម្មតាគេ

ចូលសិក្សាក្នុងផ្នែកសិល្បៈ មនុស្សសាស្ត្រ និងគរុកោសល្យ។ សិស្សស្រីកម្រមានតំណាងនៅក្នុងវិទ្យាស្ថានបច្ចេកវិទ្យាណាស់។

៧/- ប្រព័ន្ធផ្សព្វផ្សាយ :

- ទោះបីជាមាត្រាទី៤៦ នៃរដ្ឋធម្មនុញ្ញបានហាមប្រាមមិនឱ្យមានអំពើអាសអាភាស ដែលអាចធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ស្ត្រីក៏ដោយក៏រូបរាងរបស់ស្ត្រី ត្រូវបានគេប្រើសំរាប់ការផ្សព្វផ្សាយពាណិជ្ជកម្ម និងសំរាប់ការលក់ដូរទំនិញ ដូចជារថយន្ត និងស្រាបៀរជាដើម។
- កម្មវិធីតាមទូរទស្សន៍ ជាធម្មតាបង្ហាញរូបរាងរបស់ស្ត្រីជាមនុស្សក្មេងនិងមានសម្ផស្សឆើតឆាយ ដែលជាមនុស្សទន់ខ្សោយចូលចិត្តសមគំនិតគ្នាល្ងង់ខ្លៅនិងស្តាប់បង្គាប់គេសំរាប់តែការសប្បាយរបស់បុរស។ ហើយកម្មវិធីទូរទស្សន៍ទាំងនេះ កម្របង្ហាញអំពីតួនាទីគំរូជាវិជ្ជមានរបស់ស្ត្រីឡើយ។
- បច្ចុប្បន្ននេះ សារពត៌មានជាច្រើន គឺពោរពេញទៅដោយសាច់រឿង ដែលនិយាយអំពីស្ត្រីរងគ្រោះ ពីការចាប់រំលោភផ្លូវភេទ ការជួញដូរ និងអំពើឃោរឃៅដែលដាក់ទោសទៅលើស្ត្រីដែលជាខ្ញុំបំរើនៅក្នុងផ្ទះ។ ប្រសិនបើយើងសិក្សាអំពីរឿងរ៉ាវទាំងនេះ ដោយប្រុងប្រយ័ត្ន ទោះជាយ៉ាងណាក៏ដោយ វាហាក់ដូចជាថា ស្ត្រីត្រូវបានគេធ្វើឱ្យរងគ្រោះលើសពីពីរដងទៅទៀត គឺមានន័យថា លើកដំបូងដោយសារតែអ្នករំលោភ

បំពានផ្ទាល់ហើយ លើកទីពីរដោយសារពត៌មាននេះឯង។ ជាធម្មតាមានរូបថតរបស់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលត្រូវបានគេបិតបាំងភ្នែកជិត ក្នុងគោលបំណងដើម្បីកុំឱ្យគេស្គាល់អត្តសញ្ញាណ ហើយដែលជាញឹកញាប់មានឥរិយាបថអៀនខ្មាស ដោយអោនក្បាលចុះក្រោម និងមានស្នាស្នាមកំព្រើង។ យើងត្រូវចោទសួរចំពោះ ខ្លួនយើងថា តើវាជាការអៀនខ្មាសរបស់អ្នកណា? ហេតុអ្វីបាន ជាស្ត្រីដែលរងគ្រោះ ត្រូវទទួលការអៀនខ្មាសនេះទៅវិញ? សូមអានសាច់រឿង តាមដានទាំងនេះ ហើយអ្នកនឹងរកឃើញថា វាគឺជាការកំសាន្តសំរាប់អ្នកអានដែលពញ្ញាក់អារម្មណ៍ចង់ដឹងពីរឿងរ៉ាវលំអិតនៃការរំលោភបំពានទៅលើស្ត្រីរងគ្រោះ ច្រើនជាងការស្វែងរកយុត្តិធម៌សំរាប់ស្ត្រីរងគ្រោះនោះទៅទៀត។

រដ្ឋធម្មនុញ្ញនិយាយពីអ្វីវាមិនសំខាន់ទេ តែភ្នាក់ងារនៃសង្គមស៊ីវិលបង្ហាញយ៉ាងច្បាស់ថា តើភាពមិនដឹងចំពោះសិទ្ធិស្មើភាព នៃសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិពិតជាមានន័យយ៉ាងដូចម្តេច? បុរសនិងស្ត្រីមិនបានទទួលសេចក្តីថ្លៃថ្នូរស្មើភាពគ្នាទេ។ ស្ត្រីត្រូវបានគេឱ្យតម្លៃទាបជាងបុរស។

យេនឌ័រ គឺនិយាយអំពីការកែតម្រូវឡើងវិញ នូវតុល្យភាពរវាងតម្លៃដែលប្រគល់ឱ្យស្ត្រី និងបុរសនៅក្នុងវិស័យនយោបាយសេដ្ឋកិច្ចនិងសង្គម។ យើងទាំងអស់គ្នាដែលធ្វើការ ដើម្បីកែតម្រូវតុល្យភាពនេះត្រូវ

យល់ឱ្យបានច្បាស់ថា ស្ត្រីខ្លួនឯងផ្ទាល់កំពុងតែភ័ន្តច្រឡំអំពីតម្លៃរបស់គេ។ អស់រយៈពេលជាច្រើនសតវត្សមកហើយ ស្ត្រីត្រូវបានគេធ្វើឱ្យជឿថា ខ្លួនគេជាមនុស្សទន់ខ្សោយ និងមានឋានៈតូចទាប។ ទិសដៅដំបូងរបស់យើង គឺធ្វើការពន្យល់ឱ្យស្ត្រីយល់ថា គេមានកំលាំងចិត្ត និងមានសមត្ថភាពស្មើគ្នានឹងបុរសដែរ ហើយពន្យល់ឱ្យគេយល់ថា គេមានសិទ្ធិស្មើគ្នាចំពោះយុត្តិធម៌ ការការពារ ការអប់រំ ។ល។ ដូចគ្នាទៅនឹងបុរសផងដែរ។ ការទទួលខុសត្រូវដ៏សំខាន់របស់យើងមួយទៀត គឺការតស៊ូមតិ និងការបញ្ចុះបញ្ចូល ដើម្បីឱ្យគេទទួលស្គាល់និងគោរពដល់សិទ្ធិទាំងនោះនៅក្នុងផ្លូវច្បាប់។

មិនត្រឹមតែមានគម្លាតយេនឌ័រ នៅក្នុងសង្គមស៊ីវិលប៉ុណ្ណោះទេ តែថែមទាំង មានគម្លាតយ៉ាងធំរវាងអ្វីដែលយើង (ដែលជាសង្គមមួយ) "និយាយ" ថាយើងកំពុងតែធ្វើនោះ ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញនិងក្រមច្បាប់ ហើយនិងចំពោះអ្វីដែលយើង "ធ្វើ" យ៉ាងពិតាកនោះផងដែរ។ នេះគឺជាគម្លាតនៃជីវភាពជាក់ស្តែង។ តើមនោគមវិជ្ជារបស់រដ្ឋស្ថិតនៅត្រង់ណា? តើវាស្ថិតនៅក្នុងរដ្ឋធម្មនុញ្ញ ឬនៅក្នុងអាកប្បកិរិយា ឬឥរិយាបថ និងជំនឿរបស់ប្រជាពលរដ្ឋ?

## ៦.១០_សុន្ទរកថាថ្លែងដោយ លោក ញ៉ែម ទណ្ឌថន នាយកប្រតិបត្តិនៃអង្គការសិទ្ធិមនុស្សខ្មែរ និងប្រឆាំងអំពើពុករលួយ ស្តីអំពី "ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត នៅក្នុងសង្គមស៊ីវិលកម្ពុជាសំដៅលើចំណុចខ្លាំងនិងចំណុចខ្សោយ"

សេចក្តីផ្តើម :

នៅលើពិភពលោកយើងនេះ វត្ថុមានជីវិតទាំងអស់ដែលនិយាយរួមទាំងសង្គមមនុស្ស និងសង្គមសត្វផងនោះ គឺសុទ្ធតែត្រូវពឹងផ្អែកទៅលើការធ្វើសេចក្តីសំរេចចិត្តទាំងស្រុងក្នុងជីវភាពរស់នៅរបស់ខ្លួនជាចាំបាច់។ ប៉ុន្តែ គ្រាន់តែមានការវិវត្តន៍ទៅខុសប្លែកគ្នារវាងសង្គមមនុស្សនិងសង្គមសត្វតិរច្ឆាន បិតត្រង់ចំណុចនៃប្រភេទជ្រើសរើសធ្វើសេចក្តីសំរេចចិត្តតែប៉ុណ្ណោះ ពោលគឺសង្គមមនុស្សចេះ យកសតិសម្បជញ្ញៈ និងគតិបណ្ឌិត **(Conscience & Wisdom)** របស់ខ្លួន ដែលមានតាំងពីកំណើតមកធ្វើជាមធ្យោបាយ សំរាប់សំរេចចិត្តជ្រើសរើសការរស់នៅទៅតាមលក្ខណៈបានសមរម្យថ្លៃថ្នូរ ដឹងខុសដឹងត្រូវនិងដឹងថា អ្វីជាការអាក្រក់និងដឹងថា អ្វីដែលជាការល្អ ដែលការនេះគឺធ្វើឲ្យខុសពីសង្គមសត្វទាំងស្រុង។

យើងដឹងច្បាស់ហើយថា សង្គមសត្វតិរច្ឆាន គឺមានការសំរេចចិត្ត ដោយនូវសតិសម្បជញ្ញៈ និងគតិបណ្ឌិត ក្នុងជីវភាពរស់នៅរបស់ពួកគេ ដែលប្រើមធ្យោបាយនៃការរស់នៅ និងដោះស្រាយបញ្ហាជីវិត ផ្អែកទៅតាមបែបប្រើការខាំហែកគ្នាស៊ី ដើម្បីរស់នៅតែរៀងៗ

ខ្លួននៃក្រុម ឬហ្វូងណាមានកម្លាំងខ្លាំងជាងគេ គឺត្រូវតែប្រើឥទ្ធិពលនោះ រំលោភបំពានទៅលើក្រុម ឬហ្វូងតូចៗជាងខ្លួនផ្សេងៗឯទៀតតាមទំនើងចិត្ត ដើម្បីបំពេញតែតណ្ហាស្រេកឃ្លានរបស់ហ្វូងខ្លួន ឱ្យស្កប់ស្កល់តែប៉ុណ្ណោះ។

ដូច្នេះហើយ បានជាក្រុមអ្នកជំនាញខាងចិត្តវិទ្យាបានពោលយ៉ាងនេះថា ការវិវត្តន៍ឡើងរបស់ក្រុមពពួកហ្វូងសត្វតិរច្ឆានគ្មានការរីកចំរើនអ្វីខាងសតិបញ្ញា ក្នុងការប្រើប្រាស់សតិសម្បជញ្ញៈ តាំងតែពីបុរាណកាលនៃដូនតារបស់ពួកគេតរៀងមក បើទោះ ពួកគេបានរស់នៅលើពិភពលោកនេះជាមួយនឹងសង្គមមនុស្សយ៉ាងណាក៏ដោយចុះ ក៏គ្មានបានរៀនសូត្រអ្វីពីសង្គមមនុស្សឡើយ។

ម្ល៉ោះហើយ ការសន្និដ្ឋានរបស់យើងនៅពេលនេះ គឺថា កាលណាសង្គមមនុស្សណាមួយ នៅលើលោកយើងនេះរស់ក្នុងសង្គមរបស់ពួកគេ ហើយពេលដែលជួបនូវបញ្ហាកើតឡើង មិនចេះដោះស្រាយបញ្ហារវាងគ្នានិងគ្នា តាមផ្លូវប្រាជ្ញា និងសតិសម្បជញ្ញៈ ដោយសន្តិវិធីនោះឡើយ។ ផ្ទុយទៅវិញ បើពួកសង្គមមនុស្សប្រើវិធីដោះស្រាយបញ្ហាដោយការខាំហែកហួរគ្នាក្នុងជីវភាពរស់នៅនោះ សំអាងលើកម្លាំងខ្លាំងរបស់ក្រុមបក្សពួករបស់ខ្លួន លោកអ្នកប្រាជ្ញបានប្រៀបសង្គមមនុស្សបែបនោះថា ដូចសង្គមហ្វូងសត្វតិរច្ឆានអញ្ចឹងដែរ។

## ទម្រង់ការដើម្បីដំណើរការក្នុងការធ្វើសេចក្ដីសំរេចចិត្ត
PROCEDURE GUIDE ON DECISION MAKING

ជាគោលការណ៏ ដើម្បីអាចធ្វើសេចក្ដីសំរេចចិត្តឱ្យបានល្អ និងឱ្យមានប្រសិទ្ធភាពខ្ពស់ទៅបាននោះ តែត្រូវដឹងអំពីចំណុចសំខាន់ៗជាមូលដ្ឋានចំនួនប្រាំយ៉ាងជាធាតុផ្សំគ្នា។ ឥឡូវនេះ យើងផ្ដើមដាក់សំណួរសំរាប់សង្គមស៊ីវិល ឬសង្គមកម្ពុជា ដែលមានការទាក់ទងនឹងគ្នាពីមួយទៅមួយដូចតទៅ :

១. តើសង្គមជាតិ ក៏ដូចជាសង្គមស៊ីវិលកម្ពុជារបស់យើងមានបញ្ហាអ្វីខ្លះ?
What type of the problem that the Cambodian Civil Society have.?

២. តើបញ្ហាទាំងឡាយនោះវាកើតឡើងតាំងពីពេលណាមក?
When these kinds of problem were happening..?

៣. តើបញ្ហាទាំងនោះ វាកើតឡើងនៅទីកន្លែងណា?
Where we did these problems happen..?

៤. តើនណាដែលជាអ្នកបង្ក ឬជាអ្នកនាំឱ្យកើតមានបញ្ហាទាំងនោះឡើង...?
Who are the creator or brought of these problem..?

៥. តើត្រូវធ្វើការដោះស្រាយបញ្ហាទាំងនេះ ដោយមធ្យោបាយយ៉ាងណា...?
How can we solve these problems.?

## ១. តើសង្គមស៊ីវិល ឬសង្គមកម្ពុជាមានបញ្ហាអ្វីខ្លះ?

សួរថា តើសង្គមស៊ីវិលឬសង្គមជាតិកម្ពុជាមានបញ្ហាអ្វី ពីមុននិងនាពេលបច្ចុប្បន្ននេះខ្លះ? បើយោងតាម ការបកស្រាយរបស់ពួកអ្នកសង្គមវិទូខាងបស្ចិមប្រទេស គេបានហៅបញ្ហាសង្គ្រាមរ៉ាំរ៉ៃអូសបន្លាយជាង៣០ឆ្នាំ នៅកម្ពុជាកន្លងមក ទើបបញ្ចប់ទៅថ្មីៗនេះថាជា សង្គ្រាមស៊ីវិលក្នុងស្រុក ដែលបណ្តាលមកពីការឈ្លោះប្រកែករវាងជាតិ សាសន៍បងប្អូនគ្នាឯង ដោយបានបង្កឬបានញុះញង់ឱ្យមានជម្លោះនេះឡើង ពីពួកជនបរទេសនៅជិតខាង។ ជាការពិតណាស់ ដែលថាសង្គមកម្ពុជាគឺពិតជាមានបញ្ហាកន្លងមកប្រាកដមែន ហើយបញ្ហាធំជាងគេ នោះគឺវិនាសកម្មសង្គ្រាម ដែលលទ្ធផលបានធ្លាក់មកលើសង្គមជាតិទាំងមូល ដោយបន្សល់ទុកទុក្ខវិបត្តិ និងបញ្ហារាប់ពាន់ម៉ឺនបញ្ហា ដោយព្រោះពួកអ្នកដឹកនាំគណបក្សនយោបាយបង្កឡើងទាំងស្រុង។

តើនាពេលបច្ចុប្បន្ននេះ ក្រោយពីមានរដ្ឋាភិបាលថ្មីមួយកើតឡើងពីការបោះឆ្នោត សំរាប់ចូលខ្លួនមកបំរើសង្គមជាតិរួចហើយ តើមានកើតបញ្ហាថ្មីៗអ្វីខ្លះថែមទៀត ដែលបានបង្កឱ្យសង្គមជាតិរបស់យើង..ត្រួតលើបញ្ហាចាស់ៗ?

### បញ្ហាចាស់ដែលកើតមានឡើងកន្លងមករួមមាន :

(១).ធ្វើឱ្យមនុស្សស្លាប់ច្រើន ពិការភាព ក្មេងកំព្រា ស្ត្រីមេម៉ាយ និងនាំឱ្យខ្វះធនធានមនុស្ស (២)_សេដ្ឋកិច្ចបានត្រូវបំផ្លាញ និងសម្បត្តិ

ទ្រព្យជាតិត្រូវបានបំផ្លាញទាំងស្រុង ដែលនាំឱ្យប្រទេសជាតិ និងសង្គម ស៊ីវិលធ្លាក់ខ្លួនក្រីក្រ (៣)_បំផ្លាញទាំងស្រុង នូវហេដ្ឋារចនាសម្ព័ន្ធ សង្គមជាតិ ធ្វើឱ្យគ្មានមូលដ្ឋានច្បាប់ សំរាប់គ្រប់គ្រងលើគ្រប់វិស័យទាំង អស់ ។ល។

បញ្ហាថ្មីៗ ដែលទើបកើតមានឡើងជារួចមាន :
(១)_ច្បាប់ទើបបង្កើតឡើងថ្មីៗ មានកង្វះខាត មន្ត្រីទុច្ចរិតធ្វើបង្អែក ឱ្យឈ្មួញខិលខូច ការឃុបឃិតមិនអនុវត្តច្បាប់ ប្រព្រឹត្តបំពានច្បាប់. និង និទណ្ឌភាព (២)_បញ្ហាអំពើពុករលួយបាននាំមកនូវ ៖

(ក)_បំផ្លាញសេដ្ឋកិច្ចជាតិ បាត់បង់ចំណូលជាតិ ចូលធ្វើការស្ទូក ប៉ាន់មនុស្សគ្មានការងារធ្វើ និងធ្វើឱ្យកើតមានភាពក្រីក្រ។

(ខ)_នាំដល់ការរំលោភសិទ្ធិមនុស្ស ។

(គ)_បំផ្លាញរចនាសម្ព័ន្ធលទ្ធិប្រជាធិបតេយ្យ។

(ឃ)_ចៅក្រមកាត់ក្តីស៊ីសំណូកកើតមានអំពើអយុត្តិធម៌ក្នុងសង្គម ជាតិ។

(ង)_បំផ្លាញហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិ។

(ឆ)_នៅទីបំផុតនឹងនាំឱ្យប្រទេសជាតិវិលត្រឡប់ទៅរកសង្គ្រាម ជាថ្មីម្តងទៀត ។

២_តើបញ្ហាទាំងឡាយនេះបានកើតឡើងនៅពេលណា?

យើងបានបញ្ជាក់រួចហើយថា បញ្ហាចាស់គឺវាបានកើតឡើងកាលពី៣០ឆ្នាំកន្លងទៅហើយ និងបញ្ហាថ្មីវាចាប់កើតឡើងពីមុំ ៧ឆ្នាំចុងក្រោយបន្ទាប់ពីមានការបោះឆ្នោតឆ្នាំ១៩៩៣ និង ឆ្នាំ១៩៩៨។ រាល់បញ្ហាដែលបន្សល់ពីចាស់មក និងបញ្ហាថ្មីៗ វាសុទ្ធតែធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការស្តារ និងការអភិវឌ្ឍន៍សង្គមជាតិ ក្នុងនោះសង្គមស៊ីវិល គឺងាយទទួលរងនូវផលប៉ះពាល់ និងគ្រោះថ្នាក់ជាងគេ ដោយព្រោះថា ឥទ្ធិពលបញ្ហាទាំងចាស់និងថ្មីវាមានប្រភពធំបណ្តាលមកពីការប្រព្រឹត្តិអំពើពុករលួយ ហើយអំពើពុករលួយនេះវាច្រើនតែកើតឡើងរវាងពួកឈ្មួញទុច្ចរិតធំៗ និងពួកមន្ត្រីអាជ្ញាធរសាធារណៈទុច្ចរិតថ្នាក់ធំៗនៃស្ថាប័នជាតិនានា។

៣. តើបញ្ហាបានកើតឡើងនៅកន្លែងណា?

តាមការមើលឃើញបញ្ហាទាំងឡាយ គឺវាកើតឡើងនៅក្នុងសង្គមជាតិកម្ពុជាតែម្តង។ ដោយបញ្ហាខ្លះវាបានហូរចូលមកពីខាងក្រៅសង្គមតាមការប្រជែងរបស់ចរន្តលទ្ធិនយោបាយពីរ គឺលទ្ធិកុម្មុយនីស្ត និងលទ្ធិប្រជាធិបតេយ្យសេរីផង និងកើតឡើងពីមនុស្សក្នុងសង្គមជាតិផង។ ចំពោះប្រភពបញ្ហាថ្មីៗនេះ គឺបណ្តាលមកពីកើតមានគោលនយោបាយជាតិថ្មី លើពាក្យស្លោក មួយឃ្លាថា "ការបង្រួបបង្រួមជាតិ និងការផ្សះផ្សាជាតិ" ដែលនាំឱ្យពួកមន្ត្រីរាជការ ឱកាសនិយមមួយចំនួន បានជ្រកក្រោមផ្លាក

និងប្រើថ្នាក់នេះ ធ្វើអំពើផ្តេសផ្តាសដោយប្រព្រឹត្តខុស ហើយគឺអត់មានទោស។ គួបផ្សំ និងចរន្តថ្មីទំនើបរបស់ពិភពលោកនៃប្រទេសជឿនលឿនធំៗ ប្រជែងគ្នាខាងបច្ចេកវិទ្យាសេដ្ឋកិច្ច ដែលគេហៅចរន្តថ្មីនេះថា"សកលភាវូបនីយកម្ម" Globalization ហើយដែលសារៈប្រយោជន៍ និងផលប៉ះពាល់របស់វាមកលើសហគមន៍នៃប្រទេសតូចៗ ឬប្រទេសកំពុងអភិវឌ្ឍន៍ ដូចប្រទេសកម្ពុជាជាដើម ត្រូវទទួលរងនូវបញ្ហាជាច្រើនដោយព្រោះប្រទេសងើបមកពីការអន់ថយរាប់សិបឆ្នាំ ត្រូវបើកចំហទទួលយក។ ពួកអ្នកសង្គមវិទូបានធ្វើវិភាគថា សង្គមមនុស្សជាតិទាំងអស់ ដែលរស់នៅលើពិភពលោកនាបច្ចុប្បន្ននេះ បើទោះជាចង់ទទួលឬមិនចង់ក្តីក៏គេពុំអាចជៀសចេញផុតពីចរន្តថ្មីនេះបានឡើយ ដោយហេតុថា មនុស្សលោកនាសម័យបច្ចុប្បន្ននេះ ជាពិសេសសង្គមខ្មែរ គេបានឈានចូលមកដល់សង្គមសហស្សវត្សរ៍ថ្មីមួយ ដែលពេញដោយចំណង់ចំណូលចិត្តចាប់យកតែបច្ចេកវិជ្ជាថ្មីៗ ទំនើបរបស់ពិភពលោក (A New World Civilization Technology)។

ដូច្នេះហើយ បានជាយើងឃើញបញ្ហាថ្មីៗ ដែលទើបកើតមានឡើង នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន គឺវាទំនើបហើយប្លែកៗរាប់មិនអស់ឡើយ ហើយស្របពេលជាមួយគ្នានឹងសង្គមកម្ពុជាទើបបង្កើតឱ្យមានច្បាប់ថ្មីៗ នៅមានចន្លោះខ្វះខាតច្រើនផងនោះ មន្ត្រីអាជ្ញាធរសាធារណៈ នៃស្ថាប័នជាតិមួយចំនួនធំ បានឃុបឃិតប្រព្រឹត្តអំពើ

ពុករលួយជាមួយឈ្មួញទុច្ចរិតធំៗ កើតមានឡើងកាន់តែច្រើនថែមទៀត ហើយនេះគឺជាចំណោទបញ្ហាយ៉ាងធ្ងន់ធ្ងរ។

៤. តើនរណាជាអ្នកបង្កើត ឬនាំមកនូវបញ្ហាទាំងនេះ?

យើងមានការស្ទាក់ស្ទើរក្នុងចិត្ត ដោយលំបាកនឹងចង្អុលដាក់ជនណាម្នាក់ ឬក្រុមបក្សពួកណាមួយណាស់ ពីព្រោះថា បញ្ហានៅក្នុងសង្គមកម្ពុជារបស់យើង ដូចបានពោលជំរាបជូនខាងលើរួចមកអញ្ចឹង គឺមានបញ្ហា និងរឿងរ៉ាវចាស់-ថ្មីត្រួតស៊ីគ្នាចាក់ស្រេះ ដែលបញ្ហាខ្លះបានជ្រករស់មានជីវិតក្រោមផ្លាក នៃការផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ រកធ្វើការវះកាត់ពុំចេញ ជាប់ជំពាក់តគ្នាច្រើនស្ទើររាប់មិនអស់។

ប៉ុន្តែ មិនមែនមានន័យថា យើងពុំអាចរកមុខពួកដែលបង្កនិងបង្កើតបញ្ហាទាំងអស់នេះមិនឃើញនោះឡើយ បើប្រសិនជាយើងចង់រក។ ដូចបានជំរាបជូនរួចមកហើយ នៅក្នុងចំណុចខាងលើតាំងពី ឆ្នាំ១៩៩៣ មកម្លេះ ដើម្បីដោះស្រាយបញ្ហាចាស់កន្លងមកគឺត្រូវប្រើ ពាក្យ បង្រួបបង្រួមជាតិ និងការផ្សះផ្សាជាតិ ដោយពុំអាចនរណាម្នាក់គាស់កកាយរឿងចាស់មកនិយាយបានឡើយ ឬរើករកមុខជនណាជាមេនាំបញ្ហាបានឡើយ។

ដូច្នេះ ចំពោះយោបល់របស់ខ្ញុំផ្ទាល់ បញ្ហា ឬរឿងចាស់ៗទាំងនោះ អាចនឹងទុកមួយឡែកសិនចុះ ហើយបែរមករកមើលនូវបញ្ហាថ្មីៗ ដែលទើបកើតមានឡើង ដែលយើងគិតចាប់ត្រឹមពីឆ្នាំ១៩៩៣ ដែលមាន

អាជ្ញាធរជាតិថ្មី កើតចេញពីការបោះឆ្នោត ជាទូទៅ ថ្នាក់ជាតិការនេះ អាចជួយឱ្យយើងស្វែរកមុខឃើញថា តើជនណាឬបក្សពួកក្រុមណា ឬមន្ត្រីអាជ្ញាធរសាធារណៈណា ឬក្រុមពួកឈ្មួញណា ដែលបានប្រព្រឹត្តអំពើពុករលួយ ឬប្រព្រឹត្តខុសច្បាប់ បង្កឱ្យមានអំពើអយុត្តិធម៌មកលើសង្គមជាតិ ដូចជានាំធ្វើឱ្យមនុស្សស្លាប់ និងប្រព្រឹត្តអំពើអសកម្មផ្សេងៗមកលើសង្គមជាតិរបស់យើងបានយ៉ាងងាយ។ ដោយកំហុសឆ្គង និងការធ្វើខុសទាំងនេះ អាចចាប់ផ្តើមរាប់ពីពេលនេះ តទៅមុខយើងលែងលើកទោសឱ្យទៀត ហើយព្រោះ សង្គមជាតិយើងខាតបង់ពេលវេលា ទ្រព្យសម្បត្តិធនធានមនុស្សច្រើនណាស់ហើយ ដែលលើកនេះមិនលំបាកនឹងកំណត់ឬរកមុខ ថាតើជនណាឬក្រុមបក្សពួកណា ដែលត្រូវប្រឈមមុខចំពោះមុខច្បាប់ និងចំពោះមុខសង្គមជាតិជាប្រវត្តសាស្ត្រនោះឡើយ។

### ៥_តើយើងត្រូវដោះស្រាយដោយយ៉ាងដូចម្តេចចំពោះបញ្ហាទាំងនេះ?

តាមការឃ្លាំមើលពីសហគមន៍អន្តរជាតិ ក៏ដូចជាសហគមន៍ក្នុងតំបន់ និងសហគមន៍ជាតិផងដែរ ចំពោះមុខនៃបញ្ហារបស់សង្គមកម្ពុជាបច្ចុប្បន្ននេះ គឺរដ្ឋាភិបាលអាណត្តិទី១ និងរដ្ឋាភិបាលសេដ្ឋកិច្ចអាណត្តិទី២ (រដ្ឋាភិបាលនៅទីនេះគឺរាប់ទាំងរដ្ឋ សភា ព្រឹទ្ធសភា តុលាការ និងអាជ្ញាធរប្រតិបត្តិច្បាប់ឬអនុវត្តច្បាប់ ឬដែលបានបង្កើតឡើងដោយការបោះឆ្នោតដោយពលរដ្ឋកម្ពុជាទូទៅ ពីឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៨ ត្រូវធ្វើការប្រឈមមុខដោះស្រាយ ចំពោះបញ្ហាទាំងឡាយនេះតទៅដោយគ្មានលក្ខខ័ណ្ឌអ្វីទាំងអស់ ក្រៅពីការកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ

ស្ថាប័នជាតិឡើងវិញជាបន្ទាន់ ពុំដូច្នោះទេ រដ្ឋាភិបាលទាំងពីរអាណត្តិនេះ ពិតជាត្រូវទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រសង្គមជាតិជាប្រាកដ។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាចំពោះមុខនេះឱ្យចេញ គឺការធ្វើសេចក្ដីសំរេចចិត្តរបស់ស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ នៃអាណត្តិទាំងពីរនេះ ដោយផ្អែកលើការកំណែទម្រង់លើគ្រប់វិស័យ ហើយល័ក្ខខ័ណ្ឌសំរាប់ការកែទម្រង់ គឺត្រូវធ្វើឱ្យប្រាកដតាមរូបមន្តបើកចំហនៃការចូលរួមពីសង្គមស៊ីវិល NGOs ឱ្យបានទូលាយ រាល់ការផ្លាស់ ប្ដូរមតិយោបល់សំរាប់ធ្វើជាអនុសាសន៍លើការកែទម្រង់នេះ ដើម្បីឱ្យមានប្រសិទ្ធភាពល្អនៃគោលការណ៍ **អភិបាលកិច្ចល្អ**។

នៅពេលនេះសង្គមស៊ីវិលកម្ពុជា អាចសំរេចចិត្តរបស់ខ្លួនបាន ហើយចំពោះជំហរនយោបាយ កំណែទម្រង់រដ្ឋបាលសាធារណៈ ប្រព័ន្ធតុលាការ កងទ័ព ប៉ូលីស សេដ្ឋកិច្ច បង្កើតច្បាប់ប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន។ ដើម្បីធ្វើឱ្យមានអភិបាលកិច្ចល្អពិតៗ ដែលពីមុនវិស័យទាំងនេះ គឺបានធ្វើឱ្យកើតមានឡើងនូវអំពើអសកម្មជាច្រើនដល់ការគ្រប់គ្រងសហគមន៍ជាតិទាំងស្រុង។ យើងនៅចាំទ្រឹស្ដីមួយឃ្លារបស់អ្នកចិត្តវិទ្យាថា "គេមិនត្រូវខ្លាចចំពោះមនុស្សដែលប្រព្រឹត្តខុសហើយ ដល់ពេលដឹងថា ខ្លួនធ្វើខុស ធ្វើការកែកំហុសនោះឡើងវិញឡើយ ក៏ប៉ុន្តែ គេខ្លាចបំផុតចំពោះមនុស្សណាដែលប្រព្រឹត្តខ្លួនខុសហើយនៅពុំព្រមកែកំហុសនាំងនោះ"។

តាមទ្រឹស្តីខាងលើនេះ សង្គមស៊ីវិលកម្ពុជានៅមានសង្ឃឹមច្រើនគួរសម ចំពោះរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ក្នុងការកែទម្រង់ស្ថាប័នទាំងឡាយរបស់ជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងវិញ បើប្រសិនណាជាគេបានដឹងអំពីលក្ខខ័ណ្ឌនៃនីតិវិធីប្រព័ន្ធគ្រប់គ្រង តាមបែបប្រជាធិបតេយ្យ។ បើយោងបទពិសោធន៍ជិត១០ឆ្នាំក្នុងអាណត្តិទាំងពីរនេះ ប្រព័ន្ធគ្រប់គ្រងគឺពិតជាខុសឆ្គងមែនដោយប្រៀបរដ្ឋាភិបាលរាជាណាចក្រថ្មី អាស្រ័យធម្មនុញ្ញ លក្ខខ័ណ្ឌបែងចែកអំណាច និងការប្តូរវេណតាមអាណត្តិ ឱ្យទៀងទាត់ តាមរយៈការបោះឆ្នោតដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ។ល។ ចំពោះឆន្ទៈពិតដូចការរៀបរាប់មកនេះ យោបល់ខ្ញុំផ្ទាល់ថា សង្គមស៊ីវិលត្រូវតែធ្វើការគាំទ្រ ដោយឡែកជំហររបស់អង្គការក្រាកូផ្ទាល់ ដែលធ្វើការងារលើវិស័យសិទ្ធិមនុស្ស និងការងារអប់រំមហាជនប្រឆាំងនឹងអំពើពុករលួយ សូមគាំទ្ររាជរដ្ឋាភិបាលយ៉ាងពេញទំហឹង។ ព្រោះខ្ញុំយល់ថា គ្មានសកម្មភាពណាមួយ ដែលធ្វើទៅហើយ ពុំអាចជៀសផុតពីកើតមានបញ្ហា ឬមានកំហុសខ្លះនោះឡើយ ហើយក៏គ្មានរដ្ឋាភិបាលណាមួយនៅលើលោកយើងនេះគ្រប់គ្រងប្រទេសមួយដោយល្អឥតខ្ចោះ១០០%នោះដែរ។

ចំពោះការសំរេចចិត្តរបស់អង្គការសិទ្ធិមនុស្សខ្មែរ និងប្រឆាំងអំពើពុករលួយ ហៅកាត់ថា **អសខបព** / **KHRACO** សូមប្រកាសជាចំហរថា ធ្វើការគាំទ្រជំហរគោលនយោបាយកែទម្រង់ របស់រដ្ឋាភិបាលសេដ្ឋកិច្ចអាណត្តិទី២នេះ ដើម្បីធ្វើឱ្យមានអភិបាលកិច្ចល្អ ដោយអង្គការសូមចូលរួមចំណែកសហការជួយដោះស្រាយបញ្ហាសង្គម ដោយធ្វើការងារ

របស់ខ្លួនទៅតាមលក្ខន្តិកៈអង្គការ (១)_លើកតម្កើង និងការពារសិទ្ធិមនុស្ស (២)_ធ្វើការអប់រំ ដោយចលនាមហាជនគ្រប់លំដាប់ថ្នាក់នៅក្នុងសហគមន៍ជាតិ ឱ្យប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមគ្រប់រូបភាព ដែលអាចធ្វើទៅបានដើម្បីស្ដារនាសេដ្ឋកិច្ចប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

សេចក្ដីសន្និដ្ឋានជារួមចំពោះសង្គមស៊ីវិលកម្ពុជា :

អង្គការ KHRACO សូមជូនយោបល់ចំពោះអង្គការ សមាគមក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនានាទាំងអស់ ដែលជាភ្នាក់ងាររបស់សង្គមស៊ីវិលកម្ពុជាទៅលើចំណុចខ្លាំង និងខ្សោយ ក្នុងដំណើរការធ្វើសេចក្ដីសំរេចចិត្តរបស់ខ្លួនដូចតទៅ ៖

<u>ចំណុចខ្សោយ</u> : កន្លងមកចំណុចខ្សោយធំៗ របស់សង្គមស៊ីវិលកម្ពុជាដែលយើងមើលឃើញជារួមមាន :

១_ ការចងក្រងបណ្ដាញអង្គការសមាគម ដែលមានចរិតដូចគ្នាឱ្យពុំសូវបានត្រឹមត្រូវល្អឡើយ។

២_ ធ្វើគំរោងការណ៍ជួយអភិវឌ្ឍន៍សហគមន៍គ្មានចំណុចរួមឬត្រួតស៊ីគ្នាទៅលើបញ្ហាដដែល។

៣_ ប្រភពជំនួយពីសហគមន៍អន្តរជាតិ ដែលបានផ្ដល់មកប្រើមិនសូវចំទិសដៅប្រាកដ។

៤_ ការរិះគន់ ឬគាំទ្រ ក្នុងជំហរនយោបាយកែទម្រង់របស់រដ្ឋាភិបាលកម្ពុជា ច្រើនគ្មានឯកភាពគ្នាជាមូលដ្ឋាន។

៥- អង្គការ សមាគមមួយចំនួនបានធ្លាក់ខ្លួនជាឧបករសំរាប់ពួកអ្នកនយោបាយ និងគណបក្សនយោបាយ។

៦- មានចិត្តឬទស្សនៈលាក់ចាំងរវាងគ្នា ខាងប្រភពផ្ដល់ជំនួយនិងខ្វះការជួយជ្រោមជ្រែងអង្គការ សមាគមតូចៗជាដៃគូ។

<u>ចំណុចខ្លាំង</u> : កន្លងមកអង្គការ សមាគមជាតិ និងអន្តរជាតិមួយចំនួនបានជួយដល់ការអភិវឌ្ឍន៍សហគមន៍ដូចជា ៖

១- មានគោលដៅ ឬទិសដៅធ្វើសកម្មភាព និងកម្មវិធីជួយដល់សង្គមលើវិស័យសិទ្ធិមនុស្ស និងប្រជាធិបតេយ្យបានល្អ។

២- អង្គការសមាគមជាតិ និងអន្តរជាតិមួយចំនួន ដែលមានទស្សនៈនិងគោលដៅសកម្មភាពដូចគ្នាឬប្រហាក់ប្រហែល។ គ្នា បានចងក្រងគ្នាជាបណ្ដាញបានល្អបង្គួរ។

៣- ធ្វើការកោះប្រជុំជាទូទៅ ឬសិក្ខាសាលាបានល្អនៅក្នុងការជំរុញឱ្យមានការកែទម្រង់អភិបាលកិច្ចល្អ និងតម្លាភាព។

៤- មានមតិស្របគ្នាលើការធ្វើការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋនៅកម្ពុជាឡើងវិញ។

៥- បានខិតខំផ្សព្វផ្សាយ និងឃោសនារកថវិកាបានច្រើនពីសហគមន៍អន្តរជាតិសំរាប់ស្ថាបនាសហគមន៍ជាតិ។

៦- មានមតិស្របគ្នាលើការធ្វើច្បាប់ សំរាប់ប្រឆាំងនឹងអំពើពុករលួយ ដើម្បីស្ថាបនាសេដ្ឋកិច្ចជាតិ។

ចំណុចឬអនុសាសន៍ដែលរដ្ឋាភិបាលកម្ពុជាគួរចងចាំ :

បើរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន គ្រាន់តែសន្យាដោយពាក្យសម្ដីទទេ ចំពោះសង្គមជាតិទូទៅ ឬសង្គមស៊ីវិល នោះគឺមិនទាន់គ្រប់គ្រាន់ឡើយ ការវាយតម្លៃថា ធ្វើបានល្អឬមិនល្អនោះ គឺមិនផ្អែកលើការសន្យានោះឡើយ។ តែការសំខាន់បំផុតនោះ គឺត្រូវអនុវត្តឱ្យបានទៅតាមនីតិវិធីដូចដែលបាន សន្យារបស់ខ្លួនទាំងក្នុងល័ក្ខខ័ណ្ឌជំនួយបរទេសក្ដី ឬថវិកាជាតិក្ដី ទើបអាចទទួលយកជាការបាន។ ត្រូវមានគោលការណ៍កំណត់ច្បាស់លាស់ ហើយជ្រើសរើសយកនូវវិស័យអ្វីខ្លះ ដែលជាអាទិភាពក្នុងការចាប់ផ្ដើមធ្វើមុនគេ និងធ្វើជាបន្តទៅមុខទៀត ហើយគ្រោងការនេះត្រូវកំណត់កាលវិភាគបញ្ចប់នៅពេលណា។ល។

កន្លងមករដ្ឋាភិបាលបានសន្យាមិនត្រឹមត្រូវដល់សង្គមស៊ីវិល និងម្ចាស់ជំនួយ ជាពិសេស គឺសហគមន៍អន្តរជាតិ នៅលើវិស័យមួយចំនួនដូចជា (១)_ការឈប់អនុញ្ញាតឱ្យមានច្បាប់កាប់ព្រៃឈើ ឬទប់ស្កាត់បទល្មើសឱ្យបាន ប៉ុន្តែ នៅតែឃើញមានការកាប់ព្រៃឈើ បន្តតែដដែរ។ (២)_សន្យាថា រៀបចំធ្វើច្បាប់ប្រឆាំងអំពើពុករលួយ តាំងពីឆ្នាំ ១៩៩៥ ប៉ុន្តែ មកដល់ពេលនេះគឺ ៥ឆ្នាំហើយ មិនទាន់មានច្បាប់នោះនៅប្រើប្រាស់នៅឡើយទេ (៣)_បានសន្យាថា ដាក់បញ្ចូលឱ្យមានបេក្ខភាព នារីនៅក្នុងច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ប៉ុន្តែមិនបានដាក់ឡើយ។ល។ ទាំងនេះគឺជាចំណុចខ្លះ ដែលមើលឃើញ

និងឮគ្រប់គ្នា ដែលរដ្ឋាភិបាល ទាំងអាណត្តិទី១ ក៏ដូចជា អាណត្តិទី២ បានប្រកាសប្រាប់សកល។

ដូច្នេះ សង្គមស៊ីវិលនិងប្រទេសអ្នកផ្ដល់ជំនួយទាំងអស់ គេអាចនឹងសំរេចចិត្តដកក្ដីទុកចិត្ត ចំពោះរដ្ឋាភិបាលសេដ្ឋកិច្ចអាណត្តិទី២ នេះវិញ ពីព្រោះដោយគ្រាន់តែនិយាយសន្យាតែពាក្យទទេ ហើយគ្មានការអនុវត្តន៍អ្វីសោះ ឬក៏គ្រាន់តែធ្វើជានាមៗ ឱ្យល្អមើលរួចតែ ពីដៃតែប៉ុណ្ណោះ ហើយខ្វះឆន្ទៈពិតប្រាកដ។

## គោលការណ៍អភិបាលកិច្ចល្អ

**PRINCIPLE OF GOOD GOVERNANCE**

### និយមន័យ : តើអ្វីទៅដែលហៅថា អភិបាលកិច្ចល្អ?

Definition: What is Good Governance?

ដែលហៅថាអភិបាលកិច្ចល្អ គឺជាការគ្រប់គ្រងដែលមានទម្រង់ការមួយបែប ដោយមានការព្រមព្រៀង សុខចិត្ត ស្រុះស្រួលគ្នា ពីសំណាក់សមាជិករបស់សង្គមរស់នៅក្នុងសហគមន៍នោះ ដែលផ្អែកទៅលើគោលការណ៍ច្បាប់បញ្ញត្តិនៃការគ្រប់គ្រងប្រទេស ឬរដ្ឋជាមូលដ្ឋាន ដោយពុំបង្ករឱ្យមានការរំលោភបំពាន ក្នុងការធ្វើប្រតិបត្តិការជាប្រចាំ។

## លក្ខណៈធាតុផ្សំចម្បងៗនៃអភិបាលកិច្ចល្អ
(The Main Character Component of The Good Governance)

ដើម្បីឱ្យមានដំណើរការអភិវឌ្ឍន៍ធ្វើអភិបាលកិច្ចល្អ ប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពខ្ពស់នោះ ចាំបាច់គេត្រូវមានធាតុផ្សំចម្បង ៧ យ៉ាងដែលមានលំក្ខខ័ណ្ឌដូចតទៅ ៖

១_និត្យានុកូលភាព Legality

២_ការចូលរួម Participation

៣_នីតិបញ្ញត្តិ Legislative

៤_នីតិប្រតិបត្តិ Executive

៥_នីតិវិធិច្ឆ័យ Judiciary

៦_គណនេយ្យភាព Accountability

៧_តម្លាភាព Transparency.

## ១. និត្យានុកូលភាព LEGALITY

តាមទ្រឹស្ដីសង្គមប្រជាធិបតេយ្យ ចំពោះប្រព័ន្ធដឹកនាំគ្រប់គ្រង និងចាត់ចែងការ គឺគេត្រូវតែផ្អែកទៅលើច្បាប់ជាអ្នកកំណត់ទាំងស្រុង។ ពោលគឺស្ថាប័នជាតិកំពូលៗទាំងអស់ ត្រូវតែមានការបោះឆ្នោតជ្រើសរើសឡើងពីសំណាក់ប្រជាពលរដ្ឋនៃសហគមន៏នោះ ដែលការបោះឆ្នោតនេះ ត្រូវតែធ្វើឡើងដោយសេរី យុត្តិធម៌ និងត្រឹមត្រូវជាទីបំផុត។ ចំពោះការគ្រប់គ្រង ដឹកនាំ និងចាត់ចែងការវិញ គេត្រូវធ្វើការបែងចែកអំណាច

ស្របតាមច្បាប់រវាងអង្គនីតិនីមួយៗ នៃស្ថាប័នជាតិទាំងនោះឱ្យដាច់ពីគ្នា ដែលនេះជាកត្តាចាំបាច់បំផុត។

## ២. ការចូលរួម (PARTICIPATION):

ចំណុចសំខាន់ជាមូលដ្ឋានគ្រឹះ នៃអភិបាលលកិច្ចល្អ គឺត្រូវមានការចូលរួមពីសមាជិកសង្គមនៃរដ្ឋ ឬប្រទេសនោះ ដែលឱ្យស្របតាមគោលការណ៍លិទ្ធិប្រជាធិបតេយ្យ ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិមនុស្ស ជាមូលដ្ឋាននៅក្នុងការបញ្ចេញមតិ។ ការចូលរួមក្នុងការជ្រើសរើស តំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោត ដូចជាការជ្រើសរើសសភា តំណាងរាស្ត្រក្រុមប្រឹក្សាឃុំ សង្កាត់ តុលាការជាតិនិងប្រធានាធិបតីជាដើម។ល។ ពោលគឺនៅពេលកើតមានអង្គការនីតិប្បញ្ញត្តិ អង្គការនីតិតុលាការ អង្គការនីតិប្រតិបត្តិ រួចមកការធ្វើច្បាប់ ឬការអនុវត្តន៏ច្បាប់នានា របស់អង្គការនីតិទាំង៣ ចាំបាច់ត្រូវមានការចូលរួមពីសំណាក់សមាជិកសហគមន៏ជាតិ។ ធ្វើបែបនេះ អង្គការនីតិទាំង៣ អាចទទួលបានការគាំទ្រពីសង្គមជាតិ ទាំងការធ្វើច្បាប់និងការអនុវត្តន៏។ តែផ្ទុយទៅវិញ បើអង្គការនីតិទាំង៣ធ្វើច្បាប់នានាស្ងាត់ៗតែឯង ហើយប្រកាសឱ្យប្រើ មិនធ្វើការផ្សព្វផ្សាយឱ្យពលរដ្ឋចូលរួមផ្តល់មតិ ហើយមិនស្តាប់នូវចំណុចខ្វះខាត និងប្រតិកម្មពីសំណាក់សង្គម ទីបំផុតច្បាប់ទាំង នោះបង្កើតដោយគ្មានន័យ និងគ្មានប្រសិទ្ធិភាពក្នុងការអនុវត្តន៏ឡើយ។

៣. អង្គនីតិប្បញ្ញត្តិ (LEGISLATIVE):

ជាការពិតណាស់ដែលថា ការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងការ នៃរដ្ឋ ឬប្រទេសមួយត្រូវតែឱ្យស្របទៅតាមប្រព័ន្ធលទ្ធិប្រជាធិបតេយ្យនោះ។ ការនេះចាំបាច់គេត្រូវតែធ្វើការកំណត់ និងបែងចែកអំណាចឱ្យដាច់តាមអង្គនីតិនីមួយៗ ដូចដែលបានជំរាបជូនខាងដើមអញ្ចឹង។ ចំពោះតួនាទីរដ្ឋសភាដែលតំណាងឱ្យអង្គនីតិប្បញ្ញត្តិនោះ ត្រូវតែរៀបធ្វើច្បាប់នានា សំរាប់គ្រប់គ្រងលើវិស័យនានា នៅក្នុងសហគមន៍ជាតិ ដោយមិនចាំបាច់នៅអង្គុយចាំមើលថា តើរដ្ឋាភិបាល ដែលជាតំណាងអង្គនីតិប្រតិបត្តិដាក់ ស្នើច្បាប់នោះឡើយ តែគួរសួរខ្លួនឯងថា តើមានបានបង្កើតច្បាប់អ្វីខ្លះ ហើយថាតើនៅខ្វះច្បាប់អ្វីទៀត ដែលមិនទាន់មាន។

តួនាទីបន្ទាប់មកទៀតរបស់រដ្ឋសភា ត្រូវតាមឃ្លាំមើលគ្រប់ពេលវេលា ទៅលើរដ្ឋាភិបាលរបស់ខ្លួន តើគេយកច្បាប់ដែលបានបង្កើតដាក់ឱ្យអនុវត្តនោះ ធ្វើបានត្រឹមត្រូវដែរឬទេ តើមានប្រតិកម្មអ្វីពីសំណាក់សមាជិកសហគមន៍ជាតិដែរឬទេ? ហើយប្រសិនបើ ធ្វើការពិនិត្យទៅឃើញថា មានមន្ទិលនៅលើចំណុចណាមួយត្រូវធ្វើការកោះហៅរដ្ឋាភិបាលឱ្យចូលខ្លួនមកឆ្លើយបំភ្លឺនៅលើបញ្ហាទាំងនោះភ្លាមៗ ដោយពុំត្រូវទុកបញ្ហាទាំងនោះឱ្យនៅយូរ ឬធ្វើមិនដឹងមិនឮនោះឡើយ ។

## ៤. អង្គនីតិប្រតិបត្តិ (EXECUTIVE):

ចំពោះអង្គនីតិប្រតិបត្តិនេះ គឺដូចយើងបានរៀបរាប់ខ្លះៗរួចមកហើយ នៅក្នុងតួនាទី និងភារៈកិច្ចរបស់ខ្លួនដែលជារដ្ឋាភិបាលតំណាងឱ្យអង្គនីតិប្រតិបត្តិ ដែលបានបង្កើតឡើង ដោយរដ្ឋសភាហើយដាក់សំរាប់ឱ្យប្រតិបត្តិ និងអនុវត្តបញ្ញត្តិច្បាប់នានាទាំងឡាយដែលរដ្ឋសភាបានប្រគល់ជូន។ នៅពេលបំពេញភារកិច្ចក្នុងមុខនាទីរបស់ខ្លួនទៅលើវិស័យនានានោះ មិនត្រូវយកច្បាប់ទៅបកស្រាយឱ្យខុសការពិត ដើម្បីគ្របបាំងការប្រព្រឹត្តិ និងការអនុវត្តន៏ខុសឆ្គងរបស់ខ្លួននោះឡើយ ហើយក៏គ្មានសិទ្ធិអាចកែច្បាប់ ឬចេញបទបញ្ជាណាមួយ ដែលនាំឱ្យផ្ទុយនឹងច្បាប់រដ្ឋ ដែលបានអនុម័តរួចដោយរដ្ឋសភាបានឡើយ។ ប៉ុន្តែ រដ្ឋាភិបាលអាចនឹងដាក់ស្នើសុំមករដ្ឋសភានូវច្បាប់ ឬបទបញ្ជាណាមួយ ដែលខ្លួនយល់ថាចំបាច់នៅក្នុងការគ្រប់គ្រង ចាត់ចែងការលើសហគមន៏ជាតិ ដែលវាជាចំណុចខ្វះចន្លោះរបស់ច្បាប់ជាមុន ដោយមិនត្រូវធ្វើអ្វីអត្តនោម័តរបស់ខ្លួនឡើយ ។

## ៥. អង្គនីតិតុលាការ (JUDICIARY):

អភិបាលកិច្ចល្អ គឺពុំអាចកាត់ផ្តាច់បានទេ រវាងតុល្យាភាព នៃសង្គមមួយ ដែលរស់នៅចាំបាច់ត្រូវតែមានយុត្តិធម៏។ បើប្រសិនណាសហគមន៏នៃប្រជាជាតិមួយ រស់នៅគ្មានការការពារពីច្បាប់ទេ នោះភាពអយុត្តិធម៏ និងអំពើរលោភបំពាននានា នៅក្នុងសង្គមជាតិនោះនឹងប្រែក្លាយទៅជា ទីលានអនាធិបតេយ្យហើយ ការកាប់ចាក់សម្លាប់គ្នា

ដើម្បីរងពន្លឺមយកហេតុផលត្រូវ នៃអំពើដែលក្រុមបក្សពួករបស់ខ្លួនបានធ្វើនោះឡើយ ។

ចំពោះសហគមន៍នៃសង្គមជាតិកម្ពុជាវិញ តើប្រព័ន្ធយុត្តិធម៌ដែលបង្កើតឱ្យមានតុលាការនោះ បានធានាផ្តល់យុត្តិធម៌ ជូនសង្គមជាតិដែរឬទេ..? ជាការពិតណាស់ គឺសង្គមកម្ពុជាសព្វថ្ងៃ មានប្រព័ន្ធតុលាការ ៣ថ្នាក់ :

(១)_តុលាការមូលដ្ឋាន (២)_តុលាការឧទ្ធរណ៍ និង(៣)_ តុលាការកំពូល។ នៅតាមតុលាការគ្រប់លំដាប់ថ្នាក់នេះ គឺមានសាលា ជុំនំជំរះក្តី នៅតាមសាលាជុំរះក្តីនីមួយៗ គឺមានចៅក្រមសំរាប់ជុំនំជំរះក្តី និងចៅក្រមស៊ើបអង្កេត។ រាល់ការជុំនំជំរះកាត់សេចក្តីលើរឿងវិវាទនីមួយៗ គឺត្រូវតែផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី។

ថ្វីត្បិតតែសង្គមជាតិកម្ពុជាមានប្រព័ន្ធតុលាការ សំរាប់ស្វែងរកយុត្តិធម៌ជូនសង្គមជាតិដូចបានរៀបរាប់ខាងលើក៏ដោយចុះ ក៏នៅមានចំណុចខ្វះខាតជាច្រើនដូចជាសមាសភាពចៅក្រម ការហ្វឹកហ្វឺនចៅក្រមក្រមសីលធម៌សំរាប់ចៅក្រម ក្រមនីតិវិធី កាត់ក្តី និងថវិកាឯករាជ្យសំរាប់ក្រុមចៅក្រម ប្រព័ន្ធរដ្ឋបាលសាលាជុំនំជំរះក្តីជាដើម។ល។ ចំពោះមុខសំរាប់សង្គមជាតិកម្ពុជាលើវិស័យយុត្តិធម៌នេះ យើងត្រូវការថវិកាសំរាប់ធ្វើការកែទម្រង់ ដើម្បីបំរើឱ្យសមស្របតាមប្រទេសមួយ ដែលមានមាគ៌ាលទ្ធិប្រជាធិបតេយ្យជាធំពិតៗ។

## ៦. គណនេយ្យភាព (ACCOUNTABILITY):

គណនេយ្យភាព គឺជាប្រព័ន្ធមួយដែលធ្វើការគ្រប់គ្រងដោយមានការទទួលខុសត្រូវខ្ពស់ចំពោះតួនាទី និងភារកិច្ច ដែលស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់បានបំពេញបានធ្វើទាំងឡាយ។ ពាក្យគណនេយ្យភាពនេះមែនទែនទៅ គឺមានសំដៅលើការងារគ្រប់គ្រង និងចាត់ចែងថវិកា ដើម្បីឱ្យការប្រើប្រាស់ថវិកាសង្គមជាតិមានសុចរិតធម៌ល្អ នៅក្នុងការបែងចែក ក៏ដូចជាការធ្វើសេចក្តីសំរេចចាយវាយផងដែរ។

នៅក្នុងសង្គមប្រជាធិបតេយ្យ ស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ គឺមានការប្រុងប្រយ័ត្ន និងហ្មត់ចត់បំផុត នៅក្នុងការគ្រប់គ្រង និងបែងចែកថវិការបស់ជាតិ។ ដោយព្រោះថា គ្រប់សហគមន៍ជាតិ ទូទៅវិស័យគ្រប់គ្រង និងបែងចែកថវិកាជាតិនេះ វាជាចំណុចគ្រោះថ្នាក់ និងអាចបណ្តាលឱ្យវិស័យនានារបស់ជាតិស្លាប់បានយ៉ាងងាយ។ ដូច្នេះហើយបានជារដ្ឋសភានៃប្រទេសជាតិនានាលើលោក គេមានតួនាទីដ៏សំខាន់ណាស់សំរាប់ត្រួតពិនិត្យមើល និងធ្វើការគ្រប់គ្រង បែងចែក និងអនុម័តថវិកាជាតិនេះយ៉ាងតឹងរ៉ឹងបំផុត។ ត្រូវសួរនាំនិងពិនិត្យលើរាល់សំណើសុំចំណាយរបស់រដ្ឋាភិបាល និងចំណូលដែលត្រូវប្រមូលពីពន្ធដារនានាដែលជាចំណូលរបស់ជាតិ កាលណារដ្ឋសភាពុំបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដូចខាងលើនេះទេ ពេលនោះរដ្ឋាភិបាលពិតជា ធ្វើជាអធិរាជតែម្នាក់ឯងនៅលើការប្រើប្រាស់ថវិកាសង្គមជាតិតាមចិត្តពុំខាន។

## ៧. តម្លាភាព (TRANSPARENCY):

ចំពោះពាក្យថាតម្លាភាពនេះវិញ យើងប្រែថាការធ្វើអ្វីៗឱ្យភ្លឺថ្លាច្បាស់លាស់។ បើយោងតាមន័យនេះរាល់ការគ្រប់គ្រងបែងចែកការងារអ្វីៗ នៅក្នុងស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ ត្រូវមានការបើកចំហឱ្យសហគមន៍ជាតិបានដឹងបានឮគ្រប់ៗគ្នា លើកលែងតែរឿងសន្តិសុខជាតិ និងការងារស៊ើបអង្កេតណាមួយ ដែលកំពុងធ្វើប្រតិបត្តិការ តាមចាប់ខ្លួនឧក្រិដ្ឋជនតែប៉ុណ្ណោះ ដែលគេមិនបង្ហាញឱ្យដឹងជាសាធារណៈ។ តម្លាភាពនេះ គឺជួយឱ្យការគ្រប់គ្រងរបស់ជាតិមានសក្ដានុពលភាពខ្ពស់ហើយបើនិយាយពីការងារខាងគ្រប់គ្រងថវិកាជាតិវិញ គេប្រើប្រព័ន្ធតម្លាភាពនេះសំរាប់ទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយបានយ៉ាងប្រសើរ។

យើងលើកយកឧទាហរណ៍មួយ ដើម្បីបញ្ជាក់លើអត្ថន័យលើពាក្យតម្លាភាពនេះឱ្យកាន់តែច្បាស់ថែមទៀត។ កាលណាមានការស្នើសុំថវិកាពីរដ្ឋាភិបាលមកសភាមុននឹងអនុម័តជាគោលការណ៍រដ្ឋសភាត្រូវចោទសួរលើចំណុចសំខាន់ៗចំពោះរដ្ឋាភិបាលដូចតទៅ (១)_ស្នើរសុំថវិកាប៉ុន្មាន (២)_យកថវិកាទាំងនេះទៅចំណាយលើគំរោងការណ៍អ្វី (៣)_តើចំណាយទៅលើគំរោងការណ៍នៅឯណា (៤).ចំណាយលើគំរោងការណ៍មានរយៈពេលប៉ុន្មានឆ្នាំ (៥)_តើត្រូវទិញសម្ភារៈ និងឧបករណ៍អ្វីខ្លះសំរាប់គំរោងការណ៍ (៦)_តើត្រូវជួលមនុស្សប៉ុន្មាននាក់ ទាំងអ្នកបច្ចេកទេស និងកម្មករ (៧)_តើក្រសួងណាជាអ្នកគ្រប់គ្រងការងារចំណាយលើគំរោង

ការណ៍អភិវឌ្ឍន៍នេះ (៨). តើមានក្រសួងប៉ុន្មាន ដែលជាប់ពាក់ព័ន្ធជាមួយគំរោងការណ៍។ល។

ក្រោយពីត្រូវបានរដ្ឋសភាអនុម័តលើគំរោងចំណាយរួចហើយ ក្រោយពីបញ្ចប់គំរោងការហើយ ឬចន្លោះពេលដែលកំពុងអនុវត្តគំរោង សមាជិករដ្ឋសភា ឬក្រុមគណៈកម្មាធិការជំនាញនានា ដែលមានតួនាទីភារកិច្ចត្រូវធ្វើការត្រួតពិនិត្យសារឡើងវិញ នូវរាល់គ្រប់ចំណុចទាំងអស់ដូចតាមសំណើសុំ ដោយត្រួតមើលលើខ្ទង់ចំណាយគ្រប់ផ្នែកទាំងអស់។ ឧទាហរណ៍ដូចជាការចំណាយលើការបើកប្រាក់ខែឱ្យដល់បុគ្គលិកប្រចាំខែ គេតោងត្រូវមានបញ្ជីគណនេយ្យ ដែលចុះហត្ថលេខាទទួលរាល់ខែ របស់បុគ្គលិកគ្រប់គ្នា ដើម្បីបញ្ជាក់ច្បាស់លាស់ ហើយបើទិញឧបករណ៍ ឬសម្ភារៈអ្វីមួយក៏ត្រូវតែមានបង្កាន់ដៃចេញ ឱ្យដោយហាងឬក្រុមហ៊ុនផងដែរ ដែលបានទិញ ហើយនៅលើបង្កាន់ដៃនោះ ត្រូវមានចុះហត្ថលេខាម្ចាស់ក្រុមហ៊ុនជាប្រចាំផងដែរ។ល។ ធ្វើបែបនេះទើបយើងហៅបានថាជាការគ្រប់គ្រងមានតម្លាភាពត្រឹមត្រូវ ហើយការនេះត្រូវធ្វើជាប់ជាប្រចាំ ទើបយើងអាចជៀសវាងអំពើចាយវាយងងឹតបាន ដែលវាជាការផ្ទុយទៅនឹងតម្លាភាព។

សេចក្ដីសន្និដ្ឋាន (CONCLUSION):

ប្រសិនបើការអនុវត្តន៍ធ្វើដូចពាក្យសន្យានៃអាជ្ញាធរនិងស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ ចំពោះលក្ខខ័ណ្ឌ នៃកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈបានល្អ ជាពិសេសក្របខ័ណ្ឌ នៃស្ថាប័នជាតិប្រាកដមួយ

ទៅតាមគោលការណ៍ដូចបានរៀបរាប់ជូនខាងលើពិតប្រាកដ មែននោះ ការដែលអាចឈានទៅគ្រប់គ្រងនិង ដឹកនាំប្រទេសជាតិ តាមបែប ប្រជាធិបតេយ្យ ដើម្បីធ្វើឱ្យមានអភិបាលកិច្ចល្អ ពិតជាទទួលបាន លទ្ធផលជាបណ្តើរៗយ៉ាងពិត។

ដូច្នេះ ដំណើរការធ្វើសេចក្តីសំរេចចិត្តរបស់សង្គមស៊ីវិលកម្ពុជា ដែលមានអង្គការ សមាគមក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិធ្វើជាភ្នាក់ ងារនោះអាចចាប់ផ្តើមធ្វើការគាំទ្រ និងសហការណ៍បានហើយ។ ក៏ប៉ុន្តែ ឆន្ទៈរបស់រដ្ឋាភិបាល នៃស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់ ត្រូវតែធ្វើការ បង្ហាញឱ្យឃើញច្បាស់ និងធ្វើការអនុវត្តន៍ឱ្យខាងតែបានទៅតាមអ្វីដែល បានសន្យា បើពុំដូច្នោះទេ ការទទួលយកឆន្ទៈនៃគោលនយោបាយភូតភរ របស់រដ្ឋាភិបាលកម្ពុជានោះ គឺពិតជាលំបាកណាស់ ហើយដើម្បីធ្វើ ដំណើរការស្តារ និងអភិវឌ្ឍន៍កសាង នៃសហគមន៍ជាតិរបស់យើង ឡើងវិញលើ គ្រប់វិស័យនោះ ពិតជាត្រូវជួបនឹងបរាជ័យជាក់ជាមិនខាន។

ទាក់ទងដល់នីតិវិធីធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ និងរចនា សម្ព័ន្ធ នៃស្ថាប័នជាតិគ្រប់លំដាប់ថ្នាក់នោះបានរដ្ឋាភិបាលកម្ពុជា ត្រូវតែ ធ្វើគំរោងការឱ្យជាក់លាក់។ ដោយកំណត់គោលដៅជាអាទិភាព ថាតើ ត្រូវធ្វើពីចំណុចណាមុនលើវិស័យអ្វី ហើយប្តេជ្ញាធ្វើឱ្យបាននៅពេលណា និងត្រូវការថវិកាប៉ុន្មាន ដើម្បីដំណើការទាំងអស់នេះ រួមទាំងលុយកម្ចី គេ និងជំនួយឥតសំណងរបស់សហគមន៍ជាតិ និងអន្តរជាតិ ។ល។

## ៦.១១_សុន្ទរកថាថ្លែងដោយ អ្នកស្រី ម៉ាក់ ឆារ៉ា ប្រធានសមាគមលើកស្ទួយសិប្បកម្មខ្មែរស្តីអំពី "ដំណើរការក្នុងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងសង្គមស៊ីវិលកម្ពុជា ផ្តោតលើចំណុចខ្លាំងនិងខ្សោយ"

ដើម្បីធ្វើសេចក្តីសំរេចមួយ ដែលមានប្រសិទ្ធិភាព និងមានគតិយុត្តិច្រើនបំផុតនោះ យើងត្រូវផ្អែកជាសំខាន់ទៅលើពត៌មានធានាដែលជាដើមចមនៃបញ្ហា និងវិភាគបញ្ហានីមួយៗ យ៉ាងល្អិតល្អន់បំផុតជាមុនដោយចែកជំរើសដំណោះស្រាយជាប្រភេទរបស់វា។ ប្រសិនបើជំរើសណាមួយមានភាពឥតខ្ចោះច្រើនជាង គេច្រើនជ្រើសរើសយកជំរើសនោះជាអាទិភាពក្នុងការធ្វើការសំរេចចិត្ត។ ឥឡូវនេះ ចូរយើងនាំគ្នាពិចារណាមើលបន្តិច អំពីបញ្ហាសង្គមស៊ីវិលនៅកម្ពុជាយើងថា តើវាមានសភាពបែបណា ហើយមានផលប៉ះពាល់យ៉ាងណាខ្លះ ទាក់ទងនឹងសេចក្តីសំរេចចិត្ត។

ចំណុចខ្សោយ : តើសង្គមកម្ពុជាបច្ចុប្បន្នយើងមានវិបត្តិអ្វីខ្លះ?

បើយើងក្រលេកមើលមួយភ្លែតៗ យើងអាចដឹងដោយប្រាកដថា សង្គមកម្ពុជាយើងកំពុងជួបប្រទះនឹងបញ្ហារាប់រយម៉ឺនជំពូក តែក្នុងពេលនេះ យើងសាកល្បងលើកយកតែបញ្ហាធំៗ ៣_៤មកពិចារណាសិន ដើម្បីធ្វើជាគោលមុននឹងសិក្សាលំអិត ឆ្ពោះទៅរកការសំរេចមួយដ៏ត្រឹមត្រូវ ឬការសំរេចចិត្តមួយ ដែលមានកំហុសឆ្គងតិចជាអតិបរមាក្នុងការកែច្នៃធ្វើឱ្យប្រសើរឡើងដល់សង្គមកម្ពុជាបច្ចុប្បន្ន។

បញ្ហានាំឱ្យនោះរួមមាន :

១- បញ្ហាសង្គ្រាមរ៉ាំរ៉ៃ :

អ្នកណាក៏ដឹងដែរថា កម្ពុជាជាប្រទេសមួយដែលមានសង្គ្រាមក្នុងស្រុកយូរអង្វែង ដែលយើងស្ទើរតែមិនហ៊ានលើកយកកត្តានេះមកធ្វើជាសំអាងផង ព្រោះតែខ្លាចពាក្យនិន្ទា សមដូចពាក្យចាស់ពោលថា "កន្ទេលធំបន្លំដេក ក្បាលទំពែកបន្លំការ" ឬក៏ "ជាងមិនកើតបន្ទោសដែក"ជាដើម។ល។ ប៉ុន្តែទោះបី អ្នកណាមានយោបល់យល់ឃើញបែបណាក៏ដោយ តែតថភាពនៃឥទ្ធិពលរបស់សង្គ្រាមនៅតែជាសមាសភាពសំខាន់ ក្នុងការធ្វើឱ្យសង្គមកម្ពុជាវិបល្លាស។ សង្គ្រាមបំផ្លិចបំផ្លាញរាល់សមិទ្ធផលនានារបស់សង្គមជាតិ រាប់ចាប់តាំងពីភោគផលធម្មជាតិ សេដ្ឋកិច្ច គ្រួសារ និងប្រទេស ការអប់រំ ប្រព័ន្ធស្មារតី ពលរដ្ឋស្រុតចុះឆាប់ភ័យខ្លាច ឆាប់ខឹង ឆាប់ជឿ គ្មានសមត្ថភាព ពិចារណាវែកញែករកខុសត្រូវ គុណ ទោស នាំខ្លួននិងគ្រួសារ និងសង្គមជាតិធ្លាក់ទៅក្នុងហាយនភាព។

២-ភាពក្រីក្រ :

ភាពក្រីក្រ គឺជាមរតករបស់សង្គ្រាមមួយដែរនៅកម្ពុជាយើង។ វាពិតណាស់ថា នៅប្រទេសណាក៏ដោយក៏មានអ្នកក្រដែរ សូម្បីតែនៅអាមេរិក អង់គ្លេស បារាំង.. ដែលល្បីថា ជាប្រទេសអ្នកមានក៏នៅតែមានអ្នកក្រ អ្នកសុំទាន អ្នកគ្មានទីលំនៅដូចគ្នាដែរ។ ប៉ុន្តែប្រទេសទាំងនោះ ស្ថិតក្នុងសភាពមួយដែលខុសពីយើង។ ភាពក្រីក្ររបស់

ប្រទេសយើងគឺបណ្តាលមកពីសង្គ្រាមជាដើមចម។ សង្គ្រាមធ្វើឱ្យកសិករ រត់ចោលដីស្រែចំការមិនអាចដាំដុះបានឬពោរពេញទៅដោយគ្រាប់មីន។ ម្នាក់ៗ គិតតែរត់គេចសង្គ្រាមពីលិចទៅកើត ពីជើងទៅត្បូង ខ្លះមាន សំណាង បានទទួលជំនួយពីអង្គការមនុស្សធម៌នានាខ្លះទៀត គ្មាន សំណាងបានត្រឹមតែហូបមើមឈើ ឫសឈើខ្លះ ជីវជាតិអាហារនាំឱ្យ ស្លាប់បន្ថែមពីលើមរណភាព ដែលបណ្តាលកមពីសង្គ្រាមស្រាប់រឹតតែធ្វើ ឱ្យពលរដ្ឋធ្លាក់ចុះក្នុងភាពក្រីក្រ ហើយនាំឱ្យប្រទេសជាតិក្លាយជា ប្រទេសក្រីក្រដែរ។ បញ្ហានេះជាវដ្តវិលចុះវិលឡើង ហើយជះឥទ្ធិពល ឱ្យគ្នាទៅវិញទៅមក។ ពលរដ្ឋដែលក្រីក្រពុំមានលទ្ធភាពរកប្រាក់ចំណូល ឱ្យគ្រួសារគ្មានលទ្ធភាពបង់ពន្ធជូនរដ្ឋ នាំឱ្យរដ្ឋគ្មានប្រភពចំណូលថវិកា ជាតិ។ នៅមានទៀត ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ មន្ទីរពេទ្យ សុខាភិបាល ប្រព័ន្ធច្បាប់ និងការអនុវត្តន៍ច្បាប់ អំពើពុករលួយកេង ប្រវ័ញ្ចន៍ ញាតិបក្សនិយម ជាហេតុនាំឱ្យប៉ះពាល់ដល់ការវិនិយោគពី បណ្តាអ្នកវិនិយោគក្នុងនិងក្រៅប្រទេសធ្វើឱ្យសេដ្ឋកិច្ចរីកចំរើនយឺតយ៉ាវ។ បច្ចេកវិជ្ជាទំនើបត្រូវខកខានមិនបានស្រូបយកទាន់ពេលវេលា ព្រោះខ្វះ ធនធានមនុស្ស នាំឱ្យយើងមិនអាចដើរតាមទាន់បណ្តាប្រទេសដែលនៅ ជុំវិញយើង។

៣_ការអប់រំសិក្សា ហ្វឹកហ្វឺនមុខជំនាញនិងធនធានមនុស្ស :

កត្តាទីបី សុទ្ធតែទាក់ទងទាំងស្រុងទៅនឹងកត្តាទីមួយនិងទីពីរ។ ភាពក្រីក្រនាំឱ្យរដ្ឋគ្មានថវិកា ព្រោះតែរដ្ឋគ្មានថវិកា ទើបធ្វើឱ្យគ្មាន

សាលារៀនឬមានសាលារៀនដែរ តែជាសាលារៀនដែលគ្មានគុណភាព គ្មានគ្រូឬមានគ្រូដែរ តែជាគ្រូពុំមានសមត្ថភាពគ្រប់គ្រាន់ជាគ្រូដែលពុំមានការបណ្ដុះបណ្ដាល ឬរដ្ឋពុំអាចផ្ដល់ប្រាក់ខែសមរម្យ ដើម្បីឱ្យគ្រូអាចរស់នៅបាន និងដើម្បីឱ្យគ្រូបង្រៀនសិស្សឱ្យបានទៀងទាត់។ បញ្ហា នេះបាននាំឱ្យធនធានមនុស្សត្រូវបាត់បង់ ដែលមិនអាចប្រកួតប្រជែងជាមួយបណ្ដាប្រទេសនៅក្បែរខាងរបស់ខ្លួន បាននាំឱ្យប្រទេសចាញ់ប្រៀបគេលើគ្រប់វិស័យ។ ឧទាហរណ៍ ក្នុងសង្គមជុំវិញខ្លួន កុមារនាំឱ្យកុមារគិតថា ការសិក្សាគឺជាការខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍ ព្រោះវាមើលឃើញអ្នកដែលនៅជុំវិញខ្លួនវា អ្នកទាំងនេះជួនកាលពុំមានការសិក្សាខ្ពស់ៗ គ្មានសញ្ញាបត្រធំៗ តែក៏សំណាងមានអំណាចមានទ្រព្យធនស្ដុកស្ដម្ភ ព្រោះតែមានខ្សែនេះខ្សែនោះជាដើម។ ក្មេងៗដែលនៅជនបទគ្មានឱកាសរៀនសូត្របានខ្ពង់ខ្ពស់ ព្រោះគ្មានលទ្ធភាពបង់ថ្លៃរស់នៅឯទីក្រុង ម្យ៉ាងទៀត ឪពុកម្ដាយភាគច្រើនសុទ្ធតែជាបុគ្គលអវិជ្ជាគ្មានពាក្យអ្វីនឹងជួយជំរុញកូនៗ របស់គាត់ឱ្យមើលឃើញសារៈសំខាន់នៃការសិក្សាឡើយ។ ហេតុនេះហើយទើបក្មេងៗជាច្រើន ជាពិសេសក្មេងស្រីៗ ត្រូវបង្ខំចិត្តបោះបង់ការរៀនសូត្រ ព្រោះសម្ពាធសង្គមគ្រួសារ បូកថែមនឹងទុព្វលភាពខាងផ្នែកសេដ្ឋកិច្ចគ្រួសារដែលមានស្រាប់។ សរុបសេចក្ដីមកការមិនបានទទួលការអប់រំ ឬទទួលការអប់រំពីប្រព័ន្ធអប់រំមួយដែលមិនទាន់សម័យកាល សុទ្ធតែជាបញ្ហានាំឱ្យខ្វះខាតធនធានមនុស្ស

ក្នុងស្រុកជារនាំងមួយ ដែលធ្វើឱ្យការអភិវឌ្ឍន៍ទៅមុខមិនរួចឬដោយល្បឿនយឺតៗជាទីបំផុត។

៤_ សីលធម៌រស់នៅរបស់ពលរដ្ឋធ្លាក់ចុះទាប :

កត្តាទី៤នេះ ជាកត្តាសំខាន់សំរាប់ភាពសុខដុមរមនា នៃសង្គមមួយ។ សីលធម៌ជាកត្តា ដែលកប់នៅក្នុងសន្តានចិត្តរបស់មនុស្សរាល់រូប។ សន្តានចិត្តរបស់មនុស្សត្រូវកត្តារួមផ្សំពីខាងក្រៅ ដូចជាកត្តាសង្គមគ្រួសារ សង្គមធំ ការ អប់រំ ការសេពគប់ និងសាសនាជាដើម ។ល។ សង្គ្រាមនាំទៅរកសេចក្ដីវិនាសនាំទៅរកភាពក្រីក្រ ភាពក្រីក្រនាំឱ្យមនុស្សមិនបានទទួលការអប់រំប្រៀនប្រដៅដែលល្អ ការនេះនាំឱ្យមនុស្ស ដែលជាសមាជិកសង្គមពឹងផ្អែកទៅលើច្បាប់ព្រៃដើម្បីដោះស្រាយរាល់បញ្ហា។ យើងសង្កេតឃើញ គេសម្លាប់មនុស្ស ព្រោះតែមនុស្សនោះបើកឡានសាចទឹកទទឹកខ្លួន ឬព្រោះតែមនុស្សនោះលួចមាន់ ឬគោ ឬម៉ូតូគេមួយ។ ជួនកាលឪពុកម្ដាយចាប់រំលោភ ឬលក់កូនបង្កើតខ្លួនឱ្យធ្វើជាស្រីពេស្យា ទាំងនេះគឺជាសញ្ញានៃការធ្លាក់ចុះដ៏គួរឱ្យព្រឺខ្លាច នៃសីលធម៌សង្គមរបស់កម្ពុជាយើង។ នេះក៏ប្រហែលជាសញ្ញាមួយនៃការមិនជឿទុកចិត្តទៅលើច្បាប់ ឬក៏ច្បាប់ខ្វះនីតិវិធីក្នុងការរៀបចំសណ្ដាប់ធ្នាប់សង្គម ទើបពលរដ្ឋក្នុងសង្គមចាត់ការដោយខ្លួនឯងរំលងច្បាប់ដូច្នេះ?

### បញ្ហាទាំងនេះកើតតាំងពីកាលណាមក?

យើងប្រហែលអាចនិយាយដោយជាក់ច្បាស់ថា បញ្ហាទាំងនេះកើតឡើងតាំងពីដើមទសវត្សឆ្នាំ១៩៧០ របូតមក ហើយក្លាយទៅធ្ងន់ធ្ងរឡើង ក្នុងរយៈកាលបីឆ្នាំប្រាំបីខែ និងម្ភៃថ្ងៃនៃពួករបបពួកខ្មែរក្រហម។ បញ្ហាទាំងនេះ នៅតែបន្តកើតមានក្នុងសង្គមកម្ពុជាតទៅទៀត ថ្វីបើសង្គ្រាមចប់ហើយ ប្រទេសមានសុខសន្តិភាពពេញលេញក៏ដោយ។

### បញ្ហាទាំងនេះកើតឡើងនៅទីណាខ្លះ?

បើនិយាយពីសង្គមយើង គឺកើតមាននៅក្នុងសង្គមជាតិកម្ពុជាយើងផ្ទាល់តែម្ដង។ ភារៈនៃការជម្រុញឱ្យបញ្ហាមានសភាពសន្ធោរសន្ធៅឡើងនោះ ពិតណាស់វាមានឥទ្ធិពលមកពីខាងក្រៅដែរ។ យើងមើលឃើញឈ្នួនពីរធំៗ ដែលជាកត្តាជម្រុញឱ្យមានបញ្ហានៅក្នុងសង្គមកម្ពុជាទីមួយ គឺឥទ្ធិពលសង្គ្រាមត្រជាក់ វាចប់ទៅហើយមែន តែវាបានធ្វើឱ្យសង្គមកម្ពុជារងរបួសយ៉ាងដំណំ។ ចំណែកឥទ្ធិពលទីពីរ គឺជាចរន្តថ្មីស្រឡាង ដែលយើងស្គាល់វាថា "សកលភាវូបនីយកម្ម"។ នេះគឺជាសម្ពាធមួយថ្មីដែលចាប់បង្ខំឱ្យយើងទទួលយកព្រោះថាវាជាសម័យកាលមួយដែលតម្រូវឱ្យមនុស្សរត់តាមសម្ភារៈនិងបច្ចេកវិជ្ជាទំនើប។ ការវិវត្តន៍តាមសកលភាវូបនីកម្ម រួមផ្សំនឹងសង្គមកម្ពុជាយើង ដែលប្រៀបបានទៅនឹងរទេះចាស់ស្រាប់បានបង្កើតឱ្យមានបញ្ហាថ្មីបន្ថែមទៀត ច្រើនរាប់មិនអស់ បូកបន្ថែម និងច្បាប់របស់ប្រទេសយើងនៅមានការខ្វះចន្លោះ

ផង ទើបនឹងបង្កើតថ្មីផង រីឯអ្នកអនុវត្តច្បាប់ពុំទាន់មានសុក្រិតភាព រឹតតែនាំឱ្យសង្គមយើងជួបប្រទះនឹងសម្ពាធបញ្ហារឹតតែធ្ងន់ធ្ងរឡើងៗ ហើយគួរឱ្យព្រួយបារម្ភបំផុតផង។

តើអ្នកណាជាដើមហេតុរបស់បញ្ហាទាំងនេះ?

អ្នកណាក៏ដោយចុះពេលនេះត្រូវបានពាក្យស្លោក "បង្រួបបង្រួមជាតិការផ្សះផ្សាជាតិ " និងវប្បធម៌និរទេសកាយកប់លុបបំបាត់អស់ទៅហើយ។ យើងទុកឱ្យពេលវេលា ជាអ្នកកាត់ទោសអ្នកនាំភ្លើងទាំងនោះចុះ។

ចំណុចខ្លាំង : ធ្វើបែបណាដើម្បីដោះស្រាយបញ្ហារបស់សង្គមកម្ពុជាយើង?

យើងមានឱកាសនឹងវិធីដែលមានប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាទាំងនេះបាន គ្រាន់តែត្រូវការពេលវេលាការចូលរួម និងការតាំងចិត្តដ៏ត្រឹមត្រូវមួយដើម្បីឈានទៅដល់ទីនោះ។

ឱកាសទាំងនេះរួមមាន:

១_ រដ្ឋាភិបាលបានសន្យានឹងកែទម្រង់ ក្នុងការធ្វើអភិបាលកិច្ច ល្អព្រមជាមួយគ្នានេះ សភាក៏បានបង្កើតច្បាប់ស្របតាមលក្ខណៈសកលភាវូបនីយកម្មខ្លះៗហើយ។

២_ សហគមន៍អន្តរជាតិ ជាប្រទេសផ្ដល់ជំនួយជាច្រើនបានផ្ដល់និងសន្យាផ្ដល់ជំនួយមកកម្ពុជា ដើម្បីដោះស្រាយបញ្ហាដែលបានរៀបរាប់ខាងដើមតាមរយៈរាជរដ្ឋាភិបាល។

៣_ រដ្ឋាភិបាលមានច្បាប់វិនិយោគមួយ ដែលជាទីទាក់ចិត្តដល់អ្នកវិនិយោគពីបរទេស។

៤_ យើងបានទទួល GSP ពីសហរដ្ឋអាមេរិក។

៥_ យើងអាចអញ្ជើញ ធនធានមនុស្សពីក្រៅប្រទេសឱ្យគេមកជួយបំពេញការខ្វះខាតធនធានមនុស្ស។

៦_ យើងមានភោគផលធម្មជាតិ ដើម្បីកែច្នៃឱ្យតែយើងចេះប្រើវាសមស្រប។

៧_ យើងមានសង្គមស៊ីវិល ដែលជាអង្គការមិនមែនរដ្ឋាភិបាលដែលអាចស្រូបនិងទទួលយកជំនួយពីបរទេសដើម្បីកសាងសង្គមយើងជាដៃគូជាមួយរដ្ឋាភិបាល។

៨_ សង្គមស៊ីវិលអាចជួយជាមតិរិះគន់ ដើម្បីស្ថាបនាដល់រដ្ឋាភិបាល និងជម្រុញឱ្យស្ត្រីចូលរួមជាអតិបរមា។

ដើម្បីសំរេចចិត្តឲ្យបានល្អ ត្រូវមាន :

១_ មានគោលបំណងច្បាស់លាស់។

២_ មានផែនការច្បាស់លាស់។

៣_ ផ្អែកលើពត៌មានច្បាស់លាស់ និងត្រឹមត្រូវ។

៤_ ផ្អែកលើសមត្ថភាព ចំណេះដឹងនិងជំនាញច្បាស់លាស់។

៥_ បើកចំហ ផ្តល់និងទទួលការរិះគន់ មិនប្រកាន់បក្សពួកមានទំនាក់ទំនងល្អ។

៦_ យកបទពិសោធន៍ពីការងារដើម្បីធ្វើការសំរេចចិត្ត។

៧_ មានការចូលរួម និងធ្វើការងារជាក្រុម។

៨_ យកមតិរួមជាធំ និងទទួលផលស្មើៗគ្នា។

៩_ ផ្អែកទៅលើសច្ចភាព និងភាពស្មោះត្រង់។

១០_ មានឱកាសឬពេលវេលាសមស្រប។

កត្តាដែលនាំឲ្យសេចក្ដីសំរេចចិត្តមិនបានល្អមាន :

១_ អំពើពុករលួយ នាំឱ្យគ្មានការចូលរួម។

២_ ការប្រកាន់បក្សពួក នាំឱ្យក្រុមបែកបាក់ខ្វះការឯកភាព។

៣_ កង្វះសមត្ថភាព ចំណេះដឹង ជំនាញ នាំឱ្យសំរេចចិត្តខុស។

*យើងយល់ឃើញថា ដើម្បីកែទម្រង់នេះ យើងត្រូវតែមាន :*

**១_អភិបាលកិច្ចល្អ ដែលមានកាតព្វកិច្ចត្រូវធ្វើដូចតទៅ :**

| | | |
|---|---|---|
| ក) | នីត្យានុកូលភាព | Legality |
| ខ) | ការចូលរួម | Participatory |
| គ) | នីតិបញ្ញត្តិ | Legislative |
| ឃ) | នីតិប្រតិបត្តិ | Executive |
| ង) | នីតិវិធិផ្ទ័យ | Judiciary |
| ច) | គណនេយ្យភាព | Accountability |
| ឆ) | តម្លាភាព | Transparency |

# ជំហានក្នុងការអនុវត្តន៍ អភិបាលកិច្ចល្អ

**ជំហានទី១ :** កំណត់គោលបំណងក្នុងការធ្វើអភិបាលកិច្ចល្អ។

ក)_ត្រូវធ្វើទៅលើសេវាផ្នែកណាខ្លះ?

ខ)_តើធ្វើបែបណា? ធ្វើជាប្រចាំឬជារបៀបសំរង់ពត៌មានសំរាប់រយៈកាលខ្លីមួយស្តីពីការប្រព្រឹត្តិទៅនៃការងារ?

គ)_តើអ្នកណាខ្លះដែលត្រូវការលទ្ធផលពត៌មាននៃការធ្វើអភិបាលនេះ?

តារាងសំរាប់កំណត់គោលបំណងអភិបាលកិច្ច

| អភិបាលកិច្ចទៅលើ | បំណងរបស់អភិបាលកិច្ច | សំរាប់ប្រើក្នុងអង្គការ | | សំរាប់ប្រើក្រៅអង្គការ | |
|---|---|---|---|---|---|
| | | អ្នកផ្តល់សេវា | អ្នកដឹកនាំ | ម្ចាស់អំណោយ | ផ្សេងៗ |
| កម្មវិធីសេវា | | | | | |
| ១)_សិប្បកម្ម | វាស់គុណភាពផលិតកម្ម | | | | |
| ២)_សុខភាព | វាស់សុខភាពប្រជាជន | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣)_កសិកម្ម | វាស់គុណភាពផលិតកម្ម | | | | |
| | | | | | |
| ការគ្រប់គ្រង | | | | | |
| ១)_ហ្វឹកហ្វឺន | ចំនួនមនុស្សបានហ្វឹកហ្វឺន | | | | |
| ២)_ធ្វើផែនការ | កំណត់ផលិតផលចែកចាយ | | | | |
| ៣)_ថវិកា | ការចំណាយចំណូល | | | | |

**ជំហានទី២ :** សំរេចចិត្តក្នុងការជ្រើសរើសវិសាលភាពក្នុងការធ្វើអភិបាលកិច្ច។ អ្នកដឹកនាំត្រូវសំរេចចិត្តថា តើអភិបាលកិច្ចនោះគួរធ្វើក្នុងទំហំប៉ុណ្ណា? កន្លែងណា? និងត្រូវធ្វើទៅលើបុគ្គលណាខ្លះ ហើយថាតើត្រូវធ្វើរយៈពេលយូរឬឆាប់ប៉ុណ្ណា?

| |
|---|
| ១)_តើត្រូវធ្វើទៅលើតំបន់ណាខ្លះ? |
| ២)_តើត្រូវធ្វើទៅលើសេវាណាខ្លះ? |
| ៣)_តើត្រូវធ្វើទៅលើបុគ្គលិកណាខ្លះសំរាប់ធ្វើអភិបាលកិច្ច? |
| ៤)_តើអភិបាលកិច្ចនេះធ្វើមានរយៈពេលប៉ុន្មានខែឆ្នាំ? |

ជំហានទី៣ : ជ្រើសរើស indicators និងសកម្មភាពធ្វើការជាខ្នាតគំរូ

| តារាងសំរាប់ជ្រើសរើស indicators និងសកម្មភាពធ្វើការជាខ្នាតគំរូ | | | |
|---|---|---|---|
| លទ្ធផលបង្ហាញ | ចំនួនបរិមាណ | ខ្នាតគំរូ | ភាពញឹកញាប់ |
| សេវា | | | |
| ប្រសិទ្ធិភាព | ?ភាគរយ | ៥០ភាគរយ | ប្រចាំឆ្នាំ |
| លទ្ធផលទទួលបាន | ?ចំនួន | ៦០០ | ៦ខែ |
| ធនធានដាក់ចុះ | ?ភាគរយ | ៩០ភាគរយ | ១ខែ |

ជំហានទី៤ : ជ្រើសរើសប្រភពពត៌មាន និងដំណើរការប្រមូលទិន្នន័យតាមរយៈវិធីសាស្រ្តមួយចំនួន :

១)_ការលួចពិនិត្យមើល។

២)_ការធ្វើសម្រង់ពត៌មានដែលរហ័ស។

៣)_សម្ភាសអ្នកដែលមកទទួលសេវា។

៤)_សំភាសបុគ្គលិក។

ជំហានទី៥ : ប្រមូលពត៌មាន។

| បុគ្គលិក | ការទទួលខុសត្រូវ | | |
|---|---|---|---|
| | ប្រមូល | ត្រួតពិនិត្យ | វិភាគនឹងបញ្ជូនចេញ |
| មេភូមិ<br>មេឃុំ<br>អភិបាលស្រុក ខេត្ត | ប្រមូល<br>ប្រមូល<br>ទទួល | ពិនិត្យមើល<br>ពិនិត្យមើល<br>ប្រើទិន្នន័យដើម្បីចាត់ចែង | ទៅកាន់ភូមិ<br><br>ចងច្រង |

ជំហានទី៦ : វិភាគទិន្នន័យដែលប្រមូលបាន។

តារាងវិភាគទិន្នន័យដែលប្រមូលបាន

| សមាសភាព លទ្ធផលបង្ហាញ | លទ្ធផលទទួលពិត | លទ្ធផលដែលរំពឹងថានឹងទទួលបាន | ភាគរយខ្វាតគំរូទទួលបាន | សកម្មភាពត្រូវធ្វើបន្ទាន់ |
|---|---|---|---|---|
| ១)- សមាមាត្រក្រមាសូត្រ-១នាក់ | ២ | ៣ | ៥០ | លើកទឹកចិត្តអ្នកត្បាញ |

## ៦.១២_សុន្ទរកថាថ្លែងដោយ លោក សេក បរិសុទ្ធ វិទ្យាស្ថានសារគមនាគមន៍កម្ពុជា ស្តីពី "ការកសាងនិរន្តរភាព នៃសង្គមស៊ីវិលនៅកម្ពុជា : បញ្ហាប្រឈមមុខ ក្នុងការប្រមូលផ្តុំធនធាន "

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណ ចំពោះវិទ្យាស្ថានកម្ពុជាដើម្បីសហប្រតិបត្តិការ និងសន្តិភាព ដែលបានផ្តល់ឱកាសនិងកិត្តិយសឱ្យខ្ញុំបានមកចូលរួមក្នុងកិច្ចពិភាក្សាតុមូល ស្តីអំពី អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា ក្នុងនាមជាវាគ្មិនមួយរូបមកពី វិទ្យាស្ថានសារគមនាគមន៍កម្ពុជា។

មុននឹងឈានទៅការពិភាក្សាអំពីបទពិសោធន៍និងទស្សនៈវិស័យទៅថ្ងៃមុខ ខ្ញុំបាទសូមអនុញ្ញាតជម្រាបត្រួសៗ បន្តិចសិនអំពីសាវតាររបស់វិទ្យាស្ថានសារគមនាគមន៍កម្ពុជា ដោយខ្ញុំជឿថា មានអស់លោកលោកស្រីជាច្រើនប្រហែលជាមិនទាន់ស្គាល់ វិទ្យាស្ថានសារគមនាគមន៍កម្ពុជាច្បាស់នៅឡើយ។

### សាវតាសង្ខេបរបស់ ស៊ី ស៊ី អាយ

វិទ្យាស្ថានសារគមនាគមន៍កម្ពុជា ដែលហៅកាត់តាមភាសាអង់គ្លេសថា ស៊ី ស៊ី អាយ គឺជាគម្រោងរួមគ្នាមួយរវាងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពត៌មាននិងអង្គការយូណេស្កូ ដែលជាអ្នកគ្រប់គ្រងផ្ទាល់។ ក្រសួងពត៌មានបានផ្តល់ទីតាំង ពោលគឺអាគារដែលស្ថិត

នៅក្នុងបរិវេណក្រសួងតែម្តង ចំណែកយូណេស្កូ ជាអ្នកផ្តល់ថវិកាសម្រាប់ការជួសជុលអាគារបំពាក់ឧបករណ៍និងចំណាយសព្វសារពើ។

វិទ្យាស្ថាននេះត្រូវបានបង្កើតឡើងនៅខែកញ្ញាឆ្នាំ១៩៩៤ ដោយផ្អែកលើការសិក្សាមួយរបស់យូណេស្កូ នាឆ្នាំ១៩៩១ ស្តីអំពី សេចក្តីត្រូវការចាំបាច់នៃវិស័យផ្សេងៗ នៅកម្ពុជា និងទៅតាមអនុសាសន៍នៃវេទិកាតុមូលមួយ នាឆ្នាំ១៩៩២ របស់អ្នកសារពត៌មានខ្មែរ ដែលស្នើសុំឱ្យបង្កើតឡើងនូវសាលាបង្រៀនវិជ្ជាសារពត៌មាននៅកម្ពុជា។ ក្រោយមកនៅឆ្នាំ១៩៩៣ គម្រោងបង្កើតវិទ្យាស្ថាននេះ ក៏បានទទួលការគាំទ្រពីអេស អិន ស៊ី និងត្រូវបានចុះហត្ថលេខាសម្រេច ដោយក្រសួងពត៌មាន និងយូណេស្កូ នៅខែកញ្ញា ឆ្នាំ១៩៩៤។

គោលបំណងធំរបស់គម្រោងវិទ្យាស្ថាននេះ គឺបង្កលក្ខណៈឱ្យមហាជនកម្ពុជា មានលទ្ធភាពទទួលដឹងព្ទពត៌មានផ្សេងៗ ច្រើនតាមដែលអាចធ្វើទៅបានតាមរយៈការលើកកំពស់គុណភាពប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើនការចូលរួមរបស់មហាជន នៅក្នុងដំណើរការប្រជាធិបតេយ្យ។

ការប្រែក្លាយវិទ្យាស្ថាននេះ ឱ្យទៅជាស្ថាប័នសិក្សាផ្លូវការនូវវិជ្ជាសារពត៌មាន ក៏ជាគោលដៅមួយរបស់គម្រោងនេះដែរ ដែលរហូតមកដល់ពេលនេះនៅមិនទាន់ធ្វើបាននៅឡើយ។

សកម្មភាពចម្បងរបស់ ស៊ី ស៊ី អាយ សព្វថ្ងៃនេះគឺរៀបចំវគ្គបណ្តុះបណ្តាលជំនាញសារពត៌មានរយៈពេលខ្លី និងមិនផ្លូវការសម្រាប់អ្នកកាសែត ដែលកំពុងប្រកបការងារ ក៏ដូចជាបុគ្គលិកនិងមន្ត្រីពត៌មានក្រសួង មន្ទីរ អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិជុំវិញ មុខជំនាញដែលទាក់ទងនឹងវិស័យសារពត៌មាន។ មកដល់សព្វថ្ងៃនេះ ស៊ី ស៊ី អាយ បានបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងសិក្ខាសាលាផ្សេងៗ ចំនួនរាប់រយវគ្គ ដោយមានមនុស្សចូលរួមចំនួនប្រហែល៥០០០នាក់ បើគិតតែចំនួនដោយមិនគិតឈ្មោះ ព្រោះអ្នកខ្លះមានឈ្មោះចូលរួមរហូតដល់ទៅ៤_៥វគ្គ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិទ្យាស្ថានបានធ្វើការកែទម្រង់ខ្លះ ក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ដោយផ្តោតជាចម្បងតែទៅលើអ្នកកាសែតប៉ុណ្ណោះ។

នៅក្នុងដំណាក់កាលទី១នៃគម្រោង រវាងឆ្នាំ១៩៩៤និង១៩៩៦ ស៊ី ស៊ី អាយ បានទទួលការឧបត្ថម្ភពី រដ្ឋាភិបាលដាណឺម៉ាក់និងរដ្ឋាភិបាលបារាំង។ តាមកិច្ចព្រមព្រៀងដើមដំបូង ស៊ី ស៊ី អាយ នឹងត្រូវប្រគល់ទៅឱ្យរដ្ឋាភិបាល ក្រសួងពត៌មានគ្រប់គ្រង នៅក្រោយពេលដែលគម្រោងត្រូវបញ្ចប់នៅចុងឆ្នាំ១៩៩៦ ក្នុងករណីដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចដំណើរការ ស៊ី ស៊ី អាយ បានដូចដែលយូណេស្កូធ្វើ។ ក៏ប៉ុន្តែ នៅពេលនោះ ក្រសួងពុំមានលទ្ធភាព ទើបស្នើសុំឱ្យយូណេស្កូបន្តគម្រោងនេះមួយដំណាក់កាលទៀត។ សូមបញ្ជាក់ជូន

ផងដែរថា នៅក្នុងពេលនោះដែរ ក្រសួងពត៌មានក្រោមការដឹកនាំរបស់ ឯកឧត្តម អៀង មូលី យល់ឃើញថា លទ្ធភាពតែមួយគត់ដែលអាចឱ្យ ស៊ី ស៊ី អាយ បន្តស្ថិតស្ថេរទៅបានគឺឱ្យ ស៊ី ស៊ី អាយ ក្លាយទៅជាស្ថាប័នឯករាជ្យមួយ។ អាស្រ័យហេតុនេះហើយ ទើបនៅក្នុងឯកសារគម្រោង សម្រាប់ដំណាក់កាលទី២ រាជរដ្ឋាភិបាលបានសន្យាផ្តល់ឱ្យ ស៊ី ស៊ី អាយ នូវលក្ខន្តិកៈឯករាជមួយមុនពេលចប់ដំណាក់កាលទី២។ តែគួរឱ្យស្ដាយរហូតមកដល់ពេលនេះ ដំណាក់កាលទី២ បានបញ្ចប់ជិតមួយឆ្នាំ ទៅហើយ តែស៊ី ស៊ី អាយ នៅតែស្ថិតក្នុងស្ថានភាពដូចពីមុនដដែល អាស្រ័យដោយមានបញ្ហាលំបាកលំបិនខាងផ្លូវច្បាប់មួយចំនួន និងបើតាមខ្ញុំ សន្និដ្ឋានប្រហែលជាមានបញ្ហាផ្សេងៗទៀតខ្លះផងដែរ។

នៅចំពោះមុខការលំបាកនេះ យូណេស្កូក៏បានលើកឡើងនូវដំណោះស្រាយមួយ ពោលគឺស្នើសុំបញ្ចូល ស៊ី ស៊ី អាយ ទៅក្នុងសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលរហូតមកដល់ពេលនេះមានការព្រមព្រៀងគ្នាជាគោលការណ៍អស់ហើយរវាងរាជរដ្ឋាភិបាលនិងយូណេស្កូ។

ក្នុងនាមផ្នែកមួយនៃសង្គមស៊ីវិល ខ្ញុំជឿថា ស៊ី ស៊ី អាយ ក៏ប្រឈមមុខនឹងការលំបាកដូចគ្នានឹងស្ថាប័នដទៃៗទៀតដែរ។ តទៅនេះខ្ញុំសូមធ្វើការពិភាក្សាត្រួសៗ ពីសកម្មភាពអនុវត្តការងាររបស់ ស៊ី ស៊ី អាយ កន្លងមកដោយផ្អែកលើគោលការណ៍ ជាមូលដ្ឋាននៃអភិបាល

កិច្ចរបស់សង្គមស៊ីវិល ដែលក្នុងនោះរួមមានទាំងបទពិសោធន៍ល្អអាក្រក់ និងការលំបាកដែលត្រូវប្រឈមមុខផងដែរ។

## ១. ឈានទៅបំផុសឲ្យមានការចូលរួមនិងគាំទ្រ ទៅបង្កើតកម្មវិធីនិងសកម្មភាព

កាលពីចាប់ផ្តើមដំបូង នៅពេលណាដែល ស៊ី ស៊ី អាយរៀបចំកម្មវិធីបណ្តុះបណ្តាលណាមួយ ស៊ី ស៊ី អាយ តែងធ្វើសេចក្តីជូនដំណឹងដល់រាល់អង្គការពតិមានទាំងអស់ ឬអង្គការទាំងឡាយណាដែលណាដែលពាក់ព័ន្ធដោយសុំឱ្យគេបញ្ជូនមនុស្សមកចូលរួម។ ក៏ប៉ុន្តែពេលនោះ យើងបានទទួលការឆ្លើយតបយ៉ាងតិចតួចបំផុត ដែលមានន័យថាគេមិនទាន់ចាប់អារម្មណ៍ នឹងការងាររបស់យើងប៉ុន្មានទេ នៅទីបំផុតយើងត្រូវទៅទាក់ទងគេដោយផ្ទាល់តែម្តង ហើយទទូចឬបង្ខំតែម្តង ក្នុងករណីដែលយើងអាចធ្វើបានឱ្យគេចូលរួម។ ទោះជាធ្វើដូច្នេះក្តី ក៏ការចូលរួមរបស់គេនៅមានកម្រិតទាបដែរ។ ក៏ប៉ុន្តែ និន្នាការនេះបានប្រែប្រួលបន្តិចម្តងៗ។ សព្វថ្ងៃនេះរៀងរាល់កម្មវិធីរបស់យើងតែងតែមានអ្នកសុំចូលរួមលើសកំណត់ទទួល។ ថ្វីបើយើងទទួលស្គាល់ថា និន្នាការនេះអាចទទួលឥទ្ធិពលផ្សេងៗ ពីខាងក្រៅខ្លះក៏ពិតមែន តែយើងមិនអាចបដិសេធបានទេថា វាចេញមកពីការយល់ដឹង និងការគាំទ្ររបស់ពួកគេចំពោះកម្មវិធីរបស់យើង។ ទន្ទឹមគ្នានេះដែរ វិទ្យាស្ថានក៏បានបង្កើតកម្មវិធីរបស់ខ្លួនយ៉ាងច្រើនដើម្បីឆ្លើយតប។

តែទោះជាយ៉ាងណាក៏ដោយយើងនៅមានបញ្ហាមួយចំនួនដែលនៅមិនទាន់បានជោគជ័យពេញលេញនៅឡើយ ហើយត្រូវពុះពារនោះ

គឺគុណភាព នៃកម្មវិធីនៅមានកម្រិត អាស្រ័យដោយកង្វះខាតធនធាន ពិសេសគឺធនធានមនុស្ស។ សព្វថ្ងៃនេះយើងគ្មានទេ នូវគ្រូកាសែតខ្មែរ ដែលមានសញ្ញាប័ត្រសារពត៌មានឬសារគមនាគមន៍ និងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលខ្លះៗ ប៉ុណ្ណោះដែលយកមកធ្វើជាគ្រូបង្ហាត់ ក្នុងន័យអ្នកចេះច្រើនបង្រៀនអ្នកចេះតិច និងមានគ្រូបរទេសខ្លះដែលត្រូវបង្រៀនដោយឆ្លងកាត់ការបកប្រែ។ ដូច្នេះ វាប្រាកដណាស់ថា គុណភាពនៃកម្មវិធីរបស់យើងមានកម្រិត។ បញ្ហាម្យ៉ាងទៀត គឺអ្នកដែលចូលរួមភាគច្រើន គឺជាអ្នកដែលពុំមាននាទីធ្វើសេចក្តីសម្រេចចិត្ត ម្លោះហើយ មិនអាចឱ្យមានការប្រែជាដុំកំភួនបាន។

២_ <u>សិក្សាវិភាគនូវតម្រូវការហើយចាត់ចែងផ្តល់សេវាទៅតាមរបៀបផ្សេងៗដែលសមស្រប</u> :

នៅក្នុងន័យនេះ ស៊ី ស៊ី អាយ បានធ្វើការស្រាវជ្រាវមួយចំនួនជាពិសេស នៅឆ្នាំ១៩៩៦ និង១៩៩៧ អំពីសារពត៌មានវិទ្យុទូរទស្សន៍ និងអ្នកកាសែតដែលបន្ទាប់មកយើងក៏បានរៀបចំកម្មវិធីនានាតម្រូវទៅតាមស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការរបស់ពួកគេ ជាពិសេស គឺវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ សារពត៌មានរយៈពេលមួយឆ្នាំ ថ្នាក់វិញ្ញាបនប័ត្រដែលកំពុងប្រព្រឹត្តទៅសព្វថ្ងៃនេះ (ឯកសារស្រាវជ្រាវរបស់ ស៊ី ស៊ី អាយ ដោយ **John Brown; Pernille Boeggild; Michel Chasson**)។

តែទោះជាយ៉ាងណាក៏ដោយ ការងារនេះនៅមានការខ្វះខាតច្រើនអាស្រ័យដោយកង្វះខាតធនធាននិងជំនាញ ពោលគឺ មិនបានធ្វើជាប់ជាប្រចាំ និងមិនបានធ្វើទូលំទូលាយគ្រប់សព្វ។ កង្វះខាតនេះពិតជាជះឥទ្ធិពលខ្លះដល់ប្រសិទ្ធិភាព នៃកម្មវិធីដោយជៀសមិនរួច។

៧- ការស្វែងរក និងប្រមែប្រមូលធនធានដើម្បីទទួលរ៉ាប់រងនូវការទទួលខុសត្រូវដែលរដ្ឋាភិបាលបែងចែកឲ្យ :

ជាការងារមួយដ៏លំបាកណាស់ដែរ ដោយហេតុថា វាផ្សាភ្ជាប់នឹងកត្តាផ្សេងៗជាច្រើន។ ស៊ី ស៊ី អាយ ប្រហែលជាមានសំណាងជាងអង្គការខ្លះ ដោយសារកន្លងមក ស៊ី ស៊ី អាយ មានប្រភពធនធាន ហិរញ្ញវត្ថុធំពីខាងអង្គការយូណេស្កូ ដែលផ្តល់ឱ្យដោយរដ្ឋាភិបាលដាណឺម៉ាក់។ តែទោះជាយ៉ាងណាក៏ដោយ នោះគ្រាន់តែជាធនធានបង្គោលមួយប៉ុណ្ណោះ។ យើងត្រូវការចាំបាច់នូវធនធានផ្សេងៗទៀត ពីខាងក្រៅទាំងធនធានហិរញ្ញវត្ថុទាំងធនធានមនុស្ស ដើម្បីធ្វើសកម្មភាពឆ្លើយតប ឱ្យបានសមស្របទៅនឹងសេចក្តីត្រូវការរបស់សហគមន៍។ ជាពិសេសទៅទៀត គឺជាការស្វែងរកនិងប្រមូលធនធាននេះ មានតួនាទីសំខាន់ដាច់ខាតសម្រាប់និរន្តរភាព ហើយខ្ញុំសូមសារភាពដោយស្មោះត្រង់ថា យើងធ្វើការងារនេះបានជោគជ័យតិចតួចណាស់ ជាពិសេសគឺអាស្រ័យដោយបញ្ហាជាច្រើនរួមផ្សំគ្នា ដែលក្នុងនោះមាន៖ នយោបាយ ច្បាប់ និងប្រសិទ្ធិភាពការងារជាដើម។ សូមបញ្ជាក់ថាដោយសារតែ ស៊ី ស៊ី អាយ ប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងប្រព័ន្ធផ្សព្វ

ផ្សាយ និងសេរីភាព សារពត៌មាន ឯករាជភាពរបស់ ស៊ី ស៊ី អាយ ពីរដ្ឋាភិបាលហាក់ដូចជា ចំណុចគន្លឹះមួយសម្រាប់ការគាំទ្រពីខាងក្រៅ ជាពិសេស គឺអង្គការមូលនិធិឯកជនមួយចំនួន។ តែទោះជាយ៉ាងណាក៏ ដោយអ្វីដែលយើងចាត់ទុកថាជាឧបសគ្គ និងជាភាពតានតឹងទាំងប៉ុន្មាន នោះបច្ចុប្បន្ន ហាក់ដូចជាកំពុងឈានទៅភាពល្អប្រសើរជាបណ្ដើរៗដែរ ហើយដែលធ្វើឱ្យខ្ញុំមានសុទិដ្ឋិនិយមច្រើនចំពោះអនាគត។

៤_ <u>ឈ្វេងយល់</u> <u>និងសហការជាមួយរដ្ឋាភិបាល</u> <u>និងផ្នែកឯកជន</u> <u>ដើម្បីស្វែងរក មូលដ្ឋានរួមនៃការងារអភិវឌ្ឍន៍</u> :

ខ្ញុំយល់ថា នេះគឺជាការងារមួយលំបាកជាងគេក្នុងចំណោមការលំបាកទាំងប៉ុន្មានខាងលើព្រោះថា នៅក្នុងបរិយាកាសសង្គមសព្វថ្ងៃ ការកសាងជំនឿទុកចិត្តរវាងគ្នានឹងគ្នាមិនមែនជារឿងសាមញ្ញទេ។ ការពិតទៅ ខ្ញុំជឿថាឆន្ទៈសហការគ្នា ជាពិសេសរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលក្នុងបុព្វហេតុអភិវឌ្ឍន៍នេះ ខ្ញុំនិយាយជារួមតែម្ដងពោល គឺមិនមែននិយាយតែនៅក្នុងក្របខ័ណ្ឌ ស៊ី ស៊ី អាយ នោះទេ ប្រាកដជាមាន។ ក៏ប៉ុន្តែដោយសារមិនទាន់មានការជឿទុកចិត្តគ្នា ទើបបណ្ដាលឱ្យការប្រែក្លាយឆន្ទៈនោះ ទៅជាភាពជាក់ស្ដែងនៅមិនទាន់បានល្អ។ ដូច្នេះ លទ្ធផលដែលសម្រេចបាន ក៏មានកម្រិតទៅតាមនោះដែរ។ ចំពោះកិច្ចសហការរវាងសង្គមស៊ីវិល និងផ្នែកឯកជនវិញ ខ្ញុំយល់ថាពុំមានឧបសគ្គអ្វីជាដុំកំភួនទេ ក្រៅតែពីបញ្ហាផលប្រយោជន៍។ ដរាបណាយើងធ្វើឱ្យគេយល់ថា អ្វីដែលយើងធ្វើនោះវាបម្រើផលប្រយោជន៍

រួមដែលក្នុងនោះ ក៏មានផលប្រយោជន៍របស់ពួកគេផងដែរ ដរាបនោះគេប្រាកដជាសហការ។ ដូច្នេះជារួម ខ្ញុំយល់ថាសង្គមស៊ីវិលត្រូវធ្វើយ៉ាងណាឱ្យគេជឿជាក់ថា ខ្លួនពិតជាបម្រើផលប្រយោជន៍សាធារណៈមានការទទួលខុសត្រូវពិតប្រាកដ និងគ្មានជំហរប្រឆាំងប្រទូស្តរាយនឹងនរណាម្នាក់ឡើយ។ ខ្ញុំទទួលស្គាល់ថា ក្នុងកិច្ចសហការជាមួយផ្នែកឯកជន ស៊ី ស៊ី អាយ នៅមានកម្រិតទាប ដូច្នេះខ្ញុំយល់ថា ពេលនេះជាឱកាសល្អមួយដែលខ្ញុំអាចស្តាប់យោបល់និងដំបូន្មានមួយចំនួនរបស់អង្គពិភាក្សា ដើម្បីជាទុនក្នុងការកែលំអប្រសិទ្ធិភាពការងារថែមទៀត។

ទាំងអស់នេះគ្រាន់តែជាចំណុចខ្លះៗដែលជាមូលដ្ឋាននៃអភិបាលកិច្ចល្អរបស់សង្គមស៊ីវិល ដែលត្រូវបានលើកយកមកឆ្លុះបញ្ចាំងទៅនឹងបទពិសោធន៍របស់យើងខ្ញុំកន្លងមក ហើយខ្ញុំជឿថា នៅមានច្រើនទៀតដែលខ្ញុំត្រូវរៀនសូត្រ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ថា វាមិនខុសគ្នាប៉ុន្មានឡើយនឹងសមាសភាពផ្សេងៗទៀត នៃសង្គមស៊ីវិលនៅកម្ពុជា ជាពិសេសគឺបណ្តាអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ (NGOs) ដែលតាមការកត់សំគាល់ គឺជាប្រភពនៃការរីកចំរើននៃសង្គមស៊ីវិលនៅកម្ពុជានោះ។

ជារឿយៗ អត្ថន័យរបស់ សង្គមស៊ីវិល ច្រើនតែច្របូកច្របល់គ្នាជាមួយនឹងអភិបាលកិច្ចល្អ។ តាមពិតជាទូទៅគេយល់ថា សង្គមស៊ីវិល គឺជាវេទិកាមួយរបស់ពលរដ្ឋដែលចូលរួមដោយក្រុមមនុស្សមកពីផ្នែកផ្សេងៗដែលមានជាអាទិ៍ រដ្ឋាភិបាល ពាណិជ្ជកម្ម សិក្សាស្រាវ

ប្រាវ NGOs បណ្តាអង្គការសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ ហើយតួនាទីរបស់គេគឺផ្សាភ្ជាប់មហាជនជាមួយនឹងអ្នកធ្វើផែនការនយោបាយ។ ផ្ទុយទៅវិញអភិបាលកិច្ចល្អ គឺសង្កត់ធ្ងន់ទៅលើដំណើរការអភិបាលកិច្ចដែលជួយជម្រុញឱ្យមានការចូលរួមរបស់សាធារណជនកាន់តែធំធេងថែមទៀត នៅក្នុងការធ្វើផែនការនយោបាយនិងអនុវត្ត។ ទាំងពីរនេះមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។

បើតាមការកត់សំគាល់របស់ខ្ញុំ ការប្រើប្រាស់ពាក្យសង្គមស៊ីវិលនៅប្រទេសយើងសព្វថ្ងៃ ក៏មិនខុសពីនៅប្រទេសថៃដែរ ពោលគឺច្រើនសង្កត់ធ្ងន់ទៅលើភាពជាដៃគូរវាងរដ្ឋនិងសង្គម ព្រោះថា តួនាទីរបស់រដ្ឋមានឥទ្ធិពលធំធេងណាស់ ហើយវាបាននឹងកំពុងជ្រៀតចូលគ្រប់ទិសទីក្នុងសង្គម។ ដូច្នេះ គេមិនអាចមិនទទួលស្គាល់បានឡើយ នូវតួនាទីរបស់រដ្ឋទាក់ទិនទៅនឹងការរីកចំរើននៃចលនាសង្គមស៊ីវិលបច្ចុប្បន្ន។

យើងក៏អាចកត់សំគាល់បានផងដែរថា សង្គមស៊ីវិលនៅកម្ពុជាអាចបែងចែកចេញជាពីរបែប។ មួយបែបគឺមានចរិតជាទំនាស់ ពោលគឺអនុញ្ញាតឱ្យមានការតវ៉ាទៅនឹងផែនការឬនយោបាយអភិវឌ្ឍន៍ណាមួយរបស់រដ្ឋ ឧទាហរណ៍ : ដូចជាចលនាតវ៉ារបស់ក្រុមអ្នកស្រែក្រីក្រអំពីគម្រោងអភិវឌ្ឍន៍នៅលើដីធ្លីរបស់គាត់ឬចលនាតវ៉ារបស់ក្រុមអ្នកនេសាទជាដើម..។ មួយបែបទៀត គឺជាចលនាសង្គមស៊ីវិលមានចរិតមូលមតិគ្នា ពោលគឺភាពជាដៃគូគ្នារវាងរដ្ឋ និងសង្គមស៊ីវិលនៅក្នុងការរៀបចំផែនការនយោបាយនិងអនុវត្តន៍។

ប្រភេទទី១ : ភាគច្រើនតំណាងឱ្យក្រុមប្រជាពលរដ្ឋក្រីក្របំផុត ជាពិសេស គឺចលនាពួកអ្នកខ្សត់ខ្សោយជាងគេនៅតាមមូលដ្ឋានឆ្ងាយៗ ដែលតាមពិតទៅក្រុម នេះគឺជាក្រុមដែលមានចំនួនមនុស្សច្រើនជាងគេ។ ឯប្រភេទទី២ ភាគច្រើនតំណាងឱ្យក្រុមពលរដ្ឋថ្នាក់កណ្តាលដែលតាមពិតទៅតំណាងឱ្យចលនាពលរដ្ឋតិចជាងប្រភេទទី១ទេ ក៏ប៉ុន្តែសព្វថ្ងៃ ចលនានេះហាក់មានចំនួនច្រើនជាង។ ក្រុមពលរដ្ឋថ្នាក់កណ្តាលនេះតែងប្រើប្រាស់សញ្ញាណអភិបាលកិច្ចល្អ និងលទ្ធិប្រជាធិបតេយ្យក្នុងការតស៊ូទាមទារអំណាចនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួនថែមទៀត។

តែទោះជាយ៉ាងណាក៏ដោយចលនាទាំងពីរប្រភេទ សុទ្ធតែមានតួនាទីសំខាន់ ហើយទាមទារ ការខិតខំនិងតស៊ូស្វិតស្វាញជាទីបំផុត។ ជាពិសេស ប្រភេទទី២: បើយើងស្តាប់មួយភ្លែតហាក់ដូចជាងាយស្រួល តែតាមពិត មិនមែនងាយស្រួលដូចការស្មាននោះទេ ដូចដែលខ្ញុំបានលើកឡើងពីខាងលើខ្លះៗមកហើយ ហើយអស់លោក លោកស្រីក៏ប្រាកដជាសង្កេតឃើញដោយខ្លួនឯងដែរ។

<u>សេចក្តីសន្និដ្ឋាន</u>

នៅក្នុងរបបប្រជាធិបតេយ្យ សង្គមស៊ីវិល គឺជាសេចក្តីត្រូវការចាំបាច់មិនអាចខ្វះបាន។ តួនាទីរបស់សង្គមស៊ីវិលកាន់តែសំខាន់ថែមទៀត នៅប្រទេសយើងដែលបានឆ្លងកាត់យ៉ាងយូរអង្វែង នូវរបបគ្រប់គ្រងបែបអាជ្ញាធិយមនិងកុម្មុយនិស្តនិយម ហើយកំពុងឆ្លងកាត់អន្តរកាល

ទៅកាន់លទ្ធិប្រជាធិបតេយ្យ។ ដូច្នេះ ចំណុចសំខាន់នៃការពិភាក្សារបស់យើងនៅពេលនេះ គឺធ្វើដូចម្តេចពង្រឹងសង្គមស៊ីវិលនៅកម្ពុជានិងធ្វើដូចម្តេចឱ្យមាននិរន្តរភាព។ សង្គមស៊ីវិលនៅកម្ពុជា ត្រូវបានចាត់ទុកជាយន្តការអភិបាលកិច្ចថ្មីមួយសំរាប់ការកែទំរង់សង្គម ដូច្នេះការខ្វះខាត និងចំណុចខ្សោយក្នុងការអនុវត្តន៍ ដូចដែលខ្ញុំបានលើកឡើងក្នុងករណី ស៊ី ស៊ី អាយ អាចជាគម្រុយខ្លះសំរាប់ការកែលំអ។ បន្ថែមពីលើនេះ ខ្ញុំយល់ថា អង្គការទាំងឡាយនៃសង្គមស៊ីវិលគប្បីជៀសវាងឱ្យបាននូវការប្រកួតប្រជែងគ្នាដើម្បីមុខមាត់និងផលផាន ព្រោះថាធម្មតាអង្គការមួយ តែងតំណាងឱ្យផលប្រយោជន៏មនុស្សទាំងឡាយនោះដែរ។ ផ្ទុយទៅវិញ គួរតែសហការគ្នារួមសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមកឱ្យទៅជាតំណាងសំលេងរបស់ប្រជាជនគ្រប់ផ្នែកតែម្តងទើបមានកំលាំងនិងឥទ្ធិពលទៅបាន។ម្យ៉ាងទៀត ចំណុចសំខាន់មួយក្នុងការពង្រឹងដំណើរការអភិបាលកិច្ចស៊ីវិល គឺការចែករំលែកអំណាចឱ្យបានសមស្របនៅក្នុងចំណោមក្រុមទាំងឡាយ ដែលមានចំណែករួម ជាពិសេសគឺក្រុមអ្នកក្រីក្រដែលសង្គមមិនសូវបានយកចិត្តទុកដាក់៕

## ៦.១៣_សុន្ទរកថាថ្លែងដោយ លោកស្រី មាស សុខុម អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ស្តីអំពី "ការកសាងនិរន្តរភាព នៃសង្គមស៊ីវិលនៅកម្ពុជា បញ្ហាប្រឈមមុខក្នុងការប្រមូលថវិកា"

សេចក្តីផ្តើម :

ជាការប្រសើរណាស់ ដែលរាជរដ្ឋាភិបាលបានបង្កលក្ខណៈតាមផ្លូវច្បាប់ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៤២ ស្តីពី សិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ដែលអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់។

ចាប់តាំងពីឆ្នាំ១៩៩៤ រហូតដល់បច្ចុប្បន្ន អង្គការមហាជនបានចុះឈ្មោះ នៅទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានចំនួន ៧៣២ ក្នុងនោះមានអង្គការមួយចំនួនធំមានការទទួលស្គាល់និងគាំទ្រពីមហាជនពីរាជរដ្ឋាភិបាលពីម្ចាស់ជំនួយ ហើយបានបង្កការងារតាមផែនការដែលបានកំណត់ទុករបស់ខ្លួនជារៀងរហូត។ នេះជាសក្ខីភាពមួយបញ្ជាក់ឱ្យឃើញ នូវការខិតខំប្រឹងប្រែងព្យាយាមតស៊ូទាំងកំលាំង កាយ ចិត្ត ប្រាជ្ញា ចូលរួមយ៉ាងសស្រាក់សស្រាំ ជាដៃគូជាមួយ និងរដ្ឋាភិបាលជាមួយនិងអង្គការមហាជនផ្សេងៗដទៃទៀត ដែលមានគោលនយោបាយប្រហាក់ប្រហែលគ្នា ដើម្បីឈានទៅរកការផ្លាស់ប្តូរ ផ្សារភ្ជាប់និងកិច្ចអភិវឌ្ឍន៍របស់ប្រទេសគ្រប់វិស័យ។ ម្យ៉ាងវិញទៀត ក៏ឃើញមានអង្គការខ្លះ ពុំសូវមានសកម្មភាពអ្វីគួរឱ្យកត់សំគាល់ទេ ហើយខ្លះទៀត

បានជួបបញ្ហា ដែលពុំអាចដោះស្រាយបាន ក៏ត្រូវបានបាត់ឈ្មោះពីអង្គការមហាជនផងដែរ។

## ១_ លក្ខខណ្ឌរក្សាតំណែលសង្គមស៊ីវិល :

ដើម្បីកសាងនិរន្តរភាពប្រកបដោយជោគជ័យ ពិសេសរក្សាខ្លួនឱ្យស្ថិតក្នុងអត្ថប្រយោជន៍របស់សង្គមជាតិពិតប្រាកដ នោះសង្គមស៊ីវិលត្រូវ :

- **ចេះវាយតំលៃរបស់ខ្លួនឲ្យបានច្បាស់ថា** តើយើងកំពុងតែស្ថិតនៅកន្លែងណា? ដើម្បីងាយស្រួលនិងបោះជំហានឱ្យបានដល់គោលដៅគឺការរៀបចំខ្លួនឆ្លើយតបសេចក្តីត្រូវការរបស់សង្គមជាតិ។
- **មានសមត្ថភាព** នេះជាចំណុចសំខាន់មួយរបស់សង្គមស៊ីវិលដែលត្រូវតែមាននិងព្យាយាមឱ្យមានដើម្បី :
  - → ដឹកនាំការងារ ចាត់ចែងការងារ
  - → អនុវត្តការងារ
  - → ទំនាក់ទំនងចងក្រងបណ្តាញ
  - → ទំនាក់ទំនងប្រមូលថវិកា ប្រមូលធនធាន
  - → ផ្តួចផ្តើមគំនិតគ្រប់បែបយ៉ាង
- **ស្គាល់សភាពការណ៍ គោលនយោបាយប្រទេស** ការស្គាល់សភាពការណ៍ ក៏ជាលក្ខណៈសមស្របមួយ ដែលអាចឱ្យដំណើរការរបស់

អង្គការមិនរាំងស្ទះ ព្រោះ វាអាចធ្វើឱ្យយើងធ្វើការផ្លាស់ប្ដូរគោលនយោបាយឬវិធីសាស្ត្រ ឬកម្មវិធីរបស់អង្គការ ហើយការផ្លាស់ប្ដូរនោះមានការគាំទ្រ។

- **មានគោលនយោបាយ រចនាសម្ព័ន្ធ មានវិន័យ** គោលនយោបាយជាកញ្ចក់មួយឆ្លុះបញ្ចាំងនូវជំហរអព្យាក្រឹតឥតលំអៀង ដែលអាចធ្វើឱ្យមានការទទួលស្គាល់ពីអ្នកគាំទ្រថវិកានិងអាចតម្រង់ទិសឱ្យអង្គការរៀបចំរចនាសម្ព័ន្ធទៅតាមសមត្ថភាពជំនាញ និងការទទួលខុសត្រូវរបស់សមាជិកខ្លួន ដោយឥតគិតពីញាតិបក្សនិយមឬគ្រួសារនិយម។ម្យ៉ាងវិញទៀត លក្ខណៈសំខាន់ដែលពុំអាចខ្វះបានទៀត នោះគឺសង្គមស៊ីវិលត្រូវតែមានអាកប្បកិរិយា អត្តចរិកថ្លៃថ្នូរ មានវិន័យតាមបែបអ្នកមានវិជ្ជាជីវៈ។
- **ឆន្ទៈ ស្មារតីទទួលខុសត្រូវ សាមគ្គីភាព** ជាចំណែកមួយយ៉ាងធំដែលសង្គមស៊ីវិលត្រូវមាន។ មានឆន្ទៈទើបមានការទទួលខុសត្រូវ។ ក្នុងការរួមចំណែក ធ្វើការផ្លាស់ប្ដូរសង្គមទាមទារឆន្ទៈ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ទើបសង្គមស៊ីវិលមានសក្ដានុពលស្វែងរកដៃគូការងារឬដៃគូសហការឬអ្នកគាំទ្រថវិកាមានប្រសិទ្ធិភាពខ្ពស់។ សាមគ្គីភាពអាចជាកំលាំងដ៏រឹងមាំងាយស្រួល ក្នុងការជម្រុញការងារបានជោគជ័យ ហើយដែលត្រូវមានយ៉ាងចាំបាច់បំផុត ទាំងក្នុងអង្គការ ទាំងសង្គមស៊ីវិលទូទៅ ដើម្បីជាភាពជាក់លាក់មួយបង្កើតបាននូវជំនឿទុកចិត្តពីអ្នកឧបត្ថម្ភថវិកានិងពីរាជរដ្ឋាភិបាលថា សង្គម

ស៊ីវិលជាកំលាំងមួយ ដែលពុំអាចខ្វះបាន ក្នុងកំឡុងពេលដែលប្រទេសជាតិកំពុងតែអភិវឌ្ឍគ្រប់វិស័យ។

- ចម្លាភាព ការប្រើប្រាស់ថវិកាជាការចាំបាច់ ដើម្បីអនុវត្តកម្មវិធីតាមការគ្រោងទុក។ រាល់ការចំណាយសង្គមស៊ីវិលត្រូវពិចារណាឱ្យបានត្រឹមត្រូវលើទំហំការងារតម្រូវការថវិកា ពេលវេលា ជាពិសេសផលប្រយោជន៍ដែលក្រុមទទួលផលបានទទួលថា តើមានលក្ខណៈសមស្របដែរឬទេ? រាល់ការចំណាយទាំងនេះ ក៏ត្រូវតែច្បាស់លាស់ត្រឹមត្រូវ ចៀសវាងការស្រពិចស្រពិលមន្ទិលសង្ស័យពីម្ចាស់ជំនួយផង ពីអ្នកចូលរួមផង ដែលអាចធ្វើឱ្យបាត់បង់ដល់កិត្តិស័ព្ទនិងភាពរឹងមាំរបស់អង្គការនៅថ្ងៃណាមួយ ហើយភាពជឿជាក់ប្រាកដជាបាត់បង់ដូចគ្នាដែរ។

**២_ ធនធានរបស់សង្គមស៊ីវិល :**

ធនធានជាចំណុចសំខាន់មួយ ដែលសង្គមស៊ីវិលតែងតែពុះពារស្រាវជ្រាវ ស្វែងរកដើម្បីបំរើការងារឱ្យបានទាន់សភាពការណ៍ ហើយដើម្បីធ្វើឱ្យបានសំរេចទិសដៅរបស់ខ្លួន។

**ធនធានទាំងនោះមាន ៖**

- សមត្ថភាពរបស់អ្នកដឹកនាំ សមាជិកដែលមានគុណភាព
- អ្នកគាំទ្រថវិកា
- អ្នកចូលរួមកិច្ចសហការ ដៃគូ បណ្តាញការងារទាំងសង្គមស៊ីវិលទាំងស្ថាប័នពាក់ព័ន្ធទាំងរដ្ឋាភិបាល

- ជំនាញបច្ចេកទេស សម្ភារៈ ឯកសារ ព័ត៌មាន
- ឱកាស ពេលវេលា ការទំនាក់ទំនង
- ភាពជឿជាក់លើការងារ លើសមត្ថភាពរបស់ខ្លួន និងលើអ្នកដទៃ
- ភាពជឿជាក់ពីអ្នកដទៃ

៣_ ការប្រមូលផ្តុំធនធាន :

សង្គមស៊ីវិលមានសក្តានុពលគួរឱ្យកត់សំគាល់សំរាប់ជួយជម្រុញសកម្មភាពសង្គមឱ្យមានការផ្លាស់ប្តូរ ទៅរកចំណុចវិជ្ជមានលើវិស័យសេដ្ឋកិច្ច សីលធម៌ សង្គម ការតាក់តែងច្បាប់និងការគោរពច្បាប់។ សង្គមស៊ីវិលអាចពង្រីកឥទ្ធិពលរបស់ខ្លួនបានអាស្រ័យលើការចេះប្រមូលធនធាន ព្រោះធនធាននេះហើយ ដែលអាចពង្រឹងជំហរដាច់ខាតរបស់សង្គមស៊ីវិល ក្នុងការគាំទ្រចូលរួមអនុវត្តការងារ។ វាជាការពិបាកមួយសំរាប់អង្គការណា ដែលពុំអាចបំពេញនូវលក្ខខ័ណ្ឌរបស់ខ្លួន។ ម្យ៉ាងវិញទៀត ទាក់ទងនឹងការទំនាក់ទំនងល្អស្របជាមួយនឹងកិត្តិស័ព្ទ ក៏ជាមូលដ្ឋានមួយយ៉ាងធំ ដែលអាចបើកផ្លូវឱ្យអង្គការសង្គមស៊ីវិលមានច្រកចេញយ៉ាងទូលាយក្នុងការប្រមូលធនធាន ដើម្បីមានការចូលរួមនិងមានការគាំទ្រ។ កិត្តិស័ព្ទរបស់អង្គការ ជាស្ពានមួយដែលអាចចម្លងយើងឱ្យបានដល់ប្រភពធនធានរបស់យើងបានល្អប្រសើរដែរ។ ករណីពិសេសមួយទៀត ក៏ត្រូវផ្អែកទៅលើដំណើរការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការជាក់លាក់ជាបន្ទាន់ និងជាយុទ្ធសាស្ត្ររបស់សង្គមស៊ីវិលត្រូវតែព្យាយាមផ្តល់ជាគំនិតយោបល់ ធ្វើយ៉ាងណាឱ្យអង្គការដែលពុំ

មានលទ្ធភាពអាចទទួលបាន ដើម្បីយកទៅបំរើផលប្រយោជន៏សង្គម ដែលជាទិសដៅរួមសំរាប់ឆ្លើយតបទៅតាមសេចក្តីត្រូវការ។

៤_ បញ្ហាប្រឈមមុខក្នុងការប្រមូលផ្តុំធនធាន :

- ខ្វះការទំនាក់ទំនងល្អ។
- គោលនយោបាយរបស់អង្គការមិនច្បាស់លាស់។
- ខ្វះសមត្ថភាពដឹកនាំចាត់ចែង រចនាសម្ព័ន្ធមិនសមស្រប។
- ទិសដៅមិនសមស្រប គ្មានតម្លាភាព។
- ខ្វះការគាំទ្រពីរដ្ឋាភិបាល មូលដ្ឋាន ពត៏មានមិនគ្រប់គ្រាន់។
- មិនស្គាល់ប្រភពធនធាន ថវិកាពុំគ្រប់គ្រាន់សមស្រប។
- ពេលវេលាមិនសមស្រប_មិនឈ្វេងយល់អ្វីខ្លះទៀត ដែលត្រូវការផ្លាស់ប្តូរ។
- របាយការណ៏ការងារមិនច្បាស់លាស់បំផ្លើស (ជំនាញ)។
- មិនគោរពតាមកិច្ចព្រមព្រៀង_មិនស្វែងរកដៃគូ។
- ការងារមិនស្របទៅតាមពេលវេលា មិនស្របនឹងថវិកា មិនស្របនឹងផល។
- ប្រយោជន៏ក្នុងការប្រើប្រាស់ថវិកា បាត់បង់ជំនឿទុកចិត្តពីម្ចាស់ជំនួយ។
- បែកបាក់សាមគ្គី៕

## VII- សុន្ទរកថានៃវាគ្មិន ថ្លែងក្នុងកិច្ចពិភាក្សាសន្និសីទជាតិ

**៧.១_សុន្ទរកថាស្វាគមន៍ ថ្លែងដោយ ឯកឧត្តម ខៀម វ៉ាដ្ឋសាឌី ទីប្រឹក្សាព្រះប្រធានរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយកវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ស្តីអំពី "ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យនៅអនាគត "**

ដើម្បីជាកិច្ចចាប់ផ្តើមបើកសន្និសីទថ្នាក់ជាតិស្តីអំពី "ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យនៅអនាគត ក្នុងពេលព្រឹកនេះក្នុងនាមគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណ និងអំណរសាទរដ៏ជ្រាលជ្រៅ និងសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់គណៈអធិបតី ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ជាគណៈវាគ្មិនសំខាន់ៗជាភ្ញៀវកិត្តិយស ជាតិនិងអន្តរជាតិ ព្រមទាំងសមាជិក សមាជិកាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមារញឹក និងមានតម្លៃមកចូលរួមក្នុងសន្និសីទជាតិដ៏មានអត្ថប្រយោជន៍នេះ។

វត្តមានដ៏ខ្ពង់ខ្ពស់របស់គណៈអធិបតី និងការចូលរួមដោយស្មោះសររបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នេះបានឆ្លុះ

បញ្ជាំងឱ្យឃើញ នូវសហប្រតិបត្តិការដ៏បរិសុទ្ធ និងស្មារតីឧបត្ថម្ភគាំទ្រ ដោយឥតសំចៃដល់សន្និសីទជាតិ ស្តីអំពី "ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យនៅអនាគត" ឱ្យបានសំរេចគោលបំណង ជាសក្តានុពលរបស់ខ្លួនក្នុងការរួមចំណែកលើកស្ទួយវឌ្ឍនភាពនៃអង្គការសង្គមស៊ីវិលកម្ពុជា ដើម្បីបុព្វហេតុនៃការដឹកនាំ និងគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ។

ក្នុងពិធីបើកអង្គសន្និសីទនេះ ខ្ញុំក៏សូមឆ្លៀតឱកាសសម្តែង នូវអំណរគុណដ៏ស្មោះស្ម័គ្រចំពោះ "មូលនិធិ ហេនរិច បូល-Heinrich Boll Foundation" ដែលតំណាងដោយ លោកស្រីបណ្ឌិត Heike Löschmann, ដែលបានឧបត្ថម្ភគាំទ្រទាំងស្មារតី ក៏ដូចជាថវិកាបង្កើតមាន "គម្រោងកម្មវិធីសិក្សាស្រាវជ្រាវអំពីសង្គមស៊ីវិលកម្ពុជានិងអភិបាលកិច្ចល្អ" សំរាប់រយៈពេលបីឆ្នាំ និងធ្វើឱ្យសំរេចសន្និសីទថ្នាក់ជាតិក្នុងឆ្នាំទីមួយ (ឆ្នាំ២០០០) នេះ។

ម្យ៉ាងវិញទៀត ខ្ញុំក៏សូមឆ្លៀតឱកាសនេះដែរ ដើម្បីសម្តែងនូវកតញ្ញូតាដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលបានរួមចំណែកធ្វើឱ្យកិច្ចប្រជុំតុមូល អស់រយៈពេលមួយឆ្នាំកន្លងមកនេះបានដំណើរការពិភាក្សាប្រកបដោយជោគជ័យរបស់ខ្លួន។

ខ្ញុំក៏ពុំភ្លេចនឹងសម្ដែងនូវការអំណរគុណ ដោយសេចក្ដីគោរពដឹងគុណ ចំពោះឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីដែលបាន ចំណាយពេលដ៏ឧត្ដុង្គឧត្ដម ក្នុងពិធីបើកសន្និសីទថ្នាក់ជាតិ នាពេល ព្រឹកនេះ។

នៅក្នុងនាទីចាប់ផ្ដើមជាដំបូងនៃពិធីបើកអង្គសន្និសីទជាតិស្ដីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខនិងទស្សនវិស័យនៅអនាគត" នេះ ខ្ញុំសូមអនុញ្ញាតជំរាប ជូនខ្លះៗ នូវមូលប្រវត្តិ និងវត្ថុបំណងរបស់វិទ្យាស្ថានខ្មែរសំរាប់សហ ប្រតិបត្តិការ និងសន្តិភាព ក្នុងការរៀបចំបង្កើតឱ្យមានអង្គសន្និសីទថ្នាក់ ជាតិនេះ ÷

១_អំពីមូលប្រវត្តិ :

ក្នុងការពិនិត្យមើលនិន្នាការថ្មីៗនៃប្រទេសជាតិយើង ក្នុងបណ្ដា ឆ្នាំក្រោយសម័យសង្គ្រាមដ៏ខ្មៅចខ្នាំនេះ យើងបានសញ្ជឹងគិតឃើញថា កម្ពុជាពិតជាត្រូវការរបៀបរបបដឹកនាំនិងគ្រប់គ្រងមួយដែលមានលក្ខណៈ ជឿនលឿនស្អាតស្អំបរិសុទ្ធ នោះទើបអាចរំដោះជាតិយើងឱ្យរួចផុត ពីភាពក្រីក្រ ការប្រព្រឹត្តិអំពើពុករលួយ និងសង្គ្រាមវិនាសកម្មបាន។ អាស្រ័យដោយឥទ្ធិពលនៃសង្គ្រាមយូរអង្វែង និងការបាត់បង់ទៅនូវតម្លៃ សីលធម៌ គុណធម៌ សុចរិតធម៌ និងភាពស្អាតស្អំខាងផ្លូវចិត្តគំនិត ការ ដឹកនាំ និងគ្រប់គ្រងរបស់ប្រទេសជាតិយើងបានជួបនឹងការលំបាកជាបន្ត

បន្ទាប់អំពីការគ្រប់គ្រងមិនល្អ។ ម៉្លោះហើយផលទុនជាតិ ភោគផលធម្មជាតិ និងបរិស្ថានរបស់ជាតិមាតុភូមិយើងត្រូវបានយាយីដោយការគ្រប់គ្រង បែបបុគ្គលនិយមឱនថយ និងការកេងប្រវ័ញ្ចន៏យកដោយគ្មានការបែងចែកបានឱ្យប្រកបដោយសមធម៌ឡើយ។ ដរាបណា ជាតិយើងរកពុំឃើញឱ្យបានទាន់ពេលវេលានូវការគ្រប់គ្រងដោយសុចរិតធម៌ យុត្តិធម៌ និងប្រកបដោយអភិបាលកិច្ចល្អទេ នោះកម្ពុជាពុំអាចអភិវឌ្ឍឈានទ្បើងទាំងខាងវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច អប់រំ និងវប្បធម៌ ក៏ដូចជាវិស័យយោធា និងសន្តិសុខជាតិឱ្យទាន់គេឯងក្នុងតំបន់តាមរយៈសមាហរណកម្មនៃយុគសម័យឡើយ។ គឺជាការខកខាន និងយឺតយ៉ាវមួយប្រសិនបើកម្ពុជា នៅតែបណ្តែតបណ្តោយឱ្យការដឹកនាំនិងគ្រប់គ្រងជាតិស្ថិតនៅក្នុងភាពអសកម្មរ៉ាំរ៉ៃគ្របដណ្តប់ដោយការគ្រប់គ្រងឱនថយ និងការប្រព្រឹត្តិអំពើកេងប្រវ័ញ្ចន៏។

ដើម្បីជំនះបាននូវការខ្វះខាតនេះ មធ្យោបាយដោះស្រាយបញ្ហាមានតែមួយទេ នោះគឺការប្រើប្រាស់កម្លាំងសរុប សហប្រតិបត្តិការរួម និង ការប្តេជ្ញាចិត្តខ្ពស់ពីគ្រប់និន្នាការនយោបាយ នៃសង្គមជាតិយើង ពិសេសគឺសហប្រតិបត្តិការ និងស្មារតីធ្វើជាគំរូពីបណ្តាផ្នែកឯកជន និងអង្គការសង្គមស៊ីវិល ក្នុងការលើកស្ទួយអភិបាលកិច្ចល្អ។ ដោយមានសារៈជាតិកំណើត និងតួនាទីជាសារវ័ន្តរបស់ខ្លួន ក្នុងការស្វែងរកក៏ដូចជារក្សាការពារផលប្រយោជន៏សមាជិក និងសង្គមជាតិទាំងមូលអង្គការសង្គមស៊ីវិលខ្មែរគ្រប់ជាន់ថ្នាក់ ត្រូវតែចូលរួមចំណែកអភិវឌ្ឍវប្បធម៌

ប្រជាធិបតេយ្យមួយជឿនលឿន ដែលមានសារៈដល់ការអប់រំចិត្តគំនិតឱ្យមានអភិបាលកិច្ចល្អ និងសុចរិតធម៌។

ដោយប្រទេសជាតិយើង ត្រូវអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យបានរុងរឿងឆាប់រហ័ស ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្រោយសម័យ សង្គ្រាមដ៏យូរលង់នេះក៏ដូចជា ដើម្បីជំរុញការចូលរួមក្នុងតំបន់របស់យើងកាន់តែមានភាពល្អប្រសើរឡើងកម្ពុជាចាំបាច់ត្រូវប្រឈមមុខ និងបញ្ហាសំខាន់ពីរ :

ទីមួយៈ គឺការគ្រប់គ្រងឱនថយ ដែលគ្មានស្មារតីទទួលខុសត្រូវ

ទីពីរ : គឺអភិបាលកិច្ចល្អ និងសុចរិតធម៌ដែលគប្បីប្រកាន់យកដើម្បីលើកស្ទួយអភិវឌ្ឍនភាពខាងសេដ្ឋកិច្ច ការស្តារជំនឿទំនុកចិត្តនិងកាត់បន្ថយការកេងប្រវ័ញ្ច និងភាពអយុត្តិធម៌ក្នុងការបែងចែកផលទុនជាតិនិងការគ្រប់គ្រងធនធានធម្មជាតិអោយប្រកបដោយសមធម៌។

ទាំងពីរនេះគឺជាបញ្ហាដែលជនជាតិយើងពិសេសគឺមគ្គុទ្ទេសភាព និងការគ្រប់គ្រងសង្គមជាតិ យើងនិងជាសំខាន់គឺអង្គសន្និសីទជាតិយើងក្នុងរយៈពេលពីរថ្ងៃនេះ ត្រូវគិតពិចារណា ដើម្បីរកឱ្យឃើញនូវទស្សនៈវិស័យ និងចំណេះដឹងជាបទពិសោធន៍ល្អៗ សំរាប់ជួយលើកស្ទួយអភិបាលកិច្ចល្អ និងសុចរិតធម៌ ក្នុងការដឹកនាំ និងគ្រប់គ្រងសង្គមជាតិយើងនេះ។

## ២_អំពីគោលបំណងនៃអង្គសន្និសីទជាតិ :

ជាគោលដៅ វត្ថុបំណងដ៏ពិសិដ្ឋ នៃការបង្កើតឱ្យមានអង្គសន្និសីទថ្នាក់ជាតិយើងនេះគឺ ដើម្បីពិនិត្យមើលលទ្ធផលនៃការពិភាក្សាតុមូលចំនួន១០លើក ស្តីពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា" ដែលបានរៀបចំឡើងដោយ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព អស់រយៈពេលពេញមួយឆ្នាំកន្លងមកនេះ។

ការត្រួតពិនិត្យមើលនូវលទ្ធផលនេះ គឺជាការបំពេញបន្ថែម (ឬកាត់បន្ថយ) នូវទស្សនៈ និងបទពិសោធន៍ ដែលកិច្ចប្រជុំតុមូលទាំង ១០លើក បានរកឃើញអំពីអត្ថន័យ និងសារៈសំខាន់នៃអភិបាលកិច្ចល្អ និងតួនាទីរបស់អង្គការសង្គមស៊ីវិលកម្ពុជា ក្នុងការលើកស្ទួយអភិបាលកិច្ចល្អឱ្យទៅជាវប្បធម៌ដឹកនាំ និងគ្រប់គ្រងមួយរបស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង ពិសេសគឺរបស់អ្នកដឹកនាំ និងគ្រប់គ្រងទាំងឡាយ ដើម្បីជួយកាត់បន្ថយការគ្រប់គ្រងឱនថយដែលបានស៊ីបំផ្លាញសុចរិតធម៌ និងអភិវឌ្ឍធម៌របស់សង្គមសេដ្ឋកិច្ច និងនយោបាយជាតិយើងក្នុងបណ្តាឆ្នាំនៃសម័យសង្គ្រាម និងក្រោយសង្គ្រាមនេះ។

ក្រោយពីអង្គសន្និសីទនេះចប់ទៅ ចំណេះដឹងនិងបទពិសោធន៍ទាំងឡាយដែលប្រមូលផ្តុំបានតាមរយៈការពិភាក្សារួម ក្នុងសម័យពេញអង្គទាំង៦នៃអង្គសន្និសីទនេះ នឹងត្រូវយកទៅចងក្រង ទុកជាឯកសារស្រាវជ្រាវ និងបោះពុម្ពផ្សាយជាសាធារណៈ ដើម្បីជាគុណប្រយោជន៍

ដល់ការកសាង និងអភិវឌ្ឍន៍ជាតិយើងឱ្យរួចផុតពីការគ្រប់គ្រងមិនល្អនិងភាពឱនថយនេះ។

វត្ថុបំណងជាសក្តានុពលមួយទៀត ដែលអង្គសន្និសីទត្រូវសំរេចឱ្យបាន នោះគឺការរកឱ្យឃើញតួនាទីរបស់អង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ក្នុងការជួយរួមចំណែកអភិវឌ្ឍអភិបាលកិច្ចល្អ នៅក្នុងអង្គការសង្គមស៊ីវិលរបស់ខ្លួនផង និងនៅក្នុងសង្គមជាតិយើងទាំងមូលផង។

ការបំពាក់និងកំណត់បានច្បាស់នូវតួនាទីជាសារវ័ន្ត និងភារកិច្ចដ៏ចាំបាច់របស់សង្គមស៊ីវិលកម្ពុជា (ដែលមានចំនួនកើនឡើងក្នុងបច្ចុប្បន្នរហូតដល់មិនតិចជាង ១០០០ អង្គការទៅហើយនេះ) គឺជាការជួយស្ថាបនាកម្លាំងចលករដ៏ស្រួចមួយ ដើម្បីធ្វើជាដៃគូដ៏ល្អរបស់រដ្ឋាភិបាលក្នុងការអប់រំផ្សព្វផ្សាយ អនុវត្តន៍អំពីទស្សនាទាន និងសារៈសំខាន់នៃអភិបាលកិច្ចល្អ ដែលជាសំណូមពរ ដ៏ចាំបាច់របស់ប្រទេសជាតិ និងប្រជាពលរដ្ឋយើង។

ទាំងអស់នេះ គឺជាគោលដៅនិងវត្ថុបំណងរបស់អង្គសន្និសីទ។ ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាគណៈវាគ្មិន និងជាសមាជិក សមាជិកានៃអង្គពិភាក្សាទាំង៦ ពិតជាមានយោបល់ប្លែកៗ និងផ្សេងៗគ្នា។ ក៏ប៉ុន្តែ ទស្សនៈប្លែកៗទាំងនោះពុំមែនមានន័យថា ជាមតិបដិបក្ខទេ តែគឺជាទស្សនៈជម្រុះ និងជាមតិសេរីឯករាជ្យ ដែលនឹងបញ្ចេញឡើងដើម្បីគោលដៅរួមតែមួយគត់នោះ គឺការស្ថាបនាអង្គការសង្គមស៊ីវិលកម្ពុជា ឱ្យកាន់តែប្រសើរឡើងដើម្បី

លើកស្ទួយការដឹកនាំ និងគ្រប់គ្រងជាតិយើងប្រកបដោយអភិបាលកិច្ចល្អ និងសុចរិតធម៌។

ជាថ្មីម្តងទៀត នៅទីបញ្ចប់នេះ ក្នុងនាមគណៈកម្មាធិការនាយក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ខ្ញុំសូមសម្តែងនូវអំណរសាទរនិងមនោសញ្ចេតនាគោរពស្វាគមន៍ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ជាគណៈវាគ្មិន ជាភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ព្រមទាំងសមាជិក សមាជិកានៃអង្គសន្និសីទថ្នាក់ជាតិ ដែលបានអញ្ជើញចូលរួមជាគណៈអធិបតី និងជាកិត្តិយសក្នុងពិធីបើកអង្គសន្និសីទថ្នាក់ជាតិដ៏មានសារៈសំខាន់នេះ។

- សូមជូនពរ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ គណៈវាគ្មិនកិត្តិយសព្រមទាំង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិក សមាជិកាទាំងអស់ សូមបានប្រកបដោយវឌ្ឍនភាព អាយុយឺនយូរ វិបុលភាព និងសុភមង្គល!

## ៧.២_ថ្លែងដោយស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍ ឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រកម្ពុជានិងជាប្រធានគណៈកម្មាធិការនាយកវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព ស្តីអំពី "ការកសាងសង្គមស៊ីវិលកម្ពុជា ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យទៅអនាគត"

ខ្ញុំមានមនោសញ្ចេតនារំភើបរីករាយ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមកចូលរួមក្នុងសន្និសីទ ជាតិស្តីអំពី "ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យទៅអនាគត" ក្នុងពេលព្រឹកនេះ។

ខ្ញុំសូមសម្តែងនូវអំណរគុណ និងការកោតសរសើរចំពោះបុគ្គលិក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ព្រមទាំងមូលនិធិ **Heinrich Boll Foundation** ដែលបានសហការរៀបចំបង្កើតឱ្យមានការសិក្សាស្រាវជ្រាវស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលកម្ពុជា" និងបង្កើតឱ្យមានសន្និសីទជាតិប្រចាំឆ្នាំ២០០០ ដ៏មានសារៈសំខាន់នេះ។

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាពបានដើរតួនាទីសំខាន់ ក្នុងការលើកកំពស់ ការពិភាក្សា និងការផ្លាស់ប្តូរមតិទស្សនៈ

និងពត៌មាននានា ដែលពាក់ព័ន្ធទៅនឹងបញ្ហាជាតិ ការចូលរួមក្នុងតំបន់ បញ្ហានៃការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ការងារ បរទេស អភិបាលកិច្ចល្អ និងវប្បធម៌សន្តិភាព។ សន្និសីទថ្នាក់ជាតិក្នុងឆ្នាំ២០០០ ស្តីអំពី "ការកសាងសង្គមស៊ីវិលដើម្បីអភិបាលកិច្ចល្អ : សមិទ្ធិផល ការប្រឈមមុខនិងទស្សនវិស័យនៅអនាគត" នេះ គឺជាលទ្ធផលនិងជាភស្តុតាងជាក់ស្តែង ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការខិតខំប្រឹងប្រែងនេះ។

នេះគឺជាមោទនភាពមួយរបស់ជាតិយើង ដែលសន្និសីទថ្នាក់ជាតិនេះបានរៀបចំឡើង ចំពេលដែលរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងបណ្តាផ្នែកឯកជន កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើនិន្នាការនៃយុគសម័យនៅលើពិភពលោកទាំងមូលដែលបាន និងកំពុងប្រមូលផ្តុំជាសំខាន់ទៅលើ "ទស្សនាទាននៃអភិបាលកិច្ចល្អ" ថាជារបៀបរបបគ្រប់គ្រងថ្មីមួយស្អាតស្អំ_បរិសុទ្ធ សច្ចៈជឿនលឿនដែលអាចបង្ការបាននូវការប្រព្រឹត្តិអំពើពុករលួយ ញាតិបក្សនិយម បុគ្គលនិយមនិងការកេងប្រវ័ញ្ច។

ជាទស្សនៈនៃយុគសម័យ អភិបាលកិច្ចល្អ គឺជាឱសថសំរាប់ព្យាបាលជម្ងឺពុករលួយអំពើកេងប្រវ័ញ្ច និងទម្លាប់នៃការគ្រប់គ្រងឱនថយ។ ទីណាដែលទស្សនាទានអភិបាលកិច្ចល្អត្រូវបានលើកតម្កើង និងគ្រប់គ្រងបានល្អ ទីនោះអភិឌ្ឍនភាព និងកិត្យានុភាពជាតិត្រូវបាន

លើកស្ទួយ និងអភិវឌ្ឍជឿនលឿន។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ (ជាបទពិសោធន៍ដែលគួរចងចាំ) ទីណាដែលអត្ថន័យ និងសារៈសំខាន់នៃអភិបាលកិច្ចល្អពុំត្រូវបានយកចិត្តទុកដាក់ទេ ទីនោះទំនាស់អំពីបញ្ហាផលប្រយោជន៍ ជម្លោះបែកបាក់និងភាពឱនថយបានកើតមានឡើង។ ដូច្នេះ អភិបាលកិច្ចល្អ និងការគ្រប់គ្រងប្រកបដោយសុចរិតធម៌ គឺជាតម្រូវការចាំបាច់មិនអាចខ្វះបានក្នុងការដឹកនាំនិងការគ្រប់គ្រង ដើម្បីឆ្ពោះទៅរកអភិបាលកិច្ចជឿនលឿន ការកាត់បន្ថយទំនាស់ វឌ្ឍនភាពសេដ្ឋកិច្ច ភាពសុខដុមរមនា សុខុមាលភាពរបស់ប្រជាពលរដ្ឋ ក្នុងសង្គមជាតិយើង។ សារៈសំខាន់នៃអភិបាលកិច្ចល្អប្រៀបបានទៅនឹងអាវុធស័ក្តិសិទ្ធិដែលអាចកាប់ឆ្ការបាននូវអំពើអសកម្ម ដែលមានឫសគល់យ៉ាងរឹងមាំនៅក្នុងផ្នត់គំនិតរបស់មនុស្ស។ ភាពអសកម្មទាំងនោះគឺ ៖ ១_ភាពអត្តនោម័ត ២_អំពើពុករលួយ ៣_ភាពបែកបាក់ និងសង្គ្រាមវិនាសកម្ម។

ខ្ញុំសូមឆ្លៀតឱកាស ក្នុងអង្គសន្និសីទដ៏មានសារៈសំខាន់នេះ ដើម្បីសម្តែងនូវការពេញចិត្តដោយស្មោះចំពោះការកើតឡើង និងវិវត្តន៍រីកចំរើនឥតឈប់ឈរនៃអង្គការសង្គមស៊ីវិលកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ឆ្លងតាមរយៈរបាយការណ៍ផ្សេងៗនិងប្រមូលផ្តុំបានអំពីសកម្មភាពរបស់អង្គការNGOsកម្ពុជា ក៏ដូចជាអង្គការសង្គមស៊ីវិលទាំងអស់ យើង

ក្ដាប់បានថា : ដោយមានការប្រជុំពិភាក្សា វប្បធម៌ពិគ្រោះយោបល់ ការសិក្សារៀនសូត្រនៅលើគ្រប់វេទិកាសេរីនានា ដែលវិទ្យាស្ថាននិងអង្គការទាំងឡាយបានរៀបចំឡើង សុទ្ធតែបានធ្វើឱ្យអង្គការសង្គមស៊ីវិលយើងមានការវិវត្តន៍រីកចំរើនគួរជាទីមោទនៈ។ សព្វថ្ងៃ ទំនាក់ទំនងរវាងសង្គមស៊ីវិលនិងសង្គមស៊ីវិលរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ក៏ដូចជាម្ចាស់ឧបត្ថម្ភថវិកាបានវិវត្តរីកចំរើនឈានដល់ការពង្រឹងនូវភាពជាដៃគូដ៏ល្អមួយក្នុងការជួយកសាងនិងអភិវឌ្ឍន៍ជាតិយើងហើយ។ បទពិសោធន៍ឱនថយនៃការប្រឈមមុខ ការមិនយោគយល់គ្នា ការមើលគ្នាក្នុងផ្លូវខុស កង្វះទំនុកចិត្ត ភាពសង្ស័យ ស្រពិចស្រពិល ការប្រមាថមើលងាយគ្នា និងការខ្វែងគោលបំណងគ្នាត្រូវបានកាត់បន្ថយ និងលុបបំបាត់ជាអប្បបរិមា។ ទាំងស្ថាប័នសង្គមស៊ីវិល ទាំងស្ថាប័នរដ្ឋ និងស្ថាប័ននីតិប្បញ្ញត្តិ បានរកឃើញនូវទស្សនៈជឿនលឿន និងចំណេះដឹងជាបទពិសោធន៍ល្អៗ ក្នុងការពង្រឹងសហប្រតិបត្តិការ និងភាពជាដៃគូ (មិនអាចខ្វះបាន) ក្នុងការដោះស្រាយបញ្ហា ក្នុងការកសាងអភិបាលកិច្ចល្អ ប្រព័ន្ធសុចរិតធម៌ និងក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិយើង។

នេះគឺជាគុណសម្បត្តិ ដែលត្រូវទទួលស្គាល់។ គុណសម្បត្តិនេះគឺពិតជាបានមកពីការខិតខំប្រឹងប្រែងរបស់អង្គការស៊ីវិលយើងក្នុងការប្រជុំពិភាក្សា_សិក្សារៀនសូត្រ ការផ្លាស់ប្ដូរទស្សនៈ និងយោបល់ផ្សេងៗ

ដើម្បីស្វែងរកគោលគំនិតស្លាបនាល្អៗ សំដៅពង្រឹងអង្គការសង្គមស៊ីវិល និងពង្រឹងទំនាក់ទំនងល្អ របស់អង្គការសង្គមស៊ីវិលជាមួយរដ្ឋាភិបាលនិងម្ចាស់អំណោយ។

ការស្គាល់ខ្លួនឯងច្បាស់ និងស្គាល់តួនាទីរបស់ខ្លួន ចំពោះអ្នកដទៃនិងសង្គមជាតិ គឺជាចំណុចសកម្ម និងជាប្រភពនៃវឌ្ឍនភាពនេះ។

ក៏ប៉ុន្តែ ចំពោះបញ្ហានេះ យើងពុំគួរលង់លក់ស្កប់ស្កល់ នឹងគុណសម្បត្តិនេះ ហើយមើល រំលងការខ្វះខាតទេ។ ជាការពិតណាស់ ក្នុងជីវិតនេះខុស និងត្រូវល្អនិងអាក្រក់ ជឿនលឿននិងឱនថយ វាតែងនៅជាមួយគ្នា ហើយរុញច្រានគ្នាទៅវិញទៅមក។ រាល់ការប្រមាថ (ការធ្វេសប្រហែស) និងការភ្លេចខ្លួនសប្បាយភ្លើតភ្លើននឹងគុណសម្បត្តិ ហើយបំភ្លេចចោលគុណវិបត្តិ គឺជានិន្នាការឆ្ពោះទៅរកភាពបរាជ័យ។

ដូច្នេះ ដើម្បីពង្រឹងនិងពង្រីកនូវចំនុចខ្លាំងខាងលើ ហើយកាត់បន្ថយឱ្យបានជាអប្បបរិមានូវចំនុចខ្សោយ ក្នុងការកសាង និងអភិវឌ្ឍន៍សង្គមស៊ីវិល ដើម្បីលើកស្ទួយអភិបាលកិច្ចល្អ និងសុចរិតធម៌នៅក្នុងអង្គការសង្គមស៊ីវិលនិងនៅក្នុងសង្គមជាតិយើងទាំងមូលនេះ ជាទស្សនវិស័យទៅអនាគត យើងគួរបន្តការខិតខំប្រឹងប្រែងជំនះឱ្យបាននូវបញ្ហាប្រឈមមុខមួយចំនួនដូចខាងក្រោមនេះ ៖

១_ សូមខិតខំបន្តការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីកាត់បន្ថយឱ្យបាននូវស្មារតី ពឹងផ្អែកនិយម ហើយត្រូវបំពាក់ឱ្យខ្លួនយើងវិញនូវស្មារតីឧបត្ថម្ភខ្លួនដោយខ្លួនឯង។

ទស្សនាទាន "ខ្លួនទីពឹងខ្លួន" គឺជាគោលទស្សនៈដ៏ល្អដែលគួរប្រកាន់យកដើម្បីត្រៀមលក្ខណៈឧបត្ថម្ភខ្លួន ដោយខ្លួនឯងក្រោយពេលដែលជំនួយឧបត្ថម្ភទាំងឡាយ ត្រូវបានបញ្ចប់ទៅ។

២_ សូមខិតខំបន្តការពង្រឹងនូវទស្សនៈ និងគោលជំហរអព្យាក្រឹតផតលំអៀង ក្នុងការកសាង និងអភិវឌ្ឍន៍អង្គការសង្គមស៊ីវិលកម្ពុជា ឱ្យក្លាយទៅជាដៃគូដ៏ស្មោះត្រង់ដ៏សច្ចយុត្តិធម៌ជាមួយសង្គមស៊ីវិលនិងសង្គមស៊ីវិលជាមួយរដ្ឋាភិបាលក៏ដូចជា ជាមួយអាជ្ញាធរមូលដ្ឋាន និងម្ចាស់ឧបត្ថម្ភថវិកាសំដៅធានាឱ្យបានភាពស្ថិតស្ថេរជាប់លាប់ទៅអនាគត។

<u>សូមចាំថា</u>: អង្គការសង្គមស៊ីវិល ពុំមែនជាសង្គម នយោបាយទេ។ សង្គមស៊ីវិលគឺជាសង្គមរបស់ប្រជាពលរដ្ឋ។ រាល់ការធ្វើសកម្មភាពហួសព្រំដែននៃតួនាទី និងបេសកកម្មនេះ គឺជាការខុសឆ្គង។

៣_ នៅលើលោកនេះ គ្មានអ្វីប្រសើរជាង សេចក្តីស្មោះត្រង់ទេ។ បើមានសេចក្តីស្មោះត្រង់គឺមានអ្វីៗ ទាំងអស់។ បើបាត់ស្មោះ

ត្រង់អ្វីៗក៏បាត់ដែរ។ សេចក្ដីស្មោះត្រង់គឺជាមាតានៃសាមគ្គីភាព ឯកភាព ភាពជាដៃគូល្អ សហប្រតិបត្តិការ និងភាពសុខដុមរមនា។

ដូច្នេះ សូមខិតខំបន្តការពង្រឹង "សេចក្ដីស្មោះត្រង់" ដើម្បីបង្កើតឱ្យមានស្មារតីទាំងឡាយដូចពោលខាងលើ។

៤_ អភិបាលកិច្ចល្អ និងសុចរិតធម៌គឺជាទស្សនាទានដ៏មានថាមពល និងប្រសិទ្ធភាពធំពីរ ដែលនាំឱ្យមានវឌ្ឍនភាព។ ការដឹកនាំ និងគ្រប់គ្រងដែលគ្មានតម្លាភាព គ្មានគណនេយ្យភាព គ្មានសហប្រតិបត្តិការ និងការទទួលខុសត្រូវ គឺជាសត្រូវស្លាប់រស់របស់វឌ្ឍនភាព។ ភាពជាគំរូរបស់អង្គការសង្គមស៊ីវិលគ្រប់ជាន់ថ្នាក់ ក្នុងការលើកស្ទួយភាពស្អាតស្អំបរិសុទ្ធ ក្នុងការគ្រប់គ្រងប្រភពធនធានរបស់ខ្លួន គឺជាឧទាហរណ៍ ល្អប្រពៃសំរាប់ "ដើរមុខ_ធ្វើមុន" ឱ្យសង្គមស៊ីវិលទាំងមូល ក្នុងការលើកកំពស់សារៈសំខាន់នៃអភិបាលកិច្ចល្អ និងសុចរិតធម៌។ បើគ្មានគំរូល្អក្នុងបញ្ហានេះទេ នោះ"ចំណេះដឹង" ទាំងឡាយនឹងក្លាយជា "ចំណេះចាំ" គ្មានបានរកឃើញនូវភាពជាក់ស្ដែងអ្វីឡើយ។

៥_ សមត្ថភាពយល់ដឹងនិងគុណភាពសីលធម៌ គឺជាលក្ខណៈសម្បត្តិមិនអាចខ្វះបាន ដើម្បីជួយឱ្យសង្គមស៊ីវិលពង្រឹងខ្លួនឱ្យទៅជាភាពដៃគូល្អរបស់ស្ថាប័នរដ្ឋរបស់បណ្ដាផ្នែកឯកជន និងម្ចាស់

អំណោយ។ លក្ខណៈសម្បត្តិទាំងនេះ គឺជាចំណុចវិជ្ជមានក្នុងការអូសទាញជំនឿទុកចិត្ត សាមគ្គីភាពនិងសេចក្ដីយោគយល់។ វឌ្ឍនភាពរបស់ស៊ីវិល ពុំអាចកាត់ផ្ដាច់បានពីសមត្ថភាពយល់ដឹង និងគុណភាពសីលធម៌នេះទ្បើយ។

សូមខិតខំបន្តការប្រឹងប្រែងពង្រឹងសមត្ថភាព គុណភាពសីលធម៌និងធនធានមនុស្សល្អឱ្យបានច្រើនថែមទៀត ដើម្បីជួយលើកស្ទួយអភិបាលកិច្ចល្អនិងសុចរិតធម៌នៅក្នុងមគ្គុទ្ទេសភាពនិងការទទួលខុសត្រូវរបស់យើង។

៦- សូមខិតខំធ្វើការអប់រំផ្សព្វផ្សាយចំណេះដឹង និងបទពិសោធន៍ល្អអំពីការកសាងអភិបាលកិច្ចល្អឱ្យបានទូលំទូលាយនៅក្នុងស្ថាប័នសង្គមស៊ីវិលក៏ដូចជាស្ថាប័នរដ្ឋ ជាទូទៅដើម្បីជួយទប់ស្កាត់ភាពឱនថយក្នុងការគ្រប់គ្រង។

៧- ក៏ប៉ុន្ដែ អ្វីដែលសំខាន់ជាងនោះ គឺការអប់រំខ្លួនឱ្យមានចំណេះដឹងប្រតិបត្តិមុនអ្នកដទៃ។ ការស្គាល់ចំណុចខ្សោយរបស់ខ្លួន ហើយជំនះចំណុចខ្សោយនោះដោយខ្លួនឯង គឺជាប្រភពនៃការរីកចំរើនគ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ។

សូមអង្គការសង្គមស៊ីវិលកម្ពុជាទាំងអស់ ក្រោកឈរដោយស្រុះគ្នាឡើងដើម្បីលើកស្ទួយអភិបាលកិច្ចល្អ និងសុចរិតធម៌នៅក្នុងសង្គមជាតិយើង។

ខ្ញុំសូមបញ្ចប់ការមានមតិរបស់ខ្ញុំតែប៉ុណ្ណេះ។ ជាសារថ្មីម្តងទៀត និងខ្ញុំសូមថ្លែង អំណរគុណចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព និងមូលនិធិ ហេនរិចបូល ដែលបានខិតខំប្រឹងប្រែងបង្កើតឱ្យបាន មានការសិក្សាស្រាវជ្រាវអំពីអភិបាលកិច្ចល្អ និងសង្គមស៊ីវិលកម្ពុជា រហូតដល់សំរេចបាន ការបើកសន្និសីទថ្នាក់ជាតិដ៏ទូលំទូលាយ ក្នុងរយៈពេលពីរថ្ងៃនេះ។

សង្ឃឹមថា អង្គការសីទជាតិ ស្តីអំពី "តួនាទីនៃសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា" នឹងសំរេចជោគជ័យល្អប្រសើរ។

សូមជូនពរគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ គណៈវាគ្មិននិងសមាជិក សមាជិកាទាំងអស់សូមឱ្យបានប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺអាយុវណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ!

## ៧.៣ សុន្ទរកថា ស្ដីអំពី "អភិបាលកិច្ចល្អ និងសង្គមស៊ីវិលនៅកម្ពុជា និងសេចក្ដីសង្ខេបលទ្ធផល នៃការស្រាវជ្រាវអំពីសង្គមស៊ីវិលនៅកម្ពុជា" ថ្លែងដោយ លោក ឃៀវ ព្រីង ដោយមានសហប្រតិបត្តិការពី លោក សេង សុទីរះ អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

### I- សេចក្ដីផ្ដើម :

អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា ជាលទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវ ដោយផ្អែកលើមូលដ្ឋានទិន្នន័យ នៃបណ្ដាឯកសារមួយចំនួនដែលមានទាក់ទិននិងប្រធានបទ និងប្រមូលផ្ដុំទិន្នន័យតាមរយៈការប្រើប្រាស់បញ្ជីសំនួរបិទ និងសំនួរបើកចំពោះបណ្ដាប្រធានអង្គការក្នុងស្រុកចំនួន ១០៥ អង្គការ ដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ។

ការប្រមូលទិន្នន័យ បានចាប់ផ្ដើមឡើង ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០០ និងបានបញ្ចប់ជាស្ថាពរនៅ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០០។ ចំពោះលទ្ធផល ដែលបង្ហាញនៅទីនេះ ពិតជាមិនគ្រប់គ្រាន់និងមិនអាចឆ្លើយតបបានគ្រប់ជ្រុងជ្រោយឡើយ តែទោះយ៉ាងណាក៏ដោយយើងគិតថា នេះជាស្នាដៃខិតខំរបស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព ក្នុងការប្រមូលផ្ដុំនូវគំនិតយោបល់និងទស្សនៈ

រួមពីបណ្តាប្រធានអង្គការទាំង១០៥ ទុកជាទុន ដើម្បីឱ្យអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ រដ្ឋាភិបាល និងម្ចាស់ជំនួយក្នុងការពិចារណាស្វែងរកនូវយុទ្ធសាស្រ្តរួម ក្នុងការជំរុញការអនុវត្តន៏ការងារប្រកបដោយអភិបាលកិច្ចល្អ ដើម្បីជាមូលដ្ឋានក្នុងការអភិវឌ្ឍន៏ប្រទេស។

## II- និយមន័យ :

### ១_ អភិបាលកិច្ចល្អជាអ្វី?

អភិបាលកិច្ចល្អ គឺជាការគ្រប់គ្រងមួយដោយផ្អែកលើច្បាប់របស់ប្រទេស ហើយរាល់សកម្មភាពទាំងឡាយណា ដែលខ្លួនបានបំពេញត្រូវស្តែងចេញជាសាធារណៈ ដោយមានការចូលរួមមានតម្លាភាពមានការទទួលខុសត្រូវ ហើយទន្ទឹមនឹងនោះមិនបានធ្វើឱ្យមានបញ្ហាអ្វីកើតឡើង ចំពោះសង្គមមនុស្សដោយថែមទាំងធ្វើឱ្យសមាជិកនៅក្នុងសង្គមម្នាក់ៗ មានការពេញចិត្តនឹងធ្វើតាមគោរពតាមក្នុងទិសដៅមួយ គឺមានសមធម៌ និងការអភិវឌ្ឍន៏នៅក្នុងសង្គម។

### ២_ លក្ខណៈវិនិច្ឆ័យមួយចំនួនរបស់អភិបាលកិច្ចល្អ :

- ការទទួលខុសត្រូវនូវរាល់ទង្វើរបស់ខ្លួន (Accountibility)
- តម្លាភាព (Transperancy ) ពោលគឺរាល់ពត៌មាននៃការសំរេចចិត្ត លើវិស័យសាធារណៈ ដូចជាគោលនយោបាយសកម្មភាព និងការអនុវត្តន៏ ត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់

សាធារណជនបានដឹងឮដោយទទួលបានពត៌មានគ្រប់គ្រាន់អាចជឿជាក់បាននិងទាន់ពេលវេលា។

- ការប៉ាន់ប្រមាណបាន (Predictablility) នយោបាយ ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ត្រូវមានលក្ខណៈច្បាស់លាស់ និងមានលក្ខណៈ ជាទូទៅមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍។
- ការចូលរួម (Participation) សាធារណជនត្រូវមានសិទ្ធិចូលរួមរាល់ការពិគ្រោះយោបល់ ចំពោះការអនុវត្តន៍ការងាររបស់រាជរដ្ឋាភិបាល ដែលមានឥទ្ធិពលលើខ្លួន។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចូលរួម ក្នុងការអភិវឌ្ឍន៍ ការអនុវត្តន៍គោលនយោបាយនិងកម្មវិធីផ្សេងៗ ដើម្បីធានាឱ្យមានភាពម្ចាស់ការ និងការទទួលខុស។
- គោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ (Respect for Human Rights and Democracy ) គោរពច្បាប់
- មានសមត្ថភាព និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ គ្រប់គ្រងធនធាន។
- ធ្វើឱ្យកិច្ចការមានប្រក្រតីភាព ជាជាងការប្រើអំណាចក្នុងការត្រួតត្រា។

៣_ សង្គមស៊ីវិលជាអ្វី?

- សង្គមស៊ីវិល គឺជារង្វង់មួយដែលស្ថិតនៅចន្លោះ ផ្នែកឯកជន បុគ្គលនិងរដ្ឋាភិបាល។ សង្គមស៊ីវិលឱបក្រសោប និងប្រមូលផ្តុំនូវសមាគមសហជីពអង្គការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ក្រុមហ៊ុន ក្លិបគ្រប់ប្រភេទ។

៤_ លក្ខណៈវិនិច្ឆ័យសំខាន់ៗនៃសង្គមស៊ីវិល :

- ការបង្កើតឡើងដោយឆន្ទៈស្ម័គ្រចិត្តមានទិសដៅរួមគឺការចូលរួមរៀបចំកសាង និងអភិវឌ្ឍន៍ប្រទេស។
- មានភាពឯករាជ្យអព្យាក្រឹត មិនស្ថិតនៅក្រោមឥទ្ធិពលគៀបសង្កត់ពីសង្គមនយោបាយ ឬផ្នែកពាណិជ្ជកម្មណាមួយឡើយ។ បំរើសេវាកម្ម ដល់សាធារណៈជនមិនយកកំម្រៃ។
- ស្ថិតនៅក្រៅពីកំលាំងប្រដាប់អាវុធ។
- រាល់កិច្ចការធ្វើឡើងដោយផ្អែកលើគោលការណ៍អភិបាលកិច្ចល្អ
- មានការទទួលខុសត្រូវ មានតម្លាភាព មាននីត្យានុកូលភាព គោរពសិទ្ធិមនុស្សលទ្ធិប្រជាធិបតេយ្យ និងការចូលរួមជាមូលដ្ឋាន។
- រាល់សកម្មភាពមិនមានឆន្ទៈដណ្តើមអំណាចណាមួយ ក្នុងរាជរដ្ឋាភិបាល។

- រាល់ដំណោះស្រាយធ្វើឡើងដោយសន្តិវិធី ក្នុងលក្ខណៈសហប្រតិបត្តិការសម្របសម្រួលផ្សះផ្សារ និងការចរចាធ្វើជាមូលដ្ឋាន។

## III. ការកកើត និងការវិវត្តន៍នៃសង្គមស៊ីវិលនៅកម្ពុជា :

ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ គេសង្កេតឃើញបរិបទសកលលោក មានការប្រែប្រួលនឹងផ្លាស់ប្តូរលើកចំណុចមួយចំនួនគួរឱ្យកត់សំគាល់។ ការរីកសាយភាយនូវឥទ្ធិពល នៃសកលភាវូបនីយកម្ម (Globalization) លើផ្នែកសេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ សន្តិសុខនិងបច្ចេកវិជ្ជា ទំនើបៗត្រូវបានផ្សព្វផ្សាយ ហើយស្របពេលជាមួយគ្នានេះ ពន្លកសង្គមស៊ីវិលត្រូវបានរីកដុះដាលជាបន្តបន្ទាប់នៅគ្រប់បណ្តាប្រទេស ពោលគឺមិនថាប្រទេសអភិវឌ្ឍន៍ (Developed Nations) ប្រទេសកំពុងអភិវឌ្ឍន៍ (Developing Nations)និងប្រទេសតតិយលោក (Third World) បានកំពុងចាប់អារម្មណ៍លើបញ្ហាសំខាន់ៗដូចជា សន្តិសុខតំបន់ វប្បធម៌សន្តិភាព (Culture of peace) សមាជិកអាស៊ាន (Asean membership) តុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court) អង្គការ ពាណិជ្ជកម្មពិភពលោក (World trade Organization) អភិបាលកិច្ចល្អ (Good governance) និងការអភិវឌ្ឍន៍សង្គមជាតិ។ សារៈប្រយោជន៍ នៃបញ្ហាទាំងនេះបានក្លាយទៅជាទិសដៅ នៃសកម្មភាពរបស់អង្គការសង្គមស៊ីវិលទូទាំងពិភពលោក។ ហើយដោយឡែក ចំពោះអង្គការសង្គមស៊ីវិលនៅកម្ពុជា

បច្ចុប្បន្នបានកំពុងក្លាយទៅជាយន្តការមួយដ៏សំខាន់ និងចាំបាច់ក្នុងការចូលរួមពង្រឹងនូវអភិបាលកិច្ច និងការវិវឌ្ឍន៍សង្គមដែលជាគន្លឹះដ៏សំខាន់ក្នុងការដោះស្រាយនូវវិបត្តិសង្គម ដូចជាបទរំលោភ អំពើពុករលួយ អយុត្តិធម៌សង្គម វប្បធម៌ហិង្សា ការបាត់បង់ជំនឿ និងភាពក្រីក្រជាដើម។

សង្គមស៊ីវិលកម្ពុជា បើផ្អែកទៅលើប្រវត្តិសាស្ត្ររបស់ខ្លួននិងខ្លឹមសាររបស់សង្គមស៊ីវិល ដូចដែលបានកំណត់ន័យពីខាងដើម គេគិតថាសង្គមស៊ីវិលខ្មែរ បានចាប់កំណើតរបស់ខ្លួនតាំងពីការកកើតនូវវត្តអារាមក្នុងគ្រឹះសករាជទី៣ ក៏ដូចជាសម័យក្រោយៗមកទៀត ដែលប្រទេសកម្ពុជា មានសមាគមគណៈកម្មការវត្ត និងអង្គការចាត់តាំងរបស់ប្រជាពលរដ្ឋ ដូចគ្នានឹងសង្គមស៊ីវិលក្នុងសម័យនេះដែរ តែគ្រាន់បញ្ញត្តិនៃការប្រើវាមានការវិវត្តន៍ ទៅតាមសម័យកាលរបស់សង្គមតែប៉ុណ្ណោះ។ ក្នុងទ្រង់ទ្រាយខ្លឹមសារ នៃអង្គការទាំងនោះសុទ្ធតែបង្កើតឡើង ដើម្បីការពារផលប្រយោជន៍រួម។ អង្គការសមាគមទាំងនោះ មានឈ្មោះជាសមាគមវត្តអារាម សមាគម សង្គហសង្គ្រោះ សមាគមមរណៈសង្គ្រោះ សមាគមបុគ្គលិកសិក្សា សមាគមប្រជាកសិករជាដើម ដែលពួកគេបង្កើតឡើង ដើម្បីការពារផលប្រយោជន៍របស់អ្នកភូមិ អ្នកស្រុក និងសហគមរបស់ពួកគេ។ ក្នុងកំឡុងសង្គ្រាមស៊ីវិលរាំរ៉ៃជិតបីទសវត្សរ៍ អង្គការសមាគមទាំងឡាយ ដែលមានសកម្មភាពស្រដៀងគ្នានឹងសង្គមស៊ីវិល បច្ចុប្បន្នហាក់ដូចជាពុំបានបើកទូលាយ ប៉ុន្តែផ្តើមចេញពីកិច្ចព្រម

ព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ឆ្នាំ១៩៩១ ប្រទេសកម្ពុជាត្រូវបានបញ្ចប់សង្គ្រាមស៊ីវិល ហើយទន្ទឹមនឹងនោះបញ្ញត្តិ សង្គមស៊ីវិលបានចាប់កំណើត និងមានឥទ្ធិពលរបស់ខ្លួនយ៉ាងខ្លាំងនៅកម្ពុជា ចាប់តាំងពីក្នុងអាណត្តិទី១ ឆ្នាំ១៩៩៣ នោះរហូតមកដល់បច្ចុប្បន្ន។

តាមតួលេខចំនួនអង្គការសង្គមស៊ីវិលខ្មែរ នៅក្នុងអាណត្តិទី១ របស់រាជរដ្ឋាភិបាលពីឆ្នាំ ១៩៩៣_១៩៩៨ ចំនួនអង្គការក្នុងស្រុកសរុបនៅឆ្នាំ១៩៩៤មាន៥០អង្គការ តែប៉ុណ្ណោះ ប៉ុន្តែក្នុងអាណត្តិទី២របស់រាជរដ្ឋាភិបាលពីឆ្នាំ១៩៩៨_២០០៣ ចំនួនអង្គការក្នុងស្រុកមានចំនួនរហូតដល់ទៅ៧៩៧អង្គការ (តាមប្រសាសន៍ ឯកឧត្តម សក់ សេដ្ឋា នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ ហើយក្នុងចំនួនអង្គការទាំងនេះ និង បានកំពុងធ្វើសកម្មភាពលើវិស័យជាច្រើន ដើម្បីជួយដល់សង្គមជាតិ។ ជារួមអង្គការសង្គមស៊ីវិល គឺផ្តើមចេញពីមូលដ្ឋានសំខាន់ៗនៃចរន្តសកលលោក សកលភាវូបនីយ កម្មលើវិស័យនយោបាយ សេដ្ឋកិច្ច បរិស្ថាននិងបច្ចេកវិជ្ជា ឆន្ទៈរបស់ព្រះមហាក្សត្រខ្មែរ ឆន្ទៈរបស់មគ្គុទ្ទេសភាពនាំឆន្ទៈរបស់ប្រជាជន។

វប្បធម៌សន្តិភាព សន្តិសុខតំបន់ ការទប់ស្កាត់ការរីកសាយភាយនូវអាវុធប្រល័យលោក ការរីកដុះដាលការឆ្លងជំងឺហ៊ីវអេដស៍ភាពទុរភិក្ស និងអភិបាលកិច្ចល្អ ត្រូវបានសកលលោកចាប់អារម្មណ៍។ តួយ៉ាងការស្វែងរកសន្តិភាពរបស់អង្គការសហប្រជាជាតិសមាគមអាស៊ានតុលាការ ព្រហ្មទណ្ឌអន្តរជាតិ កម្មវិធីផ្តល់ជំនួយជា ដើម។ យ៉ាងណា

មិញប្រទេសកម្ពុជា បានទទួលជំនួយជាច្រើនលានដុល្លារពីសហគមអន្តរជាតិ ក្នុងមួយឆ្នាំៗ ដើម្បីយកមករៀបចំអភិវឌ្ឍន៍ស្រុកទេស។ បច្ចុប្បន្នអភិបាលកិច្ច ជាប្រធានបទដ៏ពេញនិយមសំរាប់អង្គការសង្គមស៊ីវិលក្នុងការចូលរួមចំណែក បំពេញការងាររបស់ខ្លួន ក្នុងនាមជាដៃគូរបស់រដ្ឋាភិបាលដើម្បីដោះស្រាយវិបត្តិសង្គមខ្មែរ ក៏ដូចជាការចូលរួមអភិវឌ្ឍន៍សង្គមជាតិ។

## VI- សមិទ្ធិផលរបស់សង្គមស៊ីវិល :

ការទទួលស្គាល់របស់រដ្ឋាភិបាល ចំពោះអង្គការសង្គមស៊ីវិលធ្វើជាដៃគូដ៏សំខាន់ និងចាំបាច់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសដែលជាគន្លឹះសំខាន់ ក្នុងការបើកឱកាសដល់អង្គការសង្គមស៊ីវិលបានចូលរួមដើម្បីសម្រេចនូវសមិទ្ធិផលសំខាន់មួយចំនួន ដែលជាចំណែកក្នុងការជួយសំរួល នូវបន្ទុកដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាល ក៏ដូចជាការចូលរួមដោះស្រាយរួមជាមួយប្រជាពលរដ្ឋ និងសហគមន៍អន្តរជាតិ។ អង្គការសង្គមស៊ីវិល គឺជាយន្តការសម្របសម្រួលដោះស្រាយនិងការអភិវឌ្ឍន៍។ កន្លងមកនេះ តាមរយៈការសិក្សាស្រាវស្រាវរបស់ក្រុមស្រាវជ្រាវ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានបង្ហាញថាអង្គការសង្គមស៊ីវិល បានបំពេញការងារជាច្រើន ដែលជាសមិទ្ធិផលនិងជាសារៈប្រយោជន៍សំរាប់សង្គមកម្ពុជា នាពេលបច្ចុប្បន្ន ក៏ដូចជាទៅថ្ងៃអនាគតនៃកូនចៅខ្មែរ។ ដូច្នេះអ្វីៗ ដែលជាសមិទ្ធិផលរបស់សង្គមស៊ីវិលសម្រេចបានកន្លងមក ទោះបី មិនទាន់បានចេញជាដុំកុំភួន

នាពេលបច្ចុប្បន្នក៏ពិតមែន តែទន្ទឹមនឹងនេះ វាជាមូលដ្ឋានសំខាន់ដើម្បីជាយន្តការដ៏ប្រសើរទៅថ្ងៃអនាគត។

សមិទ្ធិផលនាំងនេះ ត្រូវបានប្រមូលផ្តុំលើ

**១. យុត្តិធម៌សង្គម :**

(១). **ពង្រីកការយល់ដឹងអំពីសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស**

តាមការអប់រំ ការបណ្តុះបណ្តាលបើកវគ្គសិក្សា ការបើកសិក្ខាសាលា សន្និសីទ វេទិកាពិភាក្សា ការសន្ទនា និងការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព ជាទស្សនាវដ្តី កាសែត វិទ្យុ ការបោះពុម្ពជាសៀវភៅ ព្រឹត្តិប័ត្រ និងប្រព័ន្ធ Internet ជាដើម។

(២). **ពង្រឹងការអនុវត្តច្បាប់ និងចូលរួមធ្វើច្បាប់ :**

ការធ្វើច្បាប់កាត់ទោសខ្មែរក្រហម ច្បាប់បោះឆ្នោត ច្បាប់ប្រឆាំង អំពើពុករលួយ ច្បាប់ភូមិបាលជាដើម។

(៣). **តួនាទីភេទ (Gender) ការតស៊ូមតិ** ការចូលរួមទាមទាររបស់ស្ត្រីឈរបោះឆ្នោតមេឃុំ ចៅសង្កាត់ និងការតវ៉ាពីបទរំលោភយកដីធ្លី ឡូនេសាទ និងបុព្វសិទ្ធិកម្មសិទ្ធិផ្សេងៗពីបណ្តាអ្នកមានអំណាចនិងអ្នកមានលុយកាក់។

(៤)- **ចូលរួមចំណែកផ្តល់គំនិតយោបល់ជូនរាជរដ្ឋាភិបាលតាមរយៈការ**ប្រមូលផ្តុំគំនិតយោបល់ និងទស្សនៈពីអង្គសិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិ និងវគ្គបណ្តុះបណ្តាលជាដើម ដោយធ្វើជារបាយការណ៍ជូនទៅថ្នាក់ដឹកនាំ ក្នុងជួររាជរដ្ឋាភិបាល ដើម្បីពិចារណាចំពោះអ្វីដែលជាលទ្ធផល បានមកពីការបំពេញការងាររបស់អង្គការនីមួយៗ។

**២- ការបណ្តុះបណ្តាលធនធានមនុស្ស :**

(១)- **ការផ្លាស់ប្តូរនូវទស្សនៈ** ការបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការបើកសិក្ខាសាលា សន្និសីទជាតិនិងអន្តរជាតិ និងការបញ្ជូនបុគ្គលិកឱ្យទៅបំពេញ ទស្សនកិច្ចសិក្សានៅបរទេស។ ការផ្លាស់ប្តូរចិត្តគំនិត ការបណ្តុះឆន្ទៈឱ្យសមាជិកសង្គមចូលរួមទទួលខុសត្រូវមានគំនិតទទួលស្គាល់ នូវតម្លៃនៃមនុស្សផងគ្នា ការប្រកបការងារដោយផ្តើមចេញពីសមត្ថភាព និងការគោរពច្បាប់ជាបណ្តើរៗ។

(២)- **យន្តការសំរបសំរួល និងការផ្តល់ឱកាស** : លើបញ្ហានេះសង្គមស៊ីវិលបានកំពុងចូលរួមយ៉ាងសកម្ម ដោយបានផ្តល់ឱកាសដល់សាធារណជន ដើម្បីចូលរួមបញ្ចេញមតិក្នុងការសួរដេញដោលជាមួយរាជរដ្ឋាភិបាល និងភាគីផ្សេងៗ ដែលពាក់ព័ន្ធតាមរយៈ

ការចូលរួមពិភាក្សានៅក្នុងសិក្ខាសាលាសន្និសីទជាតិនិងអន្តរជាតិជាដើម។

### ៣- ផ្នែកកិច្ចការអភិវឌ្ឍន៍

(១)- **ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច :** មានអង្គការមួយចំនួនបានចូលរួមកសាងផ្លូវ ស្ពាន ស្តារប្រឡាយដាក់ប្រព័ន្ធលូទឹកសំអុយ ជីកអណ្តូង តបណ្តាញទឹកស្អាត រៀបចំសហគមជួយជនទុគ៌តជាដើម។

(២)- **ការផ្តល់សេវាសាធារណៈ** (Public Service ) ដូចជាការថែទាំសុខភាព បរិស្ថាន ការអប់រំក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធ ការធ្វើផែនការគ្រួសារ ការផ្តល់ឥណទានខ្នាតតូច និងជួយលើផ្នែកប្រធាន ដូចជាមានទទួលរងគ្រោះទុរភិក្ស ភ្លើងឆេះផ្ទះសម្បែង ទឹកជំនន់ និងគ្រោះធម្មជាតិដទៃទៀតជាដើម។

### ៤- ទំនាក់ទំនងក្នុងតំបន់ និងក្រៅតំបន់

ក្នុងបញ្ហានេះគេសង្កេតឃើញថា សង្គមស៊ីវិលកម្ពុជា មិនត្រឹមតែពង្រីងនូវកិច្ចការរបស់ខ្លួន នៅក្នុងប្រទេសប៉ុណ្ណោះទេ បច្ចុប្បន្នសង្គមស៊ីវិលកម្ពុជា បានពង្រីងកិច្ចការជាមួយដៃគូក្នុងតំបន់ និងក្រៅតំបន់តាមរយៈកិច្ចការអង្គសន្និសីទ ទស្សនៈកិច្ចសិក្សា ការទៅដកពិសោធន៏ទោះជាផ្លូវការ និងក្រៅផ្លូវការក្តី ឬសមាជិកជាដៃគូ មកសិក្សាបណ្តុះ

បណ្តាល និងចូលរួមក្នុងអង្គសន្និសីទជាតិនិងអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងគ្នាទៅវិញទៅមក។

## V- ការប្រឈមមុខរបស់អង្គការសង្គមស៊ីវិល :

កន្លងមកដោយមានការចូលរួមគាំពារពីប្រជាជនរាជរដ្ឋាភិបាល និងការគាំពារពីសហគមន៍អន្តរជាតិ សង្គមស៊ីវិល បានកំពុងធ្វើដំណើរស្ថិតនៅលើផងផ្លូវមួយ។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវពិតមែនសង្គមស៊ីវិលសម្រេចបាននូវសមិទ្ធិផលមួយចំនួនគួរឱ្យកត់សំគាល់ ប៉ុន្តែទន្ទឹមនឹងទទួលបាននូវសមិទ្ធិផលនេះសង្គមស៊ីវិលបានជួបនឹងបញ្ហាដូចជាៈ មិនទាន់មានច្បាប់សង្គមស៊ីវិល ការសហប្រតិបត្តិការរបស់សង្គមស៊ីវិល និងសង្គមស៊ីវិល សង្គមស៊ីវិលនិងអជ្ញាធរ សង្គមស៊ីវិលនិងប្រជាពលរដ្ឋនៅមានកំរិតមិនទាន់បានចងជាចង្កោមទៅតាមផ្នែកនិមួយៗ របស់ខ្លួន មិនមានម្ចាស់ការលើថវិកា កង្វះខាតបច្ចេកទេស កង្វះធនធានមនុស្សស្មារតីពឹងផ្អែក និងតម្លៃមជ្ឈដ្ឋានខាងក្រៅជាងមជ្ឈដ្ឋានខាង ក្នុងរបស់ខ្លួនកង្វះបទពិសោធន៍របស់អ្នកដឹកនាំ អង្គការសង្គមស៊ីវិលមិនទាន់មានយុទ្ធសាស្ត្ររួមគ្នា មានគំនិតកាច់កុង ទស្សនៈចង្អៀតចង្អល់ស្រុតចុះនូវភាពស្មោះត្រង់លើគ្នា អង្គការសង្គមស៊ីវិលមួយចំនួនមិនទាន់យល់ពីតួនាទីរបស់ខ្លួនឱ្យបានច្បាស់លាស់ នាំឱ្យធ្លាក់ចូលក្នុងអន្ទាក់នយោបាយ ឬ ខ្លួនមានបំណងចូលធ្វើនយោបាយ ក៏មានការចូលរួមរបស់ប្រជាជន និងអាជ្ញាធរនៅលើផ្នែកឬកន្លែងខ្លះនៅមានកំរិតភាពចន្លោះប្រហោងក្នុងការអនុវត្តន៍ច្បាប់ និងការមានច្បាប់មិនគ្រប់គ្រាន់ឥទ្ធិពលអាក្រក់ពីអតីត

កាល ដូចជាអំពើហិង្សា អក្ខរជន ជនឱកាសនិយម ជនពិការមាន ការរើសអើង និងការលាបមុខដាក់គ្នារវាងរដ្ឋាភិបាល និងសង្គមស៊ីវិល សង្គមស៊ីវិលនិងសង្គមស៊ីវិលនិងផ្នែកឯកជនការយល់ច្រឡំ និងទស្សនៈ ខ្វែងគ្នារបស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលម្ចាស់ជំនួយដាក់ល័ក្ខខ័ណ្ឌ តឹងតែងនៅពេលផ្តល់មូលនិធិពិបាក ក្នុងការទំនាក់ទំនងជាមួយម្ចាស់ ជំនួយ ដោយឧបសគ្គខាងភាសារភាពមិនសូវស៊ីគ្នាខាងវប្បធម៌ និង ស្ថានការណ៍ជាក់ស្តែងរបស់សង្គមកម្ពុជា ខ្វះការថ្លឹងថ្លែងរបស់ម្ចាស់ ជំនួយពីការលំបាក ដែលសង្គមស៊ីវិលជួបប្រទះ កង្វះការផ្សព្វផ្សាយ ប្រព័ន្ធផ្សាយខ្វះលក្ខណៈអព្យាក្រឹតភាព។

VI- សេចក្តីសង្ឃឹមនៅថ្ងៃអនាគត :

ប្រជាជនមានការយល់ដឹង កាន់តែច្បាស់អំពីកិច្ចការរបស់សង្គម ស៊ីវិលការផ្តល់ឱកាសរបស់រាជរដ្ឋាភិបាលក្នុងនាមសង្គមស៊ីវិលជាដៃគូជា មួយមានការកើនឡើង នូវកិច្ចសហប្រតិបត្តិការពីមជ្ឈដ្ឋានជាតិអន្តរជាតិ និងម្ចាស់ជំនួយ។ សង្គមស៊ីវិលឆ្លងតាមបទពិសោធន៏ការងាររបស់ខ្លួន កាន់តែមានបទពិសោធន៏ សង្គមស៊ីវិលកាន់តែស្គាល់តួនាទីរបស់ខ្លួនកាន់ តែច្បាស់។

VII- អនុសាសន៍ :

១_ រដ្ឋាភិបាល :

- សំរួលឱ្យច្បាប់សង្គមស៊ីវិលឆាប់បានអនុម័ត និងប្រើប្រាស់តែ ច្បាប់ ត្រូវមានលក្ខណៈសមធម៌ទាំងសងខាង។

- រាល់សកម្មភាពស្តែងចេញ ត្រូវឈរលើច្បាប់របស់ប្រទេសជាធំ តាមរយៈចរចាដោយសន្តិវិធី ទោះជាសម្ងាត់និងជាចំហរជាវេទិកាសាធារណៈ។
- មិនត្រូវគិតថាសង្គមស៊ីវិលជាគណបក្សប្រឆាំង ទោះសកម្មភាពមួយចំនួនមានលក្ខណៈស្របទៅនឹងគោលការណ៍របស់គណបក្សប្រឆាំងក៏ដោយ។
- ត្រូវពិចារណារាល់សំណូមពរ ដែលបានលើកឡើងដោយសង្គមស៊ីវិល។
- ត្រូវមានទស្សនៈទូលាយ និងមានយុទ្ធសាស្ត្រលើកទឹកចិត្តដល់សង្គមស៊ីវិល។
- រដ្ឋាភិបាលត្រូវមានយន្តការនយោបាយឱ្យបានច្បាស់លាស់។
- អនុវត្តច្បាប់របស់ប្រទេសឱ្យមានប្រសិទ្ធិភាព។
- លើកកំពស់លើវិស័យអប់រំ និងកំរិតជីវភាពរស់នៅរបស់ប្រជាជនឱ្យបានប្រសើរ។
- ត្រូវកំណត់ឱ្យអង្គការ ធ្វើសេចក្តីរាយការណ៍ពាក់ខែម្តងថា តើអង្គការរបស់ខ្លួនធ្វើសកម្មភាពឬអត់ និងអាស័យដ្ឋានរបស់ខ្លួន។
- ត្រូវមានទំនុកចិត្តលើគ្នាទៅវិញទៅមករដ្ឋាភិបាល និងសង្គមស៊ីវិលមន្ត្រីរដ្ឋាភិបាលមិនត្រូវបង្កើតអង្គការ ដើម្បីបំរើប្រយោជន៍របស់បក្សឡើយ។

២_ សង្គមស៊ីវិល :

- ត្រូវធ្វើសកម្មភាពអព្យាក្រឹត។
- ត្រូវប្រកាន់សីលធម៌ដើម្បីជាគំរូ តាមរយៈអភិបាលកិច្ចល្អ
- ត្រូវស្គាល់ពីតួនាទីរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាព ដើម្បីបំរើគណបក្សនយោបាយ។
- ត្រូវមានយុទ្ធសាស្ត្ររួមតាមរយៈសហប្រតិបត្តិការ។
- ត្រូវចេះចែកធនធាន និងបទពិសោធន៏ដល់អង្គការតូចតាច
- ត្រូវសហការចងក្រង និងគ្រប់គ្រងជាក្រុមៗចំពោះការងារដែលមានលក្ខណៈដូចគ្នា។
- ត្រូវមានទស្សនៈយូរអង្វែង ច្បាស់លាស់។
- ត្រូវមានទំនុកចិត្តលើរដ្ឋាភិបាល។
- ត្រូវសំដែងការស្មោះត្រង់លើគ្នាទៅវិញទៅមក។
- ត្រូវផ្សព្វផ្សាយអំពីការងាររបស់ខ្លួនឱ្យបានច្បាស់។
- ត្រូវធ្វើការរាយការណ៍ អំពីសកម្មភាពការងាររបស់ខ្លួន រៀងរាល់៣ខែម្តងទៅក្រសួងមហាផ្ទៃ ដើម្បីឱ្យងាយស្រួលក្នុងការគ្រប់គ្រងចំនួនអង្គការនៅមានសកម្មភាពនៅកន្លែងណា។

៣_ ម្ចាស់ជំនួយ :

- មិនត្រូវប្រើល័ក្ខខ័ណ្ឌតឹងតែងចំពោះអង្គការសង្គមស៊ីវិល។

- ត្រូវជំរុញបន្ថែមលើកការបណ្ដុះបណ្ដាលជំនាញ ចែករំលែកបទពិសោធន៍។
- ត្រូវបន្តមូលនិធិដល់ក្រុមអង្គការដែលនៅទន់ខ្សោយ ជាពិសេសលើក្រុមយុវជន។
- ត្រូវមានការថ្លឹងថ្លែង លើកិច្ចការលំបាករបស់សង្គមស៊ីវិល និងសភាពការណ៍ជាក់ស្ដែងរបស់កម្ពុជា៕

## ៧.៤_សុន្ទរកថាថ្លែងដោយៈ លោកស្រី ហោ ផល្លី នាយិកាអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ស្ដីអំពី "ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពសង្គមស៊ីវិលកម្ពុជា សមិទ្ធិផល និងការប្រឈមមុខ"

នៅក្នុងសន្និសីទជាតិ ស្ដីអំពី ការកសាងសង្គមស៊ីវិល សំរាប់អភិបាលកិច្ចល្អនៅកម្ពុជា : សមិទ្ធិផល ការប្រឈមមុខនឹងក្ដីសង្ឃឹម ដែលមានសារៈសំខាន់នេះ ខ្ញុំមានសេចក្ដីរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកនាយកប្រតិបត្តិការ និងសន្តិភាព ដែលបានផ្ដល់កិត្តិយស និងឱកាសដល់ខ្ញុំជាវាគ្មិនមួយរូប ក្នុងចំណោមវាគ្មិនដ៏ទៃទៀត ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទជាតិនេះ។

ព្រះរាជាណាចក្រកម្ពុជា ក្នុងពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកាសាងសមត្ថភាព សង្គមស៊ីវិលជាកត្តាចាំបាច់ និងសំខាន់បំផុត ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសជាតិយើង។

ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមចូលរួមក្នុងការផ្លាស់ប្ដូរយោបល់ ព្រមទាំងចែករំលែកនូវបទពិសោធន៍ផ្ទាល់របស់ខ្ញុំ ក្នុងប្រធានបទខាងលើ។

### ❋ ការអភិវឌ្ឍន៍ធនធានមនុស្ស

ជាជំហានដំបូងបង្អស់ដែលត្រូវចាប់ផ្តើមអនុវត្ត ដើម្បីឈានទៅកាន់ការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។ ធនធានមនុស្សជាមូលដ្ឋានគ្រឹះដ៏រឹងមាំ ដែលរាជរដ្ឋាភិបាលបានផ្តល់អាទិភាព បើកទូលាយក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការជួយឧបត្ថម្ភ គាំទ្រ ពីរាជរដ្ឋាភិបាលផ្ទាល់ អង្គការសហប្រជាជាតិ អង្គការសុខភាពពិភពលោក អង្គការសិទ្ធិមនុស្ស អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ ការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈការសិក្សារយៈពេលវែង រយៈពេលខ្លី តាំងពីថ្នាក់មូលដ្ឋាន ភូមិ_ឃុំ_ស្រុក_ខេត្ត_ក្រុង។

បុគ្គលិកទូទៅ ទាំងពីរភេទនៃប្រទេសកម្ពុជាកំពុងតែខិតខំរៀនសូត្រ តាមរយៈអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងរាជរដ្ឋាភិបាល ដើម្បីប្រែក្លាយខ្លួនគេ ទៅជាអ្នកបណ្តុះបណ្តាលអប់រំបន្តឱ្យបានដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។

ការបណ្តុះបណ្តាល ប្រភពធនធានមនុស្សបានកំពុងតែប្រព្រឹត្ត និងបន្តទៅមុខជាលំដាប់លើគ្រប់វិស័យទាំងអស់ ដូចជា : សុខាភិបាល អប់រំ ឧស្សាហកម្ម សេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ អភិវឌ្ឍន៍ជនបទ បរិស្ថាន ព្រមទាំងវិស័យកសិកម្ម។

ខ្ញុំសូមអនុញ្ញាតលើកជា ឧទាហរណ៍ នូវបញ្ហាអំពើហិង្សានៅក្នុងគ្រួសារ ដែលជាកត្តារាំងស្ទះ និងជាផលប៉ះពាល់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស ព្រមទាំងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិដែរ។

អាស្រ័យហេតុនេះហើយ ទើបអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ បានចូលរួមសហការរួមជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បើកវគ្គបណ្ដុះបណ្ដាលធនធានមនុស្ស ក្នុងការអប់រំអំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់របស់វា។ ទន្ទឹមនឹងនេះអង្គការ NGOs មួយចំនួនទៀត ក៏កំពុងតែធ្វើការបញ្ចូលការអប់រំអំពីអំពើហិង្សាក្នុងគ្រួសារ ក្នុងកម្មវិធីរបស់គេដោយគេយល់ថា កម្មវិធីនេះមានសារៈសំខាន់បំផុតនៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។

### ❋ ការកសាងសមត្ថភាពសង្គមស៊ីវិលនៅកម្ពុជា : សមិទ្ធិផល

ចាប់តាំងពីឆ្នាំ១៩៩៤ មកទល់ពេលបច្ចុប្បន្ននេះ យើងឃើញហើយថា ប្រជាជនកម្ពុជាក្លាយខ្លួន ទៅជាប្រភពធនធានមនុស្សមួយសំខាន់បំផុត។ បើយើងធ្វើការក្រឡេកមើលលើគ្រប់ស្ថាប័នជាតិ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រជាជនខ្មែរទាំងពីរភេទបានពង្រឹងសមត្ថភាពរបស់ខ្លួនបន្តិចម្ដងៗ រហូតដល់ពេលនេះយើងឃើញថា គ្រប់ស្ថាប័ននានា ប្រជាជនកម្ពុជាបានក្លាយទៅជាអ្នកដឹកនាំ

ចាត់ចែង អ្នកបច្ចេកទេស ដែលមានសមត្ថភាពអាចកសាងសង្គមស៊ីវិលដោយខ្លួនឯង។

ជាមួយនឹងការផ្តល់ឱកាសពីសំណាក់រាជរដ្ឋាភិបាល ក្នុងការការឧបត្ថម្ភ ការបណ្តុះបណ្តាលធនធានមនុស្សនេះ យើងសង្កេតឃើញថា អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនបានផ្ទេរតំណែងតួនាទីដឹកនាំអង្គការឱ្យទៅប្រជាជនកម្ពុជាវិញ។

ដោយមានការយល់ដឹងពី យេនឌ័រ និងការលើកតំកើងដល់សិទ្ធិស្ត្រី ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ យើងសង្កេតឃើញថា ស្ត្រីខ្មែរមួយចំនួនបានក្លាយខ្លួនទៅជាអ្នកដឹកនាំ ហើយបានទទួលនូវតួនាទីសំខាន់ៗ ក្នុងស្ថាប័នជាតិ និងអង្គការក្រៅរដ្ឋាភិបាលស្ទើរតែគ្រប់វិស័យទាំងអស់។

❈ សមិទ្ធិផលទាំងនោះបានមកដោយសារ :

- រាជរដ្ឋាភិបាល មានគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស
- ការជួយឧបត្ថម្ភពីសំណាក់អង្គការសហប្រជាជាតិ អង្គការសុខភាពពិភពលោក អង្គការសិទ្ធិមនុស្សអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។
- ការឧបត្ថម្ភពីបណ្តាប្រទេសនានាដែលជាម្ចាស់អំណោយ។
- ការខិតខំប្រឹងប្រែងរៀនសូត្រ ពីសំណាក់ប្រជាពលរដ្ឋខ្មែរទាំងពីរប្រភេទ។

- ជំហរ និងគំនិតស្នេហាជាតិ ចូលរួមដោយឆន្ទៈមោះមុតយក នូវចំណេះដឹងដែលខ្លួនបានរៀន ដើម្បីរួមចំណែកកសាងប្រទេសជាតិ។

❋ ការប្រឈមមុខនឹងបញ្ហាបណ្តុះបណ្តាលធនធានមនុស្ស :

ទន្ទឹមនឹងការបណ្តុះបណ្តាលនូវប្រភពធនធានមនុស្ស សំរាប់ការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិយើងក៏បានជួបនូវបញ្ហាមួយចំនួនដូចជា:

- ការបញ្ជូនបុគ្គលិកទៅបណ្តុះបណ្តាលខុសមុខជំនាញ។
- កង្វះខាតក្នុងការប្រាស្រ័យទាក់ទងពីសំណាក់ថ្នាក់ដឹកនាំ។
- កង្វះខាតការលើកទឹកចិត្តដល់បុគ្គលិកដែលបណ្តុះបណ្តាលរួច។
- កង្វះខាតប្រភពថវិកាដែលជាកត្តារាំងស្ទះពុំអាចអនុវត្តការងារបាន។
- បញ្ហាជីវភាពរស់នៅមានកំរិតទាប (ប្រាក់បៀវត្សរ៍) អាចបណ្តាលឱ្យប្រភពធនធានមនុស្ស ដែលបានបណ្តុះបណ្តាលរួច ព្យាយាមទៅរកការងារថ្មី ដែលអាចផ្តល់នូវប្រាក់បៀវត្សរ៍ខ្ពស់ជាង។
- បុគ្គលិកដែលបានបណ្តុះបណ្តាលរួច មិនសូវមានជំនាញក្នុងការផ្តល់ការអប់រំបន្ត។
- បុគ្គលិកដែលត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលនូវប្រទេសជឿនលឿនគេចវេសមិនត្រឡប់មកបំរើមាតុភូមិវិញ៕

## ៧.៥_សុន្ទរកថាថ្លែងដោយ លោកបណ្ឌិត ហ៊ាន សាហ៊ីប នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អ្នកស្រាវជ្រាវអមវិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការ និងសន្តិភាព ស្តីអំពី "ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពសង្គមស៊ីវិលកម្ពុជា : សមិទ្ធិផល និងការប្រឈមមុខ"

### ១_សេចក្តីផ្តើម :

ជាងពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានឆ្លងកាត់នូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសំខាន់ៗជាច្រើន ដែលបង្ហាញឡើងពីការតស៊ូរបស់ប្រជាជនកម្ពុជា ក្នុងការការពារ កសាងប្រទេស និងការកសាងជីវភាពរស់នៅរបស់ខ្លួនឱ្យបានរីកចំរើន។ ទន្ទឹមនឹងនោះ ព្រឹត្តិការណ៍ ដែលកើតមានឡើងដោយសារវិបត្តិនយោបាយ និងលទ្ធផលនៃការអូសបន្លាយសង្គ្រាមស៊ីវិល បានដាក់ទណ្ឌកម្មប្រទេសកម្ពុជានូវមហន្តរាយយ៉ាងធ្ងន់ធ្ងរលើគ្រប់វិស័យក្នុងសង្គមជាតិ។ ក្នុងនោះពុំមានវិស័យណារងផលវិបាកអវិជ្ជមាន យូរអង្វែងជាងវិស័យអប់រំឡើយ។ ប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស រងការខូចខាត និងបំផ្លាញស្ទើរដល់កំរិតមិនអាចស្តារបាន។ ជាមួយគ្នានោះ ឧត្តមសិក្សា គឺជាវិស័យដែលខូចខាតធ្ងន់បំផុត ជាពិសេសក្នុងអំឡុងឆ្នាំ១៩៧៥_១៩៧៩។ នៅក្នុងឆ្នាំ១៩៧៩ គ្រូបង្រៀន សាស្ត្រាចារ្យ និស្សិតកម្ពុជាពី៧៥% ទៅ ៨០% បានស្លាប់ឬភៀសខ្លួនចេញទៅក្រៅប្រទេស។ ធនធានមនុស្ស

ដែលមានជំនាញ និងឯកទេសផ្សេងៗ សេសសល់ប្រមាណ៣០០រូប។ សៀវភៅ ឧបករណ៍ និងសម្ភារៈសិក្សា ត្រូវបានបំផ្លាញស្ទើរទាំងស្រុង[១]។

កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស និងការរៀបចំឡើងនូវរាជរដ្ឋាភិបាលក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៣ និងការបោះឆ្នោតនៅឆ្នាំ១៩៩៨កន្លងមកនេះ បានផ្តល់ឱ្យប្រជាជនកម្ពុជានូវជីវិតថ្មី ជាមួយនឹងក្តីសង្ឃឹម និងវឌ្ឍនភាព។ ក្នុងអាណត្តិថ្មីនេះ រដ្ឋាភិបាលកម្ពុជា បានខិតខំអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលត្រូវខិតខំសំរេចឱ្យបាននូវការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាព និង រក្សាបានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការប្រឹងប្រែងឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនូវលក្ខណៈសម្បត្តិអនុគ្រោះខាងក្នុង និងកត្តាអំណោយផលពីខាងក្រៅ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព[២]។ ក្នុងនោះការអភិវឌ្ឍន៍ធនធានមនុស្សគឺជាកត្តាសំខាន់បំផុតសំរាប់ចក្ខុវិស័យយូរអង្វែងនៃការអភិវឌ្ឍន៍។

ប្រធានបទស្តីពី "ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពសង្គមស៊ីវិលកម្ពុជា : សមិទ្ធិផលនិងការប្រឈមមុខ" ដែលបានលើកឡើងក្នុងសន្និសីទជាតិ រៀបចំឡើងដោយវិទ្យាស្ថានខ្មែរសំរាប់

---

(១) * ផែនការសកម្មភាពជាតិ * ភាគ១.ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តម សិក្សា. ១៥ ខែមេសា ឆ្នាំ១៩៩៧

(២) ទីស្តីការគណៈរដ្ឋមន្ត្រី "កម្មវិធីនយោបាយរបស់រដ្ឋាភិបាលកម្ពុជា"
ភ្នំពេញ ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨

សហប្រតិបត្តិការនិងសន្តិភាព ស្របទៅនឹងការប្រែមុខមាត់ថ្មី របស់ប្រទេសកម្ពុជា តាមរយៈសន្តិភាពពេញលេញនៅលើទឹកដីទាំងមូល ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងក្នុងសកលលោក និងការរៀបចំចក្ខុវិស័យ សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ សន្និសីទជាតិនេះគឺជាការបូកសរុបមួយ ដើម្បីរំលេចនូវកត្តាវិជ្ជមាន និងអវិជ្ជមានទាំងឡាយ ដែលមាននៅក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជានៅក្នុងដើមសហសវត្សរ៍ថ្មីនេះ។

ការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាមិនមែនទាមទារស្តារឡើងវិញត្រឹមការបាត់បង់ដោយសារមានវិបត្តិនយោបាយ និងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងមកនោះទេ ប៉ុន្តែ ត្រូវទាមទារការលើកកំពស់សមត្ថភាព ជំនាញរបស់ធនធានមនុស្សឱ្យស្របទៅតាមការវិវត្តន៍របស់ពិភពលោកក្នុងពេលបច្ចុប្បន្ននេះផង។ ជាមួយគ្នានោះ រឹតតែសំខាន់ណាស់ទៅទៀត នៅពេលដែលប្រទេសកម្ពុជា បាននឹងកំពុងអនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហ និងសមាហរណកម្មទៅក្នុងចរន្តសេដ្ឋកិច្ចតំបន់និងសេដ្ឋកិច្ចពិភពលោក ដែលកំពុងឈានចូលទៅកាន់យុគសម័យនៃសកលភាវូបនីយកម្ម ដែលជាសម័យមួយបាតុភូតសេដ្ឋ កិច្ចក្នុងតំបន់ក៏ដូចជា ក្នុងពិភពលោកទាំងមូល កំពុងតែវិវត្តន៍ផ្លាស់ប្តូរឥតឈប់ឈរឈានទៅរកប្រព័ន្ធសេដ្ឋកិច្ចបែបថ្មីមួយ ដែលមានចរិតសកលភាវូបនីយកម្ម និងពឹងផ្អែកលើចំណេះដឹង (Knowledge- based Economy)។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចថ្មីនេះទស្សនាទានផលិតកម្ម (Concept of Pro-

duction) ត្រូវបានជំនួសដោយទស្សនាទាន អរូបិយភាព (Concept of Intangibility) ដែលកំណត់ដោយមូលធនបញ្ញា និងសមត្ថភាពក្នុងការនិមិត្ត និងបង្កើតគំនិត។ បច្ចុប្បន្នក្នុងបណ្ដាប្រទេសជឿនលឿន គោលគំនិត ចំណេះដឹង និងចំណេះធ្វើ ដើរតួយ៉ាងសំខាន់ក្នុងការបង្កើតកំណើនសេដ្ឋកិច្ច និងបង្កើតឧត្តមភាពប្រៀប ធៀបរបស់ប្រទេសនីមួយៗ។ វត្ថុធាតុដើម និងកម្លាំងសាច់ដុំរបស់មនុស្ស មានតួនាទីកាន់តែស្តួចស្តើងទៅៗនៅក្នុងដំណើរការអភិវឌ្ឍន៍។

ដូច្នេះ ការអភិវឌ្ឍន៍ធនធានមនុស្ស ដែលប្រកបដោយសមត្ថភាពបច្ចេកទេសនិងវិជ្ជាជីវៈខ្ពស់ទាមទារការកែតំរូវឱ្យស្របទៅតាមការឱ្យតម្លៃលើគោលគំនិត ចំណេះដឹង និងចំណេះធ្វើ ដែលមានតួនាទីកាន់តែសំខាន់ឡើងក្នុងការជម្រុញកំណើនអភិវឌ្ឍន៍ និងបង្កើនឧត្តមភាពប្រៀបធៀបរបស់ប្រទេសនីមួយៗ។ ក្នុងន័យនេះដែរ ការបណ្ដុះបណ្ដាលធនធានមនុស្សឱ្យបានប្រកបទៅដោយសមត្ថភាពជំនាញខ្ពស់ និងប្រកបទៅដោយការច្នៃប្រឌិត គឺជាកត្តាដ៏សំខាន់បំផុត ដើម្បីធានានូវឧត្តមភាពដណ្ដើមឈ្នះរបស់ប្រទេសជាតិនិងដើរតួជាគន្លឹះក្នុងការធានានូវចីរភាពនៃការអភិវឌ្ឍន៍ប្រទេស[៣]។

(៣) គាត ឈន់ ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បទឧទ្ទេសនាមក្នុងសិក្ខា សាលាស្ដីពី "គ្រប់គ្រងបញ្ហាប្រឈមនៃសកលភាវូបនីយកម្ម" វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មករា ឆ្នាំ១៩៩៨

## ២_ ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា

**(Capacity Building and Human Resource Development in Cambodia)**

របាយការណ៍ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) នៅខែឧសភា ឆ្នាំ១៩៩៧[៤] បានកំណត់ការអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សថា * សមត្ថភាពរបស់ប្រទេសមានសារៈសំខាន់ ដើម្បីប្រើប្រាស់ធនធានមនុស្ស ហិរញ្ញវត្ថុ បច្ចេកទេស និងធនធានដទៃទៀត (រួមទាំងខាងក្នុងនិងខាងក្រៅ) ឱ្យមានប្រសិទ្ធិភាព សំរាប់ជម្រុញការលូតលាស់សេដ្ឋកិច្ច។ ទាំងអស់នេះរួមបញ្ចូលទាំងសមត្ថភាពផ្ទាល់របស់បុគ្គល និងស្ថាប័នក្នុងការអនុវត្តន៍ការងារឱ្យមានប្រសិទ្ធិភាព។

ចក្ខុវិស័យរបស់ប្រទេសកម្ពុជា សំរាប់រយៈពេលពីរទសវត្សខាងមុខក្នុងសហសវត្សរ៍ថ្មីនេះ គឺការរីកចំរើនយ៉ាងឆាប់រហ័សនិងការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ពិស្តារមួយ។ ការសំរេចចក្ខុវិស័យទាំងនេះត្រូវពឹងផ្អែកទាំងស្រុងលើការអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្ស ស្របទៅតាមសេចក្តីត្រូវការរបស់ប្រទេសជាតិ។

ក្នុងវិស័យអប់រំ ទោះជាមានការប្តេជ្ញាចិត្ត ក្នុងការកែលំអគុណភាព អប់រំនិងពង្រីកប្រសិទ្ធភាព ប្រើប្រាស់ប្រភពធនធានសំរាប់វិស័យ

---

[៤] Development Cooperation report, Main Report Prepared by C DC/UNDP, May 1997

អប់រំ ដើម្បីបង្កើនចំណាយឱ្យសមស្រប ដូចបណ្ដាប្រទេសក្នុងតំបន់ក៏វិសាលភាពនៃការអប់រំគ្រប់ភូមិសិក្សា នៅមានកំរិតនៅឡើយ។ កម្មវិធីសិក្សាអភិវឌ្ឍន៍មិនបានល្អ មូលដ្ឋានសម្ភារៈសិក្សាពុំគ្រប់គ្រាន់ការបណ្ដុះបណ្ដាលគ្រូបង្រៀននៅមានកម្រិត និងពុំទាន់ឆ្លើយតបបានតាមសេចក្ដីត្រូវការដែលប្រែប្រួលឆាប់រហ័សក្នុងសេដ្ឋកិច្ចទីផ្សារ។

ក្នុងការអប់រំមូលដ្ឋាន អត្រាសិក្សាត្រួតថ្នាក់ មានកម្រិតខ្ពស់ប្រមាណ ២៥% និងអត្រាបោះបង់ការសិក្សា ប្រមាណ ១០%ក្នុងមួយឆ្នាំ នេះជាសញ្ញាមួយដែលបង្ហាញប្រសិទ្ធិភាពក្នុងការអប់រំ មានកម្រិតទាប។ បរិមាណសៀវភៅសិក្សា និងថ្នាក់រៀនសម្រាប់ទទួលសិស្សមិនទាន់គ្រប់គ្រាន់ ហើយសាលារៀនជាច្រើន កំពុងត្រូវការជួសជុល។ សេវាកម្មរបស់គ្រូបង្រៀននៅមានកម្រិតទាប ទាំងខាងចំណេះដឹងនិងការបណ្ដុះបុណ្ដាលធៀបទៅនឹងបមាណីយក្នុងតំបន់ ដោយសារប្រាក់បៀវត្សរ៍មានកម្រតិទាប គ្រូបង្រៀនតែងតែស្វែងរកមុខរបរបន្ថែមក្រៅពីការបង្រៀន។ ចំណាយពុំមានប្រសិទ្ធិភាពពី ព្រោះបុគ្គលិកសិក្សាមិនបង្រៀន មានបរិមាណរហូតដល់ទៅជាង១០% នៃបុគ្គលិកសរុបក្នុងវិស័យអប់រំបើធៀបទៅនឹងនិយមអន្តរជាតិមានត្រឹមតែ៥%ប៉ុណ្ណោះ។ ដើម្បីប្រឈមមុខដោះស្រាយបញ្ហានេះ កម្មវិធីកែទម្រង់បានចាប់ផ្ដើមដោយបន្ថែមម៉ោងសិក្សា នៅសាលារៀនផ្ដល់សៀវភៅសិក្សាបន្ថែមនិងការបង្កើនប្រាក់កម្រៃដល់គ្រូបង្រៀន ទោះបីជាប្រាក់បៀវត្សរ៍ក្នុងមុខងារ

សាធារណៈដទៃទៀត មិនទាន់ប្រែប្រួលក៏ដោយ[៥]។ ចំណាយថវិការដ្ឋក្នុងផ្នែកអប់រំនិងសុខាភិបាល បានកើនឡើងជាលំដាប់ពី ១.៣៤% នៃ GDP ក្នុងឆ្នាំ១៩៩៨ ដល់១.៨៨% ក្នុងឆ្នាំ១៩៩៩ និងតាមការគ្រោង ក្នុងឆ្នាំ២០០០នេះ នឹងកើនឡើងដល់២.៣៤% នៃGDP[៦]។

កំណែទម្រង់ក្នុងផ្នែកមធ្យមសិក្សាទុតិយភូមិ បានផ្តោតការយកចិត្តទុកដាក់លើការបង្កើនអត្រាសិស្សចូលរៀន ពិសេសនារីភេទ និងការពង្រឹងបមាណីយនៃការសិក្សា ដើម្បីឆ្លើយតបសេចក្តីត្រូវការចំពោះការសិក្សាក្រោយមធ្យមសិក្សា និងកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា តាមរយៈការកែលំអគុណភាពការអប់រំ។ អត្រាប្រឡងជាប់របស់សិស្សថ្នាក់ទី១២ បានកើនឡើងពី ៥៦.៥៣%ក្នុងឆ្នាំ១៩៩៧ ទៅ ៧១.០៧% នៅក្នុងឆ្នាំ១៩៩៨ និង៧៧.៩០%នៅក្នុងឆ្នាំ១៩៩៩។ អត្រាចូលរៀន សិស្សនារីនៅមានកម្រិតទាបនៅឡើយ ប៉ុន្តែ ស្ថានភាពនេះត្រូវបានកែលំអក្នុងឆ្នាំសិក្សា១៩៩៧_១៩៩៨ មានសិស្សនារីប្រមាណ ៣៤.៦០% នៃបរិមាណសិស្សចូលរៀនសរុប[៧]។

ចំពោះការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកំពុងមានកំណើនតម្រូវសេចក្តីត្រូវការ ខាងផ្នែកជំនាញបច្ចេកទេស ក្នុងក្របខ័ណ្ឌយ៉ាងទូលំទូលាយ ទាំងនៅជនបទ និងក្នុងទីក្រុង។ បច្ចុប្បន្នសមត្ថភាពនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

[៥] ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច តំរូវការ និងសំណើ រាជរដ្ឋាភិបាល មេសា ឆ្នាំ២០០០
[៦] ទស្សនាវដ្តីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កសហវ លេខ១៨ ត្រីមាសទី២ ឆ្នាំ២០០០
[៧] ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច តំរូវការ និងសំណើ រាជរដ្ឋាភិបាល មេសា ឆ្នាំ២០០០

នៅមានចំណុចខ្វះខាតនៅឡើយ រួមទាំងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ការចុះឈ្មោះចូលរៀនរបស់សិស្ស និងវគ្គសិក្សាបានថយចុះ ដោយសារគ្មានការធានាការងារក្នុងរដ្ឋបាលសាធារណៈ និងក្នុងផ្នែកឯកជនដល់អ្នកដែលបានបញ្ចប់ការសិក្សា។ ចំណុចខ្សោយ នៃការផ្តល់សេវាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសផ្នែកសាធារណៈត្រូវបានបំពេញបន្ថែមយ៉ាងរហ័សពីផ្នែកឯកជន ដែលមានសន្ទុះខ្លាំងតាមរយៈការកើនឡើង នៃចំនួនស្ថាប័នបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋានបង់ថ្លៃក្នុងមុខជំនាញពាណិជ្ជកម្ម បច្ចេកវិជ្ជា ពត៌មានវិទ្យា និងភាសាបរទេស។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ភាគច្រើនជារបស់ផ្នែកឯកជននៅមានកម្រិត និងសេវានេះ ច្រើនប្រមូលផ្តុំតែនៅទីក្រុងភ្នំពេញ។ ចំណែកសមត្ថភាពក្នុងការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស នៅតំបន់ជនបទគឺអាស្រ័យទៅនឹងជំនួយឧបត្ថម្ភរបស់សហគមន៍អន្តរជាតិ តាមរយៈការផ្តល់សេវាអប់រំនិងការបណ្តុះបណ្តាលក្រៅប្រព័ន្ធ។

ឧត្តមសិក្សានៅកម្ពុជា រួមមានគ្រឹះស្ថានឯកជន និងសាធារណៈដែលបង្កើតឡើងតាមសំណូមពរ នៃសេចក្តីត្រូវការ និងដែលច្រើនប្រមូលផ្តុំនៅរាជធានីភ្នំពេញ។ យោងតាមរបាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា[៨] បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានឧត្តមសិក្សា

[៨] ក្រសួងអប់រំយុវជន និងកីឡា ការអប់រំនៅកម្ពុជា ភ្នំពេញ កក្កដា ឆ្នាំ១៩៩៩

បច្ចេកទេស និងវិជ្ជាជីវៈ ជាអ្នកទទួលបន្ទុកសំរបសំរួលការងារឧត្តមសិក្សា ដោយចាត់ចែង និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាផ្ទាល់ ប៉ុន្តែជាក់ស្តែង អគ្គនាយកដ្ឋានឧត្តមសិក្សា គ្រប់គ្រងផ្ទាល់តែគ្រឹះស្ថានចំនួន៦ប៉ុណ្ណោះ ចំណែកគ្រឹះស្ថានឧត្តមសិក្សាចំនួន ៣ទៀត ស្ថិតនៅក្រោមឱវាទក្រសួងតាមជំនាញ។ ប្រការនេះ នាំឱ្យប្រព័ន្ធឧត្តមសិក្សានៅប្រទេសកម្ពុជា អនុវត្តនូវសកម្មភាពសិក្សាខុសៗគ្នា អាស្រ័យតាមក្រសួងជាអាណាព្យាបាល ដែលមានមុខងារជាអ្នកត្រួតពិនិត្យ។ ការគ្រប់គ្រង និងចាត់ចែងប្រព័ន្ធអប់រំ និងប្រព័ន្ធស្ថាប័ននៃឧត្តមសិក្សាមានលក្ខណៈដាច់ៗពីគ្នា ជាប្រការមិនអាចបង្ហាញឡើងពីភាពច្បាស់លាស់របស់ឧត្តមសិក្សា។ នៅតាមមហាវិទ្យាល័យ និងវិទ្យាស្ថានមួយចំនួនបានដំណើរការជាអង្គភាពឯករាជ្យ។ ជាទូទៅថ្នាក់ដឹកនាំ នៃគ្រឹះស្ថានឧត្តមសិក្សា (សាកលវិទ្យាធិការ ព្រឹទ្ធបុរស នាយក.,) ពុំមានការជួបប្រជុំគ្នាតាមផ្លូវការ ឬក្រៅផ្លូវការ សំរាប់ពិភាក្សា ដើម្បីផ្លាស់ប្តូរចែករំលែកយោបល់និងបទពិសោធន៍ជាមួយសហសេវិករបស់ខ្លួន។ លទ្ធផលនេះនាំឱ្យមានភាពឯកោរាំងស្ថាប័នឧត្តមសិក្សាក្នុងប្រព័ន្ធអប់រំជាតិ។

ផលវិបាកនៃការគ្រប់គ្រង និងអនុវត្តការងារដាច់ៗពីគ្នា និងកង្វះការសំរបសំរួល ក្នុងប្រព័ន្ធឧត្តមសិក្សា គឺជាការបាត់បង់នូវទំនាក់ទំនងជាមួយអង្គការក្នុងតំបន់ និងពិភពលោក។ ផលវិបាកមួយទៀតគឺការបាត់បង់កាលានុវត្តភាព ដើម្បីគ្រប់គ្រងធនធានដែលមានស្រាប់

ឱ្យមានប្រសិទ្ធភាព និងដើម្បីពង្រឹងធនធានទាំងនោះ ឱ្យស្របទៅតាមសេចក្តីត្រូវការរបស់ប្រទេសជាតិ។

## ៣_ ការអភិវឌ្ឍន៍ធនធានមនុស្ស : បញ្ហា និងដំណោះស្រាយ

នៅក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រថ្មីនេះ ប្រទេសកម្ពុជាត្រូវការនូវការផ្លាស់ប្តូរដ៏ទូលំទូលាយ និងជ្រាលជ្រៅនៅលើគ្រប់វិស័យ។ ពិតមែនតែសន្តិភាពបានកើតឡើង និងគ្របដណ្តប់ទូទាំងប្រទេស នេះគ្រាន់តែជាលក្ខខ័ណ្ឌចាំបាច់ចំបងមួយ ក្នុងចំណោមលក្ខខ័ណ្ឌដទៃទៀតជាច្រើន សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិតែប៉ុណ្ណោះ។ កម្ពុជាមានមូលដ្ឋាន និងប្រព័ន្ធសេដ្ឋកិច្ចនៅទន់ខ្សោយមានយន្តការ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនទាន់ពេញលេញ មិនអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសភាពការណ៍វិវត្តន៍នៅក្នុងប្រទេស នៅក្នុងតំបន់ និងពិភពលោកបានឡើយ។

ទន្ទឹមនឹងនោះ ការរងខ្ទេចខ្ទាំ និងការបំផ្លាញនៃប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស គឺជាបញ្ហាចម្បង ដែលកម្ពុជាកំពុងប្រឈមមុខ :

១_កង្វះខាតធនធានមនុស្ស ដែលមានសមត្ថភាព និងជំនាញវិជ្ជាជីវៈគ្រប់គ្រាន់ សំរាប់បំពេញការងារនៅតាមស្ថាប័នសាធារណៈនិងឯកជន។

២_ទាមទារការបង្កើនសមត្ថភាពជំនាញ និងវិជ្ជាជីវៈនៃធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់របស់រាជ

រដ្ឋាភិបាលនិងគោលនយោបាយសេដ្ឋកិច្ចបើកចំហ ដើម្បីធ្វើសមាហរណកម្ម ទៅក្នុងចរន្តសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក។

៣_តម្រូវការលើកកំពស់សមត្ថភាពជំនាញនិងវិជ្ជាជីវៈនៃធនធានមនុស្ស ស្របទៅតាមការឈានចូលរបស់ប្រទេស ទៅកាន់យុគសម័យនៃសកលភាវូបនីយកម្ម ដែលជាសម័យមួយបាតុភូតសេដ្ឋកិច្ច នៅក្នុងពិភពលោកទាំងមូល កំពុងតែវិវត្តន៍ផ្លាស់ប្តូរឥតឈប់ឈរ ហើយឈានទៅរកសេដ្ឋកិច្ចបែបថ្មីមួយ ដែលមានចរិតសកលភាវូបនីយកម្ម ហើយពឹងផ្អែកលើចំណេះដឹង (Knowledge-based Economy)។

ជាមួយគ្នានោះការអភិវឌ្ឍន៍ធនធានមនុស្សត្រូវផ្អែកលើលក្ខណៈសម្បត្តិសំខាន់ៗ បី គឺៈ (១)_មានសមត្ថភាពយល់ដឹងទូលំទូលាយ (២)_មានសមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈខ្ពស់ និង(៣)_មានគុណធម៌ និងសីលធម៌ស្អាតស្អំ[៩]។ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងធនធានមនុស្ស ជាពិសេសក្នុងសង្គមស៊ីវិល ត្រូវឆ្លើយតបទៅនឹងជំនាញឯកទេស សេចក្តីត្រូវការ កាលៈទេសៈ និងការវិវត្តន៍នៃចរន្តអភិវឌ្ឍន៍សង្គម ដោយផ្សារភ្ជាប់ទៅនឹងតំបន់និងពិភពលោក។

ពិតមែនតែកន្លងមក ការអភិវឌ្ឍន៍ធនធានមនុស្ស តែងតែបានទទួលការយកចិត្តទុកដាក់ និងផ្តល់អាទិភាព។ តែការអភិវឌ្ឍន៍និងការ

[៩] របាយការណ៍ការប្រជុំគុម្ពលើកទី៣ ស្តីពី "ការអភិវឌ្ឍន៍ធនធានមនុស្ស និង ការកសាងសមត្ថភាពក្នុងសង្គមស៊ីវិល" វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព, វិមានរដ្ឋាភិបាល ថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩

កសាងសមត្ថភាពធនធានមនុស្សគ្រាន់តែរៀបចំសំរាប់បំពេញសេចក្តីត្រូវការចំពោះមុខតែប៉ុណ្ណោះ។ ការបណ្តុះបណ្តាលផ្នែកឧត្តមសិក្សាបច្ចេកទេស វិជ្ជាជីវៈ ការអប់រំមូលដ្ឋាននៅកម្ពុជា រួមមានគ្រឹះស្ថានសាធារណៈ និងឯកជន ដែលបង្កើតឡើងតាមសំណូមពរ និងសេចក្តីត្រូវការ និងដែលច្រើន ប្រមូលផ្តុំនៅរាជធានីភ្នំពេញ។ ការអភិវឌ្ឍន៍មួយភាគធំអាស្រ័យទៅនឹងសេចក្តីត្រូវការសេដ្ឋកិច្ចទីផ្សារ។ ប៉ុន្តែជាក់ស្តែង ការអភិវឌ្ឍន៍ និងការកសាងសមត្ថភាពធនធានមនុស្ស មិនអាចអាស្រ័យបានទៅនឹងតម្រូវ ការទីផ្សារមួយមុខទេ។ ការអភិវឌ្ឍន៍សង្គមទាំងមូលត្រូវការធនធានមនុស្ស ដែលមានសមត្ថភាពក្នុងគ្រប់ផ្នែក គ្រប់ជំនាញ និងគ្រប់កម្រិត។ បច្ចុប្បន្ន ជំនាញដែលកំពុងមានប្រជាប្រិយភាពខ្ពស់ ដូចជាជំនាញ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ការគ្រប់គ្រង ពត៌មានវិទ្យា ភាសាបរទេសជាដើម។ ដើម្បីតម្រែតម្រង់នូវតម្រូវការនេះទាមទារកម្លាំងពីខាងក្រៅ ដើម្បីធ្វើអន្តរាគមន៍និងជួយជម្រុញឱ្យមានការអភិវឌ្ឍន៍ស្របទៅតាមសេចក្តីត្រូវការរបស់សង្គមជាតិ។ ទោះបីនៅក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចឬការកសាងធនធានមនុស្សមិនអាចសង្ឃឹមទាំងស្រុងលើដៃអរូប[១០] (Invisible Hand) ដែលជា ទ្រឹស្តីសេដ្ឋវិទូអាដាមស្មិត នៅសតវត្សទី១៨ សំរាប់ជានិមិត្តរូប នៃប្រសិទ្ធិភាពរបស់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបាននោះទេ។ ការអភិវឌ្ឍន៍ធនធានមនុស្សនៅ

[១០] "ស្ថានភាពសេដ្ឋកិច្ចកម្ពុជា:ស្ថិតនៅមាត់ច្រកសមាហរណកម្មក្នុងតំបន់" ទស្សនាវដ្តី *គំនិតខ្មែរ* (សម្ព័ន្ធនិស្សិតខ្មែរពីបរទេស) លេខ ៦ មេសា_ឧសភា_មិថុនា ឆ្នាំ១៩៩៧

កម្ពុជាទាមទារឱ្យមាន "ដៃរូបីយ" (Visible Hand) ដើម្បីណែនាំ និងតម្រែតម្រង់។ ក្នុងន័យនេះ មានតម្រូវការជាបន្ទាន់ ក្នុងការរៀបចំផែនការមេ ដែលជាចក្ខុវិស័យ សំរាប់ការអភិវឌ្ឍន៍ ព្រមទាំងការយកចិត្តទុកដាក់ និងការធ្វើអន្តរាគមន៍របស់រដ្ឋ ទាំងផ្នែកសម្ភារៈនិងស្មារតី។

ទន្ទឹមនឹងនោះ ដូចដែលបានលើកខាងដើម ការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា មិនមែនទាមទារស្តារឡើងវិញត្រឹមការបាត់បង់ដោយសារមានវិបត្តិនយោបាយ និងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងមកនោះទេ ប៉ុន្តែ ត្រូវទាមទរការលើកកំពស់សមត្ថភាពជំនាញរបស់ធនធានមនុស្សឱ្យស្របទៅតាម ការវិវត្តន៍របស់ពិភពលោកក្នុងពេលបច្ចុប្បន្ននេះផង។ ប្រសិនបើយើង ប្រៀបធៀបប្រទេសយើងទៅនឹងប្រទេសជិតខាង ដូចជាម៉ាឡេស៊ី ថៃ វៀតណាម ភូមា ធនធានមនុស្សដែលមានស្រាប់នៅក្នុងប្រទេសទាំងនេះ មានការងាយស្រួលក្នុងការឈោងចាប់នូវ វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាពត៌មាន ដែលកំពុងវិវត្តយ៉ាងលឿន ទាំងនៅក្នុងតំបន់ និងក្នុងពិភពលោកទាំងមូល។

ដោយសារវិបត្តិនយោបាយ និងសង្គ្រាមស៊ីវិលអូសបន្លាយជាងពីរទសវត្សរ៍នោះ ធ្វើឱ្យកម្រិតសមត្ថភាព និងជំនាញវិជ្ជាជីវៈធនធានមនុស្សនៅកម្ពុជាធ្លាក់ចុះយ៉ាងខ្លាំងក្លា។ ដូច្នេះការអភិវឌ្ឍន៏ធនធានមនុស្សនៅកម្ពុជាទាមទារដំណើរពីរជំហាន :

-ជំហានទី១ បំពេញវិញនូវធនធានមនុស្ស ដែលបានបាត់បង់កន្លងមក (ទាំងសមត្ថភាព ជំនាញបច្ចេកទេស និងបទពិសោធន៍)

_ជំហានទី២ ការត្រៀមធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់ សំរាប់ស្រូបយកនូវវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាពតិមានទំនើប ដែលកំពុងវិវត្តន៍យ៉ាងលឿនលឿន ទាំងនៅក្នុងតំបន់និងក្នុងពិភពលោកទាំងមូល។

ដើម្បីដោះស្រាយបញ្ហានេះ ទាមទារវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម :

១_ការរៀបចំផែនការមេ សំរាប់ការអភិវឌ្ឍន៍ និងបង្កើនសមត្ថភាពជំនាញ និងវិជ្ជាជីវៈធនធានមនុស្ស ក្នុងដំណាក់កាលយូរអង្វែង។ ខ្លឹមសារនៃផែនការនេះ ត្រូវពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពនៃសង្គម ពោលគឺយោលទៅតាមការរៀបចំយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី ការកសាងនិងកែទម្រង់ប្រព័ន្ធច្បាប់ និងជាពិសេសការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់និងពិភពលោក។

២_បង្កើនការវិនិយោគលើការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈមធ្យោបាយថវិកា ការកៀងគរជំនួយបរទេស ទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស។ ទន្ទឹមនឹងនោះ ការជំរុញវិនិយោគទុនបរទេសដោយផ្ទាល់ ក៏ជាគន្លឹះយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបង្កើនទីកន្លែងធ្វើការ ការផ្ទេរជំនាញនិងបច្ចេកវិជ្ជាទំនើប។

៣_បង្កើនលទ្ធភាព ស្រូបយករបស់មន្ត្រីជំនាញក្នុងស្រុក ដែលជាដៃគូការងារជាមួយអ្នកជំនាញការបរទេស (តាមរយៈអ្នកផ្តល់ជំនួយ

និង NGOs) ដោយជម្រុញឱ្យមានការចូលរួម និងការផ្តល់ការលើកទឹកចិត្តផ្សេងៗ។

៤_ជម្រុញកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលនាំមកនូវការបែងចែកការងារសមស្របទៅតាមសមត្ថភាពវិជ្ជាជីវៈ និងការផ្តល់មធ្យោបាយគ្រប់គ្រាន់សំរាប់ជីវភាពរស់នៅ។ ការបង្កើនទីកន្លែងការងារគឺជាការចាំបាច់ ចំណែកការផ្តល់ការងារ ការតំលើងឋានៈ និងតួនាទីត្រូវធ្វើឡើងឱ្យសមស្របតាមសមត្ថភាពជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ការងារ។

ក្នុងឆ្នាំ១៩៩៥ ក្នុងផ្នែកឧត្តមសិក្សា រដ្ឋាភិបាល បានបង្កើត "ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា" (National Higher Education Task Force) ដើម្បីរៀបចំផែនការសកម្មភាពជាតិ សំរាប់ឧត្តមសិក្សា។ ផែនការនេះត្រូវបានបញ្ចប់ជាស្ថាពរនៅឆ្នាំ១៩៩៧ ដោយបានវិភាគពីស្ថានភាព និងលើកឡើងនូវវិធានការណ៍សំខាន់ៗ និងជាពិសេស ផែនការយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធឧត្តមសិក្សានៅកម្ពុជារយៈពេល១០ឆ្នាំ។

ពិតមែនតែការអនុវត្តន៍ (ផែនការសកម្មភាពជាតិសំរាប់ឧត្តមសិក្សា) អាស្រ័យទៅនឹងការសំរេចរបស់រាជរដ្ឋាភិបាល និងការទទួលហិរញ្ញប្បទានពីសហគមន៍អន្តរជាតិ ប៉ុន្តែអ្វីដែលបង្ហាញច្បាស់ និងដើរតួនាទី ជាគន្លឹះក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា នាបច្ចុប្បន្ននេះគឺតម្រូវការកំណែទម្រង់មួយជាក់លាក់និងទូលំទូលាយក្នុងប្រព័ន្ធអប់រំ

កម្ពុជា។ ដូច្នេះ ការអនុវត្តន៍ (ផែនការសកម្មភាពជាតិ សំរាប់ឧត្តមសិក្សា) ដែលបានរៀបចំរួច អាចជាកាលានុវត្តភាពមួយជាក់លាក់ក្នុងការរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា។

សេចក្តីសន្និដ្ឋាន

ដូចដែលបានបកស្រាយខាងលើ ការអភិវឌ្ឍន៍ធនធានមនុស្សទាមទារការធ្វើអន្តរាគមន៍របស់រដ្ឋ ក្នុងការរៀបចំផែនការ ការសម្របសម្រួលនិងតម្រែតម្រង់ កម្មវិធីបណ្តុះបណ្តាលឱ្យស្របទៅតាមតម្រូវការទីផ្សារ និងតម្រូវការ ការអភិវឌ្ឍន៍សង្គមទាំងមូល។

ទន្ទឹមនឹងនោះ ដើម្បីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាល រដ្ឋមានភារកិច្ចប្រើប្រាស់ បែងចែកនូវធនធានមនុស្ស ដែលបង្កើតបានទៅតាមសមត្ថភាព មុខជំនាញ បច្ចេកទេស ទាំងក្នុងផ្នែកសាធារណៈនិងផ្នែកឯកជនតាមរយៈការបង្កើនទីកន្លែងធ្វើការ។

ការបដិសន្ធិឡើងនូវសេដ្ឋកិច្ចថ្មីក្រោមឥទ្ធិពលនៃសកលភាវូបនីយកម្ម ដែលមានចរិតជាសេដ្ឋកិច្ចឌេខូបនីយកម្ម (Digitalized Economy) ហើយពឹងផ្អែកលើចំណេះដឹង (Knowledge-based economy) ទាមទារការកែតម្រូវកម្មវិធីសិក្សាទាំងក្នុងផ្នែកសាធារណៈនិងផ្នែកឯកជនឱ្យស្របទៅតាមបមាណីយ កម្មវិធីសិក្សាក្នុងតំបន់ដើម្បីផ្តល់ឱកាសឱ្យអ្នកសិក្សាអាចចាប់យកនូវមុខជំនាញថ្មីៗ ដែលកំពុងវិវត្តន៍ក្នុងតំបន់និងពិភពលោកទាំងមូល ជាពិសេសផ្នែកបច្ចេកវិទ្យាពត៌មាន ដែលក្នុងប្រទេសជាសមាជិក អាស៊ាន កំពុងអភិវឌ្ឍន៍ដោយជោគជ័យ។ ថ្មីៗនេះ កម្ពុជា

ក្នុងនាមជា សមាជិកអាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពី E-ASEAN ដែលជាកិច្ចចាប់ផ្ដើមនៃការអនុវត្តន៍ប្រព័ន្ធបច្ចេកវិជ្ជា ក្នុងការធ្វើពាណិជ្ជកម្ម E-Commerce ក្នុងការងារគ្រប់គ្រង E-Governance និងកិច្ចការរដ្ឋាភិបាល E-Government ជាដើម។

ជាមួយគ្នានោះ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងធនធានមនុស្ស ជាពិសេសក្នុងសង្គមស៊ីវិល ត្រូវឆ្លើយតបទៅនឹងជំនាញឯកទេស សេចក្ដីត្រូវការកាលៈទេសៈ និងការវិវត្តន៍នៃចរន្តអភិវឌ្ឍន៍សង្គមដោយផ្សារភ្ជាប់ទៅនឹងតំបន់ និងពិភពលោក។ ក្នុងន័យនេះការអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវពឹងផ្អែកលើលក្ខណៈសម្បត្តិសំខាន់ៗបីគឺ :

១_មានសមត្ថភាពយល់ដឹងទូលំទូលាយ

២_មានសមត្ថភាព បច្ចេកទេស និងវិជ្ជាជីវៈខ្ពស់។

៣_មានគុណធម៌ និងសីលធម៌ស្អាតស្អំ៕

### ៧.៦_សុន្ទរកថាថ្លែងដោយ លោកស្រី ជា មុយគ្រី នាយិកា កម្មវិធីអភិវឌ្ឍន៍ធនធានយុវជនស្ដីអំពី "ការអភិវឌ្ឍន៍ធនធានមនុស្សនិងការកសាងសមត្ថភាពសង្គមស៊ីវិលកម្ពុជា : សមិទ្ធិផល និងការប្រឈមមុខ"

នៅក្នុងការអប់រំបែបធនាគារ មនុស្សជាអ្នកមើល មិនមែនជាអ្នកបង្កើតទេ គេសម្របខ្លួន ប៉ុន្ដែមិនកែច្នៃឡើយ។ បួន បួនដង ដប់ប្រាំមួយ ការអភិវឌ្ឍន៍ គឺរីកចំរើន ទាំងនេះគឺ ជាអ្វីដែលពួកសិក្សាកំណត់យកដែលពួកសិស្សចងចាំទុក និងថាតាមដោយមិនបានយល់ដឹងដោយវិញ្ញាណថា"បួនបួនដង " មានន័យពិតប្រាកដយ៉ាងដូចម្ដេច? មិនដឹងថាន័យពិតប្រាកដរបស់ពាក្យ "ការអភិវឌ្ឍន៍ " មានន័យយ៉ាងណា? ហើយតើ "ការអភិវឌ្ឍន៍ត្រូវមានដំណើរការបែបណាទេ "។

ជារឿយៗ ការអប់រំតែងតែស្ដែងឡើង ដោយសារពិពណ៌នារៀបរាប់ ដូច្នេះការពិពណ៌នារៀបរាប់ អាចចាត់ទុកដូចជាជំងឺនៃការអប់រំ។ លោក សាស្ត្រាចារ្យ លើកឡើងអំពីតថភាព តែតថភាពនោះហាក់ដូចជាគ្មានការផ្លាស់ប្ដូរអ្វីឱ្យល្អសោះ ចំណែកឯអ្នកទទួលការអប់រំវិញ គឺគេស្ដាប់ដោយឥតបានធ្វើការពិចារណាអ្វីឡើយ។ អ្នកទទួលការអប់រំប្រៀបដូចជា (ម៉ាស៊ីនថត) ចំលងយកខ្លឹមសារនៃប្រយោគទាំងឡាយ ដែលស្ទើរតែគ្រប់ពេល គ្មានអ្វីទាក់ទងទៅនឹងបទពិសោធន៍ផ្ទាល់ ក្នុងជីវិតរស់នៅរបស់គេឡើយ ហើយវាក៏គ្មានន័យអ្វីទាល់តែ

សោះផង។ ពេលនោះអ្នកទទួលការអប់រំប្រៀបដូចជា (ធប) ដែលអ្នកអប់រំត្រូវតែចាក់បំពេញ។ មតិទូទៅ យល់ថា "បើគេបំពេញធបបានច្រើនពេលណាពេលនោះគេ ក៏កាន់តែមានឈ្មោះថា ជាគ្រូដ៏ល្អប្រសើរ ពេលណាអ្នកទទួលការអប់រំបណ្តោយខ្លួន ឱ្យគេចាក់បំពេញដោយស្រួល ពេលនោះ គេក៏ក្លាយទៅជាសិស្ស ឬនិស្សិតក៏ប្រពៃដែរ "។ ការអប់រំរបៀបនេះវាជាសកម្មភាពអសកម្មឬ "ដឹកលក់ទុក " ហេតុនេះហើយបានជាគេឱ្យឈ្មោះថា "ការអប់រំបែបធនាគារ "។

នៅក្នុងការអប់រំបែបធនាគារ អ្នកអប់រំយល់ថា គេជាអ្នកមានចំណេះ ហើយគេផ្តល់ចំណេះវិជ្ជាទៅឱ្យអ្នកណាដែលគេយល់ថា ជាមនុស្សល្ងង់ ហេតុដូចនេះហើយទើបគេយល់ថា គេជាមនុស្សមានសារៈប្រយោជន៍។ ទស្សនៈបែបនេះ ប្រឆាំងនឹងការអប់រំបែបសេរីឬការអប់រំបែបគិតពិចារណា ព្រោះការអប់រំបែបសេរី គឺម្នាក់ៗអាចជាអ្នកអប់រំគេផង ហើយក៏អាចជាអ្នកទទួលការអប់រំពីគេវិញផងដែរ។

នៅក្នុងការអប់រំបែបធនាគារ :

- អ្នកអប់រំគឺជាអ្នកអប់រំគេ អ្នករៀនសូត្រ ជាអ្នកដែលត្រូវបានគេអប់រំ។
- អ្នកអប់រំ ជាអ្នកចេះ ឯអ្នកទទួលការអប់រំ ជាអ្នកដែលមិនទាន់ចេះអ្វីឡើយ។
- អ្នកអប់រំ ជាអ្នកនិយាយ អ្នកទទួលការអប់រំ ជាអ្នកដែលស្តាប់ គេបាក់ស្លឹកត្រចៀក។

- អ្នកអប់រំ ជាអ្នកជ្រើសរើស ហើយបង្ខំគេឱ្យទទួលយកការជ្រើសរើសរបស់ខ្លួន រីឯអ្នកទទួលការអប់រំវិញ គឺជាអ្នកចាំតែធ្វើអ្វីៗ តាមគេប្រាប់ប៉ុណ្ណោះ។
- អ្នកអប់រំ គឺជាអ្នកដើមហេតុនៃដំណើរការហាត់រៀន "គឺជាអ្នកបង្កើតដំណើរការ " ឯអ្នកទទួលការអប់រំវិញ គឺគ្រាន់តែជាកម្មវត្ថុនៃដំណើរការនោះប៉ុណ្ណោះ។

គោលគំនិតបែបខាងលើនេះជម្រុញឱ្យការអប់រំមានភាពអសកម្ម ហើយរាំងស្កាត់មិនឱ្យគំនិតរិះគិតពិចារណា រីកចំរើនឡើងបាន ពីព្រោះអ្នកទទួលការអប់រំត្រូវហ្វឹកហាត់ខ្លួនឱ្យក្លាយទៅជាអ្នកចេះ សម្របខ្លួនទៅនឹងពិភពលោក មិនមែនជាអ្នកញ៉ាំងពិភពលោកឱ្យបានល្អប្រសើរនោះឡើយ។ ដូចនេះ ការអប់រំ បែបធនាគារ រារាំងមនុស្សមិនឱ្យមានការរីក ចំរើន ធ្វើឱ្យមនុស្សគ្មានកំលាំង "បង្កើតគំនិតថ្មី " គ្មាន "បំលែង ឬគ្មាន "ចំណេះដឹង "។ គេទទួលបានត្រឹមតែអ្វីដែលបានមកពីការស្រាវជ្រាវពីការអនុវត្តន៍របស់មនុស្សនៅក្នុងលោក ជាមួយពិភពលោក និងជាមួយមនុស្សថែមទៀតប៉ុណ្ណោះ។ ការអប់រំបែបនេះ វាផ្ទុយពី "ជីវិតពិត " ពីព្រោះជីវិតមិនមែននៅនឹងថ្កល់មួយកន្លែងនោះឡើយ ផ្ទុយទៅវិញជីវិតមានចលនាជាប់ជាប្រចាំ។

បុគ្គលិកដែលឆ្លៀតឆក់យកឱកាស ពីស្ថានការណ៍អយុត្តិធម៌ គឺជាអ្នកលើកទឹកចិត្តការអប់រំបែបធនាគារឱ្យនៅស្ថិតស្ថេរគ្មានប្រែប្រួល គឺគេចង់ឱ្យអ្នក "ទទួលរងអំពីអយុត្តិធម៌ " ដែលពួកគេនិយមហៅតាម

"របៀបបិតុនិយម" ថា "អ្នកទទួលការឧបត្ថម្ភ" នោះឱ្យសម្របខ្លួនទៅនឹងស្ថានការណ៍។ ប៉ុន្តែ អ្នកដែលទទួលរងអំពើអយុត្តិធម៌ នឹងត្រូវបានរំដោះខ្លួន បើគេចេះកែច្នៃស្ថានការណ៍ និងចេះធ្វើខ្លួនឱ្យរីកចំរើនដោយខ្លួនឯងផ្ទាល់ គឺមិនមែនដោយរបៀបសំរបខ្លួន ទៅតាមសភាពការណ៍អយុត្តិធម៌នោះទេ។ ការរំដោះខ្លួនយ៉ាងពិតប្រាកដ *គឺជាការត្រិះរិះពិចារណានិងជាសកម្មភាពកែប្រែពិភពលោករបស់មនុស្ស។* ពេលដែលមនុស្សដឹងខ្លួនថា ខ្លួនគេត្រូវអ្នកដទៃរារាំងមិនឱ្យធ្វើអ្វីមួយ ឬពេលណាគេដឹងថា ខ្លួនគេគ្មានសមត្ថភាពក្នុងការប្រើប្រាស់សម្បទារបស់គេ ពេលនោះគេមានការឈឺចាប់ ពីព្រោះគេដឹងខ្លួនថា គេខកចិត្តដោយត្រូវបាត់បង់ប្រយោជន៍ផ្ទាល់ខ្លួនគេ និងសង្គមជូនកាលចំលើយមួយទាមទារឱ្យខ្លួនគេរិះគិតប្រៀប ដូចជាគេខ្លាចអ្នកដឹកនាំម្នាក់ដែលមានអំណាចគេចាំបាច់ត្រូវតែសំរបខ្លួននិងដាក់ខ្លួននៅចំពោះមុខអ្នកដឹកនាំ។ ដើម្បីរំដោះខ្លួនពីការកៀបសង្កត់ អ្នកជំនាន់ក្រោយភាគច្រើន ក៏ប្រើរបៀបរបបនៃការអប់រំដូចគ្នានឹងអ្នកដឹកនាំម្នាក់ ដែលមានអំណាចហើយបង្កើតឡើងវិញនូវការកៀបសង្កត់តាមរបៀបដដែលដូចគ្នា។ ការពិតដើម្បីរំដោះខ្លួនឱ្យបានពិតប្រាកដ គឺមានតែការកែប្រែស្ថានការណ៍អយុត្តិធម៌ប៉ុណ្ណោះ។

## ការអប់រំបែបសេរីគឺជាការអប់រំមួយ "ដែលចោទជាបញ្ហាឱ្យដោះស្រាយ"

អ្នកដែលអនុវត្តការអប់រំបែបធនាគារ ទោះបីដោយចេតនាក្តី ឬដោយអចេតនាក្តី (ព្រោះមានអ្នកអប់រំដែលប្រកបដោយសុឆន្ទៈច្រើនគ្នាណាស់ មិនដឹងពីអំពើដែលខ្លួនបានធ្វើមិនបានឃើញថា អ្វីដែលខ្លួន

បញ្ជូនទៅនោះមានផ្ទុក ភាពមិនចុះសំរុងគ្នា ឡើយ ព្រោះថាគេមិនសួរគិតគូរដល់តថភាពទេ។ បើ "ផ្ទៃក្នុងមិនចុះសំរុងគ្នា" កាន់តែរីកខ្លាំងក្លាពេកពេលនោះអ្នកទទួលការអប់រំអាចភ្ញាក់ស្មារតី ហើយបញ្ចេញសកម្មភាពបាន។ ប៉ុន្តែ គេក៏មិនត្រូវរង់ចាំទាល់តែមានយថាហេតុនោះកើតឡើងដែរ។ អ្នកអប់រំដែលមានគំនិត "មនុស្សនិយម " ត្រូវតែមានជំនឿទុកចិត្តយ៉ាងមុតមាំទៅលើសមត្ថភាព និងកំលាំងបង្កបង្កើតរបស់មនុស្ស។ ទាំងអស់នេះ ទាមទារឱ្យគេស្ថិតនៅក្នុងចំណងទាក់ទងគ្នា។ សាស្ត្រាចារ្យមិនអាចគិតជំនួសសិស្ស ឬបង្ខំសិស្សឱ្យគិតតាមខ្លួនបានទេ។ គំនិតពិតប្រាកដ ដែលមានជាប់ទាក់ទងទៅនឹងតថភាពអាចកើតឡើងបានលុះត្រាតែមានទំនាក់ទំនងតែប៉ុណ្ណោះ។

ការអប់រំបែបសេរី បញ្ជាក់ពីភាពចាំបាច់នៃការចរចាគ្នា ព្រោះវាចាប់ផ្តើមពីគោលការណ៍ "មនុស្សស្ថិតនៅក្នុងចំណងទាក់ទងជាមួយពិភពលោកនិងជាមួយមនុស្សឯទៀត"។ ទីនេះ គេមិនបំពេញអ្វីឡើយ គេគ្រាន់តែចោទសួរថា ហេតុអ្វីមនុស្សស្ថិតនៅក្នុងចំណងទាក់ទងជាមួយពិភពលោក? អ្នកដែលបានឆក់យកឱកាសពីអំពើអយុត្តិធម៌ ពិតជាមិនយល់សំណួររបស់អ្នកដែលទទួលរងអំពើអយុត្តិធម៌ តែងចោទសួរខ្លួនឯងថា "តើមូលហេតុអ្វី ដែលនាំយើងឱ្យរិះគិតរកដំណោះស្រាយបញ្ហានានា ដើម្បីកែប្រែសភាពការណ៍អយុត្តិធម៌? "។ នៅក្នុងការអប់រំបែបសេរីគឺ "មនុស្សអប់រំគ្នាទៅវិញទៅមក "។ ដូច្នេះ អ្នកអប់រំមិនគ្រាន់តែអប់រំគេ ប៉ុណ្ណោះទេ ប៉ុន្តែទន្ទឹមនឹងការអប់រំអ្នកដទៃ គេក៏ទទួលបាន

ការអប់រំដែលមាននៅក្នុងកិច្ចសន្ទនាជាមួយអ្នកដែលត្រូវគេអប់រំផងដែរ។ កាលណាអ្នកអប់រំ វិភាគបញ្ហាមួយជាមួយអ្នកត្រូវទទួលការអប់រំ គេនឹងធ្វើការពិនិត្យថ្លឹងថ្លែងមតិ យោបល់របស់គេឡើងវិញ ដោយឈរលើមូលដ្ឋាននៃមតិយោបល់របស់អ្នកទាំងនោះផងដែរ។

ពេលដែលមនុស្សប្រឈមមុខនឹងបញ្ហាកាន់តែច្រើន គេក៏កាន់តែដឹងខ្លួនថា ខ្លួនគេត្រូវតែបង្ខំចិត្តដោះស្រាយបញ្ហានោះ។ ពេលដែលគេមើលឃើញថា បញ្ហាទាំងនោះមានចំណងទាក់ទងជាមួយគ្នាទៅវិញទៅមក ពេលនោះគេក៏ក្លាយទៅជាអ្នកចេះរិះគិត ចេះវាយតំលៃហើយគេក៏កាន់តែមានសេរីភាពដែរ។ កាលណាគេខិតខំយល់បញ្ហាមួយ គឺគេកាន់តែមានសេរីភាព ព្រោះបញ្ហាវាជារឿងដែលអាចជៀសវាងបានឬអាចកាត់បន្ថយបាន។ សេរីភាព គឺជាការឈ្នះបញ្ហា ឬជាការនាំឱ្យចេះដោះស្រាយបញ្ហាឱ្យចេះប្រឈមមុខទល់នឹងតថភាព (ភាពពិត) ដែលកំពុងតែវិវត្តន៍ផ្លាស់ប្តូ។ ដូច្នេះ ការអប់រំបែបសេរីផ្អែកទៅដោយសេចក្តីសង្ឃឹម ព្រោះយើងគិតថា យើងចេះដោះស្រាយបញ្ហា។

ការអប់រំបែបសេរី លើកទឹកចិត្ត ឱ្យមនុស្សចេះរិះគិតពិចារណាបែបទិទ្វេនស្លាបនានិងឱ្យមនុស្សចេះធ្វើសកម្មភាពដោយឈរលើការពិត។ ការអប់រំបែបសេរីជាការឆ្លើយតបទៅនឹងឧបនិស្ស័យរបស់មនុស្សគឺធ្វើឱ្យមនុស្សបា "ពេញលក្ខណៈ"។ ផ្តើមចេញពីគោលការណ៍ "មនុស្សជាសត្វលោក ដែលមិនទាន់បានបញ្ឈប់ការវិវត្តន៍ នៅក្នុងពិភពលោកមួយដែលមានការវិវត្តន៍" នោះការអប់រំបែបសេរី ជាដំណើរសកម្មភាព

អចិន្ត្រៃយ៍ ពីព្រោះវាជាមូលដ្ឋានផ្តល់លទ្ធភាពឱ្យមនុស្សឈានទៅរកភាពប្រសើរឡើង។ ការអប់រំបែបនេះគឺជាការអប់រំដែលចាត់ទុកមនុស្សដូចជាគម្រោងការមួយនៅក្នុងប្រវត្តិសាស្ត្រ ដែលកំពុងតែមានចលនា។ ដូច្នេះ ហើយបានជាអ្វីៗគ្រប់យ៉ាងដែលផ្ទុយនឹងឧបនិស្ស័យរបស់មនុស្ស អ្វីៗគ្រប់យ៉ាង ដែលរារាំងមិនឱ្យមនុស្សចូលទៅក្នុងចលនាកែប្រែពិភពលោកជាមួយនឹងមនុស្សឯទៀតៗ វាជា "រូបភាពមួយនៃហិង្សា"។

ការស្រាវជ្រាវអំពីមនុស្សអាចមានន័យបាន លុះត្រាតែការស្រាវជ្រាវនោះ មានទិសដៅឆ្ពោះទៅរកការកែលំអ "មនុស្សវណ្ណៈខ្ពស់" ឱ្យទៅជាមនុស្សពេញលក្ខណៈពិតប្រាកដ (មនុស្សបូជនីយកម្មនៃមនុស្ស)។ ប្រការនេះអាចសំរេចបានតែនៅក្នុងទំនាក់ទំនងរវាងមនុស្ស និងមនុស្សប៉ុណ្ណោះ។ មនុស្សវណ្ណៈខ្ពស់ ដែលគេស្វែងរកនៅក្នុងទស្សនៈបុគ្គលនិយម ភាគច្រើនគឺជា "អ្នកមានកំពូលដែលអាត្មានិយម" ដែលតាមពិតគេជា មនុស្សធុនអន់ ប៉ុណ្ណោះ។ ដូច្នេះហើយបានជា ការអប់រំបែបសេរីត្រូវធ្វើការអភិវឌ្ឍន៍ "មនុស្សវណ្ណៈខ្ពស់" ទៅរកការ "កែលំអខ្លួនឱ្យក្លាយទៅជាមនុស្សពេញលក្ខណៈពិតប្រាកដ"៕

ឯកសារពិគ្រោះ : "គរុកោសល្យនៃអ្នកដែលត្រូវគេគៀបសង្កត់ " របស់លោក ប៉ូ ឡូហ្វ្រែ

## ៧.៧_សុន្ទរកថាថ្លែងដោយ លោកស្រី ប្រូក ទ៉ាន្នី ប្រធានអង្គការខេមរា ស្ដីអំពី "ការកសាង និងលើកស្ទួយបណ្ដាញការងារសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធាន ពត៌មាន បទពិសោធន៍ និងក្ដីកង្វល់ "

បណ្ដាញការងារ : ជាប្រព័ន្ធទំនាក់ទំនង សហការគ្នាទៅវិញទៅមក ក្នុងការងារចែកចាយបទពិសោធន៍ ពត៌មានផ្សេងៗដំណឹងសំខាន់ៗដែលអាចរៀនសូត្រ អាចជាកម្លាំង ជាការជួយគាំទ្រជាសារតីឬមធ្យោបាយផ្សេងៗ ដែលអាចធ្វើបាន ដើម្បីឱ្យបានសម្រេចលទ្ធផលការងារ។

បណ្ដាញសង្គមស៊ីវិល កំពុងតែរីកចំរើនជាខ្លាំង ហើយកើតមានឡើង គ្រប់ទីកន្លែងតាំងពីក្រុង ខេត្ត រហូតដល់មូលដ្ឋាន :

* ប្រភេទបណ្ដាញសង្គមស៊ីវិលដែលមាន :

- ដែលកើតឡើងពីអង្គការដៃគូ នៃអង្គការម្ចាស់ទុន ដូចជា: អង្គការអុកស្វាម អង្គការស៊ីដសេ អង្គការ ប៉ាក ។ល។

  អង្គការម្ចាស់ទុនទាំងអស់នេះ បានចាប់យកអង្គការដែលគេផ្ដល់ទុនទាំងអស់ ធ្វើជាបណ្ដាញក្នុងការងារផ្សព្វផ្សាយពតីមានផ្សេងៗ។

- បណ្ដាញសង្គមស៊ីវិល ដែលកើតឡើងពីអង្គការដែលមានកម្មវិធីដូចគ្នា ដូចជា ៖ ក្រុមអង្គការសិទ្ធិមនុស្ស ក្រុមការងារដែលកើតឡើងពីអង្គការដែលមានអ្នកដឹកនាំជាស្ត្រី ក្រុមអង្គការដែលធ្វើការងារអភិវឌ្ឍន៍សហគមន៍ ក្រុមការងារសន្តិភាព ។ល។
- បណ្ដាញសង្គមស៊ីវិលដែលកើតឡើងពីផ្ដួចផ្ដើមរបស់អង្គការមួយ ហើយអង្គការដទៃទៀត ចុះឈ្មោះជាសមាជិក ដូចជា វេទិកាអង្គការក្រៅរដ្ឋាភិបាល (NGOs Forum) គណៈកម្មាការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) មេឌីកាម (MEDICAM)
- បណ្ដាញសង្គមស៊ីវិលដែលកើតឡើងពីផ្ដួចផ្ដើមរបស់អង្គការមួយ ដោយមានការរៀបចំ តាមបែបសហការរវាងអង្គការដទៃទៀត តាមការស្ម័គ្រចិត្ត ដូចជា អង្គការស្ដារកម្ពុជាដែលមានអង្គការសហការទាំងអស់ជាងសាមសិប ទាំងរាជធានី និងតាមបណ្ដាខេត្តនានា។
- បណ្ដាញសង្គមស៊ីវិលដែលកើតឡើងពីផ្ដួចផ្ដើមរបស់ក្រុមមនុស្សមួយក្រុមដែលបានទទួលការសិក្សាក្នុងវគ្គណាមួយរួមគ្នា ហើយពេលចប់វគ្គគេទាំងអស់គ្នា ក៏រៀបចំជាក្រុម ឬក៏ជាបណ្ដាញសំរាប់ធ្វើការហ្វឹកហ្វឺនបន្តទៅឱ្យអ្នកដទៃទៀត។ ក្រុមនេះមានក្រុមកាងារដើម្បីដោះស្រាយទំនាស់ (Alliance for Conflict Transformation ACT') ជាឧទាហរណ៍។

## សមិទ្ធិផលទទួលបាន :

→ រៀបចំគណៈកម្មការសំរាប់ផ្លាស់ប្តូរពត៌មានឬក៏ជួយដោះស្រាយបញ្ហាគ្នាទៅវិញទៅមក។

→ រៀបចំក្រុមសំរាប់បើកវគ្គហ្វឹកហ្វឺន និងធ្វើការអប់រំបន្តនៅតាមមូលដ្ឋាននៃក្រុមគោលដៅរបស់គេ។

→ បានរៀបចំផែនការយុទ្ធសាស្ត្ររួមគ្នា។

→ បានរៀបចំធ្វើយុទ្ធសាស្ត្ររួមគ្នាតាំងពីក្រុង រហូតដល់ជនបទ ឧទាហរណ៍: ក្រុមអង្គការមួយចំនួនបាននិងកំពុងធ្វើយុទ្ធនាការលុបបំបាត់អំពើហិង្សាលើស្ត្រីភេទ។

→ បានរៀបចំការប្រជុំរួមគ្នាជាប់ជាប្រចាំក្នុងមួយខែម្តងឬមួយត្រីមាសម្តង ទៅតាមសភាពការណ៍ជាក់ស្តែង។

→ ក្រុមអង្គការមួយចំនួនបានរៀបចំការងារនេះបានល្អប្រសើររហូតមានឱកាសផ្តល់ឱ្យសមាជិកបណ្តាញបាន ទទួលការហ្វឹកហ្វឺនកសាងសមត្ថភាព នៅក្នុងនិងក្រៅប្រទេសទៀតផង។

→ បានធ្វើការចែចាយពត៌មាន ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

## បទពិសោធន៍

* ចំណុចល្អគួរធ្វើបាន :

- បណ្តាញក្រុមការងារ ដែលរៀបចំឡើងតាមការឯកភាពយល់ព្រមពីសាមីខ្លួន ហើយដែលខ្លួនឯងផ្ទាល់មានឆន្ទៈនឹងចូលរួមនឹងបរិច្ចាគពេលវេលាសំរាប់មកចូលរួមជាមួយក្រុមផងដែរ។

- សមាជិកនៃក្រុមការងារ ពេលដែលបានទទួលពត៌មាន ឬក៏ទទួលលិខិតអញ្ជើញណាមួយរបស់ប្រធានក្រុម ឬសមាជិកក្រុមណាមួយ។ គួរផ្តល់ពត៌មានត្រឡប់ឱ្យអ្នកផ្តល់បានដឹង"ថាយើងបានទទួលពត៌មានហើយ" និងបញ្ជាក់ថា "អាចទៅចូលរួមឬមិនអាច" បើធ្វើបានបែបនេះ គឺជាការល្អបំផុត។

- បើយើងជា ប្រធានក្រុមបណ្តាញ ក៏គួរត្រូវផ្តល់ពត៌មានឱ្យសមាជិកមុនពេលប្រជុំ ឬក៏ព្យាយាមទាក់ទងផ្តល់ពត៌មានដល់សមាជិកឱ្យជាប់ជាប្រចាំផង។ បើមិនដូច្នេះទេ បណ្តាញការងារនឹងត្រូវចាប់ផ្តើមបាត់ជាបណ្តើរៗ ជាក់ជាមិនខាន។ ជាប្រធានក្រុមការងារក៏គួររៀបចំគម្រោងការងារណាមួយ ដែលត្រូវតែឱ្យមានដំណើរការជាប់ជាលំដាប់ផងដែរ ឬក៏លើកផែនការការងាររួមគ្នាជាមួយសមាជិកនិងកំណត់ថ្ងៃចុះសកម្មភាពការងាររួមគ្នាឱ្យហើយ ប៉ុន្តែ ត្រូវតែផ្តល់ពត៌មានរំលឹកដែរ មុនពេលអនុវត្តការងារ។

ការថែរក្សាបណ្តាញការងារ គឺជាការងារមួយសំខាន់ណាស់ ព្រោះថា បើបណ្តាញការងារកើតមានឡើង តែក្នុងករណីចាំបាច់ណាមួយតែប៉ុណ្ណោះទេ នោះដូចជាមិនគួររៀបឱ្យមានសោះឡើយ។

- ការបង្កើតបណ្តាញវាជាកិច្ចការមួយមិនលំបាកខ្លាំងក្លា ដូចគ្នានឹងការថែទាំបណ្តាញឱ្យមានស្ថេរភាពជាប់ជាលំដាប់នោះទេ។ តាមបទពិសោធន៍ ការរក្សាបណ្តាញឱ្យនៅឋិតថេរ មានការទាក់ទង នឹងពីរចំណុច :

  - បុគ្គលខ្លួនឯងស្ម័គ្រចិត្ត ចូលរួមធ្វើជាសមាជិកក្រុមបណ្តាញការងារដោយឆន្ទៈផ្ទាល់និងមានការប្តេជ្ញាចិត្តខ្ពស់។
  - បុគ្គលដែលមានការគាំទ្រពីសាមីអង្គការ ដែលបានយល់ព្រមអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួនចូលរួមប្រជុំឬធ្វើសកម្មភាពផ្សេងៗ ជាមួយក្រុម នោះដំណើរការងារបណ្តាញមានប្រសិទ្ធភាពដែរ។ ប៉ុន្តែ ពេលដែលប្រធាននៃសាមីអង្គការមិនយល់ព្រម ហើយសាមីខ្លួនផ្ទាល់មិនសូវមានការចាប់អារម្មណ៍លើការងារនោះដែរ បណ្តាញការងារនេះក៏ចាប់ផ្តើមបាត់បន្តិចម្តងៗដែរ។

* ចំណុចកង្វល់

- ទស្សនៈដែលគិតប្រយោជន៍ផ្ទាល់ខ្លួន ធំជាងផលប្រយោជន៍របស់ក្រុម។ ឧទាហរណ៍ ការចូលជាសមាជិកបណ្តាញដើម្បីទាមទាររក

ប្រយោជន៍រកលាភសក្ការៈ ដែលបុគ្គលខ្លួនផ្ទាល់រំពឹងថា បុគ្គលខ្លួននឹងបានទទួល នាពេលខាងមុខ។ ប៉ុន្តែផ្ទុយទៅវិញ ដែលមិនបានដូចការប៉ងទុកនោះ ជួនកាលបុគ្គលបែបនេះចូលរួមប្រជុំសំរាប់ជាការរំខាន និងរាំងស្ទះអង្គប្រជុំទៀតតែប៉ុណ្ណោះ។

- ការរៀបចំឱ្យមានបណ្តាញជាការមួយល្អណាស់ ប៉ុន្តែ ការដែលបារម្ភ គឺការដែលធ្វើឱ្យសង្គមកម្ពុជាទាំងមូលយល់ថា "បណ្តាញការងាររបស់សង្គមស៊ីវិល រៀបចំឡើងសំរាប់ពង្រឹងការងារបង្កើនការយល់ដឹង ធ្វើឱ្យមានភាពជឿនលឿន ភាពរីកចំរើននៃសង្គមស៊ីវិល"។ មានមតិមួយចំនួនបានយល់ថា បណ្តាញការងាររបស់សង្គមស៊ីវិលគឺជាក្រុមដែលធ្វើឡើងដើម្បីប្រឆាំងឬដើម្បីរំខាន។

## ៧.៨_សុន្ទរកថាថ្លែងដោយ លោកស្រី ជូ ប៊ុនអេង អគ្គលេខាធិការ នាយកប្រតិបត្តិ អង្គការស្ត្រីកម្ពុជា ដើម្បីសន្តិភាព និង អភិវឌ្ឍន៍ស្ដីអំពី "ការកសាងនិងលើកស្ទួយបណ្ដាញការងារសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធាន ពត៌មាន បទពិសោធន៍ និងក្ដីកង្វល់"

នាងខ្ញុំ ជូ ប៊ុនអេង នាយកប្រតិបត្តិ សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវិទ្យាស្ថានខ្មែរ សំរាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាព ដែលបានផ្ដល់ឱកាស ឱ្យនាងខ្ញុំបានមកចូលរួមក្នុងសន្និសីទដ៏មានសារៈសំខាន់នេះនិងបានចែករំលែក នូវបទពិសោធន៍ជាមួយអង្គការសង្គមស៊ីវិលដទៃទៀត។

អង្គសន្និសីទនេះ ក៏ដូចជាសិក្ខាសាលា និងកិច្ចប្រជុំពិភាក្សានានាដែរបានផ្ដល់នូវសារៈប្រយោជន៍ជាច្រើនដល់យើងទាំងអស់គ្នា តាមរយៈការជជែកវែកញែកពិភាក្សាផ្លាស់ប្ដូរយោបល់ និងបទពិសោធន៍រវាងគ្នាទៅវិញទៅមក។ នេះគឺជាវិធីសាស្ត្រមួយសំរាប់ការចែករំលែកនូវធនធានពត៌មាន និងបទពិសោធន៍របស់យើងនៅក្នុងអង្គការសង្គមស៊ីវិល។

មុននឹងចូលដល់ការផ្លាស់ប្ដូរបទពិសោធន៍ ខ្ញុំសូមជំរាបជូនត្រួសៗ អំពីសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ដែល

ជាសមាគមមួយធ្វើសកម្មភាពផ្តោតការយកចិត្តទុកដាក់ទៅលើនារី និងសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រជាមួយរដ្ឋាភិបាល និងអង្គការសមាគម ដែលជាសង្គមស៊ីវិលដទៃទៀត។ ការធ្វើសកម្មភាព ដោយផ្តោតទៅលើនារី មិនមានន័យថា សមាគមមិនចាប់អារម្មណ៍ ចំពោះសកម្មភាពសំរាប់បុរសនោះទេ តែគ្រាន់តែមានគោលបំណងមួយចង់ឱ្យនារីបានទទួលនូវឱកាស ធនធាននិងផលប្រយោជន៍សមស្រប និងអាចឈានចូលទៅប្រឡូក ក្នុងតួនាទីសង្គមឱ្យបានពេញលេញជាមួយបុរសតែប៉ុណ្ណោះ។

សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍មានកម្មវិធីស្នូលបីធំៗគឺ : កម្មវិធីអភិវឌ្ឍន៍ ក្នុងនោះមានទាំងការបណ្តុះបណ្តាលធនធានមនុស្សផងដែរ បន្ទាប់មក គឺកម្មវិធីលើកកំពស់សុខភាព និងការផ្សព្វផ្សាយពត៌មាន។ ក្រៅពីនេះសមាគមបានរួមសហការជាមួយអង្គការសង្គមស៊ីវិលដទៃទៀត បើកវគ្គបណ្តុះបណ្តាលអំពី យេនឌ័រ មគ្គុទ្ទេសភាព និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ និងនយោបាយជាដើម។ ជាញឹកញាប់យើងមានកម្មវិធីជួបពិភាក្សាជា មួយក្រុមការងារអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៃអង្គការមិនមែនរដ្ឋាភិបាលនិងកិច្ចពិភាក្សាពិគ្រោះយោបល់ជាច្រើនទៀត។

ជាបទពិសោធន៍ ក្នុងការចែករំលែកធនធានពត៌មាន និងបទពិសោធន៍រវាងគ្នា ពីអង្គការមួយទៅអង្គការមួយ គឺច្រើនតែជាបទ

ពិសោធន៍ ដែលទាក់ទងទៅនឹងគោលបំណង ឬផលប្រយោជន៍នៃអង្គការរបស់ខ្លួន ដែលមានប្រហាក់ប្រហែលគ្នា។ តែទោះជាយ៉ាងណាក៏កន្លងមក អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាសង្គមស៊ីវិលនានាបានចូលរួមចំណែក ក្នុងការធ្វើសកម្មភាពនៃតំរោងនានា ដោយបង្កើតបានជាសមិទ្ធិផលយ៉ាងធំធេង ដើម្បីផ្តល់ជាសេវាដល់សង្គមជាតិស្ទើរតែគ្រប់ប្រកល្អក។ ប៉ុន្តែ ទោះជាយ៉ាងណា ក៏ការប្រឹងប្រែង នេះនៅមានកំរិតអាស្រ័យដោយកត្តាបីយ៉ាងគឺ :

- សមត្ថភាពផ្ទាល់របស់អង្គការអនុវត្តកម្មវិធី
- ជំនួយឧបត្ថម្ភមានកំរិតទៅតាមមុខសញ្ញា
- លទ្ធភាពរបស់សហគមន៍ ក្នុងការទទួលយក។

ក្នុងចំណោមកត្តាទាំងបីនេះ កត្តាសមត្ថភាពផ្ទាល់របស់អង្គការគឺជាចំណុចសំខាន់ ព្រោះវាជាកត្តាចាំបាច់ ដែលធ្វើឱ្យកម្មវិធីមួយទទួលជោគជ័យឬបរាជ័យ។ កត្តានេះទាក់ទងទៅនឹងធនធានមនុស្សធនធានថវិកា មធ្យោបាយ គំនិតផ្តួចផ្តើម វិធីសាស្ត្រអនុវត្ត ឆន្ទៈ ការប្តេជ្ញាចិត្ត ការកំណត់ទិសដៅ គោលបំណង និងបេសកកម្មរបស់អង្គការ។

រីឯជំនួយឧបត្ថម្ភ គឺជាកត្តាកំណត់ ដែលធ្វើឱ្យសកម្មភាពមួយមានដំណើរការ។ ជាធម្មតា ជំនួយទាំងឡាយកំណត់ទៅតាមល័ក្ខខ័ណ្ឌរបស់ម្ចាស់ជំនួយ ដែលស៊ីចង្វាក់គ្នាទៅនឹងល័ក្ខខ័ណ្ឌរបស់អង្គការទទួលជំនួយ។ តែទោះជាយ៉ាងណាក៏ជំនួយនេះ មានចំនួននិងពេលវេលាកំណត់ ដែលអ្នកអនុវត្តត្រូវតែបត់បែនតាម។ ដូច្នេះ ក្នុងរយៈពេលដ៏ខ្លី

នៃជំនួយចាំបាច់ណាស់ ដែលអង្គការទទួលជំនួយ ត្រូវតែប្រើប្រាស់ឱ្យចំទិសដៅ និងតំរង់ទិសទៅរកផលប្រយោជន៍និងសេចក្តីត្រូវការពិតប្រាកដរបស់សហគមន៍។

នៅពេលអនុវត្តគម្រោង លទ្ធផលទទួលយករបស់សហគមន៍ គឺជាកត្តាសំខាន់។ លទ្ធភាពនេះ មានទ្រង់ទ្រាយខុសៗគ្នា ពីសហគមន៍មួយទៅសហគមន៍មួយ ដែលអ្នកអនុវត្ត ត្រូវតែស្គាល់ឱ្យច្បាស់ និងរកគន្លឹះដើម្បីឱ្យសហគមន៍របស់ខ្លួនចូលរួមក្នុងកម្មវិធីប្រកបដោយជោគជ័យ។

ក្នុងតួនាទីជាសង្គមស៊ីវិល សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក៏ដូចជាអង្គការ សមាគមដទៃទៀតដែរ បានប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីសហការ និងមិនប្រកាន់នូវទស្សនៈនិន្នាការ ឬប្រភេទអង្គការឡើយ ពោលគឺឱ្យតែមានគោលដៅ គោលបំណងប្រហាក់ប្រហែលគ្នា គឺយើងអាចសហការគ្នាបាន។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះការយកចិត្តទុកដាក់ស្តាប់របស់អង្គសន្និសីទ និងត្រៀមចាំទទួលនូវការផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ទាំងឡាយ ពីបណ្តាអង្គការនិងវាគ្មិនដទៃទៀត៕

## ៧.៩_សុន្ទរកថាថ្លែងដោយ លោកបណ្ឌិត ហង្ស ពុន្ធា ប្រធានសមាគមវិចិត្រសិល្បៈ និងជានាយកប្រតិបត្តិ គណៈកម្មាធិការអព្យាក្រឹត យុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរីនៅកម្ពុជា ស្តីអំពី "ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធាន ព័ត៌មាន បទពិសោធន៍ និងក្តីកង្វល់"

ជាបឋមខ្ញុំសូមឆ្លៀតឱកាសសម្តែងនូវការគោរព និងកោតសរសើរចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ដែលបានបន្ត ប្រពៃណីការងាររបស់ខ្លួនជាជំហានៗនិងជាខ្សែចង្វាក់ ដែលទោះជាក្នុងស្ថានភាពយ៉ាងណាក៏ដោយវិទ្យាស្ថានបានជម្រុញការយកចិត្តទុកដាក់ជាពិសេសដល់ការងារនៃសង្គមស៊ីវិល។ នៅថ្ងៃនេះដែរ យើងមានឱកាសមកពីបណ្តាញការងារផ្សេងៗបានអង្គុយជាមួយគ្នា បង្ហាញគំនិតនិងពិភាក្សាគ្នា ឆ្ពោះទៅរកការងារឯកភាព និងយល់ចិត្ត យល់ថ្លើមគ្នាដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។

ចំពោះប្រធានបទ ដែលលើកឡើងពីការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា ការចែករំលែកធនធានពត៌មាន បទពិសោធន៍ និងក្តីកង្វល់ ខ្ញុំបាទសូមសម្តែងជាមតិខ្លះៗ ដើម្បីថ្វាយ និងផ្តល់ជូនអង្គសន្និសីទ។

## I. ការកកើតឡើងនៃសង្គមស៊ីវិល :

សង្គមស៊ីវិលបានកើតឡើងនៅពេលដែលមានសង្គមមនុស្ស ប៉ុន្តែមនុស្សខ្លួនឯងពុំបានដាក់ចំណងជើងខ្លួនឯងថា ជាសង្គមស៊ីវិលឬជាសង្គមយោធានោះទេ។ ផ្អែកលើប្រវត្តិសាស្ត្រនៃការរីកចំរើន របស់មនុស្សជាតិ សង្គមមនុស្សត្រូវការ ការអភិវឌ្ឍន៍ជាចាំបាច់ និងត្រូវការអ្នកដឹកនាំនៃកិច្ចអភិវឌ្ឍន៍សង្គមប្រកបដោយប្រសិទ្ធិភាព។

ក្នុងការដឹកនាំ ឬចូលរួមការងារដឹកនាំសង្គមមនុស្ស តែងមានទស្សនៈខុសៗគ្នា។ ខ្លះយល់ថា : ដើម្បីសង្គមរីកចំរើនត្រូវដឹកនាំតាមបែបអាជ្ញាយោធា តាមបែបបុព្វកាលតាមបែបសេរីនិយម តាមបែបកុម្មុយនីស្តនិយម តាមបែបរាជានិយម ឬតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ដូចមាគ៌ានៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន។ ការខ្វែងទស្សនៈគ្នាបានធ្វើឱ្យពិភពលោកមានការបែងចែកគ្នា ឧទាហរណ៍ ប្លុកនៃប្រទេសលោកសេរីប្លុកនៃប្រទេសកុម្មុយនីស្ត ប្លុកនៃប្រទេសដែលប្រកាន់អព្យាក្រឹត ។ល។និង។ល។

យើងឃើញហើយថា : ការរីកចំរើនតាមបែបកុម្មុយនីស្តនិយមមានសន្ទុះយឺតជាងការរីកចំរើនតាមបែបសេរីនិយម។ ដូច្នេះ ពិភពលោកមានការកែទម្រង់មួយយ៉ាងធំដែលបណ្តាប្រទេសសង្គមនិយម កុម្មុយនីស្តស្ទើរតែរលំរលាយអស់។

ក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិឃើញថា នៅគ្រប់ប្រទេសមានស្ថាប័នជំនាញៗដូចជា : ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ អង្គការសារពត៌មាន។ល។ ការកកើតឡើងនៃស្ថាប័ន និងអង្គការខាងលើ

គឺជាសំណូមពរចាំបាច់នៃការអភិវឌ្ឍន៍សង្គម។ ប៉ុន្តែសង្គមនៅតែត្រូវការរីកចំរើនទៀត ដែលបរាក់បង្ហាញថា : ត្រូវការសង្គមស៊ីវិលចូលរួមផងដែរ។

ពាក្យថា "សង្គមស៊ីវិល" ត្រូវបានប្រើប្រាស់ជាបឋម មិនមែននៅប្រទេសកម្ពុជាយើងនេះទេ។ ពាក្យថា "សង្គមស៊ីវិល" ត្រូវបានប្រជាពលរដ្ឋទទួលយក ក្រោយពេលមានការចុះហត្ថលេខាសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលបន្ទាប់មក UNTAC មករៀបចំការបោះឆ្នោតនៅកម្ពុជា។ ពាក្យថាសង្គមស៊ីវិលប្រែក្លាយជាបញ្ញតិមួយ និងត្រូវបានទទួលការគាំទ្រពីស្ថាប័នព្រះមហាក្សត្រ ស្ថាប័ននីតិប្បញ្ញតិ រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ និងសាធារណៈមតិជាតិ និងអន្តរជាតិ។

តម្លៃនៃសង្គមស៊ីវិល ដែលកន្លងមកប្រើពាក្យថា : ជាអង្គការសមាគម មិនមែនរដ្ឋាភិបាល។ល។និង។ល។ គឺបិតនៅត្រង់សង្គមស៊ីវិលខ្លួនឯងមានគោលការណ៍ច្បាស់លាស់។ ឧទាហរណ៍ មានអព្យាក្រឹតភាព មិនប្រើហឹង្សាយកការសំរបសំរួលជាធំៗ។ល។ មកទល់ពេលនេះ បណ្តាញសង្គមស៊ីវិលមានគ្រប់ទិសទីក្នុងទូទាំងប្រទេសនិងនៅលើឆាកអន្តរជាតិ។ ដូច្នេះ អាចនិយាយបានថា : នៅកម្ពុជាមានបណ្តាញសង្គមស៊ីវិលដ៏រឹងមាំគួរសមហើយដែរ។

## II. ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា :

សង្គមស៊ីវិលនៅកម្ពុជា ត្រូវបានកសាងឡើងដោយប្រជាពលរដ្ឋកម្ពុជា ដែលមានអ្នកដឹកនាំនៃសង្គមស៊ីវិល មានសមត្ថភាព មានការ

គាំទ្រពីរាជរដ្ឋាភិបាល ដូចជាមានការអនុញ្ញាតឱ្យចុះឈ្មោះ នៅក្រសួងមហាផ្ទៃ ទីស្ដីការគណៈរដ្ឋមន្ត្រី និងមានសហការល្អដោយ អាជ្ញាធរដែនដី និងអង្គភាពគ្រប់ជំនាញពាក់ព័ន្ធ។ បណ្ដាប្រទេសជិតឆ្ងាយឬអង្គការអន្តរជាតិក៏គឺជាអ្នកគាំទ្រយ៉ាងសកម្ម ដូចជាការផ្ដល់ប្រាក់ជំនួយសំរាប់អង្គការ សមាគមមិនមែនរដ្ឋាភិបាលឬលើកឡើងជាគោលការណ៍ថា ជំនួយឬប្រាក់កម្ចីនេះ ត្រូវមានការចូលរួមសង្កេតការណ៍ពីអង្គការនៃសង្គមស៊ីវិលក្នុងការប្រើប្រាស់ធ្វើសកម្មភាព។ល។ ពាក្យថា "សង្គមស៊ីវិលឬអង្គការក្រៅរដ្ឋាភិបាល " បានក្លាយជាពាក្យប្រជាប្រិយហើយដែរ។ ឧទាហរណ៍ មានម្ហូបមួយឈ្មោះថា: "ភ្លាក្រៅអង្គការ "....។

ខ្ញុំសូមឯកភាពចំពោះវាគ្មិនខាងដើម ដែលបានលើកឡើងស្ដីពីការកសាងបណ្ដាញការងារនៃសង្គមស៊ីវិល :

- តើគួររៀបចំបណ្ដាញការងារយ៉ាងណា?
- ហេតុអ្វីបានត្រូវមានបណ្ដាញការងារនេះ?
- តើអ្នកណាអាចជាសមាជិកនៃបណ្ដាញនេះ?
- តើគួរលើកឡើង នូវប្រធានបទយ៉ាងណាសំរាប់បណ្ដាញការងារ?
- ការចាប់ផ្ដើម និងកន្លែងប្រជុំសំរាប់បណ្ដាញការងារ
- .................។ល។ និង។ល។

សម្តេច ឯកឧត្តម លោកជំទាវ លោកស្រី ជ្រាបហើយថា តើអ្នកណាអាចជាសមាជិកនៃបណ្តាញនៃសង្គមស៊ីវិល? កន្លងមកមានការយល់ថា: មន្ត្រីរាជការរបស់រាជរដ្ឋាភិបាល មន្ត្រីនគរបាលជាតិ មន្ត្រីនៃកងយោធពលខេមរភូមិន្ទ មិនអាចជាសមាជិកនៃបណ្តាញ សង្គមស៊ីវិលបានទេ។

ខ្ញុំបាទយល់ថា មន្ត្រីរាជការរបស់រដ្ឋាភិបាល មន្ត្រីនគរបាលជាតិ មន្ត្រីនៃកងយោធពលខេមរភូមិន្ទក៏អាចជាសមាជិកបណ្តាញការងារសង្គមស៊ីវិលបានដែរ។ ប៉ុន្តែបញ្ហាបិតនៅត្រង់ដែលថា ខ្លួនមិនប្រើប្រាស់វេទិការបស់សង្គមស៊ីវិលបំរើឱ្យការងារអង្គភាពខ្លួន។

ព្រោះបច្ចុប្បន្នយើងឃើញថា មានមន្ត្រីរាជការមួយចំនួនដូចជាគ្រូបង្រៀនជាដើមបានបង្កើតសមាគម ហើយដំណើរការបានជោគជ័យមួយចំនួន និងមានការគាំទ្រពីរាជរដ្ឋាភិបាល និងអង្គការអន្តរជាតិផងដែរ។

## III. បទពិសោធន៍ក្តីបារម្ភណ៍ និងសំណូមពរ :

១_ការកកើតសង្គមស៊ីវិលនៅកម្ពុជា គឺជាបញ្ហាក្មេងខ្ចី ទាំងមន្ត្រីរាជរដ្ឋាភិបាល មានការយល់ដឹងនៅមានកំរិតទាបនៅឡើយ។ ដូច្នេះទើបបានជាយើងសង្កេតឃើញថា មានពេលខ្លះ មានការចោទប្រកាន់គ្នាថា ប៉ូលីសរំលោភសិទ្ធិមនុស្ស ហើយមន្ត្រីរបស់អង្គការមិនមែនរដ្ឋាភិបាលជាអ្នកការពារចោរ។ល។ និង។ល។ បញ្ហានេះគួរតែត្រូវបានដោះស្រាយដោយការយោគយល់គ្នា អង្គុយរួមគ្នាដើម្បីពិភាក្សា ហើយមន្ត្រីរាជរដ្ឋាភិបាល មិនគួរគិតថា មានគណបក្សនៅពីក្រោយខ្នងសង្គមស៊ីវិលទេ។

ទាំងអស់គ្នា គួរតែជាអ្នកមានសមត្ថភាព មានសុជីវធម៌មាន តម្លាភាព មានអព្យាក្រឹតភាព មានទស្សនៈលទ្ធិប្រជាធិបតេយ្យ និងស្មារតីសម្របសម្រួលគ្មានហិង្សានិងគ្មានការមួលបង្កាច់គ្នា។

២_ក្នុងស្ថានភាពដែលប្រទេសកម្ពុជា នៅមានការផ្ទុះអាវុធមានគណបក្សមានអំណាច មានគណបក្សសម្ព័ន្ធភាព មានគណបក្សប្រឆាំង គួរតែមេដឹកនាំគណបក្សទាំងអស់ បង្កលក្ខណៈឱ្យអង្គការនៃសង្គមស៊ីវិលឈរឱ្យបានអព្យាក្រឹតល្អ ទប់ស្កាត់ការបង្កើតជាអង្គការបំរើគណបក្សមិនអនុញ្ញាតឱ្យសកម្មជនរបស់គណបក្សជ្រកក្រោមផ្លាកសង្គមស៊ីវិល។ បុគ្គលណាដែលស្រឡាញ់ការងារគណបក្ស គួរតែចេញផុតពីសង្គមស៊ីវិលនិងគួរប្រកាន់ខ្ជាប់យុត្តិធម៌សង្គម។

៣_តុលាការត្រូវតែឯករាជ្យ។ អ្នកប្រព្រឹត្តខុសច្បាប់ មានទោសដូចគ្នា ។ល។និង។ល។

៤_មន្ត្រីនៃអង្គការសង្គមស៊ីវិលខ្លួនឯង គួរបង្កើនការយល់ដឹងឱ្យក្លាយជាអ្នកមានសមត្ថភាពពិតប្រាកដ ថ្លៃថ្នូរ និងមានសហការល្អជាមួយរាជរដ្ឋាភិបាល ទើបបណ្ដាញសង្គមស៊ីវិលរឹងមាំ។

៥_អង្គការសង្គមស៊ីវិលត្រូវមានការប្រជុំទៀងទាត់និងរកឱ្យឃើញបញ្ហាប្ដូរយោបល់គ្នាលើកផែនការដោះស្រាយនិងអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់។

៦_គួរបង្កើតជាកម្មវិធីសំវាចារិទ្យុ ឬទូរទស្សន៍ផ្សព្វផ្សាយអំពីសកម្មភាពល្អៗនៃអង្គការមិនមែនរដ្ឋាភិបាល។

សរុបសេចក្ដីមក :

កត្តាជោគជ័យនៃសង្គមស៊ីវិល គឺពឹងផ្អែកលើយើងទាំងអស់គ្នា។ ខ្ញុំយល់ថាមិនពិបាកទេ ឱ្យតែមានការព្យាយាម ព្រោះយើងមាន :

១. ប្រជាពលរដ្ឋចូលរួមកុះករ

២. មានក្រុមដឹកនាំ ដែលមានសមត្ថភាព

៣. មានការគាំទ្រ និងឧបត្ថម្ភពីអង្គការអន្តរជាតិ

៤. មានបណ្ដាញសង្គមស៊ីវិលនៅលើសកលលោកផ្ដល់បទពិសោធន៍

៥. មានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការបង្ហាញសមត្ថភាពចូលរួមចំណែកធ្វើឱ្យមានការរីកចំរើនបន្តឈានការពារដំណែលដូនតាកម្ពុជា ដែលធ្លាប់មានឈ្មោះជាមហានគរ មានប្រពៃណីថ្លៃថ្នូរ សុភាពរាបសារនិងឧស្សាហ៍ព្យាយាម។

នាទីបញ្ចប់នេះ ខ្ញុំសូមអនុញ្ញាតប្រសិទ្ធពរជូន សម្ដេចក្រុមឃុន ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងសមាជិក សមាជិកានៃអង្គសន្និសីទ ជួបប្រទះតែនឹងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ៕

## ៧.១០_សុន្ទរកថាថ្លែងដោយឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា នាយកដេប៉ាតឺម៉ង់ទស្សនវិជ្ជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ក្រុមការងាររាជបណ្ឌិតសភាកម្ពុជា អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពស្តីអំពី "សកលភាវូបនីយកម្ម និងផលប៉ះពាល់មកលើសង្គមស៊ីវិលកម្ពុជា : ការគ្រប់គ្រងតម្លៃចាយវាយ និងទាញយកផលប្រយោជន៍ឲ្យអតិបរិមា"

## I. សេចក្តីផ្តើម

កម្ពុជាបានឆ្លងកាត់មាគ៌ាដ៏ច្រើននៅក្នុងជីវិតរបស់ខ្លួន ដូចដែលប្រវត្តិសាស្រ្តបានបញ្ជាក់ស្រាប់។ នៅក្នុងសម័យរុងរឿង ប្រជាជនមានវឌ្ឍនភាព ដូចក្នុងសម័យមហានគរជាឧទាហរណ៍។ ផ្ទុយទៅវិញ នៅក្នុងសម័យអាប់ឱន ប្រជាជនបាត់បង់កិត្តិយស និងអំណាចរបស់ខ្លួន ដោយឆ្លងកាត់សង្គ្រាមយ៉ាងជូរចត់ខ្លោចផ្សា។ នោះជាមេរៀនដែលគ្រប់ប្រទេសនៅក្នុងពិភពលោកសុទ្ធតែបានបញ្ជាក់ថា សង្គ្រាមជាប្រភពនៃគ្រប់គ្រោះមហន្តរាយ។

ពេលនេះ ប្រទេសទាំងអស់នៅក្នុងពិភពលោករួបរួមសហការ និងកសាងមូលដ្ឋានសន្តិភាព ភាតរភាព និងមិត្តភាព។ គំនិតឈ្លានពានលុកលុយពីប្រទេសមួយទៅប្រទេសមួយ ជាគំនិតអន់ថយ។ នៅចំពោះមុខស្ថានការណ៍នេះ ប្រជាជនកម្ពុជាដ៏អង់អាចក្លាហានត្រូវតស៊ូ

យ៉ាងប្តូរផ្តាច់ សំរាប់អត្ថិភាពរបស់ខ្លួនក្នុងពេលសព្វថ្ងៃផង និងសំរាប់មនុស្សជំនាន់ក្រោយផង។ ប្រជាជនកម្ពុជា ត្រូវតែគិតពិចារណាអំពីឱកាស ការប្រលងប្រណាំង និងចក្ខុវិស័យអនាគតដែលត្រូវចាប់ផ្តើមដោះស្រាយដោយមិនគ្រាន់តែនៅក្នុងចំណោមខ្មែរទាំងអស់គ្នាទេ តែត្រូវពិចារណាដោះស្រាយជាមួយប្រជាជនដទៃទៀតផង។ ការពង្រឹងនិងការពង្រីកអត្ថិភាពរបស់ខ្លួន ជាមួយប្រជាជាតិដទៃ ដើម្បីសន្តិសហវិជ្ជមាន គឺជាកត្តាចាំបាច់មិនអាចខ្វះបានឡើយ។

ក្នុងឋានៈជាប្រទេសមួយ ស្ថិតនៅក្នុងប្រទេសតតិយលោក កម្ពុជាត្រូវខិតខំចងមិត្តជាមួយប្រជាជាតិដទៃទៀត ជាពិសេសជាមួយសមាជិកនៃអាស៊ាន (ASEAN)។ យោងតាមកំណែទម្រង់គ្រប់វិស័យ យើងចង់កសាងកម្ពុជាប្រកបដោយសណ្តាប់ធ្នាប់ល្អ។ ការផ្តួចផ្តើមមតិដើម្បីបង្កើតសណ្តាប់ធ្នាប់កម្ពុជាថ្មីនេះ អាចនឹងត្រូវវាយតម្លៃថា ជាអ្វីដែលប្រជាជនកម្ពុជា រួមចំណែកពង្រឹងពង្រីកសិទ្ធិមនុស្ស សេរីភាព និងប្រជាធិបតេយ្យ។ គំនិតនេះអាចទទួលជោគជ័យបានដោយអវត្តមាននៃហិង្សា ឬដោយវត្តមាននៃការអត់ឱននិងយុត្តិធម៌។ ការបណ្តុះស្មារតីអត់ឱន យោគយល់គ្នាទៅវិញទៅមក នៅក្នុងសង្គមជាតិរបស់យើងជាកត្តាកំណត់ក្នុងការពង្រឹងអត្តសញ្ញាណជាតិឡើងវិញ បន្ទាប់ពីយើងបែកបាក់គ្នាអស់រយៈពេលជាច្រើនឆ្នាំមក។

ពេលនេះ ជាពេលដែលយើងត្រូវចោទសួរពីអ្វី ដែលយើងត្រូវធ្វើដើម្បីមាតុភូមិរបស់យើង នៅចំពោះមុខទិសដៅរួមនៃសកលលោក។

ពិតណាស់ យើងមិនអាចរស់នៅឯកោបានឡើយ ប្រសិនបើយើងបិទទ្វារ យើងនឹងស្លាប់។ យើងត្រូវបើកទ្វារចំហគ្រប់ទិសទី ប៉ុន្តែនៅពេលដែលយើងបើកទ្វារចំហ ផ្លុំទាំងពីរ_ល្អ និងអាក្រក់នៃសាកលភាវូបនីយកម្ម ពិតជាឈានជើងចូលមកដល់សង្គមយើង។ យើងត្រូវក្លាហាន និងតស៊ូដើម្បីកាត់បន្ថយផ្លុំអវិជ្ជមាននៃសាកលភាវូបនីយកម្ម ដោយសារការប្រើប្រាស់វិចារណញ្ញាណរបស់យើង។ ក្នុងករណីនេះ បើយើងមិនបើកទ្វារចំហក៏យើងស្លាប់ តែបើយើងបើកទ្វារចំហ ដោយខ្វះការពិចារណាក៏យើងស្លាប់ដែរ។

## II. បរិបទពិភពលោក សាកលភាវូបនីយកម្ម សាកលនិយម

### ១. បរិបទពិភពលោក

សភាពឯកោ ដែលធ្លាប់មាននៅក្នុងសង្គមបុព្វកាល ឬនៅក្នុងសង្គមទាសភាព ត្រូវរលាយបាត់បង់តាំងពីយូរយាណាស់មកហើយ។ ទំនាក់ទំនងសកលបាននឹងកំពុងរីករាលដាល។ ពិភពលោកមានទំនោរទៅរកលក្ខណៈរួមមួយ មានទំនោរទៅរកទំនាក់ទំនងទៅវិញទៅមក និងសាកលភាវូបនីយកម្មស្តីពីល័ក្ខខ័ណ្ឌសេដ្ឋកិច្ច បច្ចេកវិជ្ជាសង្គម និងវប្បធម៌។ ទិដ្ឋភាពដ៏សំខាន់នៃបំរែបំរួលខាងបច្ចេកវិជ្ជាគឺជាបដិវត្តន៍ខាងទូរគមនាគមន៍។ គឺបដិវត្តន៍ទូរគមនាគមន៍នេះហើយ ដែលធ្វើឱ្យផែនដីរបស់យើងហាក់ដូចជានៅរួញតូចត្រឹមតែជាភូមិមួយប៉ុណ្ណោះ។ លោក សាពួរ រ៉ាសិច (Shapour Reassekh) បានសរសេរថា :

*"ទិដ្ឋភាពដ៏សំខាន់ នៃបំរែបំរួលខាងបច្ចេកវិជ្ជា ដែលកំពុងកោតឡើង គឺបដិវត្តន៍ទូរគមនាគមន៍ ដែលធ្វើឱ្យពិភពលោកមានទំហំត្រឹមតែជាភូមិធំមួយប៉ុណ្ណោះ" (៥_ទំព័រទី១១) ។*

ក្នុងករណីនេះ ប្រជាជាតិនីមួយៗ អាចទទួលពត៌មានយ៉ាងឆាប់រហ័សដោយសារមធ្យោបាយទូរគមនាគមន៍ផ្សេងៗដូចជា សាតែលីត (Satellites) កុំព្យូទ័រ (Computers) វិទ្យុ (Radios) ទូរទស្សន៍ (Televisions) ហ្វាក់ និងអ៊ីមែល (Fax and E-mail) ទូរស័ព្ទចល័ត (Mobile Phones) និងបណ្តាញអ៊ីនធឺរណេត (Network of Internet)ជាដើម។ ឧបករណ៍ ទាំងនេះកំពុងជម្រុញឱ្យមនុស្សក្នុងពិភពលោកមានទំនាក់ទំនងជាមួយគ្នាយ៉ាងឆាប់រហ័ស ដោយឥតគិតអំពីជាតិសាសន៍និងពណ៌សម្បុរឡើយ។

ដើម្បីគូសបញ្ជាក់បញ្ហានេះ លោក អង់តូនី ហ្គីដិន (Anthony Giddens) អះអាងថាៈ " សាតែលីត ពាណិជ្ជកម្មទី១ ត្រូវបានបង្ហោះនៅក្នុងឆ្នាំ១៩៦៩។ ឥឡូវនេះ មានសាតែលីតបែបនេះជាង ២០០នៅលើផែនដី ហើយសាតែលីតនីមួយៗ កំពុងទទួលពត៌មានយ៉ាងច្រើន "(①_ទំព័រទី១១)។ នោះជាទម្រង់មួយនៃសាកលភាវូបនីយកម្ម។ វាគូសបញ្ជាក់អំពីការរីកចំរើននៃបច្ចេកវិជ្ជា ដែលធ្វើឱ្យមនុស្សកាន់តែឈានទៅធ្វើជាម្ចាស់លើធម្មជាតិ និងលើសង្គម។

## ២. សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នាទៅវិញទៅមក

យើងគួរបែងចែកថា អ្វីទៅដែលហៅថា សាកលភាវូបនីយកម្ម សាកលនិយមនិងការចំណុះគ្នាទៅវិញទៅមក។

នៅក្នុងបណ្តាប្រទេសខាងលិចបញ្ញត្តិ "*សាកលភាវូបនីយកម្ម* " (Globalization) បាន កើតឡើងយូរមកហើយ។ ពាក្យនេះ មិនមែនទើបនឹងកើតឡើងទេ។ រ៉ូប៊ែរ គីអូហាន (Robert Keohane) និងហ្សូហ្សឹបណាយ (Joseph Nye) អះអាងថា: "*សព្វថ្ងៃនៅពេលគេជជែកគ្នាអំពីសាកលភាវូបនីយកម្ម គេតែងតែយល់ថាសាកលភាវូបនីយកម្ម គឺជាបញ្ហាមួយថ្មី* " (③_ទំព័រទី២នៃ៨)។ លោកទាំងពីរបានផ្តល់ឧទាហរណ៍ថា: "The Silk Road " ដែលធានាអះអាងអំពីទំនាក់ទំនងវប្បធម៌ និងសេដ្ឋកិច្ចរវាងពាណិជ្ជករអឺរ៉ុប និងពាណិជ្ជករ អាស៊ី គឺជាសាកលភាវូបនីយកម្ម ដែលទើបនឹងចាប់ផ្តើមមុនដំបូង (thin globalization)។ ឯសហប្រតិបត្តិការខាងទីផ្សារហិរញ្ញវត្ថុរួម សព្វថ្ងៃគឺជាសាកលភាវូបនីយកម្ម ដែលមានដំណើរពេញលេញ (thin globalization)។ "*សាកលភាវូបនីយកម្ម* " ជាពាក្យមួយដែលទើបនឹងលេចឡើងខ្ញុំខ្ញារ នៅទសវត្សរ៍១៩៩០ដូចពាក្យ "*ការចំណុះគ្នាទៅវិញទៅមក* " (Dependence) ដែលលេចឡើងនៅទសវត្ស១៩៧០ដែរ តែបាតុភូតនៃសាកលភាវូបនីយកម្មមិនមែនថ្មីទាំងស្រុងឡើយ។

លោកទាំងពីរបានបែងចែកច្បាស់លាស់ នូវពាក្យទាំងបី គឺៈ សាកលភាវូបនីយកម្ម សាកលនិយម និងការចំណុះគ្នាទៅវិញទៅមក។ លោកបង្ហាញឱ្យឃើញថា ពាក្យទាំងបីមានន័យខុសគ្នា។ លោកពោលថាៈ " *សាកលភាវូបនីយកម្ម និងការចំណុះគ្នាទៅវិញទៅមក មិនមែនស្របគ្នាទាំងស្រុងទេ។ ការចំណុះគ្នាសំដៅលើលក្ខខ័ណ្ឌ និងសភាពនៃកិច្ចការ។ វាអាចកើនឡើង ឬថយចុះដោយយោងទៅតាមកាលៈទេសៈ។ សាកលភាវូបនីយកម្ម សំដៅលើអ្វីដែលកំពុងកើនឡើង...។ ចំនែកឯសាកលនិយមវិញ* (Globalism) *វាជាសភាពមួយ នៃពិភពលោកដែលក្នុងនោះមានបណ្តាញ នៃការចំណុះគ្នាទៅវិញទៅមកនៅក្នុងចំងាយពហុទ្វីប ដោយមានទំនាក់ទំនងដែលកើតឡើង ដោយឆ្លងកាត់បណ្តូរសង្គមនិងសេដ្ឋកិច្ច។ ប៉ុន្តែ ការចំណុះគ្នា សំដៅលើស្ថានការណ៍ដែលកត់សំគាល់ដោយផល ដែលមានទៅវិញទៅមករវាងប្រទេសនានា ឬរវាងតួអង្គទាំងឡាយនៅក្នុងប្រទេសផ្សេងៗ* " (③.ទំព័រទី១នៃ៨)។ បើតាមសម្តីខាងលើនេះ យើងឃើញថា ពាក្យទាំងបីមានទំនាក់ទំនងបដិសំយោគជាមួយគ្នា និងជះឥទ្ធិពលទៅវិញទៅមក។

**ហ្វីលីព ស៊ីរស៊ី** (Philip Cersy) ពោលថាៈ " *សាកលភាវូបនីយកម្មមិនមែនសុទ្ធតែជាការប៉ះទង្គិច ដែលបង្កឡើងដោយការចំណុះគ្នាខាង សេដ្ឋកិច្ចជាមួយនឹងប្រព័ន្ធនយោបាយក្នុងស្រុក និងអន្តរកម្មរបស់រដ្ឋនានាឡើយ។ វាជាការធ្វើឱ្យយល់ឡើង នូវវិស័យវិទ្យាសាស្ត្រនយោបាយ និយាយរួម (និងវិទ្យាសាស្ត្រសង្គមដ៏ទូលំទូលាយផងដែរ)*

*នៅលើមាគ៌ា ដែលបានពន្យល់ទាំងខាងអំណាចប្រវត្តិសាស្ត្ររបស់រដ្ឋទាំងខាងការបញ្ជាក់ឱ្យឃើញច្បាស់នូវចរន្តនាដកម្ម នៃបណ្ដាញសេដ្ឋកិច្ចនយោបាយ និងសង្គមដ៏ស្មុគស្មាញដែលមានប្រព័ន្ធពិភពលោកពោរពេញទៅដោយការផ្លាស់ប្ដូរសព្វថ្ងៃនេះ* " (②_ទំព័រទី៦២៤.International Journal)។ បើតាម សីរសី (Cersy) ការចំណុះគ្នាខាងសេដ្ឋកិច្ចគ្រាន់តែជាកត្តាមួយនៃសាកលភាវូបនីយកម្មប៉ុណ្ណោះ។ នៅមានកត្តាជាច្រើនទៀតដែលឱ្យសាកលភាវូបនីយកម្មលេចឡើង។

អង់តូនី ហ្គីឌិន (Anthony Giddens) អះអាងថា : "គឺជាការខុសឆ្គងមួយក្នុងការគិតថា សាកលភាវូបនីយកម្មទាក់ទងតែនឹងប្រព័ន្ធធំៗដូចជាទាក់ទងនឹងសណ្ដាប់ធ្នាប់ហិរញ្ញវត្ថុពិភពលោកជាដើម។ សាកលភាវូបនីយកម្មមិនមែនគ្រាន់តែជាអ្វីដែល ស្ថិតនៅខាងក្រៅ" ដែលស្ថិតនៅឆ្ងាយពីបុគ្គលទេ។ សាកលភាវូបនីយកម្ម គឺជាបាតុភូតដែល "ស្ថិតនៅក្នុងទីនេះ" ដែលកំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់ទិដ្ឋភាពបុគ្គលក្នុងជីវិតរបស់យើង" (១_ទំព័រទី១២)។ លោកបានបន្ថែមថា : "សាកលភាវូបនីយកម្មមានលក្ខណៈនយោបាយ បច្ចេកទេស និងវប្បធម៌" ដូចលក្ខណៈសេដ្ឋកិច្ចដែរ។ វាត្រូវបានទទួលឥទ្ធិពលមុនបង្អស់ដោយសារការអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធទូរគមនាគមន៍ ចាប់តាំងពីចុងទសវត្ស១៩៦០មកម្ល៉េះ (១_ទំព័រ១០)។ លោកបាន បញ្ជាក់អំពីវិសាលភាពនៃសាកលភាវូបនីយកម្មថា : "*សាកលភាវូបនីយកម្ម កំពុងតាក់តែង រចនាសម្ព័ន្ធមាគ៌ា ដែលយើងកំពុងរស់នៅ និងឈានចូលជ្រៅទៅក្នុងរបៀបរបប*

*របស់យើង។ វាធ្វើដំណើរមកពីលោកខាងលិច វាមានស្នាម ដ៏ធំនៃអំណាចសេដ្ឋកិច្ចនិងអំណាចនយោបាយរបស់សហរដ្ឋអាមេរិក និងបន្សល់ទុកនូវផលវិបាកដ៏ច្រើន។ ប៉ុន្តែ សាកលភាវូបនីយកម្មមិនមែនគ្រាន់តែជាការគ្របសង្កត់ នៃលោកខាងលិចទៅលើប្រទេសដទៃប៉ុណ្ណោះទេ។ វាធ្វើឱ្យប៉ះពាល់ដល់សហរដ្ឋអាមេរិក ដូចដែលសហរដ្ឋអាមេរិកធ្វើឱ្យប៉ះពាល់ដល់ប្រទេសដទៃដែរ"* (①_ទំព័រទី៤)។

បើតាមទស្សនៈខាងលើនេះ យើងឃើញថា គ្មានរដ្ឋណាមួយដែលស្ថិតនៅក្រៅប្រព័ន្ធសាកលភាវូបនីយកម្មឡើយ។ ប្រជាជាតិទាំងអស់ទោះចង់ក្តី ឬមិនចង់ក្តី ត្រូវតែមានទំនាក់ទំនងគ្នាខាងវិស័យសេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌ ។ល។ ហេតុនេះ យើងមិនអាចទប់ដំណើរសាកលភាវូបនីយកម្មបានឡើយ។ វាកំពុងតែជ្រៀតចូលមក ក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ធ្វើឱ្យយើងឃ្លាតចេញបន្តិចម្តងៗ ពីក្របខ័ណ្ឌជាតិទៅដល់ក្របខ័ណ្ឌអន្តរជាតិ ដែលមិនមានប្រទេសណាមួយជៀសផុតបានឡើយ។

## III. ដំណើរវប្បធម៌ខ្មែរក្នុងយុគសម័យសាកលភាវូបនីយកម្ម

សមាសភាគនៃវប្បធម៌ខ្មែរ (The components of Khmer Culture) រួមមានអ្វីៗ ដែលទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរនិយាយដោយឡែក និងប្រជាជនកម្ពុជានិយាយរួម។ កាលណានិយាយអំពីវប្បធម៌ខ្មែរ យើងច្រើនតែនឹកដល់ស្ថាបត្យកម្មសម័យមហានគរ និងរបៀបរបបរស់នៅសម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គ

ជាដើមប៉ុណ្ណោះ។ តាមពិត វប្បធម៌ខ្មែរ គឺជារបៀបរបបរស់នៅ និងអ្វីៗដែលទាក់ទងនឹងការរស់នៅរបស់ប្រជាជនខ្មែរ តាំងពីខ្មែរបានចាប់កំណើតឡើងរហូតមកដល់សព្វថ្ងៃនេះ។

សង្គមកម្ពុជាធ្វើដំណើរទៅមុខរៀងរាល់វិនាទី។ សមាជិកសង្គមនេះ ក៏កំពុងបោះជំហានទៅមុខរៀងរាល់វិនាទីដែរ។ ហេតុនេះ វប្បធម៌ដែលជាជីវិតស្មារតីនៃប្រជាជនខ្មែរតែងធ្វើចលនា ប្រែប្រួល និងរីកចំរើនឬថយក្រោយតាមដំណើររុងរឿងឬដំណើរអន់ថយនៃសង្គមកម្ពុជា។

ក្នុងយុគសម័យនៃអន្តរកម្មពហុវប្បធម៌សព្វថ្ងៃនេះ ដែលកើតឡើងដោយសារសាកលភាវូបនីយកម្មសេដ្ឋកិច្ច វប្បធម៌ខ្មែរកំពុងតែប្រឈមមុខយ៉ាងស្វិតស្វាញជាមួយវប្បធម៌បរទេស ជាពិសេសជាមួយវប្បធម៌បស្ចឹមប្រទេស ដែលកំពុងហូរចូលមកក្នុងកម្ពុជា ដើម្បីអត្ថិភាពរបស់ខ្លួន។ ប៉ុន្តែនៅក្នុងនិម្មិត្តកម្មសេដ្ឋកិច្ច សង្គមកម្ពុជា វិស័យសេដ្ឋកិច្ច ដែលជាកត្តាកំណត់លើគ្រប់វិស័យទាំងអស់កំពុងតែទទួលឥទ្ធិពលយ៉ាងខ្លាំង ពីសំណាក់សាកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោក។ រីឯវិស័យវប្បធម៌ ដែលចំណុះវិស័យសេដ្ឋកិច្ច ក៏មិនអាចជៀសផុតពីសំពាធនៃសាកលភាវូបនីយកម្មនេះដែរ។

នៅក្នុងប្រទេសកម្ពុជា មានហាងលក់ទំនិញធំៗ ដែលក្នុងនោះមានសុទ្ធតែទំនិញបរទេស។ យើងអាចឱ្យឈ្មោះថា នោះជាផ្សារវប្បធម៌រួម។ ផ្សារវប្បធម៌រួម តែងលើកតំកើងសញ្ញាណនៃតំលៃវប្បធម៌រួមនិងសញ្ញាណនៃផលិតផលណាមួយដែលមានលក់ពាសពេញពិភពលោក

គំនិតនេះជះឥទ្ធិពលទៅលើមនុស្សខ្មែររាប់ម៉ឺននាក់ ដោយធ្វើឱ្យចំណូលចិត្តនិងអាកប្បកិរិយារបស់ខ្មែរមានលក្ខណៈប្រហាក់ប្រហែលគ្នាឆ្ពោះទៅរករបៀបរស់នៅតាមអំពើចិត្តដែលគេចង់ ពោលគឺម្នាក់ៗ ចង់រស់នៅតាមទំនើងចិត្តរបស់ខ្លួន។ ការកើនឡើងដោយគ្មានលំអានជាមុននៅក្នុងពាណិជ្ជកម្មរួម ការទិញ និងការលក់វត្ថុ និងសេវាផ្សេងៗនៅក្នុងកម្ពុជា បានបង្កើតឱ្យមានហាងទំនិញធំៗជាច្រើន ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយហាងទំនិញធំៗក្នុងពិភពលោក។ ការទិញ និងការលក់ប្រទាក់គ្នា ដោយឆ្លងតាមរយៈមធ្យោបាយពាណិជ្ជកម្ម។ ទូរទស្សន៍ វិទ្យុ ទូរស័ព្ទ កាសែត ទស្សនាវដ្ដី សុទ្ធតែជាមធ្យោបាយ ដែលបានបំរើការងារផ្សព្វផ្សាយនេះ។ តាមពិតសាកលភាវូបនីយកម្មនៃសេដ្ឋកិច្ចបានបង្កើតសាកលភាវូបនីយកម្មនៃការផ្សាយ។ ទោះច្រើន ឬតិចការផ្សព្វផ្សាយតែងផ្អែកលើអំណាចនិងវប្បធម៌នៃប្រទេសអ្នកមាន។ ទីផ្សារហិរញ្ញវត្ថុរួម បានបង្កើតបរិយាកាសថ្មីមួយក្នុងការស្វែងរកផលចំណេញឱ្យបានឆាប់រហ័ស។ ទីផ្សារប្ដូរប្រាក់កំពុងមានទំនាក់ទំនងជាមួយការកេងកំរៃរូបិយវត្ថុ ដោយធ្វើយ៉ាងណាឱ្យបានចំណេញច្រើនជាអតិបរមា។

ភាពមិនទៀងទាត់ក្នុងការបង្កើនមុខរបរ ដូចជារបរកសិកម្ម ជាដើម បានជំរុញឱ្យមានកន្លែងធ្វើការងាររួម ហើយបញ្ហានេះបណ្ដាលឱ្យមានការផ្លាស់លំនៅដ្ឋាននៃពលករ ស្ទើរពាសពេញប្រទេសកម្ពុជា ជាពិសេសការផ្លាស់លំនៅស្ថានរបស់យុវវ័យ។ គេធ្វើដំណើរពីជនបទមក

រស់នៅទីក្រុង និងធ្វើដំណើរពីទីក្រុងទៅរស់នៅឯបរទេស ដើម្បីលក់កម្លាំងពលកម្ម ក្នុងពេលដែលកម្ពុជានៅមានផ្ទៃដីទំនេរជាច្រើន។

កំណែទម្រង់សេដ្ឋកិច្ចតំរង់ទៅរកទីផ្សារ តែងជំរុញឱ្យក្រុមហ៊ុនអន្តរជាតិនៅកម្ពុជាកាន់តែមានអានុភាពខ្លាំងឡើងៗ។ ការណ៍នេះកំពុងជម្រុញឱ្យពលករខ្មែរជាច្រើន ស្វែងរកការងារនៅក្នុងប្រទេស ឬស្វែងរកការងារនៅឯបរទេស ដោយបំភ្លេចចោលតាមបែបអចេតនានូវវប្បធម៌របស់ខ្លួន។ នៅក្នុងល័ក្ខខ័ណ្ឌមួយចំនួន ម្ចាស់កម្មន្តសាលបង្ខំឱ្យពលរដ្ឋឱ្យពលករខ្មែរទាំងនោះ ធ្វើការក្នុងសភាពអមនុស្សធម៌ ដោយបានទទួលបៀវត្សរ៍តិចតួចប៉ុណ្ណោះ។

យើងអាចនិយាយថា នៅក្នុងសម័យសាកលភាវូបនីយកម្មមនុស្សជាតិអាចឈានទៅរកវាសនារួម ដែលកើតឡើងដោយសារបដិវត្តន៍បច្ចេកទេសខាងពត៌មាន និងគមនាគមន៍។ គួរចងចាំថា ក្រុមហ៊ុនអន្តរជាតិជាចំណុចសំខាន់ នៃសាកលភាវូបនីយកម្ម។ គឺក្រុមហ៊ុនអន្តរជាតិនេះហើយ ដែលក្លាយជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច និងក្លាយជាកំលាំងនយោបាយនៅក្នុងសេដ្ឋកិច្ចពិភពលោក។ ក្រុមហ៊ុនអន្តរជាតិ តែងបង្កើនការប្រណាំងប្រជែង និងបង្កើនការកៀបសង្កត់លើគ្នាទៅវិញទៅមកដើម្បីការពារអត្ថិភាព និងប្រាក់ចំណេញរបស់ខ្លួន។ ការណ៍នេះ ជំរុញឱ្យពួកគេស្វែងរកយ៉ាងទទូចនូវទីផ្សារពលកម្មតំលៃថោក។ នៅក្នុងចំណោមទីផ្សារពលកម្មដែលមានតំលៃថោក នោះកម្ពុជាមានតួនាទីមួយ យ៉ាងសំខាន់។ ក្រុមហ៊ុនអន្តរជាតិជាច្រើនបានបង្កើតកម្មន្តកាល និងសេវា

ឧស្សាហកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ជួនកាល គេពុំយកផលិតផលទាំងនោះបំរើឱ្យប្រជាជនកម្ពុជាទេ។ ឧទាហរណ៍ៈ សំលៀកបំពាក់ជាច្រើនដែលបានផលិតនៅប្រទេសកម្ពុជា ត្រូវបានគេបញ្ជូនទៅលក់នៅឯបរទេស។ ចំណែកប្រជាជនកម្ពុជា បែរជានិយមស្លៀកពាក់ "សំលៀកបំពាក់ជជុះ" ដែលនាំចូលពីបរទេសវិញ។

**The Structural Adjustment Programmes (SAP)** អះអាងថា សាកលភាវូបនីយកម្ម បានរួមចំណែកយ៉ាងធំក្នុងការបង្កើនបំណុល សេចក្តីក្រលំបាក និងវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍន៏។ អង្គការនេះសង្កត់ធ្ងន់ថា ស្ថាប័នឥណទានទាយករួម (The global creditor Institutions) បាននឹងកំពុងបង្កើតបរិយាកាស ដែលប៉ះពាល់យ៉ាងខ្លាំងដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៏។ ប្រាក់ជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ត្រូវបានប្រើប្រាស់ទៅលើទិសដៅនាំចេញ។ សេដ្ឋកិច្ចក្នុងស្រុកចំណុះសេដ្ឋកិច្ចពិភពលោកទាំងស្រុង។ ស្ថាប័នដែលមានអំណាចខ្លាំងដូចជា The International Monetary Fund, The World Bank, The World Trade Organization ជាដើម តែងផ្តល់ទឡ្ហីករណ៏ថា "គ្មានផ្លូវណាផ្សេងទៀត "ឡើយ (There Is No Alternative)។ ផលវិបាកដែលប្រទេសកំពុងអភិវឌ្ឍន៏បានទទួល គឺធ្លាក់ទៅលើផលិតករក្នុងស្រុក ដូចជាវណ្ណៈកម្មករ និងកសិករជាដើម។ ដូចនេះ ផលិតករកម្ពុជាក៏កំពុងទទួលផលវិបាកនេះដែរ។

គឺពិតជាត្រឹមត្រូវនៅពេលដែលគេអះអាងថា ប្រជាជនមួយចំនួនដែលស្ថិតនៅក្នុងវណ្ណៈកណ្ដាល និងវណ្ណៈអ្នកមាន មានការរីកចំរើននៅក្នុងសង្គមដែលមានការឆ្លងកាត់ទៅរកប្រព័ន្ធផ្សារសេរី។ វណ្ណៈកណ្ដាល និងវណ្ណៈអ្នកមានថ្មីនេះពិតជាលទ្ធផលនៃសាកលភាវូបនីយកម្ម។ ពួកគេធានាបង្កើតទីផ្សារ ដើម្បីនាំផលិតផលចូលមកក្នុង ស្រុក។ បើគេនាំផលិតផលបរទេសចូលក្នុងស្រុកកាន់តែច្រើន សេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ ដែលជាម្ចាស់ផលិតផល ក៏កាន់តែរីកចំរើនដែរ។

ជាការណ៍ដែលគួរឱ្យឆ្ងល់ណាស់ នៅពេលដែលគេនិយាយថា ផលិតផលខ្មែរមិនមានស្តង់ដារអន្តរជាតិ នៅពេលណាក៏គេលើកតំកើងផលិតផលបរទេសដែរ។ នេះមកពីខ្មែរបាត់បង់ជំនឿលើខ្លួនឯង បាត់បង់ជំនឿលើសង្គមរបស់ខ្លួនពីជំនាន់មួយទៅជំនាន់មួយ។

យើងមានផ្សារទំនើបសំរាប់ផលិតផលបស្ចិមប្រទេស តាំងពីជីដាក់ស្រែ និងម្ហូបកំប៉ុងជាដើម។ កសិករទាំងអស់ ស្ទើរតែបោះបង់ចោលការផ្សាំជីធម្មជាតិ ដែលមានគុណភាពខ្ពស់ ហើយស្រវាចាប់យកជីគីមីដែលមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួន និងអាយុជីវិតនៃអ្នកប្រើប្រាស់ផលិតផលកសិកម្ម។ សំលៀកបំពាក់ Levis Jeans និងស្បែកជើង Nike atheletic ជាដើម បានឈានជើងមកដល់កម្ពុជា។ សំលៀកបំពាក់មួយសំរាប់មានតំលៃខ្ពស់ជាងច្រើនដង បើប្រៀបធៀបនឹងបៀវត្សដែលរកបានក្នុងមួយខែ។ ឯការដើរចូលសណ្ឋាគារខារ៉ាអូខេ ឬផ្ទះសំណាក់ខារ៉ាអូខេ បានក្លាយជាបញ្ហាសាមញ្ញនៅតាម

ទីក្រុង ជាយក្រុង និងទីរួមខេត្តនានា។ ការភ្នាល់កីឡាប្រដាល់ និងកីឡាបាល់ទាត់ ដែលមានទឹកប្រាក់រាប់ម៉ឺនដុល្លាក្នុងមួយសប្ដាហ៍ ត្រូវបានប្រព្រឹត្តនៅក្នុងទីក្រុងភ្នំពេញ។

សភាពការណ៍នេះ កំពុងជំរុញឱ្យប្រជាជនខ្មែរបោះបង់ចោលបន្តិចម្ដងៗ នូវវប្បធម៌បុរាណរបស់ខ្លួន ដោយឈោងចាប់ពហុវប្បធម៌ ដែលកំពុងលុកលុយក្នុងសតិអារម្មណ៍របស់ជាតិ។ ប្រជាជនមួយចំនួនធំយល់ថា មានប្រាក់គឺមានអ្វីៗទាំងអស់។ សព្វថ្ងៃ មានក្មេងជំទង់ និងយុវជនរាប់ម៉ឺននាក់ ដែលកំពុងរស់នៅក្នុងបរិស្ថាននៃអ្នកមានពហុប្រព័ន្ធផ្សព្វផ្សាយ។ ពួកគេមានលក្ខណៈរួមដូចគ្នា មានចំណង់ចំណូលចិត្តប្រហាក់ប្រហែលគ្នា និងមានទំនោរងាកចេញពីប្រពៃណីដូចគ្នា។ គេកំពុងតែច្រានចោលកត្តាសកម្មនៃប្រពៃណីជាតិ ហើយស្រវាយកដោយសេចក្ដីពេញចិត្តនូវកត្តាអកម្មនៃវប្បធម៌ ដែលហូរចូលមកពីក្រៅដូចជា :

- ការលែងស្ដាប់ដំបូន្មានឪពុកម្ដាយ
- ការប្រើសំលៀកបំពាក់តាមទំនើងចិត្ត
- ការតុបតែងខ្លួន
- ការស្វែងរកដៃគូដើរកំសាន្ត
- ការពន្លូតកូនមុនអាពាហ៍ពិពាហ៍ពេញច្បាប់
- ការផ្លាស់ប្ដូរសង្សារពីមួយទៅមួយ

- ការសម្ដែងសិល្បៈមួយចំនួន
- ការបំរើក្នុងភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ និងការបំរើសេវាផ្លូវភេទ
- ពាក្យសម្ដីចំអេសចំអាស លេងសើចបែរតំរង់ទៅរកសេចក្ដីស្នេហា ដើម្បីប្រាក់......។ល។

កត្ដាទាំងអស់នេះ បង្ហាញឱ្យឃើញថា យើងកំពុងរត់តាមកម្លាំងសម្ភារៈ ដែលជាផលិតផលនៃសាកលភាវូបនីយកម្មផ្សព្វផ្សាយ ដោយឥតបានប្រើវិចារណញាណ ថាត្រូវទទួលយកអ្វី និងត្រូវបដិសេធអ្វីឡើយ។ ការផ្សាយពាណិជ្ជកម្មបារីជាឧទាហរណ៍ មានលក្ខណៈផ្ទុយស្រឡះពីវេជ្ជបញ្ញា។ ដោយផ្អែកលើវិទ្យាសាស្រ្ដ វេជ្ជបណ្ឌិតអះអាងថា បារីបណ្ដាលឱ្យខូចសុខភាព។ ផ្ទុយទៅវិញ ដោយផ្អែកលើការបង់ពន្ធក្នុងការផ្សាយ អ្នកនាំពាក្យអះអាងថា បារីនាំឱ្យមានបញ្ញាភ្លឺថ្លា។ ចំពោះបញ្ហាបារីតែមួយក្នុងពេលតែមួយ មានការផ្សាយពីរបែបផ្ទុយគ្នាពោលគឺ បារីបំផ្លាញសុខភាពផង និងបារីនាំឱ្យមានបញ្ញាភ្លឺថ្លាផង។ គំនិតទីពីរជាគំនិតក្បត់វិទ្យាសាស្រ្ដ។ គេដឹង! តែគេនៅតែបំពាន ព្រោះគេខ្លាចប្រាក់។ អ្នកមានខ្លះ គ្រាន់តែឃើញការផ្សាយម៉ូតសំលៀកបំពាក់នៅតាមទូរទស្សន៍នៃប្រទេសជិតខាងភ្លាម ក៏ប្រញាប់ប្រញាល់ទៅឱ្យជាងកាត់ដេរកាត់តាមម៉ូតសំលៀកបំពាក់នោះ តែក្នុងរយៈពេល ២ ឬ៣ម៉ោងប៉ុណ្ណោះ។ រីឯអ្នកក្រខ្លះ ក៏រត់តាមបញ្ហានេះដែរ ព្រោះកុំឱ្យចាញ់អ្នកមានពេក។ យុវជន និងក្មេងជំទង់នៅតាមទីក្រុង ក៏ដូច

ជានៅតាមជនបទដែរ មិនមានចំណូលចិត្តចំពោះការរាំវង់ រាំក្បាច់ រាំសារ៉ាវ៉ាន់ទេ តែគេចូលចិត្តអ្វីដែលហៅថា ការរាំញាក់ រាំញាក់មិនត្រូវជ្រុង មិនដូចប្រភពដើម។ នេះជាការរត់តាមគ្នាពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ ពីខេត្តមួយទៅខេត្តមួយ ដែលខ្វះចំណាត់តាំង ខ្វះការអប់រំដែលមានលក្ខណៈជាប្រព័ន្ធ។

ម្យ៉ាងទៀត ក្នុងការអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្ស គេច្រើនតែនិយាយថា ត្រូវរត់តាមសេដ្ឋកិច្ចទីផ្សារសេរី។ ប៉ុន្តែ គេភ្លេចនិយាយថា ត្រូវបង្កើនកត្តាសកម្មនៃសេដ្ឋកិច្ចទីផ្សារសេរី និងបន្ថយកត្តាអសកម្មរបស់វាទេ។ ហេតុនេះ ធនធានមនុស្សដែលគេផលិតបានច្រើន ច្រើនតែជាអ្នកមានចំណេះវិទ្យាសាស្ត្រដែលខ្វះសីលធម៌។ ទស្សនវិទូបស្ចិមប្រទេសម្នាក់បានពោលយូរមកហើយថា: *"វិទ្យាសាស្ត្រខ្វះមនសិការ ជាការបំផ្លិចបំផ្លាញព្រលឹងមនុស្ស"* (Science sans conscience n'est que ruine de l'âme)។ ការណ៍នេះបានបង្កើតផលអាក្រក់ជាច្រើនផ្សេងៗទៀត ដូចជា អំពើពុករលួយការកេងប្រវ័ញ្ចការជេរប្រមាថ ការប្រើអំពើហឹង្សា ការប្រើអាកប្បកិរិយាច្រងេងច្រងាង ដែលក្នុងគ្រួសារខ្លះស្ទើរតែក្លាយទៅជាវប្បធម៌ទៅហើយ។

អង្គការ Human Development Report បានធ្វើរបាយការណ៍នៅឆ្នាំ១៩៩៧ថា សាកលភាវូបនីយកម្ម បានលើកគំរូនៃការប្រើប្រាស់សម្ភារៈផ្សេងៗដូចជា រថយន្តប្រណិត និងភេសជ្ជៈជាដើមកំពុងតែក្លាយជាជំនក់ចិត្ត នៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ។ គំរូ

នេះកំពុងតែបំផ្លាញផលិតផលក្នុងស្រុក ដែលប្រជាជនក្រីក្រកំពុងពឹងពាក់។ លោក រ៉ូប៊ែរតូ វ៉េរហ្សូឡា (Roberto Verzola) សង្គមវិទូហ្វីលីពីនពោលថា ក្នុងរយៈពេល១០០ឆ្នាំមុន មានអាណានិគមនិយម តែឥឡូវមានសាកលភាវូបនីយកម្ម។ សព្វថ្ងៃ សាជីវកម្មរួម បានចូលមកជំនួសអំណាចអាណានិគមនិយម។ លោកគូសបញ្ជាក់ថា នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សាជីវកម្មរួមត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធនធានធម្មជាតិ ធនធានមនុស្ស និងទ្រព្យសម្បត្តិជាតិ។ ពួកគេប្តូរទីកន្លែងកសិករ ពីដីស្រែ ប្តូរទីកន្លែងកម្មករពីមុខរបរ និងប្តូរទីកន្លែងសហគមន៍ពីឬសគល់របស់វា។ ពួកគេត្រូវទទួលខុសត្រូវចំពោះការបែកបាក់សហគមន៍ និងការបំផ្លិចបំផ្លាញបរិស្ថាន ដើម្បីបំរើដល់តម្រូវការសម្ភារៈដើម និងមនុស្សដែលជាផលិតផលសំរាប់ផ្សាររួម។ ផលវិបាកដែលប្រជាជនក្រីក្របានទទួល គឺអសន្តិសុខខាងម្ហូបអាហារ និងវិបត្តិបរិស្ថាន ដែលថ្ងៃក្រោយអាចអាក្រក់ជាង របបអាណានិគមនិយមទៀតផង។

ការរៀបរាប់ខាងលើនេះ មិនមែនជាការបដិសេធចំណុចល្អនៃសាកលភាវូបនីយកម្មទេ។ សាកលភាវូបនីយកម្មក៏មានចំណុចល្អរបស់វាដែរ។ សាកលភាវូបនីយកម្មបច្ចេកទេស ពិតជាធ្វើឱ្យពិភពលោករីកចំរើន។ ប៉ុន្តែរបបបច្ចេកាធិបតេយ្យ ដែលយកបច្ចេកទេសទៅធ្វើនយោបាយមិនបានបំរើសង្គមមនុស្សឡើយ។ វាគ្រាន់តែជារបបមួយដែលបំរើអ្នកមានមួយចំនួនតូចប៉ុណ្ណោះ។

នៅចំពោះមុខសភាពការណ៍បែបនេះ ដើម្បីរក្សាតំលៃដើមរបស់ខ្លួន វប្បធម៌ខ្មែរត្រូវស្ថិតនៅក្នុងសតិអារម្មណ៍ប្រជាជនកម្ពុជាគ្រប់រូប។ វាត្រូវតែស្តែងឡើង តាមរយៈសកម្មភាពប្រចាំថ្ងៃ ដូចជាតាមរយៈពាក្យសំដី ឥរិយាបថ ពិធីបុណ្យ និងសំលៀកបំពាក់ជាដើម។ សំលេងខ្លុយអាចពិរោះដល់ត្រចៀកមនុស្សចាស់ តែអាចមិនពិរោះដល់ត្រចៀកយុវជន។ ប៉ុន្តែ ទោះពិរោះក្តី ឬមិនពិរោះក្តី ក៏គួរតែក្រអៅបេះដូងរបស់មនុស្សខ្មែរត្រូវបានជ្រួតជ្រាបដោយសំលេងខ្លុយខ្មែរ ប្រសិនបើមិនចង់ឱ្យសំលេងខ្លុយសាបសូន្យ។ យើងនឹងបាត់បង់សម្បត្តិវប្បធម៌ហួលជ្រលក់លំក្អខ្មែរដែលខ្មែរបានធ្វើសំភារៈដើមដោយខ្លួនឯង ប្រសិនបើយើងមិនរិះរកមធ្យោបាយឧបត្ថម្ភអ្នកត្បាញហូលទេ។

## IV. ការប្រួលប្រណាំងដើម្បីជោគជ័យទាំងអស់គ្នា

យើងបានរស់នៅរាប់សតវត្សមកហើយ ដែលមុជចូលជ្រៅទៅក្នុងវប្បធម៌សង្គ្រាមក្នុងវប្បធម៌ ដែលហេតុផលនៃកំលាំងបាយឈ្នះលើកំលាំងនៃហេតុផល។ គឺមិនមែនជាការពន្យល់ឱ្យយល់ទេ តែជាការយកឈ្នះ។ ឈ្នះដោយសារយើងប្រើគ្រប់មធ្យោបាយ។ តើយើងទទួលផលចំណេញអ្វីខ្លះ? តាមការពិត នោះជាហេតុផលមួយ ដែលបញ្ជាក់ថា យើងខាតបង់ទាំងអស់គ្នា។ ទាំងអស់គ្នាសុទ្ធតែខាតបង់។

យើងបានចំណាយរាប់សតវត្សរ៍មក ហើយនូវថ្លៃសង្គ្រាម និងជីវិតមនុស្ស ដែលជាតម្លៃខ្ពស់បំផុត។ ឥឡូវនេះ យើងត្រូវចេះចំណាយ

ថ្លៃសន្តិភាពម្តងវិញ។ ប៉ុន្តែ តើយើងត្រូវធ្វើយ៉ាងណា នៅចំពោះមុខសាកលភាវូបនីយកម្មនេះ?

ពិតណាស់ សាកលភាវូបនីយកម្ម និងទំនើបភាវូបនីយកម្មបានធ្វើឱ្យពិភពលោកមានការរីកចំរើន។ វាបានរួមចំណែកលើកតំកើងបមាណភីយរួមសំរាប់មនុស្សជាច្រើន លើកតំកើងការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែ នៅក្នុងដំណើររបស់វា សាកលភាវូបនីយកម្មមានជ្រុងអាក្រក់ជាច្រើន ដូចជាការចុះថយខាងសីលធម៌ជាដើម។ ឯប្រព័ន្ធសង្គមដែលធ្លាប់មានរបៀបរៀបរយ កំពុងក្លាយជាប្រព័ន្ធសង្គមដែលខ្វះរបៀបរៀបរយវិញ។ ចលាចលសង្គម និងអំពើពុករលួយ ដែលរត់តាមកំលាំងសម្ភារៈសុទ្ធសឹងជាកូនបង្កើតរបស់វា។

នៅក្នុងស្ថានភាពបែបនេះ យើងត្រូវប្រលងប្រណាំង ដើម្បីឆ្លើយតបចំពោះឱកាសថ្មីសំរាប់ការលេចឡើង នៃវប្បធម៌របស់ប្រជាជាតិនានាលើសាកលលោក។ ដោយសារការលេចឡើង នៃវប្បធម៌នោះអត្តសញ្ញាណនៃប្រជាជាតិនានា អាចត្រូវបានធានាខាងផ្លូវកាយ និងត្រូវបានលើកកំពស់ខាងសោភ័ណភាពទាំងបុគ្គល និងសង្គមទាំងនៅក្នុងប្រទេស និងក្នុងពិភពលោក។ យើងប្រលងប្រណាំងដើម្បីធ្វើឱ្យន័យនៃអត្តសញ្ញាណសីលធម៌មានវឌ្ឍនភាព ដោយស្ថិតនៅក្នុងបរិបទពហុវប្បធម៌ ដែលក្នុងនោះភាពផ្សេងគ្នា និងពហុភាពមានកំលាំងច្រើន ហើយពន្លឺសហប្រតិបត្តិការមានកំលាំងជាងការអុជអាលឱ្យមានជម្លោះ។ យើងប្រលងប្រណាំងដើម្បីឱ្យបុគ្គល និងប្រជាជាតិទាំងអស់រីកចំរើននៅ

ក្នុងបរិបទពិភពលោកថ្មី និងជៀសវាងយ៉ាងណាកុំឱ្យមានសង្គ្រាមកើតឡើង។

លោក **សាង ជីនហាន** (Sang Jin Han) ពោលថា: "*សេដ្ឋកិច្ចនៅសតវត្សទី២១ ត្រូវបានធ្វើនិទស្សន៍ទុកជាមុនថា សេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ។ គេបានទាយទុកមុនផងដែរថា សេដ្ឋកិច្ចផ្អែកលើពុទ្ធិនោះមានស្ថេរភាព និងមានលក្ខណៈរស់រវើក* " (①_ទំព័រ១៤)។ ទិដ្ឋភាពនៃសេដ្ឋកិច្ចផ្អែកលើពុទ្ធិ គឺការពង្រឹងសារៈប្រយោជន៍នៃមូលធនមនុស្ស។ អ្វីដែលមានលក្ខណៈសារវន្ត ដើម្បីការរីកចំរើននៃសេដ្ឋកិច្ចនាសតវត្សទី២១ គឺមិនមែនធនធានមុស្ស ដែលមានអំណាចខាងកំលាំងបាយទេ តែជាមូលធនមនុស្សដែលមានបញ្ញាឆ្នៃប្រឌិត។

ទន្ទឹមនោះដែរ យើងគួររំលឹកឡើងវិញនូវគ្រោះថ្នាក់ ដែលគួរជៀសវាង។ គ្រោះថ្នាក់នោះធ្វើឱ្យសង្គមមួយឃ្លាតឆ្ងាយពីអតីតកាលរបស់ខ្លួន គឺខុសពីលក្ខណៈពិសេសដំបូង នៅក្នុងអរិយធម៌ឧស្សាហកម្មទំនើប។ គ្រោះថ្នាក់មានពីរបែបសំខាន់គឺ គ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិ និងគ្រោះថ្នាក់ដែលកើតឡើងដោយមនុស្សផ្ទាល់។ ការខុសគ្នារវាងគ្រោះថ្នាក់ទាំងពីរបែបនេះមានដូចខាងក្រោម ៖

- នៅក្នុងវប្បធម៌បូរាណ និងនៅក្នុងសង្គមឧស្សាហកម្មដំបូង មនុស្សមានការភ័យព្រួយចំពោះគ្រោះថ្នាក់ ដែលកើតឡើងដោយធម្មជាតិខាងក្រៅ ដូចជាការមិនបានប្រមូលផល

ទឹកជំនន់ ជំងឺរាតត្បាត និងទុរភិក្សជាដើម។ នេះហើយហៅថា គ្រោះថ្នាក់ដែលធម្មជាតិខាងក្រៅបានប្រព្រឹត្តមកលើសង្គមមនុស្ស។

- សព្វថ្ងៃ នៅក្នុងករណីមួយចំនួន យើងមិនសូវព្រួយបារម្ភអំពីអ្វីដែលធម្មជាតិ បានប្រព្រឹត្តមកលើយើងទេ តែយើងគួរព្រួយបារម្ភយ៉ាងខ្លាំងអំពីអ្វី ដែលយើងបានប្រព្រឹត្តទៅលើធម្មជាតិវិញ។ នេះហើយហៅថាគ្រោះថ្នាក់ដែលមនុស្សបានប្រព្រឹត្តទៅលើធម្មជាតិ។

ក្នុងការប្រៀបធៀបនេះ យើងឃើញថា សព្វថ្ងៃមានការឆ្លងកាត់ពីឧត្តមានុភាពនៃគ្រោះថ្នាក់ ដែលបង្កឡើងដោយធម្មជាតិមកលើសង្គមមនុស្ស ទៅដល់ឧត្តមានុភាពនៃគ្រោះថ្នាក់ដែលបង្កឡើង ដោយសង្គមមនុស្សទៅលើធម្មជាតិវិញ។ គ្រោះថ្នាក់ទី២នេះ តែងធ្វើឱ្យវប្បធម៌នៃប្រទេសនីមួយៗរង្គោះរង្គើ រហូតដល់បាត់បង់សញ្ញាណដើមរបស់ខ្លួនប្រសិនបើយើងមិនប្រុងប្រយ័ត្ន។

នៅចំពោះមុខគ្រោះថ្នាក់ខាងលើ យើងដែលជាពលរដ្ឋកម្ពុជាគួរពង្រឹងពង្រីកបន្ថែមទៀត នូវសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍន៍វប្បធម៌នៃប្រទេសនីមួយៗ ដោយរក្សាធាតុដើមរបស់ខ្លួនផង និងអាចរស់នៅក្នុងពហុវប្បធម៌ផង។ ការប្រើឆន្ទៈអត្តនោម័ត និងប្រើអំណាចទាំងកំរោល ដើម្បីលុបបំបាត់កត្តាអសកម្មនៃវប្បធម៌បរទេស ឬ "វប្បធម៌ពាលាអាវ៉ាសែ" មិនអាចប្រព្រឹត្តទៅបានទេ។ បញ្ហាសំខាន់ គឺការអប់រំ

ឱ្យខ្មែរភ្ញាក់រឭកឡើងវិញ តាមរយៈការពង្រឹងវិន័យសីលធម៌ តាមរយៈការសម្ដែងសិល្បៈ តាមរយៈប្រលោមលោកជាដើម។

ការទប់ស្កាត់ចំណូលចិត្តដែលសមស្រប ដែលបំផ្លិចបំផ្លាញប្រពៃណីជាតិ ដូចជាគំនិតដែលអះអាងថា (កូនធំហើយ ម៉ែឪមិនបាច់ណែនាំច្រើនពេកទេ) (កុំទូលផែនដីម្នាក់ឯង) (សម័យនេះជាសម័យយន្តហោះ មិនមែនជាសម័យរទេះគោទៀតទេ) (មានលុយគឺមានអ្វីៗទាំងអស់) (បើមាត់ហោចៅនៅខាងលើ លុយជាបញ្ហាចំបងបំផុត)…. មានអត្ថន័យយ៉ាងសំខាន់ សំរាប់ឱ្យវប្បធម៌របស់យើងមានអត្ថិភាពរឹងមាំជាមួយនឹងពហុវប្បធម៌ ដែលឈានចូលមកពីក្រៅ។ កូនធំ កូនតូចសុទ្ធតែត្រូវមានសិទ្ធសេរីភាព តែការប្រើសិទ្ធសេរីភាពមិនអាចឃ្លាតឆ្ងាយពីការទូន្មាន ការណែនាំរបស់ម៉ែឪឡើយ។ របៀបរស់នៅតាមសម័យយន្តហោះ ជាកត្តាសំខាន់ តែក៏មិនគួរបំភ្លេចរបៀបរស់នៅតាមបែបរទេះគោដែរ។ ប្រាក់ជាកត្តាចាំបាច់សំរាប់ជីវិតប្រចាំថ្ងៃ តែមិនគួរចាត់ទុកប្រាក់ជាចៅហ្វាយរបស់ខ្លួនឡើយ។

## V. សេចក្ដីសន្និដ្ឋាន

ប្រទេសនីមួយៗ មានវប្បធម៌ដោយឡែករបស់ខ្លួន។ ជនជាតិនីមួយៗ មានវប្បធម៌ដោយឡែករបស់ខ្លួន។ នៅក្នុងប្រទេសមួយដែលមានសញ្ជាតិច្រើន ក៏មានវប្បធម៌ច្រើនដែរ។ ដើម្បីរួមរស់ជាមួយគ្នាបាន

ជនជាតិទាំងនេះ ត្រូវទទួលស្គាល់ភាពដោយឡែកផង និងទទួលស្គាល់ភាពរួមផង។

នៅក្នុងពិភពលោក ដែលមានប្រជាជាតិដ៏ច្រើន ពហុវប្បធម៌កំពុងតែឆ្លងកាត់គ្នាទៅវិញទៅមក។ វប្បធម៌បស្ចិមប្រទេសកំពុងទន្រ្ទានចូលមកក្នុងប្រទេសដទៃទៀត តែទោះបីតិច ឬច្រើន បស្ចិមប្រទេសក៏ទទួលឥទ្ធិពលវប្បធម៌នៃប្រទេសដទៃវិញដែរ។ ការឆ្លងគ្នារវាងវប្បធម៌និងវប្បធម៌ជាកត្តាបរានុម័ត នៅក្នុងយុគសម័យសាកលភាវូបនីយកម្មនេះ។

ដំណើរសាកលភាវូបនីយកម្ម ដែលកំពុងមានវិសាលភាពទូលំទូលាយ តែងមានជ្រុងល្អ និងជ្រុងអាក្រក់របស់វា។ សេចក្តីក្លាហាននៃប្រជាជាតិនីមួយៗ ក្នុងការបន្ថយឥទ្ធិពល នៃជ្រុងអាក្រក់របស់វាពិតជាធ្វើឱ្យវប្បធម៌របស់ខ្លួនរស់នៅប្រកបដោយលក្ខណៈច្នៃប្រឌិត។ ប៉ុន្តែការបន្ថយឥទ្ធិពលនៃជ្រុងអាក្រក់នោះ ត្រូវតែប្រព្រឹត្តទៅក្រោមវិចារណញាណ ប្រកបដោយវិធីសាស្ត្រ។ កង្វះវិធីវិទ្យាសាស្ត្រ កង្វះបញ្ញាប្រមូលផ្តុំសំរាប់ដំណោះស្រាយតាមជំហាននីមួយៗ អាចបណ្តាលឱ្យវប្បធម៌ខ្មែរលេចបាត់បន្តិចម្តងៗ។

ពលរដ្ឋម្នាក់ៗ ត្រូវមានស្មារតីទទួលខុសត្រូវ ដូចដែល ហ្សង់ប៉ូលសាត្រ (Jean Paul Sartre) បានអះអាងថា : "មនុស្សទទួលខុសត្រូវគ្រប់នាទី។ មនុស្សទទួលខុសត្រូវអ្វីៗទាំងអស់ នៅចំពោះមុខអ្នកទាំងអស់គ្នា។ គេរែកពុនពិភពលោកទាំងមូលនៅលើស្មារបស់គេ " (L'homme est responsible à toute minute. Il est responsa-

ble de tout devant tous. Il porte le poids du monde entire sur ses épaules) (⑥_ទំព័រទី១៤១)។

# ឯកសារពិគ្រោះ


①-**Anthony Giddens** — *Runaway World.* Profile Books Ltd, London, 1999

②-**Philip G. Cersy** — *Globalization and other stories:* The reach for a new paradigm for international relations, International Journal. Volume II, n$^0$

③-**Rebert O. Keohane and Joseph S. Nye Jr.** — Globalization: What's new? What's not? (And so what?), Sprint, 2000- 3/23/2000.

④- **Sang Jin Han** — Economy and Human Researches in the 21 century (the Academy of Korean study) (no date)

⑤-**Shapour Sassekh** — Education et Culture de la Paix. IBE data. UNESCO. 1996

⑥**Jacqueiine Russ** — Histore de la phiosophie de Socrate a Foucauit Hatier. Paris. 1985

## ៧.១១_សុន្ទរកថាថ្លែងដោយ លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី ប្រធាននាយកដ្ឋានត្រួតពិនិត្យគំរោងគណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព ស្តីអំពី "សកលភាវូបនីយកម្ម និងផលប៉ះពាល់មកលើសង្គមស៊ីវិលកម្ពុជា : ការគ្រប់គ្រងតម្លៃចាយវាយ និងទាញយកផលប្រយោជន៍ឲ្យអតិបរិមា"

សេចក្ដីផ្ដើម :

ពាក្យសកលភាវូបនីយកម្ម ជាពាក្យសព្ទថ្មីមួយ ដែលប្រជាជនសាមញ្ញមិនសូវបានយល់ច្បាស់ អំពីន័យនៃពាក្យនេះទេ សូម្បីតែសិស្សនិស្សិតឬមន្ត្រីរាជការមួយចំនួនក៏មិនទាន់យល់អត្ថន័យនិងអត្ថប្រយោជន៍ឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។ នៅក្នុងប្រធានបទនេះ យើងខ្ញុំសូមលើកតែអំពីសកលភាវូបនីយកម្មវិស័យសេដ្ឋកិច្ចមកពិភាក្សា។ ដំបូងជាការចាប់ផ្ដើមយើងនឹងធ្វើការពិនិត្យអំពីកត្តាគោលធំៗ ដែលបង្ហាញរូបភាពទូទៅនៃសភាពការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន ដូចមានខាងក្រោម :

ការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម បានលាតសន្ធឹងទៅគ្រប់ទីកន្លែងទូទាំងពិភពលោក គ្រាន់តែការអភិវឌ្ឍន៍នោះស្ថិតនៅក្នុងកម្រិត ប្លែកៗពីគ្នា។ ទន្ទឹមនឹងដំណើរការនៃការរីកចំរើនសេដ្ឋកិច្ច យើងសង្កេតឃើញថា ក៏មានការរីកចំរើនយ៉ាងខ្លាំង អំពីការរីកចំរើនផ្នែកចំណេះដឹង (Knowledge) និងចំណេះធ្វើ (Know-how)។ ក្នុងការជម្រុញ

កំណើនសេដ្ឋកិច្ច គេត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើចំណេះដឹងចំណេះធ្វើ គំនិតផ្តួចផ្តើម ដែលនេះជាចំណុចសំខាន់ ក្នុងការប្រកួតប្រជែងដណ្តើមទីផ្សារដណ្តើមឧត្តមភាពពីប្រទេសជិតខាងនិងពីតំបន់នានា។ ការប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន ដូចជាវត្ថុធាតុដើម ចំនួនកំលាំងពលកម្មជាដើមមិនអាចជាការគ្រប់គ្រាន់ទេ ក្នុងការទៅដណ្តើមយកឧត្តមភាពពីគូប្រជែង។ អ្វីដែលជាអាទិភាពនៅក្នុងសេដ្ឋកិច្ចនោះ គឺមូលធនបញ្ញា (Intellectual Capital) ដែលមាននៅ ក្នុងធនធានមនុស្សប្រកបដោយសមត្ថភាព។ សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍មូលធនមនុស្ស (Human Capital) ប្រកបដោយសមត្ថភាព ចំណេះដឹងខ្ពស់ ជំនាញខ្ពស់ មិនទាន់មានអត្រាភាគរយខ្ពស់ ដូចជានៅបណ្តាប្រទេសជឿនលឿននៅឡើយទេ។ នៅក្នុងដំណើរសកលភាវូបនីយកម្ម គេកាន់តែខិតខំជម្រុញឱ្យកាន់តែខ្លាំងឡើង នូវសេរីភាវូបនីយកម្មទីផ្សារការបង្កើននូវភាពសំខាន់នៃមូលធនបញ្ញា ដើម្បីកំណើនសេដ្ឋកិច្ច និងការស្វះស្វែងរកឧត្តមភាពប្រៀបធៀបរបស់ប្រទេសរៀងៗខ្លួន។

មួយវិញទៀត ដែលយើងគួរធ្វើការពិចារណាដែរ គឺបញ្ហាវិបត្តិសេដ្ឋកិច្ច ដែលពិភពលោកយើងបានជួបប្រទះក្នុងពេលបច្ចុប្បន្ន។ នេះជាបញ្ហាប្រឈមមួយដ៏ធំសំរាប់ប្រទេសកម្ពុជា ក៏ដូចប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍។

*សកលភាវូបនីយកម្មសេដ្ឋកិច្ច*

តាមការពិត ដំណើរការនៃសកលភាវូបនីយកម្ម មិនមានអ្វីជាថ្មីទេ សំរាប់សង្គមមនុស្ស បាតុភូតនេះ បានកើតឡើងតាំងតែពីយូរលង់ណាស់មកហើយ។ លក្ខណៈបុរេ_សកលភាវូបនីយកម្ម ចាប់កកើតឡើងតាំងតែពីសង្គមបុរេបុព្វកាល តាំងតែពីពេលដែលមនុស្សលោកចាប់ផ្ដើមចេះធ្វើបំណែងចែកពលកម្ម (Division of Labor) មានផលិតកម្មទំនិញ (Production of Goods) នៅពេលនោះហើយក្រុមមនុស្សកុលសម្ព័ន្ធឬសហគមន៍ ចាប់ផ្ដើមមានទំនាក់ទំនងជាមួយសហគមន៍នានាដទៃទៀត។ បន្ទាប់មកនៅសតវត្សរ៍ទី១៦ទី១៧ និងទី១៨ និន្នាការនៃសកលភាវូបនីយកម្មចេះតែរីកចំរើនជាលំដាប់ស្រប ជាមួយការចាប់ផ្ដើមកំណើតនៃចរាចរមូលធននិងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ហើយសកម្មភាពនេះកាន់តែរីកដុះដាលកាន់តែខ្លាំងឡើង ស្របទៅតាមសកម្មភាពរីកចំរើននៃការដឹកជញ្ជូននិងទូរគមនាគមន៍។

ចាប់ពីក្រោយសង្គ្រាមលោកលើកទី២នេះ សេដ្ឋកិច្ចនៅក្នុងប្រទេស ទូទាំងពិភពលោកមានការរីកចំរើនយ៉ាងខ្ពស់។ វិស័យពាណិជ្ជកម្មក្រៅប្រទេស និងការបណ្ដាក់ទុននៅក្រៅប្រទេស និងការបណ្ដាក់ទុននៅក្រៅប្រទេស ក៏មានការវិវត្តន៍យ៉ាងខ្លាំងជាមួយគ្នានេះដែរ។ ដោយសារការកាត់បន្ថយកាន់តែច្រើនឡើង នូវរបាំងពាណិជ្ជកម្ម ការរីកចំរើនវិស័យទូរគមនាគមន៍ វិស័យពត៌មានវិទ្យា (Information Technology) វិស័យដឹកជញ្ជូន ដូច្នេះទីផ្សារទំនិញក្នុងពិភពលោក បានបើកកាន់តែទូលាយជាងមុន ប៉ុន្តែ ផ្ទុយទៅវិញភាពស្មុគស្មាញក៏កាន់តែមានកំរិត

ជ្រៅជាងមុនដែរ។ ដោយសារភាពលឿនលឿនផ្នែកអេឡិកត្រូនិក ការបង្វិលកាន់តែលឿន ធ្វើឱ្យចរាចរនៃមូលធនកាន់តែរហ័ស ជាពិសេសក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្ម (GATT) បានត្រូវបង្កើតឡើងក្នុងគោលបំណង ដើម្បីបង្កើនសេរីភាពវិស័យពាណិជ្ជកម្ម និងជាបន្តបន្ទាប់ទៅលើវិស័យនានាផ្សេងៗទៀត ដូចយ៉ាងវិស័យទេសចរណ៍ជាដើម។ និន្នាការនៃការកាត់បន្ថយ និងឈានទៅរកការលុបបំបាត់ចោលទាំងស្រុង នូវការត្រួតពិនិត្យមូលធន ការបើកទូលាយនូវដំណើរការទីផ្សារ គឺជាការរួមចំណែកមួយក្នុងការជួយជម្រុញវិស័យពាណិជ្ជកម្ម វិស័យវិនិយោគ និងទីផ្សារហិរញ្ញវត្ថុ (Financial Market) ឱ្យមានការរីកចំរើន។ បុព្វហេតុដូចបានលើកឡើងខាងលើនេះ ជាអំណោយផលល្អមួយ សំរាប់បង្កើនការបណ្តាក់ទុន ពីប្រទេសមានសេដ្ឋកិច្ចរីកចំរើនទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលធ្វើឱ្យប្រទេសក្រីក្រទាំងនោះអាចទទួលផលកម្រៃ និងសេដ្ឋកិច្ចរីកចំរើនបានយ៉ាងឆាប់រហ័ស។

គុណវិបត្តិមួយចំនួននៃសកលភាវូបនីយកម្ម

ទន្ទឹមនឹងគុណសម្បត្តិ ដែលបានលើកឡើងខាងលើនេះ ដំណើរការសកលភាវូបនីយកម្មក៏មានគុណវិបត្តិដែលគួរឱ្យធ្វើការកត់សំគាល់ដែរ។ ចំពោះប្រទេសកម្ពុជា វិស័យផលិតទំនិញអាចជួបប្រទះការលំបាកទីផ្សារកម្ពុជាតូច កំលាំងទិញតិច ដូច្នេះក្នុងការសាងសង់រោងចក្រប្រភេទដូចគ្នាតំលៃដើមត្រូវខ្ពស់ជាង (Economy of scale) យើងមិនអាច

ប្រកួតប្រជែងតំលៃជាមួយគេបាន។ យោងតាមច្បាប់វិនិយោគកម្ពុជាឆ្នាំ ១៩៩៤ មាត្រាទី១០ រដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយ។

គ្រោះថ្នាក់មួយ ដែលប្រទេសនានាអាចជួបប្រទះដែរ សំរាប់ប្រទេសសេដ្ឋកិច្ចកំពុងងើបឡើង គឺថាការបណ្តាក់ទុនយ៉ាងឆាប់រហ័សទៅក្នុងប្រទេសមួយ ក៏អាចមានដំណើរការ នៃការដកទុនយ៉ាងរហ័សចេញពីប្រទេសនោះវិញដែរ គឺនៅពេលដែលវិនិយោគិនបាត់សេចក្តីទុកចិត្តជាទូទៅនៅពេលមានវិបត្តិផ្សេងៗ ដូចជាវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ភាពមិនមានស្ថេរភាពផ្នែកនយោបាយ ជម្លោះជាតិសាសន៍ ជម្លោះសាសនាភាពខ្វះសន្តិសុខ។ល។ នៅក្នុងការបើកទូលាយទីផ្សារនេះ រដ្ឋាភិបាលត្រូវមានការគ្រប់គ្រងប្រកបដោយយន្តការ ដែលមានប្រសិទ្ធិភាព និងដោយប្រុងប្រយ័ត្នគឺថា ត្រូវអនុវត្តគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវការបង្កើតប្រព័ន្ធស្ថាប័នសមស្រប និងការបង្កើតនូវប្រព័ន្ធទ្រទ្រង់កម្រិតអន្តរជាតិសំខាន់ៗមួយចំនួនទៀត។

ចំណោទមួយដែលជារបស់កម្ពុជាផ្ទាល់ គឺថាប្រទេសកម្ពុជាយើងស្ថិតនៅក្នុងភាពម្ចាស់ការ ឯកោដាច់ពីគេ អស់រយៈពេលជាង ២៧សវត្ស។ យើងស្ថិតនៅដាច់ឆ្ងាយពីចរន្តសេរីភាវូបនីយកម្មពាណិជ្ជកម្មមិនបានចូលរួមនៅក្នុងខ្សែចង្វាក់ នៃការពង្រីកវិស័យពាណិជ្ជកម្មអន្តរជាតិ និងមិនបានទទួលការបណ្តាក់ទុនអ្វីជាដុំកំភួនពីសំណាក់លោកខាងលិច។ អាស្រ័យហេតុនេះ កិរិតនៃការរីកចំរើនវិស័យសេដ្ឋកិច្ច និងការអភិវឌ្ឍន៍

ធនធានមនុស្ស នៅមានការអន់ថយនេះជាកត្តាសំខាន់នៃភាពក្រតោកយ៉ាកនៃប្រជាជនកម្ពុជា។

ផលប៉ះពាល់នៃសកលភាវូបនីយកម្មមកលើសង្គមកម្ពុជា

ក្រោយពីបានវិភាគ ពិចារណា ទៅលើចំណុចនានានៃគុណសម្បត្តិ និងគុណវិបត្តិនៃសកលភាវូបនីយកម្មរួចមកកម្ពុជា ក៏សំរេចចិត្តបញ្ចូលខ្លួនទៅក្នុងចរន្តសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក។ កម្ពុជាសង្ឃឹមថា ខ្លួននឹងបានទទួលនូវអត្ថប្រយោជន៍នានាជាច្រើន អំពីការធ្វើសមាហរណកម្មនេះ ជាពិសេសសេដ្ឋកិច្ចនឹងមានការលូតលាស់ល្អជាងមុន និងអាចតាមទាន់ប្រទេសនានាជិតខាងបាន។ ក្នុងការប្រណាំងប្រជែងសេដ្ឋកិច្ចជាមួយប្រទេសជិតខាង កម្ពុជាបច្ចុប្បន្នមានកាតព្វកិច្ចជាច្រើនដែលត្រូវបំពេញជារួមកម្ពុជាត្រូវប្រើប្រាស់នូវឧត្តមភាពប្រៀបធៀបរបស់ខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន និងត្រូវប្រើប្រាស់នូវកត្តាអភិវឌ្ឍន៍ទាំងប៉ុន្មានដែលខ្លួនមាន។ ដោយសារកម្ពុជាទើបបានចូលក្នុងចរន្តសេដ្ឋកិច្ច ក្នុងតំបន់ក្រោយគេនោះ។ វិស័យឧស្សាហកម្មមានភាពទន់ខ្សោយ ជាពិសេសផ្នែកបច្ចេកវិទ្យាទំនើប (High-Technology) មិនឱ្យយកវិស័យនេះមកធ្វើជាឧត្តមភាព ដណ្តើមឈ្នះបានទេ។ អ្នកជំនាញការជាច្រើនហាក់មានការឯកភាពគ្នាថា ឧត្តមភាពប្រៀបធៀបកម្ពុជា គួរតែជាវិស័យកសិកម្ម ដូចជាស្រូវ សណ្តែក កសិផល កៅស៊ូ ឈើ ប្រសិនបើប្រើប្រាស់ត្រឹមត្រូវវិស័យ កសិ-

ឧស្សាហកម្ម និងវិស័យទេសចរណ៍។ បច្ចុប្បន្នកំណើននៃវិស័យទាំងនេះមាននៅទាបនៅឡើយ។

អាស្រ័យដោយនយោបាយបើកចំហសេដ្ឋកិច្ចប្រទេសកម្ពុជាបានទទួលលំហូរមូលធនពីបរទេស (FDI) យ៉ាងច្រើនគួរជាទីមោទនៈ។ ការបណ្តាក់ទុនពីបរទេស ចាប់ពីឆ្នាំ១៩៩៤ មកទល់ចុងឆ្នាំ២០០០ មានតួលេខទុនវិនិយោគដូចខាងក្រោម :

| Year | 1994 | 1995 | 1996 |
|---|---|---|---|
| Number of Project | 38 | 162 | 1997 |
| Capital Investment (Million USD) | 599 | 1,941 | 1997 |

| Year | 1997 | 1998 | 1999 | 2000 (up to October) |
|---|---|---|---|---|
| Number of Project | 206 | 143 | 99 | |
| Capital Investment (Million USD) | 759 | 854 | 853 | |

សរុបមក ប្រទេសកម្ពុជាបានទទួលគម្រោងវិនិយោគ គិតជាទឹកប្រាក់មកទល់នឹងខែតុលាឆ្នាំ២០០០ ចំនួន៦.០៤០លានដុល្លារ។ ក្នុងចំណោមគម្រោងទាំងនេះ មានប្រមាណតែ៦០%ទេ ដែលបានអនុវត្ត។ ទឹកប្រាក់ នៃការបណ្តាក់ទុនខាងលើ បានធ្វើឱ្យមានចលនាអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ បានផ្តល់ការងារដល់ប្រជាជនខ្មែរប្រមាណ១៤០.០០០នាក់

ការផ្ទេរបច្ចេកវិជ្ជា ការបង្កើនចំណូលដល់ប្រជាជន ការបង្កើនចំណូលចូលដល់ថវិការដ្ឋ តាមរយៈការបង់ពន្ធដារបង្កើនការនាំចេញផលិតផលសំរេចនិងបង្កើនល្បឿនចរន្តសេដ្ឋកិច្ចនៅក្នុងទូទាំងប្រទេស។

ចំណែកឯលំហូរទុនជាលក្ខណៈវិនិយោគសាធារណៈវិញប្រទេសកម្ពុជាបានទទួលដូចខាងក្រោមៈ

| Year | 1992 | 1993 | 1994 | 1995 |
|---|---|---|---|---|
| Capital Investment (Million USD) | 250 | 321 | 358 | 513 |

| Year | 1996 | 1997 | 1998 | 1999 | 2000(Est.) |
|---|---|---|---|---|---|
| Capital Investment (Million USD) | 518 | 383 | 433 | 400 | 445 |

សរុបមក ប្រទេសកម្ពុជាបានទទួលជំនួយពីបរទេស ពីឆ្នាំ ១៩៩២-១៩៩៩ បានចំនួន៣.១៧២ លានដុល្លារ។ សំរាប់ឆ្នាំ២០០០ កម្ពុជា បានទទួលការសន្យានូវទឹកប្រាក់ជំនួយ៥៤៨លានដុល្លារ។

សេចក្តីសន្និដ្ឋាន :

បច្ចុប្បន្ននេះប្រទេសកម្ពុជា បានហក់ចូលទៅក្នុងចរន្ត នៃសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងក្នុងសេដ្ឋកិច្ចពិភពលោក ក្រោយពីបានរស់នៅក្នុងភាពឯកោ ម្នាស់ការអស់រយៈពេលជាង ២ទសវត្សរ៍រួចមក។ ការបើកចំហសេដ្ឋកិច្ចគឺជាការលំបាកមួយជាបញ្ហាប្រឈមជាចំណោទ

មួយចំនួនសំរាប់កម្ពុជារយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែ វាអាចនឹងផ្តល់នូវឱកាស និងផលប្រយោជន៍ជាច្រើនមកដល់កម្ពុជា សំរាប់ដំណើរការអភិវឌ្ឍន៍សង្គមរបស់ខ្លួនសំរាប់រយៈពេលវែងឆ្ងាយទៅអនាគត។ សកលភាវូបនីយកម្មសេដ្ឋកិច្ចជាកត្តាដ៏ចំបង សំរាប់លើកស្ទួយជីវភាពប្រជាជន និងការរីកចំរើនសង្គមកម្ពុជា។ ការរៀបចំច្បាស់លាស់ និងត្រឹមត្រូវអំពីផលប៉ះពាល់ គឺជាកត្តាមួយដែលកម្ពុជាអាចគ្រប់គ្រងបាននូវគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ដែលជះឥទ្ធិពល យ៉ាងខ្លាំងដល់អាយុជីវិតនៃសេដ្ឋកិច្ចកម្ពុជា។ ប្រទេសកម្ពុជាបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីវិបត្តិសេដ្ឋកិច្ចក្នុងតំបន់នេះ ជាបទពិសោធន៍មួយដ៏ល្អ សំរាប់អ្នករៀបចំគោលនយោបាយសេដ្ឋកិច្ចកម្ពុជា ដើម្បីបង្កើនការប្រុងប្រយ័ត្ន សំរាប់កិច្ចដំណើរសេដ្ឋកិច្ចដ៏សំខាន់របស់ខ្លួន។ យើងមានការសង្ឃឹមជឿជាក់ថាសកលភាវូបនីយកម្មនឹងនាំ នូវភាពរីកចំរើនវិបុលភាពនិងអនាគតភ្លឺស្វាងសំរាប់កម្ពុជា។

## ៧.១២ សុន្ទរកថាថ្លែងដោយ លោក ញ៉ែម ចណ្ណថន នាយកប្រតិបត្តិអង្គការសិទ្ធិមនុស្សខ្មែរនិងប្រឆាំងអំពើពុករលួយ ស្តីអំពី "សកលភាវូបនីយកម្មនិងផលប៉ះពាល់មកលើសង្គមស៊ីវិលកម្ពុជា : ការគ្រប់គ្រងតម្លៃចាយវាយ និងទាញយកផលប្រយោជន៍ឲ្យបានអតិបរិមា"

បញ្ហាសន្តិសុខមនុស្សនៅក្នុងសង្គមជាតិកម្ពុជា ដែលបានឆ្លងកាត់ក្នុងអំឡុងជាងពាទសវត្សរ៍កន្លងទៅនេះ គឺមានសភាពធ្លាក់ចុះដល់កម្រិត ដោយសារតែសីលធម៌របស់មេដឹកនាំខ្មែរគ្រប់និន្នាការ នៃលទ្ធិរបបនយោបាយគ្រប់គ្រងរបស់ពួកគេ បានរងនូវការស្រុតចុះយ៉ាងខ្លាំងព្រោះតែពួកគេបានខិតខំប្រឹងប្រែងប្រជែងគ្នា រៀនសូត្រនូវមនោគមន៍វិជ្ជាបរទេស ដើម្បីធ្វើសង្គ្រាមដណ្តើមអំណាចរវាងពូជអំបូរគ្នាឯងយ៉ាងជក់ចិត្តភ្លេចខ្លួន។ ជាង៣០ឆ្នាំកន្លងទៅនេះ ពួកឈ្មួញសង្គ្រាមបរទេសគេបានជ្រៀតចូលមកញុះញង់សង្គមជាតិខ្មែរលើគ្រប់វិស័យ ជាហេតុនាំឱ្យកើតមានជម្លោះនៅក្នុងសហគមន៍ជាតិគ្នាឯងតែម្តង តែប្រទេសគេនៅជិតខាងប្រទេសឯងវិញ មេដឹកនាំរបស់ពួកគេបានជាប់ដៃរវល់ដឹកនាំប្រជាពលរដ្ឋរបស់គេឱ្យខិតខំធ្វើការអភិវឌ្ឍន៏កសាងប្រទេសជាតិ សំរាប់ការរីកចំរើនទៅមុខលើគ្រប់វិស័យ។ ប៉ុន្តែផ្ទុយទៅវិញ មេដឹកនាំប្រទេសខ្មែរឯង បែរជាដឹកនាំប្រជាពលរដ្ឋរបស់ខ្លួន បោះជំហានដើរថយក្រោយអស់ជាង៣០ឆ្នាំ នៅក្នុងការជាប់ដៃធ្វើសង្គ្រាមរហូត និងបន្តមកដល់សព្វ

ថ្ងៃនេះទៀត ហើយមេរៀនបែបនេះ ដែលជាបទពិសោធន៍ដ៏សែនជូរចត់ កន្លងមកនៅពុំព្រមភ្ញាក់រលឹកដឹងខ្លួនទាល់តែសោះ ចេះតែចង់ដឹកនាំទៅរកការធ្វើសង្គ្រាមសារជាថ្មីម្តងហើយម្តងទៀត ព្រោះតែអំណាច។

ជាការពិតណាស់ កាលណានិយាយដល់សង្គ្រាម គឺយើងចងចាំអំពីឥទ្ធិពលរបស់វា និងលទ្ធផលរបស់វាមិនភ្លេច ដែលនាំឱ្យមនុស្សខ្មែរបាត់បង់ជីវិត ស្ថេរភាពសន្តិសុខលើគ្រប់វិស័យតែម្តង ម្ល៉ោះហើយនៅឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិ គេអាណិតដល់សង្គមខ្មែរ ឃើញមនុស្សខ្មែរស្លាប់រង្គាលរាប់លាននាក់ ព្រាត់ប្រាស់ញាតិមិត្ត រត់ភៀសខ្លួនចេញពីស្រុកកំណើតទៅសុំទានប្រទេសគេជិតខាងជ្រក។ ដោយប្រទេសរាប់រយជាសមាជិកអង្គការសហប្រជាជាតិ នៅជុំវិញលើសកលលោក គេបានប្រមូលផ្តុំថវិកាលុយគ្នាយកមកជួយដល់ជាតិកម្ពុជា សំរាប់បោះឆ្នោតដោយសេរី តាមបែបលទ្ធិប្រជាធិបតេយ្យធ្វើជាគោលមាគ៌ា ឱ្យមានការប្រកួតប្រជែងគ្នាធ្វើល្អជូនសង្គមជាតិខ្មែរ នៃបក្សពួកក្រុមនយោបាយនានាដែលមានទំនាស់នឹងគ្នា តែងតែប្រើកាំភ្លើងប្រជែងគ្នាដឹកនាំសង្គមជាតិឱ្យបែរមកយកជំនួសដោយការប្រជែងគ្នាទៅតាមបែបការបោះឆ្នោតដោយសេរីយុត្តិធម៌ គ្មានការបង្ហូរឈាមជាតិគ្នាឯងទៀតឡើយ។

### ប្រវត្តិសន្តិសុខរបស់សង្គមមនុស្សខ្មែរ :

តើសន្តិសុខសង្គមមនុស្សគេសំដៅទៅលើអ្វីខ្លះ...? បើតាមទ្រឹស្តីអ្នកសង្គមវិទូបានពោលថា សន្តិសុខរបស់មនុស្ស គឺពុំមែននិយាយសំដៅតែទៅលើការជៀសផុត ពីអំពើត្រូវគេវាយដំធ្វើបាបលើរូបរាង

កាយប៉ុណ្ណោះនោះឡើយ ផ្ទុយទៅវិញគឺមនុស្សគួរត្រូវមានសន្តិសុខរបស់ខ្លួនល្អប្រសើរ ដោយផ្អែកទៅលើកត្តា៤យ៉ាងធំៗ ចាំបាច់ជាមូលដ្ឋាន ដែលធាតុទាំងនោះរួមមានៈ ១_ការទទួលសន្តិសុខខាងសេដ្ឋកិច្ច ២_ការទទួលសន្តិសុខខាងអារ្យធម៌_វប្បធម៌ ៣_ការទទួលសន្តិសុខខាងជំរកស្នាក់អាស្រ័យរស់នៅ និង ៤_ការទទួលសន្តិសុខខាងជំនឿសាសនា និងលទ្ធិនយោបាយ។

## សន្តិសុខមនុស្សខាងសេដ្ឋកិច្ច :

មនុស្សពុំអាចរស់នៅមានសេចក្តីសុខបានទេ ប្រសិនណាគេមិនមានស្ថេរភាពខាងសន្តិសុខសេដ្ឋកិច្ចឱ្យល្អគត់មត់ទេនោះ។ ជាទ្រឹស្តីបទរបស់ធម្មជាតិ មនុស្សគ្រប់រូបបើទោះជាមានជាតិសាសន៍អ្វីក៏ដោយ គេមានសិទ្ធិដូចៗគ្នា នាំចំពោះការទទួលបានខាងសន្តិសុខស្បៀងអាហារបរិភោគគ្រប់គ្រាន់ និងគ្រឿងឧបភោគនានា សំរាប់ប្រើប្រាស់ ដែលនេះគឺជាធនធានធម្មជាតិ បានផ្តល់ឱ្យពួកគេនៅលើទឹកដីរបស់គេ តាំងពីកំណើតមកម្ល៉េះ។ ឧទាហរណ៍ជាក់ស្តែង ដូចជាមនុស្សខ្មែរ ឬសង្គមខម_ខ្មែរ ឬ មន_ខ្មែរ គេមានភ័ព្វសំណាងយ៉ាងល្អខាងសន្តិសុខសេដ្ឋកិច្ច បើប្រៀបធៀបទៅប្រជាជាតិ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកយើងនេះ ដែលបានកើតមកនៅលើទឹកដីអ្នកផងហៅថា *ជ្រោយសុវណ្ណភូមិ* គឺសម្បូរទៅដោយភោគទ្រព្យគ្រប់បែបយ៉ាងរួមមាន : ផលដំណាំកសិកម្មមច្ឆាជាតិ សត្វពាហនៈគ្រប់ប្រភេទ ព្រៃឈើ រ៉ែត្បូងពេជ្រ រ៉ែមាសប្រាក់ រ៉ែដែក រ៉ែប្រេង ជ័រកៅស៊ូ ថ្ម ស៊ីម៉ង់ និងមានបឹង ទន្លេ សមុទ្រ

ដែលធនធានទាំងនេះ បានបង្កលក្ខណៈដ៏យ៉ាងងាយស្រួលឱ្យដល់សង្គមមនុស្សខ្មែរ រស់នៅមានសេដ្ឋកិច្ចសម្បូរធូធារក្រៃលែង គ្មានការព្រួយបារម្ភឡើយ។

**សន្តិសុខមនុស្សខាងអារ្យធម៌_វប្បធម៌ :**

ជាតិមនុស្សនៃពូជសាសន៍ណាក៏ដោយ កាលបើរស់នៅផ្ដុំគ្នាក្នុងសង្គមជាតិមួយហើយ គេតែងតែមានអារ្យធម៌ និងវប្បធម៌របស់ពួកគេរៀងៗខ្លួន ដោយមិនគិតថាជាសង្គមជតិតូចឬធំឡើយ។ អារ្យធម៌_វប្បធម៌នៃសង្គមជាតិសាសន៍នីមួយៗ គឺប្រៀបដូចជាកញ្ចក់ឆ្លុះបញ្ចាំងអំពី ភាពរីកចំរើនជឿនលឿននៃសង្គមជាតិនោះដូចជា : ប្រពៃណីទំនៀមទំលាប់ សិល្បៈចម្លាក់ ចរិយាធម៌ សីលធម៌ សុជីវធម៌ សាមគ្គីធម៌។ល។ ចំពោះសង្គមជាតិកម្ពុជា វិស័យអារ្យធម៌_វប្បធម៌នេះគឺបានល្បីខ្ទរខ្ទារ លើសកលលោក ដែលអ្នកផងបានចាត់ថា ពិតជាសង្គមជាតិមួយអ្នកមានស្ដុកស្ដម ខាងអារ្យធម៌ និងវប្បធម៌ពិតៗមែន ហើយមានជាតិសាសន៍នៅលើពិភពលោកតិចណាស់ ដែលមានសំណាងទទួលបានបែបយ៉ាងដូចនេះ។

**សន្តិសុខមនុស្សខាងជំរក_ដីធ្លីសំរាប់ការស្នាក់នៅ :**

សង្គមជាតិមនុស្សខ្មែរ មានប្រវត្តិជាអ្នកមានដីធ្លីធំទូលាយ ដែលលាតសន្ធឹង នៅលើទឹកដីកោះនៃដងទន្លេមេគង្គ បើយើងគិតត្រឹមត្រឹសសករាជ ឆ្នាំ១៨១២ មានទឹកដីអណាខេត្ត_ក្រុងសរុបជាង៥០ សំរាប់ឱ្យប្រជានុរាស្ត្រសង់ជំរកស្នាក់នៅបានសុខស្រួល ដោយគ្មានភ័យព្រួយ

អ្វីឡើយ។ មិនតែប៉ុណ្ណោះ សង្គមខ្មែរនៅមានស្ថាបត្យកម្មដ៏ល្បី ខាងការសាងសង់សំណង់អាគារថ្មជាច្រើន ហើយពួកអ្នកផងថា មនុស្សខ្មែរនេះ មានប្រាសាទថ្ម និងផ្ទះថ្មអាស្រ័យនៅមុនគេបង្អស់ តែក្រោយៗតមក ទឹកដីផ្ទះសម្បែងនៃប្រជាជាតិ ខម_ខ្មែរ បានត្រូវជនបរទេសទាំងជិតទាំងឆ្ងាយមានមហិច្ឆតាលេបយកអស់ នៅគ្រប់ពេលបែកបាក់សាមគ្គីក្នុងរង្វង់សង្គមជាតិ។ គេញុះញង់ឱ្យស្រុកខ្មែរកើតមានសង្គ្រាម ឈ្លោះប្រកែកបងប្អូនឯង ពេលនោះហើយ ដែលជាឱកាសសំរាប់ជនបរទេសអស់ នោះប្រើល្បិចគ្រប់គ្រងទាំងស្រុកខ្មែរតែម្តង។ សព្វថ្ងៃទឹកដីនៅសល់តិចតួចណាស់ទៅហើយ បើប្រៀបជាមួយនឹងជំនាន់មុនៗ។

## សន្តិសុខមនុស្សខាងជំនឿសាសនា_លទ្ធិរបបនយោបាយ

កាលណាគេនិយាយដល់សន្តិសុខខាងជំនឿសាសនា និងរបបនយោបាយ ត្រូវនិយាយដល់សិទ្ធិខាងជំនឿសាសនា និងនយោបាយផងដែរ ដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលនៃអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមានជំនឿនិងការចូលរួមនយោបាយនៅក្នុងសហគមន៍របស់ខ្លួននីមួយៗផងដែរ។ តាំងពីបុរាណកាលរៀងមកសន្តិសុខនៃការសម្តែងជំនឿសាសនា គឺត្រូវបានបន្តគ្រប់ៗ ជំនាន់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិមិនថា ស្ថិតក្នុងស្ថានភាពមានសង្គ្រាមឬក៏មានសន្តិភាពនោះឡើយ។

ចំណែករឿងសន្តិសុខខាងនយោបាយវិញ ជាទូទៅប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ គេយកចិត្តទុកដាក់លើវិស័យការការពារ

សន្តិសុខធនធានមនុស្ស និងសន្តិសុខហិរញ្ញវត្ថុ នៃអ្នកនយោបាយ ទៅតាមគោលមាគ៌ាច្បាប់ជាមូលដ្ឋាន។ ដោយមនុស្សអ្នកធ្វើនយោបាយ គេមានសិទ្ធិសំរាប់ជ្រើសរើសលទ្ធិគណបក្សនយោបាយដោយសេរី ហើយជាអាទិភាពបំផុតនោះ គឺចំពោះអារ្យប្រទេសប្រជាធិបតេយ្យធំៗ នៅលើលោកមួយចំនួន គេនៅមានគោលនយោបាយ យកចិត្តទុកដាក់ទៅលើការបង្កើតសាលាហ្វឹកហ្វឺនរៀនសូត្រ ចំណេះដឹងខាងធ្វើនយោបាយដល់និសិត្ស បញ្ញវន្ត ដែលមានចំណង់ចំណូលចិត្តចាប់យកការងារខាងអ្នកធ្វើនយោបាយយ៉ាងត្រឹមត្រូវទៀតផង។ ជាការពិតណាស់ កាលណាសង្គមជាតិមួយមានធនធានមនុស្ស ខាងអ្នកធ្វើនយោបាយច្រើន ហើយបានធ្វើការហ្វឹកហ្វឺនច្បាស់លាស់ត្រឹមត្រូវល្អ ជាកិរិតជាតិ និងអន្តរជាតិក្តី គឺសង្គមជាតិនោះ ពុំងាយនឹងធ្លាក់ចូលទៅរកការធ្វើសង្គ្រាមឡើយ ផ្ទុយទៅវិញ បញ្ញវន្ត នយោបាយនិងអ្នកធ្វើនយោបាយទាំងនោះ គេអាចដឹកនាំប្រជាពលរដ្ឋ ឱ្យគេចផុតពីមហន្តរាយផ្សេងៗ ដែលវាប៉ុរុងនឹងកើតឡើងបានយ៉ាងងាយ ហើយមិនតែប៉ុណ្ណោះ អាចនាំសង្គមជាតិឱ្យឈានទៅរកវឌ្ឍនភាពលើគ្រប់វិស័យ។

## បញ្ហាចម្បងៗដែលសង្គមស៊ីវិលកម្ពុជាកំពុងប្រឈមមុខនាពេលបច្ចុប្បន្ន ចំពោះសន្តិសុខមនុស្សខ្មែរ

ចំពោះកម្មវត្ថុខាងលើនេះ យើងនឹងលើកយកបញ្ហាសង្គមស៊ីវិលកម្ពុជា ត្រឹមពេលមានការស្រុតចុះយ៉ាងខ្លាំង នៅដំណាក់កាលចុងក្រោយដែលគិតចាប់ពីឆ្នាំ១៩៧០ មកដល់ឆ្នាំ ២០០០ មកជំរាបជូនតែប៉ុណ្ណោះ

ដើម្បីឱ្យយើងងាយស្រួលរកមើលមុខក្រុមអ្នកបង្កបញ្ហានេះឡើង ព្រោះថាមនុស្សខ្មែរមួយចំនួន បាននឹងកំពុងរស់នៅសព្វថ្ងៃនេះនៅឡើយ ពេលយើងនិយាយទៅក្រែងពួកគេអាចជួយដោះស្រាយបញ្ហាសង្គមជាមួយយើងនាពេលបច្ចុប្បន្ននេះបាន។

ឆ្នាំ១៩៧០_១៩៧៥ មានការធ្វើរដ្ឋប្រហារមួយគួរឱ្យរន្ធត់ ដែលពួកអ្នកនយោបាយ បានកេណ្ឌជនស៊ីវិលកម្ពុជាយ៉ាងច្រើន ឱ្យចូលរួមគាំទ្រការធ្វើរដ្ឋប្រហារនេះ ដែលយើងនៅចាំមេដឹកនាំធ្វើរដ្ឋប្រហារនោះបានគឺឧត្តមសេនីយ៍ លុន នល់ ដែលបានផ្តួលរំលំរបបរាជានិយម ដឹកនាំដោយសម្ដេច នរោត្តម សីហនុ។ រដ្ឋប្រហារនេះ បានបង្កឱ្យមនុស្សស្លាប់រាប់ម៉ឺននាក់ ហើយអ្នកនយោបាយជាច្រើននាក់ បានត្រូវគេចាប់សម្លាប់រាប់រយនាក់។ រដ្ឋាភិបាលរដ្ឋប្រហារមួយ បានត្រូវបង្កើតឡើង ហើយមេដឹកនាំរដ្ឋប្រហារនេះ គេបានតាំងខ្លួនជាប្រមុខរដ្ឋនៃរបបរបស់ខ្លួន ដែលបានដាក់ឈ្មោះរដ្ឋាភិបាលនេះថា *របបសាធារណៈរដ្ឋខ្មែរ* ប៉ុន្តែ ដោយសារមេដឹកនាំអសមត្ថភាព បានបណ្ដាលឱ្យកើតមានពួកមន្ត្រីពុករលួយជាច្រើនយ៉ាងឆាប់រហ័ស ពួកមន្ត្រីទាំងនោះ គេបានផ្ដើមកេងប្រវ័ញ្ចន៏យកសម្បត្តិទ្រព្យជាតិ ឃុបឃិតជាមួយឈ្មួញទុច្ចរិតលួចលក់ក្បាលអ្នកតា លួចលក់វត្ថុបុរាណជាសម្បត្តិវប្បធម៌ជាតិ ធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចសង្គមជាតិចាប់ផ្ដើមធ្លាក់ចុះដល់គិរិត ជាហេតុធ្វើឱ្យអសន្តិសុខស្បៀងអាហារសង្គម ហើយមនុស្សខ្មែរជាច្រើន បានធ្លាក់ខ្លួនក្រតោកយ៉ាកឈ្មួញទុច្ចរិតតំឡើងថ្លៃទំនិញស្រេចចិត្ត គ្មានមន្ត្រីណាម្នាក់អាចចេញមុខ

ដោះស្រាយបញ្ហានេះបានឡើយ។ ចំពោះការបាញ់សម្លាប់គ្នា ដើម្បីរករស់រៀងៗខ្លួន ក៏កើតមានឡើងស្ទើររាល់ថ្ងៃ មនុស្សគ្រួសារអ្នកមានៗគេចាប់ផ្តើមរត់ចេញទៅក្រៅប្រទេស អ្នកក្រចាប់ផ្តើមភៀសខ្លួនរត់គេចពីការបាញ់គ្នានៅជនបទ ហើយសំរុកចូលមកទីក្រុងរាប់ម៉ឺននាក់ កាន់តែមានចំនួនច្រើនឡើងៗរាល់ថ្ងៃ សង្គ្រាមបានផ្ទុះឡើងនៅពាសពេញលើផ្ទៃប្រទេស មនុស្សខ្វះទីជំរកសំរាប់ស្នាក់នៅ ជម្ងឺឆ្លងបានរីករាលដាលយ៉ាងឆាប់រហ័ស ហើយគ្មានថ្នាំសំរាប់ព្យាបាលជម្ងឺឡើយ ជាហេតុធ្វើឱ្យមានសម្លាប់ជីវិតមនុស្ស ជាពិសេសកុមារ និងស្ត្រីមានផ្ទៃពោះរាប់ពាន់ម៉ឺននាក់ក្នុងមួយឆ្នាំៗ។ ចំណែកពួកយុវជន និងនិស្សិតគេពុំមានពេលគ្រប់គ្រាន់បានទៅរៀនទៀងទាត់ត្រឹមត្រូវឡើយ បណ្តាលឱ្យកើតមានមនុស្សអវិជ្ជាកាន់តែកើនឡើងៗ នៅពាសពេញក្នុងសង្គមជាតិ។

ឆ្នាំ១៩៧៥_១៩៧៩ ដោយសារតែកើតមានអំពើអសន្តិសុខគ្រប់បែបយ៉ាងនៅក្នុងសង្គមជាតិនោះ កម្លាំងចលនាប្រឆាំងថ្មីមួយ បានលេចចេញជារូបរាងឡើងនៅតាមជនបទស្រែចំការ និងទីក្រុងភ្នំពេញ។ ក្រុមចលនានេះ បានធ្វើការឃោសនាដល់សង្គមស៊ីវិលកម្ពុជា ឱ្យចូលរួមជាមួយក្រុមពួកគេ ដើម្បីផ្តួលរំលំរបបអនាធិបតេយ្យពុករលួយ និងអស្ថេរភាពនេះចេញ ដោយកាលនោះចលនាមួយនេះ គេបានហៅខ្លួនឯងថាជា *រណសិរ្សខ្មែរកងរំដោះជាតិ* ដឹកនាំដោយមនុស្សមួយក្រុមដែលអ្នកខ្លះស្នាក់នៅក្នុងស្រុក អ្នកខ្លះទៀត ធ្វើសកម្មភាពនៅក្រៅស្រុក ហើយ បានវាយប្រហារផ្តួលរំលំរបបសាធារណរដ្ឋ របស់លោកឧត្តម

សេរីយ៉ា លុន ណុល រួចបានតាំងខ្លួនជារបបកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយលោក ប៉ុល ពត ហៅ សាឡុត ស នៅក្នុងឆ្នាំ ១៩៧៥ នោះទៅ។

របបលោក ប៉ុល ពត ត្រូវបានសង្គមជាតិស្គាល់ថា ជារបប ដែលគ្រប់គ្រងប្រទេស តាមបែបលទ្ធិកុម្មុយនីស្តផ្តាច់ការ ដែលមាន ប្រទេសចិនកុម្មុយនីស្តប្រជាមានិតធ្វើជាបង្អែក។ នៅក្នុងរយៈពេលពួកគេ កាន់កាប់អំណាចរបបកុម្មុយនីស្តផ្តាច់ការនេះ ដោយមានអ្នកជំនាញការ មកពីប្រទេសចិនកុម្មុយនីស្តផងនោះ ពួកគេបានសម្លាប់ជីវិតមនុស្សខ្មែរ រាប់លាននាក់ រួមទាំងព្រះសង្ឃ គ្រូបង្រៀន វេជ្ជបណ្ឌិត ប៉ូលីស ទាហាន និសិត្ស ក្រុមព្រះរាជវង្សានុវង្សខ្មែរផងដែរ។ល។ នាពេលនោះ សន្តិសុខ ស្បៀងរបស់មនុស្សខ្មែរ គឺត្រូវពួករបបនេះបង្អត់ឱ្យដាច់ពោះស្ទើរ ទាំងស្រុង ហើយជំនឿសាសនាគ្មានអនុញ្ញាត វប្បធម៌ប្រពៃណីជាតិត្រូវ លុបបំបាត់ ចោលទាំងស្រុង ការសិក្សាអប់រំកីរិតជាតិ គឺគ្មានធនធាន មនុស្សខ្មែរនាពេលនោះ ត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យកុម្មុយនីស្ត ផ្តាច់ការបំផ្លាញចោលស្ទើរទាំងស្រុង។

ឆ្នាំ១៩៧៩_១៩៩០ ដោយសារតែមានអំពើប្រល័យពូជសាសន៍ យ៉ាងរង្គាលឃោរឃៅនៃរបបកុម្មុយនីស្តផ្តាច់ការ ដូចពោលជូនខាងលើ នេះហើយ បានជារបបកុម្មុយនីស្តផ្តាច់ការនេះ ត្រូវចលនាថ្មីមួយផ្សេង ទៀត ដែលគេហៅខ្លួនឯងថាចលនារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមមានទាំងកងកម្លាំងប្រដាប់អាវុធបរទេស មកពីប្រទេសវៀតណាម

ជួយជ្រុំជ្រែងផង ចលនានេះដឹកនាំដោយលោក **ហេង សំរិន** បានធ្វើការវាយរំលំរបបកម្ពុជាប្រជាធិបតេយ្យហៅថា *ខ្មែរក្រហម* ដែលដឹកនាំដោយលោក **ប៉ុល ពត** ឱ្យចេញពីអំណាច។

ឆ្នាំ១៩៧៩ របបបក្សកុម្មុយនីស្តកម្ពុជាប្រជាមានិត ដែលដឹកនាំដោយលោក **ហេង សំរិន** ហើយដោយមានអ្នកជំនាញការមកពីប្រទេសវៀតណាម ជួយនាំផ្លូវផងនោះ បានធ្វើការគ្រប់គ្រងសង្គមជាតិបែបសហមូហភាព គឺអ្វីៗបក្សនិងរដ្ឋជាអ្នកគ្រប់គ្រងទាំងស្រុង។ របបនេះត្រូវបានសហគមន៍ជាតិ និងអន្តរជាតិមើលឃើញថា ចាប់បង្ខំយុវជនឱ្យកាន់កាំភ្លើង ដើម្បីទៅច្បាំងនឹងពួកបាក់ទ័ពខ្មែរក្រហមនៅក្នុងព្រៃតាមជាយដែន កេណ្ឌមនុស្សខ្មែរឱ្យទៅកាប់ព្រៃ កុំឱ្យខ្មែរក្រហម អាចពួនលាក់ខ្លួន ធ្វើសកម្មភាពប្រឆាំងតបវិញបាន។ កាលនោះមានមនុស្សខ្មែរស្លាប់ច្រើនណាស់ ដោយសារដើរជាន់គ្រាប់មីនបង្កប់ ក្នុងដីរបស់ពួកខ្មែរក្រហមនិងពួកសេរីការខ្មែរ ពេលនោះសហគមន៍អន្តរជាតិ បានហ៊ុំព័ទ្ធសេដកិច្ចរបបក្រុងភ្នំពេញ ដោយគ្មានអនុញ្ញាត ការធ្វើវិនិយោគទុនបើកចំហពីខាងក្រៅប្រទេសឡើង ពលរដ្ឋធ្លាក់ខ្លួនក្រលំបាក ចលនាប្រឆាំងទាមទារសេរីភាព បានបង្កើតកាន់តែច្រើនឡើងៗ នៅតាមព្រំដែនខ្មែរថៃ។ រីឯកងកម្លាំងប្រដាប់អាវុធរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាមានិតរួមផ្សំជាមួយកងកម្លាំងប្រដាប់អាវុធប្រទេសវៀតណាមផង នោះបានបើកធ្វើការប្រយុទ្ធរាល់ថ្ងៃនៅតាមជាយដែន ការអភិវឌ្ឍន៍ ប្រទេសជាតិគ្មានបានលើកផែនការណ៍ជាដុំកំភួនអ្វីឡើយ។

ឆ្នាំ១៩៩០_១៩៩៣ ពេលនេះជាដំណាក់កាលនៃការចរចា ពីសំណាក់បក្សពួកប្រឆាំងគ្នាគ្រប់ភាគី ដែលមានជាអាទិ៍ : ១_ក្រុមខ្មែរក្រហម (ដឹកនាំដោយលោក ប៉ុល ពត) ២_ក្រុមចលនាតស៊ូរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ដឹកនាំដោយលោក សឺន សាន) ៣_ក្រុមចលនាមូលីណាកា ឬចលនាហ៊្វុនស៊ិនប៉ិច (ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ) ៤_បក្សកុម្មុយនីស្តកម្ពុជាប្រជាមានិត (ដឹកនាំដោយលោក ហេង សំរិន)។ នៅក្នុងរយៈពេលអន្តរកាលនេះ សង្គមមនុស្សខ្មែរមានការលំបាកយ៉ាងខ្លាំងណាស់ ទាំងពួកអ្នកត្រូវធ្វើមាតុភូមិនិវត្តន៍ពីជំរំជាយដែន និងការធ្វើសកម្មភាពឃោសនារកសម្លេងឆ្នោត របស់បក្សភាគីនីមួយៗ ការប្រជែងគ្នានេះ បានធ្វើឱ្យមានមនុស្សខ្មែរស្លាប់ស្ទើររាល់ថ្ងៃ។ ពួកខ្មែរក្រហម គេបែរជាប្រកែកមិនព្រមចូលរួមការបោះឆ្នោតជាតិហើយបានធ្វើសកម្មភាពបាញ់សម្លាប់ជីវិតមនុស្ស គ្រប់ទីកន្លែងរហូតមានស្លាប់ជីវិតជនបរទេស ដែលជាអាជ្ញាធរអន្តរជាតិ អ៊ុនតាក់ ថែមទៀតផង។

ឆ្នាំ១៩៩៣_១៩៩៨ ការបោះឆ្នោតសង្គមជាតិខ្មែរមួយ ដែលនៅក្រោមការត្រួតពិនិត្យ និងឧបត្ថម្ភថវិការាប់ពាន់លានដុល្លារអាមេរិកពីអាជ្ញាធរអ៊ុនតាក់ បានត្រូវធ្វើឡើងដោយចប់សព្វគ្រប់។ ចំណែកឯលទ្ធផលនៃការបោះឆ្នោតនេះ គឺត្រូវបានគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានជ័យជំនះ ដោយសម្លេងឆ្នោតភាគច្រើន ក៏ប៉ុន្តែគណបក្សប្រជាជនកម្ពុជាម្ខាងមួយទៀត មិនព្រមទទួលយកលទ្ធផលនៃការរាប់សន្លឹកឆ្នោត

នេះឡើយ ដោយក្រុមនេះថាអាជ្ញាធរអ៊ុនតាក់ បានកេងបន្លំសន្លឹកឆ្នោតរបស់បក្សខ្លួនយកទៅឱ្យក្រុមហ្វុនស៊ិនប៉ិចទៅវិញ។

រដ្ឋប្រហារមួយបានកើតមានឡើង ដែលបង្កឡើងពីក្រុមគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស លោក ស៊ិន សុង និងបក្សពួកមួយចំនួនផ្សេងទៀត បើកធ្វើការវាយប្រហារទៅលើអាជ្ញាធរអ៊ុនតាក់ ឱ្យចាកចេញពីស្រុកខ្មែរជាបន្ទាន់។ ប៉ុន្តែពេលនោះមានអន្តរាគមន៍ពីសំណាក់ សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គយាងធ្វើជាអាជ្ញាកណ្តាល នៅក្នុងការចរចាជាមួយភាគីទាំងពីរឱ្យឈប់ធ្វើរដ្ឋប្រហារ ហើយសុំឱ្យអាជ្ញាធរអ៊ុនតាក់ដកទ័ពចេញភ្លាមៗ ជាប្រញាប់ពីកម្ពុជា។

ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលមួយ ដែលមាននាយករដ្ឋមន្ត្រីពីរនាក់ បានត្រូវបង្កើតឡើង។ សង្គមមនុស្សខ្មែរ បាននៅចាំបានច្បាស់ថា កាលនោះនាយករដ្ឋមន្ត្រីទី១ គឺព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទី ២ គឺលោក ហ៊ុនសែន ហើយចំណែកឯ រដ្ឋមន្ត្រីរដ្ឋលេខាធិការចៅក្រសួងមន្ទីរទូទាំងប្រទេស គឺសុទ្ធតែត្រូវដាក់ពីរនាក់ៗទាំងអស់ មានក្រសួងខ្លះដាក់រហូតដល់ទៅ៣នាក់ឯណោះ។ រដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រីពីរនេះ នៅឆ្នាំ១៩៩៧ បានឈ្លោះគ្នា ដោយសារមានមន្ត្រីពុករលួយច្រើននៅក្នុងក្រសួងមន្ទីរនីមួយៗ រហូតដល់មានការប្រើប្រាស់កម្លាំងអាវុធបាញ់សម្លាប់គ្នាយ៉ាងឃោរឃៅនៅកណ្តាលទីក្រុងភ្នំពេញ ពេលនោះមានជនស៊ីវិលខ្មែរស្លាប់ជាច្រើននាក់ និងរួមទាំងអ្នក

នយោបាយក៏ស្លាប់ច្រើនដែរ រីឯទ្រព្យសម្បត្តិជាតិ និងឯកជន មានការខូចខាតអស់ជាច្រើនពាន់លានដុល្លារអាមេរិក។

ឆ្នាំ១៩៩៨_២០០០ នៅពេលនេះគណបក្សឈ្លោះគ្នាទាំងអស់គេបានព្រមព្រៀងចូលមកបោះឆ្នោតសភាជាតិម្តងទៀត គណបក្សហ៊្វុនស៊ិនប៉ិច ដែលបានរត់ចូលព្រៃនៅជាយដែនខ្មែរ_ថៃ បានវិលចូលមកនេះវិញ តែការបោះឆ្នោតលើកនេះ គ្មានអាជ្ញាធរអ៊ុនតាក់នោះទេ គឺមានតែអាជ្ញាធរជាតិរៀបចំការបោះឆ្នោតខ្មែរខ្លួនឯង។ គណបក្សនយោបាយនានាដែលចូលរួមការបោះឆ្នោតនៅពេលនោះ បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ទៅលើសមាសភាពអាជ្ញាធរជាតិរៀបចំការបោះឆ្នោតនេះថា អាចមានការលំអៀងជាពុំខាន។ តែទោះជាយ៉ាងណាក្តី ការបោះឆ្នោតសភាជាតិឆ្នាំ១៩៩៨ ត្រូវប្រព្រឹត្តទៅតាមកាលកំណត់បានធ្វើឡើង ហើយការតវ៉ាពីសំណាក់គណបក្សនានា ក្រោយការបោះឆ្នោតនោះមានជាច្រើន បានធ្វើឡើងមែន ហើយលើកនេះក៏មានមនុស្សខ្មែរស្លាប់ជាច្រើននាក់ថែមទៀតដែរ ក្នុងមូលហេតុដើរក្បួនតវ៉ាអំពីលទ្ធផល នៃនីតិវិធីរាប់សន្លឹកឆ្នោត និងប្រព័ន្ធរាប់សន្លឹកឆ្នោត ថាមិនយុត្តិធម៌ត្រឹមត្រូវ។ នៅទីបញ្ចប់ សម្តេចព្រះនរោត្តម សីហនុ ទ្រង់បានយាងចូលធ្វើជាអាជ្ញាកណ្តាលម្តងទៀត ហើយការបែងចែកអំណាចរវាងគណបក្សពីរបានធ្វើឡើង គឺគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា រីឯគណបក្ស សម រង្ស៊ី នៅធ្វើជាគណបក្សប្រឆាំងក្រៅរដ្ឋាភិបាល តែមានសមាជិកអង្គុយនៅក្នុងរដ្ឋសភាដែរ។

ឆ្នាំ១៩៩៨ ពេលនោះរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រីតែម្នាក់ត្រូវបានបង្កើតឡើង ហើយរដ្ឋាភិបាលនេះបានហៅខ្លួនឯងថា *រាជរដ្ឋាភិបាលសេដ្ឋកិច្ច* ដែលមានមាគ៌ាទិសដៅ ធ្វើការកសាងសេដ្ឋកិច្ចជាតិឱ្យប្រសើរឡើងនិងមានគោលការណ៍កែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីឆ្ពោះទៅរកការគ្រប់គ្រងបែបអភិបាលកិច្ចល្អ មាននយោបាយកាត់បន្ថយភាពក្រីក្រសន្យាថានឹងបង្ក្រាបអំពើពុករលួយ។ល។

រដ្ឋាភិបាលសេដ្ឋកិច្ចអាណត្តិទី២នេះ គឺដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានខិតខំយ៉ាងខ្លាំង ដើម្បីឆ្លើយតបចំពោះម្ចាស់ឆ្នោត ពោលគឺសង្គមស៊ីវិលកម្ពុជាតែម្តង ដែលបានបោះឆ្នោតជូនតាមសេចក្តីសន្យារបស់ខ្លួន។ ប៉ុន្តែ មិនត្រឹមតែមិនបានប្រសើរឡើងដូចការគ្រោងទុក ឥឡូវនេះ រដ្ឋាភិបាលនេះបែរជាត្រូវប្រឈមមុខទល់នឹងឥទ្ធិពលនៃសកលភាវូបនីយកម្មទៅវិញ ព្រោះតែចង់ឱ្យសេដ្ឋកិច្ចសង្គមជាតិមានសន្ទុះឆាប់រីកចំរើន បានបើកចំហបច្ចេកវិជ្ជាគ្រប់ប្រភេទ ឱ្យហូរចូលមកក្នុងស្រុកដូចទឹកបាក់ទំនប់ ហើយពុំមានធ្វើច្បាប់ទាន់ពេលវេលា ការនេះបានប្រែក្លាយទៅជាជួបវិបត្តិ រាប់ពាន់ម៉ឺនបញ្ហាក្នុងសង្គមជាតិនាពេលបច្ចុប្បន្ននេះ។

យើងសង្កេតជារួមទៅ បញ្ហាដែលសង្គមជាតិកំពុងប្រឈមមុខនោះគឺ : ១_ការមិនគោរពច្បាប់ ២_ការខ្វះច្បាប់ ៣_មន្ត្រីពុករលួយកើតមានច្រើន ៤_ការរំលោភសិទ្ធិមនុស្ស មានការជួញដូរផ្លូវភេទ ជាពិសេសគឺកុមារ និងស្ត្រី ៥_ការរីករាលដាលជម្ងឺអេដស៍ ៦_ការកាប់

បំផ្លាញព្រៃឈើ នាំឱ្យខូចបរិស្ថាន ៧_កើតចោរម៉ាហ្វីយ៉ាចាប់ជីវិតច្រើន ៨_ជួញដូរគ្រឿងញៀនខុសច្បាប់ ៩_ជនអន្តោប្រវេសន៍ហូរចូលខុសច្បាប់ ១០_ប្រព័ន្ធតុលាការកាត់ក្ដីអយុត្តិធម៌ ប្រព្រឹត្តអំពើពុករលួយ ១១_មន្ត្រីរាជការភាគច្រើនចូលកាន់តំណែងទិញដូរបុណ្យសក្ដិ ១២_ការពុំដាក់ទោសពៃរ៍ដល់ជនមានទោស។ល។

ជាឧទាហរណ៍ នៅថ្ងៃទី២៣_២៤ ខែវិច្ឆិកា ឆ្នាំ២០០០ កន្លងទៅថ្មីៗនេះ មានករណីបាញ់សម្លាប់មនុស្សជាច្រើននាក់ ដែលនៅក្នុងយុទ្ធនាការមួយ ដែលហៅថា បង្ក្រាបជនចាស់ចោរមួយក្រុម ដែលអ្នកផងខ្លះហៅពួកនេះថា ជាចលនាខ្មែរសេរីឬអ្នកខ្លះទៀត គេហៅក្រុមនេះថា ជាពួកទាហ៊ានអស់ទឹកចិត្តក្នុងជួរកងទ័ព ដោយព្រោះរដ្ឋាភិបាលមិនបានបើកប្រាក់ខែឱ្យ២_៣ខែកន្លងមកហើយ។ ម្ល៉ោះហើយ សព្វថ្ងៃនេះគេឃើញមានអំពើបាញ់សម្លាប់គ្នា នៅកណ្ដាលទីក្រុងភ្នំពេញពេលថ្ងៃស្ទើររាល់ថ្ងៃ ករណីខ្លះបាញ់សម្លាប់ព្រោះតែគំនុំ ហើយករណីខ្លះទៀតបាញ់សម្លាប់ពាក់ព័ន្ធក្នុងរឿងនយោបាយថែមទៀតផង។ល។

## តួនាទីនិងក្ដីសង្ឃឹមរបស់សង្គមស៊ីវិលកម្ពុជា

សេចក្ដីសន្និដ្ឋានរួម :

តួនាទីសង្គមស៊ីវិលកម្ពុជា ដែលមានអង្គការ_សមាគមជាតិ និងអន្តរជាតិ ជាភ្នាក់ងាររបស់ខ្លួននោះ គឺបានមើលឃើញពីតួនាទីរបស់ខ្លួននោះគឺបានមើលឃើញពីតួនាទីរបស់ខ្លួនថា ១_ធ្វើការអប់រំនិងផ្សព្វផ្សាយ

ដល់សង្គមមនុស្សខ្មែរឱ្យស្គាល់អំពីសិទ្ធិរបស់ខ្លួននិងអំពីលទ្ធិប្រជាធិបតេយ្យ ២_ចូលរួម និងជំរុញឱ្យអាជ្ញាធរជាតិគ្រប់លំដាប់ថ្នាក់ ធ្វើការកែទម្រង់រដ្ឋបាលសាធារណៈ ៣_អនុវត្តការគ្រប់គ្រងសង្គមជាតិ ដោយផ្អែកទៅលើកត្តាអភិបាលកិច្ចល្អ ៤_ជម្រុញឱ្យមានការបោះឆ្នោតតាមបែបត្រឹមត្រូវយុត្តិធម៌ ៥_អប់រំប្រជាពលរដ្ឋឱ្យចេះបោះឆ្នោតនៅក្នុងការជ្រើសរើសមេដឹកនាំរបស់ខ្លួន ដែលរកមើលអ្នកណាមានចរិយាល្អមានឧត្តមគតិស្រឡាញ់ជាតិខ្ពស់ ៦_អំពាវនាវរកជំនួយបរទេសគ្រប់ប្រភេទ ដើម្បីយកមកជួយធ្វើការអភិវឌ្ឍន៍សហគមន៍ជាតិ ៧_ធ្វើជាដៃគូល្អជា មួយរដ្ឋាភិបាលណាដែលកើតឡើងត្រឹមត្រូវតាមរយៈការបោះឆ្នោតតាមច្បាប់។

ក្តីសង្ឃឹមរបស់អង្គការ សមាគមក្រៅរដ្ឋាភិបាលជាតិកម្ពុជា និងអន្តរជាតិ ដែលជាភ្នាក់ងាររបស់សង្គមស៊ីវិលកម្ពុជា បានមើលឃើញទៅអនាគតថា ១_អង្គការ សមាគមក្រៅរដ្ឋាភិបាលទាំងអស់ ពិតជាអាចរួបរួមគ្នាបានដោយធ្វើការចងក្រងជាបណ្តាញតាមផ្នែកនីមួយៗ ដើម្បីជួយសង្គមជាតិនៅលើគ្រប់វិស័យ ២_ម្ចាស់អ្នកផ្តល់ជំនួយបរទេស ប្រាកដជាអាចជួយឧបត្ថម្ភបន្ថែមមកទៀត ដល់សង្គមស៊ីវិលកម្ពុជា បើសិនណាសង្គមស៊ីវិលមានគោលដៅល្អ ៣_អង្គការ_សមាគម ដែលជាភ្នាក់ងារសង្គមស៊ីវិលកម្ពុជា ប្រាកដជាអាចយករដ្ឋាភិបាលធ្វើជាដៃគូល្អ ទាំងរដ្ឋាភិបាលអាណត្តិនេះនិងអាណត្តិក្រោយៗទៀត ៤_សង្ឃឹមថា រដ្ឋាភិបាលសេដ្ឋកិច្ចអាណត្តិទី២នេះ ពិតជាអាចស្តាបនាសេដ្ឋកិច្ចជាតិ ឱ្យបានរីកចំរើនឡើង ប្រសិបើ មានច្បាប់ប្រឆាំងអំពើពុករលួយជាមុនដែលអាច

ជួយឱ្យធ្វើការបង្ក្រាបចំពោះជនពុករលួយគ្រប់រូបភាព បានពិតមែននោះ និង ៥_សង្គមមនុស្សស៊ីវិលកម្ពុជាអាចនឹងមានសន្តិសុខបានប្រសើរឡើង លើគ្រប់វិស័យ និងអាចជៀសផុតពីសង្គ្រាមស៊ីវិលគ្រប់ៗជាតិបាន បើពួកអ្នកនយោបាយនិងមេដឹកនាំជាតិគ្រប់គ្នា ស្អប់ខ្ពើមសង្គ្រាម ហើយចេះគោរពតាមច្បាប់លទ្ធិប្រជាធិបតេយ្យគ្រប់ៗគ្នា៕

## ៧.១៣_សុន្ទរកថាថ្លែងដោយ លោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ស្ដីអំពី "តួនាទីសង្គមស៊ីវិលកម្ពុជាលើសន្តិសុខមនុស្ស : បញ្ហា និងក្ដីសង្ឃឹម"

## ១. ប្រវត្តិ :

ជាងបីទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានរងទុក្ខលំបាកដោយសារសង្គ្រាម អំពើប្រល័យពូជសាសន៍ និងភាពចលាចលនៃសង្គម។ សោកនាដកម្មនៃប្រជាជនកម្ពុជា បច្ចុប្បន្នបានចាប់ផ្ដើមក្នុងឆ្នាំ ១៩៧០ ដោយមានការរំលំព្រះមហាក្សត្រសីហនុ ដែលជាប្រមុខរដ្ឋនៅសម័យនោះ ដែលតាមជាប់មកជាមួយដោយសង្គ្រាមក្នុងស្រុក និងក្រៅស្រុកដ៏យូរអង្វែង។ នៅក្នុងសម័យនោះ របបនយោបាយបានផ្លាស់ប្ដូរពីរាជាធិតេយ្យទៅជាសាធារណរដ្ឋមូលធននិយម កុម្មុយនិស្តផ្ដាច់ការរបបសាធារណរដ្ឋសង្គមនិយមរួចហើយក៏ត្រឡប់មកកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញវិញ។ បទពិសោធន៍ដ៏គួរឱ្យភ័យបំផុតសំរាប់ប្រជាជនកម្ពុជាបានកើតឡើង នៅក្រោមរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ជាពេលដែលគេបានប្រព្រឹត្តអំពើព្រៃផ្សៃជាច្រើន។ ក្នុងអំឡុងពេលនោះ ប្រជាជនជាង៥លាននាក់ ក្នុងចំណោមប្រជាជនទាំងអស់ ៨លាននាក់ ត្រូវគេជន្លៀស ចេញពីទីលំនៅ ហើយ២លាននាក់ទៀតបានស្លាប់ដោយជំងឺអត់អាហារ និងដោយការកាប់សម្លាប់។

ប្រវត្តិសោកនាដកម្មនៃប្រទេសកម្ពុជា ត្រូវបានអន្តរជាតិទទួលស្គាល់ ហើយបទបញ្ញត្តិស្តីពីសិទ្ធមនុស្ស ត្រូវបានគេដាក់បញ្ចូលក្នុងសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស ឆ្នាំ ១៩៩១ ដើម្បីបញ្ចប់សង្គ្រាមនៅក្នុងប្រទេសកម្ពុជា ដើម្បីខិតខំស្តាបនាការគោរពសិទ្ធិមនុស្សនិងដើម្បីបង្ការការរំលោភបំពានទៅអនាគត។ ដូច្នេះ ភាគច្រើននៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ពីដំបូងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ក្នុងការរៀបចំសំរាប់ការបោះឆ្នោតជាតិឆ្នាំ១៩៩៣។ ក្រោយមកទៀត ទើបមានអង្គការមួយចំនួនធំទៀតដែលយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ ធនធានមនុស្ស អភិវឌ្ឍន៍សង្គមនិងជនបទ។

២. ការរីកចំរើននៃសង្គមស៊ីវិល :

ដូចគ្នានឹងប្រទេសផ្សេងៗជាច្រើន ដែលទើបមានការផ្លាស់ប្តូររបបគ្រប់គ្រងប្រទេសដែរ សង្គមស៊ីវិលក៏កំពុងតែលូតលាស់មួយជំហ៊ានម្តងៗនៅក្នុងប្រទេសកម្ពុជា។ កត្តាសំខាន់ ក្នុងការផ្លាស់ប្តូរបរិបទនយោបាយសង្គម ដែលបានបង្កើតឱ្យមានការរីកលូតលាស់ដំបូងនៃសង្គមស៊ីវិល គឺចលនាពួកកម្មកររោងចក្រ ការកើនចំនួននៃកាសែតខ្មែរ និងប្រព័ន្ធផ្សាយពត៌មានផ្សេងៗ ការកើនឡើងនៃសេរីភាពក្នុងការសម្តែងមតិ កំណើតនៃគណបក្សនយោបាយប្រឆាំង និងសម្លេងគេនៅក្នុងរដ្ឋសភា។

ក្នុងវិស័យជំនឿ និងវប្បធម៌ គតិបណ្ឌិតត្រូវបានផ្តល់ដោយព្រះសង្ឃនិងធម្មកថិកល្បីៗជាច្រើន ការចូលរួមរបស់ប្រជាជនក្នុងដំណើរការ

ហែរក្បួនសន្តិភាព និងការកើនចំនួននៃអង្គការសន្តិភាព មានឥទ្ធិពលជាវិជ្ជមានដល់ស្រទាប់ចិត្តគំនិត និងស្មារតីនៃប្រទេស (ដូចជា វេទិកាដើម្បីសន្តិភាព មជ្ឈមណ្ឌលធម្មយាត្រា ដើម្បីសន្តិភាពនិងអហិង្សា)។ ប្រការសំខាន់ជាចុងក្រោយ គឺស្ត្រីកំពុងខិតខំរៀបចំខ្លួន ដើម្បីបង្កើតឥទ្ធិពលឱ្យសំលេងពួកគេលាន់ឮឡើង ទាំងផ្នែកសង្គមនិងនយោបាយ។

អ្វីដែលហៅថាអង្គការសង្គមស៊ីវិល ហើយតើសង្គមស៊ីវិលអាចជួយយ៉ាងដូចម្ដេច ដើម្បីបង្កើតឱ្យមានអភិបាលកិច្ចល្អ? អង្គការសង្គមស៊ីវិល គឺរួមបញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការប្រជាពលរដ្ឋ សហជីពកម្មករ សមាគមសិទ្ធមនុស្ស សមាគមស្ត្រីសារពត៌មាន សមាគមជម្រុះក្នុងសហគមន៍ សមាគមអ្នកកាន់សាសនា បណ្ឌិតសភា និងវិជ្ជាស្ថានស្រាវជ្រាវផ្សេងៗ ដទៃទៀត។ អង្គការសង្គមស៊ីវិលបានជះឥទ្ធិពល និងទទួលឥទ្ធិពលផងដែរ ពីរដ្ឋនិងរដ្ឋាភិបាល។

សមាគមជួយខ្លួនឯង ក្នុងប្រទេសកម្ពុជាបានចងក្រងសហគមន៍ជាមួយគ្នានៅជុំវិញបញ្ហា និងក្ដីកង្វល់ជាក់ស្ដែងនៅក្នុងមូលដ្ឋាន ដូចជាបញ្ហាទឹក បញ្ហាគំរោង ឥណទាន និងសន្សំប្រាក់និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ទ្រង់ទ្រាយតូចៗ។ ពួកគេមិនត្រឹមតែជួយឧបត្ថម្ភសហគមន៍ ក្នុងការកែលំអលក្ខខណ្ឌរស់នៅ និងការចិញ្ចឹមជីវិតពួកគេប៉ុណ្ណោះទេ គឺថែមទាំងកំពុងលើកទឹកចិត្ត ក្នុងដំណើរការចូលរួមដែលនាំទៅរកការ

បើកចំហ ទុកចិត្ត ជឿជាក់ និងមានការសង្ឃឹមលើខ្លួនឯងក្នុងចំណោមសហគមន៍ទាំងអស់។

អង្គការមិនមែនរដ្ឋាភិបាលនៅប្រទេសកម្ពុជា បានចាប់ផ្តើមមានឡើង នៅពេលកងកំលាំងរក្សាសន្តិភាព នៃអង្គការសហប្រជាជាតិមកដល់ក្នុងឆ្នាំ១៩៩១ និងការហូរចូលនៃជំនួយបរទេស មកក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ ថ្វីបើនៅក្នុងវ័យក្មេងខ្ចី ក៏អង្គការមិនមែនរដ្ឋាភិបាលបំពេញមុខនាទី យ៉ាងសំខាន់និងយ៉ាងសកម្មក្នុងសង្គមកម្ពុជា។ ដោយសហការជាមួយរដ្ឋាភិបាលអង្គការទាំងនេះ :

១. ជម្រុញឱ្យមានការទទួលខុសត្រូវផ្នែកនយោបាយ តាមរយៈការចូលរួមដោយយល់ដឹង និងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងកិច្ចការនៃរដ្ឋាភិបាល។

២. កាត់បន្ថយភាពក្រីក្រដល់ប្រជាជនមូលដ្ឋានដើម្បីធានាថា ប្រជាជនតាមជនបទបានប្រើប្រាស់ធនធានជាតិ។ វិធីដោះស្រាយ ដើម្បីអភិវឌ្ឍន៏ ដែលប្រើដោយអង្គការមិនមែនរដ្ឋាភិបាល សង្កត់ធ្ងន់ទៅលើការចូលរួមការជឿជាក់លើខ្លួនឯង និងយុត្តិធម៌សង្គម។

៣. បានចាប់ផ្តើមបំពេញមុខនាទីចាំបាច់ ក្នុងការសិក្សាគោលនយោបាយការបណ្តុះបណ្តាល និងការពិភាក្សាលើបញ្ហាសង្គម និងបញ្ហាជាតិដែលមានសារៈសំខាន់ចំពោះអ្នកធ្វើសេចក្តីសំរេចចិត្ត និងអ្នកដឹកនាំទាំងស្ត្រីទាំងបុរស។

៤. ផ្ដល់យោបល់ និងជំនួយផ្នែកច្បាប់ដល់ក្រុមជនអ្នកខ្សត់ខ្សោយ និងអ្នករងគ្រោះក្នុងសង្គម ដូចជាស្ត្រីមានវិបត្តិ និងជនក្រីក្រជាដើម។ល។

៥. បង្កើនសុខភាពសាធារណៈ និងសុខុមាលភាពដល់ប្រជាជនដល់មាតា និងទារក។ អប់រំសាធារណជនឱ្យយល់ដឹងអំពីបញ្ហា ជម្ងឺអេដស៍និងវិធីការពារទប់ស្កាត់។ល។

៦. បង្កើនលក្ខខ័ណ្ឌការងារកម្មកររោងចក្រ និងកម្មករផ្សេងៗទៀត។

៧. ផ្ដល់ទីជំរក ម្ហូបអាហារនិងការសិក្សាអប់រំដល់កុមារា កុមារី អានាថារស់នៅតាមចិញ្ចើមថ្នល់។ ផ្ដល់ជូនអ្នកពិការភ្នែក ថ្លង់ គ ឱ្យទៅរៀនវិជ្ជាជីវៈដូចជាលេងភ្លេង រៀនវិជ្ជាសិប្បកម្មផ្សេងៗជាដើម ដើម្បីគេអាចប្រកបការងារចិញ្ចឹមជីវិតដោយខ្លួនគេបាន។ល។

៣. គុណវិបត្តិ :

ទោះណាជារដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលខិតខំទប់ស្កាត់យ៉ាងសកម្មក៏ដោយ ក៏បាតុភូតសកលភាវូបនីយកម្ម និងការប្ដូររបបនយោបាយ ស្រុកទេសបានធ្វើឱ្យបញ្ហាសង្គមរីកដុះដាលយ៉ាងលឿន។

- សិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិនយោបាយ និងបាតុកម្មអហិង្សាសាធារណៈនៅមានកំរិតទាប។ ប្រព័ន្ធផ្សាយពត៌មានជាទូទៅមានភាពទន់ខ្សោយ ហើយរហូតដល់មានពេលខ្លះ មាននាទីផ្ទុយនឹងលក្ខណៈស្ថាបនា ក្នុងការអប់រំប្រជាពលរដ្ឋ និងការលើកតម្លៃនៃសង្គមស៊ីវិល។

- ១៧០,០០០នាក់ មានផ្ទុកមេរោគ HIV ដែលនៅក្នុងចំណោមនេះ មានគ្រួសារប្ដីប្រពន្ធ៦០,០០០គ្រួសារផង។ ក្រុមដែលប៉ះពាល់ខ្លាំងគឺនារីឡង់សេអ្នកធ្វើការនៅ Massage Karaoke។

- ប្រជាពលរដ្ឋចុងកាត់មាត់ញកខ្វះដីធ្វើស្រែចំការ។

- ជីវភាពរស់នៅនៃប្រជាពលរដ្ឋខ្មែរនៅទាបជាងប្រទេសជិតខាង។ ផលទុនក្នុងស្រុកសរុប សំរាប់ប្រជាពលរដ្ឋម្នាក់ៗ មានតិចជាង៣០០ ដុល្លារ ប្រទេសថៃមានជាង ៣០០០ដុល្លារអាមេរិក។

- ចំនួននៃប្រជាពលរដ្ឋដែលមិនចេះអក្សរមានចំនួនជាង៦០%។

- ភាពវឹកវរក្នុងសង្គម ដោយការប្រើអំពើហិង្សាយកមកជាមធ្យោបាយដោះស្រាយបញ្ហា តែងតែកើតមានជាបន្តបន្ទាប់ ដូចជាការគប់គ្រាប់បែក នៅមុខរដ្ឋសភា ១៩៩៧ ការបានប្រដាប់អាវុធរវាងគណបក្សហ្វ៊ុនស៊ិនប៊ិច និងគណបក្សប្រជាជន ១៩៩៧ ការប្រើហិង្សា ទៅលើពួកបាតុករ ១៩៩៨ ការប្រឈមអាវុធរវាងក្រុមដែលហៅថាខ្មែរសេរី នៅខែវិច្ឆិកា ឆ្នាំ២០០០។ ប្រជាជនដែលរស់នៅក្នុងភូមិគ្មានច្បាប់ទំលាប់ភាគខាងលិចស្ថានីយ៍រថភ្លើង ក្រុងភ្នំពេញបានត្អូញត្អែរថា ប៉ូលីសបានចាប់ខ្លួនពួកគេដោយគ្មានហេតុផល ក្រោយពីការបះបោរប្រដាប់អាវុធកាលពីសប្តាហ៍មុន (ដកស្រង់ចេញពី កាសែត The Cambidia Daily ចេញផ្សាយនៅថ្ងៃសុក្រ ទី០១ ឆ្នាំ២០០០)។

❑ ក្រុមចាប់ជំរិត បងធំ ក្រុមឆក់ប្លន់ប្រដាប់អាវុធ បាននឹងកំពុងបង្កការភ័យខ្លាចដល់សាធារណជន។

៤_សេចក្តីសង្ឃឹម :

នាអនាគតទៅមុខតួនាទីសង្គមស៊ីវិលកាន់តែសំខាន់ក្នុងការជួយដល់ការកាត់បន្ថយភាពក្រីក្រ និងការលើកតំកើងជីវភាពប្រជាពលរដ្ឋឱ្យបានសមរម្យ។

មាត្រាទី៣នៃសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្ស កម្រងឯកសារនៃឧបករណ៍អង្គការសហប្រជាជាតិបានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខដល់ខ្លួន "។ ដោយសង្ខេប សន្តិសុខមនុស្ស គឺសន្តិសុខសេដ្ឋកិច្ចឬសន្តិសុខស្បៀង សន្តិសុខសង្គមនយោបាយ។ សន្តិសុខស្បៀងមានរួមទាំងការដែលកសិករគ្រប់រូបមានដីធ្លីគ្រប់គ្រាន់ និងអាចរកស៊ីចិញ្ចឹមជីវិត និងគ្រួសារខ្លួនបាន។

បើយើងរៀនសូត្រតាមប្រវត្តិសាស្ត្រ និងបទពិសោធន៍ពីប្រទេសជឿនលឿន គេសង្កេតឃើញថា ការអនុវត្តន៍អភិបាលកិច្ចល្អនាំមកនូវភាពចំរុងចំរើន និងសន្តិសុខជូនប្រទេសជាតិ និងប្រជាពលរដ្ឋ។

ក_ អ្វីដែលហៅថាអភិបាលកិច្ចល្អ?

តាមនិយមន័យនៃអង្គការ UNDP អភិបាលកិច្ច គឺការអនុវត្តន៍អំណាចនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់

ជាតិ។ តាមអត្ថន័យនេះ អភិបាលកិច្ច គឺជាភាពស្មុគស្មាញនៃយន្តការ របៀបដំណើរការ ទំនាក់ទំនង និងស្ថាប័ននានា ដែលតាមរយៈនោះ ពលរដ្ឋ និងសមាគមនាំគ្នាបញ្ចេញឱ្យឃើញពីប្រយោជន៍ខ្លួន ប្រើប្រាស់សិទ្ធិនិងកាតព្វកិច្ចខ្លួន និងសម្រុះសម្រួលទំនាស់របស់ខ្លួន។ អភិបាលកិច្ចល្អ គឺជាការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពនៃធនធានសាធារណៈ និងការដោះស្រាយបញ្ហាដោយឆ្លើយតបទៅនឹងសេចក្តីត្រូវការនិងផលប្រយោជន៍ជាតិទាំងមូល។ លទ្ធិប្រជាធិបតេយ្យជាមួយអភិបាលកិច្ចល្អ មានចំណងទាក់ទងទៅនឹងការចូលរួមរបស់ប្រជាពលរដ្ឋ ការទទួលខុសត្រូវ និងតម្លាភាព។

គោលបំណងជាចម្បងនៃទម្រង់ប្រជាធិបតេយ្យ ប្រកបដោយប្រសិទ្ធភាពនៃអភិបាលកិច្ច គឺត្រូវជម្រុញឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៍មនុស្ស។ ថ្វីបើ អភិបាលកិច្ចគ្របដណ្តប់លើគ្រប់ស្ថាប័ន និងអង្គការក្នុងសង្គមពីគ្រួសារទៅរដ្ឋអត្ថន័យ ដែលបានស្នើឡើងនេះផ្តោតទៅលើវិស័យសំខាន់ៗបី នៃអភិបាលកិច្ច ដែលនាំឆ្ពោះទៅរកនិរន្តរភាពនៃការអភិវឌ្ឍន៍មនុស្ស។ វិស័យទាំងនេះរួមមានរដ្ឋ (ស្ថាប័ននយោបាយនិងរដ្ឋាភិបាល) អង្គការសង្គមស៊ីវិល និងផ្នែកឯកជន។

ចរិតលក្ខណៈមួយនៃអភិបាលកិច្ចល្អ គឺវត្តមាននៃអង្គច្បាប់ ដែលផ្តល់សេរីភាព ដើម្បីបង្កើតសមាគម សិទ្ធិសេរីភាពចំពោះការបញ្ចេញមតិលើកិច្ចការរដ្ឋ និងសេរីភាពនៃសារពត៌មាន។ អភិបាលកិច្ចល្អមានលក្ខណៈប្រាកដឡើងផងដែរ ដោយការអនុម័តច្បាប់ដោយផ្អែកលើឆន្ទៈ

ប្រជាពលរដ្ឋតម្លាភាព និងភាពទទួលខុសត្រូវក្នុងកិច្ចការរដ្ឋ ប្រសិទ្ធភាពក្នុងការគ្រប់គ្រងសាធារណៈ និងសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងសង្គម ស៊ីវិល។

១. អ្វីដែលហៅថា "តម្លាភាព"?

តាមន័យតម្លាភាព មិនមានអ្វីខុសពីពាក្យថា (**ភាពបើកចំហដោយស្មោះ និងដោយទូលំទូលាយ**) នោះឡើយ។ សង្គមមួយដែលអាចចាត់ទុកថា ជាសង្គមមានតម្លាភាពបានលុះត្រាតែសង្គម នោះបង្កលក្ខណៈឬបង្កឱ្យមានការចូលរួមពិសំណាក់សហគមន៍ ក្នុងដំណើរការដឹកនាំសាធារណៈ។ តម្លាភាពអាចត្រូវគេយកទៅអនុវត្តនៅក្នុងគ្រប់ទិដ្ឋភាព នៃជីវភាពនយោបាយសេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គមនិងវប្បធម៌។ តម្លាភាពអាចលូតលាស់បានតែក្នុងសង្គម ដែលមានការគោរពសិទ្ធិមនុស្សខ្ពស់ មានការដឹកនាំតាមគន្លង នៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដមានយុត្តិធម៌ មានសីលធម៌សង្គមខ្ពង់ខ្ពស់ ជាពិសេសក្នុងសង្គម ដែលមានអ្នកដឹកនាំប្រកបដោយគុណធម៌។ អវត្តមាននៃតម្លាភាព នៅក្នុងសង្គមណាមួយតែងតែនាំមកនូវការរីករាលដាលនៃការខូចប្រយោជន៍ដល់សង្គមនាំមកនូវការក្លែងបន្លំក្នុងការចែកធនធានជាតិ នាំមកដល់សង្គមនូវភាពអយុត្តិធម៌ និងធ្វើឱ្យបទបញ្ញាឬបទប្បញ្ញត្តិ ព្រមទាំងច្បាប់នានាគ្មាន ប្រសិទ្ធិភាព នាំមកផងដែរ នូវការកើតឡើងនៃអំពើពុករលួយ និងការគំរាមកំហែងទៅលើជីវភាពសហគមន៍។

តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យមានតម្លាភាពក្នុងសង្គម? កត្តាសំខាន់មួយសម្រាប់ឱ្យមានតម្លាភាពក្នុងសង្គម គឺការផ្តល់និងទទួលពត៌មានពិតៗ។

ដើម្បីឱ្យកិច្ចការផ្តល់ពត៌មាននេះ មានដំណើរការល្អប្រសើរ ក្នុងការដឹកនាំរដ្ឋ ត្រូវតែបោះពុម្ពផ្សាយឱ្យបានទូលំទូលាយ អំពីគម្រោងថវិកាជាតិប្រចាំសារពើពន្ធនីមួយៗ ផ្សព្វផ្សាយប្រាក់ចំណូល និងប្រាក់ចំណាយសាធារណៈ ផ្សព្វផ្សាយលក្ខន្តិកៈ បទប្បញ្ញត្តិ និងនីតិវិធីនានារបស់ស្ថាប័ននីតិប្បញ្ញត្តិ។

សង្គមស៊ីវិល ត្រូវសហការជាមួយអ្នកដឹកនាំសង្គមគ្រប់ជាន់ថ្នាក់ ដើម្បីបង្កលក្ខណៈយ៉ាងណាឱ្យប្រជាពលរដ្ឋបានទទួលពត៌មានទាំងនោះ ដោយគ្មានលក្ខខ័ណ្ឌ។ តម្លាភាពកកើតឡើងបាននៅលើ ការហូរចូលដោយសេរីនៃពត៌មានបានន័យថា ពត៌មានគ្រប់គ្រាន់សម្រាប់កំណត់ការទទួលខុសត្រូវទៅលើបរាជ័យ អសមត្ថកិច្ច ឬការវៀចវេរបោកប្រាស់។ មិនតែប៉ុណ្ណោះសោត អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ត្រូវបើកចំហនិងលើកទឹកចិត្តឱ្យអង្គការត្រួតពិនិត្យឯករាជ្យ បានធ្វើការត្រួតពិនិត្យលើមូលនិធិរបស់ខ្លួនផងដែរ ព្រោះបើសិនជា ខ្លួនមិនធ្វើដូច្នេះទេ នោះសង្គមមិនគ្រាន់តែជាសង្គមមិនស្អាតបរិសុទ្ធ ហើយគុណប្រយោជន៍ទាំងប៉ុន្មានមិនត្រឹមតែមិនបានធ្លាក់ដល់ដៃរាស្ត្រតែប៉ុណ្ណោះទេ តែទង្វើបែបនេះនឹងអាចធ្វើឱ្យអំពើពុករលួយ បង្កើនឫទ្ធិបានមួយកម្រិតថែមទៀត។ សម្លេងប្រជាពលរដ្ឋ សម្លេងប្រព័ន្ធពត៌មានផ្តល់សារៈសំខាន់ដ៏ធំធេង ក្នុង

ការធ្វើឱ្យមានតម្លាភាពក្នុងសង្គម និងជាកត្តាមួយដ៏សំខាន់សម្រាប់ជម្រុញឱ្យស្ថាប័នរដ្ឋ និងឯកជនទទួលខុសត្រូវទៅ លើភារកិច្ចខ្លួន ព្រោះប្រជាពលរដ្ឋសេរី ប្រព័ន្ធពត៌មានសេរី គឺជាអ្នកឃ្លាំមើលដ៏មានប្រសិទ្ធភាពទៅលើកិច្ចការរដ្ឋ និងកិច្ចការឯកជន។ ក្នុងករណីដូចនេះ ដើម្បីបណ្តុះតម្លាភាពក្នុងសង្គម អ្នកដឹកនាំរដ្ឋគួរតែរិះរកមធ្យោបាយសមស្រប ដើម្បីដោះស្រាយបញ្ហានេះ។ តាមការស្រាវជ្រាវ គេអាចមានដំណោះស្រាយ ២យ៉ាង : ១)-ការបង្កើតកម្មវិធីអប់រំ ដើម្បីជួយប្រជាពលរដ្ឋឱ្យយល់ពីអ្វីដែលហៅថា ភាពស្របច្បាប់នៃរដ្ឋាភិបាល ឱ្យដឹងពីកិច្ចការ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចំពោះមុខរដ្ឋ ២)-រដ្ឋាភិបាលគួរសិក្សាឱ្យបានច្បាស់លាស់ និងប្រកបដោយសត្យានុម័តទៅលើតម្រូវការ និងកង្វល់នានារបស់ប្រជាពលរដ្ឋ ហើយប្រញាប់ប្រញាល់ដោះស្រាយឱ្យស្របតាមគតិច្បាប់ គតិយុត្តិធម៌។ ម្យ៉ាងទៀត រដ្ឋាភិបាលគួរតែធ្វើការធានាដោយច្បាប់ទៅលើសេរីភាព ក្នុងការបញ្ចេញមតិយោបល់របស់ប្រជាពលរដ្ឋថា អ្វីដែលប្រជាពលរដ្ឋផ្តល់មតិ ឬរិះគន់ មិនត្រូវមានទោសពៃរ៍អ្វីឡើយ។ លើសពីនេះទៅទៀត មានប្រទេសមួយចំនួន(តូច) បានបង្កើតច្បាប់ ដើម្បីធានាសិទ្ធិ និងសុវត្ថិភាពដល់ពលរដ្ឋណាដែលបានបកអាក្រាតរឿងអាស្រូវ ដែលមាននៅក្នុងកន្លែងធ្វើការ (សាធារណៈ ឬឯកជន) នានា។ អ្នកដែលបកអាក្រាតរឿងអាស្រូវនោះមានឈ្មោះថា (អ្នកផ្លុំកញ្ចែ Whistleblower)។ ការអនុញ្ញាតិឱ្យអង្គការសង្គមស៊ីវិលចូលរួមក្នុងការធ្វើឱ្យមាននិយតភាព ក្នុងការដឹកនាំរដ្ឋក៏ជាមធ្យោបាយដ៏

សក្តិសិទ្ធិមួយទៀត ក្នុងការធ្វើឱ្យមានតម្លាភាព។ តាមគោលការណ៍ អង្គការសង្គមស៊ីវិលមានមុខនាទី ជាស្ពានសម្រាប់ឱ្យអ្នកដឹកនាំ និងប្រជាពលរដ្ឋបានប្រាស្រ័យទាក់ទងគ្នា បង្ហាញកង្វល់ និងសេចក្តីត្រូវការដល់គ្នាទៅវិញទៅមក។ ស្ពានចំលង ដែលអង្គការសង្គមស៊ីវិលបំពេញនាទីជារឿយៗនោះ គឺការចុះជាប់ ជាមួយពលរដ្ឋ តាមរយៈកម្មវិធីអភិវឌ្ឍន៍ទាំងផ្លូវសម្ភារៈនិងស្មារតី។ ការចុះជាប់ជាមួយប្រជាពលរដ្ឋតាមរយៈកម្មវិធីនានា ដូចបានពោលមកខាងលើនេះ ជាការមួយធ្វើឱ្យអង្គការសង្គមស៊ីវិលបានដឹងច្បាស់ពីសុខទុក្ខនិងតម្រូវការរបស់រាស្ត្រហើយពាំនាំពត៌មាននេះមកជម្រាបរដ្ឋាភិបាលដែលជាអ្នកដឹកនាំប្រទេស ដើម្បីរកដំណោះស្រាយសមស្របនិងវិជ្ជមានណាមួយ។

គ_ទស្សនាវដ្តី ផ្ការីក :

ដើម្បីឆ្លុះបញ្ចាំងនូវភាពផ្ទុយគ្នារវាង អភិបាលកិច្ចល្អ (Good Governance) ទៅនឹងបរិបាលកិច្ច (Patronage) នោះ ខ្ញុំសូមដកស្រង់ពីទស្សនាវដ្តី ផ្ការីក។

ទស្សនាវដ្តី ផ្ការីក ខែតុលា វិច្ឆិកា ធ្នូ ក្រោយជ័យជំនះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យ បានកាន់កាប់អំណាចមិនមែនក្នុងឋានៈជារដ្ឋឬរដ្ឋាភិបាលទេ តែក្នុងឋានៈជាគណបក្សកុម្មុយនិស្តកម្ពុជា តាំងពីកំពូលដល់ភូមិឃុំឬសហករណ៍ទៀតផង ហើយនៅក្នុងគណបក្សកុម្មុយនិស្ត នេះទៀតសោត គឺលេខាបក្សតែម្នាក់គត់

ដែលយកវិធានការឬធ្វើសេចក្តីសម្រេចទាំងអស់។ ការប្រមូលផ្តុំអំណាចទៅលើបុគ្គលតែមួយ (លេខាបក្ស) ដូច្នេះ នាំមកនូវបច្ច័យជាច្រើន :

## ទី១. អំណាចផ្តាច់ការ :

ពិតមែនហើយ គណបក្សកុម្មុយនិស្ត បានលើកឡើងនូវគោលការណ៍ដឹកនាំមួយចំនួន ដែលឈរលើរបបប្រជាធិបតេយ្យ ប្រមូលផ្តុំ សមូហភាពទទួលខុសត្រូវរួម ហើយបុគ្គលទទួលខុសត្រូវដោយឡែក។ ប៉ុន្តែ ជាក់ស្តែងបុគ្គលដឹកនាំគ្រប់ជាន់ថ្នាក់ ច្រើនតែដឹកនាំ និងធ្វើការងារតាមអត្តនោមតិរបស់ខ្លួន ឬតាមមតិយោបល់មនុស្សមួយចំនួនតិច ដែលជាមនុស្សពួកខ្លួន។ ជាបច្ច័យ សេចក្តីសម្រេច ឬវិធានការនានាភាគច្រើនលើសលប់ មិនស្របនឹងសភាពការណ៍ជាក់ស្តែងនិងសំណូមពររបស់ប្រជាជនមហាជនទេ ដូច្នេះ ផ្ទុយនឹងផលប្រយោជន៍ទូទៅ។ ជាបច្ច័យប្រជាជនមហាជនបាត់បង់ជំនឿទុកចិត្តជាបណ្តើរៗ។ សភាពការណ៍នេះរឹតតែធ្ងន់ធ្ងរថែមទៀត បើកើតមានសកម្មភាពការបំពានលើច្បាប់ឬអំពើអយុត្តិធម៌កាន់តែច្រើនឡើងៗ។

## ទី២. បក្សពួកនិយម :

ដោយការដឹកនាំរបស់បុគ្គលដើរតួនាទីគ្របដណ្តប់ ជំនួសការដឹកនាំឈរលើក្រឹត្យក្រមប្រជាធិបតេយ្យ បុគ្គលដឹកនាំ តែងតែផ្តល់ទំនុកចិត្តទៅលើមនុស្សជិតស្និទ្ធមួយក្តាប់តូច ជាក្រុមគ្រួសារ ឬជាមិត្តភក្តិរបស់ខ្លួនផ្ទាល់ ដែលមានលទ្ធភាពស្គាល់ច្បាស់បំផុតដើម្បីប្រឆាំងខ្លួន។

ទី៣. សង្ស័យនិយម :

ការដឹកនាំជាបុគ្គល ដែលឈរលើភក្តីភាព និងការស្មោះត្រង់ពីសំណាក់បក្សពួករបស់ខ្លួនមួយក្តាប់តូច ដូច្នេះបានបង្កើតបរិយាកាសសង្ស័យ និយមដែលចាត់ទុកអ្នកផ្សេង ឬអ្នកដែលមានមតិខុសពីខ្លួនថាជាមនុស្សដែលត្រូវតាមដាននិងពិនិត្យ។ ដូច្នេះក្នុងរង្វង់ដឹកនាំគ្រប់ថ្នាក់តាំងពីកំពូលដល់មូលដ្ឋាន សង្ស័យនិយមប្រែក្លាយទៅជារបបគ្រប់គ្រងតែម្តង។

ទី៤. អត្តនោម័តិនិយម

ដោយថ្នាក់ដឹកនាំក្តាប់សភាពការណ៍នៅតាមមូលដ្ឋាន តែតាមសេចក្តីរាយការណ៍ ហើយសេចក្តីរាយការណ៍នេះទៀតសោត ធ្វើឡើងដោយខ្សែតែមួយមិនមានច្រើនខ្សែ។ តាមសេចក្តីរាយការណ៍ជា "ខ្សែឯក" នេះអ្នករាយការណ៍ភាគច្រើន សុទ្ធតែរាយការណ៍ឱ្យស្របតាមទស្សនៈរបស់អ្នកដឹកនាំ សុទ្ធតែតម្រូវតាមសំណូមពររបស់អ្នកដឹកនាំដោយលើកតំកើង "ភាពត្រឹមត្រូវរបស់មាគ៌ា "ឬបញ្ចើចបញ្ចើ" ការឈ្លាសវៃរបស "អ៊ុំ" ជាដើម។

ទី៥. ការផ្សព្វផ្សាយពត៌មានចំបាច់តែក្នុងរង្វង់តូច :

ក្នុងការអប់រំផ្ទៃក្នុង ប៉ុលពត តែងតែគូសសង្កត់ថា "រក្សាការសម្ងាត់បាន គឺទទួលជ័យជំនះបាន៥០%"។

ដោយការដឹកនាំ ឈរតែលើបក្សពួករបស់អ្នកដឹកនាំទី១ មួយចំនួនតូច ព្រោះគ្មានទំនុកចិត្តលើអ្នកផ្សេងទៀត យ៉ាងនេះទើបការផ្សព្វផ្សាយពត៌មានសំខាន់ៗ ដល់អ្នកដឹកនាំផ្សេងទៀតមិនបានទូលំទូលាយ។ បើខ្វះពត៌មានចាំបាច់ហើយនោះ ការវិភាគក៏មិនអាចធ្វើទៅបានដែរ ហើយការរួមចំណែកក្នុងការដឹកនាំ ក៏មានកម្រិតចំពោះអ្នកដឹកនាំ ដែលមិនមែនជាបក្សពួករបស់គេ។ ទស្សនាវដ្តី ផ្ការីក បានបន្តទៀតថា "ជាសរុប ចំណុចខ្សោយរបស់ខ្មែរក្រហម គឺការដឹកនាំអត្តនោមតិ ឯកោភាគីផ្តាច់ការ ខ្វះប្រជាធិបតេយ្យផ្ទៃក្នុងផង ខ្វះប្រជាធិបតេយ្យក្នុងប្រជាជនមហាជនផង។ ការខ្វះខាតក្នុងការសភាពការណ៍ជាក់ស្តែង នាំឱ្យកំណត់មាគ៌ានយោបាយមិនសមស្រប គួបផ្សំនឹងការខ្វះបទពិសោធន៍ ក្នុងការគ្រប់គ្រងរដ្ឋអំណាចនាំទៅដល់វិធានការមិនសមស្របរហូតដល់អំពើរលោភដ៏ធ្ងន់ធ្ងរ ដែលប៉ះពាល់ទៅលើអាយុជីវិតរបស់កម្មាភិបាលយុទ្ធជន និងប្រជាជនស្លូតត្រង់ដ៏ច្រើនកុះករ។

**៥_ សេចក្តីសន្និដ្ឋាន :**

ហេតុដូច្នេះ បើសិនជាគោលបំណងជាតិចុងក្រោយគឺការបង្កើនសន្តិសុខ សុខុមាលភាពប្រជាជន និងកសាងសង្គម ដែលមានសន្តិភាពយុត្តិធម៌ និងមានការអត់អោនគ្នាមានសីលធម៌ខ្ពស់ នោះគួរទាំងផ្នែករដ្ឋផ្នែកសង្គមស៊ីវិលនិងផ្នែកឯកជនយល់ព្រមទទួលយកទាំងស្រុងនូវទស្សនៈអភិបាលកិច្ចល្អ និងអនុវត្តន៍ច្បាប់ ដោយគ្មានការយោគយល់ និងខ្លាចក្រែង។ នៅពេលនោះហើយដែលប្រជាពលរដ្ឋខ្មែរយើងមានមោទនភាព

ជាប្រជាពលរដ្ឋកម្ពុជា ហើយយល់ថា ខ្លួនមានវាសនាល្អដែលបានរស់នៅក្នុងប្រទេសកម្ពុជា។ នេះជាការលំបាក ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏ជាភារកិច្ចដែលសង្គមស៊ីវិល យើងបានប្ដេជ្ញា ដើម្បីនាំប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជាឱ្យបានទៅដល់ឋានៈនៃជីវភាពនេះ។

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ជាអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រឱ្យមានអភិបាលកិច្ចល្អតាមរយៈការស្ដាបនាតម្លៃ និងគោលការណ៍ប្រជាធិបតេយ្យ គាំទ្រសមធម៌និងយុត្តិធម៌សង្គម ព្រមទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ស្ថិតស្ថេរ ដោយបើកឱកាសឱ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ៕

## ៧.១៤_ សុន្ទរកថាថ្លែងដោយ លោក សុក សំអឿន នាយកក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ស្ដីអំពី "សង្គមស៊ីវិលនិងគម្រោងច្បាប់នៅកម្ពុជា : ការប្រឈមមុខ និងទិសដៅអនាគត"

ក្នុងសង្គមបុព្វកាល មនុស្សរស់នៅជាមួយគ្នាជាក្រុម ជាកុលសម្ព័ន្ធដោយចែកគ្នារស់ដោយសហការណ៍ជាមួយគ្នា និងការពារគ្នាទៅវិញទៅមក។ គេរស់នៅដោយគ្មានច្បាប់សរសេរជាលាយលក្ខណ៍អក្សរអ្វីនោះទេ ក៏ប៉ុន្តែ គេរស់នៅដោយយោគយល់គ្នា និងជួយគ្នាទៅវិញទៅមកបានអ្វីចែកគ្នាទទួលទាន ដោយគ្មានការកេងប្រវ័ញ្ចន៏អ្វីឡើយ។ តែនៅពេលដែលសង្គមមានការរីកចំរើន ជាពិសេស នៅពេលដែលមនុស្សត្រូវការលើសពីការគ្រាន់តែរស់ និងត្រូវការរីកចំរើនផ្នែកសេដ្ឋកិច្ចនោះមនុស្សចាប់ផ្ដើមកេងប្រវ័ញ្ចគ្នា ហើយឈានពីចែកគ្នារស់មកជាដណ្ដើមគ្នារស់ទៅវិញ។ នៅពេលនោះបញ្ហាក៏កើតឡើងច្រើនការដោះស្រាយបញ្ហា ដែលពីដើមផ្អែកតែទៅលើការសម្រុះសម្រួលគ្នា នោះក៏បានវិវត្តទៅរកការដោះស្រាយដោយតុលាការ។ ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយនិងដើម្បីងាយកុំឱ្យភាគីណាមួយចោទថា តុលាការកាត់សេចក្ដីមិនត្រឹមត្រូវនោះ វិធីមួយដែលគេយកមកប្រើ គឺការធ្វើជាច្បាប់ជាលាយលក្ខណ៍អក្សរ។ ពោលគឺច្បាប់ធ្វើឡើងសំរាប់ដោះស្រាយនូវអ្វីដែលជាបញ្ហា ហើយបើគ្មានអ្វីចែងជាលាយលក្ខណ៍អក្សរទេ នោះនឹងនាំឱ្យកាត់ក្ដីមានការពិបាក។

ចំពោះរឿងច្បាប់សមាគម យើងឃើញថា រាជរដ្ឋាភិបាលមានចេតនានឹងបង្កើតឱ្យមាននូវច្បាប់នេះជាយូរឆ្នាំមកហើយតែមិនបានសំរេចរហូតមកដល់ពេលនេះ។ បើមិនគិតពីអ្វីដែលមានមុនឆ្នាំ ១៩៧៥ ទេ នោះយើងឃើញថា ពាក្យថា សមាគម មានតាំងពីក្នុងសម័យរដ្ឋកម្ពុជា គ្រាន់តែទាស់ត្រង់ថា នៅពេលនេះពាក្យថាសមាគមនេះ អាចមានន័យខុសពីសមាគម ក្រោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ ក្រៅពី សមាគម គឺយើងឃើញមានអង្គការក្រៅរដ្ឋាភិបាលមិនយកកម្រៃ និងពាក់កណ្តាលយកកម្រៃថែមទៀត។ តែទោះជាយ៉ាងណាក៏ដោយ យើងត្រូវព្យាយាមយល់ពីអត្ថន័យ នៃពាក្យថា សិទ្ធិធ្វើសមាគម ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

តាមពិតទៅ ពាក្យថា សិទ្ធិធ្វើសមាគមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងទប់ទល់នឹងអ្នកកាន់អំណាចផ្តាច់ការ ដែលគេតែងតែយកពាក្យ ការរក្សារបៀបរៀបរយទៅបង្ក្រាប ការប្រមូលចងក្រងនៃមនុស្សឬការចងក្រងជាសមាគមនោះ។ ម្យ៉ាងទៀត ប្រទេសដែលកាន់អំណាចផ្តាច់ការខ្លះ តែងតែបង្កើតច្បាប់ដើម្បីបំបិទសិទ្ធិ ដែលប្រគល់និងធានាឱ្យដោយរដ្ឋធម្មនុញ្ញទៅវិញ។

ដូចនេះ នៅពេលដែលយើងនិយាយពីការចង់ធ្វើសេចក្តីព្រាងឬស្នើច្បាប់នោះ យើងត្រូវពិនិត្យមើលទៅលើចំណុចសំខាន់ៗដូចតទៅ:

១_នៅក្នុងសង្គមមានបញ្ហាកើតឡើង ដែលត្រូវការឱ្យមានច្បាប់

នោះជាចាំបាច់ ដើម្បីដោះស្រាយដែរឬទេ? តើបញ្ហាដែលយើងចង់ដោះស្រាយនោះគឺជាបញ្ហាអ្វីខ្លះ?

២_តើក្នុងគោលបំណង នៃរដ្ឋធម្មនុញ្ញចំពោះបញ្ហា ដែលយើងកង្វល់ និងចង់បង្កើតឱ្យមានច្បាប់នេះឡើងគឺអ្វីខ្លះ?

ច្បាប់សមាគមត្រូវតែមាន :

មាត្រា ៤២ ច្បាប់រដ្ឋធម្មនុញ្ញចែងថាៈ " *ប្រជាពលរដ្ឋខ្មែរមានសិទ្ធិ បង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់* "។

ដូច្នេះគឺមានន័យថា ទោះជាយ៉ាងណារាជរដ្ឋាភិបាល ត្រូវតែធ្វើច្បាប់មួយស្តីពីសមាគម។

ច្បាប់សមាគមមិនមែនជាច្បាប់ដែលមានអាទិភាពនោះទេ :

សមាគម និងអង្គការក្រៅរដ្ឋាភិបាលបានកើតឡើងព្រោងព្រាតចាប់ពីក្រោយឆ្នាំ ១៩៩៣ ហើយអង្គការ និងសមាគមទាំងនោះអាចដំណើរការរបស់គេដោយគ្មានបញ្ហា ដូចនេះ បើទោះជាមានច្បាប់ថែមទៀតក៏គ្មានអ្វីជាផលចំណេញ ឬប៉ះពាល់ដល់ដំណើរការដល់ពួកគេទាំងនោះដែរ។ ព្រោះថា អង្គការឬសមាគមនីមួយៗ គេមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់គេ ដែលកាលបើមានបញ្ហាអ្វីកើតឡើង នៅក្នុង

អង្គការឬសមាគមរបស់គេនោះ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង របស់គេគឺជាច្បាប់របស់អង្គការ ឬសមាគមរបស់គេសំរាប់ដោះស្រាយបញ្ហានោះ។ ចៅក្រមនឹងធ្វើការសំរេចសេចក្ដី ដោះស្រាយវិវាទរបស់ពួកគេទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គេ។

ម៉្យាងទៀត បច្ចុប្បន្ននេះកម្ពុជានៅខ្វះច្បាប់ជាច្រើនជាពិសេសច្បាប់មូលដ្ឋានមានក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណី។ ដូចនេះរាជរដ្ឋាភិបាលត្រូវតែផ្ដោត និងផ្ដល់អាទិភាពឱ្យបានខ្លាំង លើច្បាប់ទាំងនោះជាមុនសិន។ ក្រោយពីច្បាប់គ្រឹះទាំង៤ ត្រូវបានបង្កើតឡើងហើយ សឹមធ្វើការផ្ដោតទៅលើច្បាប់បន្ទាប់បន្សំផ្សេងទៀត មានច្បាប់សមាគមនេះជាដើម។

ច្បាប់សមាគម ត្រូវតែជាច្បាប់ដែលធានាដល់សិទ្ធិធ្វើសមាគម :

សិទ្ធិធ្វើសមាគមគឺជាសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញតាមមាត្រា ៤២។ ថ្វីត្បិតតែមាត្រានេះចែងថា នឹងត្រូវចែងនៅក្នុងច្បាប់មួយក៏ពិតមែន ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញ បានបញ្ជាក់ច្បាស់ណាស់ថា ពលរដ្ឋកម្ពុជាត្រូវតែមានសិទ្ធិនេះ។ ដូចនេះ ច្បាប់ស្ដីពីសមាគមត្រូវតែមានលក្ខណៈដូចតទៅ៖

- ជាច្បាប់ដែលធានា និង ការពារនូវសិទ្ធិធ្វើសមាគមរបស់ប្រជាពលរដ្ឋ។

- សូមឱ្យបែងចែកឱ្យដាច់រវាងបុគ្គលដែលប្រព្រឹត្តខុសនិងកំហុសរបស់សមាគម។ បញ្ហានេះគឺចង់និយាយថា ក្នុងករណីដែលមានបុគ្គលណាមួយប្រព្រឹត្តខុស មិនត្រូវយកជាលេសដើម្បីបិទសមាគមនោះទេ។ ដូចនេះជាការប្រសើរច្បាប់នេះមិនត្រូវមានទណ្ឌកម្មរំលាយសមាគមឬអង្គការណាទ្បើយគ្រាន់តែចែងថា លក្ខន្តិកៈនៃសមាគមឬអង្គការនីមួយៗត្រូវមានចែងពីរបៀបបង្កើត និងរំលាយសមាគមឬអង្គការបានហើយ។

- សមាគមឬអង្គការក្រៅរដ្ឋាភិបាល ជានីតិបុគ្គលឯករាជ្យមួយដូចជាក្រុមហ៊ុនឯកជននានាដែរ ដូចនេះ រដ្ឋាភិបាលមិនអាចជ្រៀតជ្រែក កិច្ចការផ្ទៃក្នុងរបស់គេបានទ្បើយ លើកលែងតែមានការពិនិត្យទាក់ទិនទៅនឹងភាពមិនច្បាស់លាស់នៃការប្រមូលពន្ធ។ ដូចនេះចំពោះអង្គការក្រៅរដ្ឋាភិបាល ដែលទាក់ទងនឹងការប្រមូលពន្ធក៏គ្មានអ្វីដែលទាក់ទងទៅនឹងរដ្ឋាភិបាលដែរ ពោលគឺរដ្ឋាភិបាលមិនត្រូវមានសិទ្ធិត្រួតពិនិត្យថវិការបស់សមាគម ឬអង្គការទ្បើយ។ នេះគឺជាគោលការណ៍នៃសង្គមលទ្ធិប្រជាធិបតេយ្យសេរី។

- នីតិវិធីនៃការចុះបញ្ជីត្រូវមានបង្គលក្ខណៈងាយស្រួល។ កន្លងមកនេះមានការត្អូញត្អែរច្រើនណាស់ ពីរបៀបរបប នៃការធ្វើការរបស់រាជរដ្ឋាភិបាលថា មានការវែងអន្លាយ និងត្រូវការប្រើប្រាស់លុយកាក់ជាច្រើន ដូចនេះសូមធ្វើយ៉ាងណា កុំឱ្យច្បាប់សមាគមនេះមាននីតិវិធីនៃការចុះ បញ្ជីនោះវែងអន្លាយពេក ព្រោះការ

បង្កើតឱ្យមាន នីតិវិធីស្មុគ្រស្មាញនិងវែងអន្លាយបែបនេះ មិនមែនជាវិធីសំរាប់ការពារអំពើពុករលួយនោះទេ។

៣ សូមកុំកំណត់ទម្រង់រចនាសម្ព័ន្ធសមាគមឬអង្គការ។ សព្វថ្ងៃនេះពិភពលោកមានការរីកចំរើនរចនាសម្ព័ន្ធសមាគម ឬអង្គការក៏មានការប្រែប្រួលមិនមែនដូចជារបនាសម្ពន្ធ័របស់សមាគមមុនឆ្នាំ១៩៧៥ នោះទេ។ ដូចនេះច្បាប់សមាគមមិនគួរកំណត់ថា តើសមាគមឬអង្គការនោះ ត្រូវតែមានរចនាសម្ពន្ធ័បែបណាឡើយ។

សេចក្តីសន្និដ្ឋាន :

ជាការប្រសើរហើយ ដែលយើងត្រូវតែមានច្បាប់ សំរាប់គ្រប់គ្រងអ្វីៗនៅក្នុងសង្គមនោះ។ ពោលគឺយើងចង់បាននូវប្រទេសមួយដែលគ្រប់គ្រងដោយច្បាប់ តែទោះជាយ៉ាងណា យើងក៏មិនចង់បានច្បាប់ដូចជាច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជា លទ្ធិប្រជាធិបតេយ្យរបស់ខ្មែរក្រហមដែលមាននៅលើក្រដាស នឹងនូវច្បាប់មួយដែលបំរើឱ្យអ្នកកាន់អំណាចផ្តាច់ការនោះក៏ទេដែរ។ ដូចនេះ ជាការប្រសើរណាស់ ដែលរាជរដ្ឋាភិបាលបានបើកទូលាយឱ្យមានការពិគ្រោះយោបល់ពីសង្គមស៊ីវិលក្នុងការធ្វើច្បាប់សមាគមនេះ៕

## ៧.១៥_សុន្ទរកថាថ្លែងដោយ លោក ញឹក សារិន នាយកប្រតិបត្តិ អង្គការស្តារកម្ពុជា ស្តីអំពី "សង្គមស៊ីវិល និងគំរោងច្បាប់នៅកម្ពុជា : ការប្រឈមមុខ និងទិសដៅអនាគត"

ជាបឋមទូលបង្គំខ្ញុំបាទ សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពដែលបានផ្តល់ឱកាស និងកិត្តិយសដល់ទូលបង្គំ ខ្ញុំបាទមកចូលរួមថ្លែងបទអន្តរាគមន៍ស្តីពីបញ្ហាទាក់ទងនឹងសង្គមស៊ីវិល និងគម្រោងច្បាប់នៅកម្ពុជា ក្នុងសន្និសីទនេះ។

សង្គមស៊ីវិលគឺជាបញ្ញត្តិមួយ ដែលបានវិវត្តតាំងពីសតវត្សរ៍ទី១៥ នៅអឺរ៉ុបមកម្ល៉េះ ហើយជាសង្គមមួយដែលមានការអភិវឌ្ឍន៍ផ្នែកសង្គមភាវូបនីយកម្ម។ សង្គមស៊ីវិលឋិតនៅចន្លោះរវាងគ្រួសារនិងរដ្ឋ។

សង្គមស៊ីវិលផ្តោតទៅលើកត្តានយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ចរួមគ្នាហើយមានសិទ្ធិស្វ័យសំរេចក្នុងការធ្វើសកម្មភាពរបស់ខ្លួន។ អង្គការ សមាគម សហជីព សុទ្ធសឹងជា សមាជិករបស់សង្គមស៊ីវិលដែលបាន និងកំពុងធ្វើនយោបាយរបស់ខ្លួនក្នុងសកម្មភាពមួយមិនដណ្តើមអំណាច។ សង្គមស៊ីវិលធ្វើការងារ ក្នុងគោលបំណងផ្លាស់ប្តូរនូវអ្វីដែលជាអំពើផ្ទុយនឹងគន្លងច្បាប់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យតែប៉ុណ្ណោះ។

មានអង្គការសង្គមស៊ីវិលជាច្រើនប្រភេទ ដែលកំពុងធ្វើការបំរើសង្គមទៅតាមទិសដៅរបស់ខ្លួនជាអាទិ៍ សមាគម អ្នកសារពត៌មាន

សមាគម មេធាវី គ្រូពេទ្យ អង្គការ ដែលគិតពីគុណធម៌ដូចជា : សមាគមព្រះសង្ឃ សមាគមសាសនា អង្គការ ដែលគិតពីវិបត្តិសង្គម ដូចជា អង្គការបរិស្ថាន វប្បធម៌ សិទ្ធិមនុស្សនិងការអភិវឌ្ឍន៍និងសង្គមស៊ីវិលដែលគិតពីប្រយោជន៍អ្នកទីបី ដោយជួយផ្តល់ជាជំនួយដល់អង្គការសមាគមមួយទៀត ដើម្បីឱ្យគេធ្វើសកម្មភាពជួយដល់ប្រជាពលរដ្ឋ។

ដោយឡែក នៅអំឡុងទសវត្សរ៍ទី៨០ ប្រទេសកម្ពុជាមានអង្គការសង្គមស៊ីវិលអន្តរជាតិ មួយចំនួនតូច បានចាប់ផ្តើមបំពេញតួនាទីជាចម្បងនូវជំនាញសង្គ្រោះការអភិវឌ្ឍន៍ ការស្តារលទ្ធភាពពលកម្មឡើងវិញដើម្បីឱ្យប្រជាពលរដ្ឋ តាមសហគមន៍អាចជួយខ្លួនឯង បានដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងជំនាញនិងរដ្ឋាភិបាល។

លើសពីនេះទៅទៀត សង្គមស៊ីវិលមានការរីកដុះដាលយ៉ាងឆាប់រហ័សគួរឱ្យចាប់អារម្មណ៍បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលាឆ្នាំ១៩៩១ និងក្រោយពីមានការបោះឆ្នោតជាសកលឆ្នាំ១៩៩៣មក។

ប៉ុន្តែ ដោយកម្ពុជាស្ថិតក្នុងស្ថានភាពមួយ មិនទាន់មានច្បាប់សំរាប់គ្រប់គ្រងសមាគម និងអង្គការនានា និងដោយសារបុគ្គលមួយចំនួនខ្វះកិច្ចសហការផ្ទៃក្នុងរវាងនឹងគ្នារវាង អាជ្ញាធរ គ្មានតម្លាភាព និងខ្វះបទពិសោធន៍ បានធ្វើឱ្យក្រុមសង្គមស៊ីវិលមួយចំនួនតូច ប្រព្រឹត្តប្រាសចាកពីសេចក្តីថ្លៃថ្នូរ និងក្រមសីលធម៌របស់ខ្លួន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើសង្គមស៊ីវិល បានខិតខំព្យាយាមសហការគ្នា រួមជាមួយគណៈកម្មការសហប្រតិបត្តិការ ដើម្បីកម្ពុជាធ្វើការពិភាក្សា ចងក្រងនូវក្រមសីលធម៌ មួយសំរាប់អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការមហាជន ដើម្បីអភិវឌ្ឍសង្គមកម្ពុជានិងសំរាប់ជួយតំរែតម្រង់ផ្លូវសង្គមស៊ីវិលទាំងអស់ បន្ថែមលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែលមានស្រាប់។

ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ កន្លងមកសង្គមស៊ីវិលហាក់បីដូចជានៅតែមានភាពរងារ ព្រោះយើងនៅខ្វះច្បាប់សំរាប់សមាគមអង្គការមិនមែនរដ្ឋាភិបាលប្រកប ដោយលក្ខណៈស្ថាបនាជួយសំរួលរាល់កិច្ចការផ្សេងៗ តែយើងក៏មិនចង់បានឬគាំទ្រនូវច្បាប់ណាមួយដែលមានការរឹតត្បិតកាត់បន្ថយសិទ្ធិសេរីភាព ឬ បង្កឱ្យរាំងស្ទះដល់សកម្មភាពសង្គមស៊ីវិល និងផលប្រយោជន៍សាធារណៈនោះឡើយ ។

ទាក់ទងនឹងចំណុចខាងលើនេះ យើងឃើញថារាជរដ្ឋាភិបាលជាពិសេសក្រសួងមហាផ្ទៃបាន និងកំពុងយកចិត្តទុកដាក់ធ្វើសេចក្ដីព្រាងច្បាប់សមាគម អង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងកំណត់បែបបទនិងល័ក្ខខ័ណ្ឌនៃការបង្កើតការចុះបញ្ជី និងការធ្វើសកម្មភាពរបស់សមាគម និងអង្គការក្រៅរដ្ឋាភិបាល។ ទន្ទឹមនឹងដំណើរការនៃការធ្វើសេចក្ដីព្រាងច្បាប់នេះ ក្រសួងបានផ្ដល់ឱកាសដល់សង្គមស៊ីវិល ដើម្បីផ្ដល់អនុសាសន៍លើសេចក្ដីព្រាងច្បាប់ទាំងនោះ។ ជាក់ស្ដែងកន្លងមកអង្គការជាតិនិងអន្តរជាតិមួយចំនួន ជាពិសេសអង្គការចំនួន១៤៩បានធ្វើ

ការពិភាក្សាគ្នាលើសេចក្តីព្រាងច្បាប់ ស្តីអំពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងពិធីពិពរណ៍សមិទ្ធិផលលើកទី៤ នៃសមាគមអង្គការមិនមែនរដ្ឋាភិបាលនៅសាលសន្និសីទចតុមុខកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩ ហើយបានផ្តល់អនុសាសន៍ល្អៗជូនទៅក្រសួងមហាផ្ទៃ ដែលជាសាមីក្រសួងទទួលខុសត្រូវធ្វើសេចក្តីព្រាងច្បាប់នេះ។ ដូចនេះទៅថ្ងៃអនាគតយើងសង្ឃឹមថា សង្គមស៊ីវិលទាំងអស់ ពិតជាស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់ដ៏ល្អសមដូចបំណងរបស់ខ្លួន។

ជាទីបញ្ចប់និងជាថ្មីម្តងទៀត ទូលបង្គំខ្ញុំបាទសូមថ្លែងអំណរគុណជាអតិបរមា ចំពោះវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបតិការ និងសន្តិភាព ដែលបានផ្តល់កិត្តិយសអោយទូលបង្គំ ខ្ញុំបាទ បានថ្លែងបទអន្តរាគមន៍ ជុំវិញបញ្ហាសង្គមស៊ីវិលនៅកម្ពុជា ហើយសូមថ្វាយព្រះពរនិងប្រសិទ្ធពរជ័យដល់ស្តេចក្រុមឃុន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ដែលមានព្រះរាជវត្តមាននិងវត្តមាននៅទីនេះ បានជួបប្រទះតែនឹងពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ និងសំរេចបានជោគជ័យរាល់ការបំពេញភារកិច្ចបំរើជាតិមាតុភូមិនៃយើង៕

៧.១៦_សុន្ទរកថាថ្លែងដោយ លោកស្រីបណ្ឌិត ហៃគី ឡូស្នាន់ នាយិកា មូលនិធិ ហេនរិចបូល ប្រទេសអាឡឺម៉ង់ នៅប្រទេសថៃឡង់ដ៍ និងការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍ ស្តីអំពី "ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា: សមិទ្ធិផល ការប្រឈមមុខ និងទស្សនវិស័យនៅអនាគត"

ជាបឋម ខ្ញុំសូមអរគុណដល់អ្នករៀបចំអង្គសន្និសីទ ព្រមទាំងអស់លោក លោកស្រីទាំងអស់នៅក្នុងសន្និសីទនេះ ដែលបានផ្តល់ឱកាសឱ្យនាងខ្ញុំ បានស្តាប់ការពិភាក្សា។

ខ្ញុំបានឃើញដោយផ្ទាល់ថា មានអស់លោក លោកស្រី មួយចំនួនបាននិយាយសម្តែងចេញពីទឹកចិត្ត និងបេះដូងដោយត្រង់ៗ មានពេលខ្លះការសម្តែងចេញនេះ មានសភាពចេញពីអារម្មណ៍ដ៏ពិតៗ។ ភាពបើកចំហដែលអាចធ្វើទៅបាន នេះគឺជាសញ្ញាដ៏ប្រពៃមួយដែលបង្ហាញពីការសម្តែងចេញរបស់ពួកអស់លោក លោកស្រីថា :

១_មានសេរីភាពក្នុងការបញ្ចេញមតិយោបល់ និង

២_សំខាន់ជាងនេះទៅទៀត មានបងប្អូនជា ច្រើននាក់ចង់ផ្តល់វិភាគទាន ដើម្បីការផ្លាស់ប្តូរនិងភាពប្រសើរឡើងក្នុងសង្គម។ មានបងប្អូនជាច្រើនទៀតបាន យកចិត្តទុកដាក់ចំពោះសង្គមច្រើនជាង ការយកចិត្តទុកដាក់ចំពោះផ្ទាល់។

អង្គសន្និសីទទាំងមូលបានចង្អុលបង្ហាញយ៉ាងច្បាស់ថា មានបញ្ហារចនាសម្ព័ន្ធ ដែលត្រូវដោះស្រាយហើយដលពេលនោះ ដំណោះស្រាយរាល់បញ្ហាដែលបានលើកឡើង ជាពិសេសនៅក្នុងសម័យប្រជុំទី ២ ពីការអភិវឌ្ឍន៍ធនធានមនុស្ស នឹងត្រូវបានដោះស្រាយជ្រះស្រឡះ។ បើមិនធ្វើដូច្នោះទេ ការខិតខំប្រឹងប្រែងរបស់ម្ចាស់ជំនួយ និងវិភាគទាននានារបស់ស្ថាប័នសង្គមស៊ីវិល នឹងគ្រាន់តែជាការព្យាបាលដោយសើរៗប៉ុណ្ណោះ។ វាមិនមែនជាការព្យាបាលពិតប្រាកដ ចំពោះបុព្វហេតុដើមនៃបញ្ហានោះទេ។ របៀបនេះវាអាចប្រៀបបានដូចការផ្តល់ថ្នាំអាស្ពេរីនព្យាបាលអ្នកមានជំងឺមហារីកតែប៉ុណ្ណោះ។

ក្រោយពីធ្វើការវិភាគ និងធ្វើការឥស្សមតិ សង្គមស៊ីវិលបច្ចុប្បន្ននេះត្រូវតែចូលរួមបង្កើតគោលនយោបាយ និងត្រូវខិតខំព្យាយាមជជែកស្តីអំពីបញ្ហាសំខាន់ៗ ដែលទាក់ទិនទៅនឹងស្ថាប័នក្នុងរដ្ឋាភិបាល។

នេះគឺតួនាទីឥស្សមតិនៃសង្គមស៊ីវិល ដែលជួនកាលអាចនាំឱ្យឈានផ្តល់ការចំរូងចំរាស់។ សង្គមស៊ីវិលត្រូវត្រៀមខ្លួន សំរាប់ករណីនេះ ក៏ប៉ុន្តែ ត្រូវជឿជាក់ក្នុងចិត្តថា តែងតែមានផ្លូវឬលំនាំ ដែលអាចនាំឱ្យយើងទៅដល់មន្ត្រីរដ្ឋាភិបាល ដែលជាអ្នកធ្វើគោលនយោបាយ។

ប្រទេសកម្ពុជាបានស្តែងយ៉ាងច្បាស់ហើយថា ត្រូវការអភិបាលកិច្ចល្អដែលមានន័យថា អ្នកដឹកនាំត្រូវមានលក្ខណៈសម្បត្តិដូច លោក សំរ៉ាំង កំសាន្ត បានរ៉ាយរ៉ាប់ពីម្សិលមិញ។ នៅក្នុងន័យ នេះជាដំបូង

គឺការយកចិត្តទុកដាក់ដល់ប្រជាជនទាំងមូល ហើយនិងត្រូវការទទួលខុសត្រូវចំពោះជាតិ។ ជាការខ្មាសអៀនមួយ នៅពេលដែលយើងឃើញថា មានចំនួនទឹកប្រាក់របស់ជំនួយអន្តរជាតិប៉ុន្មាន ហើយបានហូរចូលស្រុកខ្មែរហើយជាការរន្ធត់មួយទៀត នៅពេលដែលយើងបានអានរបាយការណ៍របស់ Global Witness អំពីវិសាលភាពនៃធនធានព្រៃឈើដែលត្រូវបានកាប់រួចហើយដឹងថា ប្រាក់ចំណូលបានមកពីព្រៃឈើទាំងនោះមិនបានត្រូវគេប្រើប្រាស់បានសមស្រប។

ការរិះគន់នេះ មិនមែនបដិសេធការរីកចំរើន នៅក្នុងប្រទេសកម្ពុជាទេ។ យើងមានសេចក្ដីសង្ឃឹមជាច្រើន ប៉ុន្តែខ្ញុំមានអារម្មណ៍ថាផលទុនដាក់បញ្ចូល និងលទ្ធផលទទួលបានមិនមានតុល្យភាពត្រឹមត្រូវ។ នៅមានតម្រូវការដ៏ធំធេងនៅឡើយ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស ក៏ប៉ុន្តែទោះ ជាយ៉ាងណាក្ដីក៏មានអ្នកគិតគូរខ្លាំងក្លារួចហើយ ក្នុងប្រទេសនេះគ្រាន់តែមិនទាន់ស្ថិត ក្នុងជំហរមួយសមស្របឬមួយក៏នៅដាច់ដោយឡែកពីគ្នា។ សង្គមស៊ីវិលមិនអាចផ្ដាច់ចេញពីលំនាំឬគំរូនៃមគ្គុទ្ទេសភាពបែបឋានន្តរក្រមបែបបុរាណ។ គ្រប់អង្គការ NGOs ត្រូវរៀនសូត្រនិងពិសោធន៍នូវអត្ថន័យនៃការចូលរួម និងការធ្វើផែនការបែបចូលរួមផងដែរ។ ខ្ញុំក៏បានអង្កេតឃើញ NGOs រីកដូចផ្សិតដែល" ជាសញ្ញា "ភាគីនិយម" ជាជាងសញ្ញានៃការចែករំលែកឬផ្លាស់ប្ដូរធនធានទាំងធនធានមនុស្ស និងធនធានសម្ភារៈ។ វាហាក់ដូចជាមាននិន្នាការកសាងរាជាណាចក្រតូចៗជាជាងការចូលរួមទាំងអស់គ្នា។ និន្នាការនេះជាការ

គំរាមកំហែងចំពោះកំលាំង និងជាឥទ្ធិពលប្រកបដោយសក្តានុពលគ្រប ដណ្តប់សង្គមស៊ីវិល ដែលជាភ្នាក់ងារសំរាប់ការផ្លាស់ប្តូរនៅក្នុងសង្គម។ បញ្ហាមួយទៀត គឺការផ្តុំគ្នានៃអង្គការ NGOs នៅតែក្នុងទីក្រុងភ្នំពេញ ដូច្នេះ គួរតែមានការសង្កត់ធ្ងន់ នៃស្ថាប័នសង្គមស៊ីវិលនៅតំបន់ជនបទ ដែលជាផ្នែកមួយ ដែលប្រជាជនកម្ពុជាភាគច្រើនរស់នៅដើម្បីផ្តល់វិភាគទានដល់ការធ្វើវិមជ្ឈការ និងអភិបាលល្អនៅតាមមូលដ្ឋាន។

សកលភាវូបនីយកម្ម : ការប្រឈមមុខ និងឱកាសជាច្រើននៃសកលភាវូបនីយកម្ម ទាមទារឱ្យមានរដ្ឋាភិបាលរឹងមាំ ដើម្បីអាចធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវចំពោះប្រទេស ហើយក្នុងករណីនេះវាអាចចាំបាច់ ដើម្បីការពារប្រទេសកម្ពុជា ឥទ្ធិពលអវិជ្ជមានឬការវិនិយោគមិនល្អ។ មានតែរដ្ឋាភិបាលទេ ដែលមានកាតព្វកិច្ចចំពោះគោលការណ៍នៃអភិបាលកិច្ចល្អ និងមានការទទួលការខុសត្រូវចំពោះជាតិ ដែលអាចរៀបចំផែនការ ដោយជោគជ័យក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដោយមិនប៉ះពាល់ដល់ធនធានធម្មជាតិរបស់ខ្លួន ហើយនិងមិនមានបង្កើតភាពក្រីក្របន្ថែម ទៀតដល់ប្រជាជនដោយលុបបំបាត់នូវជីវភាពរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។

សង្គមស៊ីវិល នឹងចូលរួមវិភាគទានដើម្បីការរីកចំរើន និងឿនលឿនក៏ដូចជាយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជានេះ និងការផ្លាស់ប្តូរមុខមាត់ប្រទេសជាតិនេះ ពីភាពក្រីក្រដោយសារតែមានមេដឹកនាំពុករលួយជាច្រើន។ មុខមាត់ថ្មីនេះនឹងអាចនាំឱ្យប្រទេសកម្ពុជា មានមោទនភាព

និងការទទួលស្គាល់ ជាសមាជិកនៃសហគមន៍អន្តរជាតិ ដោយមានកិត្តិយសនឹងមានតម្លៃខ្ពស់។ ធ្វើដូច្នេះ លោក ហ៊ីង ថូរ៉ាក់ស៊ី ពុំចាំបាច់ព្រួយបារម្ភណ៍ ចំពោះផលិតផល ដែលផលិតនៅប្រទេសកម្ពុជា ហើយពិបាករកទីផ្សារទេ។

ជាឧទាហរណ៍ នៅមានគំនិតជាច្រើនដែល និងត្រូវលើកយកពិភាក្សានៅក្នុងប្រទេសកម្ពុជា នាថ្ងៃនេះ គឺនោះជាគំនិតសន្តិសុខមនុស្សហើយ និងទស្សនៈពាក់ព័ន្ធជាច្រើនទៀត។ ទស្សនៈទាំងនេះគួរតែត្រូវលើកកំពស់ផងដែរ។ ដើម្បីធ្វើឱ្យមានសន្តិសុខមនុស្ស និងអនុវត្តសិទ្ធិប្រជាពលរដ្ឋ សង្គមកម្ពុជាត្រូវតែចូលរួមជាមួយស្ថាប័នរដ្ឋាភិបាលតស៊ូដើម្បីនីតិរដ្ឋនូវគ្រប់ជាន់ថ្នាក់ទាំងអស់។ ធ្វើដូច្នេះទាមទារនូវការផ្តល់អំណាចជូនមូលដ្ឋាន ព្រមទាំងធ្វើការកែទម្រង់ច្បាប់ ហើយនឹងការអនុវត្តន៍នូវប្រព័ន្ធតុលាការឯករាជ្យ។

នាងខ្ញុំសូមសម្តែងនូវកត្តញ្ញូតាដ៏ជ្រាលជ្រៅ ចំពោះវាគ្មិនទាំងអស់ ក៏ដូចជាសមាជិក សមាជិកា ដែលបានរួមវិភាគទាន ក្នុងអង្គសន្និសីទជាតិ ដែលនាងខ្ញុំមានជំនឿទុកចិត្តថា ការជជែកពិភាក្សាបែបនេះ ប្រសិនបើ យើងប្រែក្លាយវាឱ្យទៅជាសកម្មភាពវិញនោះនិងផ្តល់វិភាគទាន ចំពោះការផ្លាស់ប្តូរដោយវិជ្ជមាននៅក្នុងសង្គម។

នាងខ្ញុំសូមឧទ្ទិស នូវការពិភាក្សាក្នុងឱកាសនេះឱ្យជិតជាប់ទៅអនាគត ហើយនឹងរីកសាយភាយជាទីភ្នាក់ងារមួយនៅក្នុងសង្គមស៊ីវិលដូចដែល លោកស្រី ជា វណ្ណាត មានប្រសាសន៍ថា មិនមែនមាន

តែអង្គការ NGOs ក្នុងស្រុកនិងក្នុងក្រៅស្រុកទេ ប៉ុន្តែក៏មានសហជីព សមាគម អង្គការជំនួញ ឧទាហរណ៍ សភាពាណិជ្ជកម្មហើយក៏រួមមានគណបក្សនយោបាយផងដែរ។ បើក្រឡេកមើល បញ្ជីរាយនាមអ្នកចូលរួមអង្គសន្និសីទភាគច្រើនគឺមកពីអង្គការ NGOs ឬក៏សកលវិទ្យាល័យ និងគណបក្សនយោបាយផ្សេងៗ ជាពិសេស ខ្ញុំបានឃើញភាគច្រើនមកពីគណបក្ស សម រង្ស៊ី។ ចំពោះការចែករំលែកទស្សនវិស័យការពិភាគបញ្ហា តំណាងទាំងឡាយ និងសមាជិកសភាមកពីគណបក្សទាំងអស់គួរតែមានវត្តមាន៕

## VIII កម្មវិធីនៃកិច្ចពិភាក្សានីមួយៗ

### កិច្ចពិភាក្សាតុមូលលើកទី១ ស្តីពី អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា

ឧបត្ថម្ភ អង្គការ មូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

**ក ម្ម វិ ធី**

៧:៤៥_៨០:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

: សំរបសំរួលដោយ:

: ឯកឧត្តម អ៊ុន ធឹង អនុប្រធានគណៈកម្ម-ការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិនិងពត៌មាននៃរដ្ឋសភាជាតិ សមាជិកគណៈគម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៨:០០_៨:៣០ : មតិផ្តើមបើកការពិភាក្សា

: លោកស្រីបណ្ឌិត Hema Goonatilake តំណាងអង្គការមូលនិធិ ហេនរិច បូល

| | |
|---|---|
| | : លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៣០_៩:០០ | : វាគ្មិនទី១ |
| | : ឯកឧត្តម នៅ កាសុី នាយកវិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស និងជាអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "សញ្ញាណអភិបាលកិច្ចល្អដោយផ្សាភ្ជាប់នៅ នឹងតួនាទីសង្គមស៊ីវិលខ្មែរ" |
| ៩:០០_៩:១០ | : សំរាកពិសារកាហ្វេ |
| ៩:១០_៩:៤០ | : វាគ្មិនទី២ |
| | : លោក Jeffrey A. Kaplan អតីតទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "សញ្ញាណអភិបាលកិច្ចល្អដោយផ្សាភ្ជាប់នៅ នឹងតួនាទីសង្គមស៊ីវិលខ្មែរ" |
| ៩:៤០_១១:៤៥ | : បើកកិច្ចពិភាក្សា |
| ១១:៤៥_១២:០០ | : បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី១ |

## កិច្ចពិភាក្សាតុមូលលើកទី២ *ស្ដីអំពី*
## មគ្គុទ្ទេសភាពនិងភាពទទួលខុសត្រូវនៅក្នុងសង្គមស៊ីវិលកម្ពុជា

ឧបត្ថម្ភដោយ អង្គការមូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំ នៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការនិងសន្តិភាព

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

### ក ម្ម វិ ធី

| | |
|---|---|
| ៧:៤៥_៨:០០ | : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស |
| | : សំរបសំរួលដោយ: |
| | : **លោក កៅ គីមហួន** នាយកប្រតិបត្តិនិងជានាយកគំរោងកម្មវិធី នៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការនិងសន្តិភាព |
| ៨:០០_៨:៣០ | : មតិផ្ដើមបើកការពិភាក្សា |
| | : **លោក សំរាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| | : **លោក កៅ គីមហួន** នាយកប្រតិបត្តិ និងជានាយកគំរោងកម្មវិធីនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការនិងសន្តិភាព |

៨:៣០_៩:៣០ : វាគ្មិនទី១

: ឯកឧត្តមបណ្ឌិត ប៉ែន ដារេត ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអង្គការក្រៅរដ្ឋាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី "មគ្គុទ្ទេសភាពនិងភាពទទួលខុសត្រូវនៅក្នុងសង្គមស៊ីវិលកម្ពុជា: ទស្សនៈរបស់រដ្ឋាភិបាល"

: វាគ្មិនទី២

: លោក ហៀវ វាសនា ប្រធានរដ្ឋបាលមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម "មគ្គុទ្ទេសភាពនិងភាពទទួលខុសត្រូវនៅក្នុងសង្គមស៊ីវិលកម្ពុជា:ទស្សនៈ របស់អង្គការក្រៅរដ្ឋាភិបាល"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី២

## កិច្ចពិភាក្សាតុមូលលើកទី៣ ស្តីអំពី
## ការអភិវឌ្ឍន៍ធនធានមនុស្សនិងការកសាង សមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា : បទពិសោធន៍ខ្មែរ

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិជ បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

## កម្មវិធី

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

: សំរបសំរួលដោយ

: **ឯកឧត្តម អ៊ុន ធឹង អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិនិងពត៌មាននៃរដ្ឋសភាជាតិ សមាជិកគណៈកម្មាធិការនាយក វ.ខ.ស.ស.**

៨:០០_៨:៣០ : មតិផ្តើមបើកការពិភាក្សា

: **លោក សំរ៉ាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

: **លោក កៅ គឹមហួន** នាយកប្រតិបត្តិ និងជានាយកគំរោងកម្មវិធី នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៨:៣០_៩:៣០ : វាគ្មិនទី១

: **លោកស្រី ធីតា ឃឹះ** នាយកប្រតិបត្តិ អង្គការសីលការ(SILAKA) "ការអភិវឌ្ឍន៍

ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា : បទពិសោធន៍ខ្មែរ"

: វាគ្មិនទី២

: លោកស្រី ជូ ប៊ុនអេង អគ្គលេខាធិការនាយកប្រតិបត្តិ សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ "ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពនៅក្នុងសង្គមស៊ីវិលកម្ពុជា : បទពិសោធន៍ខ្មែរ"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៣

## កិច្ចពិភាក្សាតុមូលលើកទី ៤ ស្តីអំពី
## ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

### ក ម្ម វិ ធី

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ

: ឯកឧត្តម ណារិទ្ធ តាន់ អគ្គលេខាធិការ រាជរដ្ឋាភិបាលទីស្តីការគណៈរដ្ឋមន្ត្រីសមាជិកគណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

: មតិផ្តើមបើកការពិភាក្សា

: លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

: លោក កៅ គឹមហួន នាយកប្រតិបត្តិ និងជានាយកគំរោងកម្មវិធី

: នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

៨:៣០_៩:៣០ : វាគ្មិនទី១

: លោក ស្ទើរិន ប៉ក់ នាយកប្រតិបត្តិការ វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស "ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា

: វាគ្មិនទី២

: លោកស្រី ជា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម "ឥទ្ធិពលនៃសកលភាវូបនីយកម្មមកលើសង្គមស៊ីវិលកម្ពុជា"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៤

## កិច្ចពិភាក្សាតុមូលលើកទី ៥ ស្ដីអំពី
## តួនាទីរបស់សង្គមស៊ីវិលកម្ពុជា ក្នុងការពារសន្តិសុខមនុស្ស

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

**ក ម្ម វិ ធី**

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ:

: ឯកឧត្តម ណារី តាន់ អគ្គលេខាធិការរាជរដ្ឋាភិបាល ទីស្ដីការ គណៈរដ្ឋមន្ត្រី សមាជិក គណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

| | | |
|---|---|---|
| | : | មតិផ្ដើមបើកការពិភាក្សា |
| | : | **លោក សំរាំង កំសាន្ត** អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៣០_៩:៣០ | : | វាគ្មិនទី១ |
| | : | **លោក ធន សារាយ** ប្រធានសមាគមកម្ពុជា ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏ (ADHOC) “តួនាទីរបស់សង្គមស៊ីវិលកម្ពុជា លើសន្តិសុខមនុស្ស : ទស្សនៈសង្គមស៊ីវិល” |
| | : | វាគ្មិនទី ២ |
| | : | **ឯកឧត្ដមឧត្ដមសេនីយ៍ទោ ណឹម សុវត្ថិ** អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវានាយក នាយកដ្ឋាននយោបាយ និងផែនការក្រសួងការពារជាតិ អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិ_ការនិងសន្តិភាព "តួនាទីរបស់សង្គមស៊ីវិលកម្ពុជាលើសន្តិសុខមនុស្ស : ទស្សនៈយោធា" |
| ៩:៣០_៩:៤០ | : | សំរាកពិសារកាហ្វេ |

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៥

## កិច្ចពិភាក្សាតុមូលលើកទី ៦ ស្តីអំពី
## គំរោងច្បាប់និងសង្គមស៊ីវិលនៅកម្ពុជា :
## ស្ថានភាពណ៍ ការប្រឈមមុខ និងក្តីសង្ឃឹមនៅអនាគត

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិជ បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

**ក ម្ម វិ ធី**

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ

: ឯកឧត្តម ឱម រ៉ាដ្ឋសាឌី ទីប្រឹក្សាព្រះប្រធានរដ្ឋសភា សមាជិកគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរ សំរាប់សហ_ប្រតិបត្តិការនិងសន្តិភាព

: មតិផ្តើមបើកការពិភាក្សា

: លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធីនិងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

| | | |
|---|---|---|
| ៨:៣០_៩:៣០ | : | វាគ្មិនទី១ |
| | : | ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ "គំរោងច្បាប់និងសង្គមស៊ីវិលនៅកម្ពុជា : ស្ថាន_ការណ៍ ការប្រឈមមុខ និងក្តីសង្ឃឹមនៅអនាគត : ទស្សនៈរដ្ឋាភិបាល" |
| | : | វាគ្មិនទី២ |
| | : | លោក សុក សំអឿន នាយកប្រតិបត្តិក្រុមអ្នកច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប្រចាំនៅកម្ពុជា "គំរោងច្បាប់ និងសង្គមស៊ីវិលនៅកម្ពុជា : ស្ថានការណ៍ ការប្រឈមមុខ និងក្តីសង្ឃឹមនៅអនាគត : ទស្សនៈសង្គមស៊ីវិល" |
| ៩:៣០_៩:៤០ | : | សំរាកពិសារកាហ្វេ |
| ៩:៤០_១១:៤៥ | : | បើកកិច្ចពិភាក្សា |
| ១១_៤៥_១២:០០ | : | បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៦ |

## កិច្ចពិភាក្សាតុមូលលើកទី ៧ ស្តីអំពី
## ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា :
## ការចែករំលែកធនធាន ពត៌មាន បទពិសោធន៍ និងក្តីកង្វល់

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិជ បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

## ក ម្ម វិ ធី

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ

: **ឯកឧត្តម អ៊ឹម សិទ្ធី** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡាសមាជិក គណៈកម្មាធិការនាយក វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

: មតិផ្តើមបើកការពិភាក្សា

: **លោក សំរាំង កំសាន្ត** អ្នកសំរបសំរួល គំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៨:៣០_៩:៣០ : វាគ្មិនទី១

: **លោក ណែប ស៊ិនថៃ** អ្នកសំរបសំរួល ការងារប្រតិបត្តិ ក្រុមការងារដើម្បីកាត់បន្ថយអាវុធនៅកម្ពុជា "ការកសាងបណ្តាញ

សង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធានពត៌មាន បទពិសោធន៍ និងក្តីបារម្ភ"

: វាគ្មិនទី២

: លោកស្រី ប្រុក វ៉ាន់ធី នាយិកាប្រតិបត្តិ អង្គការខេមរា "ការកសាងបណ្តាញសង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែកធនធានពត៌មាន បទពិសោធន៍ និងក្តីកង្វល់"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៧

## កិច្ចពិភាក្សាតុមូលលើកទី ៨ ស្តីអំពី

## តួនាទីនៃតុល្យភាពភេទនៅក្នុងសង្គមស៊ីវិលកម្ពុជា: ប្រភពដើម ស្ថានការណ៍ និង ក្តីសង្ឃឹម

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

<u>ទីកន្លែង</u>: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

### <u>ក ម្ម វិ ធី</u>

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ:

: ឯកឧត្តម ឱម រ៉ាដ្ឋសាឌី ទីប្រឹក្សា ព្រះ-ប្រធានរដ្ឋសភា សមាជិកគណៈកម្មាធិការនាយកវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការនិងសន្តិភាព

: មតិផ្តើមបើកការពិភាក្សា

: លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការ និងសន្តិភាព

៨:៣០-៩:៣០ : វាគ្មិនទី១

: លោកស្រី កុយ វើត ប្រធានអង្គការសម្លេងស្ត្រីខ្មែរ "តួនាទីនៃតុល្យភាពភេទ នៅក្នុងសង្គមស៊ីវិលកម្ពុជា : ប្រភពដើមស្ថាន-ការណ៍ និងក្តីសង្ឃឹម"

: វាគ្មិនទី២

: លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិអង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា "តួនាទីនៃតុល្យភាពភេទ នៅក្នុងសង្គមស៊ីវិលកម្ពុជា ប្រភពដើម ស្ថានការណ៍និងក្តីសង្ឃឹម"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៨

## កិច្ចពិភាក្សាតុមូលលើកទី ៩ ស្តីអំពី
## ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនៅក្នុងសង្គមស៊ីវិលកម្ពុជា: ចំណុចខ្លាំង និងចំណុចខ្សោយ

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិដ បូល (Heinrich Boll Foundation)

ទីកន្លែង: បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

### ក ម្ម វិ ធី

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ:

: **ឯកឧត្តម អ៊ុន នឹង អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងពត៌មាននៃរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយក នៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព**

: មតិផ្តើមបើកការពិភាក្សា

| | |
|---|---|
| | : លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់ អមវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព |
| ៨:៣០_៩:៣០ | : វាគ្មិនទី១ |
| | : លោកស្រី ម៉ាក់ ផារ៉ា ប្រធានសមាគមលើកស្ទួយសិប្បកម្មខ្មែរ "ស.ស.ស.ខ." "ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនៅក្នុងសង្គមស៊ីវិលកម្ពុជា : ចំណុចខ្លាំងនិងចំណុចខ្សោយ" |
| | : វាគ្មិនទី២ |
| | : លោក ពៀម វណ្ណថន នាយកប្រតិបត្តិ អង្គការសិទ្ធិមនុស្សខ្មែរ និងប្រឆាំងអំពើពុករលួយ "ដំណើរការ នៃការធ្វើសេចក្តីសំរេចចិត្តក្នុងសង្គមស៊ីវិលកម្ពុជា : ចំណុចខ្លាំងនិងចំណុចខ្សោយ" |
| ៩:៣០_៩:៤០ | : សំរាកពិសារកាហ្វេ |
| ៩:៤០_១១:៤៥ | : បើកកិច្ចពិភាក្សា |
| ១១_៤៥_១២:០០ | :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី៩ |

# កិច្ចពិភាក្សាតុមូលលើកទី ១០ ស្តីអំពី
# ការកសាងនិរន្តរភាពនៃសង្គមស៊ីវិលនៅកម្ពុជា ៖ បញ្ហាប្រឈមមុខ ក្នុងការប្រមូលផ្តុំធនធាន

ឧបត្ថម្ភដោយអង្គការ មូលនិធិ ហេនរិច បូល (Heinrich Boll Foundation)

ទីកន្លែង៖ បន្ទប់ប្រជុំនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់

## ក ម្ម វិ ធី

៧:៤៥_៨:០០ : ការចុះឈ្មោះនៃភ្ញៀវកិត្តិយស

៨:០០_៨:៣០ : សំរបសំរួលដោយ

: ឯកឧត្តម ឱម រ៉ាដ្ឋសាឌី ទីប្រឹក្សាព្រះប្រធានរដ្ឋសភា សមាជិកគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

: មតិផ្តើមបើកការពិភាក្សា

: លោក សំរាំង កំសាន្ត អ្នកសំរបសំរួលគំរោងកម្មវិធី និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិ-ការនិងសន្តិភាព

៨:៣០_៩:៣០ : វាគ្មិនទី១

: លោក សេក បរិសុទ្ធ នាយកវិទ្យាស្ថានសារគមនាគមន៍កម្ពុជា"ការកសាងនិរន្តរភាពនៃសង្គមស៊ីវិលនៅកម្ពុជា : បញ្ហាប្រឈមមុខក្នុងការប្រមូលផ្តុំធនធាន"

: វាគ្មិនទី២

: លោកស្រី មាស សុខុម អ្នកសំរបសំរួលអង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ "ការកសាងនិរន្តរភាព នៃសង្គមស៊ីវិលនៅកម្ពុជា : បញ្ហាប្រឈមមុខ ក្នុងការប្រមូលផ្តុំធនធាន"

៩:៣០_៩:៤០ : សំរាកពិសារកាហ្វេ

៩:៤០_១១:៤៥ : បើកកិច្ចពិភាក្សា

១១_៤៥_១២:០០ :បូកសរុបលទ្ធផលកិច្ចពិភាក្សាតុមូលលើកទី១០

**សន្និសីទជាតិស្តីពី**

**ការកសាងសង្គមស៊ីវិល ដើម្បីអភិបាលកិច្ចល្អនៅកម្ពុជា :**

**សមិទ្ធិផល ការប្រឈមមុខ និង ទស្សនវិស័យទៅអនាគត**

វិមានរាជរដ្ឋាភិបាល ថ្ងៃទី ៤_៥ ខែធ្នូ ឆ្នាំ ២០០០ ភ្នំពេញ

រៀបចំឡើយដោយ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

ដោយសហប្រតិបត្តិការជាមួយមូលនីធិ ហេនរិច បូល

## ក ម្ម វិ ធី

**ថ្ងៃទីមួយ ថ្ងៃច័ន្ទ ទី ៤ ខែធ្នូ ឆ្នាំ ២០០០**

០៨:៣០_០៩:០០ : ការចុះវត្តមាន

៩:០០_១០:៣០ : ពិធីបើកសម័យប្រជុំ

: សុន្ទរកថាស្វាគមន៍ ថ្លែងដោយ ឯកឧត្តម ឱម រ៉ាវឌ្ឍសាឌី ទីប្រឹក្សា ព្រះប្រធានរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយក វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

: សុន្ទរកថាថ្លែងដោយ បណ្ឌិត Heike Löschmann ប្រធានប្រចាំតំបន់អាស៊ីអគ្នេយ៍នៃមូលនិធិ ហេនរិជ បូល

: សុន្ទរកថាសំខាន់ ស្តីពី "តួនាទីនៃសង្គមស៊ីវិល ក្នុងការធ្វើអោយប្រសើរឡើងនូវអភិ_បាលកិច្ចល្អនៅកម្ពុជា" ថ្លែងដោយ ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ ប្រធានគណៈកម្មាធិការនាយកវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាពនិងជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

១០:៣០_១០:៤៥ : **សំរាកទទួលភេសជ្ជៈ**

១០:៤៥_១២:០០ : **សម័យប្រជុំទី១**

: របាយការណ៍អំពីកម្រងនាទីពិភាក្សា ស្តីអំពី "អភិបាលកិច្ចល្អនិងសង្គមស៊ីវិលនៅកម្ពុជា និងសេចក្តីសង្ខេបលទ្ធផលនៃការស្រាវជ្រាវអំពីសង្គមស៊ីវិលនៅកម្ពុជា"

: **ប្រធាន**

: ឯកឧត្តម ឱម រ៉ាវុឌ្ឍសាឌី ទីប្រឹក្សាព្រះប្រធានរដ្ឋសភាជាតិ និងជាសមាជិកគណៈកម្មាធិការនាយកនៃវិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព

: **<u>គណៈវាគ្មិន</u>**

: បណ្ឌិត កៅ គីមហួន នាយកប្រតិបត្តិវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិ និងសន្តិភាព

: លោក សំរាំង កំសាន្ត អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិ-បត្តិការនិងសន្តិភាព

: លោក ហៀក ព្រីង អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព

១២:០០_១៤:០០ : **សំរាកទទួលភោជនាហារ**

១៤:០០_១៦:០០ : **សម័យប្រជុំទី២**

: ការអភិវឌ្ឍន៍ធនធានមនុស្ស និងការកសាងសមត្ថភាពសង្គមស៊ីវិលកម្ពុជា: សមិទ្ធផល និងការប្រឈមមុខ

: **ប្រធាន**

: ឯកឧត្តមបណ្ឌិត ឆយ យីហាំង ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការអប់រំ នាយកដេប៉ាតឺម៉ង់ ទស្សនវិជ្ជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ក្រុមការងារ រាជបណ្ឌិតសភាកម្ពុជា អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

: **គណៈអាធិបតី**

: លោកស្រី ហោ ផល្លី ប្រធានអង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ

: លោកបណ្ឌិត ហង់ន សាហ៊ីប នាយក វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុអ្នកស្រាវជ្រាវអមនៃ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិង សន្តិភាព

: លោកស្រី ផា មុយគ្រី នាយិកា កម្មវិធី អភិវឌ្ឍន៍ធនធានយុវជន

: **ពិភាក្សាពេញអង្គ**

១៥:៤៥_១៦:០០ : **សំរាកទទួលភេសជ្ជៈ**

១៦:០០_១៨:០០ : **សម័យប្រជុំទី៣**

: ការកសាង និងលើកស្ទួយបណ្ដាញការងារ សង្គមស៊ីវិលនៅកម្ពុជា : ការចែករំលែក ធនធានពត៌មាន បទពិសោធន៍និងក្ដីកង្វល់

: <u>ប្រធាន</u>

: បណ្ឌិត កៅ គីមហួន នាយកប្រតិបត្តិ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព

: <u>គណៈវាគ្មិន</u>

: លោកស្រី ប្រុក វ៉ាន្នី ប្រធានអង្គការ_ ខេមរា

: លោកស្រី ជូ ប៊ុនអេង អគ្គលេខាធិការនាយកប្រតិបត្តិ អង្គការស្ត្រីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍

: លោកបណ្ឌិត ហង្ស ពុទ្ធា ប្រធានសមាគមមិត្តសិល្បៈនិងជានាយកប្រតិបត្តិគណៈកម្មាធិការអព្យាក្រឹត យុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរីនៅកម្ពុជា

: ពិភាក្សាពេញអង្គ

**ថ្ងៃទីពីរ ថ្ងៃអង្គារ ទី ៥ ខែធ្នូ ឆ្នាំ ២០០០**

០៨:០០_១០:០០ : **សម័យប្រជុំទី ៤**

: សកលភាវូបនីយកម្ម និងផលប៉ះពាល់មកលើសង្គមស៊ីវិលកម្ពុជា : ការគ្រងគ្រប់តម្លៃចាយវាយនិងទាញយកផលប្រយោជន៍ឱ្យបានអតិបរិមា

: **ប្រធាន**

: លោក ស្ទីវិន ម៉ាក់ នាយកប្រតិបត្តិ វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស

: គណៈវាគ្មិន

: ឯកឧត្តមបណ្ឌិត ឆយ យីហាង ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា នាយក ដេប៉ាតឺម៉ង់ទស្សនវិជ្ជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ក្រុមការងារ រាជបណ្ឌិតសភាកម្ពុជា អ្នកស្រាវជ្រាវជាន់ខ្ពស់អមវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

: លោកបណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី ប្រធាននាយកដ្ឋានត្រួតពិនិត្យគំរោងគណៈកម្មការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

: លោក ញ៉ែម វណ្ណថន នាយកប្រតិបត្តិអង្គការសិទ្ធិមនុស្សខ្មែរ និងប្រឆាំងអំពើពុករលួយ

: **ពិភាក្សាពេញអង្គ**

១០:០០_១០:១៥ : **សំរាកទទួលភេសជ្ជៈ**

១០:១៥_១២:១៥ : **សម័យប្រជុំទី ៥**

: មុខនាទីសង្គមស៊ីវិលកម្ពុជា : លើសន្តិសុខមនុស្សបញ្ហា និងសេចក្តីសង្ឃឹម

: **<u>ប្រធាន</u>**

: លោក សំរាំង កំសាន្ត អ្នកស្រាវជ្រាវជាន់ខ្ពស់អមរិទ្យាស្ថាន ខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព

: <u>គណៈវាគ្មិន</u>

: ឯកឧត្តមឧត្តមសេនីយ៍ទោ ណឹម សុវត្ថិ អគ្គនាយករង អគ្គនាយកដ្ឋាន យោធសេវា នាយ នាយកដ្ឋាននយោបាយនិងផែនការ ក្រសួងការពារជាតិ អ្នកស្រាវជ្រាវជាន់ខ្ពស់អមរិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

: ឯកឧត្តមបណ្ឌិត ប៉ែន ដារេត ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល

: លោកស្រី ផា វណ្ណាត ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

១២:១៥_១៤:០០ : **សំរាកទទួលភោជនាហារ**

១៤:០០_១៦:០០ : **សម័យប្រជុំទី ៦**

: សង្គមស៊ីវិល និង គំរោងច្បាប់នៅកម្ពុជា: ការប្រឈមមុខ និងទិសដៅអនាគត

: **<u>ប្រធាន</u>**

: ឯកឧត្តមបណ្ឌិត ប៉ែន ដារេត ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល

: <u>គណៈវាគ្មិន</u>

: ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

: លោក សុក សំអឿន នាយកប្រតិបត្តិការក្រុមអ្នកច្បាប់សិទ្ធិមនុស្ស អន្តរជាតិប្រចាំកម្ពុជា

: លោក ញ៉ឹក សារិន នាយកប្រតិបត្តិអង្គការស្តារកម្ពុជា

: ពិភាក្សាពិពេញអង្គ

១៦:០០-១៦:១៥ : សំរាកទទួលភេសជ្ជៈ

១៦:១៥-១៧:១៥ : ពិធីបិទសម័យប្រជុំ

: <u>ប្រធាន</u>

: ស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍ ព្រះប្រធានគណៈកម្មាធិការនាយក វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាពនិងជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រកម្ពុជា

: សុន្ទរកថាសំខាន់ ស្តីពី "អភិបាលកិច្ចល្អនៅកម្ពុជា : តើតួនាទីសង្គមស៊ីវិលអាចបំពេញមុខនាទីអ្វីខ្លះ? ថ្លែងដោយ លោក **Bonaventure Mbida Essama** ប្រធានការិយាល័យបេសកកម្ម នៃធនាគារពិភពលោក ភ្នំពេញ

: មតិចុងក្រោយ ស្តីអំពី "អភិបាលកិច្ចល្អនៅកម្ពុជា : តើតួនាទីសង្គមស៊ីវិលអាចបំពេញមុខនាទីអ្វីខ្លះ" ថ្លែងដោយ បណ្ឌិត **Heike Löschmann** ប្រធានប្រចាំតំបន់អាស៊ីអគ្នេយ៍នៃមូលនិធិ ហេនរិជ បូល

ម៉ោង១៧:១៥ : **ចប់សន្និសីទ**